ព្រះរាជក្រម

នស/រកម/១២០៧/០៣០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ក្រមរដ្ឋប្បវេណី

ROYAUME du CAMBODGE • LE MINISTRE du PALAIS ROYAL •

គន្ថីទី ១

បទប្បញ្ញត្តិទូទៅ

ជំពូកទោល

បទប្បញ្ញត្តិទូទៅ

មាត្រា ១.- ច្បាប់ទូទៅនៃនីតិឯកជន

ក្រមនេះ បញ្ញត្តអំពីគោលការណ៍ទូទៅដែលទាក់ទងទៅនឹងទំនាក់ទំនងគតិយុត្តផ្នែករដ្ឋប្បវេណី ។ បញ្ញត្តិនៃក្រមរដ្ឋប្បវេណីនេះ ត្រូវយកមកអនុវត្ត ចំពោះទំនាក់ទំនងទ្រព្យសម្បត្តិ និង ទំនាក់ទំនងញាតិ លើកលែងតែមានកំណត់ផ្សេង នៅក្នុងច្បាប់ពិសេស ។

មាត្រា ២.- គោលការណ៍ជាមូលដ្ឋាន

ក្រមនេះ កំណត់អំពីគោលការណ៍នៃការធានាសេចក្តីថ្លៃថ្នូររបស់បុគ្គល ភាពស្មើគ្នារបស់បុរស នារី និង សិទ្ធិលើទ្រព្យសម្បត្តិ ដែលត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ។

មាត្រា ៣.- គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន

ក្រមនេះ គោរពនូវសេរីភាពនៃឆន្ទៈរបស់បុគ្គល និង បញ្ញត្តអំពីទំនាក់ទំនងគតិយុត្តប្រកបដោយសមភាពរវាងបុគ្គលឯកជន ដោយរួមបញ្ចូលទាំងនីតិបុគ្គល ។ នីតិបុគ្គល សាធារណៈ ដែលនៅក្នុងទំនាក់ទំនងនៃការជួញដូរ ត្រូវចាត់ទុកថាជាបុគ្គលឯកជន ។

មាត្រា ៤.- ការហាមឃាត់មិនឱ្យប្រើប្រាស់សិទ្ធិដោយបំពាន

ទោះបីជាសិទ្ធិក៏ដោយ ក៏ពុំត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ដោយបំពានឡើយ ។ នៅក្នុងករណីដែលបានប្រើប្រាស់សិទ្ធិ ដោយបំពានហួសពីទំហំនៃការការពារ ដែលត្រូវបានបញ្ញត្តទុក មិនអាចទទួលស្គាល់អានុភាពនៃការប្រើសិទ្ធិនោះឡើយ ។

មាត្រា ៥.- គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់

ការប្រើសិទ្ធិ និង ការអនុវត្តករណីយកិច្ច ត្រូវធ្វើឡើងដោយសុចរិត ផ្អែកតាមភាពស្មោះ

ROYAUME DU CAMBODGE · LE MINISTÈRE DU PALAIS ROYAL

គន្ថីទី ២

បុគ្គល

ជំពូកទី ១

រូបវន្តបុគ្គល

ផ្នែកទី ១

សមត្ថភាពទទួលសិទ្ធិ

មាត្រា ៦.- គោលការណ៍សមភាពនៃសមត្ថភាពទទួលសិទ្ធិ

រូបវន្តបុគ្គលគ្រប់រូប មានលក្ខណសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ចបាន ។

មាត្រា ៧.- ការកម្រិតក្នុងការទទួលសិទ្ធិចំពោះជនបរទេស

ជនជាតិបរទេស មិនអាចទទួលបាន ឬ កាន់កាប់នូវសិទ្ធិមួយចំនួនដែលត្រូវបានកំណត់ឡើយ ក្នុងករណីដែលមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ជាតិ ឬ សន្ធិសញ្ញា ឬ អនុសញ្ញាអន្តរជាតិ ។

មាត្រា ៨.- ពេលចាប់ផ្តើម និង បញ្ចប់សមត្ថភាពទទួលសិទ្ធិ

រូបវន្តបុគ្គលម្នាក់ៗ មានសមត្ថភាពទទួលសិទ្ធិនៅពេលចាប់កំណើត ហើយបាត់បង់អស់នូវសមត្ថភាពទទួលសិទ្ធិនេះ នៅពេលទទួលមរណភាព ។

មាត្រា ៩.- ទារកនៅក្នុងគភ៌

១-ទារកដែលនៅក្នុងគភ៌នាពេលមានអំពើអនីត្យានុកូល បើទារកនេះមានកំណើតនៅពេលក្រោយ អាចទាមទារនូវសំណងនៃការខូចខាតដែលបានកើតឡើងពេលដែលខ្លួន នៅក្នុងគភ៌ ដោយអំពើអនីត្យានុកូលនោះបាន ។

២-ទារកដែលនៅក្នុងគភ៌នាពេលដែលចាប់ផ្តើមសន្តតិកម្ម បើទារកនោះមានកំណើតនៅពេលក្រោយ អាចទទួលមត៌ក ដោយសន្តតិកម្មនោះបាន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៣-ទារកដែលនៅក្នុងគភ៌នាពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព បើទារកនោះមានកំណើតនៅពេលក្រោយ អាចទទួលនូវអានុភាពនៃបណ្តាំនោះបាន ។

ផ្នែកទី ២

សិទ្ធិបុគ្គល

មាត្រា ១០.- អត្ថន័យនៃសិទ្ធិបុគ្គល

សិទ្ធិបុគ្គល សំដៅទៅលើសិទ្ធិដែលមានអត្ថន័យពាក់ព័ន្ធនឹងជីវិតរូបកាយ សុខភាព សេរីភាព នាម កិត្តិយស ភាពឯកជន ឬ សិទ្ធិផ្សេងទៀតដែលជាផលប្រយោជន៍ទាក់ទងនឹងលក្ខណបុគ្គល ។

មាត្រា ១១.- សិទ្ធិទាមទារឱ្យបញ្ឈប់

ប្រសិនបើមានការបារម្ភថា នឹងអាចមានការរំលោភសិទ្ធិបុគ្គលដោយខុសច្បាប់ ឬ មានការបារម្ភថា ការរំលោភសិទ្ធិបុគ្គលដែលបានកើតឡើងហើយនោះ នឹងអាចបន្ត ឬនឹងអាចកើតឡើងទៀតដោយខុសច្បាប់ អ្នកដែលមានសិទ្ធិបុគ្គលអាចទាមទារឱ្យបញ្ឈប់នូវការរំលោភនោះបាន ។

មាត្រា ១២.- សិទ្ធិទាមទារឱ្យដកចេញនូវលទ្ធផលនៃសកម្មភាពរំលោភ

បើស្ថានភាពរំលោភសិទ្ធិបុគ្គលនៅតែមានជាបន្តបន្ទាប់ ដោយសារសំណល់នៃលទ្ធផលដែលកើតពីសកម្មភាពរំលោភនោះ អ្នកដែលបានទទួលរងនូវការរំលោភសិទ្ធិបុគ្គលដោយខុសច្បាប់នោះ អាចទាមទារឱ្យដកចេញនូវលទ្ធផលនៃសកម្មភាពរំលោភនោះបាន លុះត្រាតែលទ្ធផលនោះអាចដកចេញបាន ។

មាត្រា ១៣.- សិទ្ធិទាមទារសំណងការខូចខាត

បញ្ញត្តិនៃមាត្រា ១១ (សិទ្ធិទាមទារឱ្យបញ្ឈប់) និងមាត្រា ១២ (សិទ្ធិទាមទារឱ្យដកចេញនូវលទ្ធផលនៃសកម្មភាពរំលោភ) នៃក្រមនេះ មិនរារាំងការទាមទារសំណងការខូចខាតដោយអ្នក

ROYAUME DU CAMBODGE
LE MINISTRE DE ...

ដែលបានទទួលរងនូវការរំលោភផលប្រយោជន៍ទាក់ទងនឹងលក្ខណបុគ្គលនោះ ដោយយោងទៅតាមបញ្ញត្តិស្តីពីអំពើអនីត្យានុកូលបានឡើយ ។

ផ្នែកទី ៣

សមត្ថភាពខាងឆន្ទៈ

មាត្រា ១៤.- ការខ្វះសមត្ថភាពខាងឆន្ទៈ

សកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន អាចលុបចោលបាន ។

មាត្រា ១៥.- និយមន័យនៃសកម្មភាព

ពាក្យ "សកម្មភាព" ដែលត្រូវបានប្រើនៅក្នុងផ្នែកទី ៣(សមត្ថភាពខាងឆន្ទៈ) ផ្នែកទី ៤ (សមត្ថភាពក្នុងការធ្វើសកម្មភាព) និងផ្នែកទី ៦(ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន និងការប្រកាសអំពីការបាត់ខ្លួន) នៃជំពូកទី ១ នេះ សំដៅទៅលើកិច្ចសន្យា និងសកម្មភាពឯកតោភាគី ។

ផ្នែកទី ៤

សមត្ថភាពក្នុងការធ្វើសកម្មភាព

មាត្រា ១៦.- អត្ថន័យនៃជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព

ជនដែលត្រូវបានកម្រិតសមត្ថភាព សំដៅទៅលើអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភ ។

កថាភាគទី ១

អនីតិជន

មាត្រា ១៧.- អត្ថន័យនៃអនីតិជន

អនីតិជន សំដៅទៅលើជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

មាត្រា ១៨.- សិទ្ធិលុបចោលសកម្មភាព

សកម្មភាពដែលអនីតិជនបានធ្វើដោយមិនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចលុបចោលបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះសកម្មភាពដែលទទួលសិទ្ធិ ឬ ឱ្យរួចផុតពីកាតព្វកិច្ច ឬ សកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ។

មាត្រា ១៩.- ការចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអនុញ្ញាតឱ្យចាត់ចែង

អនីតិជនអាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែង ដោយកំណត់គោលបំណង ក្នុងទំហំនៃគោលបំណងនេះបាន ។ម្យ៉ាងទៀត អនីតិជនក៏អាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែង ដោយមិនបានកំណត់គោលបំណងបានដែរ ។

មាត្រា ២០.- អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម

១-អនីតិជនដែលបានទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្មមួយប្រភេទ ឬ ច្រើនប្រភេទពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានសមត្ថភាពដូចនីតិជនចំពោះមុខជំនួញនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើបានដឹងច្បាស់ថា អនីតិជននោះមិនអាចបំពេញកិច្ចការអាជីវកម្មនោះបាន អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចលុបចោល ឬ កម្រិតនូវការអនុញ្ញាតនៃការប្រកបអាជីវកម្មនោះបាន ។

មាត្រា ២១.- លំនួខ័ណ្ឌនៃអគ្គាធិនភាព

១-ក្នុងករណីដែលអនីតិជនដែលបានដល់អាយុ ១៦ (ដប់ប្រាំមួយ) ឆ្នាំ ទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ តុលាការអាចប្រកាសនូវអគ្គាធិនភាពរបស់អ្នកនោះបាន តាមពាក្យសុំ

របស់អនីតិជននោះ ប្រសិនបើតុលាការយល់ឃើញថា អត្តាធីនភាពស្របនឹងផលប្រយោជន៍របស់អនីតិជននោះ ។ ក្នុងករណីនេះ តុលាការត្រូវសួរយោបល់ពីអ្នកមានសិទ្ធិអំណាចមេបា ។

២-អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលអត្តាធីនភាព ដោយមិនចាំបាច់មានការប្រកាសពីតុលាការទេ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ទោះបីភាគីលែងលះគ្នាក៏ដោយ ក៏អានុភាពនៃអត្តាធីនភាព មិនត្រូវរលត់ឡើយ ។

មាត្រា ២២.- អានុភាពនៃអត្តាធីនភាព

អនីតិជនដែលទទួលអត្តាធីនភាព ត្រូវបានចាត់ទុកថា បានដល់នីតិភាព ។

មាត្រា ២៣.- កិច្ចសន្យាការងាររបស់អនីតិជន

១-ទោះបីជាមានបញ្ញត្តិនៃមាត្រា ១០៥៣(ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង) និង មាត្រា ១០៨០(ការគ្រប់គ្រងទ្រព្យសម្បត្តិ និងការតំណាង) នៃក្រមនេះ ក៏ដោយ ក៏អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន មិនអាច ធ្វើកិច្ចសន្យាការងារជំនួសអនីតិជនបានដែរ ។

២-កិច្ចសន្យាដែលផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនមានអានុភាពចំពោះសាមីអនីតិជនឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះករណីដែលសាមីអនីតិជនផ្តល់សច្ចានុមតិលើកិច្ចសន្យានោះ ។

៣-ក្នុងករណីដែលយល់ឃើញថា កិច្ចសន្យាការងាររបស់អនីតិជនអាចធ្វើឱ្យខូចផលប្រយោជន៍ដល់អនីតិជននោះ អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាល សម្រាប់អនីតិជន ឬ ស្ថាប័នរដ្ឋបាល អាចរំលាយកិច្ចសន្យានោះ ឆ្ពោះទៅអនាគតបាន ។

កថាភាគទី ២

ជននៅក្រោមអាណាព្យាបាលទូទៅ

មាត្រា ២៤.- ការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ

១-ចំពោះជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង

និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី តុលាការអាចប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅបាន តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល សម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសាមីខ្លួនមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ នៅពេលដែលមានពាក្យសុំ ។

២-ក្នុងករណីដែលធ្វើការប្រកាសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ នេះ បើសាមីខ្លួនជាជននៅក្រោមហិតូបត្ថម្ភ តុលាការត្រូវលុបចោលការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភចំពោះជននោះ ។

មាត្រា ២៥.- អត្ថន័យនៃជននៅក្រោមអាណាព្យាបាលទូទៅ និង ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ

ជនដែលបានទទួលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ត្រូវហៅថាជននៅក្រោមអាណាព្យាបាលទូទៅ ហើយត្រូវស្ថិតនៅក្រោមអ្នកអាណាព្យាបាលទូទៅ ។

មាត្រា ២៦.- សិទ្ធិលុបចោលសកម្មភាព

សកម្មភាពរបស់ជននៅក្រោមអាណាព្យាបាលទូទៅ អាចលុបចោលបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ។

មាត្រា ២៧.- ការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ

បើមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ២៤ (ការប្រកាសការចាប់ផ្តើម អាណាព្យាបាលទូទៅ) នៃក្រមនេះ បានរលាយ តុលាការត្រូវលុបចោលនូវការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅ ក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។

កថាភាគទី ៣

ជននៅក្រោមហិតូបត្ថម្ភ

មាត្រា ២៨.- ការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ

១-ចំពោះជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និង វិនិច្ឆ័យ អំពីលទ្ធ-ផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី តុលាការអាចប្រកាសការចាប់ផ្តើមហិតូបត្ថម្ភលើជននោះបាន តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នក អាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។

២-ក្នុងករណីដែលធ្វើការប្រកាសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ នេះ បើសាមីខ្លួនជាជននៅក្រោមអាណាព្យាបាលទូទៅ តុលាការត្រូវលុបចោលការ ប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅចំពោះជននោះ ។

មាត្រា ២៩.- អត្ថន័យនៃជននៅក្រោមហិតូបត្ថម្ភ និង ការជ្រើសតាំងហិតូបត្ថម្ភកៈ

ជនដែលបានទទួលការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ ត្រូវហៅថា ជននៅក្រោមហិតូប-ត្ថម្ភ ហើយត្រូវស្ថិតនៅក្រោមការថែរក្សាដោយហិតូបត្ថម្ភកៈ ។

មាត្រា ៣០.- សិទ្ធិលុបចោលសកម្មភាព

លើកលែងតែសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ សកម្មភាពដែលបានធ្វើឡើងដោយជននៅក្រោមហិតូបត្ថម្ភ ដោយគ្មានការយល់ព្រមពីហិតូបត្ថម្ភកៈដូចខាងក្រោមនេះ អាចលុបចោលបាន ៖

ក-ការទទួល ឬ ការប្រើប្រាស់ទុន ។

ខ-ការខ្ចីទ្រព្យ ឬ ការធានា ។

គ-ការធ្វើសកម្មភាពដែលមានគោលបំណងទទួលបាន ឬ ធ្វើឱ្យបាត់បង់សិទ្ធិ ដែលទាក់ទងនឹងអចលនវត្ថុ ឬ ទ្រព្យសម្បត្តិដែលមានសារៈសំខាន់ផ្សេងទៀត ។

ឃ-ការធ្វើសកម្មភាពបណ្តឹង ។

ង-ការធ្វើប្រទានកម្ម ឬ ធ្វើកិច្ចសន្យាសម្រុះសម្រួល ឬ កិច្ចសន្យាមជ្ឈត្តកម្ម ។

ច-ការទទួលស្គាល់នូវសន្តតិកម្ម ឬ ការបោះបង់ចោលនូវសិទ្ធិសន្តតិកម្ម ឬ ការបែងចែកនូវមរតក ។

ឆ-ការប្រកែកមិនទទួលប្រទានកម្ម ឬ អច្ច័យទាន ឬ ការយល់ព្រមទទួលនូវប្រទានកម្ម ឬ អច្ច័យទានដែលភ្ជាប់នឹងបន្ទុក ។

ជ-ការសាងសង់សំណង់ថ្មី ការសង់ឡើងវិញ ការសង់បន្ថែម ឬ ការជួសជុលធំ ។

ឈ-ការធ្វើភតិសន្យា ដែលមានអំឡុងពេលលើសពី ៣ (បី) ឆ្នាំ ចំពោះដីធ្លី លើសពី ២ (ពីរ) ឆ្នាំ ចំពោះអគារ លើសពី ៦ (ប្រាំមួយ) ខែ ចំពោះចលនវត្ថុ ។

ញ-សកម្មភាពដែលតុលាការបានប្រកាសជាពិសេសថា ចាំបាច់ត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈ តាមពាក្យសុំរបស់ជនដែលបានរៀបរាប់នៅក្នុងមាត្រា ២៨ (ការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ) នៃក្រមនេះ ឬ ហិតូបត្ថម្ភកៈ ឬ អ្នកត្រួតពិនិត្យ ហិតូបត្ថម្ភកៈ ។

មាត្រា ៣១.- ការលុបចោលការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ

បើមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ២៨ (ការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ) នៃក្រមនេះបានរលាយ តុលាការត្រូវលុបចោលនូវការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។

កថាភាគទី ៤

ការការពារភាគីម្ខាងទៀតនៃជនដែលត្រូវបានកម្រិតសមត្ថភាព

មាត្រា ៣២.- សិទ្ធិដាស់តឿន

១-ភាគីម្ខាងទៀតនៃជនដែលត្រូវបានកម្រិតសមត្ថភាព អាចដាស់តឿនឱ្យជននោះ ឆ្លើយថាផ្តល់ ឬ មិនផ្តល់សច្ចានុមតិ លើសកម្មភាពដែលជននោះអាចលុបចោលបាន ក្នុងអំឡុងពេលលើសពី ១ (មួយ) ខែ ក្រោយពេលជននោះបានក្លាយជាសមត្ថជនវិញ ។ ប្រសិនបើជន

ដែលត្រូវបានកម្រិតសមត្ថភាពដែលបានក្លាយជាសមត្ថជនវិញនោះ មិនឆ្លើយតបក្នុងអំឡុងពេលដែលបានកំណត់ទេ ត្រូវចាត់ទុកថា ជននោះផ្តល់សច្ចានុមតិលើសកម្មភាពនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលភាគីម្ខាងទៀតបានដាស់តឿន ដូចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើទៅអ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឬ ហិតូបត្ថម្ភកៈ អំពីសកម្មភាពដែលស្ថិតនៅក្នុងទំហំនៃសិទ្ធិរបស់ខ្លួន នៅពេលដែលជនដែលត្រូវបានកម្រិតសមត្ថភាព មិនទាន់ក្លាយជាសមត្ថជន តែអ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឬ ហិតូបត្ថម្ភកៈ មិនឆ្លើយតបក្នុងអំឡុងពេលដែលបានកំណត់ទេ ។

៣-ភាគីម្ខាងទៀតអាចដាស់តឿនឱ្យជននៅក្រោមហិតូបត្ថម្ភទទួលយកសច្ចានុមតិពីហិតូបត្ថម្ភកៈ ក្នុងអំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។ ប្រសិនបើជននៅក្រោមហិតូបត្ថម្ភ មិនបានជូនដំណឹងថា ខ្លួនបានទទួលសច្ចានុមតិក្នុងអំឡុង ពេលនោះទេ ត្រូវចាត់ទុកថា ជននោះបានលុបចោលសកម្មភាពនោះ ។

មាត្រា ៣៣.- ការឆបោករបស់ជនដែលត្រូវបានកម្រិតសមត្ថភាព

ប្រសិនបើជនដែលត្រូវបានកម្រិតសមត្ថភាព បានប្រើប្រាស់មធ្យោបាយឆបោក ដើម្បីឱ្យគេជឿជាក់ថា ខ្លួនជាសមត្ថជន ជននោះមិនអាចលុបចោលសកម្មភាពបានទេ ។

ផ្នែកទី ៥

លំនៅឋាន

មាត្រា ៣៤.- អត្ថន័យនៃលំនៅឋាន

កន្លែងដែលជាទីតាំងនៃជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ ត្រូវយកធ្វើជាលំនៅឋាន ។

មាត្រា ៣៥.- ទីសំណាក់

ក្នុងករណីដែលកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅមិនច្បាស់លាស់ទេ ទីសំណាក់ត្រូវបានចាត់ទុកថាជាលំនៅឋាន ។

មាត្រា ៣៦.- ករណីដែលគ្មានលំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា

ចំពោះបុគ្គលដែលគ្មានលំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ទោះបីជាបុគ្គលនោះជាជនជាតិខ្មែរក៏ដោយ ជាជនជាតិបរទេសក៏ដោយ ទីសំណាក់របស់បុគ្គលនោះនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានចាត់ទុកថាជាលំនៅឋាន ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវអនុវត្តឡើយ ចំពោះករណីដែលច្បាប់នៃលំនៅឋានត្រូវបានយកមកអនុវត្ត ។

ផ្នែកទី ៦

ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន និងការប្រកាសអំពីការបាត់ខ្លួន

កថាភាគទី ១

ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន

មាត្រា ៣៧.- ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយតុលាការ

ក្នុងករណីដែលបុគ្គលណាម្នាក់ដែលបានចេញពីលំនៅឋាន ឬ ទីសំណាក់ ហើយដែលគ្មានលទ្ធភាពនឹងត្រឡប់មកវិញដោយងាយស្រួលនោះ មិនបានចាត់តាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនទេ តុលាការអាចជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ឬ បង្គាប់ ចាត់ចែងជាចាំបាច់ដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិនោះបាន តាមពាក្យសុំរបស់បុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ មេឃុំ ឬ ចៅសង្កាត់ដែលលំនៅឋានជននោះស្ថិតនៅ ឬ តំណាងអយ្យការ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលសិទ្ធិរបស់អ្នកគ្រប់គ្រងត្រូវបានរលត់នៅក្នុងរយៈពេលដែលសាមីខ្លួនអវត្តមាន ។

មាត្រា ៣៨.- ការលុបចោលការបង្គាប់ឱ្យគ្រប់គ្រងទ្រព្យសម្បត្តិ

ក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ៣៧ (ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយតុលាការ) នៃក្រមនេះ ប្រសិនបើក្រោយមក បុគ្គលដែលអវត្តមានបានចាត់តាំងអ្នកគ្រប់គ្រង តុលាការអាចលុបចោលនូវការបង្គាប់ តាមពាក្យសុំរបស់អ្នកគ្រប់គ្រង អ្នកដែលមានផលប្រយោជន៍ មេឃុំ ឬ ចៅសង្កាត់ដែលលំនៅឋានជននោះស្ថិតនៅ ឬ តំណាងអយ្យការ ។

មាត្រា ៣៩.- ការផ្លាស់ប្តូរអ្នកគ្រប់គ្រង

ក្នុងករណីដែលបុគ្គលអវត្តមាន បានចាត់តាំងអ្នកគ្រប់គ្រង ប្រសិនបើពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននោះនៅរស់ ឬ ទទួលមរណភាពទេ តុលាការអាចផ្លាស់ប្តូរអ្នកគ្រប់គ្រងបាន តាមពាក្យសុំរបស់អ្នកដែលមានផលប្រយោជន៍ មេឃុំ ឬ ចៅសង្កាត់ ដែលលំនៅឋានជននោះស្ថិតនៅ ឬ តំណាងអយ្យការ ។

មាត្រា ៤០.- សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ជាអាទិ៍

១-អ្នកគ្រប់គ្រងដែលបានជ្រើសតាំងមានសិទ្ធិធ្វើសកម្មភាពដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ មាត្រា ៣៦៦ (ទំហំនៃសិទ្ធិតំណាង) នៃក្រមនេះ ។ ប្រសិនបើចាំបាច់ ត្រូវធ្វើសកម្មភាពផ្សេងទៀត អ្នកគ្រប់គ្រងនោះអាចធ្វើបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

២-ក្នុងករណីដែលពុំមានដំណឹងច្បាស់លាស់ថា បុគ្គលអវត្តមាននៅរស់ ឬ ទទួលមរណភាពទេ ហើយអ្នកគ្រប់គ្រងរបស់បុគ្គលអវត្តមាននោះចាំបាច់ត្រូវធ្វើសកម្មភាពដែលហួសសិទ្ធិ ដែលបុគ្គលអវត្តមានបានកំណត់ អ្នកគ្រប់គ្រងនោះអាចធ្វើបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

៣-បើយល់ឃើញថា សមរម្យក្នុងការផ្តល់កម្រៃដល់អ្នកគ្រប់គ្រង ដោយគិតពិចារណានូវទំនាក់ទំនងរវាងអ្នកអវត្តមាន និង អ្នកគ្រប់គ្រង និង ស្ថានភាពផ្សេងទៀត តុលាការអាចផ្តល់កម្រៃចំនួនសមរម្យដល់អ្នកគ្រប់គ្រង ដោយយកពីទ្រព្យសម្បត្តិរបស់អ្នកអវត្តមានបាន ។

កថាភាគទី ២

ការប្រកាសអំពីការបាត់ខ្លួន

មាត្រា ៤១.- លក្ខខណ្ឌដើម្បីធ្វើការប្រកាសអំពីការបាត់ខ្លួន

១-ប្រសិនបើពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាព ក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ តុលាការអាចប្រកាសបានថា បុគ្គលនោះបានបាត់ខ្លួនតាមពាក្យសុំរបស់សហព័ទ្ធ អ្នកដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឪពុកម្តាយ ឬ អ្នកផ្សេងទៀតដែលមានផលប្រយោជន៍សំខាន់តាមផ្លូវច្បាប់ក្នុងការប្រកាសអំពីការបាត់ខ្លួន ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីបុគ្គលដែលចូលទៅតំបន់ដែលមានសង្គ្រាម បុគ្គលដែលមានវត្តមាននៅក្នុងនាវាដែលបានលិច ឬ បុគ្គលដែលបានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងទៀតដែលអាចនាំឱ្យទទួលមរណភាព ហើយពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាព ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក្រោយពីចប់សង្គ្រាម ក្រោយពីនាវាបានលិច ឬ ក្រោយពីគ្រោះថ្នាក់ផ្សេងទៀតនោះ បានកន្លងផុតទៅ ។

មាត្រា ៤២.- ការដាស់តឿនជាសាធារណៈ

ការប្រកាសអំពីការបាត់ខ្លួន ត្រូវធ្វើឡើងដោយឆ្លងកាត់ទៅតាមនីតិវិធីនៃការដាស់តឿនជាសាធារណៈ ។

មាត្រា ៤៣.- អានុភាពនៃការប្រកាសអំពីការបាត់ខ្លួន

ក្នុងករណីដែលការបាត់ខ្លួនត្រូវបានប្រកាសតាមបញ្ញត្តិនៃកថាខណ្ឌទី ១នៃមាត្រា ៤១ (ល័ក្ខខ័ណ្ឌដើម្បីធ្វើការប្រកាសអំពីការបាត់ខ្លួន) នៃក្រមនេះ បន្ទាប់ពីពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នោះ បានកន្លងផុត និង ក្នុងករណីដែលការបាត់ខ្លួនត្រូវបានប្រកាសតាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រាដដែល បន្ទាប់ពីពេលដែលគ្រោះថ្នាក់បានកន្លងផុតទៅ អ្នកបាត់ខ្លួនត្រូវបានចាត់ទុកថា បានទទួលមរណភាព ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តចំពោះតែទំនាក់ទំនងគតិយុត្តជុំវិញលំនៅឋាន ឬ ទីសំណាក់កន្លងមក រហូតដល់ពេលនោះ ។

មាត្រា ៤៤.- ការចាត់ចែងពេលបុគ្គលដែលបាត់ខ្លួនត្រឡប់មកវិញ

១-ប្រសិនបើមានការបញ្ជាក់ថា បុគ្គលដែលបាត់ខ្លួននៅរស់ ឬ មានការបញ្ជាក់ថាទទួលមរណភាពនៅពេលខុសពីពេលដែលបានកំណត់នៅក្នុងមាត្រា ៤៣ (អានុភាពនៃការប្រកាសអំពីការបាត់ខ្លួន) ខាងលើនេះ តុលាការត្រូវលុបចោលការប្រកាសអំពីការបាត់ខ្លួន តាមពាក្យសុំរបស់សាមីខ្លួន ឬ បុគ្គលដែលមានផលប្រយោជន៍ ។

២-បុគ្គលដែលបានទទួលទ្រព្យសម្បត្តិដោយចំពោះ ដោយសារអានុភាពនៃការប្រកាសអំពីការបាត់ខ្លួន ត្រូវបាត់បង់សិទ្ធិ ដោយសារការលុបចោលនូវការប្រកាសអំពីការបាត់ខ្លួននោះ ។

ប៉ុន្តែ បុគ្គលដែលមិនបានដឹងថាការប្រកាសបាត់ខ្លួននោះ ផ្ទុយពីការពិត នៅពេលដែលខ្លួនបានទទួលទ្រព្យសម្បត្តិនោះ ត្រូវមានករណីយកិច្ចសងត្រឹមតែកម្រិតនៃផលប្រយោជន៍ដែលខ្លួននៅតែទទួលផលប្រយោជន៍តែប៉ុណ្ណោះ ។

៣-អានុភាពនៃសកម្មភាពដែលបានធ្វើឡើង ដោយទុកចិត្តលើការប្រកាសអំពីការបាត់ខ្លួន នៅក្រោយការប្រកាសអំពីការបាត់ខ្លួន ប៉ុន្តែមុនពេលលុបចោលការប្រកាសអំពីការបាត់ខ្លួននោះ ពុំទទួលឥទ្ធិពល ដោយសារការលុបចោលការប្រកាសអំពីការបាត់ខ្លួនឡើយ ។

៤-ក្នុងករណីដែលការប្រកាសអំពីការបាត់ខ្លួនត្រូវបានលុបចោល ក្រោយពេលសហព័ទ្ធរបស់បុគ្គលដែលត្រូវបានប្រកាសអំពីការបាត់ខ្លួននោះ បានរៀបអាពាហ៍ពិពាហ៍ជាមួយអ្នកផ្សេង ហើយ អាពាហ៍ពិពាហ៍មុនត្រូវរលាយ ដោយសារអាពាហ៍ពិពាហ៍ក្រោយនោះ ។

ផ្នែកទី ៧

ការចាត់ទុកថាបានទទួលមរណភាពព្រមពេលជាមួយគ្នា

មាត្រា ៤៥.- ការចាត់ទុកថាបានទទួលមរណភាពព្រមពេលជាមួយគ្នា

ក្នុងចំណោមបុគ្គលដែលបានទទួលមរណភាពជាច្រើននាក់ ប្រសិនបើមិនច្បាស់លាស់ថា មានបុគ្គលណាម្នាក់នៅរស់ ក្រោយពេលបុគ្គលផ្សេងទៀតបានទទួលមរណភាពទេ បុគ្គលទាំងនោះត្រូវបានចាត់ទុកថាបានទទួលមរណភាពព្រមពេលជាមួយគ្នា ។

ជំពូកទី ២

នីតិបុគ្គល

ផ្នែកទី ១

បទប្បញ្ញត្តិទូទៅ

កថាភាគទី ១

និយមន័យ ប្រភេទ និង គោលការណ៍នៃការបង្កើត

មាត្រា ៤៦.- និយមន័យ ប្រភេទ និង គោលការណ៍នៃការបង្កើតនីតិបុគ្គល

១-នៅក្នុងក្រមនេះ ក្រុមដែលមានសមាជិក ហើយត្រូវបានប្រគល់នូវឋានៈជាប្រធាន

នៃសិទ្ធិ និងកាតព្វកិច្ចដោយឯករាជ្យ ហៅថា នីតិបុគ្គលសាជីវកម្ម ចំណែកឯទ្រព្យសម្បត្តិវិភាគទានដែលត្រូវបានប្រគល់នូវឋានៈជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ច ដោយឯករាជ្យ ហៅថានីតិបុគ្គលមូលនិធិ ។

២-នៅក្នុងក្រមនេះ នីតិបុគ្គលដែលគ្មានគោលបំណងទាញយកចំណេញ ហៅថា នីតិបុគ្គលមិនយកចំណេញ ចំណែកឯនីតិបុគ្គលដែលទាញយកចំណេញ ហៅថា នីតិបុគ្គលយកចំណេញ ។ នៅក្នុងចំណោមនីតិបុគ្គលមិនយកចំណេញ នីតិបុគ្គលដែលមានគោលបំណងពិសេសដើម្បីបម្រើប្រយោជន៍សាធារណៈ ហៅថា នីតិបុគ្គលបម្រើប្រយោជន៍សាធារណៈ ។

៣-នៅក្នុងក្រមនេះ នីតិបុគ្គលសាជីវកម្មដែលសមាជិកទទួលខុសត្រូវនូវកាតព្វកិច្ចរបស់នីតិបុគ្គល តាមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានធ្វើវិភាគទាន ហៅថា នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ចំណែកឯនីតិបុគ្គលសាជីវកម្មដែលសមាជិកទទួលខុសត្រូវនូវកាតព្វកិច្ចរបស់នីតិបុគ្គល ដោយយកទ្រព្យសម្បត្តិទូទៅរបស់ខ្លួន ហៅថា នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ។

៤-នីតិបុគ្គលមិនអាចធ្វើជាសមាជិកដែលទទួលខុសត្រូវគ្មានកម្រិតរបស់នីតិបុគ្គលសាជីវកម្មផ្សេងទៀតបានឡើយ ។

៥-នីតិបុគ្គលមិនយកចំណេញ អាចបង្កើតឡើងតាមក្រមនេះ ឬ បទដ្ឋានគតិយុត្តផ្សេងទៀតបាន ។

៦-នីតិបុគ្គលទាញយកចំណេញ អាចបង្កើតឡើងបាន ដោយយោងទៅតាមបញ្ញត្តិនៃច្បាប់ផ្សេង ។

កថាភាគទី ២

នាមករណ៍នៃនីតិបុគ្គលមិនយកចំណេញ

មាត្រា ៤៧.- នាមករណ៍នៃនីតិបុគ្គលមិនយកចំណេញ

១-អង្គភាពដែលមិនមែនជានីតិបុគ្គលសាជីវកម្ម ឬ មិនមែនជានីតិបុគ្គលមូលនិធិ មិនអាចប្រើពាក្យ "នីតិបុគ្គលសាជីវកម្ម" ឬ "នីតិបុគ្គលមូលនិធិ" ក្នុងនាមករណ៍របស់ខ្លួនបានឡើយ ។

២-ចំពោះនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ត្រូវបង្ហាញថា ជានីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត នៅក្នុងនាមករណ៍នោះ ចំណែកឯនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ត្រូវបង្ហាញថា ជានីតិបុគ្គលសាជីវកម្មទទួលខុសត្រូវ គ្មានកម្រិត នៅក្នុងនាមករណ៍នោះ ។

មាត្រា ៤៨.- នីតិបុគ្គលបរទេស

១-នៅក្នុងក្រមនេះ នីតិបុគ្គលដែលបានបង្កើតឡើង ដោយយោងទៅតាមច្បាប់បរទេស ហៅថា នីតិបុគ្គលបរទេស ។

២-នីតិបុគ្គលបរទេស ក្រៅពីរដ្ឋ តំបន់រដ្ឋបាលរបស់រដ្ឋ និង ក្រុមហ៊ុនពាណិជ្ជកម្ម ពុំអាចទទួលស្គាល់ជានីតិបុគ្គលបានឡើយ ។ ប៉ុន្តែ បើមានសេចក្តីអនុញ្ញាតតាមច្បាប់ ឬ សន្ធិសញ្ញា ឬ អនុសញ្ញានៃព្រះរាជាណាចក្រកម្ពុជា អាចទទួលស្គាល់ថាជានីតិបុគ្គលបាន ។

៣-នីតិបុគ្គលបរទេសដែលទទួលស្គាល់ថាជានីតិបុគ្គល តាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ មានសិទ្ធិតាមច្បាប់ឯកជន ដូចនីតិបុគ្គលដែលត្រូវបានបង្កើត ដោយផ្អែកលើច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដែលមានប្រភេទដូចគ្នាដែរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសិទ្ធិដែលជនជាតិបរទេសមិនអាចមានបាន ឬ ករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ ឬ សន្ធិសញ្ញា ឬ អនុសញ្ញា ។

កថាភាគទី ៣

ការចុះបញ្ជីនៃការបង្កើត

មាត្រា ៤៩.- ការចុះបញ្ជីនៃការបង្កើត និង ពេលវេលាកំណើតនៃនីតិបុគ្គល

នីតិបុគ្គលត្រូវបានបង្កើតឡើង ដោយការចុះបញ្ជីនៅកន្លែងដែលមានទីតាំងនៃទីស្នាក់ការកណ្តាលរបស់នីតិបុគ្គលនោះ ។

មាត្រា ៥០.- ចំណុចដែលត្រូវចុះបញ្ជី

១-ដើម្បីចុះបញ្ជី នីតិបុគ្គលត្រូវចុះនូវចំណុចនីមួយៗដូចបានកំណត់ខាងក្រោមនេះ :

ក-គោលបំណង ។

- ៧ -

ខ-នាមករណ៍ ។

គ-ទីស្នាក់ការកណ្តាល និង ទីស្នាក់ការសាខា ។

ឃ-មូលហេតុនៃការរំលាយ បើបានកំណត់មូលហេតុនោះ នៅក្នុងលក្ខន្តិកៈ ។

ង-ឈ្មោះ ឬ នាមករណ៍ និង លំនៅឋានរបស់អភិបាល និង អ្នកត្រួតពិនិត្យ ។ ប៉ុន្តែចំពោះនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ត្រូវចុះឈ្មោះ និងលំនៅឋានរបស់សមាជិក ។

ច-ឈ្មោះរបស់អភិបាលដែលត្រូវធ្វើជាតំណាងនីតិបុគ្គល បើមានជនដែលជាអភិបាល តែមិនតំណាងឱ្យនីតិបុគ្គលនោះ ។

ឆ- សេចក្តីកំណត់អំពីសហតំណាង ដែលកំណត់ថា អភិបាលច្រើននាក់ធ្វើតំណាងឱ្យនីតិបុគ្គលដោយរួមគ្នា ប្រសិនបើមាន ។

២-បើមានការផ្លាស់ប្តូរចំណុចណាមួយ ក្នុងចំណោមចំណុចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចុះបញ្ជីនៅទីតាំងនៃទីស្នាក់ការកណ្តាល ក្នុងអំឡុងពេល ២(ពីរ) សប្តាហ៍ និង នៅទីតាំងនៃទីស្នាក់ការផ្សេងទៀត ក្នុងអំឡុងពេល ៣ (បី) សប្តាហ៍ ។ នៅក្នុងអំឡុងពេលដែលមិនទាន់បានចុះបញ្ជីទេ ការផ្លាស់ប្តូរពុំអាចតតាំងចំពោះតតិយជនបានឡើយ ។

៣-ប្រសិនបើមានការចាត់ចែងជាបណ្តោះអាសន្ន ដែលផ្អាកការអនុវត្តកិច្ចការរបស់អភិបាល ឬ ដែលជ្រើសតាំងបុគ្គលជំនួសអភិបាល ឬ បើមានការផ្លាស់ប្តូរ ឬ លុបចោលនូវការចាត់ចែងជាបណ្តោះអាសន្ននោះ ត្រូវចុះបញ្ជីនៅទីតាំងនៃទីស្នាក់ការកណ្តាល និង ទីតាំងនៃទីស្នាក់ការផ្សេងទៀត ។ នៅក្នុងករណីនេះ វាក្យខណ្ឌទី ២ នៃ កថាខណ្ឌទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

កថាភាគទី ៤
លំនៅឋាននៃនីតិបុគ្គល

មាត្រា ៥១.- លំនៅឋាននៃនីតិបុគ្គល

នីតិបុគ្គលត្រូវមានលំនៅឋាន នៅទីតាំងនៃទីស្នាក់ការកណ្តាលរបស់នីតិបុគ្គលនោះ ។

30/468

មាត្រា ៥២.- ការចុះបញ្ជីអំពីការផ្លាស់ប្តូរទីតាំងនៃទីស្នាក់ការ

១-នៅពេលដែលនីតិបុគ្គលផ្លាស់ប្តូរទីតាំងនៃទីស្នាក់ការកណ្តាល ត្រូវចុះបញ្ជីអំពីការផ្លាស់ប្តូរនោះ នៅទីតាំងចាស់ ហើយត្រូវចុះបញ្ជីនូវចំណុចដែលបានកំណត់នៅក្នុងមាត្រា ៥០ (ចំណុចដែលត្រូវចុះបញ្ជី) នៃក្រមនេះ នៅទីតាំងថ្មី ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ។ នៅពេលដែលផ្លាស់ប្តូរទីតាំងទីស្នាក់ការឯទៀត ត្រូវចុះបញ្ជីអំពីការផ្លាស់ប្តូរនោះ នៅទីតាំងចាស់ក្នុងអំឡុងពេល ៣ (បី) សប្តាហ៍ ហើយត្រូវចុះបញ្ជីនូវចំណុចដែលបានកំណត់នៅក្នុងមាត្រា ៥០ (ចំណុចដែលត្រូវចុះបញ្ជី) នោះ នៅទីតាំងថ្មី ក្នុងអំឡុងពេល ៤ (បួន) សប្តាហ៍ ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ នៅក្នុងករណីដែលការផ្លាស់ប្តូរទីតាំងទីស្នាក់ការ ត្រូវបានធ្វើឡើងនៅក្នុងដែនសមត្ថកិច្ចនៃការិយាល័យចុះបញ្ជីដូចគ្នានោះ គ្រាន់តែចុះបញ្ជីអំពីការផ្លាស់ប្តូរទីតាំងជាការគ្រប់គ្រាន់ហើយ ។

មាត្រា ៥៣.- ការចុះបញ្ជីទីស្នាក់ការដែលបង្កើតថ្មី

១-ក្នុងករណីដែលនីតិបុគ្គលបានបង្កើតទីស្នាក់ការថ្មី ត្រូវចុះបញ្ជីនូវចំណុចដែលបានកំណត់នៅក្នុងមាត្រា ៥០ (ចំណុចដែលត្រូវចុះបញ្ជី) នៃក្រមនេះ ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ នៅទីតាំងនៃទីស្នាក់ការថ្មីនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចុះបញ្ជីអំពីការបង្កើតទីស្នាក់ការថ្មី នៅទីតាំងនៃទីស្នាក់ការកណ្តាល និង ទីតាំងនៃទីស្នាក់ការផ្សេងទៀត ក្នុងអំឡុងពេល ៣ (បី) សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានបង្កើតទីស្នាក់ការថ្មីនោះ ។

កថាភាគទី ៥

ការចុះបញ្ជីនៃនីតិបុគ្គលបរទេស

មាត្រា ៥៤.- ការចុះបញ្ជីនៃនីតិបុគ្គលបរទេស

១-បញ្ញត្តិនៃមាត្រា ៥០ (ចំណុចដែលត្រូវចុះបញ្ជី) មាត្រា ៥២ (ការចុះបញ្ជីអំពីការផ្លាស់ប្តូរទីតាំងទីស្នាក់ការ) និងមាត្រា ៥៣ (ការចុះបញ្ជីទីស្នាក់ការដែលបង្កើតថ្មី) នៃក្រមនេះ ត្រូវអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលនីតិបុគ្គលបរទេស បើកទីស្នាក់ការនៅក្នុង

ព្រះរាជាណាចក្រកម្ពុជា ។

២-ក្នុងករណីដែលនីតិបុគ្គលបរទេសបើកទីស្នាក់ការជាដំបូង នៅក្នុងព្រះរាជាណាចក្រកម្ពុជា បុគ្គលដទៃអាចបដិសេធបុគ្គលភាពរបស់នីតិបុគ្គលនោះបាន រហូតដល់ពេលដែលនីតិបុគ្គលនោះបានចុះបញ្ជីនៅទីតាំងនៃទីស្នាក់ការនោះ ។

កថាភាគទី ៦

ការគ្រប់គ្រង និង ការចាត់ចែងកិច្ចការនៃនីតិបុគ្គល

មាត្រា ៥៥.- បញ្ជីទ្រព្យសម្បត្តិ និង បញ្ជីរាយនាមសមាជិក

១-នីតិបុគ្គលត្រូវធ្វើបញ្ជីទ្រព្យសម្បត្តិនៅពេលបង្កើត និង ក្នុងអំឡុងពេល ៣ (បី) ខែ នៃដើមឆ្នាំអនុវត្តកិច្ចការ ហើយត្រូវទុកបញ្ជីនោះនៅក្នុងទីស្នាក់ការជានិច្ច ។

២-នីតិបុគ្គលសាជីវកម្មត្រូវធ្វើបញ្ជីរាយនាមសមាជិក និង ទុកនៅទីស្នាក់ការជានិច្ច ហើយរាល់ពេលដែលមានការផ្លាស់ប្តូរសមាជិក ត្រូវកែតម្រូវបញ្ជីនោះ ។

មាត្រា ៥៦.- ចំនួន ការជ្រើសតាំង ការដកហូតតំណែង និង ភារកិច្ចនៃអភិបាល

១-នីតិបុគ្គលត្រូវមានអភិបាលដែលជាអង្គភាពមួយដើម្បីអនុវត្តកិច្ចការរបស់នីតិបុគ្គល ។ ប៉ុន្តែ នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ពុំត្រូវមានអភិបាលឡើយ ។

២-អភិបាល អាចមានមួយរូប ឬ ច្រើនរូបបាន ។ ប៉ុន្តែ ចំពោះនីតិបុគ្គលមូលនិធិ ត្រូវមានអភិបាលយ៉ាងតិច ៣ (បី) រូប ។

៣-ក្នុងករណីដែលមានអភិបាលច្រើនរូប កិច្ចការរបស់នីតិបុគ្គលត្រូវសម្រេច ដោយសម្លេងភាគច្រើន បើគ្មានការកំណត់ពិសេសក្នុងលក្ខន្តិកៈទេ ។

៤-អភិបាលត្រូវបានជ្រើសតាំងដោយលក្ខន្តិកៈ ឬ ដោយមហាសន្និបាតសមាជិក ។

៥-អភិបាលនៃនីតិបុគ្គលសាជីវកម្ម អាចត្រូវបានដកហូតតំណែងដោយសេចក្តីសម្រេចនៃមហាសន្និបាតសមាជិកបាន ។

មាត្រា ៥៧.- ករណីយកិច្ចរបស់អភិបាល

១-អភិបាលមានករណីយកិច្ចត្រូវគោរពទៅតាមច្បាប់និងបទដ្ឋានគតិយុត្ត និង ខ្លឹមសារ

នៃលក្ខន្តិកៈ និង ត្រូវចាត់ចែងការងាររបស់នីតិបុគ្គលដោយស្មោះត្រង់ ។

២-ក្រៅពីបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ទំនាក់ទំនងរវាងអភិបាល និងនីតិបុគ្គល ត្រូវអនុវត្តតាមបញ្ញត្តិស្តីពីអាណត្តិ ។

មាត្រា ៥៨.- សិទ្ធិតំណាងរបស់អភិបាល

១-អភិបាលត្រូវតំណាងឱ្យនីតិបុគ្គល ។ ប៉ុន្តែ អភិបាលមិនអាចប្រតិបត្តិផ្ទុយនឹងខ្លឹមសារនៃលក្ខន្តិកៈបានឡើយ ។

២-ក្នុងករណីដែលមានអភិបាលច្រើនរូប អភិបាលនីមួយៗត្រូវមានសិទ្ធិតំណាង ។ ប៉ុន្តែ អាចកំណត់ផ្សេងបានក្នុងលក្ខន្តិកៈ ។

៣-ចំពោះនីតិបុគ្គលសាជីវកម្ម អភិបាលត្រូវគោរពតាមសេចក្តីសម្រេចនៃមហាសន្និបាតសមាជិក ។

មាត្រា ៥៩.- ការកម្រិតនូវសិទ្ធិតំណាង

ការកម្រិតដែលបានធ្វើលើសិទ្ធិតំណាងរបស់អភិបាល ឬ អ្នកតំណាងនីតិបុគ្គលផ្សេងទៀត ពុំអាចតតាំងចំពោះតតិយជនសុចរិតបានឡើយ ។

មាត្រា ៦០.- អភិបាលបណ្តោះអាសន្ន

ក្នុងករណីដែលខ្វះអភិបាល ហើយមានការបារម្ភថា នឹងបណ្តាលឱ្យមានការខូចខាតដោយសារមានការយឺតយ៉ាវក្នុងកិច្ចការរបស់នីតិបុគ្គល តុលាការអាចជ្រើសតាំងអភិបាលបណ្តោះអាសន្នបាន តាមពាក្យសុំរបស់អ្នកដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ឬ តាមពាក្យសុំរបស់តំណាងអយ្យការ ។

មាត្រា ៦១.- អ្នកតំណាងពិសេស

ចំពោះចំណុចដែលផលប្រយោជន៍របស់អភិបាល និង ផលប្រយោជន៍របស់នីតិបុគ្គលប្រឆាំងគ្នា អភិបាលនោះពុំត្រូវមានសិទ្ធិតំណាងឡើយ ។ ក្នុងករណីដែលខ្វះអ្នកតំណាងឱ្យនីតិបុគ្គលដោយសារហេតុនេះ អ្នកតំណាងពិសេសត្រូវបានជ្រើសតាំង តាមនីតិវិធីដូចដែលបានកំណត់ក្នុងមាត្រា ៦០ (អភិបាលបណ្តោះអាសន្ន) នៃក្រមនេះ ។

មាត្រា ៦២.- អ្នកត្រួតពិនិត្យ

១-នីតិបុគ្គលត្រូវមានអ្នកត្រួតពិនិត្យម្នាក់ ឬ ច្រើននាក់ ។ ប៉ុន្តែ នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត អាចមិនមានអ្នកត្រួតពិនិត្យ ។

២-អ្នកត្រួតពិនិត្យត្រូវបានជ្រើសតាំងតាមការកំណត់នៃលក្ខន្តិកៈ ឬ ដោយសេចក្តីសម្រេចនៃមហាសន្និបាតសមាជិក ឬ ក្រុមប្រឹក្សាភិបាល ។

៣-អភិបាល ឬ និយោជិតរបស់នីតិបុគ្គល ពុំអាចធ្វើជាអ្នកត្រួតពិនិត្យបានឡើយ ។

៤-នីតិបុគ្គលសវនករអាចធ្វើជាអ្នកត្រួតពិនិត្យបាន ។

មាត្រា ៦៣.- ភារកិច្ចរបស់អ្នកត្រួតពិនិត្យជារួម

១-អ្នកត្រួតពិនិត្យត្រូវត្រួតពិនិត្យកិច្ចការរបស់នីតិបុគ្គល ។

២-អ្នកត្រួតពិនិត្យអាចទាមទារឱ្យអភិបាល និង និយោជិតរបស់នីតិបុគ្គលធ្វើសេចក្តីរាយការណ៍អំពីស្ថានភាពនៃការអនុវត្តកិច្ចការ ឬ អាចស្រាវជ្រាវនូវស្ថានភាពនៃកិច្ចការ និងទ្រព្យសម្បត្តិរបស់នីតិបុគ្គលបាន ។

៣-អ្នកត្រួតពិនិត្យត្រូវស្រាវជ្រាវរបៀបវារៈ និង ឯកសារដែលអភិបាលបម្រុងនឹងដាក់ជូនមហាសន្និបាតសមាជិក ឬ ក្រុមប្រឹក្សាភិបាល ។ ក្នុងករណីនេះ បើយល់ឃើញថាមានការបំពានបទដ្ឋានគតិយុត្ត ឬ លក្ខន្តិកៈ ឬ មានចំណុចដែលមិនត្រឹមត្រូវហួសហេតុ អ្នកត្រួតពិនិត្យត្រូវធ្វើសេចក្តីរាយការណ៍ នៅក្នុងមហាសន្និបាតសមាជិក ឬ អង្គប្រជុំនៃក្រុមប្រឹក្សាភិបាល ។

៤-អ្នកត្រួតពិនិត្យអាចបញ្ចេញមតិអំពីការជ្រើសតាំង ឬ ការបញ្ឈប់ពីតំណែងនៃអ្នកត្រួតពិនិត្យ ឬ ប្រាក់កម្រៃរបស់អ្នកត្រួតពិនិត្យបាន នៅក្នុងមហាសន្និបាតសមាជិក ឬ អង្គប្រជុំនៃក្រុមប្រឹក្សាភិបាល ។

៥-បើយល់ឃើញថា អភិបាលបានធ្វើសកម្មភាពក្រៅពីគោលបំណងរបស់នីតិបុគ្គល ឬ សកម្មភាពផ្សេងទៀត ដែលផ្ទុយនឹងបទដ្ឋានគតិយុត្ត ឬ លក្ខន្តិកៈ ឬ មានការបារម្ភថាអភិបាលនឹងធ្វើសកម្មភាពនោះ អ្នកត្រួតពិនិត្យត្រូវធ្វើសេចក្តីរាយការណ៍អំពីហេតុនោះនៅក្នុងមហាសន្និបាតសមាជិក ឬ អង្គប្រជុំនៃក្រុមប្រឹក្សាភិបាល ។ ក្នុងករណីនេះ បើមានភាពចាំបាច់ដើម្បីធ្វើសេចក្តីរាយការណ៍នោះ អ្នកត្រួតពិនិត្យអាចកោះប្រជុំមហាសន្និបាតសមាជិក ឬ ប្រជុំក្រុម

ROYAL PALACE / LE MINISTRE DU PALAIS ROYAL

ប្រឹក្សាភិបាលបាន ។ អ្នកត្រួតពិនិត្យនៃនីតិបុគ្គល មូលនិធិត្រូវធ្វើសេចក្តីរាយការណ៍ខាងលើនេះទៅក្រសួង ឬ ស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យយ៉ាងយឺតបំផុតក៏ឱ្យទាន់ជាមួយពេលធ្វើសេចក្តីរាយការណ៍ទៅក្រុមប្រឹក្សាភិបាល។

៦-ក្នុងករណីដែលអភិបាលបានធ្វើសកម្មភាពដូចបានកំណត់នៅក្នុងកថាខណ្ឌទី ៥ ខាងលើនេះ ឬ មានការបារម្ភថា អភិបាលនឹងធ្វើសកម្មភាពនោះ ហើយបើមានការបារម្ភថាសកម្មភាពនោះអាចនឹងបណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់នីតិបុគ្គល សមាជិកអាចទាមទារឱ្យអភិបាលនោះបញ្ឈប់នូវសកម្មភាពនោះបាន ។

៧-ក្នុងករណីដែលនីតិបុគ្គលប្តឹងអភិបាល ឬ អភិបាលប្តឹងនីតិបុគ្គល អ្នកត្រួតពិនិត្យត្រូវតំណាងឱ្យនីតិបុគ្គលក្នុងបណ្តឹងនេះ ។

កថាភាគទី ៧

ការរំលាយ និង ការជម្រះបញ្ជី

មាត្រា ៦៤.- មូលហេតុនៃការរំលាយ

១-នីតិបុគ្គលត្រូវរលាយដោយមូលហេតុណាមួយដូចខាងក្រោមនេះ :

ក-ការកើតឡើងនូវមូលហេតុនៃការរំលាយដែលបានកំណត់នៅក្នុងលក្ខន្តិកៈ ។

ខ-ការបញ្ចប់កិច្ចការដែលជាគោលបំណងរបស់នីតិបុគ្គល ឬ អលទ្ធភាពក្នុងការបំពេញកិច្ចការនោះ ។

គ-ធនក្ស័យ ។

ឃ-សាលក្រម ឬ សាលដីកាដែលបង្គាប់ឱ្យរំលាយ ។

២-ក្រៅពីមូលហេតុដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ នីតិបុគ្គលសាជីវកម្មក៏ត្រូវរលាយដោយមូលហេតុណាមួយដូចខាងក្រោមនេះផងដែរ :

ក-សេចក្តីសម្រេចនៃមហាសន្និបាតសមាជិក ចំពោះនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ឬ មតិយល់ស្របនៃសមាជិកទាំងអស់ចំពោះនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ។

ខ-ករណីដែលសមាជិកនៅសល់តែម្នាក់ ។

-ល-

៣-ចំពោះសេចក្តីសម្រេចរំលាយនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ដែលបានកំណត់នៅក្នុងចំណុច ក នៃ កថាខណ្ឌទី ២ ខាងលើនេះ ត្រូវមានការយល់ព្រមពីសមាជិកចាប់ពីពាក់កណ្តាលឡើងទៅ នៃចំនួនសមាជិកទាំងអស់ និង ដោយសម្លេង ចំនួនចាប់ពី ៣ ភាគ ៤ (បីភាគបួន) ឡើងទៅ នៃសិទ្ធិសម្រេចរបស់សមាជិកទាំងអស់ ។

មាត្រា ៦៥.- បណ្តឹងទាមទារការរំលាយ

១-សមាជិកដែលមានសិទ្ធិសម្រេចចាប់ពី ១ ភាគ ១០ (មួយភាគដប់) ឡើងទៅនៃចំនួនសិទ្ធិសម្រេចរបស់សមាជិកទាំងអស់ នៃនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិតសមាជិកម្នាក់ៗនៃនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ឬ អភិបាលនៃនីតិបុគ្គលមូលនិធិ ឬ ក្រសួង ឬ ស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យនៃនីតិបុគ្គលមូលនិធិ អាចដាក់ពាក្យបណ្តឹងទាមទារការរំលាយនីតិបុគ្គលបាន ។

២-ក្នុងករណីដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ តុលាការអាចបង្គាប់ឱ្យរំលាយនីតិបុគ្គលបាន លុះត្រាតែមានហេតុការណ៍ដូចរៀបរាប់ខាងក្រោមនេះ ហើយមានហេតុដែលពុំអាចជៀសវាងបាន :

ក-នីតិបុគ្គលមានស្ថានភាពលំបាកគួរឱ្យកត់សំគាល់ក្នុងការអនុវត្តកិច្ចការ ហើយការខូចខាតដែលពុំអាចស្តារឡើងវិញបាន បានកើតឡើង ឬ មានការបារម្ភថា នឹងកើតឡើងចំពោះនីតិបុគ្គល ។

ខ-ការគ្រប់គ្រង ឬ ការចាត់ចែងទ្រព្យសម្បត្តិរបស់នីតិបុគ្គលបាត់បង់ភាពត្រឹមត្រូវគួរឱ្យកត់សំគាល់ និង ធ្វើឱ្យមានគ្រោះថ្នាក់ដល់អត្ថិភាពនៃនីតិបុគ្គលនោះ ។

៣-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះក៏ដោយ ក្នុងករណីដែលយល់ឃើញថា មានហេតុដែលបានកំណត់នៅក្នុងចំណុចណាមួយដូចខាងក្រោមនេះតុលាការអាចបង្គាប់ឱ្យរំលាយនីតិបុគ្គលបាន តាមពាក្យសុំរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬ សមាជិកម្ចាស់បំណុល ឬ បុគ្គលផ្សេងទៀតដែលពាក់ព័ន្ធនឹងផលប្រយោជន៍ បើយល់ឃើញថា មិនអាចអនុញ្ញាតឱ្យមានអត្ថិភាពនៃនីតិបុគ្គលតទៅទៀត ដើម្បីរក្សាផលប្រយោជន៍សាធារណៈ :

ក-នីតិបុគ្គលត្រូវបានបង្កើតឡើងដើម្បីគោលបំណងមិនស្របច្បាប់ ។

ខ- នីតិបុគ្គលពុំបានចាប់ផ្តើមកិច្ចការក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក្រោយពីការបង្កើត ឬ បានបញ្ឈប់កិច្ចការលើសពី ១ (មួយ) ឆ្នាំ ដោយគ្មានមូលហេតុត្រឹមត្រូវ ។

គ- ទោះបីអ្នកអនុវត្តកិច្ចការនីតិបុគ្គលនោះបានទទួលសេចក្តីព្រមានជាលាយលក្ខណ៍អក្សរពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ហើយក៏ដោយ ក៏នៅតែបន្តប្រព្រឹត្ត ឬ ប្រព្រឹត្តដដែលៗនូវសកម្មភាពដែលហួស ឬ បំពានសិទ្ធិអំណាចដែលបានកំណត់ក្នុងបទដ្ឋាន គតិយុត្ត ឬ លក្ខន្តិកៈ ឬ សកម្មភាពដែលផ្ទុយនឹងបទដ្ឋានគតិយុត្តព្រហ្មទណ្ឌ ។

៤-ក្នុងករណីដែលមានពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើ នេះ ទោះបីមិនទាន់បង្គាប់ឱ្យរំលាយក៏ដោយ ក៏តុលាការអាចធ្វើការជ្រើសតាំងអ្នកគ្រប់គ្រង ឬ ធ្វើការចាត់ចែងចាំបាច់ផ្សេងទៀតដើម្បីរក្សាការពារទ្រព្យសម្បត្តិរបស់នីតិបុគ្គល បានតាមពាក្យសុំរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សមាជិកម្ចាស់បំណុល ឬ បុគ្គលផ្សេងទៀតដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

មាត្រា ៦៦.- ករណីដែលត្រូវជម្រះបញ្ជី និង នីតិបុគ្គលដែលត្រូវជម្រះបញ្ជី

ក្នុងករណីដែលនីតិបុគ្គលត្រូវបានរំលាយ ត្រូវធ្វើការជម្រះបញ្ជីដោយយោងទៅតាមបញ្ញត្តិនៃកថាភាគទី ៧ (ការរំលាយ និង ការជម្រះបញ្ជី) នេះ លើកលែងតែករណីដែលបានកំណត់នៅក្នុងចំណុច គ កថាខណ្ឌទី ១ នៃមាត្រា ៦៤ (មូលហេតុនៃការរំលាយ) នៃក្រមនេះ ។ ក្នុងករណីនេះ នីតិបុគ្គលនេះ ត្រូវបានចាត់ទុកថា មានអត្ថិភាពតទៅទៀតរហូតដល់ការជម្រះបញ្ជីបានសម្រេចចប់សព្វគ្រប់ នៅក្នុងទំហំនៃគោលបំណងដើម្បីការជម្រះបញ្ជី ។

មាត្រា ៦៧.- ការបង្វែរទ្រព្យសម្បត្តិដែលនៅសល់

១-ការបង្វែរទ្រព្យសម្បត្តិដែលនៅសល់ បន្ទាប់ពីការសងចំពោះកាតព្វកិច្ចទាំងអស់ក្រោយការរំលាយនីតិបុគ្គល ត្រូវអនុលោមតាមសេចក្តីកំណត់ក្នុងលក្ខន្តិកៈ ។

២-ចំពោះនីតិបុគ្គលសាជីវកម្ម បើការបង្វែរទ្រព្យសម្បត្តិដែលនៅសល់មិនអាចកំណត់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបានទេ ការបង្វែរនោះត្រូវអនុលោមតាមសេចក្តីសម្រេចនៃមហាសន្និបាតសមាជិកនៃនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ឬ តាមការយល់ព្រមរួមរបស់សមាជិកទាំងអស់នៃនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ។

៣-ទ្រព្យសម្បត្តិនៅសល់ ដែលមិនអាចកំណត់ការបង្វែរបាន តាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវបាននៅរតនាគារជាតិ ។

មាត្រា ៦៨.- ការកាន់តំណែងនៃអ្នកជម្រះបញ្ជី

១-ក្នុងករណីដែលនីតិបុគ្គលត្រូវបានរំលាយ ដោយមូលហេតុដែលបានកំណត់នៅក្នុងចំណុច ក ឬ ខ កថាខណ្ឌទី ១ឬ ចំណុចក កថាខណ្ឌទី ២ នៃមាត្រា ៦៤(មូលហេតុនៃការរំលាយ)នៃក្រមនេះ បុគ្គលដូចខាងក្រោមនេះត្រូវក្លាយទៅជាអ្នកជម្រះបញ្ជីដោយយោលទៅតាមលំដាប់ :

ក-បុគ្គលដែលបានកំណត់នៅក្នុងលក្ខន្តិកៈ ។

ខ-បុគ្គលដែលត្រូវបានជ្រើសតាំង ដោយសេចក្តីសម្រេចនៃមហាសន្និបាត សមាជិកនៃនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ឬ បុគ្គលដែលត្រូវបានជ្រើសតាំងដោយមតិលើសពីពាក់កណ្តាលនៃចំនួនសមាជិកនៃនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ។

គ- អភិបាលនៃនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត និង នីតិបុគ្គលមូលនិធិ ឬ សមាជិកនៃនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើពុំមានបុគ្គលណាម្នាក់ក្លាយជាអ្នកជម្រះបញ្ជីតាមបញ្ញត្តិនៃកថាខណ្ឌទី ១ នោះទេ តុលាការត្រូវជ្រើសតាំងអ្នកជម្រះបញ្ជី តាមពាក្យសុំរបស់បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ។

៣-ក្នុងករណីដែលនីតិបុគ្គលត្រូវបានរំលាយ ដោយមូលហេតុដែលបានកំណត់នៅក្នុងចំណុច ឃ កថាខណ្ឌទី ១ និង ចំណុច ខ កថាខណ្ឌទី ២ នៃមាត្រា ៦៤ (មូលហេតុនៃការរំលាយ) នៃក្រមនេះ តុលាការត្រូវជ្រើសតាំងអ្នកជម្រះបញ្ជី តាមពាក្យសុំរបស់បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ឬ របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬ ដោយឆន្ទានុសិទ្ធិរបស់តុលាការ ។

មាត្រា ៦៩.- ការដកហូតតំណែងរបស់អ្នកជម្រះបញ្ជី

១-បើមានហេតុធ្ងន់ធ្ងរ តុលាការអាចដកហូតតំណែងរបស់អ្នកជម្រះបញ្ជីបានតាមពាក្យសុំរបស់អ្នកដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ។

២-ក្រៅពីអ្នកជម្រះបញ្ជីដែលត្រូវបានជ្រើសតាំងដោយតុលាការ អ្នកជម្រះបញ្ជីនៃនីតិបុគ្គលសាជីវកម្ម អាចត្រូវបានដកហូតតំណែងបាន ដោយសេចក្តីសម្រេចនៃមហាសន្និបាតសមា-

- ៧១ -

ជិកនៃនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ឬ ដោយមតិលើសពីពាក់កណ្តាលនៃចំនួនសមាជិកទាំងអស់នៃនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ។

មាត្រា ៧០.- ការចុះបញ្ជីអំពីអ្នកជម្រះបញ្ជី និង ការរំលាយ

លើកលែងតែករណីដែលបានកំណត់នៅក្នុងចំណុច គ កថាខណ្ឌទី ១ នៃមាត្រា ៦៤ (មូលហេតុនៃការរំលាយ) នៃក្រមនេះ អ្នកជម្រះបញ្ជីត្រូវចុះបញ្ជីអំពីឈ្មោះនិងលំនៅឋានរបស់ខ្លួន និង មូលហេតុនិងកាលបរិច្ឆេទនៃការរំលាយ នៅទីតាំងនៃទីស្នាក់ការកណ្តាលក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ និង នៅទីតាំងនៃទីស្នាក់ការឯទៀត ក្នុងអំឡុងពេល ៣ (បី) សប្តាហ៍ក្រោយពីការរំលាយ ។

មាត្រា ៧១.- មុខងារ និង សិទ្ធិអំណាចរបស់អ្នកជម្រះបញ្ជី

១-អ្នកជម្រះបញ្ជីត្រូវអនុវត្តនូវមុខងារដែលបានកំណត់នៅចំណុចនីមួយៗខាងក្រោមនេះ :

ក-បំពេញបញ្ចើ្ចយនូវកិច្ចការបច្ចុប្បន្នរបស់នីតិបុគ្គល ។

ខ-ប្រមូលសិទ្ធិលើបំណុល និងសងកាតព្វកិច្ច ។

គ-ប្រគល់ទ្រព្យសម្បត្តិដែលនៅសល់ ។

២-បើមានអ្នកជម្រះបញ្ជីច្រើនរូប កិច្ចការរបស់នីតិបុគ្គល ត្រូវអនុលោមតាមសេចក្តីសម្រេចដោយមតិលើសពីពាក់កណ្តាលនៃចំនួនអ្នកជម្រះបញ្ជី ។

៣-បញ្ញត្តិនៃមាត្រា ៥៨ (សិទ្ធិតំណាងរបស់អភិបាល) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកជម្រះបញ្ជី ។ ប៉ុន្តែ បើតុលាការជ្រើសតាំងអ្នកជម្រះបញ្ជីច្រើនរូប តុលាការអាចជ្រើសតាំងអ្នកតំណាង ឬ ជ្រើសតាំងសហតំណាងពីចំណោមអ្នកជម្រះបញ្ជីនោះ ។

មាត្រា ៧២.- ករណីយកិច្ចធ្វើសេចក្តីរាយការណ៍អំពីការស្រាវជ្រាវទ្រព្យសម្បត្តិនីតិបុគ្គល

១-ក្រោយពេលឡើងកាន់តំណែង អ្នកជម្រះបញ្ជីត្រូវស្រាវជ្រាវស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់នីតិបុគ្គល ធ្វើបញ្ជីសារពើភ័ណ្ឌ និង តារាងតុល្យការ និង ដាក់ជូនតុលាការដោយគ្មានការយឺតយ៉ាវ ។

២-ចំពោះនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ឯកសារដែលបានកំណត់ នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវទទួលការយល់ព្រមពីមហាសន្និបាតសមាជិក មុននឹងដាក់ទៅតុលាការ ។

៣-ចំពោះនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ឯកសារដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ ត្រូវទទួលការយល់ព្រមពីសមាជិកទាំងអស់ មុននឹងដាក់ទៅតុលាការ ។

៤-ចំពោះនីតិបុគ្គលមូលនិធិ ឯកសារដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ ត្រូវទទួលការយល់ព្រមពីក្រសួង ឬ ស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យ មុននឹងដាក់ទៅតុលាការ ។

មាត្រា ៧៣.- ការប្រកាសជាសាធារណៈចំពោះម្ចាស់បំណុល

១-អ្នកជម្រះបញ្ជីត្រូវប្រកាសជាសាធារណៈនៅក្នុងព្រឹត្តិបត្រផ្លូវការរបស់ក្រសួងយុត្តិធម៌យ៉ាងតិចបំផុតចំនួន ៣ (បី) ដង ក្នុងអំឡុងពេល ២ (ពីរ) ខែ គិតចាប់ពីថ្ងៃដែលខ្លួនឡើងកាន់តំណែង ចំពោះម្ចាស់បំណុលថាម្ចាស់បំណុលត្រូវបង្ហាញសិទ្ធិលើបំណុលរបស់ខ្លួន ក្នុងអំឡុងពេលដែលកំណត់មិនឱ្យតិចជាង ២ (ពីរ) ខែ ។

២-ក្នុងការប្រកាសជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ នេះ ត្រូវសរសេរបន្ថែមថាម្ចាស់បំណុលនឹងត្រូវដកហូតចេញពីការជម្រះបញ្ជី បើខ្លួនពុំបង្ហាញសិទ្ធិលើបំណុលរបស់ខ្លួនក្នុងអំឡុងពេលដែលបានកំណត់នោះទេ ។

៣-អ្នកជម្រះបញ្ជីត្រូវដាស់តឿនដោយឡែកៗ ចំពោះម្ចាស់បំណុលដែលខ្លួនស្គាល់ឱ្យបង្ហាញសិទ្ធិលើបំណុល ។

៤-អ្នកជម្រះបញ្ជី ពុំអាចដកហូតម្ចាស់បំណុលដែលខ្លួនស្គាល់ចេញពីការជម្រះបញ្ជីបានឡើយ ។

មាត្រា ៧៤.- ការសងក្នុងអំឡុងពេលដើម្បីបង្ហាញសិទ្ធិលើបំណុល

១-អ្នកជម្រះបញ្ជីមិនអាចសងទៅម្ចាស់បំណុល ក្នុងអំឡុងពេលដើម្បីបង្ហាញសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងមាត្រា ៧៣ (ការប្រកាសជាសាធារណៈចំពោះម្ចាស់បំណុល)

នៃក្រមនេះបានឡើយ ។ ប៉ុន្តែ នីតិបុគ្គលមិនទទួលខុសត្រូវ ក្នុងការអនុវត្តយឺតយ៉ាវដោយសារហេតុនេះឡើយ ។

២-ទោះជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏អ្នកជម្រះបញ្ជីអាចសងសិទ្ធិលើបំណុលដែលមានចំនួនទឹកប្រាក់តិច សិទ្ធិលើបំណុលដែលភ្ជាប់នឹងប្រាតិភោគ និង សិទ្ធិលើបំណុលផ្សេងទៀតដែលពុំមានការបារម្ភថានឹងបង្កឱ្យមានការខូចខាតដល់ម្ចាស់បំណុលឯទៀតដោយការសងបានដែរ ដោយទទួលសេចក្តីអនុញ្ញាតពីតុលាការ ។

មាត្រា ៧៥.- ការសងចំពោះម្ចាស់បំណុលដែលត្រូវបានដកចេញ

ម្ចាស់បំណុលដែលត្រូវបានដកចេញពីការជម្រះបញ្ជី អាចទាមទារឱ្យសងបាន ចំពោះតែទ្រព្យសម្បត្តិដែលនៅសល់ ក្រោយពីការបែងចែកប៉ុណ្ណោះ ។

មាត្រា ៧៦.- ការសងសិទ្ធិលើបំណុល

១-នីតិបុគ្គលអាចសង នូវកាតព្វកិច្ចរបស់ខ្លួនបាន ទោះជាពុំទាន់ដល់ពេលកំណត់ត្រូវសងក៏ដោយ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ ចំពោះសិទ្ធិលើបំណុលដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌ សិទ្ធិលើបំណុលដែលរយៈពេលបន្តអត្ថិភាពមិនពិតប្រាកដ និងសិទ្ធិលើបំណុលផ្សេងទៀតដែលមិនកំណត់ចំនួនទឹកប្រាក់ពិតប្រាកដ នីតិបុគ្គលត្រូវសងតាមការវាយតម្លៃរបស់អ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការ ។

មាត្រា ៧៧.- ការចាត់ចែងទ្រព្យសម្បត្តិដែលនៅសល់

អ្នកជម្រះបញ្ជីមិនអាចចាត់ចែងទ្រព្យសម្បត្តិរបស់នីតិបុគ្គលដោយយោងតាមមាត្រា ៦៧ (ការបង្វែរទ្រព្យសម្បត្តិដែលនៅសល់) នៃក្រមនេះបានឡើយ បើមិនទាន់បានសងកាតព្វកិច្ចរបស់នីតិបុគ្គលហើយទេ ។ ប៉ុន្តែ ចំពោះកាតព្វកិច្ចដែលមានវិវាទវិញ អ្នកជម្រះបញ្ជីអាចចាត់ចែងផ្នែកនៃទ្រព្យសម្បត្តិដែលនៅសល់ ដោយទុកនូវទ្រព្យសម្បត្តិដែលទទួលស្គាល់ថា ចាំបាច់សម្រាប់សងនោះបាន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា ៧៨.- ធនក្ស័យនៅក្នុងពេលជម្រះបញ្ជី

១-នៅក្នុងពេលកំពុងជម្រះបញ្ជី បើបានដឹងច្បាស់ថា ទ្រព្យសម្បត្តិរបស់នីតិបុគ្គលនោះ ពុំគ្រប់គ្រាន់ក្នុងការសងកាតព្វកិច្ចទាំងអស់ទេ អ្នកជម្រះបញ្ជីត្រូវទាមទារការប្រកាសធនក្ស័យ ជាបន្ទាន់ ហើយត្រូវផ្សាយជាសាធារណៈនូវហេតុនេះ ក្នុងព្រឹត្តិបត្ររបស់ក្រសួងយុត្តិធម៌ ។

២-ភារកិច្ចរបស់អ្នកជម្រះបញ្ជីត្រូវចាត់ទុកថាបានបញ្ចប់ បើបានប្រគល់កិច្ចការនោះ ទៅឱ្យអ្នកគ្រប់គ្រងទ្រព្យធនក្ស័យហើយ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងមាត្រានេះ បើមានទ្រព្យសម្បត្តិណាដែលបាន សងទៅឱ្យម្ចាស់បំណុល ឬ បានប្រគល់ទៅឱ្យអ្នកដែលមានសិទ្ធិទទួលកម្មសិទ្ធិរួចហើយអ្នកគ្រប់ គ្រងទ្រព្យធនក្ស័យអាចយកទ្រព្យនោះមកវិញបាន ។

មាត្រា ៧៩.- ការបញ្ចប់ការជម្រះបញ្ជី

១-បើបានបញ្ចប់កិច្ចការជម្រះបញ្ជីរួចហើយ អ្នកជម្រះបញ្ជីត្រូវធ្វើរបាយការណ៍គណនី ទូទាត់ដោយគ្មានការយឺតយ៉ាវ ។

២-ចំពោះនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត អ្នកជម្រះបញ្ជីត្រូវដាក់របាយ-ការណ៍គណនីទូទាត់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ជូនទៅមហាសន្និបាត សមាជិក ដោយគ្មានការយឺតយ៉ាវ ហើយត្រូវទទួលការយល់ព្រមពីមហាសន្និបាតសមាជិកនោះ ។

៣-ចំពោះនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត អ្នកជម្រះបញ្ជីត្រូវដាក់របាយ-ការណ៍គណនីទូទាត់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ជូនទៅសមាជិកម្នាក់ៗ ដោយគ្មានការយឺតយ៉ាវ ហើយត្រូវទទួលការយល់ព្រមពីសមាជិកម្នាក់ៗនោះ ។

៤-ចំពោះនីតិបុគ្គលមូលនិធិ អ្នកជម្រះបញ្ជីត្រូវដាក់របាយការណ៍គណនីទូទាត់ដែល បានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ជូនទៅក្រសួង ឬ ស្ថាប័នដែលមានសមត្ថកិច្ចត្រួត ពិនិត្យ ដោយគ្មានការយឺតយ៉ាវ ហើយត្រូវទទួលការយល់ព្រមពីក្រសួង ឬ ស្ថាប័ននោះ ។

៥-អ្នកជម្រះបញ្ជីដែលត្រូវបានជ្រើសតាំងដោយតុលាការ ត្រូវដាក់របាយការណ៍គណនី ទូទាត់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះជូនទៅតុលាការ ដោយគ្មានការយឺត យ៉ាវ ។

ROYAUME DU CAMBODGE * LE MINISTERE DU PALAIS ROYAL *

មាត្រា ៨០.- ការចុះបញ្ជីអំពីការបញ្ចប់ការជម្រះបញ្ជី

បើបានបញ្ចប់នីតិវិធីដែលបានកំណត់នៅក្នុងមាត្រា ៧៩ (ការបញ្ចប់ការជម្រះបញ្ជី)នៃក្រមនេះរួចហើយ អ្នកជម្រះបញ្ជីត្រូវចុះបញ្ជីអំពីការបញ្ចប់ការជម្រះបញ្ជីនោះនៅទីតាំងនៃទីស្នាក់ការកណ្តាល ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ និង ត្រូវចុះនៅទីតាំងនៃទីស្នាក់ការឯទៀត ក្នុងអំឡុងពេល ៣ (បី) សប្តាហ៍ ។

មាត្រា ៨១.- ការរក្សាទុកឯកសារ

បញ្ជីគណនី និង ឯកសារសំខាន់ៗឯទៀតរបស់នីតិបុគ្គលដែលពាក់ព័ន្ធនឹងកិច្ចការ និង ការជម្រះបញ្ជី ត្រូវរក្សាទុក ក្នុងអំឡុងពេល ១០ (ដប់) ឆ្នាំ ក្រោយពីបានចុះបញ្ជីអំពីការបញ្ចប់ការជម្រះបញ្ជីនៅទីតាំងនៃទីស្នាក់ការកណ្តាល ។ អ្នករក្សាទុកឯកសារនោះ ត្រូវបានជ្រើសតាំងដោយតុលាការ តាមពាក្យសុំរបស់អ្នកជម្រះបញ្ជី ឬ បុគ្គលផ្សេងទៀត ដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ។

ផ្នែកទី ២
នីតិបុគ្គលសាជីវកម្ម

កថាភាគទី ១
នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត

មាត្រា ៨២.- ការបង្កើត និង លក្ខន្តិកៈ

១-ដើម្បីបង្កើតនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត បុគ្គលដែលមានបំណងធ្វើជាសមាជិកត្រូវសហការគ្នាបង្កើតលក្ខន្តិកៈ ហើយចុះហត្ថលេខារៀងៗខ្លួន ។

២-លក្ខន្តិកៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសរសេរនូវគ្រប់ចំណុចដូចខាងក្រោម :

ក-គោលបំណង ។

ខ-នាមករណ៍ ។

គ-ទីតាំងនៃទីស្នាក់ការកណ្តាល ។

ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL

ឃ-បញ្ញត្តិស្តីពីចំនួនទឹកប្រាក់សរុបនៃទ្រព្យសម្បត្តិជាមូលដ្ឋានដែលត្រូវធានាក្នុងនាមជានីតិបុគ្គល និង ទ្រព្យធនសកម្ម ។ ក្នុងករណីដែលមានវិភាគទានជាវត្ថុក្រៅពីប្រាក់ ត្រូវសរសេរនូវឈ្មោះ ឬ នាមករណ៍របស់បុគ្គលធ្វើវិភាគទានជាវត្ថុក្រៅពីប្រាក់ ឈ្មោះ និងតម្លៃនៃទ្រព្យសម្បត្តិនោះ ឬ ក្នុងករណីដែលបុគ្គលណាម្នាក់បានសន្យាថា នឹងធ្វើអនុប្បទានទ្រព្យសម្បត្តិណាមួយក្រោយពីការបង្កើតនីតិបុគ្គល ត្រូវសរសេរនូវតម្លៃ នៃទ្រព្យសម្បត្តិនោះ និង ឈ្មោះ ឬ នាមករណ៍របស់អនុប្បទាយី ឬ ត្រូវសរសេរនូវចំនួនប្រាក់នៃសោហ៊ុយដែលចំណាយក្នុងការបង្កើតនីតិបុគ្គល ហើយដែលនីតិបុគ្គលត្រូវទទួលបន្ទុក ។

ង-ឆ្នាំអនុវត្តកិច្ចការ ។

ច-ចំណុចស្តីពីអភិបាល អ្នកត្រួតពិនិត្យ និង អ្នកមានតួនាទីផ្សេងទៀត ។

ឆ-បញ្ញត្តិស្តីពីការទទួល និង ការបាត់បង់សមាជិកភាព ។

ជ-ចំណុចស្តីពីគណនេយ្យ ។

ឈ-ចំណុចស្តីពីការរំលាយ ។

ញ-ចំណុចស្តីពីការកែប្រែលក្ខន្តិកៈ ។

ដ-វិធីផ្សព្វផ្សាយជាសាធារណៈ ។

៣-លក្ខន្តិកៈពុំមានអានុភាពឡើយ បើពុំបានទទួលសេចក្តីបញ្ជាក់ពីសារការីទេ ។

៤-លក្ខន្តិកៈត្រូវរក្សាទុកនៅទីស្នាក់ការកណ្តាល និង ទីស្នាក់ការសាខា ។

មាត្រា ៨៣.- ចំនួនទឹកប្រាក់អប្បបរមានៃទ្រព្យសម្បត្តិជាមូលដ្ឋាន

នីតិបុគ្គលទទួលខុសត្រូវមានកម្រិត ត្រូវមានទ្រព្យសម្បត្តិជាមូលដ្ឋានដែលមានតម្លៃមិនតិចជាង ២០.០០០.០០០ (ម្ភៃលាន) រៀល ។

មាត្រា ៨៤.- ការជ្រើសតាំងអភិបាល និង អ្នកត្រួតពិនិត្យ

១-បើពុំបានកំណត់អភិបាល ឬ អ្នកត្រួតពិនិត្យនៅក្នុងលក្ខន្តិកៈ នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិតដែលកំពុងស្ថិតនៅក្នុងនីតិវិធីនៃការបង្កើត ត្រូវជ្រើសតាំងអភិបាល ឬ អ្នកត្រួតពិនិត្យ ដោយមហាសន្និបាតសមាជិក មុននឹងបង្កើតនីតិបុគ្គល ។

២-សមាជិកម្នាក់ៗអាចកោះប្រជុំមហាសន្និបាតដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១

ខាងលើនេះបាន ។

មាត្រា ៨៥.- ការស្រាវជ្រាវទ្រព្យសម្បត្តិជាមូលដ្ឋាន ជាអាទិ៍

១-អភិបាលត្រូវអញ្ជើញអ្នកដែលធ្វើវិភាគទានទ្រព្យសម្បត្តិជាមូលដ្ឋាន បែងចែកចំនួនដែលអ្នកនីមួយៗនោះត្រូវធ្វើវិភាគទាន ហើយទាមទារឱ្យអ្នកទាំងនោះធ្វើវិភាគទាន ដើម្បីធ្វើឱ្យមានទ្រព្យសម្បត្តិជាមូលដ្ឋានពេញលេញ ។

២-ក្នុងករណីដែលមានការសរសេរនូវចំណុចដែលបានកំណត់នៅវាក្យខណ្ឌទី ២ ចំណុច ឃ កថាខណ្ឌទី ២ នៃមាត្រា ៨២ (ការបង្កើត និង លក្ខន្តិកៈ) នៃក្រមនេះ នៅក្នុងលក្ខន្តិកៈអភិបាលត្រូវទាមទារឱ្យតុលាការជ្រើសតាំងអធិការ ដើម្បីស្រាវជ្រាវនូវចំណុចដែលបានសរសេរនោះ ដោយពុំមានការយឺតយ៉ាវ ។

៣-អធិការដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ត្រូវធ្វើសេចក្តីរាយការណ៍ទៅតុលាការអំពីលទ្ធផលនៃការស្រាវជ្រាវ ។

៤-ក្នុងករណីដែលតុលាការយល់ឃើញថា ការសរសេរនៅក្នុងលក្ខន្តិកៈនោះមិនត្រឹមត្រូវ ដោយយោងតាមលទ្ធផលនៃការស្រាវជ្រាវ តុលាការត្រូវចេញដីកាសម្រេចឱ្យផ្លាស់ប្តូរចំណុចនោះ ។ ក្នុងករណីនេះ តុលាការត្រូវជូនដំណឹងអំពីដីកាសម្រេចទៅសមាជិក អភិបាល ហើយបើមានការផ្លាស់ប្តូរចំណុចដែលពាក់ព័ន្ធនឹងវិភាគទានជាវត្ថុក្រៅពីប្រាក់ ត្រូវជូនដំណឹងទៅអ្នកដែលធ្វើវិភាគទានជាវត្ថុក្រៅពីប្រាក់នោះ ។

៥-អ្នកដែលធ្វើវិភាគទានជាវត្ថុក្រៅពីប្រាក់ដែលបានទទួលដំណឹងដូចបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ អាចលុបចោលនូវសកម្មភាពនៃវិភាគទានជាវត្ថុក្រៅពីប្រាក់ បានក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលដីកាសម្រេចនោះចូលជាស្ថាពរ ។ ក្នុងករណីនេះ នីតិបុគ្គលទទួលខុសត្រូវមានកម្រិតដែលកំពុងស្ថិតនៅក្នុងនីតិវិធីនៃការបង្កើត អាចបន្តនូវនីតិវិធីនៃការបង្កើតបាន ដោយផ្លាស់ប្តូរលក្ខន្តិកៈ ។

មាត្រា ៨៦.- ការស្រាវជ្រាវនីតិវិធីនៃការបង្កើត

១-អភិបាល និង អ្នកត្រួតពិនិត្យ ត្រូវស្រាវជ្រាវអំពីការកំណត់ជាស្ថាពរនូវអ្នកដែលត្រូវធ្វើវិភាគទានចំពោះតម្លៃសរុបនៃទ្រព្យសម្បត្តិជាមូលដ្ឋាន និងការប្រគល់ទាំងស្រុងនូវតាវកាលិក

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

នៃទ្រព្យសម្បត្តិដែលជាវិភាគទានជាវត្ថុក្រៅពីប្រាក់ ។

២-តាមលទ្ធផលនៃការស្រាវជ្រាវដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ នេះ បើយល់ឃើញថា មានការបំពានច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេង ឬ លក្ខន្តិកៈ ឬ មានចំណុចមិនត្រឹមត្រូវ អភិបាល ឬ អ្នកត្រួតពិនិត្យ ត្រូវធ្វើសេចក្ដីរាយការណ៍ទៅសមាជិក ។

មាត្រា ៨៧.- ចំណុចដែលត្រូវចុះបញ្ជី និង អំឡុងពេលចុះបញ្ជី

១-ក្រៅពីចំណុចដែលបានកំណត់នៅក្នុងមាត្រា ៥០(ចំណុចដែលត្រូវចុះបញ្ជី) នៃក្រមនេះ នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ត្រូវចុះបញ្ជីនូវគ្រប់ចំណុចដូចកំណត់ខាងក្រោមនេះ :

ក-តម្លៃសរុបនៃទ្រព្យសម្បត្តិជាមូលដ្ឋាន ។

ខ-បញ្ញត្តិស្ដីពីសិទ្ធិរបស់អ្នកដែលធ្វើវិភាគទានទ្រព្យសម្បត្តិជាមូលដ្ឋាន ។

គ-នីតិវិធីនៃការបង្វិលសងនូវទ្រព្យសម្បត្តិជាមូលដ្ឋាន ។

ឃ-វិធីផ្សព្វផ្សាយជាសាធារណៈ ។

២-ការចុះបញ្ជីបង្កើតនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ត្រូវធ្វើឡើងនៅទីតាំងនៃទីស្នាក់ការកណ្ដាល ក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ គិតចាប់ពីថ្ងៃដែលបានបញ្ចប់នីតិវិធី ដែលបានកំណត់នៅក្នុងមាត្រា ៨៥(ការស្រាវជ្រាវទ្រព្យសម្បត្តិជាមូលដ្ឋាន ជាអាទិ៍) និងមាត្រា ៨៦(ការស្រាវជ្រាវនីតិវិធីនៃការបង្កើត) នៃក្រមនេះ ។

៣-នៅទីតាំងនៃទីស្នាក់ការសាខា ការចុះបញ្ជីត្រូវធ្វើឡើង ក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ គិតពីថ្ងៃដែលបានចុះបញ្ជី តាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ។

មាត្រា ៨៨.- ការទទួលខុសត្រូវក្នុងការធានាអំពីវិភាគទានទ្រព្យសម្បត្តិជាមូលដ្ឋាន

១-នៅពេលបង្កើតនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត បើមានផ្នែកខ្លះពុំទាន់បានសម្រេចជាស្ថាពរអំពីការកំណត់អ្នកដែលត្រូវធ្វើវិភាគទាន ក្នុងតម្លៃសរុបនៃទ្រព្យសម្បត្តិជាមូលដ្ឋាន ត្រូវចាត់ទុកថា អភិបាល និងសមាជិកនៃនីតិបុគ្គល នាពេលបង្កើតនីតិបុគ្គលនោះ ជាអ្នកដែលត្រូវធ្វើវិភាគទានដោយរួមគ្នា ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះផលវិបាកដែលសកម្មភាពនៃវិភាគទានទ្រព្យសម្បត្តិជាមូលដ្ឋានរបស់អ្នកដែលធ្វើវិភាគទានទ្រព្យ

សម្បត្តិជាមូលដ្ឋាន ត្រូវបានលុបចោលក្រោយការបង្កើតនីតិបុគ្គល ។

២-នៅពេលបង្កើតនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត បើមានទ្រព្យសម្បត្តិជាមូលដ្ឋានដែលមិនទាន់បានបង់ ឬ ពុំទាន់បានផ្តល់តាវកាលិកនៃទ្រព្យសម្បត្តិ ដែលជាវិភាគទានជាវត្ថុក្រៅពីប្រាក់ អភិបាល និង សមាជិកនៃនីតិបុគ្គលនាពេលបង្កើតនោះ ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពក្នុងការសងចំនួនប្រាក់ដែលមិនទាន់បានបង់នោះ ឬ តម្លៃនៃទ្រព្យសម្បត្តិដែលជាវិភាគទានជាវត្ថុក្រៅពីប្រាក់ដែលពុំទាន់បានផ្តល់នោះ ។

៣-នៅពេលបង្កើតនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត បើតម្លៃនៃទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ ចំណុច ឃ នៃមាត្រា ៨២ (ការបង្កើត និង លក្ខន្តិកៈ) នៃក្រមនេះ មិនគ្រប់គ្រាន់យ៉ាងខ្លាំងធៀបនឹងតម្លៃដែលបានចុះនៅក្នុងលក្ខន្តិកៈអភិបាល និង សមាជិកនៃនីតិបុគ្គលនាពេលបង្កើតនោះ ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពក្នុងការសងតម្លៃដែលខ្វះខាតចំពោះនីតិបុគ្គលនោះ ។ ប៉ុន្តែក្នុងករណីដែលបានឆ្លងកាត់តាមការស្រាវជ្រាវរបស់អធិការ ដោយយោងតាមបញ្ញត្តិនៃមាត្រា ៨៥ (ការស្រាវជ្រាវទ្រព្យសម្បត្តិជាមូលដ្ឋាន ជាអាទិ៍) នៃក្រមនេះ អភិបាល និង សមាជិកនោះ ត្រូវរួចផុតពីការទទួលខុសត្រូវ លើកលែងតែខ្លួនជាអ្នកដែលត្រូវធ្វើវិភាគទានជាវត្ថុក្រៅពីប្រាក់ ឬ អនុប្បទាយីនៃទ្រព្យសម្បត្តិនោះ ។

មាត្រា ៨៩.- សិទ្ធិ និង ករណីយកិច្ចរបស់សមាជិក

១-សមាជិកមានករណីយកិច្ចបង់សោហ៊ុយចំណាយរបស់នីតិបុគ្គល ។

២-សមាជិកអាចប្រើសិទ្ធិបោះឆ្នោតក្នុងមហាសន្និបាតសមាជិកបាន ។ ប៉ុន្តែ សមាជិកពុំអាចប្រើសិទ្ធិបោះឆ្នោតបានឡើយ ក្នុងករណីដែលសេចក្តីសម្រេចត្រូវធ្វើឡើងចំពោះទំនាក់ទំនងរវាងសមាជិកនោះ និង នីតិបុគ្គល ។

៣-សិទ្ធិបោះឆ្នោតរបស់សមាជិកមានតែមួយសំឡេង ។ ប៉ុន្តែ អាចកំណត់ផ្សេងនៅក្នុងលក្ខន្តិកៈ ដោយគិតពិចារណាអំពីចំនួនប្រាក់នៃវិភាគទានបាន ។

៤-សមាជិកដែលមិនបានចូលរួមក្នុងមហាសន្និបាតសមាជិក ត្រូវបោះឆ្នោតដោយលិខិតជាលាយល័ក្ខណ៍អក្សរ ឬ ដោយអ្នកតំណាង ។ ប៉ុន្តែ បើមានការកំណត់ផ្សេង នៅក្នុងលក្ខន្តិកៈ ត្រូវអនុវត្តតាមការកំណត់នោះ ។

មាត្រា ៩០.- ការបាត់បង់សមាជិកភាព

១-សមាជិកអាចលាឈប់នៅពេលណាក៏បាន ។ ប៉ុន្តែ បើមានកំណត់ក្នុងលក្ខន្តិកៈដែលតម្រូវឱ្យសមាជិកដែលមានបំណងលាឈប់ ផ្តល់ដំណឹងជាមុនទៅនីតិបុគ្គល មុនអំឡុងពេលដែលត្រូវកំណត់មុនពេលលាឈប់ សមាជិកនោះ ត្រូវផ្តល់ដំណឹងនេះ លើកលែងតែមានហេតុដែលពុំអាចជៀសវាងបាន ។

២-អំឡុងពេលដើម្បីផ្តល់ដំណឹងជាមុនដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវលើសពី ១ (មួយ) ឆ្នាំ ឡើយ ។

៣-ក្រៅពីករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ សមាជិកត្រូវបាត់បង់សមាជិកភាព ដោយហេតុដូចខាងក្រោមនេះ :

ក-ហេតុដែលបានកំណត់នៅក្នុងលក្ខន្តិកៈបានកើតឡើង ។

ខ-មតិយល់ស្របពីសមាជិកទាំងអស់ ។

គ-មរណភាព ឬ ការរំលាយ ។

ឃ-ការលុបឈ្មោះ ។

មាត្រា ៩១.- ការលុបឈ្មោះ

១-ការលុបឈ្មោះសមាជិក អាចធ្វើដោយសេចក្តីសម្រេចនៃមហាសន្និបាតសមាជិក បានលុះត្រាតែមានហេតុត្រឹមត្រូវ ។ ក្នុងករណីនេះ នីតិបុគ្គលត្រូវជូនដំណឹងអំពីហេតុនោះ យ៉ាងតិច ១ (មួយ) សប្តាហ៍ មុនថ្ងៃបើកមហាសន្និបាតដល់សមាជិកនោះ ហើយត្រូវផ្តល់នូវឱកាសដើម្បីធ្វើសេចក្តីដោះសារចំពោះមុខអង្គមហាសន្និបាតសមាជិកនោះ ។

២-ដើម្បីសម្រេចសេចក្តីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវមានសំឡេងចាប់ពីពាក់កណ្តាលឡើងទៅ នៃចំនួនសមាជិកទាំងអស់ ហើយត្រូវមានមតិយល់ស្របចាប់ពី ៣ ភាគ ៤ (បីភាគបួន) ឡើងទៅនៃសិទ្ធិសម្រេចរបស់សមាជិកទាំងអស់ ។

៣-ការលុបឈ្មោះ ពុំមានអានុភាពឡើយ បើមិនបានជូនដំណឹងទៅដល់សមាជិកដែលត្រូវបានលុបឈ្មោះនោះ ។

ROYAUME du CAMBODGE
LE MINISTRE du PALAIS ROYAL

មាត្រា ៩២.- មហាសន្និបាតសាមញ្ញ

អភិបាលត្រូវបើកមហាសន្និបាតសាមញ្ញនៃសមាជិក យ៉ាងតិច ១ (មួយ)ដង ក្នុង ១ (មួយ) ឆ្នាំ ។

មាត្រា ៩៣.- មហាសន្និបាតវិសាមញ្ញ

១-បើយល់ឃើញថាចាំបាច់ អភិបាលអាចកោះប្រជុំមហាសន្និបាតវិសាមញ្ញនៃសមាជិក នៅពេលណាក៏បាន ។

២-ក្នុងករណីដែលសមាជិកដែលមានសិទ្ធិសម្រេចចាប់ពី ១ ភាគ ១០ (មួយភាគដប់) ឡើងទៅនៃចំនួនសិទ្ធិសម្រេចរបស់សមាជិកទាំងអស់ ទាមទារឱ្យបើកមហាសន្និបាត ដោយបង្ហាញនូវគោលបំណងនៃការប្រជុំនោះ អភិបាលត្រូវកោះប្រជុំមហាសន្និបាតវិសាមញ្ញ ។ ប៉ុន្តែក្នុងករណីដែលមានការកំណត់ផ្សេងអំពីកូរ៉ុមនៅក្នុងលក្ខន្តិកៈ ត្រូវអនុវត្តតាមការកំណត់នោះ ។

៣-ទោះជាមានការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះក៏ដោយ ក្នុងករណីដែលអភិបាលបានធ្វេសប្រហែសក្នុងការកោះប្រជុំមហាសន្និបាតដោយគ្មានការយឺតយ៉ាវទេ សមាជិកដែលបានទាមទារនោះ អាចកោះប្រជុំមហាសន្និបាតបាន ដោយទទួលសេចក្តីអនុញ្ញាតពីតុលាការ ។

មាត្រា ៩៤.- ការកោះប្រជុំមហាសន្និបាត

១-ដើម្បីកោះប្រជុំមហាសន្និបាតរបស់សមាជិក ត្រូវជូនដំណឹងអំពីមហាសន្និបាត នោះ ដល់សមាជិកម្នាក់ៗ យ៉ាងតិច ១ (មួយ) សប្តាហ៍ មុនការបើកមហាសន្និបាតនោះ ។ ប៉ុន្តែអំឡុងពេលនេះអាចបង្រួញឱ្យខ្លីបាន អាស្រ័យដោយលក្ខន្តិកៈ ។

២-បើមានមតិយល់ស្របពីសមាជិកទាំងអស់ មហាសន្និបាតរបស់សមាជិក អាចត្រូវបានបើកដោយមិនឆ្លងកាត់តាមនីតិវិធីកោះប្រជុំ ។

មាត្រា ៩៥.- សិទ្ធិអំណាចនៃមហាសន្និបាត

១-មហាសន្និបាតសមាជិក អាចធ្វើសេចក្តីសម្រេចបាន ត្រឹមតែចំណុចដែលបានកំណត់នៅក្នុងក្រមនេះ ឬ លក្ខន្តិកៈ ។

២-អភិបាល និង អ្នកត្រួតពិនិត្យ ត្រូវពន្យល់នូវចំណុចដែលសមាជិកបានទាមទារ នៅក្នុងមហាសន្និបាតសមាជិក ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលចំណុចនោះពុំមានទំនាក់ទំនងនឹងចំណុចដែលជាគោលបំណងនៃអង្គប្រជុំ ករណីដែលការពន្យល់នោះអាចបណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់ផលប្រយោជន៍របស់សមាជិក ករណីដែលការពន្យល់នោះតម្រូវឱ្យមានការស្រាវជ្រាវ ឬ ករណីផ្សេងទៀតដែលមានមូលហេតុត្រឹមត្រូវ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បើសមាជិកបានជូនដំណឹងអំពីចំណុចដែលត្រូវពន្យល់ នៅក្នុងមហាសន្និបាត ជាលិខិតលាយលក្ខណ៍អក្សរមុនអំឡុងពេលសមរម្យមួយ មុនថ្ងៃបើកមហាសន្និបាតសមាជិកនោះ អភិបាល និងអ្នកត្រួតពិនិត្យមិនអាចបដិសេធការពន្យល់ ដោយយកមូលហេតុថា ការពន្យល់នោះ តម្រូវឱ្យមានការស្រាវជ្រាវបានឡើយ ។

មាត្រា ៩៦.- ចំណុចដែលមហាសន្និបាតអាចសម្រេចបាន

មហាសន្និបាតសមាជិកអាចសម្រេច តែចំណុចដែលត្រូវបានជូនដំណឹងជាមុន ដោយយោងទៅតាមបញ្ញត្តិនៃមាត្រា ៩៤ (ការកោះប្រជុំមហាសន្និបាត) នៃក្រមនេះប៉ុណ្ណោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានការកំណត់ផ្សេងនៅក្នុងលក្ខន្តិកៈ ។

មាត្រា ៩៧.- ការកែប្រែលក្ខន្តិកៈ

១-លក្ខន្តិកៈរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិតអាចកែប្រែបាន លុះត្រាតែមានសេចក្តីយល់ព្រមពីចំនួនចាប់ពី ៣ ភាគ ៤ (បីភាគបួន) ឡើងទៅ នៃសិទ្ធិសម្រេចរបស់សមាជិកទាំងអស់ ។ ប៉ុន្តែ បើមានការកំណត់ផ្សេងនៅក្នុងលក្ខន្តិកៈ ត្រូវអនុវត្តតាមការកំណត់នោះ ។

២-ការកែប្រែលក្ខន្តិកៈពុំមានអានុភាពឡើយ បើពុំបានទទួលសេចក្តីបញ្ជាក់ពីសារការី ។

មាត្រា ៩៨.- ការធ្វើ និង ការយល់ព្រមលើឯកសារគណនេយ្យ ជាអាទិ៍

១-រាល់ឆ្នាំអនុវត្តកិច្ចការ អភិបាលត្រូវធ្វើឯកសារដែលបានកំណត់ដូចខាងក្រោមនេះ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

និង ឯកសារលំអិតភ្ជាប់ជាមួយ ដែលសរសេរអំពីហេតុសំខាន់ដើម្បីពន្យល់បន្ថែម ទៅលើការសរសេរនៅក្នុងឯកសារនោះ :

ក-តារាងតុល្យការ ។

ខ-របាយការណ៍ចំណេញខាត ។

គ-របាយការណ៍អំពីកិច្ចការ ។

ឃ-សេចក្តីព្រាងនៃសេចក្តីសម្រេចអំពីការចាត់ចែងប្រាក់ដែលនៅសល់ ឬ ដំណោះស្រាយចំពោះការខាតបង់ ។

២-អភិបាលត្រូវដាក់ជូនមហាសន្និបាតសាមញ្ញ នូវឯកសារដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ១ ខាងលើនេះ ហើយចំពោះឯកសារដែលបានកំណត់នៅក្នុងចំណុច គ ត្រូវរាយការណ៍អំពីខ្លឹមសារនោះរីឯឯកសារដែលបានកំណត់នៅក្នុងចំណុច ក ចំណុច ខ និង ចំណុច ឃ ត្រូវទទួលការយល់ព្រមពីមហាសន្និបាត ។

មាត្រា ៩៩.- ការត្រួតពិនិត្យឯកសារគណនា ជាអាទិ៍

១-អភិបាលត្រូវទទួលការត្រួតពិនិត្យដោយអ្នកត្រួតពិនិត្យ ទៅលើឯកសារដែលបានកំណត់នៅក្នុងចំណុចនីមួយៗ នៃកថាខណ្ឌទី ១ នៃមាត្រា ៩៨(ការធ្វើ និង ការយល់ព្រមលើឯកសារគណនា ជាអាទិ៍) នៃក្រមនេះ ។

២-ការត្រួតពិនិត្យដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើង មុនមហាសន្និបាតសាមញ្ញរបស់សមាជិក ។

៣-អភិបាលត្រូវដាក់ជូនអ្នកត្រួតពិនិត្យ នូវឯកសារដែលបានកំណត់នៅក្នុងចំណុចនីមួយៗ នៃកថាខណ្ឌទី ១ មាត្រា ៩៨ (ការធ្វើ និង ការយល់ព្រមលើឯកសារគណនា ជាអាទិ៍)នៃក្រមនេះ យ៉ាងតិច ៥ (ប្រាំ) សប្តាហ៍មុន ហើយត្រូវដាក់ឯកសារលំអិតភ្ជាប់ជាមួយយ៉ាងតិច ៣ (បី) សប្តាហ៍ មុនការចាប់ផ្តើមការត្រួតពិនិត្យរបស់អ្នកត្រួតពិនិត្យ ។

៤-អ្នកត្រួតពិនិត្យត្រូវដាក់ជូនអភិបាលនូវរបាយការណ៍នៃការត្រួតពិនិត្យ ក្នុងអំឡុងពេល ៤ (បួន) សប្តាហ៍ គិតពីថ្ងៃដែលខ្លួនបានទទួលឯកសារដែលបានកំណត់នៅកថាខណ្ឌទី ៣ ខាងលើនេះ ដោយមិនរាប់បញ្ចូលនូវឯកសារលំអិតភ្ជាប់ជាមួយ ។

មាត្រា ១០០.- ការបង្ហាញជាសាធារណៈនូវឯកសារគណនេយ្យ ជាអាទិ៍

១-នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ត្រូវរក្សាទុកឯកសារដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ១ មាត្រា ៩៨ (ការធ្វើ និង ការយល់ព្រមលើឯកសារគណនេយ្យជាអាទិ៍) នៃក្រមនេះ និង របាយការណ៍នៃការត្រួតពិនិត្យក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ ចាប់ពីពេលដែលរបាយការណ៍នៃការត្រួតពិនិត្យនោះត្រូវបានដាក់ជូនអភិបាល នៅទីស្នាក់ការកណ្តាល ហើយត្រូវរក្សាទុកច្បាប់ចម្លងនៃឯកសារទាំងនោះ ក្នុងអំឡុងពេល ៣ (បី) ឆ្នាំ នៅទីស្នាក់ការសាខា ។

២-សមាជិក និង ម្ចាស់បំណុលរបស់នីតិបុគ្គល អាចទាមទារមើលឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ឬ ទាមទារឱ្យប្រគល់ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬ ឯកសារដកស្រង់នៃឯកសារទាំងនោះពីនីតិបុគ្គលនោះ នៅក្នុងម៉ោងធ្វើការរបស់នីតិបុគ្គលនោះបាន ។ ប៉ុន្តែ ក្នុងករណីដែលទាមទារឱ្យប្រគល់ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬ ឯកសារដកស្រង់ អ្នកទាមទារត្រូវបង់សោហ៊ុយដែលបានកំណត់ដោយនីតិបុគ្គលនោះ ។

កថាភាគទី ២

នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត

មាត្រា ១០១.- ការបង្កើត និងលក្ខន្តិកៈ

១-ដើម្បីបង្កើតនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត បុគ្គលដែលមានបំណងធ្វើជាសមាជិកត្រូវសហការគ្នាបង្កើតលក្ខន្តិកៈ ហើយចុះហត្ថលេខារៀងៗខ្លួន ។

២-លក្ខន្តិកៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសរសេរនូវគ្រប់ចំណុចដូចខាងក្រោមនេះ :

ក-គោលបំណង ។

ខ-នាមករណ៍ ។

គ-នាម និង លំនៅឋានរបស់សមាជិក ។

ឃ-ទីតាំងនៃទីស្នាក់ការកណ្តាល និង ទីស្នាក់ការសាខា ។

៣-លក្ខន្តិកៈពុំមានអានុភាពឡើយ បើពុំបានទទួលសេចក្តីបញ្ជាក់ពីសារការី ។

ROYAUME DU CAMBODGE * LE MINISTÈRE DU PALAIS ROYAL *

៤-លក្ខន្តិកៈត្រូវរក្សាទុកនៅទីស្នាក់ការកណ្តាល និង ទីស្នាក់ការសាខា ។

មាត្រា ១០២.- ចំណុចដែលត្រូវចុះបញ្ជី និង អំឡុងពេលចុះបញ្ជី

១-ក្រៅពីចំណុចដែលបញ្ញត្តិនៅក្នុងមាត្រា ៥០(ចំណុចដែលត្រូវចុះបញ្ជី) នៃក្រមនេះ នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ត្រូវចុះបញ្ជីនៅទីតាំងនៃទីស្នាក់ការកណ្តាលនូវគ្រប់ចំណុចដូចកំណត់ខាងក្រោមនេះ :

ក-នាមសមាជិកដែលធ្វើតំណាងឱ្យនីតិបុគ្គល ក្នុងករណីដែលមានសមាជិកខ្លះពុំធ្វើជាតំណាងឱ្យនីតិបុគ្គលនោះ ។

ខ-សេចក្តីកំណត់ ក្នុងករណីដែលមានការកំណត់ថា សមាជិកច្រើនរូបធ្វើតំណាងឱ្យនីតិបុគ្គលនោះ ។

២-នៅទីតាំងនៃទីស្នាក់ការសាខា ការចុះបញ្ជីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើង ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ គិតពីថ្ងៃដែលបានចុះបញ្ជី តាមបញ្ញត្តិនៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

មាត្រា ១០៣.- ការទទួលខុសត្រូវរបស់សមាជិក ជាអាទិ៍

១-បើនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិតពុំអាចសងគ្រប់នូវកាតព្វកិច្ចដោយទ្រព្យសម្បត្តិរបស់ខ្លួនទេ សមាជិកត្រូវទទួលខុសត្រូវក្នុងការសងដោយសាមគ្គីភាព ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលការអនុវត្តដោយបង្ខំចំពោះទ្រព្យសម្បត្តិរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិតពុំមានប្រសិទ្ធភាព ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសមាជិកបានបញ្ជាក់ថា នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត នោះមានសាធនភាព ហើយការអនុវត្តដោយបង្ខំអាចធ្វើឡើងចំពោះនីតិបុគ្គលនោះដោយងាយស្រួល ។

៤-សមាជិកអាចតតាំងជាមួយនឹងម្ចាស់បំណុលរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ដោយយកការតវ៉ាដែលនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិតនោះមានចំពោះម្ចាស់បំណុលនោះបាន ។

៥-នៅក្នុងករណីដែលនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត មានសិទ្ធិទូទាត់ សិទ្ធិលុបចោល សិទ្ធិរំលាយ ចំពោះម្ចាស់បំណុលរបស់ខ្លួន សមាជិករបស់នីតិបុគ្គលនោះអាចបដិសេធមិនអនុវត្តកាតព្វកិច្ចចំពោះម្ចាស់បំណុលនោះបាន ។

៦-សមាជិកដែលបានចូលរួមក្រោយការបង្កើតនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់នីតិបុគ្គលដែលបានកើតឡើងនៅមុនពេលសមាជិកនោះបានចូលរួមផងដែរ ។

៧-សមាជិកដែលបានលាឈប់ ត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់នីតិបុគ្គលដែលបានកើតឡើង នៅមុនពេលដែលសមាជិកនោះបានចុះបញ្ជីអំពីការលាឈប់ នៅទីតាំងនៃទីស្នាក់ការកណ្តាលនៃនីតិបុគ្គលនោះ ។

៨-បើអំឡុងពេល ២ (ពីរ) ឆ្នាំកន្លងហួស ក្រោយពីការចុះបញ្ជីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៧ ខាងលើនេះ ការទទួលខុសត្រូវដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៧ នោះត្រូវរលត់ ចំពោះម្ចាស់បំណុលរបស់នីតិបុគ្គលដែលមិនបានទាមទារ ឬ មិនបានជូនដំណឹងជាមុនអំពីការទាមទារ ក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ ក្រោយពីការចុះបញ្ជីនោះ ។

៩-សមាជិកត្រូវទទួលបន្ទុកនូវសោហ៊ុយចំណាយរបស់នីតិបុគ្គល ដោយអនុលោមតាមការកំណត់នៅក្នុងលក្ខន្តិកៈ ។

មាត្រា ១០៩.- ការបាត់បង់សមាជិកភាព

១-សមាជិកអាចលាឈប់នៅពេលណាក៏បាន លើកលែងតែមានការកំណត់នៅក្នុងលក្ខន្តិកៈ ។

២-ទោះជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏សមាជិកអាចលាឈប់នៅពេលណាក៏បានដែរ បើមានហេតុដែលពុំអាចជៀសវាងបាន ។

៣-ក្រៅពីករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ សមាជិកត្រូវបាត់បង់សមាជិកភាព ដោយហេតុដូចខាងក្រោមនេះ :

ក-ហេតុដែលបានកំណត់នៅក្នុងលក្ខន្តិកៈបានកើតឡើង ។

ខ-មតិយល់ស្របពីសមាជិកទាំងអស់ ។

ROYAUME du CAMBODGE · LE MINISTRE du PALAIS ROYAL

គ-ការលុបឈ្មោះ ។

ឃ-មរណភាព ។

ង-ធនក្ស័យ ។

ច-ការទទួលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ ។

មាត្រា ១០៥.- ការលុបឈ្មោះ

ការលុបឈ្មោះសមាជិក អាចធ្វើដោយមតិឯកច្ឆន្ទរបស់សមាជិកឯទៀតបាន លុះត្រាតែមានមូលហេតុត្រឹមត្រូវ ។ ប៉ុន្តែ ការលុបឈ្មោះមិនមានអានុភាពឡើយ បើមិនបានជូនដំណឹងអំពីហេតុនោះដល់សមាជិកដែលត្រូវបានលុបឈ្មោះនោះទេ ។

មាត្រា ១០៦.- ការអនុវត្តកិច្ចការ

១-សមាជិកត្រូវអនុវត្តកិច្ចការរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ។

២-កិច្ចការរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ត្រូវអនុលោមតាមសេចក្តីសម្រេចដោយផ្អែកលើមតិលើសពីពាក់កណ្តាលនៃចំនួនសមាជិក លើកលែងតែមានការកំណត់ផ្សេងនៅក្នុងលក្ខន្តិកៈ ។

៣-ក្នុងករណីមានកំណត់នៅក្នុងលក្ខន្តិកៈ អំពីសមាជិកដែលត្រូវអនុវត្តកិច្ចការរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត សមាជិកដែលបានកំណត់នោះត្រូវអនុវត្តកិច្ចការរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិតនោះ ។

៤-បើសមាជិកដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ មានចំនួនច្រើនរូប កិច្ចការរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ត្រូវអនុលោមតាមសេចក្តីសម្រេចដោយផ្អែកលើមតិលើសពីពាក់កណ្តាលរបស់សមាជិកនោះ លើកលែងតែមានការកំណត់ផ្សេងនៅក្នុងលក្ខន្តិកៈ ។

៥-ទោះជាមានបញ្ញត្តិនៃកថាខណ្ឌទី ២ និង កថាខណ្ឌទី ៤ ខាងលើនេះក៏ដោយ កិច្ចការប្រចាំថ្ងៃរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត អាចអនុវត្តដោយសមាជិកគ្រប់ៗរូប ។ ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ មានតែសមាជិកដែលបានកំណត់នៅក្នុងកថាខណ្ឌនោះទេ ដែលអាចអនុវត្តកិច្ចការប្រចាំថ្ងៃបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិន ,

ត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសមាជិកផ្សេង តវ៉ាអំពីការអនុវត្តកិច្ចការប្រចាំថ្ងៃ មុននឹងកិច្ចការនោះត្រូវបានបញ្ចប់ ។

មាត្រា ១០៧.- តំណាងនៃនីតិបុគ្គល

១-សមាជិកត្រូវតំណាងឱ្យនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ។ ប៉ុន្តែក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រា ១០៦ (ការអនុវត្តកិច្ចការ) នៃក្រមនេះ មានតែសមាជិកដែលបានកំណត់នៅក្នុងកថាខណ្ឌនោះ ដែលត្រូវតំណាងឱ្យនីតិបុគ្គល ។

២-បើមានសមាជិកច្រើននាក់ដែលត្រូវតំណាងឱ្យនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ សមាជិកម្នាក់ៗនោះ ត្រូវតំណាងឱ្យនីតិបុគ្គលនោះដោយឡែកៗខ្លួន ។ ប៉ុន្តែ នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត អាចកំណត់ជាពិសេសនូវអ្នកដែលត្រូវតំណាងឱ្យនីតិបុគ្គល ក្នុងចំណោមសមាជិកទាំងនោះ ដោយយោងតាមលក្ខន្តិកៈ ឬ តាមមតិយល់ស្របនៃសមាជិកទាំងអស់បាន ។

៣-បញ្ញត្តិស្តីពីអភិបាលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសមាជិកដែលត្រូវតំណាងឱ្យនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ។

មាត្រា ១០៨.- ការរាយការណ៍ និង ការស្រាវជ្រាវ

១-សមាជិកអាចទាមទារឱ្យសមាជិកឯទៀត ធ្វើសេចក្តីរាយការណ៍អំពីស្ថានភាពនៃការអនុវត្តកិច្ចការ ឬ អាចស្រាវជ្រាវនូវស្ថានភាពនៃកិច្ចការ និង ទ្រព្យសម្បត្តិរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិតបាន ។ ប៉ុន្តែ ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រា ១០៦(ការអនុវត្តកិច្ចការ) នៃក្រមនេះ សមាជិកអាចទាមទារចំពោះតែសមាជិកដែលបានកំណត់នៅក្នុងកថាខណ្ឌនោះ ឱ្យធ្វើសេចក្តីរាយការណ៍ ឬ អាចស្រាវជ្រាវបាន ។

២-ក្នុងករណីដែលសមាជិកផ្សេងទៀតបានធ្វើសកម្មភាពក្រៅពីគោលបំណងរបស់នីតិបុគ្គល ឬ សកម្មភាពផ្សេងទៀតដែលផ្ទុយនឹងច្បាប់ ឬ បទដ្ឋានគតិយុត្ត ឬ លក្ខន្តិកៈ ឬ មានការបារម្ភថា សមាជិកនោះនឹងធ្វើសកម្មភាពនោះ ហើយបើមានការបារម្ភថា សកម្មភាពនោះអាចបណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់នីតិបុគ្គល សមាជិកអាចទាមទារឱ្យសមាជិកផ្សេងនោះបញ្ឈប់នូវសកម្មភាពបាន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · Conforme

៣-ក្នុងករណីដែលមានអ្នកត្រួតពិនិត្យ កិច្ចការដែលបានកំណត់នៅក្នុងកថាខណ្ឌ ទី ១ និងទី ២ ខាងលើនេះ ត្រូវបានធ្វើឡើងដោយអ្នកត្រួតពិនិត្យ ។

មាត្រា ១០៩.- ការកែប្រែលក្ខន្តិកៈ

១-ដើម្បីកែប្រែលក្ខន្តិកៈ ត្រូវមានមតិយល់ស្របពីសមាជិកទាំងអស់ ។

២-ទោះជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បើមានកំណត់នៅក្នុងលក្ខន្តិកៈថា លក្ខន្តិកៈអាចកែប្រែបាន ដោយមានការយល់ព្រមលើសពីអត្រាណាមួយ ដែលបានកំណត់ក្នុងចំណោមសមាជិកទាំងអស់ ត្រូវអនុលោមតាមការកំណត់នោះ ។

៣-លក្ខន្តិកៈដែលត្រូវបានកែប្រែ ពុំមានអានុភាពឡើយ បើពុំបានទទួលសេចក្តីបញ្ជាក់ពីសារការី ។

ផ្នែកទី ៣

នីតិបុគ្គលមូលនិធិ

មាត្រា ១១០.- ការបង្កើត និង លក្ខន្តិកៈ

១-នីតិបុគ្គលមូលនិធិ អាចត្រូវបានបង្កើតឡើង ដោយធ្វើលក្ខន្តិកៈ និង ទទួលការអនុញ្ញាតពីសំណាក់ស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យ លុះត្រាតែមានគោលបំណងដើម្បីផ្តល់ប្រយោជន៍សាធារណៈ ។

២-លក្ខន្តិកៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក-គោលបំណង ។

ខ-នាមករណ៍ ។

គ-ទីតាំងនៃទីស្នាក់ការកណ្តាល ។

ឃ-បញ្ញត្តិស្តីពីចំនួនទឹកប្រាក់សរុបនៃទ្រព្យសម្បត្តិជាមូលដ្ឋាន និង ទ្រព្យធនសកម្ម ។ ក្នុងករណីដែលមានវិភាគទានជាវត្ថុក្រៅពីប្រាក់ ត្រូវសរសេរនូវឈ្មោះ និង តម្លៃនៃទ្រព្យសម្បត្តិនោះ ។ ក្នុងករណីដែលបុគ្គលណាបានសន្យាថា នឹងធ្វើអនុប្បទានទ្រព្យសម្បត្តិណាមួយក្រោយពីការបង្កើតនីតិបុគ្គល ត្រូវសរសេរនូវតម្លៃនៃទ្រព្យសម្បត្តិនោះ និង ឈ្មោះ ឬ នាមករណ៍របស់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

អនុប្បទាយី ឬ ត្រូវសរសេរនូវចំនួនប្រាក់នៃសោហ៊ុយសម្រាប់ការបង្កើតដែលនីតិបុគ្គលត្រូវទទួលបន្ទុក ។

ង-ឆ្នាំអនុវត្តកិច្ចការ ។

ច-ចំណុចស្តីពីអភិបាល អ្នកត្រួតពិនិត្យ និង អ្នកមានតួនាទីផ្សេងទៀត ។

ឆ-ចំណុចស្តីពីគណនេយ្យ ។

ជ-ចំណុចស្តីពីការរំលាយ ។

ឈ-ចំណុចស្តីពីការកែប្រែលក្ខន្តិកៈ ។

ញ-វិធីផ្សព្វផ្សាយជាសាធារណៈ ។

៣-លក្ខន្តិកៈពុំមានអានុភាពឡើយ បើពុំបានទទួលសេចក្តីបញ្ជាក់ពីសារការី ។

៤-លក្ខន្តិកៈត្រូវរក្សាទុកនៅទីតាំងនៃទីស្នាក់ការកណ្តាល និង ទីស្នាក់ការសាខា ។

មាត្រា ១១១.- ចំនួនទឹកប្រាក់អប្បបរមានៃទ្រព្យសម្បត្តិជាមូលដ្ឋាន

នីតិបុគ្គលមូលនិធិ ត្រូវមានទ្រព្យសម្បត្តិជាមូលដ្ឋានដែលមានតម្លៃមិនតិចជាង ២០០.០០០.០០០ (ពីររយលាន) រៀល ។

មាត្រា ១១២.- ការបំពេញបន្ថែមលក្ខន្តិកៈ

ក្នុងករណីដែលអ្នកបង្កើតនីតិបុគ្គលមូលនិធិបានទទួលមរណភាពដោយមិនទាន់បានកំណត់នាមករណ៍ ទីស្នាក់ការ ឬ វិធីចាត់តាំង និង បញ្ឈប់អភិបាលទេ តុលាការអាចកំណត់ចំណុចនេះតាមពាក្យសុំរបស់អ្នកដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ឬ ដោយតំណាងអយ្យការបាន ។

មាត្រា ១១៣.- ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីប្រទានកម្ម និង អច្ច័យទាន

១-បញ្ញត្តិនៃជំពូកទី ៣ (ប្រទានកម្ម) នៃគន្ថីទី ៥ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានវិភាគទានទ្រព្យសម្បត្តិដើម្បីបង្កើតនីតិបុគ្គលមូលនិធិ ដោយចាត់ចែងនៅមុនពេលទទួលមរណភាព ។

២-បញ្ញត្តិនៃផ្នែកទី ៦ (អច្ច័យទាន) ជំពូកទី ៣ នៃគន្ថីទី ៨ ត្រូវយកមកអនុវត្តដូចគ្នាផង

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS

ដែរ ចំពោះករណីដែលមានវិភាគទានទ្រព្យសម្បត្តិដើម្បីបង្កើតនីតិបុគ្គលមូលនិធិដោយមតក-សាសន៍ ។

មាត្រា ១១៤.- ពេលដែលទទួលសិទ្ធិលើទ្រព្យសម្បត្តិដែលត្រូវបានធ្វើវិភាគទាន

១-នៅក្នុងករណីដែលមានវិភាគទានទ្រព្យសម្បត្តិដើម្បីបង្កើតនីតិបុគ្គលមូលនិធិដោយចាត់ចែងនៅមុនពេលទទួលមរណភាព ទ្រព្យសម្បត្តិដែលបានធ្វើវិភាគទាននោះ នឹងក្លាយទៅជាទ្រព្យសម្បត្តិរបស់នីតិបុគ្គល ចាប់ពីពេលដែលការចុះបញ្ជីដែលបានកំណត់នៅក្នុងមាត្រា ៤៩ (ការចុះបញ្ជីនៃការបង្កើត និង ពេលវេលាកំណើតនៃនីតិបុគ្គល) នៃក្រមនេះ ត្រូវបានធ្វើឡើង ។

២-នៅក្នុងករណីដែលមានវិភាគទានទ្រព្យសម្បត្តិដើម្បីបង្កើតនីតិបុគ្គលមូលនិធិ ដោយមតកសាសន៍ ទ្រព្យសម្បត្តិដែលបានធ្វើវិភាគទាននោះ ត្រូវចាត់ទុកថា ក្លាយជាទ្រព្យសម្បត្តិរបស់នីតិបុគ្គល ចាប់ពីពេលដែលមតកសាសន៍នោះបង្កើតអានុភាព ។

មាត្រា ១១៥.- ចំណុចដែលត្រូវចុះបញ្ជី និង អំឡុងពេលចុះបញ្ជី

១-ក្រៅពីចំណុចដែលបានកំណត់នៅក្នុងមាត្រា ៥០ (ចំណុចដែលត្រូវចុះបញ្ជី) នៃក្រមនេះ នីតិបុគ្គលមូលនិធិត្រូវចុះបញ្ជីនូវគ្រប់ចំណុចដូចកំណត់ខាងក្រោមនេះ :

ក-តម្លៃសរុបនៃទ្រព្យសម្បត្តិជាមូលដ្ឋាន ។

ខ-វិធីផ្សព្វផ្សាយជាសាធារណៈ ។

គ-ថ្ងៃដែលបានទទួលសេចក្តីអនុញ្ញាតអំពីស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យ ។

២-ការចុះបញ្ជីបង្កើតនីតិបុគ្គលមូលនិធិ ត្រូវធ្វើឡើងនៅទីតាំងនៃទីស្នាក់ការកណ្តាល ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានទទួលសេចក្តីអនុញ្ញាតពីស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យ ។

៣-នៅទីតាំងនៃទីស្នាក់ការសាខា ការចុះបញ្ជីត្រូវធ្វើឡើង ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានចុះបញ្ជីតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS
ក្រសួងព្រះបរមរាជវាំង

មាត្រា ១១៦.- ការធ្វើ និង ការយល់ព្រមលើឯកសារគណនេយ្យ ជាអាទិ៍

១-រាល់ឆ្នាំអនុវត្តកិច្ចការ អភិបាលត្រូវធ្វើឯកសារដែលបានកំណត់ដូចខាងក្រោម នេះ និង ឯកសារលំអិតភ្ជាប់ជាមួយដែលសរសេរអំពីហេតុសំខាន់ដើម្បីពន្យល់បន្ថែមទៅលើការសរសេរនៅក្នុងឯកសារនោះ :

ក-តារាងតុល្យការ ។

ខ-របាយការណ៍ចំណេញខាត ។

គ-របាយការណ៍អំពីកិច្ចការ ។

ឃ-សេចក្តីព្រាងនៃសេចក្តីសម្រេចអំពីការបាត់ចែងប្រាក់ដែលនៅសល់ ឬ ដំណោះស្រាយចំពោះការខាតបង់ ។

២-អភិបាលត្រូវដាក់ជូនស្ថាប័នដែលមានសមត្ថកិច្ច ត្រួតពិនិត្យនូវឯកសារដែលមានកំណត់នៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ១ ខាងលើនេះ ហើយត្រូវទទួលការយល់ព្រមពីស្ថាប័ននោះ ។

មាត្រា ១១៧.- ការពិនិត្យឯកសារគណនេយ្យ ជាអាទិ៍

១-អភិបាលត្រូវទទួលការត្រួតពិនិត្យដោយអ្នកត្រួតពិនិត្យ ទៅលើឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១១៦ (ការធ្វើ និង ការយល់ព្រមលើឯកសារគណនេយ្យជាអាទិ៍) នៃក្រមនេះ ។

២-ការត្រួតពិនិត្យដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើងមុនពេលដាក់ឯកសារនោះជូនទៅស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យ ។

៣-អភិបាលត្រូវដាក់ជូនអ្នកត្រួតពិនិត្យនូវឯកសារដែលបានកំណត់នៅក្នុងចំណុចនីមួយៗ នៃកថាខណ្ឌទី ១ មាត្រា ១១៦ (ការធ្វើ និង ការយល់ព្រមលើឯកសារគណនេយ្យ ជាអាទិ៍) នៃក្រមនេះ យ៉ាងតិច ៥ (ប្រាំ) សប្តាហ៍មុន ហើយត្រូវដាក់ឯកសារលំអិតភ្ជាប់ជាមួយយ៉ាងតិច ៣ (បី) សប្តាហ៍ មុនការចាប់ផ្តើមការត្រួតពិនិត្យរបស់អ្នកត្រួតពិនិត្យ ។

៤-អ្នកត្រួតពិនិត្យត្រូវដាក់ជូនអភិបាលនូវរបាយការណ៍នៃការត្រួតពិនិត្យ ក្នុងអំឡុងពេល ៤ (បួន) សប្តាហ៍ គិតពីថ្ងៃដែលខ្លួនបានទទួលឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌ

ទី ៣ ខាងលើនេះ ដោយមិនរាប់បញ្ចូលនូវឯកសារលំអិតភ្ជាប់ជាមួយ ។

មាត្រា ១១៨.- ការបង្ហាញជាសាធារណៈនូវឯកសារគណនេយ្យ ជាអាទិ៍

១-នីតិបុគ្គលមូលនិធិ ត្រូវរក្សាទុកនូវឯកសារដែលបានកំណត់នៅក្នុងចំណុចនីមួយៗ នៃកថាខណ្ឌទី ១ មាត្រា ១១៦ (ការធ្វើ និង ការយល់ព្រមលើឯកសារគណនេយ្យ ជាអាទិ៍) នៃក្រមនេះ និង របាយការណ៍នៃការត្រួតពិនិត្យ ក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ ចាប់ពីពេលដែលរបាយការណ៍នៃការត្រួតពិនិត្យនោះត្រូវបានដាក់ជូនអភិបាល នៅទីស្នាក់ការកណ្តាល ហើយត្រូវរក្សាទុកនូវច្បាប់ចម្លងនៃឯកសារទាំងនោះ ក្នុងអំឡុងពេល ៣ (បី) ឆ្នាំ នៅទីស្នាក់ការសាខា ។

២-ម្ចាស់បំណុលរបស់នីតិបុគ្គលមូលនិធិ អាចទាមទារមើលឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ខាងលើនេះ ឱ្យប្រគល់ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬ ឯកសារដកស្រង់នៃឯកសារទាំងនោះពីនីតិបុគ្គលនោះ នៅក្នុងម៉ោងធ្វើការរបស់នីតិបុគ្គលនោះបាន ។ ប៉ុន្តែ ក្នុងករណីដែលទាមទារប្រគល់ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬ ឯកសារដកស្រង់ អ្នកទាមទារត្រូវបង់សោហ៊ុយដែលបានកំណត់ដោយនីតិបុគ្គលនោះ ។

គន្ថីទី ៣

សិទ្ធិប្រត្យក្ស

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

ផ្នែកទី ១

វត្ថុ

មាត្រា ១១៩.- និយមន័យនៃវត្ថុ

ក្នុងក្រមនេះ វត្ថុសំដៅទៅលើរបស់ដែលមានរូបរាងជាសារធាតុឧស្ម័ន ជាសារធាតុរាវ ជាសារធាតុរឹង ។

មាត្រា ១២០.- ចលនវត្ថុ និង អចលនវត្ថុ

១-វត្ថុត្រូវបានចែកជាចលនវត្ថុ និង អចលនវត្ថុ ។

២-អចលនវត្ថុសំដៅទៅលើ ដីធ្លី និង វត្ថុជាប់នៅលើដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជាអគារ សំណង់ ដំណាំ រុក្ខជាតិ ជាអាទិ៍ ។

៣-ចលនវត្ថុសំដៅទៅលើវត្ថុក្រៅពីអចលនវត្ថុ ។

៤-បញ្ញត្តិស្តីពីចលនវត្ថុត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះទ្រព្យសម្បត្តិគ្មានរូបរាងដែលអាចគ្រប់គ្រងបាន លើកលែងតែមានបញ្ញត្តិក្នុងច្បាប់ពិសេស ។

មាត្រា ១២១.- សមាសភាគនៃវត្ថុ

ចំពោះសមាសភាគនៃវត្ថុអ្វីមួយ ដែលមិនអាចបែងចែកបានដោយមិនបំបែកវត្ថុនោះ ឬដោយមិនផ្លាស់ប្តូរលក្ខណៈដើមនៃសមាសភាគនោះទេ ភាគនៃវត្ថុនោះមិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិឯករាជ្យបានឡើយ ។

មាត្រា ១២២.- សមាសភាគនៃដី : គោលការណ៍

វត្ថុដែលនៅជាប់នឹងដី ឬ វត្ថុដែលក្លាយជាភាគមួយនៃដី ជាពិសេស អគារ ឬ សំណង់ដែលសង់នៅលើដី ហើយមិនអាចប្តូរកន្លែងបាន ឬ ពូជដែលសាបនៅលើដីដំណាំដែលបានដាំ រុក្ខជាតិដែលរស់នៅលើដី គឺជាសមាសភាគនៃដី លុះត្រាតែមិនបំបែកចេញពីដី ហើយមិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិឯករាជ្យបានឡើយ លើកលែងតែមានបញ្ញត្តិផ្សេង ។

មាត្រា ១២៣.- សមាសភាគនៃដី : ករណីលើកលែង

អគារ ឬ សំណង់ផ្សេងទៀតដែលម្ចាស់សិទ្ធិបានសង់នៅលើដី ឬ រុក្ខជាតិ ឬ ដំណាំដែលម្ចាស់សិទ្ធិបានដាំ ជាអាទិ៍ ដែលជាការអនុវត្តសិទ្ធិចំពោះដីរបស់អ្នកដទៃមិនត្រូវក្លាយជាសមាសភាគនៃដីឡើយ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះវត្ថុដែលត្រូវបានភ្ជាប់ជាមួយនឹងដី ដោយមានគោលបំណងជាបណ្តោះអាសន្ន ។

មាត្រា ១២៤.- អគារ ជាអាទិ៍ ដែលត្រូវបានសង់ដោយផ្អែកលើសិទ្ធិលើដីរបស់អ្នកដទៃ

ក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ១២៣ (សមាសភាគនៃដី : ករណីលើកលែង)

14/493

នៃក្រមនេះ អគារ ឬ សំណង់ផ្សេងទៀត ដែលម្ចាស់សិទ្ធិបានសង់នៅលើដី ឬ រុក្ខជាតិ ឬ ដំណាំ ដែលម្ចាស់សិទ្ធិបានដាំ ជាអាទិ៍ ត្រូវបានចាត់ទុកថាជាសមាសភាគនៃសិទ្ធិលើដីរបស់អ្នកដទៃ ។

មាត្រា ១២៥.- សមាសភាគនៃអគារ

ចំពោះវត្ថុធាតុដែលជាសមាសភាគនៃអគារ គ្រឿងអគារ គ្រឿងសង្ហារឹម ផ្ទាំង វត្ថុតុបតែង ជាអាទិ៍ ដែលមិនអាចបែងចែកបាន ដោយមិនបំបែកអគារនោះ ឬ ដោយមិនផ្លាស់ប្តូរលក្ខណៈដើមនៃវត្ថុនោះទេ ភាគនៃវត្ថុនោះគឺជាសមាសភាគនៃអគារ ហើយមិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិឯករាជ្យបានឡើយ ។

មាត្រា ១២៦.- វត្ថុចម្បង និង វត្ថុចំណុះ

១-វត្ថុដែលមិនមែនជាសមាសភាគនៃវត្ថុចម្បង ហើយដែលកម្មសិទ្ធិករនៃវត្ថុចម្បងបានភ្ជាប់ទៅនឹងវត្ថុចម្បងក្នុងគោលបំណងសេដ្ឋកិច្ចនៃវត្ថុចម្បងជាបន្តបន្ទាប់នោះហៅថាវត្ថុចំណុះ ។

២-ការបង្កើត និង ការផ្ទេរសិទ្ធិចំពោះវត្ថុចម្បង ត្រូវមានអានុភាពទៅលើវត្ថុចំណុះផងដែរ លើកលែងតែមានការសន្យាពិសេស ។

មាត្រា ១២៧.- និយមន័យនៃវត្ថុដើម និង ផល

១-អត្ថប្រយោជន៍ដែលកើតពីវត្ថុអ្វីមួយ ហៅថាផល ។ វត្ថុដែលបង្កើតផល ហៅថាវត្ថុដើម ។

២-វត្ថុដែលបានកើតឡើង ហើយត្រូវបានធ្វើលទ្ធកម្ម តាមវិធីប្រើធម្មតា ហៅថាផលធម្មជាតិ ។

៣-ប្រាក់ ដូចជាប្រាក់ថ្លៃឈ្នួល ជាអាទិ៍ ឬ វត្ថុផ្សេងទៀត ដែលទទួលជាថ្នូរចំពោះការប្រើវត្ថុណាមួយ ហៅថាផលស៊ីវិល។

មាត្រា ១២៨.- សិទ្ធិទទួលផល

១-ផលធម្មជាតិ ជាកម្មសិទ្ធិរបស់អ្នកដែលមានសិទ្ធិទទួលផលនោះ នៅពេលដែលផលធម្មជាតិនោះបានបំបែកពីវត្ថុដើម ។

២-ផលស៊ីវិលអាចទទួលបានទៅតាមអំឡុងពេលដែលមានសិទ្ធិទទួលផលនេះដោយ

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL ·

1463

គណនាតាមចំនួនថ្ងៃ ។

មាត្រា ១២៩.- សិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់អ្នកដែលមានករណីយកិច្ចសងផល

អ្នកដែលមានករណីយកិច្ចសងផល អាចទាមទារឱ្យសងសោហ៊ុយធម្មតាដើម្បីទទួលផលនោះ ។ ប៉ុន្តែ សោហ៊ុយធម្មតានោះ មិនអាចលើសពីតម្លៃនៃផលដែលត្រូវសងឡើយ ។

ផ្នែកទី ២
សិទ្ធិប្រត្យក្ស

មាត្រា ១៣០.- និយមន័យនៃសិទ្ធិប្រត្យក្ស

សិទ្ធិប្រត្យក្ស សំដៅទៅលើសិទ្ធិគ្រប់គ្រងលើវត្ថុដោយចំពោះ ដែលអាចអះអាងចំពោះបុគ្គលដទៃទៀតបាន ។

មាត្រា ១៣១.- គោលការណ៍កំណត់សិទ្ធិប្រត្យក្សដោយច្បាប់

សិទ្ធិប្រត្យក្សអាចបង្កើតបាន តែតាមប្រភេទ និង ខ្លឹមសារដែលត្រូវបានទទួលស្គាល់ដោយក្រមនេះ និង ដោយច្បាប់ពិសេសតែប៉ុណ្ណោះ ។ សិទ្ធិប្រត្យក្សដែលត្រូវបានទទួលស្គាល់ដោយវិធានទំនៀមទម្លាប់ ត្រូវមានអានុភាពនៅក្រោមក្រមនេះ លុះត្រាតែគ្មានភាពផ្ទុយនឹងក្រមនេះ ឬ ច្បាប់ពិសេស ។

មាត្រា ១៣២.- ប្រភេទនៃសិទ្ធិប្រត្យក្ស

សិទ្ធិប្រត្យក្សដែលបានកំណត់នៅក្នុងក្រមនេះ មានដូចតទៅ :

ក-កម្មសិទ្ធិ ។

ខ-សិទ្ធិកាន់កាប់ ។

គ-សិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផល :

គ១) សិទ្ធិជួលអចិន្ត្រៃយ៍

គ២) ផលុបភោគ

គ៣) សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS

គ៤) សេវភាព ។

ឃ-សិទ្ធិប្រាតិភោគប្រត្យក្ស:

ឃ១) សិទ្ធិឃាត់ទុក

ឃ២) ឯកសិទ្ធិ

ឃ៣) សិទ្ធិលើការបញ្ចាំ

ឃ៤) ហ៊ីប៉ូតែក

ឃ៥) សិទ្ធិប្រាតិភោគដោយអនុប្បទាន ។

ផ្នែកទី ៣

គោលការណ៍នៃការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស

មាត្រា ១៣៣.- ការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស ដោយការព្រមព្រៀង

ការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស ត្រូវមានអានុភាព តាមការព្រមព្រៀងរវាងភាគី ។

មាត្រា ១៣៤.- លក្ខខណ្ឌតតាំងនៃការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស

១-ការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្សលើអចលនវត្ថុ ក្រៅពីសិទ្ធិកាន់កាប់ សិទ្ធិឃាត់ទុក សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ មិនអាចតតាំងនឹងតតិយជន បានឡើយ បើពុំបានចុះបញ្ជីសិទ្ធិនោះ តាមបញ្ញត្តិនៃច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេង ដែលទាក់ទងនឹងការចុះបញ្ជី ។

២-អនុប្បទាននូវសិទ្ធិប្រត្យក្សលើចលនវត្ថុទៅបុគ្គលណាមួយ មិនអាចតតាំងនឹងតតិយជន បានឡើយ បើពុំបានផ្ទេរការកាន់កាប់ចលនវត្ថុទៅបុគ្គលនោះទេ ។

មាត្រា ១៣៥.- លក្ខខណ្ឌដើម្បីបង្កើតអានុភាពនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង

ទោះបីមានបញ្ញត្តិនៃមាត្រា ១៣៣ (ការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្សដោយការព្រមព្រៀង) និងមាត្រា ១៣៤ (លក្ខខណ្ឌតតាំងនៃការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស) នៃក្រមនេះក៏ដោយ ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង មិន•

ROYAUME DU CAMBODGE LE MINISTRE du PALAIS ROYAL

មានអានុភាព បើមិនបានចុះបញ្ជី ដោយយោងតាមបញ្ញត្តិនៃច្បាប់ និង បទដ្ឋានគតិយុត្តផ្សេងទៀតស្តីពីការចុះបញ្ជី ។

មាត្រា ១៣៦.- ល្បាក្សុលភាព

១-ចំពោះវត្ថុតែមួយ បើកម្មសិទ្ធិលើវត្ថុនោះ និង សិទ្ធិប្រត្យក្សផ្សេងទៀតលើវត្ថុនោះធ្លាក់ទៅលើបុគ្គលតែម្នាក់ សិទ្ធិប្រត្យក្សផ្សេងនោះត្រូវរលត់ ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលវត្ថុនោះ ឬ សិទ្ធិប្រត្យក្សនោះជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជន ។

២-បើសិទ្ធិប្រត្យក្សក្រៅពីកម្មសិទ្ធិ និង សិទ្ធិផ្សេងទៀតដែលមានកម្មវត្ថុជាសិទ្ធិប្រត្យក្សនោះ ធ្លាក់ទៅលើបុគ្គលតែម្នាក់ សិទ្ធិនោះត្រូវរលត់ ។ ក្នុងករណីនេះ បញ្ញត្តិនៃវាក្យខណ្ឌទី ២នៃកថាខណ្ឌទី ១ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ មិនត្រូវអនុវត្តចំពោះសិទ្ធិកាន់កាប់ឡើយ ។

មាត្រា ១៣៧.- អានុភាពក្នុងការសន្មតនៃការចុះបញ្ជី

១-នៅពេលដែលបានចុះសិទ្ធិក្នុងបញ្ជីអចលនវត្ថុហើយ សិទ្ធិនេះត្រូវបានសន្មតថា ជាសិទ្ធិរបស់អ្នកដែលមានឈ្មោះនៅក្នុងបញ្ជីនោះ ។

២-បើសិទ្ធិដែលបានចុះបញ្ជីអចលនវត្ថុហើយ ត្រូវបានលុបចេញពីបញ្ជីអចលនវត្ថុនោះ សិទ្ធិនោះត្រូវបានសន្មតថាបានរលត់ ។

ជំពូកទី ២

កម្មសិទ្ធិ

ផ្នែកទី ១

ខ្លឹមសារ និង ការម្រិតនៃកម្មសិទ្ធិ

មាត្រា ១៣៨.- និយមន័យនៃកម្មសិទ្ធិ

កម្មសិទ្ធិ សំដៅទៅលើសិទ្ធិដែលកម្មសិទ្ធិករនោះអាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែងវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួន ដោយសេរី បាននៅក្នុងទំហំដែលច្បាប់បានកម្រិត ។

មាត្រា ១៣៩.- កម្រិតនៃកម្មសិទ្ធិដី

១-កម្មសិទ្ធិដី ត្រូវមានអានុភាពទាំងផ្នែកលើដី និង ផ្នែកក្រោមដី នៅក្នុងទំហំនៃការកម្រិត ដែលច្បាប់ និង បទដ្ឋានគតិយុត្តបានកំណត់ ហើយក្នុងទំហំដែលមានផលប្រយោជន៍សម្រាប់កម្មសិទ្ធិករ ។

២-កម្មសិទ្ធិករនៃដី មិនអាចប្រើប្រាស់ដីរបស់ខ្លួន ក្នុងគោលបំណងព្យាបាទអ្នកដទៃ ឬ រំខានដល់ជីវភាពរស់នៅរបស់អ្នកដទៃតែប៉ុណ្ណោះ បានឡើយ ។

មាត្រា ១៤០.- ការបញ្ឈប់អំពើដែលរំខានដល់ជីវភាពរស់នៅ

១-ក្នុងករណីដែលអំពើរំខានដល់ជីវភាពរស់នៅដែលមកពីឧស្ម័ន ចំហាយទឹក ក្លិន ផ្សែង ផ្សែងភ្លើង កំដៅ សំឡេង រំញ័រ ជាអាទិ៍ ដែលកើតពីដីរបស់អ្នកដទៃ ស្ថិតនៅក្នុងទំហំនៃការប្រើប្រាស់ជាធម្មតា ហើយបទដ្ឋានគតិយុត្តមិនបានហាមឃាត់ទេ កម្មសិទ្ធិករនៃដីមិនអាចទាមទារឱ្យអ្នកដទៃបញ្ឈប់នូវអំពើដែលធ្វើឱ្យមានឥទ្ធិពលដល់ដីខ្លួនបានឡើយ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ កម្មសិទ្ធិករនៃដីដែលទទួលឥទ្ធិពលអាក្រក់ដ៏ធ្ងន់ធ្ងរ តាមភាពជាក់ស្តែង អាចទាមទារឱ្យអ្នកដែលរំខានដល់ជីវភាពរស់នៅនោះសងសំណងសមរម្យបាន ។ ម្យ៉ាងទៀត បញ្ញត្តិនេះមិនរារាំងកម្មសិទ្ធិករដីក្នុងការទាមទារសំណងនៃការខូចខាត ដោយផ្អែកលើអំពើអនីត្យានុកូលឡើយ ។

មាត្រា ១៤១.- ការជីកកកាយបេតិកភណ្ឌវប្បធម៌ និង រ៉ែក្នុងដី

១-កម្មសិទ្ធិករនៃដីមិនអាចអះអាងនូវកម្មសិទ្ធិលើគ្រប់ប្រភេទនៃបដិមា ចម្លាក់ ក្រឡោត បុរាណវត្ថុ ឬ បេតិកភណ្ឌវប្បធម៌ផ្សេងទៀតដែលរកឃើញនៅក្នុងដីរបស់ខ្លួនបានឡើយ ។ វត្ថុទាំងនេះ គឺជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយកម្មសិទ្ធិករនៃដីដែលបានរកឃើញវត្ថុទាំងនេះ មានករណីយកិច្ចប្រគល់ឱ្យក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។

២-កម្មសិទ្ធិករនៃដីមិនអាចអះអាងនូវកម្មសិទ្ធិលើរ៉ែនៅក្នុងដីដែលបានកំណត់នៅក្នុងច្បាប់ផ្សេងបានឡើយ ។ វត្ថុទាំងនេះ គឺជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយអ្នកដែលត្រូវបានទទួលអាជ្ញាប័ណ្ណសិទ្ធិជីកដោយរដ្ឋ តាមបញ្ញត្តិនៃច្បាប់ផ្សេងមានសិទ្ធិជីក និងទទួលវត្ថុនោះ ។

ROYAUME DU CAMBODGE • LE MINISTERE DU PALAIS ROYAL

មាត្រា ១៤២.- សិទ្ធិកាប់ចោលមែកឈើឆ្លងព្រំដី

នៅពេលដែលមែកឈើ ឬ ឫសឈើនៃដីជិតខាងបានលយចូលមកដីរបស់ខ្លួន កម្មសិទ្ធិករនៃដីអាចយកផលពីមែកឈើ ឬ ឫសឈើនោះ ឬ កាប់មែកឈើ ឬ ឫសឈើ នោះបាន ។

ផ្នែកទី ២

ទំនាក់ទំនងរវាងដីដែលនៅជាប់គ្នា

មាត្រា ១៤៣.- សិទ្ធិប្រើដីដែលជាប់គ្នា

កម្មសិទ្ធិករនៃដីអាចទាមទារប្រើដីដែលជាប់គ្នាបាន ក្នុងទំហំចាំបាច់ដើម្បីធ្វើរបង ឬ សង់សំណង់ ឬ ជួសជុល របស់ទាំងពីរនេះ នៅព្រំប្រទល់ដី ឬ នៅក្បែរព្រំប្រទល់នោះ ។ ប្រសិនបើអ្នកជិតខាងទទួលការខូចខាត ដោយសារការសាងសង់ ឬ ជួលជុលនេះ កម្មសិទ្ធិករនៃដីត្រូវបង់ប្រាក់សំណង ។

មាត្រា ១៤៤.- សិទ្ធិចេញចូលដីបិទជិត

១-ដីដែលព័ទ្ធជុំវិញដោយដីរបស់អ្នកដទៃ ហើយគ្មានច្រកចេញទៅផ្លូវសាធារណៈ និង ដីដែលមានច្រកចេញនោះមិនគ្រប់គ្រាន់ហើយមានឧបសគ្គដ៏ខ្លាំងដើម្បីប្រើប្រាស់ដីនោះសម្រាប់ការធ្វើកសិកម្ម ឬ ឧស្សាហកម្ម ហៅថា ដីបិទជិត ។

២-កម្មសិទ្ធិករនៃដីបិទជិត មានសិទ្ធិស្នើសុំឆ្លងកាត់ដីអ្នកជិតខាងបាន ដោយបង់ប្រាក់សំណងតាមការខូចខាត ដោយសារការឆ្លងកាត់នោះ ។

៣-ជាគោលការណ៍ សិទ្ធិឆ្លងកាត់នេះ ត្រូវរៀបចំតាមទិស ឬ ផ្លូវដែលមានចម្ងាយជិតបំផុត ពីដីបិទជិតទៅផ្លូវសាធារណៈ ។ ទោះបីជាមានបញ្ញត្តិនៃវាក្យខណ្ឌទី ១ នៃកថាខណ្ឌនេះក៏ដោយ សិទ្ធិឆ្លងកាត់នេះត្រូវតែរៀបចំនៅកន្លែងណាដែលមានការខូចខាតតិចបំផុតសម្រាប់កម្មសិទ្ធិករនៃដីដែលទទួលបន្ទុកឱ្យឆ្លងកាត់នោះ ។

៤-ប្រសិនបើដីបិទជិត កើតឡើងពីការបែងចែកដីតាមរយៈការលក់ ការដូរ ការចែកមត៌ក ឬ កិច្ចសន្យាផ្សេងទៀត សិទ្ធិឆ្លងកាត់អាចស្នើសុំបានតែចំពោះដីដែលនៅសល់ ក្រោយពីការបែងចែកនោះប៉ុណ្ណោះ ។ ក្នុងករណីនេះ កម្មសិទ្ធិករនៃដីបិទជិតមិនចាំបាច់បង់ប្រាក់សំណង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ឡើយ ។ ប៉ុន្តែ ក្នុងករណីដែលមិនមានច្រកចេញគ្រប់គ្រាន់ទេ បញ្ញត្តិនៃកថាខណ្ឌទី ២ និង កថាខណ្ឌទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តផងដែរ ។

មាត្រា ១៤៥.- ករណីយកិច្ចទទួលទឹកហូរតាមធម្មជាតិ

១-កម្មសិទ្ធិករនៃដីក្រោម មានករណីយកិច្ចទទួលទឹកដែលហូរតាមធម្មជាតិពីដីលើ ។ កម្មសិទ្ធិករនៃដីក្រោម មិនអាចលើកទំនប់ ភ្លឺ របាំង ឬ ការរៀផ្សេងទៀតទប់មិនឱ្យទឹកហូរបាន ឡើយ ។ កម្មសិទ្ធិករនៃដីលើមិនអាចធ្វើអំពើអ្វីបន្ថែមបន្ទុករបស់កម្មសិទ្ធិករនៃដីក្រោមបានឡើយ។

២-ពេលមានការប្រែប្រួលដោយប្រធានសក្តិដែលគ្មានការទទួលខុសត្រូវរបស់ភាគី ធ្វើឱ្យរាំងស្ទះទឹកហូរនៅដីក្រោមកម្មសិទ្ធិករនៃដីលើអាចធ្វើប្រឡាយឱ្យទឹកហូរ ដោយចេញសោ-ហ៊ុយផ្ទាល់ខ្លួនបាន ។

មាត្រា ១៤៦.- សិទ្ធិប្រើទឹកភ្លៀង ជាអាទិ៍

យោងទៅតាមវាក្យខណ្ឌទី ៣ កថាខណ្ឌទី ១ មាត្រា ១៤៥ (ករណីយកិច្ចទទួលទឹកហូរ តាមធម្មជាតិ) នៃក្រមនេះ កម្មសិទ្ធិករនៃដីលើ មានសិទ្ធិប្រើប្រាស់ទឹកដែលមានប្រភពផុសឡើង នៅដីរបស់ខ្លួន និង ទឹកភ្លៀងដែលធ្លាក់មកលើដីរបស់ខ្លួន និង មានសិទ្ធិបង្ហូរចោលទឹកទាំងអស់ នោះ ។

មាត្រា ១៤៧.- ករណីយកិច្ចរក្សាការពារទឹកហូរ

កម្មសិទ្ធិករនៃដីដែលស្ថិតនៅជាប់ផ្លូវទឹកហូរ មានករណីយកិច្ចទុកឱ្យទឹកហូរទៅលើដី អ្នកជិតខាង តាមតម្រូវការនៃកសិកម្ម ហើយកម្មសិទ្ធិករនៃដីជិតខាងក៏មានករណីយកិច្ចដូចគ្នា ដែរ ដោយយោគយល់ចំពោះដីដែលនៅឆ្ងាយទៀត ។

មាត្រា ១៤៨.- សិទ្ធិធ្វើផ្លូវទឹកដើម្បីស្រោចស្រព

កម្មសិទ្ធិករដែលចង់ឱ្យទឹកដែលខ្លួនមានសិទ្ធិប្រើប្រាស់ដើម្បីស្រោចស្រពដីរបស់ខ្លួន អាចធ្វើ និង រក្សាទុកនូវផ្លូវទឹកឆ្លងកាត់ដីដែលស្ថិតនៅចន្លោះប្រភពទឹកនឹងដីរបស់ខ្លួនបានដោយ មិនចេញប្រាក់សំណងនៃការខូចខាតដល់កម្មសិទ្ធិករនៃដីដែលត្រូវឆ្លងកាត់នោះ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

មាត្រា ១៤៩.- សិទ្ធិបង្ហូរចោលទឹកស្រោចស្រព

កម្មសិទ្ធិករនៃដីអាចបង្ហូរចោលទឹកដែលបានស្រោចស្រពលើដីរបស់ខ្លួនឆ្លងកាត់ដីក្រោមបាន ដោយបង់ប្រាក់សំណងដល់កម្មសិទ្ធិករនៃដីក្រោមនោះ ។

មាត្រា ១៥០.- សិទ្ធិបង្ហូរទឹកចោលនៃកម្មសិទ្ធិករនៃដីលិចទឹក

កម្មសិទ្ធិករនៃដីលិចទឹកទាំងស្រុង ឬ មួយចំណែក អាចបង្ហូរទឹកដែលបណ្ដាលឱ្យមានការខូចខាតចេញពីដីរបស់ខ្លួនបាន លុះត្រាតែគោរពបញ្ញត្តិនៃច្បាប់ ឬ បទដ្ឋានគតិយុត្តស្ដីពីអនាម័យ ។

មាត្រា ១៥១.- សិទ្ធិលើក និង សិទ្ធិប្រើប្រាស់ទំនប់ ជាអាទិ៍

១-កម្មសិទ្ធិករនៃដីជាប់មាត់ទន្លេ ស្ទឹង ឬ ព្រែក ដែលចង់ប្រើប្រាស់ទឹក ទន្លេ ស្ទឹង ឬ ព្រែក ដើម្បីស្រោចស្រពដីរបស់ខ្លួន អាចធ្វើសិល្បៈការ្យចាំបាច់ដើម្បីយកទឹកទៅលើដីដែលស្ថិតនៅមាត់ទឹកម្ខាងទៀតបាន ដោយបង់ប្រាក់សំណងដល់កម្មសិទ្ធិករនៃដីនៅមាត់ទឹកម្ខាងទៀត ។

២-កម្មសិទ្ធិករនៃដីដែលអនុញ្ញាតឱ្យធ្វើសិល្បៈការ្យនៅលើដីរបស់ខ្លួន អាចទាមទារប្រើប្រាស់រួមនូវទំនប់ទឹក ជាអាទិ៍ ពីអ្នកដែលបានធ្វើសិល្បៈការ្យនោះបាន ដោយយកល័ក្ខខ័ណ្ឌទទួលបន្ទុកពាក់កណ្ដាលនៃសោហ៊ុយធ្វើ និង ថែទាំ ។ ក្នុងករណីនេះ អ្នកដែលបានធ្វើសិល្បៈការ្យពុំមានករណីយកិច្ចបង់ប្រាក់សំណងដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះទេ ហើយអាចទាមទារឱ្យសងសំណងដែលខ្លួនបានបង់ហើយវិញបាន ។

មាត្រា ១៥២.- អំពើដែលរំខានដល់ជីវភាពរស់នៅ

កម្មសិទ្ធិករដែលមានបំណងធ្វើនៅលើដីរបស់ខ្លួន នូវអំពើដែលនឹងអាចរំខានដល់ជីវភាពរស់នៅរបស់អ្នកជិតខាង ដោយការខួងអណ្ដូង ការជីកស្នង់ ការជីករុករក ឬ ដោយការទុកវត្ថុមានគ្រោះថ្នាក់ វត្ថុដែលរំខានដល់អ្នកដទៃ ឬ វត្ថុគ្មានអនាម័យ ត្រូវអនុលោមតាមបញ្ញត្តិពិសេសដែលកំណត់អំពីចម្ងាយដែលត្រូវគោរព និង អំពើដែលត្រូវអនុវត្ត ។

~~មាត្រា ១៥៣.-~~ ករណីយកិច្ចដាក់ចម្ងាយនៅបង្គួច តើយ ជាអាទិ៍

អ្នកដែលធ្វើបង្គួច តើយ ឬ សិល្បៈការ្យប្រហាក់ប្រហែលរបស់ទាំងអស់នេះ ដែលសម្ទឹង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ទៅឃើញដីផ្ទះអ្នកជិតខាងនោះ នៅចម្ងាយតិចជាង ២ (ពីរ) ម៉ែត្រ ពីព្រំដីអ្នកជិតខាងត្រូវដាក់រនាំងបាំង ។

មាត្រា ១៥៤.- ដើមឈើនៅជិតព្រំដី

កម្មសិទ្ធិករនៃដីមិនអាចដាំដើមឈើ គុម្ពោត ឬ ចុល្លព្រឹក្សដែលមានកម្ពស់លើសពី ២ (ពីរ) ម៉ែត្រ ក្នុងចម្ងាយ ២ (ពីរ) ម៉ែត្រ ពីព្រំប្រទល់ដីអ្នកជិតខាងបានឡើយ ។ ក្នុងករណីដែលធ្វើផ្ទុយពីបញ្ញត្តិនេះ កម្មសិទ្ធិករនេះមានករណីយកិច្ចដកចេញ តាមការទាមទាររបស់កម្មសិទ្ធិករនៃដីជិតខាង ។

ផ្នែកទី ៣
សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ

មាត្រា ១៥៥.- សិទ្ធិទាមទារឱ្យប្រគល់វិញដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ

កម្មសិទ្ធិករអាចទាមទារឱ្យអ្នកកាន់កាប់ប្រគល់វត្ថុរបស់ខ្លួនវិញបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកកាន់កាប់នោះមានមូលហេតុគតិយុត្តនៃសិទ្ធិកាន់កាប់ចំពោះកម្មសិទ្ធិករ ។

មាត្រា ១៥៦.- អ្នកកាន់កាប់ និង ផល

១-អ្នកកាន់កាប់ដោយសុចរិត អាចទទួលផលដែលកើតពីវត្ថុកាន់កាប់នោះ ។

២-នៅពេលអ្នកកាន់កាប់ដោយសុចរិតបានចាញ់ក្តីក្នុងបណ្តឹងអំពីមូលហេតុគតិយុត្តនៃការកាន់កាប់ អ្នកកាន់កាប់នោះ ត្រូវបានចាត់ទុកថាជាអ្នកកាន់កាប់ដោយទុច្ចរិត គិតតាំងពីពេលបានដាក់ពាក្យបណ្តឹងនោះ ។

៣-ក្នុងករណីដែលអ្នកកាន់កាប់ប្រគល់វត្ថុកាន់កាប់ឱ្យកម្មសិទ្ធិករវិញ អ្នកកាន់កាប់ទុច្ចរិតនៅពេលដែលផលបានកើតឡើង មានករណីយកិច្ចសងផលដែលខ្លួនបានទទួលនោះវិញ ហើយមានករណីយកិច្ចសងសំណងនូវតម្លៃនៃផលដែលត្រូវបានខូចខាត ឬ ធ្វេសប្រហែសក្នុងការទទួលផលដោយកំហុស ។

មាត្រា ១៥៧.- ការទទួលខុសត្រូវចំពោះការបាត់បង់ ឬ ខូចខាតនៃវត្ថុកាន់កាប់

ក្នុងករណីដែលអ្នកកាន់កាប់មានកំហុសចំពោះការបាត់បង់ ឬ ការខូចខាតវត្ថុកាន់កាប់ ឬ ការមិនអាចប្រគល់វត្ថុនោះវិញបាន អ្នកកាន់កាប់ទុច្ចរិត នៅពេលដែលការបាត់បង់ការខូចខាតដល់វត្ថុ ឬ ហេតុផ្សេងដែលមិនអាចប្រគល់វត្ថុនោះវិញបាននោះ បានកើតឡើងមានករណីយកិច្ចសងសំណងការខូចខាតទាំងអស់នោះ រីឯអ្នកកាន់កាប់សុចរិតមានករណីយកិច្ចសងសំណងការខូចខាត ត្រឹមតែកម្រិតនៃផលប្រយោជន៍ដែលខ្លួននៅតែទទួលប៉ុណ្ណោះ ។ ប៉ុន្តែ អ្នកកាន់កាប់ដែលគ្មានឆន្ទៈយកជាកម្មសិទ្ធិ ទោះបីជាក្នុងករណីកាន់កាប់ដោយសុចរិតក៏ដោយក៏មានករណីយកិច្ចសងនូវការខូចខាតទាំងអស់ដែរ ។

មាត្រា ១៥៨.- សិទ្ធិរបស់អ្នកកាន់កាប់ក្នុងការទាមទារសងសោហ៊ុយ

១-ក្នុងករណីដែលអ្នកកាន់កាប់ប្រគល់វត្ថុកាន់កាប់ទៅកម្មសិទ្ធិករវិញ អ្នកកាន់កាប់អាចទាមទារឱ្យកម្មសិទ្ធិករសងនូវសោហ៊ុយចាំបាច់ដែលខ្លួនបានចំណាយក្នុងការគ្រប់គ្រង និង ថែរក្សាវត្ថុនោះ ។ ក្នុងករណីអ្នកកាន់កាប់នោះបានទទួលផលពីវត្ថុកាន់កាប់ អ្នកកាន់កាប់ត្រូវទទួលបន្ទុកនូវសោហ៊ុយចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សាវត្ថុជាធម្មតា ។

២-ប្រសិនបើអ្នកកាន់កាប់បានចំណាយប្រាក់ដើម្បីកែលំអវត្ថុកាន់កាប់ ឬ ចំណាយ ដើម្បីបង្កើនតម្លៃផ្សេងចំពោះវត្ថុនោះ កម្មសិទ្ធិករត្រូវសងទៅអ្នកកាន់កាប់វិញនូវសោហ៊ុយដែលអ្នកកាន់កាប់បានចេញ ឬ តម្លៃប្រាក់ដែលកើននោះ តាមការជ្រើសរើសរបស់កម្មសិទ្ធិករក្នុងកម្រិតដែលកំណើនតម្លៃនោះនៅតែមាន ។ ប៉ុន្តែ ចំពោះអ្នកកាន់កាប់ទុច្ចរិត តុលាការអាចអនុញ្ញាតឱ្យកម្មសិទ្ធិករមានអំឡុងពេលសមរម្យសម្រាប់ការសងនេះ ។

៣-ក្នុងករណីដែលអ្នកកាន់កាប់ប្រគល់ដីធ្លីឱ្យកម្មសិទ្ធិករវិញ កម្មសិទ្ធិករត្រូវសងនូវសោហ៊ុយដែលអ្នកកាន់កាប់បានចេញ ឬ កំណើនតម្លៃដែលនៅតែមានចំពោះសំណង់ដែលអ្នកកាន់កាប់សុចរិតបានសង់ ដំណាំដែលអ្នកនោះបានដាំ តែមិនទាន់បានទទួលផល និងដើមឈើមិនទាន់បានកាប់ ។ ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះក៏ដោយ ចំពោះអ្នកកាន់កាប់ទុច្ចរិតវិញ កម្មសិទ្ធិករមានសិទ្ធិជ្រើសរើសឱ្យអ្នកកាន់កាប់យកសំណង់ដែលបានសង់ ដំណាំដែលបានដាំតែមិនទាន់បានទទួលផល និង ដើមឈើមិនទាន់កាប់នោះ

ចេញពីដី ឬ យកវត្ថុនោះជាកម្មសិទ្ធិរបស់ខ្លួន ។ ប្រសិនបើ កម្មសិទ្ធិករជ្រើសរើសឱ្យដកយកវត្ថុនោះចេញ អ្នកកាន់កាប់ត្រូវយកសំណង់ ដំណាំ និង ដើមឈើទាំងនោះចេញដោយមិនគិតថ្លៃ ។ ប្រសិនបើកម្មសិទ្ធិករជ្រើសរើសយកសំណង់ ដំណាំ និង ដើមឈើនោះ ជាកម្មសិទ្ធិរបស់ខ្លួនវិញ កម្មសិទ្ធិករនោះត្រូវសងសោហ៊ុយ ដែលអ្នកកាន់កាប់បានចេញ ឬ តម្លៃប្រាក់ដែលកើនឡើងរួមទាំងតម្លៃនៃវត្ថុដែលទទួលយក ដោយមិនគិតពិចារណាពីអធិកលាភនៃដីនោះទេ ។ ក្នុងករណីនេះ តុលាការអាចអនុញ្ញាតឱ្យកម្មសិទ្ធិករមានអំឡុងពេលសមរម្យសម្រាប់ការសងនេះ ។

មាត្រា ១៥៩.- សិទ្ធិទាមទារឱ្យបញ្ឈប់ និង បង្ការការរារាំង ដោយផ្អែកលើកម្មសិទ្ធិ

១-ក្នុងករណីដែលការអនុវត្តកម្មសិទ្ធិរបស់ខ្លួនត្រូវបានរារាំង កម្មសិទ្ធិករអាចទាមទារឱ្យបញ្ឈប់ការរារាំង ចំពោះអ្នករារាំងនោះបាន ។

២-ក្នុងករណីដែលមានការបារម្ភជាក់ស្តែងថា ការអនុវត្តកម្មសិទ្ធិរបស់ខ្លួននឹងទទួលការរារាំង នោះកម្មសិទ្ធិករអាចទាមទារឱ្យបង្ការការរារាំងនោះបាន ចំពោះអ្នកដែលអាចនឹងរារាំងនោះ ។

ផ្នែកទី ៤
លទ្ធកម្មនៃកម្មសិទ្ធិ
កថាភាគទី ១
លទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុ

មាត្រា ១៦០.- លទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុ

កម្មសិទ្ធិលើអចលនវត្ថុ អាចត្រូវបានធ្វើលទ្ធកម្ម ដោយកិច្ចសន្យា សន្តតិកម្ម និង ហេតុដែលបានកំណត់នៅក្នុងផ្នែកទី ៤ (លទ្ធកម្មនៃកម្មសិទ្ធិ) នេះ ព្រមទាំងតាមបញ្ញត្តិនៃក្រមនេះ ឬ ច្បាប់ផ្សេង ។

មាត្រា ១៦១.- អចលនវត្ថុគ្មានម្ចាស់

អចលនវត្ថុដែលគ្មានម្ចាស់ ត្រូវជាកម្មសិទ្ធិរបស់រដ្ឋ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

(តទៅរាជកិច្ច លេខ ០២)

មាត្រា ១៦២.- អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុ

១-ជនដែលបានកាន់កាប់អចលនវត្ថុ ដោយសន្តិវិធី និង ដឹងឮជាសាធារណៈ ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ក្នុងអំឡុងពេល ២០ (ម្ភៃ) ឆ្នាំ ត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុនោះ ។

២-ជនដែលបានកាន់កាប់អចលនវត្ថុ ដោយសន្តិវិធី និង ដឹងឮជាសាធារណៈ ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ក្នុងអំឡុងពេល ១០ (ដប់) ឆ្នាំ ត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុនោះ បើជននោះសុចរិត និង គ្មានកំហុស នៅពេលដែលខ្លួនបានចាប់ផ្តើមកាន់កាប់ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ទោះបីជាប្រភេទណាក៏ដោយ ។

មាត្រា ១៦៣.- អានុភាពប្រតិសកម្មនៃអាជ្ញាយុកាលនៃលទ្ធកម្ម

អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិដែលបានកំណត់នៅក្នុងមាត្រា ១៦២ (អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុ) នៃក្រមនេះ មានអានុភាពប្រតិសកម្ម ចាប់ពីថ្ងៃចាប់ផ្តើមគិតអាជ្ញាយុកាលនេះ ។ ផលដែលបានកើតឡើង ក្រោយថ្ងៃចាប់ផ្តើមគិតអាជ្ញាយុកាលនេះ ត្រូវធ្លាក់ទៅអ្នកដែលធ្វើលទ្ធកម្មនូវកម្មសិទ្ធិដោយអាជ្ញាយុកាល ។

មាត្រា ១៦៤.- ការលើកឡើងនូវអាជ្ញាយុកាលនៃលទ្ធកម្ម

១-តុលាការមិនអាចសម្រេចសេចក្តីដោយផ្អែកលើអាជ្ញាយុកាលនៃលទ្ធកម្មបានឡើយ លើកលែងតែភាគីបានលើកឡើងនូវអាជ្ញាយុកាលនៃលទ្ធកម្មនោះ ។

២-មានតែអ្នកដែលនឹងធ្វើលទ្ធកម្មនូវកម្មសិទ្ធិដោយអាជ្ញាយុកាល អ្នកដែលទទួលការបង្កើតសិទ្ធិផលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ សេវភាព សិទ្ធិជួល ហ៊ីប៉ូតែក ឬ សិទ្ធិលើការបញ្ចាំ ពីអ្នកដែលនឹងធ្វើលទ្ធកម្មនូវកម្មសិទ្ធិ និង បុគ្គលផ្សេងទៀតដែលមានផលប្រយោជន៍ត្រឹមត្រូវតាមផ្លូវច្បាប់ក្នុងការលើកឡើងនូវអាជ្ញាយុកាលនៃលទ្ធកម្មទេ ដែលអាចលើកឡើងនូវអាជ្ញាយុកាលនៃលទ្ធកម្មបាន ។

៣-ប្រសិនបើអ្នកដែលនឹងធ្វើលទ្ធកម្មនូវកម្មសិទ្ធិដោយអាជ្ញាយុកាល លើកឡើងនូវអាជ្ញាយុកាលនៃលទ្ធកម្ម តតិយជនក៏ទទួលបាននូវផលប្រយោជន៍នៃអាជ្ញាយុកាលនៃលទ្ធកម្មនេះ

ដែរ ។ ប្រសិនបើអ្នកដែលមានសិទ្ធិលើកឡើង ក្រៅពីអ្នកដែលនឹងធ្វើលទ្ធកម្មនូវកម្មសិទ្ធិដោយអាជ្ញាយុកាល បានលើកឡើងនូវអាជ្ញាយុកាលនៃលទ្ធកម្ម អានុភាពនៃការលើកឡើងនេះកើតឡើងតែរវាងអ្នកដែលបានលើកឡើងនូវអាជ្ញាយុកាលនៃលទ្ធកម្ម និង ម្ចាស់កម្មសិទ្ធិដើមតែប៉ុណ្ណោះ ។

មាត្រា ១៦៥.- ការបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាលនៃលទ្ធកម្ម

ផលប្រយោជន៍នៃអាជ្ញាយុកាលនៃលទ្ធកម្ម មិនអាចបោះបង់ចោលជាមុនបានឡើយ ។ មានតែផលប្រយោជន៍នៃអាជ្ញាយុកាលនៃលទ្ធកម្មដែលបានសម្រេចហើយទេ ទើបអាចបោះបង់ចោលបាន ។

មាត្រា ១៦៦.- វិសាលភាពនៃជនដែលទទួលអានុភាពនៃការបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាលនៃលទ្ធកម្ម

ការបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាលនៃលទ្ធកម្ម មានអានុភាពតែរវាងម្ចាស់កម្មសិទ្ធិដើម និង អ្នកមានសិទ្ធិលើកឡើងដែលបានបោះបង់ចោលនូវផលប្រយោជន៍នោះប៉ុណ្ណោះ ។

មាត្រា ១៦៧.- ហេតុនៃការផ្អាកអាជ្ញាយុកាលនៃលទ្ធកម្ម

អាជ្ញាយុកាលនៃលទ្ធកម្ម ត្រូវផ្អាកក្នុងករណីណាមួយដូចខាងក្រោមនេះ :

ក-ការបាត់បង់ការកាន់កាប់ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ។

ខ-ការទាមទារតាមផ្លូវតុលាការ ឬ ការអនុវត្តសិទ្ធិដែលមានលក្ខណៈប្រហាក់ប្រហែល ។

គ-សកម្មភាពអនុវត្តដោយបង្ខំ ឬ សកម្មភាពបាត់ចែងការរក្សាការពារ ។

ឃ-ការទទួលស្គាល់ ។

មាត្រា ១៦៨.- វិសាលភាពនៃជនដែលទទួលអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃលទ្ធកម្ម

ប្រសិនបើហេតុនៃការផ្អាកអាជ្ញាយុកាលនៃលទ្ធកម្ម កើតឡើងចំពោះអ្នកដែលនឹងធ្វើលទ្ធកម្មនូវកម្មសិទ្ធិដោយអាជ្ញាយុកាល អ្នកដទៃទៀតមិនអាចបដិសេធនូវអានុភាពនៃការផ្អាក

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

នេះបានទេ ។ ប្រសិនបើហេតុនៃការផ្អាកអាជ្ញាយុកាលនៃលទ្ធកម្ម កើតឡើងចំពោះអ្នកមានសិទ្ធិលើកឡើង ក្រៅពីអ្នកដែលនឹងធ្វើលទ្ធកម្មនូវកម្មសិទ្ធិដោយអាជ្ញាយុកាលអានុភាពនៃការផ្អាកនេះ ត្រូវកើតឡើងតែរវាងម្ចាស់កម្មសិទ្ធិដើម និង អ្នកមានសិទ្ធិលើកឡើងប៉ុណ្ណោះ ។

មាត្រា ១៦៩.- ការបាត់បង់ការកាន់កាប់ដោយមានឆន្ទៈយកជាកម្មសិទ្ធិ

បើអ្នកកាន់កាប់ដោយមានឆន្ទៈយកជាកម្មសិទ្ធិ បានបាត់បង់ការកាន់កាប់ ក្រៅពីឆន្ទៈរបស់ខ្លួន ហើយកាន់កាប់ឡើងវិញនៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ឬ ដោយបណ្តឹងដែលដាក់ពាក្យ នៅក្នុងអំឡុងពេល ១(មួយ) ឆ្នាំ ត្រូវចាត់ទុកថា អាជ្ញាយុកាលនៃលទ្ធកម្មមិនបានផ្អាក ។

មាត្រា ១៧០.- ការទាមទារតាមផ្លូវតុលាការ

ការទាមទារតាមផ្លូវតុលាការមិនត្រូវបង្កើតអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃលទ្ធកម្មឡើយ ក្នុងករណីដែលបណ្តឹងត្រូវបានលើកចោល ឬ ត្រូវបានដកវិញ ។

មាត្រា ១៧១.- ការលុបចោលនូវការចាត់ចែងការអនុវត្តដោយបង្ខំ ឬ ការចាត់ចែងការរក្សាការពារ

ក្នុងករណីដែលការចាត់ចែងការអនុវត្តដោយបង្ខំ ឬ ការចាត់ចែងការរក្សាការពារ ត្រូវបានលុបចោល តាមពាក្យសុំរបស់ម្ចាស់សិទ្ធិ ឬ ដោយខ្វះល័ក្ខខ័ណ្ឌតាមផ្លូវច្បាប់ ការផ្អាកអាជ្ញាយុកាលនៃលទ្ធកម្ម ដោយសកម្មភាពអនុវត្តដោយបង្ខំ ឬ ដោយសកម្មភាពចាត់ចែងការរក្សាការពារនេះ ត្រូវចាត់ទុកថាមិនបានកើតឡើងឡើយ ។

មាត្រា ១៧២.- ដំណើរការនៃអាជ្ញាយុកាលនៃលទ្ធកម្ម ក្រោយការផ្អាក

១-អាជ្ញាយុកាលនៃលទ្ធកម្មដែលត្រូវបានផ្អាក នឹងចាប់ផ្តើមគិតជាថ្មីម្តងទៀត ក្រោយពីហេតុនៃការផ្អាកបានចប់ ។

២-អាជ្ញាយុកាលនៃលទ្ធកម្មដែលត្រូវបានផ្អាកដោយការទាមទារតាមផ្លូវតុលាការនឹងចាប់ផ្តើមគិតជាថ្មីម្តងទៀត បន្ទាប់ពីសេចក្តីសម្រេចបានចូលជាស្ថាពរ ។

មាត្រា ១៧៣.- ការបង្អង់ការសម្រេចអាជ្ញាយុកាលដោយការទាមទារ

១-ប្រសិនបើម្ចាស់កម្មសិទ្ធិដើមបានទាមទារ នៅពេលណាមួយក្នុងអំឡុងពេល ៦ (ប្រាំ

មួយ) ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលនៃលទ្ធកម្ម អាជ្ញាយុកាលនៃលទ្ធកម្ម នោះមិនត្រូវបានសម្រេចចំពោះភាគីម្ខាងទៀតនៃការទាមទារនោះ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីការទាមទារឡើយ ។ ប៉ុន្តែ ទោះបីជាម្ចាស់កម្មសិទ្ធិដើមទាមទារម្តងទៀតក៏ដោយ ក៏មិនអាចពន្យឺតការសម្រេចអាជ្ញាយុកាលនៃលទ្ធកម្ម ដោយការទាមទារម្តងទៀតនោះដែរ ។

២-ទោះបីជាការទាមទារតាមផ្លូវតុលាការ មិនបង្កើតអានុភាពនៃការផ្អាកអាជ្ញាយុកាល ដោយសារការលើកចោលបណ្តឹង ឬ ការដកពាក្យបណ្តឹងក៏ដោយ ក៏ត្រូវចាត់ទុកថាអ្នកប្តឹង បានទាមទារជាបន្ត ចាប់ពីពេលដែលពាក្យបណ្តឹងត្រូវបានបញ្ជូនទៅភាគីម្ខាងទៀត រហូតដល់ពេលដែលបណ្តឹងនោះត្រូវបានលើកចោល ឬ ពេលដែលពាក្យបណ្តឹង នោះត្រូវបានដកដែរ ។ ក្នុងករណីនេះ អាជ្ញាយុកាលនៃលទ្ធកម្មនោះមិនត្រូវបានសម្រេច ចំពោះភាគីម្ខាងទៀតនោះក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីការលើកចោលបណ្តឹង ឬ ការដកពាក្យបណ្តឹងឡើយ ។

៣-ប្រសិនបើម្ចាស់កម្មសិទ្ធិដើមបានអះអាងសិទ្ធិរបស់ខ្លួន ក្នុងនាមជាចុងចម្លើយក្នុងបណ្តឹងនោះ ត្រូវចាត់ទុកថា អ្នកនោះទាមទារជាបន្ត ក្នុងពេលដែលបណ្តឹងនោះកំពុងចាត់ការ ចាប់ពីពេលដែលអ្នកនោះអះអាងសិទ្ធិរបស់ខ្លួន ។ ក្នុងករណីនេះ អាជ្ញាយុកាលនៃលទ្ធកម្មនោះ មិនត្រូវសម្រេចចំពោះដើមចោទ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីសាលក្រម ឬ សាលដីកានៃបណ្តឹងនោះចូលជាស្ថាពរ ។

មាត្រា ១៧៤.- ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃលទ្ធកម្ម ចំពោះអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ

ប្រសិនបើអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ គ្មានអ្នកតំណាងដែលច្បាប់បានកំណត់នៅពេលណាមួយ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលនៃលទ្ធកម្ម អាជ្ញាយុកាលនៃលទ្ធកម្មនោះ មិនត្រូវបានសម្រេចចំពោះអ្នកនោះក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីពេលដែលអ្នកនោះ ក្លាយទៅជាសមត្ថជន ឬ ពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់ត្រូវបានជ្រើសតាំងឡើយ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

មាត្រា ១៧៥.- ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃលទ្ធកម្ម ខាងអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ និង អ្នកតំណាងដែលច្បាប់បានកំណត់

ក្នុងករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់សម្រាប់អនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ ធ្វើលទ្ធកម្មដោយអាជ្ញាយុកាលនូវកម្មសិទ្ធិលើអចលនវត្ថុដែលជាកម្មសិទ្ធិរបស់អនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅនោះ អាជ្ញាយុកាលនៃលទ្ធកម្មនោះ មិនត្រូវបានសម្រេចក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីពេលដែលអ្នកនោះក្លាយទៅជាសមត្ថជន ឬ ពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់ថ្មីត្រូវបានជ្រើសតាំងឡើយ ។

មាត្រា ១៧៦.- ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃលទ្ធកម្មខាងប្តីប្រពន្ធ

ក្នុងករណីដែលសហព័ទ្ធម្ខាងធ្វើលទ្ធកម្មដោយអាជ្ញាយុកាលនូវកម្មសិទ្ធិលើអចលនវត្ថុដែលជាកម្មសិទ្ធិរបស់សហព័ទ្ធម្ខាងទៀត អាជ្ញាយុកាលនៃលទ្ធកម្មនោះមិនត្រូវបានសម្រេច ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ក្រោយពីការរលាយអាពាហ៍ពិពាហ៍នោះឡើយ ។

មាត្រា ១៧៧.- ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃលទ្ធកម្មដោយសារមហន្តរាយធម្មជាតិ

ប្រសិនបើម្ចាស់កម្មសិទ្ធិដើមមិនអាចផ្អាកអាជ្ញាយុកាលនៃលទ្ធកម្ម ដោយសារការជួបប្រទះនូវគ្រោះមហន្តរាយធម្មជាតិ ឬ ប្រធានសក្តិផ្សេង នៅពេលណាមួយក្នុង ៦ (ប្រាំមួយ) ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលនៃលទ្ធកម្ម អាជ្ញាយុកាលនៃលទ្ធកម្មនេះមិនត្រូវបានសម្រេចក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីប្រធានសក្តិនោះបានកន្លងផុតឡើយ ។

មាត្រា ១៧៨.- អាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិដែលទាក់ទងនឹងអចលនវត្ថុ

១-ជនដែលបានប្រើសិទ្ធិដែលទាក់ទងនឹងអចលនវត្ថុ ដូចជាសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ សិទ្ធិជួល សិទ្ធិលើការបញ្ចាំ ជាអាទិ៍ ដោយសន្តិវិធី និង ដឹងឮជាសាធារណៈ ដោយមានឆន្ទៈប្រើសម្រាប់ខ្លួន ត្រូវលទ្ធកម្មនូវសិទ្ធិនោះក្រោយពេល ២០ (ម្ភៃ) ឆ្នាំ ឬ ១០ (ដប់) ឆ្នាំ តាមការបែងចែកដែលបានកំណត់នៅក្នុងមាត្រា ១៦២ (អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុ) នៃក្រមនេះ ។ ប៉ុន្តែ សេវភាពអាចត្រូវបានលទ្ធកម្មនៅក្នុងករណីដែលល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងមាត្រា ៣០០ (អាជ្ញាយុកាលនៃលទ្ធកម្ម

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

8/453

សេរីភាព) នៃក្រមនេះ ត្រូវបានបំពេញផងដែរ ។

២-បញ្ញត្តិពីមាត្រា ១៦៣ (អានុភាពប្រតិសកម្មនៃអាជ្ញាយុកាលនៃលទ្ធកម្ម) ដល់មាត្រា ១៧៧ (ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃលទ្ធកម្មដោយសារមហន្តរាយធម្មជាតិ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ទោះបីជាប្រភេទណាក៏ដោយ ។

មាត្រា ១៧៩.- កម្មសិទ្ធិនៃដីដុះ

ដីដែលដុះដែលកើនឡើងជាបន្តបន្ទាប់ បន្តិចម្តងៗដោយធម្មជាតិ លើដីជាប់មាត់ទន្លេ ស្ទឹង ឬ ព្រែក ត្រូវបានធ្លាក់ទៅកម្មសិទ្ធិករដែលមានដីជាប់មាត់ទន្លេ ស្ទឹង ឬ ព្រែក ដែលបង្កើតដីដុះនោះ ទោះបីជានាវា ឬ ក្បូនអាចចេញចូលទន្លេ ស្ទឹង ឬ ព្រែកនោះបាន បណ្តែតបាន ឬ មិនបានក៏ដោយ ។ ចំពោះទន្លេ ស្ទឹង ឬ ព្រែកដែលនាវា ឬ ក្បូនអាចចេញចូលបាន បណ្តែតបាន កម្មសិទ្ធិករនៃដីជាប់មាត់ទន្លេ ស្ទឹង ឬ ព្រែក ត្រូវទុកផ្លូវសម្រាប់ទាញពួរនាវា ឬ ក្បូន ដោយស្របទៅតាមច្បាប់ ឬ បទដ្ឋានគតិយុត្ត ។

មាត្រា ១៨០.- កម្មសិទ្ធិនៃដីដុះ

ចំពោះដីដែលកើនឡើងដោយសារចរន្តទឹកហូរ នាំដីដុះរបស់អ្នកនៅច្រាំងម្ខាងទៅគរនៅច្រាំងម្ខាងទៀតបន្តិចម្តងៗ តាមធម្មជាតិ កម្មសិទ្ធិករនៃដីដែលជាប់នឹងដីដុះនោះ ត្រូវទទួលផលប្រយោជន៍នៃដីដុះនេះ ។ កម្មសិទ្ធិករនៅច្រាំងម្ខាងទៀតដែលបាត់ដី មិនអាចទាមទារយកដីដែលបាត់នោះបានឡើយ ។

មាត្រា ១៨១.- សិទ្ធិទាមទារឱ្យប្រគល់វិញនូវដីដែលបានហូរទៅភ្ជាប់នឹងដីផ្សេង

ចំពោះទន្លេ ស្ទឹង ឬ ព្រែកដែលនាវា ឬ ក្បូនចេញចូលបាន បណ្តែតបាន ឬ មិនបានក៏ដោយ ក្នុងករណីដែលទន្លេ ស្ទឹង ឬ ព្រែកនោះ បាននាំយកចំណែកដីដ៏ធំ ដែលអាចទទួលស្គាល់យ៉ាងច្បាស់លាស់ ដោយកម្លាំងទឹកជំនន់ភ្លាមៗ ពីច្រាំងម្ខាងទៅភ្ជាប់នឹងដីក្រោមខ្សែទឹក ឬ នៅ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

1453

ច្រាំងម្ខាងទៀត កម្មសិទ្ធិករនៃដីបាក់អាចទាមទារឱ្យប្រគល់វិញនូវផ្នែកនៃដីនោះបាន ។ កម្មសិទ្ធិ-ករនោះត្រូវអនុវត្តសិទ្ធិទាមទារឱ្យប្រគល់វិញនូវផ្នែកនៃដីនោះ ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកម្មសិទ្ធិករដែលបានដីបាក់ទៅភ្ជាប់នោះ មិនទាន់បានកាន់កាប់ដីនោះនៅឡើយ ។

មាត្រា ១៨២.- កម្មសិទ្ធិនៃកោះ និង ដីដុះ

កោះ និង ដីដុះ ដែលកើតនៅផ្ទៃទន្លេ ឬ ស្ទឹងដែលនាវា ឬ ក្បូនអាចចេញចូលបាន បណ្ដែតបាន ត្រូវជាកម្មសិទ្ធិរបស់រដ្ឋ ។

មាត្រា ១៨៣.- កម្មសិទ្ធិនៃកោះ និង ដីដុះ

ចំពោះកោះ និង ដីដុះ ដែលកើតនៅផ្ទៃទន្លេ ស្ទឹង ឬ ព្រែកដែលនាវា ឬ ក្បូនមិនអាចចេញចូល មិនអាចបណ្ដែតបាន ត្រូវបានទៅកម្មសិទ្ធិករនៃដីខាងច្រាំងដែលមានកោះ ឬ ដីដុះនោះ ។ ប្រសិនបើកោះ និង ដីដុះនោះមិនបានដុះផ្អៀងទៅច្រាំងម្ខាងទេនោះ ត្រូវបានទៅកម្ម-សិទ្ធិករដែលមានដីជាប់ច្រាំងទាំងសងខាង ដោយយកខ្សែបន្ទាត់កណ្ដាល ទន្លេ ស្ទឹង ឬ ព្រែកនោះជាមូលដ្ឋាន ។

មាត្រា ១៨៤.- កម្មសិទ្ធិនៃកោះ

ប្រសិនបើទន្លេ ស្ទឹង ឬ ព្រែកបានបង្កើតផ្លូវទឹកថ្មី ហើយកាត់ផ្ដាច់ដីរបស់កម្មសិទ្ធិករនៅជាប់មាត់ច្រាំង ហើយបង្កើតជាកោះ ទោះបីជាកោះនោះដុះនៅក្នុងទន្លេ ស្ទឹង ឬ ព្រែក ដែលនា-វា ឬ ក្បូនអាចចេញចូលបាន បណ្ដែតបានក៏ដោយ ក៏កម្មសិទ្ធិករនៅជាប់មាត់ច្រាំងមិនបាត់បង់នូវកម្មសិទ្ធិនៃដីនោះឡើយ ។

មាត្រា ១៨៥.- កម្មសិទ្ធិនៃបាតទន្លេ ឬ ស្ទឹងចាស់ដោយសារការបង្កើតផ្លូវទឹកថ្មី

នៅពេលទន្លេ ស្ទឹង ឬ ព្រែកដែលនាវា ឬ ក្បូនអាចចេញចូលបាន បណ្ដែតបានបង្កើតផ្លូវទឹកថ្មី ដោយបោះបង់ចោលផ្លូវទឹកចាស់ កម្មសិទ្ធិករនៃដីជាប់មាត់ច្រាំងនោះអាចធ្វើលទ្ធកម្មកម្មសិទ្ធិនៃបាតទន្លេ ស្ទឹង ឬ ព្រែកចាស់ ហើយទំហំនៃកម្មសិទ្ធិលើដីគោករបស់ម្នាក់ៗ ត្រូវមានព្រំប្រទល់ត្រឹមខ្សែបន្ទាត់កណ្ដាលនៃទន្លេ ស្ទឹង ឬ ព្រែកនោះ ។ កម្មសិទ្ធិករនៃដីជាប់មាត់ច្រាំងនោះ

ត្រូវបង់តម្លៃដែលត្រូវបានកំណត់ដោយអ្នកវាយតម្លៃ ។ តម្លៃនៃបាតទន្លេ ស្ទឹង ឬ ព្រែកចាស់ ត្រូវបានកំណត់ដោយអ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំង ដោយតុលាការដែលមានសមត្ថកិច្ច លើទីកន្លែងនោះ តាមពាក្យសុំរបស់អាជ្ញាធរខេត្ត-ក្រុង ឬ អ្នកដែលមានពាក់ព័ន្ធផលប្រយោជន៍ ។ ប៉ុន្តែ ក្នុងករណីដែលកម្មសិទ្ធិករនៃដីជាប់មាត់ច្រាំងនោះ មិនបង្ហាញឆន្ទៈយកកម្មសិទ្ធិលើបាតទន្លេ ស្ទឹង ឬ ព្រែកចាស់នោះទេ ដីគោកនោះត្រូវបានលក់ជាសាធារណៈដោយអាជ្ញាធរខេត្ត-ក្រុង ។ ប្រាក់ដែលកម្មសិទ្ធិករនៃដីជាប់មាត់ច្រាំងបានបង់ ឬ ប្រាក់ដែលបានទទួលពីការលក់បាតទន្លេ ស្ទឹង ឬ ព្រែកចាស់ នោះត្រូវបែងចែកឱ្យកម្មសិទ្ធិករដែលបានបាត់បង់ដីដោយសារការបង្កើតផ្លូវទឹកថ្មី តាមសមាមាត្រនៃតម្លៃដីដែលបានបាត់បង់ដោយសារទឹកហូរ ។

មាត្រា ១៨៦.- ការជាប់គ្នារវាងចលនវត្ថុ និង អចលនវត្ថុ

ក្នុងករណីដែលចលនវត្ថុបានក្លាយជាផ្នែកមួយនៃអចលនវត្ថុ ដោយភ្ជាប់ជាមួយនឹងអចលនវត្ថុនោះ កម្មសិទ្ធិលើអចលនវត្ថុនោះ ត្រូវមានអានុភាពទៅលើចលនវត្ថុនោះផងដែរ លើកលែងតែមានបញ្ញត្តិនៃច្បាប់ ឬ ការព្រមព្រៀងពិសេស ។ ក្នុងករណីនេះ អ្នកដែលបានបាត់បង់កម្មសិទ្ធិលើចលនវត្ថុ អាចទាមទារប្រាក់សំណងបាន តាមបញ្ញត្តិស្តីពីសេចក្តីចម្រើនដោយឥតហេតុ តែមិនអាចទាមទារឱ្យធ្វើបដិទានបានឡើយ ។

កថាភាគទី ២
លទ្ធកម្មនៃកម្មសិទ្ធិលើចលនវត្ថុ

មាត្រា ១៨៧.- លទ្ធកម្មនៃកម្មសិទ្ធិលើចលនវត្ថុ

កម្មសិទ្ធិលើចលនវត្ថុ អាចត្រូវបានធ្វើលទ្ធកម្មដោយកិច្ចសន្យា សន្តតិកម្ម និង ហេតុដែលបានកំណត់នៅក្នុងផ្នែកទី ៤ (លទ្ធកម្មនៃកម្មសិទ្ធិ) នេះ ព្រមទាំងតាមបញ្ញត្តិនៃក្រមនេះ ឬ ច្បាប់ផ្សេង ។

មាត្រា ១៨៨.- កម្មសិទ្ធិនៃចលនវត្ថុគ្មានម្ចាស់

ចលនវត្ថុដែលគ្មានម្ចាស់ ត្រូវជាកម្មសិទ្ធិរបស់អ្នកកាន់កាប់វត្ថុនោះមុនគេ ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមាន

បញ្ញត្តិពិសេសនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្ត ស្តីពីការការពារសត្វព្រៃ ។

មាត្រា ១៨៩.- កម្មសិទ្ធិលើសត្វដែលរត់ចេញ ជារបាយ

ជនដែលកាន់កាប់ដោយសុចរិតនូវសត្វ ឬ បក្សីដែលមិនមែនជាបសុសត្វ ឬ បសុបក្សី ហើយដែលអ្នកដទៃចិញ្ចឹម ត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើសត្វ ឬ បក្សីនោះ លុះត្រាតែមិនទទួលការទាមទារពីអ្នកចិញ្ចឹម ក្នុងអំឡុងពេល ១(មួយ) ខែ គាំងពីពេលសត្វ ឬ បក្សីនោះរត់ចេញ ។

មាត្រា ១៩០.- កម្មសិទ្ធិលើត្រីរស់ក្នុងបឹង ឬ ស្រះ

ត្រីដែលរស់ក្នុងបឹង ឬ ស្រះដែលជាកម្មសិទ្ធិឯកជន ត្រូវបានទៅកម្មសិទ្ធិករនៃបឹង ឬ ស្រះនោះ ។

មាត្រា ១៩១.- កម្មសិទ្ធិនៃវត្ថុបាត់

១-អ្នកដែលបានរើសវត្ថុដែលអ្នកដទៃបានបាត់ ប្រសិនបើដឹងកម្មសិទ្ធិករនៃវត្ថុនោះច្បាស់លាស់ ត្រូវប្រគល់វត្ថុនោះឱ្យកម្មសិទ្ធិករវិញ ហើយប្រសិនបើមិនដឹងកម្មសិទ្ធិករនៃវត្ថុនោះច្បាស់លាស់ទេ ត្រូវប្រគល់វត្ថុនោះជូនប្រធានប៉ុស្តិ៍នគរបាល ក្នុងអំឡុងពេល ៧ (ប្រាំពីរ) ថ្ងៃ ក្រោយពេលបានរើស ។

២-ប្រធានប៉ុស្តិ៍នគរបាល ត្រូវរក្សាទុកនូវវត្ថុរើសបាននោះ ហើយប្រកាសជាសាធារណៈ ហើយប្រសិនបើមិនឃើញមានកម្មសិទ្ធិករក្នុងអំឡុង ៦ (ប្រាំមួយ) ខែ ទេ អ្នករើសត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុនោះ ។ ប៉ុន្តែ ប្រសិនបើអ្នករើស មិនបានប្រគល់ជូន ទៅប្រធានប៉ុស្តិ៍នគរបាល ក្នុងអំឡុងពេល ៧ (ប្រាំពីរ) ថ្ងៃ ក្រោយពេលបានរើសទេ អ្នករើសនេះមិនអាចធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុបានទេ ហើយវត្ថុនោះត្រូវធ្លាក់ទៅជាកម្មសិទ្ធិរបស់រដ្ឋ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នករើសមិនមកយកវត្ថុរើស ក្នុងអំឡុងពេល ២ (ពីរ) ខែក្រោយពេលខ្លួនបានធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុនោះ ។

៣-ប្រសិនបើវត្ថុរើសបាននោះជាវត្ថុដែលមិនអាចទុកយូរបាន ប្រធានប៉ុស្តិ៍នគរបាលអាចលក់វត្ថុនោះ ហើយរក្សាទុកនូវប្រាក់លក់នោះបាន ។ ការចាត់ចែងប្រាក់លក់នេះ ត្រូវធ្វើដូចគ្នានឹងការបាត់បង់វត្ថុរើស ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៤-ក្នុងករណីដែលវត្ថុរើសត្រូវបានប្រគល់ឱ្យកម្មសិទ្ធិករវិញ កម្មសិទ្ធិករត្រូវផ្តល់ប្រាក់រង្វាន់ទៅអ្នករើសពី ៥ (ប្រាំ) ភាគរយ ទៅ ២០ (ម្ភៃ) ភាគរយ នៃតម្លៃវត្ថុនោះ ។ អ្នករើសត្រូវបាត់បង់សិទ្ធិទាមទារប្រាក់រង្វាន់នេះ ប្រសិនបើអ្នកនោះ មិនទាមទារក្នុងអំឡុងពេល ១ (មួយ) ខែ ក្រោយពេលកម្មសិទ្ធិករបានទទួលយកវត្ថុនោះ ។

មាត្រា ១៩២.- កម្មសិទ្ធិលើកំណប់

បញ្ញត្តិនៃមាត្រា ១៩១ (កម្មសិទ្ធិនៃវត្ថុបាត់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះកំណប់ លើកលែងតែករណីដែលបានកំណត់នៅក្នុងមាត្រា ១៤១ (ការជីកកកាយបេតិកភណ្ឌវប្បធម៌ និង រ៉ែក្នុងដី) នៃក្រមនេះ ។ ប៉ុន្តែ ក្នុងករណីដែលកំណប់ដែលមិនដឹងច្បាស់អំពីកម្មសិទ្ធិករ ត្រូវបានរកឃើញនៅក្នុងវត្ថុដែលជាកម្មសិទ្ធិរបស់អ្នកដទៃ អ្នករកឃើញ និង កម្មសិទ្ធិករនៃវត្ថុនោះ ត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើកំណប់នោះពាក់កណ្តាលម្នាក់ ។

មាត្រា ១៩៣.- លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ

អ្នកដែលបានទទួលការផ្ទេរការកាន់កាប់នូវចលនវត្ថុ ដោយកិច្ចសន្យាអនុប្បទានកម្មសិទ្ធិ ដែលមានសុពលភាព ហើយដោយសុចរិត និង គ្មានកំហុស ត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុនោះ ទោះបីជាអនុប្បទាយីគ្មានកម្មសិទ្ធិលើចលនវត្ថុនោះក៏ដោយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអនុប្បទាយីនៅតែបន្តការកាន់កាប់ដោយចំពោះ ។

មាត្រា ១៩៤.- អនុប្បទាននូវវត្ថុលួច ឬ វត្ថុបាត់

១-ក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ ប្រសិនបើវត្ថុដែលត្រូវបានធ្វើអនុប្បទាននោះ ជាវត្ថុលួច ឬ វត្ថុបាត់ ជនរងគ្រោះ ឬ ម្ចាស់វត្ថុបាត់នោះអាចទាមទារឱ្យអនុប្បទានិកនោះ សងវត្ថុនោះមកវិញបានក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ គិតតាំងពីពេលបាត់ ឬ ពេលត្រូវបានលួច ។

២-ប្រសិនបើអនុប្បទានិកបានទិញវត្ថុបាត់ ឬ លួចនោះ ដោយសុចរិត តាមរយៈការលក់ដេញថ្លៃ ឬ នៅផ្សារសាធារណៈ ឬ ពីពាណិជ្ជករ ឬ អាជីវករដែលលក់វត្ថុប្រភេទដូចគ្នានេះ ជនរងគ្រោះ ឬ ម្ចាស់វត្ថុបាត់មិនអាចទាមទារឱ្យសងវត្ថុនោះវិញបានឡើយ បើមិនសងប្រាក់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ដែលអ្នកកាន់កាប់នោះបានបង់ ។

មាត្រា ១៩៥.- អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ

១-ជនដែលបានកាន់កាប់ចលនវត្ថុ ដោយសន្តិវិធី និង ដឹងឮជាសាធារណៈ ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ក្នុងអំឡុងពេល ១០ (ដប់) ឆ្នាំ ត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើចលនវត្ថុនោះ ។

២-ជនដែលបានកាន់កាប់ចលនវត្ថុ ដោយសន្តិវិធី និង ដឹងឮជាសាធារណៈ ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ ត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើ ចលនវត្ថុនោះ បើជននោះសុចរិត និង គ្មានកំហុស នៅពេលដែលខ្លួនបានចាប់ផ្តើមកាន់កាប់ ។

មាត្រា ១៩៦.- អាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិដែលទាក់ទងនឹងចលនវត្ថុ និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

ជនដែលបានប្រើសិទ្ធិដែលទាក់ទងនឹងចលនវត្ថុ ដូចជាសិទ្ធិលើការបញ្ចាំ សិទ្ធិផ្លុលជាអាទិ៍ និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ដោយសន្តិវិធី និង ដឹងឮជាសាធារណៈដោយមានឆន្ទៈប្រើសម្រាប់ខ្លួន ត្រូវលទ្ធកម្មនូវសិទ្ធិនោះ ក្រោយពេល ១០ (ដប់) ឆ្នាំ ឬ ៥ (ប្រាំ) ឆ្នាំ តាមការបែងចែកដែលបានកំណត់នៅក្នុងមាត្រា ១៩៥ (អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ ។

មាត្រា ១៩៧.- ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីអាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុ

បញ្ញត្តិពីមាត្រា ១៦៣ (អានុភាពប្រតិសកម្មនៃអាជ្ញាយុកាលនៃលទ្ធកម្ម) ដល់មាត្រា ១៧៧ (ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃលទ្ធកម្មដោយសារមហន្តរាយធម្មជាតិ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះមាត្រា ១៩៥ (អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ) និងមាត្រា ១៩៦ (អាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិដែលទាក់ទងនឹងចលនវត្ថុ និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) នៃក្រមនេះ ។

មាត្រា ១៩៨.- ការជាប់គ្នា ការលាយច្របល់គ្នានៃចលនវត្ថុ

១-ក្នុងករណីដែលចលនវត្ថុជាច្រើនបានភ្ជាប់គ្នា ហើយមិនអាចបំបែកចេញបានដោយមិនធ្វើឱ្យខូចខាតនោះ កម្មសិទ្ធិនៃវត្ថុភ្ជាប់គ្នានេះ ត្រូវធ្លាក់ទៅកម្មសិទ្ធិករនៃចលនវត្ថុដែល

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ជាចំណែកចម្បង ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលត្រូវចំណាយសោហ៊ុយហួសហេតុសម្រាប់ការបំបែក ។

២-នៅពេលដែលមិនអាចបែងចែកអំពីចំណែកចម្បង ឬ ចំណែកបន្ទាប់បន្សំចំពោះចលនវត្ថុដែលភ្ជាប់គ្នា កម្មសិទ្ធិករនៃវត្ថុនីមួយៗ ត្រូវមានកម្មសិទ្ធិអវិភាគលើវត្ថុនោះតាមសមាមាត្រនៃតម្លៃវត្ថុនីមួយៗនាពេលបានជាប់គ្នា ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលចលនវត្ថុជាច្រើនត្រូវបានលាយច្របល់គ្នា ហើយមិនអាចបំបែកចេញបាននោះ ។

មាត្រា ១៩៩.- ការកែច្នៃចលនវត្ថុ

១-ជនដែលផលិតចលនវត្ថុមួយថ្មី ដោយយកវត្ថុធាតុដើមរបស់អ្នកដទៃមកកែច្នៃ ឬ កែប្រែ ត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុកែច្នៃនោះ ។ ប៉ុន្តែ ប្រសិនបើតម្លៃកើនឡើងដោយការកែច្នៃ ឬ កែប្រែនោះ តិចហួសហេតុជាងតម្លៃវត្ថុធាតុដើម កម្មសិទ្ធិលើវត្ថុកែច្នៃនោះ ត្រូវធ្លាក់ទៅម្ចាស់នៃវត្ថុធាតុដើម ។

២-ក្នុងករណីអ្នកកែច្នៃវត្ថុបានផ្តល់វត្ថុធាតុដើមមួយចំណែក មានតែករណីដែលតម្លៃវត្ថុធាតុដើម ព្រមទាំងតម្លៃកើនឡើងដោយការកែច្នៃ ឬ កែប្រែនោះ លើសពីតម្លៃវត្ថុធាតុដើមនៃអ្នកដទៃទេ ទើបអ្នកកែច្នៃត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុកែច្នៃនោះ ។

មាត្រា ២០០.- អានុភាពនៃខ្សែបាតបង់នៃចលនវត្ថុ

១-ក្នុងករណីដែលកម្មសិទ្ធិលើវត្ថុត្រូវរលត់ ដោយសារការជាប់គ្នា ការលាយច្របល់គ្នា ឬ ការកែច្នៃ សិទ្ធិដែលមាននៅលើវត្ថុនោះក៏ត្រូវរលត់ដែរ ។

២-សិទ្ធិរបស់អ្នកដទៃដែលមានលើវត្ថុ ដែលធ្លាប់ជាកម្មសិទ្ធិរបស់ជនដែលក្លាយជាកម្មសិទ្ធិករនៃវត្ថុភ្ជាប់គ្នា វត្ថុលាយច្របល់គ្នា ឬ វត្ថុកែច្នៃ ត្រូវបន្តអត្ថិភាពលើវត្ថុដែលត្រូវបានធ្វើលទ្ធកម្មជាថ្មីនេះទៀត ។ ក្នុងករណីនេះ ប្រសិនបើក្លាយជាម្ចាស់កម្មសិទ្ធិអវិភាគសិទ្ធិនោះ ត្រូវបន្តអត្ថិភាពលើចំណែកនៃម្ចាស់កម្មសិទ្ធិអវិភាគនោះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា ២០១.- ខូចខាតចលនវត្ថុ និង សិទ្ធិទាមទារប្រាក់សំណង

ជនដែលបាត់បង់សិទ្ធិដោយសារការជាប់គ្នា ការលាយគ្នា ការច្របល់គ្នា ឬ ការកែច្នៃនៃចលនវត្ថុ អាចទាមទារប្រាក់សំណងចំពោះអ្នកដែលបានធ្វើលទ្ធកម្មសិទ្ធិ និង ទទួលផលប្រយោជន៍បានតាមបញ្ញត្តិស្តីពីសេចក្តីចម្រើនដោយឥតហេតុ តែមិនអាចទាមទារឱ្យធ្វើបដិទានបានឡើយ ។

ផ្នែកទី ៥

កម្មសិទ្ធិអវិភាគ

មាត្រា ២០២.- និយមន័យនៃកម្មសិទ្ធិអវិភាគ

ស្ថានភាពដែលបុគ្គលច្រើននាក់មានកម្មសិទ្ធិស្របទៅតាមភាគចំណែករបស់ខ្លួន ដែលគិតទៅតាមចំនួននៅលើទ្រព្យតែមួយ ហៅថាកម្មសិទ្ធិអវិភាគ ។

មាត្រា ២០៣.- សមភាពនៃចំណែកកម្មសិទ្ធិអវិភាគ

ចំណែកនៃម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ ត្រូវបានសន្មតថាស្មើគ្នា ។

មាត្រា ២០៤.- ការចាត់ចែងចំណែកនៃកម្មសិទ្ធិអវិភាគ

ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ អាចធ្វើអនុប្បទាន ឬ ដាក់ជាប្រាតិភោគនូវចំណែករបស់ខ្លួនបាន ។ ម្ចាស់បំណុលនៃម្ចាស់កម្មសិទ្ធិអវិភាគនេះ អាចរឹបអូសចំណែកនោះបាន ។

មាត្រា ២០៥.- ការប្រើប្រាស់វត្ថុកម្មសិទ្ធិអវិភាគ

ម្ចាស់កម្មសិទ្ធិអវិភាគ អាចប្រើប្រាស់វត្ថុកម្មសិទ្ធិអវិភាគទាំងមូល តាមសមាមាត្រនៃចំណែករបស់ខ្លួនបាន ។

មាត្រា ២០៦.- ការថែទាំវត្ថុកម្មសិទ្ធិអវិភាគ

ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ អាចធ្វើសកម្មភាពថែទាំវត្ថុកម្មសិទ្ធិអវិភាគដោយឯកឯងបាន ។

មាត្រា ២០៧.- ការផ្លាស់ប្តូរមុខងារប្រើប្រាស់នៃវត្ថុកម្មសិទ្ធិអវិភាគ

ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ មិនអាចចាត់ចែងវត្ថុកម្មសិទ្ធិអវិភាគ ឬ ធ្វើការផ្លាស់ប្តូរអ្វី

ROYAUME DU CAMBODGE LE MINISTRE ...

សិខាន់ៗទៅលើវត្ថុកម្មសិទ្ធិអវិភាគបានឡើយ លើកលែងតែមានការយល់ព្រមពីម្ចាស់កម្មសិទ្ធិអវិភាគផ្សេងទៀត ។

មាត្រា ២០៨.- ការគ្រប់គ្រងវត្ថុកម្មសិទ្ធិអវិភាគ

កិច្ចការទាំងឡាយដែលទាក់ទងនឹងការគ្រប់គ្រងវត្ថុកម្មសិទ្ធិអវិភាគ ត្រូវសម្រេចដោយមតិភាគច្រើន តាមតម្លៃនៃចំណែករបស់ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ លើកលែងតែករណីដែលបានកំណត់នៅក្នុងមាត្រា ២០៦ (ការថែទាំវត្ថុកម្មសិទ្ធិអវិភាគ) និងមាត្រា ២០៧ (ការផ្លាស់ប្តូរមុខងារប្រើប្រាស់នៃវត្ថុកម្មសិទ្ធិអវិភាគ) នៃក្រមនេះ ។

មាត្រា ២០៩.- បន្ទុកនៃវត្ថុកម្មសិទ្ធិអវិភាគ

១-ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ ត្រូវទទួលបន្ទុកក្នុងការបង់សោហ៊ុយគ្រប់គ្រងពន្ធដារជាអាទិ៍ តាមសមាមាត្រនៃចំណែករៀងៗខ្លួន ។

២-ប្រសិនបើម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់បានបង់សោហ៊ុយដើម្បីការថែទាំ គ្រប់គ្រង ឬ បន្ទុកផ្សេងទៀតដែលលើសពីបន្ទុករបស់ខ្លួន ម្ចាស់កម្មសិទ្ធិអវិភាគនោះអាចទាមទារឱ្យម្ចាស់កម្មសិទ្ធិអវិភាគផ្សេងទៀតសងប្រាក់ដែលខ្លួនបានបង់លើសនោះ តាមសមាមាត្រនៃចំណែករៀងៗខ្លួនបាន ។

៣-សិទ្ធិទាមទារសងសោហ៊ុយដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះក៏អាចអនុវត្តបានដែរ ចំពោះជនដែលបានទទួលបន្តនូវចំណែករបស់ម្ចាស់កម្មសិទ្ធិអវិភាគផ្សេង ។

មាត្រា ២១០.- ការបោះបង់សិទ្ធិនៃចំណែក ជាអាទិ៍

ពេលដែលម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់ បានបោះបង់នូវចំណែករបស់ខ្លួន ឬ បានទទួលមរណភាពហើយគ្មានសន្តតិជនទេនោះ ចំណែករបស់អ្នកនោះនឹងត្រូវបានទៅម្ចាស់កម្មសិទ្ធិអវិភាគផ្សេង ។

មាត្រា ២១១.- សិទ្ធិទាមទារបែងចែកវត្ថុកម្មសិទ្ធិអវិភាគ

១-ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ អាចទាមទារឱ្យបែងចែកវត្ថុកម្មសិទ្ធិអវិភាគបានគ្រប់ពេលវេលា ។ ប៉ុន្តែ ម្ចាស់កម្មសិទ្ធិអវិភាគអាចធ្វើកិច្ចសន្យាហាមមិនឱ្យបែងចែកវត្ថុកម្មសិទ្ធិអវិ-

ROYAUME DU CAMBODGE LE MINISTERE DU PALAIS ROYAL

ភាគ ក្នុងអំឡុងពេលដែលមិនលើសពី ៥ (ប្រាំ) ឆ្នាំ បាន ។

២-កិច្ចសន្យាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចធ្វើបន្តបានតែកិច្ចសន្យាដែលត្រូវបានធ្វើបន្តថ្មីនេះ មិនអាចមានអំឡុងពេលលើសពី ៥ (ប្រាំ) ឆ្នាំបានឡើយ ។

មាត្រា ២១២.- វិធីបែងចែកវត្ថុកម្មសិទ្ធិអវិភាគ

ក្នុងករណីការពិភាក្សារបស់ម្ចាស់កម្មសិទ្ធិអវិភាគអំពីការបែងចែកមិនអាចសម្របសម្រួលគ្នាបានទេ ម្ចាស់កម្មសិទ្ធិអវិភាគអាចទាមទារការបែងចែង ដោយប្តឹងទៅតុលាការ បាន ។ ក្នុងករណីនេះ តុលាការអាចបង្គាប់ឱ្យបែងចែកវត្ថុ តាមរូបដើមរបស់វា ឬ ប្រសិនបើមានការបារម្ភថា ការបែងចែកតាមរូបដើមនឹងធ្វើឱ្យខូចតម្លៃហួសហេតុ ឬ ប្រសិនបើមានមូលហេតុសមរម្យ តុលាការអាចបង្គាប់ឱ្យលក់ដេញថ្លៃហើយចែកប្រាក់លក់នោះតាមចំណែក ឬ អាចបង្គាប់ឱ្យផ្ទេរចំណែកកម្មសិទ្ធិអវិភាគមួយភាគឱ្យម្ចាស់កម្មសិទ្ធិអវិភាគផ្សេង ដោយឱ្យបង់ប្រាក់សំណងនៃចំណែកនោះបាន ។

មាត្រា ២១៣.- សិទ្ធិលើបំណុលពាក់ព័ន្ធនឹងកម្មសិទ្ធិអវិភាគ

១-ប្រសិនបើម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់ មានសិទ្ធិលើបំណុលចំពោះម្ចាស់កម្មសិទ្ធិអវិភាគឯទៀត ដោយសារការថែទាំ គ្រប់គ្រង ឬ បន្ទុកផ្សេងទៀតទៅលើវត្ថុកម្មសិទ្ធិអវិភាគ កម្មសិទ្ធិអវិភាគនោះអាចឱ្យកូនបំណុលសង ដោយយកចំណែកនៃវត្ថុកម្មសិទ្ធិអវិភាគដែលជាចំណែករបស់កូនបំណុលនោះ នៅពេលបែងចែក បាន ។

២-ប្រសិនបើមានភាពចាំបាច់ត្រូវលក់ចំណែកនៃវត្ថុកម្មសិទ្ធិអវិភាគរបស់កូនបំណុលដើម្បីទទួលការសងសំណងដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ ម្ចាស់បំណុលអាចទាមទារការលក់នោះចំពោះតុលាការ បាន ។

មាត្រា ២១៤.- ឧបកម្មសិទ្ធិអវិភាគ

បញ្ញត្តិស្តីពីកម្មសិទ្ធិអវិភាគ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបុគ្គលជាច្រើននាក់មានសិទ្ធិលើទ្រព្យសម្បត្តិដែលក្រៅពីកម្មសិទ្ធិ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេង ។

ផ្នែកទី ៦
អឡ្យសិទ្ធិភាព

មាត្រា ២១៥.- និយមន័យនៃអឡ្យសិទ្ធិភាព

ស្ថានភាពដែលជនដែលមានកម្មសិទ្ធិលើដីជាប់គ្នា មានកម្មសិទ្ធិរួមដោយមានភាពអវិភាគលើជញ្ជាំង ឬ កំពែងដូចជាស្នាមភ្លោះ ភ្លឺ របង ជាអាទិ៍ ដែលនៅត្រង់ព្រំខ័ណ្ឌដី ឬ អគារលើដីនោះ ហៅថាអឡ្យសិទ្ធិភាព ។

មាត្រា ២១៦.- ជញ្ជាំងអឡ្យសិទ្ធិ

ចំពោះជញ្ជាំងខ័ណ្ឌអគារជាប់គ្នាដែលមានកម្ពស់ខុសគ្នា ចំណែកនៃជញ្ជាំងដែលជាប់គ្នាត្រឹមអគារទាប និង របងខ័ណ្ឌដីដែលចែកសួនច្បារទាំងអស់ ត្រូវសន្មតថា នៅក្រោមអឡ្យសិទ្ធិភាព ។

មាត្រា ២១៧.- ការជួសជុល និង ការសាងសង់ឡើងវិញនូវជញ្ជាំងអឡ្យសិទ្ធិ

ការជួសជុល និង ការសាងសង់ឡើងវិញ នូវជញ្ជាំងអឡ្យសិទ្ធិ ជាបន្ទុករបស់អ្នកដែលមានអឡ្យសិទ្ធិលើជញ្ជាំងនោះ តាមសមាមាត្រទៅនឹងសិទ្ធិម្នាក់ៗ ។ អ្នកមានអឡ្យសិទ្ធិណាម្នាក់អាចរួចផុតពីបន្ទុកនៃសោហ៊ុយជួសជុល ឬ សាងសង់ឡើងវិញបាន ដោយបោះបង់អឡ្យសិទ្ធិ ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលជញ្ជាំងអឡ្យសិទ្ធិនោះជាផ្នែកមួយនៃអគារ ។

មាត្រា ២១៨.- ការប្រើប្រាស់ជញ្ជាំងអឡ្យសិទ្ធិ

កម្មសិទ្ធិករនៃអឡ្យសិទ្ធិម្នាក់ៗ អាចបោះធ្នឹម ឬ រនូតឱ្យចូលដល់ពាក់កណ្តាលនៃកម្រាស់ជញ្ជាំង ដើម្បីធ្វើការផ្សេងៗ ដោយប្រើជញ្ជាំងនោះ ។

មាត្រា ២១៩.- ការធ្វើការចំពោះជញ្ជាំងអឡ្យសិទ្ធិ

១-កម្មសិទ្ធិករនៃអឡ្យសិទ្ធិមិនអាចចោះជញ្ជាំងអឡ្យសិទ្ធិ ឬ ធ្វើការអ្វីដែលបណ្តាលឱ្យមានការខូចខាតដល់ជញ្ជាំងអឡ្យសិទ្ធិ ដោយគ្មានការយល់ព្រមពីកម្មសិទ្ធិករម្ខាងទៀតបានឡើយ ។

ROYAUME du CAMBODGE
LE MINISTRE du PALAIS ROYAL

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើកម្មសិទ្ធិករនៃអឡ្សសិទ្ធិម្ខាងទៀតបដិសេធមិនយល់ព្រម ដោយគ្មានមូលហេតុត្រឹមត្រូវ កម្មសិទ្ធិករនៃអឡ្សសិទ្ធិអាចទាមទារឱ្យតុលាការចេញសាលក្រម ឬ សាលដីកា ជំនួសការយល់ព្រមនោះ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ តុលាការអាចចេញសាលក្រម ឬ សាលដីកាជំនួសការយល់ព្រមបាន ដោយប្តូរនឹងការដាក់ប្រាតិភោគសមរម្យ ។

មាត្រា ២២០.- ការធ្វើជញ្ជាំងដែលមិនមែនអឡ្សសិទ្ធិឱ្យទៅជាជញ្ជាំងអឡ្សសិទ្ធិ

កម្មសិទ្ធិករនៃដីដែលជាប់នឹងជញ្ជាំង អាចធ្វើជញ្ជាំងនោះឱ្យទៅជាជញ្ជាំងអឡ្សសិទ្ធិ បាន ដោយចេញពាក់កណ្តាលនៃថ្លៃជញ្ជាំងនោះ និង ពាក់កណ្តាលនៃថ្លៃដីដែលសង់ជញ្ជាំងពីលើនោះ ។

មាត្រា ២២១.- ការសង់បន្ថែមកម្ពស់នៃជញ្ជាំងអឡ្សសិទ្ធិ

កម្មសិទ្ធិករនៃអឡ្សសិទ្ធិអាចសង់បន្ថែមកម្ពស់ជញ្ជាំងអឡ្សសិទ្ធិបាន ។ ប៉ុន្តែ សោហ៊ុយក្នុងការសង់បន្ថែមនោះ និង សោហ៊ុយក្នុងការជួសជុលដើម្បីថែទាំជញ្ជាំងដែលខ្ពស់ហួសកម្ពស់ដើមដែលជាអឡ្សសិទ្ធិនោះ ត្រូវក្លាយជាបន្ទុករបស់កម្មសិទ្ធិករនៃអឡ្សសិទ្ធិដែលបានសង់បន្ថែមកម្ពស់ជញ្ជាំងនោះ ។

មាត្រា ២២២.- ការសាងសង់ឡើងវិញនៃជញ្ជាំងអឡ្សសិទ្ធិ ជាអាទិ៍

១-ក្នុងករណីដែលជញ្ជាំងអឡ្សសិទ្ធិមិនអាចទ្រទ្រង់នឹងទម្ងន់ដែលសង់បន្ថែមកម្ពស់បានទេ អ្នកដែលចង់សង់បន្ថែមនោះ អាចសង់ឡើងវិញទាំងអស់បាន ដោយចំណាយសោហ៊ុយផ្ទាល់ខ្លួន ។ ប៉ុន្តែ ក្នុងករណីដែលបន្ថែមកម្រាស់វិញ ចំណែកកម្រាស់ដែលបន្ថែមនោះ ត្រូវជាបន្ទុកនៃខាងដីរបស់ខ្លួន ។

២-អ្នកជិតខាងដែលមិនបានសហការក្នុងការសង់បន្ថែមកម្ពស់ជញ្ជាំង អាចទទួលអឡ្សសិទ្ធិនៃចំណែកដែលបានបន្ថែមកម្ពស់នោះបាន ដោយបង់ពាក់កណ្តាលនៃសោហ៊ុយសង់ ហើយដោយបង់ពាក់កណ្តាលនៃថ្លៃដីដែលត្រូវការ ដើម្បីបន្ថែមកម្រាស់ ប្រសិនបើបានបន្ថែមកម្រាស់ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
0/453

មាត្រា ២២៣.- កំពែងអឡ្យសិទ្ធិ

កំពែងទាំងអស់ដែលនៅត្រង់ព្រំខណ្ឌអចលនវត្ថុ ត្រូវសន្មតថាជាវត្ថុអឡ្យសិទ្ធិរបស់កម្មសិទ្ធិករនៃអចលនវត្ថុនីមួយៗ ។

មាត្រា ២២៤.- សោហ៊ុយថែទាំកំពែង

១-កំពែងអឡ្យសិទ្ធិក្រៅពីជញ្ជាំងអឡ្យសិទ្ធិ ត្រូវថែទាំដោយសោហ៊ុយរួមរបស់កម្មសិទ្ធិករនៃកំពែងអឡ្យសិទ្ធិនោះ ។

២-កម្មសិទ្ធិករនៃកំពែងអឡ្យសិទ្ធិ អាចរួចផុតពីបន្ទុកនៃការបង់សោហ៊ុយបាន ដោយបោះបង់នូវអឡ្យសិទ្ធិរបស់ខ្លួន ។

៣-កម្មសិទ្ធិករនៃស្លាមភ្លោះដែលមានទឹកហូរ មិនអាចបោះបង់អឡ្យសិទ្ធិរបស់ខ្លួនតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះបានឡើយ ។

មាត្រា ២២៥.- កំពែងដែលមិនមែនជាវត្ថុអឡ្យសិទ្ធិ

កម្មសិទ្ធិករដែលមានអចលនវត្ថុជាប់នឹងកំពែងក្រៅពីជញ្ជាំងដែលមិនមែនជាវត្ថុអឡ្យសិទ្ធិ មិនអាចទាមទារឱ្យកម្មសិទ្ធិករនៃកំពែងនោះធ្វើជាវត្ថុអឡ្យសិទ្ធិបានឡើយ ។

មាត្រា ២២៦.- របងអឡ្យសិទ្ធិ ជាអាទិ៍

១-កម្មសិទ្ធិករនៃរបងអឡ្យសិទ្ធិ អាចយករបងចេញ តាមកម្រិតនៃកម្មសិទ្ធិរបស់ខ្លួនបាន ។ ប៉ុន្តែ កម្មសិទ្ធិករនោះ មានករណីយកិច្ចធ្វើជញ្ជាំង នៅកន្លែងត្រឹមកម្រិតនៃកម្មសិទ្ធិនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះត្រូវយកមកអនុវត្តផងដែរ ចំពោះស្លាមភ្លោះ និង ភ្លឺអឡ្យសិទ្ធិ សម្រាប់ធ្វើជាកំពែងតែប៉ុណ្ណោះ ។

ROYAUME DU CAMBODGE · LE MINISTÈRE DU PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង

ជំពូកទី ៣
សិទ្ធិកាន់កាប់
ផ្នែកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ២២៧.- និយមន័យនៃការកាន់កាប់

១-ការកាន់កាប់ សំដៅទៅលើការក្តាប់ទុកវត្ថុ ។

២-ការក្តាប់ទុកសំដៅទៅលើការគ្រប់គ្រងលើវត្ថុ តាមការជាក់ស្តែង ទោះដោយចំពោះក្តី ឬ ដោយប្រយោលក្តី ។

មាត្រា ២២៨.- ការកាន់កាប់ដោយចំពោះ និង ការកាន់កាប់ដោយប្រយោល

១-ការកាន់កាប់អាចធ្វើបានដោយប្រយោល តាមរយៈអ្នកដទៃបាន ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកដែលក្តាប់ទុកវត្ថុដោយផ្ទាល់ ហៅថា អ្នកកាន់កាប់ដោយចំពោះ រីឯអ្នកក្តាប់ទុកវត្ថុនោះ តាមរយៈអ្នកដទៃហៅថាអ្នកកាន់កាប់ដោយប្រយោល ។

មាត្រា ២២៩.- ការផ្ទេរការកាន់កាប់

១-ការកាន់កាប់ត្រូវបានផ្ទេរ ដោយការប្រគល់វត្ថុកាន់កាប់ ។ ការផ្ទេរការកាន់កាប់បែបនេះ ហៅថា ការប្រគល់ដោយជាក់ស្តែង ។

២-ការកាន់កាប់អាចត្រូវបានផ្ទេរ ដោយការព្រមព្រៀងគ្នារវាងគូភាគីតែប៉ុណ្ណោះ ដោយគ្មានការប្រគល់ដោយជាក់ស្តែង ។ ក្នុងករណីនេះ អនុប្បទានិកនៃការកាន់កាប់ ត្រូវទទួលការកាន់កាប់ដោយប្រយោល តាមរយៈអនុប្បទាយី ។ ការផ្ទេរការកាន់កាប់បែបនេះ ហៅថាការប្តូរលក្ខណៈនៃការកាន់កាប់ ។

៣-បើអ្នកដែលនឹងទទួលអនុប្បទាននូវការកាន់កាប់ ក្តាប់ទុកវត្ថុកាន់កាប់ដោយចំពោះតាមការជាក់ស្តែង ការកាន់កាប់អាចត្រូវបានផ្ទេរ ដោយការព្រមព្រៀងគ្នារវាងគូភាគីតែប៉ុណ្ណោះ ។ ដោយសារហេតុនេះ អនុប្បទាយីនៃការកាន់កាប់ ត្រូវបាត់បង់ការកាន់កាប់ដោយប្រយោល

ដែលខ្លួនធ្លាប់មាន តាមរយៈអ្នកក្តាប់ទុកវត្ថុកាន់កាប់ ។ ការផ្ទេរ ការកាន់កាប់បែបនេះ ហៅថា ការប្រគល់ដោយសង្ខេប ។

៤-អ្នកកាន់កាប់ដោយប្រយោល តាមរយៈអ្នកដទៃ អាចផ្ទេរការកាន់កាប់ទៅឱ្យតតិយជនបាន ដោយការព្រមព្រៀងជាមួយនឹងតតិយជន និង ដោយការជូនដំណឹងអំពីហេតុនោះ ទៅឱ្យអ្នកកាន់កាប់ដោយចំពោះ ។ ការផ្ទេរការកាន់កាប់បែបនេះហៅថា ការផ្ទេរការកាន់កាប់ដោយបញ្ជា ។

មាត្រា ២៣០.- ការរលត់ការកាន់កាប់

ការកាន់កាប់ ត្រូវរលត់នៅពេលដែលអ្នកកាន់កាប់ បាត់បង់នូវការក្តាប់ទុកវត្ថុកាន់កាប់ ។ ប៉ុន្តែ ក្នុងករណីដែលអ្នកកាន់កាប់ត្រូវបានដកហូតនូវការកាន់កាប់ ប្រសិនបើអ្នកនោះទទួលការប្រគល់វត្ថុកាន់កាប់មកវិញ ឬ ធ្វើបណ្តឹងទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ការកាន់កាប់នោះ មិនត្រូវរលត់ឡើយ ។

មាត្រា ២៣១.- ការរលត់ការកាន់កាប់របស់អ្នកកាន់កាប់ដោយប្រយោល

១-ការកាន់កាប់របស់អ្នកកាន់កាប់ដោយប្រយោល ត្រូវរលត់ក្នុងករណីដូចខាងក្រោមនេះ :

ក-មូលហេតុគតិយុត្តរបស់អ្នកកាន់កាប់ដោយចំពោះក្នុងការកាន់កាប់សម្រាប់អ្នកកាន់កាប់ដោយប្រយោល និង ករណីយកិច្ចរបស់អ្នកកាន់កាប់ដោយចំពោះក្នុងការកាន់កាប់សម្រាប់អ្នកកាន់កាប់ដោយប្រយោលរលត់ ។

ខ-មានស្ថានភាពដែលត្រូវបានទទួលស្គាល់ថា អ្នកកាន់កាប់ដោយចំពោះ មិនយល់ព្រមនឹងការកាន់កាប់របស់អ្នកកាន់កាប់ដោយប្រយោល ។

គ-អ្នកកាន់កាប់ដោយចំពោះ បាត់បង់នូវការក្តាប់ទុកវត្ថុកាន់កាប់ ។

២-ក្នុងករណីដែលអ្នកកាន់កាប់ត្រូវបានដកហូតនូវការកាន់កាប់ ក្នុងចំណោមករណីដែលបានកំណត់នៅក្នុងចំណុច គ នៃកថាខណ្ឌទី ១ ខាងលើនេះ បើអ្នកកាន់កាប់ដោយចំពោះ ឬ អ្នកកាន់កាប់ដោយប្រយោល ទទួលការប្រគល់វត្ថុកាន់កាប់មកវិញ ឬ ធ្វើបណ្តឹងទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ការកាន់កាប់នោះមិនត្រូវរលត់ឡើយ ។

1453.

មាត្រា ២៣២.- ការកាន់កាប់ដោយមានឆន្ទៈយកជាកម្មសិទ្ធិ និង ការកាន់កាប់ដោយគ្មានឆន្ទៈយកជាកម្មសិទ្ធិ

១-ការកាន់កាប់ មានការកាន់កាប់ដោយមានឆន្ទៈយកជាកម្មសិទ្ធិ និង ការកាន់កាប់ដោយគ្មានឆន្ទៈយកជាកម្មសិទ្ធិ ។ ការកាន់កាប់ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ឬ គ្មានត្រូវកំណត់ទៅតាមលក្ខណៈសត្យានុម័តនៃមូលហេតុនៃលទ្ធកម្មនូវការកាន់កាប់នោះ ។

២-ក្នុងករណីដែលការកាន់កាប់ ជាការកាន់កាប់ដោយគ្មានឆន្ទៈយកជាកម្មសិទ្ធិ តាមលក្ខណៈសត្យានុម័តនៃការទទួលការកាន់កាប់ ការកាន់កាប់ដោយគ្មានឆន្ទៈយកជាកម្មសិទ្ធិមិនត្រូវប្តូរទៅជាការកាន់កាប់ដោយមានឆន្ទៈយកជាកម្មសិទ្ធិឡើយ លើកលែងតែករណីដែលអ្នកកាន់កាប់ បង្ហាញឆន្ទៈយកជាកម្មសិទ្ធិ ចំពោះអ្នកដែលឱ្យខ្លួនកាន់កាប់ ឬ ចាប់ផ្តើមកាន់កាប់ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ដោយផ្អែកលើមូលហេតុនៃលទ្ធកម្មនូវការកាន់កាប់ថ្មី ។

មាត្រា ២៣៣.- ការកាន់កាប់ដោយមានវិការៈ

១-ការកាន់កាប់ដោយបានដឹងថាខ្លួនគ្មានសិទ្ធិកាន់កាប់ទេ ហៅថា ការកាន់កាប់ដោយទុច្ចរិត រីឯការកាន់កាប់ដោយមិនបានដឹងថាខ្លួនគ្មានសិទ្ធិទេ ហៅថា ការកាន់កាប់ដោយសុចរិត ។ ករណីដែលមានកំហុសក្នុងការមិនបានដឹងនោះ ហៅថា ការកាន់កាប់ដោយមានកំហុស ។

២-ការកាន់កាប់ដោយសន្តិវិធី សំដៅទៅលើការកាន់កាប់ដោយពុំប្រើហិង្សា ។ ប៉ុន្តែទោះបីជាករណីអ្នកដែលចាប់ផ្តើមការកាន់កាប់ដោយសន្តិវិធី ការពារការកាន់កាប់របស់ខ្លួនដោយប្រើហិង្សា ចំពោះការបំពានមិនត្រឹមត្រូវរបស់តតិយជនក៏ដោយ ក៏ការកាន់កាប់នោះនៅតែជាការកាន់កាប់ដោយសន្តិវិធីដែរ ។

៣-ការកាន់កាប់ដោយដឹងឮជាសាធារណៈ សំដៅទៅលើការកាន់កាប់ដោយមិនលាក់បិទបាំង ដើម្បីធ្វើឱ្យអ្នកមានសិទ្ធិលើវត្ថុកាន់កាប់ អាចដឹង ឬ ឃើញវត្ថុកាន់កាប់នោះ ។

៤-ការកាន់កាប់ដោយទុច្ចរិត ការកាន់កាប់ដោយសុចរិតតែមានកំហុស ការកាន់កាប់ដោយគ្មានសន្តិវិធី និង ការកាន់កាប់ដោយមិនសាធារណៈហៅថា ការកាន់កាប់ដោយមានវិការៈ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

មាត្រា ២៣៤.- ការសន្មត

១-អ្នកកាន់កាប់ត្រូវបានសន្មតថា កាន់កាប់ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ។

២-អ្នកកាន់កាប់ត្រូវបានសន្មតថាកាន់កាប់ដោយសុចរិត ដោយសន្តិវិធី និងជាសាធារណៈ ។

៣-ប្រសិនបើមានភស្តុតាងដែលបញ្ជាក់ថា បានកាន់កាប់នៅពេលមួយ និង នៅពេលមួយផ្សេងទៀតដែលក្រោយពេលនោះ អ្នកកាន់កាប់នោះត្រូវបានសន្មតថាកាន់កាប់ជាប់រហូតក្នុងអំឡុងពេលនោះ ។

៤-អ្នកកាន់កាប់ត្រូវបានសន្មតថា មានសិទ្ធិត្រឹមត្រូវស្របច្បាប់ក្នុងការកាន់កាប់វត្ថុកាន់កាប់ ។

មាត្រា ២៣៥.- ការបន្តការកាន់កាប់

១-អ្នកដែលបន្តការកាន់កាប់ អាចអះអាងតែការកាន់កាប់របស់ខ្លួនក៏បាន ឬ អាចអះអាងការកាន់កាប់របស់ខ្លួន ជាមួយនឹងការកាន់កាប់របស់អ្នកកាន់កាប់មុនក៏បាន ។

២-ក្នុងករណីដែលបានអះអាងការកាន់កាប់របស់អ្នកកាន់កាប់មុនជាមួយនឹងការកាន់កាប់របស់ខ្លួន អ្នកដែលបន្តការកាន់កាប់នោះ ត្រូវបន្តនូវវិការៈនៃការកាន់កាប់របស់អ្នកកាន់កាប់មុន ។ ជាលទ្ធផល ក្នុងករណីដែលការកាន់កាប់របស់អ្នកកាន់កាប់មុន ជាការកាន់កាប់ដោយមានវិការៈ ទោះបីជាការកាន់កាប់របស់ខ្លួនជាការកាន់កាប់ដោយគ្មានវិការៈក៏ដោយ ក៏ការកាន់កាប់នោះក្លាយជាការកាន់កាប់ដោយមានវិការៈ ដោយបញ្ចូលការកាន់កាប់ទាំងពីរនោះដែរ ។

ផ្នែកទី ២

សិទ្ធិទាមទារឱ្យការពារការកាន់កាប់

មាត្រា ២៣៦.- សិទ្ធិទាមទារឱ្យការពារការកាន់កាប់

អ្នកកាន់កាប់អាចទាមទារឱ្យប្រគល់វត្ថុដែលត្រូវបានដកហូតមកវិញ ទាមទារឱ្យបញ្ឈប់ការរំខានការកាន់កាប់ ឬ ទាមទារឱ្យបង្ការជាមុននូវការរារាំងការកាន់កាប់បាន ដោយយោង

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

តាមបញ្ញត្តិចាប់ពីមាត្រា ២៣៧ (សិទ្ធិទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ) ដល់មាត្រា ២៤១ (ទំនាក់ទំនងនឹងសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្ត) នៃក្រមនេះ ទោះបីជាការកាន់កាប់នោះជាការកាន់កាប់ដោយចំពោះ ឬ ដោយប្រយោលក៏ដោយ ។

មាត្រា ២៣៧.- សិទ្ធិទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ

១-ប្រសិនបើអ្នកកាន់កាប់ត្រូវបានដកហូតនូវវត្ថុកាន់កាប់របស់ខ្លួន អ្នកកាន់កាប់នោះអាចទាមទារឱ្យប្រគល់វត្ថុនោះមកវិញបាន ។

២-ការទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ មិនអាចធ្វើចំពោះអ្នកដែលបានទទួលវត្ថុពីអ្នកដកហូតការកាន់កាប់ ចំពោះអ្នកដែលបានទទួលការបង្កើតសិទ្ធិលើការបញ្ចាំ និង ចំពោះប្រតិសិទ្ធិដោយឡែកផ្សេងទៀតបានឡើយ ។ ប៉ុន្តែ ក្នុងករណីដែលប្រតិសិទ្ធិ នោះបានដឹង ឬ អាចដឹងនូវការដកហូតការកាន់កាប់នោះ អ្នកដែលបានកាន់កាប់ អាចទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ ចំពោះប្រតិសិទ្ធិនោះបាន ។

៣-បណ្តឹងទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ ត្រូវធ្វើឡើងក្នុងអំឡុងពេល ១(មួយ) ឆ្នាំ គិតចាប់ពីការដកហូតការកាន់កាប់នោះ ។

មាត្រា ២៣៨.- សិទ្ធិទាមទារឱ្យបញ្ឈប់ការរារាំងការកាន់កាប់

១-ប្រសិនបើអ្នកកាន់កាប់ត្រូវបានរារាំងនូវការកាន់កាប់របស់ខ្លួន អ្នកកាន់កាប់នោះអាចទាមទារឱ្យបញ្ឈប់ការរារាំងការកាន់កាប់បាន ។

២-បណ្តឹងទាមទារឱ្យបញ្ឈប់ការរារាំងការកាន់កាប់ ត្រូវធ្វើឡើងនៅពេលដែលមានការរារាំង ឬ ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក្រោយពីការរារាំងនោះបានចប់ ។ ប៉ុន្តែ ក្នុងករណីដែលវត្ថុកាន់កាប់នោះ បានទទួលនូវការខូចខាតដោយសារស្ថាបនកម្ម បណ្តឹងនោះមិនអាចធ្វើឡើងបានឡើយ បើអំឡុងពេល ១ (មួយ) ឆ្នាំ បានកន្លងហួស ចាប់តាំងពីស្ថាបនកម្មបានចាប់ផ្តើម ឬ បើស្ថាបនកម្មនោះបានចប់ ។

មាត្រា ២៣៩.- សំណងការខូចខាត

១-បញ្ញត្តិនៃមាត្រា ២៣៧ (សិទ្ធិទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ) និងមាត្រា ២៣៨

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

(សិទ្ធិទាមទារឱ្យបញ្ឈប់ការរារាំងការកាន់កាប់) នៃក្រមនេះ មិនត្រូវរារាំងក្នុងការទាមទារសំណងការខូចខាត ដោយផ្អែកលើអំពើអនីត្យានុកូលឡើយ ។

២-បណ្តឹងទាមទារសំណងការខូចខាតដែលបានកើតឡើងដោយសារការដកហូតនូវការកាន់កាប់ ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលការកាន់កាប់ត្រូវបានដកហូត ។

៣-បណ្តឹងទាមទារសំណងការខូចខាតដែលបានកើតឡើងដោយសារការរារាំង ការកាន់កាប់ ត្រូវធ្វើឡើងនៅពេលដែលមានការរារាំង ឬ ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក្រោយពីការរារាំងនោះបានចប់ ។ ប៉ុន្តែ ក្នុងករណីដែលវត្ថុកាន់កាប់នោះ បានទទួលនូវការខូចខាតដោយសារស្ថាបនកម្ម បណ្តឹងនោះមិនអាចធ្វើឡើងបានឡើយ បើអំឡុងពេល ១ (មួយ) ឆ្នាំ បានកន្លងហួស ចាប់តាំងពីស្ថាបនកម្មបានចាប់ផ្តើម ឬ បើស្ថាបនកម្មនោះបានចប់ ។

មាត្រា ២៤០.- សិទ្ធិទាមទារឱ្យបង្ការជាមុននូវការរារាំងការកាន់កាប់

១-ប្រសិនបើមានការបារម្ភថា អាចមានការរារាំងនូវការកាន់កាប់របស់ខ្លួន អ្នកកាន់កាប់អាចទាមទារឱ្យបង្ការការរារាំងនូវការកាន់កាប់បាន ។ ប៉ុន្តែ តុលាការអាចឱ្យភាគីម្ខាងទៀតដាក់ការធានាសមរម្យ ជំនួសការបង្ការជាមុននូវការរារាំងនោះ ។

២-បណ្តឹងទាមទារឱ្យបង្ការជាមុននូវការរារាំងការកាន់កាប់ អាចធ្វើឡើងបាន ក្នុងអំឡុងពេលដែលមានការបារម្ភចំពោះការរារាំង ។ ប៉ុន្តែ ក្នុងករណីដែលមានការបារម្ភថា អាចមានការខូចខាតចំពោះវត្ថុកាន់កាប់ ដោយសារស្ថាបនកម្ម បណ្តឹងនោះមិនអាចធ្វើឡើងបានឡើយ បើអំឡុងពេល ១ (មួយ) ឆ្នាំ បានកន្លងហួស ចាប់តាំងពីស្ថាបនកម្មបាន ចាប់ផ្តើម ឬ បើស្ថាបនកម្មនោះបានចប់ ។

មាត្រា ២៤១.- ទំនាក់ទំនងនឹងសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្ត

១-សិទ្ធិដែលធ្វើឱ្យការក្តាប់ទុកវត្ថុមានភាពត្រឹមត្រូវតាមច្បាប់ ដូចជាកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិលើការបញ្ចាំ សិទ្ធិជួល ជាអាទិ៍ ហៅថា សិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្ត ។

២-ចំពោះការអនុវត្តសិទ្ធិទាមទារឱ្យការពារការកាន់កាប់ ភាគីម្ខាងទៀតមិនត្រូវបាន

អនុញ្ញាតឱ្យអះអាងសេចក្តីតវ៉ា ដោយផ្អែកលើសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្តឡើយ ។

៣-បណ្តឹងដែលផ្អែកលើការកាន់កាប់ និង បណ្តឹងដែលផ្អែកលើសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្ត ពុំរារាំងគ្នាទៅវិញទៅមកឡើយ ។ ចំពោះការអនុវត្តសិទ្ធិប្តឹងទាមទារដោយផ្អែកលើការកាន់កាប់ ភាគីម្ខាងទៀតអាចដាក់ពាក្យបណ្តឹងតបបាន ដោយផ្អែកលើសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្ត ។

៤-បណ្តឹងដែលផ្អែកលើការកាន់កាប់ មិនត្រូវបានសម្រេចសេចក្តីដោយផ្អែកលើមូលហេតុដែលទាក់ទងនឹងសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្តឡើយ ។

ផ្នែកទី ៣

ការការពារអ្នកកាន់កាប់ពិសេសអំពីអចលនវត្ថុ

មាត្រា ២៤២.- ការការពារភោគីអចលនវត្ថុដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់

១-ភោគីដែលប្រើប្រាស់ និង អាស្រ័យផលជាបន្តនូវអចលនវត្ថុ ដែលបានទទួលប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ តែមិនទាន់ចុះបញ្ជីអចលនវត្ថុដែលជាការចាំបាច់ ដើម្បីទទួលកម្មសិទ្ធិពេញលេញ ដោយសារមិនទាន់បានរៀបចំប្រព័ន្ធប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដីទេ ត្រូវចាត់ទុកថាជាកម្មសិទ្ធិករ ចំពោះការអនុវត្តសិទ្ធិទាមទារ ដោយផ្អែកលើសិទ្ធិប្រត្យក្ស ។

២-ក្នុងករណីដែលភោគីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះឱ្យតតិយជនប្រើប្រាស់ និង អាស្រ័យផលនូវអចលនវត្ថុ ភោគីនោះត្រូវចាត់ទុកថាជាកម្មសិទ្ធិករ ចំពោះការអនុវត្តសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស ។

៣-អ្នកដែលបានទទួលអនុប្បទាននូវភោគៈ ដោយភ្ជាប់ជាមួយនឹងប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុពីភោគីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ ក៏ត្រូវចាត់ទុកថា ជាកម្មសិទ្ធិករចំពោះការអនុវត្តសិទ្ធិទាមទារ ដោយផ្អែកលើសិទ្ធិប្រត្យក្សដែរ ។

មាត្រា ២៤៣.- ការការពារភោគីដែលកាន់កាប់អចលនវត្ថុតាំងពីពេលដែលមិនទាន់ប្រកាសឱ្យប្រើច្បាប់ភូមិបាល

១-ភោគីដែលបានកាន់កាប់អចលនវត្ថុដែលអាចកាន់កាប់ដោយឯកជនដោយស្រប

ច្បាប់ជាបន្តបន្ទាប់ ដោយសន្តិវិធី និង មិនមានការជំទាស់ចាប់ពី ៥ (ប្រាំ) ឆ្នាំ យ៉ាងតិច គិតមក ដល់កាលបរិច្ឆេទនៃការប្រកាសឱ្យប្រើច្បាប់ភូមិបាល តែបានធ្វេសប្រហែសក្នុងការចុះបញ្ជីអំពីភោគៈនោះ ដោយផ្អែកលើច្បាប់ភូមិបាល អាចអនុវត្តសិទ្ធិទាមទារឱ្យការពារការកាន់កាប់ចំពោះការបំពានការកាន់កាប់ដោយតតិយជន ។

២-ភោគីដែលបានចាប់ផ្តើមកាន់កាប់អចលនវត្ថុនៅមុនពេលប្រកាសឱ្យប្រើច្បាប់ភូមិបាល ហើយបានទទួលការអនុញ្ញាតក្នុងការបន្តការកាន់កាប់ដើម្បីធ្វើលទ្ធកម្មនូវកម្មសិទ្ធិពីស្ថាប័នដែលមានសមត្ថកិច្ច អាចអនុវត្តសិទ្ធិទាមទារឱ្យការពារការកាន់កាប់ ចំពោះការបំពានការកាន់កាប់ដោយតតិយជន ។

៣-ក្នុងការអនុវត្តសិទ្ធិទាមទារឱ្យការពារការកាន់កាប់ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ អំឡុងពេល ១ (មួយ) ឆ្នាំ ដែលបានកំណត់នៅក្នុងមាត្រា ២៣៧(សិទ្ធិទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ) ដល់មាត្រា ២៤០ (សិទ្ធិទាមទារឱ្យបង្ការជាមុននូវការរារាំងការកាន់កាប់) នៃក្រមនេះ ត្រូវបានបកស្រាយថា ៣ (បី) ឆ្នាំ ។

ជំពូកទី ៤
សិទ្ធិជួលអចិន្ត្រៃយ៍

មាត្រា ២៤៤.- និយមន័យនៃសិទ្ធិជួលអចិន្ត្រៃយ៍

សិទ្ធិជួលអចិន្ត្រៃយ៍ សំដៅទៅលើសិទ្ធិជួលអចលនវត្ថុរយៈពេលវែង ចាប់ពី ១៥ (ដប់ប្រាំ) ឆ្នាំ ឡើងទៅ ។

មាត្រា ២៤៥.- ការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍

១-សិទ្ធិជួលអចិន្ត្រៃយ៍ពុំមានអានុភាពឡើយ បើមិនបានបង្កើតឡើងជាលាយល័ក្ខណ៍អក្សរ ។

២-សិទ្ធិជួលអចិន្ត្រៃយ៍ដែលត្រូវបានបង្កើតឡើង ដោយពុំបានធ្វើជាលាយល័ក្ខណ៍អក្សរ ត្រូវចាត់ទុកថាជាភតិសន្យាដែលពុំមានកំណត់អំឡុងពេល ហើយអាចត្រូវបានបញ្ឈប់ដោយភាគីម្ខាងនៅពេលណាក៏បាន ដោយផ្អែកតាមបញ្ញត្តិនៃមាត្រា ៦១៥ (ការស្នើសុំឱ្យរំលាយភតិ-

សន្យាដែលពុំមានកំណត់អំឡុងពេល) នៃក្រមនេះ ។

មាត្រា ២៤៦.- ល័ក្ខខ័ណ្ឌតតាំងនៃសិទ្ធិជួលអចិន្ត្រៃយ៍

១-អ្នកជួលអចិន្ត្រៃយ៍ មិនអាចយកសិទ្ធិជួលអចិន្ត្រៃយ៍របស់ខ្លួន ទៅតតាំងចំពោះតតិយជនបានឡើយ បើមិនបានចុះបញ្ជី ។

២-សិទ្ធិជួលអចិន្ត្រៃយ៍ដែលបានចុះបញ្ជីហើយ អាចតតាំងនឹងអនុប្បទានិកនៃកម្មសិទ្ធិដីដែលជាកម្មវត្ថុនៃសិទ្ធិជួលអចិន្ត្រៃយ៍បាន ទោះបីជាកម្មសិទ្ធិលើដីនោះត្រូវបានធ្វើអនុប្បទានក៏ដោយ ។

៣-ចំពោះសិទ្ធិជួលអចិន្ត្រៃយ៍ដែលមិនបានចុះបញ្ជី បញ្ញត្តិនៃមាត្រា ៥៩៨ (ល័ក្ខខ័ណ្ឌតតាំងនៃសិទ្ធិជួលអចលនវត្ថុ) នៃក្រមនេះ ត្រូវយកមកអនុវត្តរហូតដល់គ្រប់អំឡុងពេល ១៥ (ដប់ប្រាំ) ឆ្នាំ ។

មាត្រា ២៤៧.- អំឡុងពេលដែលសិទ្ធិជួលអចិន្ត្រៃយ៍មានអត្ថិភាព

១-អំឡុងពេលដែលសិទ្ធិជួលអចិន្ត្រៃយ៍មានអត្ថិភាព មិនអាចឱ្យលើសពី៥០ (ហាសិប) ឆ្នាំ បានឡើយ ។ ប្រសិនបើបានបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ដែលមានអំឡុងពេលលើសពី ៥០ (ហាសិប) ឆ្នាំ ត្រូវបន្ថយមកត្រឹម ៥០ (ហាសិប) ឆ្នាំ ។

២-សិទ្ធិជួលអចិន្ត្រៃយ៍អាចបន្តសាជាថ្មីបាន ។ ប៉ុន្តែ អំឡុងពេលនេះមិនអាចលើសពី ៥០ (ហាសិប) ឆ្នាំ ឡើយ គិតចាប់ពីថ្ងៃដែលបានបន្តសាជាថ្មី ។

មាត្រា ២៤៨.- ថ្លៃឈ្នួល

១-អ្នកជួលអចិន្ត្រៃយ៍មានករណីយកិច្ចបង់ថ្លៃឈ្នួល ចំពោះអ្នកឱ្យជួលអចិន្ត្រៃយ៍ នៅពេលដែលបានកំណត់ ។

២-ប្រសិនបើពុំមានកំណត់ពេលបង់ថ្លៃឈ្នួលទេ អ្នកជួលអចិន្ត្រៃយ៍ត្រូវបង់នៅរាល់ដំណាច់ឆ្នាំ ។ ប៉ុន្តែ ចំពោះវត្ថុដែលមានរដូវប្រមូលផល ត្រូវបង់នៅក្រោយរដូវនោះ ដោយគ្មានការយឺតយ៉ាវ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

មាត្រា ២៤៩.- សិទ្ធិទាមទារឱ្យតម្លើង ឬ បញ្ចុះថ្លៃឈ្នួល

ភាគីទាំងសងខាងនៃសិទ្ធិជួលអចិន្ត្រៃយ៍ អាចទាមទារទៅតុលាការឱ្យតម្លើង ឬ បញ្ចុះថ្លៃឈ្នួល ទៅតម្លៃសមរម្យបាន ក្នុងករណីដែលថ្លៃឈ្នួលនោះក្លាយជាតម្លៃមិនសមរម្យដោយសារស្ថានភាពផ្សេងៗ ។

មាត្រា ២៥០.- សិទ្ធិរំលាយរបស់អ្នកឱ្យជួលអចិន្ត្រៃយ៍

ប្រសិនបើអ្នកជួលអចិន្ត្រៃយ៍មិនបានបង់ថ្លៃឈ្នួលដែលបានកំណត់ ក្នុងអំឡុងពេល ៣ (បី) ឆ្នាំ អ្នកឱ្យជួលអចិន្ត្រៃយ៍អាចរំលាយការជួលអចិន្ត្រៃយ៍នោះបាន ។

មាត្រា ២៥១.- សិទ្ធិរំលាយរបស់អ្នកជួលអចិន្ត្រៃយ៍

ក្នុងករណីដែលអ្នកជួលអចិន្ត្រៃយ៍មិនបានទទួលចំណេញសោះពីអចលនវត្ថុ ក្នុងអំឡុងពេល ៣ (បី) ឆ្នាំ ដោយសារស្ថានភាពដែលមិនអាចព្យាករទុកជាមុនបាន ឬ ដោយសារប្រធានសក្តិ ឬ ក្នុងករណីដែលប្រាក់ចំណេញប្រចាំឆ្នាំ ដែលនឹងបានមកពីអចលនវត្ថុនៅពេលអនាគតពុំមានលទ្ធភាពអាចលើសថ្លៃឈ្នួលសម្រាប់មួយឆ្នាំបាន ដោយសារការខូចខាតផ្នែកណាមួយនៃអចលនវត្ថុនោះ អ្នកជួលអចិន្ត្រៃយ៍អាចរំលាយការជួលអចិន្ត្រៃយ៍នោះបាន ។

មាត្រា ២៥២.- អនុប្បទាន ជារអាគី នូវសិទ្ធិជួលអចិន្ត្រៃយ៍

១-សិទ្ធិជួលអចិន្ត្រៃយ៍អាចធ្វើអនុប្បទាន ឬ ធ្វើការចាត់ចែងផ្សេងទៀត ដោយយកថ្លៃ ឬ ដោយមិនយកថ្លៃបាន ។

២-អ្នកជួលអចិន្ត្រៃយ៍ អាចយកវត្ថុជួលអចិន្ត្រៃយ៍នោះ ទៅជួលបន្តបាន ។

៣-សិទ្ធិជួលអចិន្ត្រៃយ៍អាចជាកម្មវត្ថុនៃសន្តតិកម្មបាន ។

មាត្រា ២៥៣.- សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សរបស់អ្នកជួលអចិន្ត្រៃយ៍

អ្នកជួលអចិន្ត្រៃយ៍ អាចអនុវត្តសិទ្ធិទាមទារឱ្យប្រគល់វិញ សិទ្ធិទាមទារឱ្យបញ្ឈប់ការរារាំង និង សិទ្ធិទាមទារឱ្យបង្ការជាមុននូវការរារាំង ចំពោះការបំពានសិទ្ធិជួលអចិន្ត្រៃយ៍ដូចសិទ្ធិដែលកម្មសិទ្ធិករមាន ។

ROYAUME DU CAMBODGE • LE MINISTÈRE DU PALAIS ROYAL •

មាត្រា ២៥៤.- ការបញ្ចប់ការជួលអចិន្ត្រៃយ៍

១-ពេលបញ្ចប់ការជួលអចិន្ត្រៃយ៍ អ្នកឱ្យជួលអចិន្ត្រៃយ៍ មិនអាចទាមទារឱ្យអ្នកជួលអចិន្ត្រៃយ៍ធ្វើបដិទានបានឡើយ លើកលែងតែករណីដែលអ្នកជួលអចិន្ត្រៃយ៍បានបំផ្លាញអចលនវត្ថុ ឬ បានបំប្លែងជាសារវន្តនូវលក្ខណៈនៃអចលនវត្ថុនោះ ។

២-ពេលបញ្ចប់ការជួលអចិន្ត្រៃយ៍ អ្នកឱ្យជួលអចិន្ត្រៃយ៍ អាចទទួលកម្មសិទ្ធិលើការកែលំអ ឬ សំណង់ ជាអាទិ៍ ដែលអ្នកជួលអចិន្ត្រៃយ៍បានធ្វើចំពោះអចលនវត្ថុ ដោយគ្មានសងប្រាក់សំណងទៅអ្នកជួលអចិន្ត្រៃយ៍ ។

៣-ភាគីអាចធ្វើការសន្យាពិសេស ផ្សេងពីកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះបាន ។ ប៉ុន្តែ ការសន្យានោះ មិនអាចតតាំងនឹងតតិយជនបានឡើយ បើមិនបានចុះបញ្ជី ។

មាត្រា ២៥៥.- ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីភតិសន្យា

បញ្ញត្តិស្តីពីភតិសន្យា ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសិទ្ធិជួលអចិន្ត្រៃយ៍ ចំពោះចំណុចដែលមិនបានកំណត់នៅក្នុងជំពូកទី ៤ (សិទ្ធិជួលអចិន្ត្រៃយ៍) នេះ ។

ជំពូកទី ៥

ផលុបភោគ

មាត្រា ២៥៦.- និយមន័យនៃផលុបភោគ

១-ផលុបភោគ សំដៅទៅលើសិទ្ធិប្រើប្រាស់ និង អាស្រ័យផលលើអចលនវត្ថុ ដែលជាកម្មសិទ្ធិរបស់អ្នកដទៃ ក្នុងអំឡុងពេលកំណត់ណាមួយដែលមិនអាចលើសពីមួយជីវិតរបស់ផលុបភោគី ។

២-ផលុបភោគីមានសិទ្ធិប្រើប្រាស់អចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ តាមវិធីប្រើប្រាស់ និង មានសិទ្ធិអាស្រ័យផលធម្មជាតិ និង ផលស៊ីវិលដែលកើតចេញពីអចលនវត្ថុនោះ ។

មាត្រា ២៥៧.- ផលុបភោគដែលកំណត់ដោយការព្រមព្រៀង និង ផលុបភោគដែលច្បាប់បានកំណត់

១-ផលុបភោគ ត្រូវបានបង្កើតឡើងដោយការព្រមព្រៀងរវាងភាគី ឬ ដោយបញ្ញត្តិនៃ

ច្បាប់ ។

២-បញ្ញត្តិនៃជំពូកទី ៥ (ផលុបភោគ) នេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះផលុបភោគដែលកើតឡើងដោយបញ្ញត្តិនៃច្បាប់ លើកលែងតែមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ ។

៣-ផលុបភោគដែលកើតឡើងដោយបញ្ញត្តិនៃច្បាប់ មានអាទិភាពជាងផលុបភោគដែលត្រូវបានបង្កើតដោយការព្រមព្រៀង លើកលែងតែមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ ។

មាត្រា ២៥៨.- ការបង្កើតផលុបភោគ

១-ផលុបភោគអាចបង្កើតតាមលិខិតជាលាយលក្ខណ៍អក្សរ ឬ មិនតាមលិខិតជាលាយលក្ខណ៍អក្សរបាន ។

២-កម្មសិទ្ធិករអាចស្នើសុំឱ្យរំលត់ផលុបភោគដែលមិនធ្វើតាមលិខិតជាលាយលក្ខណ៍អក្សរនៅពេលណាក៏បាន ។ ក្នុងករណីដែលការស្នើសុំឱ្យរំលត់ មិនបានបញ្ជាក់អំពីពេលរលត់ និង ក្នុងករណីដែលអំឡុងពេលគិតចាប់ពីពេលស្នើសុំឱ្យរំលត់ រហូតដល់ពេលរលត់ដែលបានបញ្ជាក់នៅក្នុងការស្នើសុំឱ្យរំលត់នោះ តិចជាងអំឡុងពេលដូចបានកំណត់ខាងក្រោមនេះ ផលុបភោគត្រូវរលត់ នៅពេលដែលអំឡុងពេលដូចបានកំណត់ខាងក្រោមនេះ បានកន្លងហួសគិតចាប់ពីពេលស្នើសុំឱ្យរំលត់ :

ក-៣ (បី) ខែ ចំពោះអគារ ។

ខ-១ (មួយ) ឆ្នាំ ចំពោះដី ។

៣-ចំពោះផលុបភោគដីដែលមានរដូវប្រមូលផល ការស្នើឱ្យរំលត់ត្រូវធ្វើនៅមុនពេលដែលផលុបភោគីចាប់ផ្តើមការងារកសិកម្ម សម្រាប់រដូវបន្ទាប់ពីរដូវមុន ។

មាត្រា ២៥៩.- លក្ខខណ្ឌតតាំងនៃផលុបភោគ

១-ផលុបភោគីមិនអាចយកផលុបភោគរបស់ខ្លួន ទៅតតាំងចំពោះតតិយជនបានឡើយ បើមិនបានចុះបញ្ជី ។

២-ផលុបភោគដែលបានចុះបញ្ជីហើយ អាចតតាំងចំពោះអនុប្បទាទិកនៃអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគបាន ទោះបីជាកម្មសិទ្ធិលើអចលនវត្ថុនោះត្រូវបានធ្វើអនុប្បទានក៏ដោយ ។

ROYAUME DU CAMBODGE · LE MINISTÈRE DU PALAIS ROYAL

មាត្រា ២៦០.- អំឡុងពេលដែលផលុបភោគមានអត្ថិភាព

១-ផលុបភោគអាចមានអត្ថិភាពក្នុងអំឡុងពេលដែលបានកំណត់ ឬ រហូតដល់ពេលដែលហេតុណាមួយដែលបានកំណត់កើតឡើង ។

២-ប្រសិនបើមិនបានកំណត់អំឡុងពេលដែលផលុបភោគមានអត្ថិភាពទេ ផលុបភោគនោះត្រូវចាត់ទុកថា មានអត្ថិភាពរហូតដល់ពេលផលុបភោគីទទួលមរណភាព ។

មាត្រា ២៦១.- សិទ្ធិអាស្រ័យផលធម្មជាតិ

១-ផលធម្មជាតិដែលមានអត្ថិភាពលើដី នៅពេលបង្កើតផលុបភោគ ត្រូវបានទៅផលុបភោគី ។

២-ផលធម្មជាតិដែលមានអត្ថិភាពលើដី នៅពេលផលុបភោគរលត់ ត្រូវបានទៅកម្មសិទ្ធិករនៃដី ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ទំនាក់ទំនងនៃសេចក្តីចម្រើនដោយឥតហេតុ ចំពោះការងារពលកម្ម ជាអាទិ៍ ដើម្បីបង្កើតផលធម្មជាតិនោះមិនត្រូវកើតឡើយ ។

៤-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក្នុងករណីដែលមានសិទ្ធិជួលដែលមានអានុភាពតតាំងលើដីដែលជាកម្មវត្ថុនៃផលុបភោគ បញ្ញត្តិនៃកថាខណ្ឌ ទី ១ ខាងលើនេះ ពុំមានឥទ្ធិពលដល់សិទ្ធិរបស់ភតិកៈនោះក្នុងការអាស្រ័យផលធម្មជាតិឡើយ ។

៥-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះក៏ដោយ ចំពោះផលធម្មជាតិ ដែលខ្លួនបានថែទាំរហូតដល់ផលុបភោគរលត់ ភតិកៈដែលជួលដីពីផលុបភោគីមានសិទ្ធិអាស្រ័យផលធម្មជាតិ ។

មាត្រា ២៦២.- សិទ្ធិអាស្រ័យផលស៊ីវិល

ផលស៊ីវិលត្រូវបានទៅផលុបភោគី តាមសមាមាត្រទៅនឹងអំឡុងពេលដែលផលុបភោគមានអត្ថិភាព ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា ២៦៣.- អនុប្បទាន ជាអាទិ៍ នូវផលុបភោគ

ផលុបភោគីអាចធ្វើអនុប្បទាននូវផលុបភោគ ឬ ធ្វើការចាត់ចែងផ្សេងទៀត ដោយយកថ្លៃ ឬ ដោយមិនយកថ្លៃបាន ។

មាត្រា ២៦៤.- ភតិសន្យានៃអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ

១-ផលុបភោគីអាចយកអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ ធ្វើជាកម្មវត្ថុនៃភតិសន្យា ដោយកំណត់អំឡុងពេលដែលមិនឱ្យលើសពី ៣ (បី) ឆ្នាំ ។

២-អំឡុងពេលនៃភតិសន្យាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចបន្តសាជាថ្មីបាន ។ ប៉ុន្តែ អំឡុងពេលនេះ មិនអាចលើសពី ៣ (បី) ឆ្នាំ បានឡើយ ។

៣-បើផលុបភោគរលត់ ភតិសន្យាអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ មិនអាចតតាំងចំពោះកម្មសិទ្ធិករនៃអចលនវត្ថុបានឡើយ ។

មាត្រា ២៦៥.- សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សរបស់ផលុបភោគី

ផលុបភោគី អាចអនុវត្តសិទ្ធិទាមទារឱ្យប្រគល់វិញ សិទ្ធិទាមទារឱ្យបញ្ឈប់ការរារាំង និងសិទ្ធិទាមទារឱ្យបង្ការជាមុននូវការរារាំង ចំពោះការបំពានផលុបភោគ ដូចសិទ្ធិដែលកម្មសិទ្ធិករមាន ។

មាត្រា ២៦៦.- ករណីយកិច្ចជូនដំណឹងរបស់ផលុបភោគី

១-បើមានតតិយជនអះអាងអំពីសិទ្ធិលើអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ ផលុបភោគីត្រូវជូនដំណឹងអំពីហេតុនេះទៅកម្មសិទ្ធិករនៃអចលនវត្ថុនោះ ដោយគ្មានការយឺតយ៉ាវ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកម្មសិទ្ធិករដឹងអំពីហេតុនោះហើយ ។

២-ផលុបភោគីត្រូវទទួលករណីយកិច្ចសងសំណងនៃការខូចខាតដែលកើតឡើង ចំពោះកម្មសិទ្ធិករដោយសារខ្លួនបានធ្វេសប្រហែសក្នុងការជូនដំណឹង ។

មាត្រា ២៦៧.- ការទាមទារឱ្យរំលត់ផលុបភោគ

១-ក្នុងករណីដែលផលុបភោគីបានធ្វើអំពើថ្មយនឹងខ្លឹមសារនៃផលុបភោគ ដូចជាករណី

ដែលបានបង្កឱ្យមានការខូចខាត ឬ ថែរក្សាមិនបានត្រឹមត្រូវ ជាអាទិ៍ នូវអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ កម្មសិទ្ធិករនៃអចលនវត្ថុនោះ អាចទាមទារទៅតុលាការឱ្យរំលត់ផលុបភោគបាន ។

២-ការទាមទារឱ្យរំលត់ផលុបភោគដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងក្នុងការទាមទារសំណង ការខូចខាត ដោយផ្អែកលើអំពើអនីត្យានុកូល ចំពោះផលុបភោគីឡើយ ។

មាត្រា ២៦៨.- ការរលត់ផលុបភោគដោយមរណភាពនៃផលុបភោគី ឬ ការបញ្ចប់អំឡុងពេល

ផលុបភោគត្រូវរលត់ នៅពេលដែលផលុបភោគីទទួលមរណភាព ឬ បញ្ចប់អំឡុងពេល ដែលបានកំណត់នៅក្នុងកិច្ចសន្យាបង្កើតផលុបភោគ ។

មាត្រា ២៦៩.- អានុភាពនៃការរំលត់ផលុបភោគ

១-ប្រសិនបើផលុបភោគបានរលត់ កម្មសិទ្ធិករអចលនវត្ថុ មិនអាចទាមទារឱ្យផលុបភោគីធ្វើបដិទានបានឡើយ លើកលែងតែករណីដែលផលុបភោគីបានបំផ្លាញអចលនវត្ថុ ឬ បានបំប្លែងជាសារវន្តនូវលក្ខណៈនៃអចលនវត្ថុនោះ ។

២-ប្រសិនបើផលុបភោគបានរលត់ កម្មសិទ្ធករអចលនវត្ថុ អាចទទួលកម្មសិទ្ធិលើការ ដែលបានកែលំអ ឬ សំណង់ ជាអាទិ៍ ដែលផលុបភោគីបានធ្វើចំពោះអចលនវត្ថុដោយគ្មានសង ប្រាក់សំណងទៅផលុបភោគី ឬ សន្តតិជនរបស់អ្នកនោះ ។

៣-ភាគីអាចធ្វើការសន្យាពិសេស ផ្សេងពីកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះបាន ។ ប៉ុន្តែ ការសន្យានោះ មិនអាចតតាំងនឹងតតិយជនបានឡើយ បើមិនបានចុះបញ្ជី ។

មាត្រា ២៧០.- ការអន្តរាយនូវអគារដែលជាកម្មវត្ថុនៃផលុបភោគ

១-ក្នុងករណីដែលកម្មវត្ថុនៃផលុបភោគជាអគារនៅលើដីតែប៉ុណ្ណោះ ហើយអគារនោះ ត្រូវអន្តរាយ ផលុបភោគីមិនអាចអនុវត្តផលុបភោគចំពោះដីនោះបានឡើយ ។

២-ក្នុងករណីដែលកម្មវត្ថុនៃផលុបភោគជាដីផង និង អគារផង ហើយមានតែអគារប៉ុណ្ណោះដែលត្រូវអន្តរាយ ផលុបភោគចំពោះដីនៅតែមានដដែល ។

មាត្រា ២៧១.– ការទទួលបន្ទុកនូវសោហ៊ុយ

១-សោហ៊ុយសម្រាប់ការជួសជុលថែទាំនូវអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ ត្រូវជាបន្ទុករបស់ផលុបភោគី ចំណែកឯសោហ៊ុយសម្រាប់ការជួសជុលធំៗ ត្រូវជាបន្ទុករបស់កម្មសិទ្ធិករ ។ ប៉ុន្តែ ក្នុងករណីដែលភាពចាំបាច់ក្នុងការជួសជុលធំៗបានកើតឡើង ដោយសារផលុបភោគីមិនបានជួសជុលថែទាំ សោហ៊ុយនោះត្រូវជាបន្ទុករបស់ផលុបភោគី ។

២-នៅក្នុងមាត្រានេះ ការជួសជុលធំៗ សំដៅទៅលើការកែប្រែជញ្ជាំងចម្បងធ្នឹម ដំបូល និង គ្រឹះ និង ការរៀបចំឡើងវិញនូវដំបូល ចំណែកឯការជួសជុលក្រៅពីនេះ គឺជាការជួសជុលថែទាំ ។

៣-ក្នុងករណីដែលអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ បានទទួលការខូចខាត ឬ អន្តរាយ ដោយករណីប្រធានសក្តិ នោះទាំងកម្មសិទ្ធិករទាំងផលុបភោគី គ្មានការទទួលខុសត្រូវក្នុងការសង់ឡើងវិញ ឬ ការទទួលខុសត្រូវផ្សេងទៀត ចំពោះការខូចខាត ឬ អន្តរាយនោះឡើយ ។

មាត្រា ២៧២.– ការទទួលបន្ទុកនូវពន្ធនិងអាករ និង សោហ៊ុយធានារ៉ាប់រង

នៅក្នុងអំឡុងពេលនៃផលុបភោគ ផលុបភោគីមានករណីយកិច្ចត្រូវទទួលបន្ទុកនូវពន្ធនិងអាករ ចំពោះអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ និង សោហ៊ុយសម្រាប់ការធានារ៉ាប់រងអចលនវត្ថុនោះ ដែលកម្មសិទ្ធិករបានធ្វើកិច្ចសន្យាមុនពេលបង្កើតផលុបភោគ ។

មាត្រា ២៧៣.– ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីសិទ្ធិជួលអចិន្ត្រៃយ៍

បញ្ញត្តិនៃមាត្រា ២៤៨ (ថ្លៃឈ្នួល) និងមាត្រា ២៤៩ (សិទ្ធិទាមទារឱ្យតម្លើង ឬ បញ្ចុះថ្លៃឈ្នួល) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលផលុបភោគីមានករណីយកិច្ចបង់តម្លៃថ្នូរតាមការកំណត់ពេល ។

ជំពូកទី ៦
សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ

មាត្រា ២៧៤.- និយមន័យនៃសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ

១-សិទ្ធិប្រើប្រាស់ សំដៅទៅលើសិទ្ធិអាស្រ័យផលនៃអចលនវត្ថុ ត្រឹមកម្រិតនៃសេចក្ដីត្រូវការរបស់ម្ចាស់សិទ្ធិប្រើប្រាស់ និង គ្រួសាររបស់ខ្លួន ។

២-សិទ្ធិអាស្រ័យនៅ សំដៅទៅលើសិទ្ធិកាន់កាប់ចំណែកមួយនៃអគារ ត្រឹមកម្រិតនៃសេចក្ដីត្រូវការសម្រាប់ការរស់នៅរបស់ម្ចាស់សិទ្ធិអាស្រ័យនៅ និង គ្រួសាររបស់ខ្លួន ។

មាត្រា ២៧៥.- សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ដែលកំណត់ដោយការសន្យា និង សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ដែលច្បាប់បានកំណត់

១-សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ត្រូវបានបង្កើតឡើងដោយការព្រមព្រៀង រវាងភាគី ឬ កើតឡើងតាមបញ្ញត្តិនៃច្បាប់ ។

២-បញ្ញត្តិនៃជំពូកទី ៦ (សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ) ត្រូវយកមកអនុវត្តផងដែរ ចំពោះសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅដែលកើតឡើងដោយបញ្ញត្តិនៃច្បាប់ លើកលែងតែមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ ។

៣-សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ដែលកើតឡើងដោយបញ្ញត្តិនៃច្បាប់មានអាទិភាពជាងសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ដែលត្រូវបានបង្កើតដោយការព្រមព្រៀង លើកលែងតែមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ ។

មាត្រា ២៧៦.- ការបង្កើតសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ

១-សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅអាចបង្កើតតាមលិខិតជាលាយល័ក្ខណ៍អក្សរ ឬ មិនតាមលិខិតជាលាយល័ក្ខណ៍អក្សរបាន ។

២-កម្មសិទ្ធិករអាចស្នើសុំឱ្យរំលត់សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅដែលមិនធ្វើតាមលិខិតជាលាយល័ក្ខណ៍អក្សរ នៅពេលណាក៏បាន ។ ក្នុងករណីដែលការស្នើសុំឱ្យរំលត់មិនបាន [illegible]លត់ និង ក្នុងករណីដែលអំឡុងពេលគិតចាប់ពីពេលស្នើសុំឱ្យរំលត់ រហូតដល់

ពេលរលត់ដែលបានបញ្ជាក់នៅក្នុងការស្នើសុំឱ្យរលត់នោះ តិចជាងអំឡុងពេល ៣ (បី) ខែ សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ត្រូវរលត់នៅពេលអំឡុងពេល ៣ (បី) ខែ បានកន្លងហួសគិតចាប់ពីពេលស្នើសុំឱ្យរលត់ ។

មាត្រា ២៧៧.- លក្ខខណ្ឌតតាំងនៃសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ

១-ម្ចាស់សិទ្ធិប្រើប្រាស់ និង ម្ចាស់សិទ្ធិអាស្រ័យនៅ មិនអាចយកសិទ្ធិរបស់ខ្លួនទៅតតាំងចំពោះតតិយជនបានឡើយ បើមិនប្រើប្រាស់ ឬ អាស្រ័យនៅជាក់ស្តែង ។

២-សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ អាចតតាំងចំពោះអនុប្បទានិកបាន ទោះបីជាកម្មសិទ្ធិលើអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិនោះត្រូវបានធ្វើអនុប្បទានក៏ដោយ បើម្ចាស់សិទ្ធិនោះប្រើប្រាស់ ឬ អាស្រ័យនៅជាក់ស្តែង ។

មាត្រា ២៧៨.- អំឡុងពេលដែលសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅមានអត្ថិភាព

១-សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ អាចមានអត្ថិភាពក្នុងអំឡុងពេលដែលបានកំណត់ ឬ រហូតដល់ពេលដែលហេតុណាមួយដែលបានកំណត់កើតឡើង ។

២-ប្រសិនបើមិនបានកំណត់អំឡុងពេលដែលសិទ្ធិប្រើប្រាស់ ឬ សិទ្ធិអាស្រ័យនៅមានអត្ថិភាពទេ សិទ្ធិប្រើប្រាស់ ឬ សិទ្ធិអាស្រ័យនៅនោះត្រូវចាត់ទុកថាមានអត្ថិភាពរហូតដល់ពេលដែលម្ចាស់សិទ្ធិប្រើប្រាស់ ឬ សិទ្ធិអាស្រ័យនៅនោះទទួលមរណភាព ។

មាត្រា ២៧៩.- ការកើនចំនួនសមាជិកគ្រួសារ

សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ នៅតែមានអត្ថិភាព ទោះបីជាមានការកើនឡើងនូវចំនួនសមាជិកគ្រួសារ ដោយអាពាហ៍ពិពាហ៍ ឬ កំណើតនៃកូន នៅក្រោយពេលបង្កើតសិទ្ធិនេះក៏ដោយ ។

មាត្រា ២៨០.- អនុប្បទាន ជាអាទិ៍ នូវសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ

១-ម្ចាស់សិទ្ធិប្រើប្រាស់ និង ម្ចាស់សិទ្ធិអាស្រ័យនៅ ពុំអាចធ្វើអនុប្បទាន ឬ ធ្វើការចាត់ចែងផ្សេងទៀតនូវសិទ្ធិនោះបានឡើយ ។

២-ម្ចាស់សិទ្ធិប្រើប្រាស់ និង ម្ចាស់សិទ្ធិអាស្រ័យនៅ ពុំអាចយកអចលនវត្ថុដែលជាកម្ម-

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

វត្ថុនៃសិទ្ធិនេះ ធ្វើជាកម្មវត្ថុនៃភតិសន្យាបានឡើយ ។

មាត្រា ២៨១.- សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សរបស់ម្ចាស់សិទ្ធិប្រើប្រាស់ និង ម្ចាស់សិទ្ធិអាស្រ័យនៅ

ម្ចាស់សិទ្ធិប្រើប្រាស់ និង ម្ចាស់សិទ្ធិអាស្រ័យនៅ អាចអនុវត្តសិទ្ធិទាមទារឱ្យប្រគល់វិញ សិទ្ធិទាមទារឱ្យបញ្ឈប់ការរារាំង និង សិទ្ធិទាមទារឱ្យបង្ការជាមុននូវការរារាំង ចំពោះការបំពានសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅដូចសិទ្ធិដែលកម្មសិទ្ធិករមាន ។

មាត្រា ២៨២.- ការទាមទារឱ្យរំលត់សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ

១-ក្នុងករណីដែលម្ចាស់សិទ្ធិប្រើប្រាស់ ឬ ម្ចាស់សិទ្ធិអាស្រ័យនៅ បានធ្វើអំពើផ្ទុយនឹងខ្លឹមសារនៃសិទ្ធិប្រើប្រាស់ ឬ សិទ្ធិអាស្រ័យនៅ ដូចជាករណីដែលបានបង្កឱ្យមានការខូចខាតធ្ងន់ធ្ងរដល់អចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិនោះ ឬ ថែរក្សាមិនបានត្រឹមត្រូវកម្មសិទ្ធិករនៃអចលនវត្ថុនោះ អាចទាមទារទៅតុលាការឱ្យរំលត់សិទ្ធិប្រើប្រាស់ ឬ សិទ្ធិអាស្រ័យនៅបាន ។

២-ការទាមទារឱ្យរំលត់សិទ្ធិប្រើប្រាស់ ឬ សិទ្ធិអាស្រ័យនៅ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងក្នុងការទាមទារសំណងការខូចខាត ដោយផ្អែកលើអំពើអនីត្យានុកូលចំពោះម្ចាស់សិទ្ធិប្រើប្រាស់ ឬ ម្ចាស់សិទ្ធិអាស្រ័យនៅឡើយ ។

មាត្រា ២៨៣.- ការរលត់នូវសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ដោយមរណភាពនៃម្ចាស់សិទ្ធិប្រើប្រាស់ ឬ ម្ចាស់សិទ្ធិអាស្រ័យនៅ ឬ តាមការកំណត់នៅក្នុងកិច្ចសន្យាបង្កើតសិទ្ធិប្រើប្រាស់ ឬ សិទ្ធិអាស្រ័យនៅ

សិទ្ធិប្រើប្រាស់ ឬ សិទ្ធិអាស្រ័យនៅ ត្រូវរលត់ដោយមរណភាពនៃម្ចាស់សិទ្ធិប្រើប្រាស់ ឬ ម្ចាស់សិទ្ធិអាស្រ័យនៅ ឬ ដោយយោងល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងកិច្ចសន្យាបង្កើតសិទ្ធិប្រើប្រាស់ ឬ សិទ្ធិអាស្រ័យនៅ ។

មាត្រា ២៨៤.- ការទទួលបន្ទុកនូវសោហ៊ុយ

១-ក្នុងករណីដែលម្ចាស់សិទ្ធិប្រើប្រាស់ និង ម្ចាស់សិទ្ធិអាស្រ័យនៅ អាស្រ័យផលទាំងស្រុងពីដី ឬ ការកាន់កាប់អគារទាំងមូល ម្ចាស់សិទ្ធិនោះមានករណីយកិច្ចត្រូវទទួលបន្ទុកនូវសោ-

ហើយជួសជុល សោហ៊ុយថែរក្សា ពន្ធនិងអាករ និង សោហ៊ុយសម្រាប់ការធានាភាប់រង ដូចផលុបភោគីដែរ ។

២-ក្នុងករណីដែលម្ចាស់សិទ្ធិប្រើប្រាស់ និង ម្ចាស់សិទ្ធិអាស្រ័យនៅ អាស្រ័យផលមួយភាគ ឬ កាន់កាប់អគារតែមួយភាគ ម្ចាស់សិទ្ធិនោះមានករណីយកិច្ចត្រូវទទួលបន្ទុកនូវសោហ៊ុយដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តាមសមាមាត្រនៃភាគនោះ ។

ជំពូកទី ៧

សេវភាព

ផ្នែកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ២៨៥.- និយមន័យនៃសេវភាព

១-សេវភាព សំដៅទៅលើសិទ្ធិប្រើប្រាស់ដីរបស់អ្នកដទៃ សម្រាប់ផលប្រយោជន៍ដីរបស់ខ្លួន ដោយយោងទៅតាមគោលបំណងដែលបានកំណត់នៅក្នុងកិច្ចសន្យាបង្កើត ។ ប៉ុន្តែ សេវភាពដែលមានខ្លឹមសារផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈពុំអាចបង្កើតបានឡើយ ។

២-ដីអ្នកដទៃដែលផ្តល់ផលប្រយោជន៍ហៅថា "ដីបម្រើ" រីឯដីដែលធ្វើឱ្យកើនផលប្រយោជន៍របស់ខ្លួនហៅថា "ដីប្រើ" ។

៣-ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍នៃដី ឬ ផលុបភោគី អាចបង្កើតសេវភាព ដោយយកដីនោះធ្វើជាដីប្រើបាន ។

មាត្រា ២៨៦.- ការបង្កើតសេវភាព

១-សេវភាពអាចបង្កើតតាមលិខិតជាលាយលក្ខណ៍អក្សរ ឬ មិនតាមលិខិតជាលាយលក្ខណ៍អក្សរបាន ។

២-កម្មសិទ្ធិករនៃដីបម្រើ អាចស្នើសុំឱ្យរំលត់សេវភាពដែលមិនធ្វើតាមលិខិតជាលាយលក្ខណ៍អក្សរ នៅពេលណាក៏បាន ។ ក្នុងករណីដែលការស្នើសុំឱ្យរំលត់មិនបានបញ្ជាក់អំពីពេលរលត់ និង ក្នុងករណីដែលអំឡុងពេលគិតចាប់ពីពេលស្នើសុំឱ្យរំលត់ រហូតដល់ពេលរលត់ដែលបានបញ្ជាក់នៅក្នុងការស្នើសុំឱ្យរំលត់នោះ តិចជាងអំឡុងពេល ១ (មួយ) ខែ សេវភាពត្រូវរលត់

នៅពេលដែលអំឡុងពេល ១ (មួយ) ខែ បានកន្លងហួស គិតចាប់ពីពេលស្នើសុំឱ្យរំលត់ ។

មាត្រា ២៨៧.- លក្ខខណ្ឌតតាំងនៃសេវភាព

១-សេវភាពពុំអាចតតាំងចំពោះតតិយជនបានឡើយ បើពុំបានចុះបញ្ជី ។

២-សេវភាពដែលបានចុះបញ្ជីហើយ អាចតតាំងចំពោះអនុប្បទានិកនៃដីបម្រើបាន ។

មាត្រា ២៨៨.- វិសាលភាពនៃជនដែលអាចទទួលបាននូវសេវភាព

ក្រៅពីកម្មសិទ្ធិករនៃដីប្រើ ភតិកៈនៃដីប្រើដែលត្រូវបានបង្កើតសេវភាព អ្នកជួលអចិន្ត្រៃយ៍នៃដីប្រើដែលត្រូវបានបង្កើតសេវភាព ផលុបភោគីនៃដីប្រើដែលត្រូវបានបង្កើត សេវភាព និងម្ចាស់សិទ្ធិប្រើប្រាស់និងម្ចាស់សិទ្ធិអាស្រ័យនៅដីប្រើដែលត្រូវបានបង្កើតសេវភាពក៏អាចទទួលបាននូវសេវភាពផងដែរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានការកំណត់ផ្សេងនៅក្នុងកិច្ចសន្យាបង្កើតសេវភាព ។

មាត្រា ២៨៩.- ភាពនៅជាមួយគ្នានៃសេវភាព

១-សេវភាព ត្រូវបានធ្វើអនុប្បទាន បើកម្មសិទ្ធិលើដីប្រើត្រូវបានធ្វើអនុប្បទាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានការកំណត់ផ្សេងនៅក្នុងកិច្ចសន្យាបង្កើតសេវភាព ។

២-សេវភាពពុំអាចត្រូវបានធ្វើអនុប្បទាន ឬ ក្លាយជាកម្មវត្ថុនៃសិទ្ធិផ្សេង ដោយបំបែកពីកម្មសិទ្ធិលើដីប្រើបានឡើយ ។

មាត្រា ២៩០.- ករណីយកិច្ចរបស់កម្មសិទ្ធិករនៃដីបម្រើ

១-កម្មសិទ្ធិករនៃដីបម្រើពុំអាចរារាំងការអនុវត្តសេវភាព ឬ ធ្វើអំពើណាដែលបន្ថយការប្រើប្រាស់សេវភាពនោះបានឡើយ ។

២-កម្មសិទ្ធិករនៃដីបម្រើពុំអាចយកដីផ្សេងមកធ្វើជាដីបម្រើ ដោយប្តូរជាមួយនឹងដីបម្រើដែលបានព្រមព្រៀងគ្នាពីដំបូង ដោយគ្មានការយល់ព្រមពីម្ចាស់សេវភាពបានឡើយ ។ ប៉ុន្តែ ក្នុងករណីដែលការបន្តទុកដីបម្រើពីដំបូងនោះ នាំឱ្យមានការខូចខាតផលប្រយោជន៍យ៉ាងធ្ងន់ដល់កម្មសិទ្ធិករនៃដីបម្រើ ដោយសារស្ថានភាពនៅក្រោយពេលបង្កើតសេវភាព នោះមានការ

ROYAUME DU CAMBODGE LE MINISTERE DU PALAIS ROYAL

ប្រែប្រួល កម្មសិទ្ធិករនៃដីបម្រើអាចប្រគល់ដីផ្សេងជាដីបម្រើដែលផ្តល់ផលប្រយោជន៍សម្រាប់ដីប្រើដូចគ្នានឹងដីបម្រើពីដំបូងបាន ។ ក្នុងករណីដែលម្ចាស់សេវភាព ពុំយល់ព្រមទេ ជននោះអាចទាមទារឱ្យតុលាការចេញសាលក្រម ឬ សាលដីកា ដើម្បីជំនួសការយល់ព្រមបាន ។

មាត្រា ២៩១.- ករណីយកិច្ចរបស់ម្ចាស់សេវភាព

១-ម្ចាស់សេវភាព ពុំអាចប្រើប្រាស់ដីបម្រើ ឱ្យហួសពីកម្រិតដែលបានកំណត់នៅក្នុងកិច្ចសន្យាបង្កើតឡើយ ។ សេវភាពនៃការយកទឹកបង្កើតឡើងនៅកន្លែងប្រភពទឹក រាប់បញ្ចូលសិទ្ធិឆ្លងកាត់ដីដែលមានប្រភពទឹកនោះដែរ ។

២-ម្ចាស់សេវភាពក៏ពុំអាចធ្វើការផ្លាស់ប្តូរណាមួយទៅលើដីបម្រើ ឬ ដីប្រើ ដែលអាចមានឥទ្ធិពលធ្ងន់ធ្ងរដល់ស្ថានភាពនៃដីបម្រើបានឡើយ ។

៣-បើម្ចាស់សេវភាពបានធ្វើផ្ទុយនឹងបញ្ញត្តិនៃវាក្យខណ្ឌទី ១ កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ កម្មសិទ្ធិករនៃដីបម្រើអាចទាមទារទៅតុលាការឱ្យរំលត់សេវភាពបាន ។

៤-ការទាមទារឱ្យរំលត់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ មិនរារាំងក្នុងការទាមទារសំណងនៃការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូលចំពោះផលុបភោគីឡើយ ។

៥-នៅក្នុងករណីដែលមានកំណត់តម្លៃថ្នូរចំពោះសេវភាព បើម្ចាស់សេវភាពមិនបានបង់តម្លៃថ្នូរដែលបានកំណត់ទេ កម្មសិទ្ធិករនៃដីបម្រើអាចទាមទារទៅតុលាការឱ្យរំលត់សេវភាពបាន ។

មាត្រា ២៩២.- សិទ្ធិសាងសង់ការ្យរបស់ម្ចាស់សេវភាព

១-អ្នកមានសេវភាព អាចសាងសង់ការ្យដែលចាំបាច់ក្នុងការអនុវត្តសេវភាពនៅលើដីបម្រើបាន ។ ម្ចាស់សេវភាពមានករណីយកិច្ចត្រូវយកការ្យចេញ និង ធ្វើបដិទានទូវដីបម្រើ នៅពេលដែលសេវភាពរលត់ ។

២-កម្មសិទ្ធិករនៃដីបម្រើ អាចប្រើប្រាស់ការ្យដែលត្រូវបានសាងសង់នៅលើដីបម្រើ ដើម្បីអនុវត្តសេវភាព បាន ក្នុងកម្រិតដែលមិនរារាំងការអនុវត្តសេវភាព ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ កម្មសិទ្ធិករនៃដីបម្រើត្រូវទទួលបន្ទុកចំណាយហើយក្នុងការសាងសង់ និង រក្សាទុកការ្យនោះ តាមសមាមាត្រនៃចំណែក

ដែលខ្លួនទទួលផលប្រយោជន៍ ។

មាត្រា ២៩៣.- បន្ទុកនៃសោហ៊ុយសម្រាប់ការសាងសង់ការៀ

១-កម្មសិទ្ធិករនៃដីប្រើត្រូវទទួលបន្ទុកនូវសោហ៊ុយសាងសង់ និង រក្សាទុកការ្យ ដែលចាំបាច់ដើម្បីអនុវត្តសេវភាព លើកលែងតែមានការកំណត់ផ្សេង ។

២-នៅក្នុងករណីដែលមានការសន្យាពិសេសដែលកំណត់ថា កម្មសិទ្ធិករនៃដីបម្រើ ត្រូវទទួលបន្ទុកនូវសោហ៊ុយក្នុងការសាងសង់ និង រក្សាទុកការ្យ បើបានចុះបញ្ជីអំពីការសន្យាពិសេសនោះ អនុប្បទានិកនៃកម្មសិទ្ធិលើដីបម្រើនោះ ក៏ត្រូវទទួលបន្ទុនូវករណីយកិច្ចនោះដែរ ។

មាត្រា ២៩៤.- សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សរបស់ម្ចាស់សេវភាព

ម្ចាស់សេវភាព អាចអនុវត្តសិទ្ធិទាមទារឱ្យប្រគល់វិញ សិទ្ធិទាមទារឱ្យបញ្ឈប់ការរារាំង និង សិទ្ធិទាមទារឱ្យបង្ការជាមុននូវការរារាំង ចំពោះការបំពានសេវភាព ដូចសិទ្ធិដែលកម្មសិទ្ធិករមាន ។

មាត្រា ២៩៥.- ការលះបង់ និង ផ្ទេរកម្មសិទ្ធិនៃដីប្រើឱ្យម្ចាស់សេវភាព

១-ក្នុងករណីដែលមានការសន្យាពិសេសដែលកំណត់ថា កម្មសិទ្ធិករនៃដីបម្រើត្រូវទទួលបន្ទុកនូវសោហ៊ុយដែលបានកំណត់នៅក្នុងមាត្រា ២៩៣ (បន្ទុកនៃសោហ៊ុយសម្រាប់ការសាងសង់ការ្យ) នៃក្រមនេះ កម្មសិទ្ធិករនៃដីបម្រើអាចរួចខ្លួនពីករណីយកិច្ចនេះបាន ដោយលះបង់ និង ផ្ទេរនូវកម្មសិទ្ធិលើចំណែកដីដែលចាំបាច់សម្រាប់សេវភាព ឱ្យទៅម្ចាស់សេវភាព នៅពេលណាក៏បាន ។

២-ការលះបង់និង ផ្ទេរ គឺជាការបោះបង់កម្មសិទ្ធិនៃដីបម្រើដោយឆន្ទៈឯកតោភាគីរបស់កម្មសិទ្ធិករនៃដីបម្រើ ហើយធ្វើឱ្យកម្មសិទ្ធិនោះស្ថិតនៅក្រោមម្ចាស់សេវភាព ។

មាត្រា ២៩៦.- ការកំណត់អំឡុងពេលដែលសេវភាពមានអត្ថិភាព

១-បើមានការកំណត់អំឡុងពេលក្នុងកិច្ចសន្យាបង្កើតសេវភាព សេវភាពនោះត្រូវរលត់ដោយការផុតរយៈអំឡុងពេលនោះ ។

២-បើគ្មានកំណត់អំឡុងពេលក្នុងកិច្ចសន្យាបង្កើតសេវភាពទេ កម្មសិទ្ធិករនៃដីបម្រើ

ROYAUME DU CAMBODGE LE MINISTERE DU PALAIS ROYAL

អាចទាមទារទៅតុលាការឱ្យរំលត់សេវភាពបាន ។ តុលាការត្រូវវិនិច្ឆ័យទទួលស្គាល់ ឬ មិនទទួលស្គាល់ការទាមទារឱ្យរំលត់ ដោយពិចារណាទៅលើស្ថានភាពទាំងឡាយ ដូចជាកាលៈទេសៈនៃការបង្កើត អំឡុងពេលដែលមានកន្លងទៅ អត្ថិភាព ឬ នត្ថិភាពនៃតម្លៃផ្លូវជាអាទិ៍ ។

មាត្រា ២៩៧.- ការរលត់សេវភាពដោយមហន្តរាយទាំងស្រុងនៃដីប្រើ

សេវភាពត្រូវរលត់ ក្នុងករណីដែលដីប្រើទទួលរងនូវមហន្តរាយទាំងស្រុង ។

មាត្រា ២៩៨.- ការរំលត់សេវភាពដោយម្ចាស់កម្មសិទ្ធិអវិភាគ

១-កម្មសិទ្ធិអវិភាគម្នាក់នៃដីប្រើ ពុំអាចរំលត់សេវភាពចំពោះចំណែករបស់ខ្លួនបានឡើយ ។

២-ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់នៃដីបម្រើ ពុំអាចរំលត់សេវភាពចំពោះចំណែករបស់ខ្លួនបានឡើយ ។

មាត្រា ២៩៩.- ការបែងចែកដី ឬ អនុប្បទាននូវដីមួយផ្នែក និង សេវភាព

១-ក្នុងករណីដែលដីប្រើត្រូវបានបែងចែក ឬ ផ្នែកនៃដីប្រើណាមួយត្រូវបានធ្វើអនុប្បទាន សេវភាពនៅតែមានបន្តសម្រាប់ផ្នែកនីមួយៗនោះ ។ ប៉ុន្តែ ប្រសិនបើសេវភាពមានទំនាក់ទំនងតែមួយផ្នែកនៃដីប្រើតាមលក្ខណៈនៃសេវភាពនោះ សេវភាពមិនត្រូវមានបន្តសម្រាប់ផ្នែកឯទៀតឡើយ ។

២-ក្នុងករណីដែលដីបម្រើត្រូវបានបែងចែក ឬ ផ្នែកនៃដីបម្រើណាមួយត្រូវបានធ្វើអនុប្បទាន សេវភាពនៅតែមានបន្តលើផ្នែកនីមួយៗនោះ ។ ប៉ុន្តែ ប្រសិនបើសេវភាពមានទំនាក់ទំនងតែមួយផ្នែកនៃដីបម្រើតាមលក្ខណៈនៃសេវភាពនោះ សេវភាពមិនត្រូវមានបន្តលើផ្នែកឯទៀតឡើយ ។

ផ្នែកទី ២

សេវភាព និង អាជ្ញាយុកាល

មាត្រា ៣០០.- អាជ្ញាយុកាលនៃលទ្ធកម្មសេវភាព

១-មានតែសេវភាពដែលបន្តជានិរន្តរ៍ និង អាចមើលឃើញជាក់ស្តែងតែប៉ុណ្ណោះទេ ដែលអាចធ្វើលទ្ធកម្មដោយអាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិបាន ។

២-សេវភាពដែលបន្តជានិរន្តរ៍ សំដៅទៅលើសេវភាពដែលស្ថិតនៅក្នុងស្ថានភាព ដែលសេវភាពនោះមានអត្ថិភាព ដោយពុំចាំបាច់ឱ្យមានសកម្មភាពរបស់បុគ្គល ដោយសារតែទីតាំងនៃកន្លែង ហើយផ្តល់ប្រយោជន៍ដល់ដីប្រើ ដោយមិនផ្អាករអាក់រអួល ហើយធ្វើឱ្យមានបន្ទុកដល់ដីបម្រើ ។

៣-សេវភាពដែលអាចមើលឃើញជាក់ស្តែង សំដៅទៅលើសេវភាពដែលស្ថិតនៅក្នុងស្ថានភាពដែលសេវភាពនោះមានអត្ថិភាព ដោយការបង្ហាញខ្លួនតាមរយៈសំណង់ ឬ សញ្ញាសំគាល់ខាងក្រៅ ។

មាត្រា ៣០១.- អាជ្ញាយុកាលនៃលទ្ធកម្មសេវភាពដោយម្ចាស់កម្មសិទ្ធិអវិភាគម្នាក់នៃដីប្រើ

១-ប្រសិនបើម្ចាស់កម្មសិទ្ធិអវិភាគម្នាក់នៅក្នុងចំណោមម្ចាស់កម្មសិទ្ធិអវិភាគនៃដីប្រើ បានធ្វើលទ្ធកម្មនូវសេវភាពដោយអាជ្ញាយុកាល ម្ចាស់កម្មសិទ្ធិអវិភាគដទៃទៀតក៏ត្រូវធ្វើលទ្ធកម្មនូវសេវភាពដែរ ។

២-ការផ្អាកអាជ្ញាយុកាលនៃលទ្ធកម្មចំពោះម្ចាស់កម្មសិទ្ធិអវិភាគ ពុំមានអានុភាពឡើយ បើពុំបានធ្វើចំពោះម្ចាស់កម្មសិទ្ធិអវិភាគនីមួយៗដែលអនុវត្តសេវភាព ។

៣-ក្នុងករណីម្ចាស់កម្មសិទ្ធិអវិភាគដែលអនុវត្តសេវភាពមានចំនួនច្រើននាក់ ទោះជាមានមូលហេតុបង្អង់អាជ្ញាយុកាល ចំពោះតែម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់ក៏ដោយ ក៏អាជ្ញាយុកាលនៅតែមានដំណើរការទៅមុខ ចំពោះម្ចាស់កម្មសិទ្ធិអវិភាគនីមួយៗដែរ ។

មាត្រា ៣០២.- ពេលចាប់ផ្តើមគិតអាជ្ញាយុកាលនៃការរំលត់សេវភាព

អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់ដែលបានកំណត់នៅក្នុងមាត្រា ៥០០ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើទ្រព្យសម្បត្តិ ក្រៅពីសិទ្ធិលើបំណុល ឬ កម្មសិទ្ធិ) នៃក្រមនេះ ត្រូវគិតចាប់ពីពេលដែលបានអនុវត្តចុងក្រោយបំផុត ចំពោះសេវភាពដែលមិនបន្តជានិរន្តរ៍ រីឯសេវភាពដែលបន្តជានិរន្តរ៍វិញ ត្រូវគិតចាប់តាំងពីពេលហេតុដែលរារាំង ការអនុវត្តសេវភាពនោះបានកើតឡើង ។

ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL

មាត្រា ៣០៣.- ការផ្អាក ឬ បង្អង់អាជ្ញាយុកាលនៃការរំលត់សេវភាព ក្នុងករណីមានកម្មសិទ្ធិអវិភាគលើដីបម្រើ

ក្នុងករណីដែលដីបម្រើស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់បុគ្គលច្រើននាក់ ប្រសិនបើមានការផ្អាក ឬ បង្អង់អាជ្ញាយុកាល ចំពោះបុគ្គលណាម្នាក់ក្នុងចំណោមម្ចាស់កម្មសិទ្ធិអវិភាគ ការផ្អាក ឬ បង្អង់នោះត្រូវមានអានុភាពលើម្ចាស់កម្មសិទ្ធិអវិភាគដទៃទៀត ។

មាត្រា ៣០៤.- ការរលត់សេវភាពតែមួយផ្នែកដោយអាជ្ញាយុកាល

ប្រសិនបើម្ចាស់សេវភាពពុំបានអនុវត្តផ្នែកណាមួយនៃសិទ្ធិរបស់ខ្លួន ផ្នែកដែលពុំបានអនុវត្តនោះនឹងត្រូវរលត់ ដោយអាជ្ញាយុកាលនៃការរំលត់សិទ្ធិ ។

មាត្រា ៣០៥.- លទ្ធកម្មដោយអាជ្ញាយុកាលរបស់អ្នកកាន់កាប់ដីបម្រើ និង ភ័ព្វវាសនានៃសេវភាព

១-ប្រសិនបើអ្នកកាន់កាប់ដីបម្រើ បានកាន់កាប់ដោយមានល័ក្ខខ័ណ្ឌចាំបាច់សម្រាប់អាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិ សេវភាពត្រូវរលត់ដោយសារហេតុនោះ ។

២-ប្រសិនបើម្ចាស់សេវភាពបានអនុវត្តសិទ្ធិរបស់ខ្លួន នៅក្នុងអំឡុងពេលនៃការកាន់កាប់ដែលចាំបាច់សម្រាប់អាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិ អ្នកកាន់កាប់នោះត្រូវធ្វើលទ្ធកម្ម ដោយអាជ្ញាយុកាលនូវដីដែលមានបន្ទុករបស់សេវភាព ។

ជំពូកទី ៨

កម្មសិទ្ធិ និង សិទ្ធិប្រត្យក្សផ្សេងៗរបស់រដ្ឋ វត្តអារាមនៃព្រះពុទ្ធសាសនា សហគមន៍ជនជាតិដើមភាគតិច និង សហគមន៍ផ្សេងៗ

មាត្រា ៣០៦.- កម្មសិទ្ធិ និង សិទ្ធិប្រត្យក្សផ្សេងៗរបស់រដ្ឋ វត្តអារាមនៃព្រះពុទ្ធសាសនា សហគមន៍ជនជាតិដើមភាគតិច និង សហគមន៍ផ្សេងៗ

បញ្ញត្តិនៃក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្ត ចំពោះកម្មសិទ្ធិ និង សិទ្ធិប្រត្យក្សផ្សេងៗ របស់រដ្ឋ វត្តអារាមនៃព្រះពុទ្ធសាសនា សហគមន៍ជនជាតិដើមភាគតិច និង សហគមន៍ផ្សេងៗ លើកលែងតែមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ពិសេស ឬ ទំនៀមទម្លាប់ ។

ROYAUME DU CAMBODGE · LE MINISTÈRE DU PALAIS ROYAL

ជំពូកទី ៩
សិទ្ធិដែលត្រូវបានបង្កើតឡើងដោយសម្បទានដីធ្លី

មាត្រា ៣០៧.- សិទ្ធិដែលត្រូវបានបង្កើតឡើងដោយសម្បទាន

បញ្ញត្តិស្តីពីសិទ្ធិផលអចិន្ត្រៃយ៍ ក្នុងក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសិទ្ធិលើដីដែលត្រូវបានបង្កើតឡើងដោយសម្បទាន ក្នុងទំហំនៃល័ក្ខខ័ណ្ឌនៃសម្បទាន លើកលែងតែករណីដែលមានកំណត់ផ្សេងនៅក្នុងច្បាប់ពិសេស ។

គន្ថីទី ៤
កាតព្វកិច្ច

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

ផ្នែកទី ១
ប្រភពនៃកាតព្វកិច្ច និង និយមន័យនៃពាក្យផ្សេងៗ

មាត្រា ៣០៨.- និយមន័យនៃកាតព្វកិច្ច

១-កាតព្វកិច្ចគឺជាទំនាក់ទំនងគតិយុត្តដែលចងបុគ្គលពីរនាក់ ដោយឱ្យបុគ្គលម្នាក់ដែលបានកំណត់មានករណីយកិច្ចមួយចំនួន ចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត ។

២-បុគ្គលដែលមានករណីយកិច្ចហៅថា កូនបំណុលរីឯបុគ្គលដែលទទួលផលប្រយោជន៍ពីករណីយកិច្ចនោះហៅថា ម្ចាស់បំណុល ។

៣-ម្ចាស់បំណុលមានសិទ្ធិត្រូវគ្នាទៅនឹងករណីយកិច្ចរបស់កូនបំណុល ។

មាត្រា ៣០៩.- ប្រភពនៃកាតព្វកិច្ច

១-កាតព្វកិច្ចកើតមានឡើងដោយកិច្ចសន្យា ដោយសកម្មភាពឯកតោភាគី ដោយការគ្រប់គ្រងដោយឥតអាណត្តិ ដោយសេចក្តីចម្រើនដោយឥតហេតុ ដោយអំពើអនីត្យានុកូល និង

ដោយបញ្ញត្តិនៃច្បាប់ ។

២-កាតព្វកិច្ចដែលកើតឡើងដោយកិច្ចសន្យា និង ដោយសកម្មភាពឯកតោភាគី គឺជាកាតព្វកិច្ចដែលកើតឡើងដោយឆន្ទៈរបស់ភាគី ។

៣-កាតព្វកិច្ចដែលកើតឡើងដោយការគ្រប់គ្រងដោយឈឺឆ្អាល ដោយសេចក្តីចម្រើនដោយឥតហេតុ ដោយអំពើអនីត្យានុកូល និង ដោយបញ្ញត្តិនៃច្បាប់ គឺជាកាតព្វកិច្ចដែលកំណត់ដោយច្បាប់ ។ បញ្ញត្តិពីជំពូកទី ៣(ការអនុវត្តកិច្ចសន្យា) ដល់ជំពូកទី ៧ (ការរលត់កាតព្វកិច្ច) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះកាតព្វកិច្ចដែលកំណត់ ដោយច្បាប់ ។

មាត្រា ៣១០.- និយមន័យនៃការបង្ហាញឆន្ទៈ

១-ការបង្ហាញឆន្ទៈរបស់ភាគីដែលមានបំណងបង្កើតអានុភាពគតិយុត្ត ហៅថាការបង្ហាញ ឆន្ទៈ ។

២-ការបង្ហាញឆន្ទៈ ត្រូវមានអានុភាព ចាប់ពីពេលដែលការជូនដំណឹងអំពីការបង្ហាញឆន្ទៈនោះ បានទៅដល់ភាគីម្ខាងទៀត ។

មាត្រា ៣១១.- និយមន័យនៃកិច្ចសន្យា

កិច្ចសន្យាគឺជាកិរិយាដែលបុគ្គលពីរនាក់ ឬ ច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច ។

មាត្រា ៣១២.- និយមន័យនៃសកម្មភាពឯកតោភាគី

១-សកម្មភាពឯកតោភាគី គឺជាសកម្មភាពដែលបង្កើត កែប្រែ ឬ រំលត់នូវ កាតព្វកិច្ច ដោយបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យដោយភាគីម្ខាង ឬ ដោយអនុវត្តសិទ្ធិ ដែលបានទទួលតាមកិច្ចសន្យា ឬ តាមបញ្ញត្តិនៃច្បាប់ ។

២-បញ្ញត្តិនៃផ្នែកទី ២(វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា) និង ផ្នែកទី ៤ (ការតំណាង) នៃជំពូកទី ២ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសកម្មភាពឯកតោ-ភាគី ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ផ្នែកទី ២
ប្រភេទ និង បែបយ៉ាងនៃកាតព្វកិច្ច

មាត្រា ៣១៣.- ប្រភេទនៃកាតព្វកិច្ច

ក្រៅពីគោលបំណងផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់លើវត្ថុ ឬ ប្រាក់ កាតព្វកិច្ចអាចមានគោលបំណងធ្វើ ឬ មិនធ្វើសកម្មភាពណាមួយ ។

មាត្រា ៣១៤.- កាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់

ចំពោះកាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់អ្វីមួយ កូនបំណុលមានករណីយកិច្ចថែរក្សាវត្ថុនោះ ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ រហូតដល់ពេលប្រគល់វត្ថុនោះ ។

មាត្រា ៣១៥.- កាតព្វកិច្ចដែលបានកំណត់ប្រភេទនៃវត្ថុ

១-ក្នុងករណីដែលកម្មវត្ថុនៃកាតព្វកិច្ចត្រូវបានកំណត់ដោយប្រភេទនៃវត្ថុ ប្រសិនបើកម្មវត្ថុដែលត្រូវផ្តល់ មានគុណភាពច្រើនយ៉ាង កូនបំណុលមានករណីយកិច្ចផ្តល់នូវវត្ថុដែលមានគុណភាពដូចដែលគូភាគីបានកំណត់ ។ ក្នុងករណីដែលគូភាគីមិនកំណត់គុណភាពទេ កូនបំណុលមានករណីយកិច្ចផ្តល់នូវវត្ថុដែលមានគុណភាពមធ្យម ។

២-ចំពោះកាតព្វកិច្ចដែលបានកំណត់ប្រភេទ ក្រោយពេលដែលកូនបំណុលបានកំណត់កម្មវត្ថុដែលត្រូវផ្តល់ច្បាស់លាស់ និង ដែលបានបញ្ចប់សកម្មភាពចាំបាច់ដើម្បីផ្តល់នូវកម្មវត្ថុដែលបានកំណត់ហើយនោះ កូនបំណុលមានករណីយកិច្ចផ្តល់នូវវត្ថុនោះតែប៉ុណ្ណោះ ។

មាត្រា ៣១៦.- កាតព្វកិច្ចជាប្រាក់

១-ក្នុងករណីដែលកម្មវត្ថុនៃកាតព្វកិច្ចជាប្រាក់ កូនបំណុលអាចសងជារូបិយវត្ថុផ្សេងៗតាមការជ្រើសរើសរបស់ខ្លួនបាន ។ ប៉ុន្តែ ម្ចាស់បំណុល និង កូនបំណុលអាចកំណត់ការសងជារូបិយវត្ថុពិសេសបានដែរ ។

២-ក្នុងករណីដែលរូបិយវត្ថុពិសេសដែលបានកំណត់ជាកម្មវត្ថុនៃកាតព្វកិច្ច លែងជារូបិយវត្ថុស្របច្បាប់នៅពេលអនុវត្តកាតព្វកិច្ច កូនបំណុលអាចសងជារូបិយវត្ថុណាមួយផ្សេង

ទៀតបាន ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលការផ្តល់នូវរូបិយវត្ថុបរទេស ត្រូវបានកំណត់ជាកម្មវត្ថុនៃកាតព្វកិច្ច ។

មាត្រា ៣១៧.- កាតព្វកិច្ចជារូបិយវត្ថុបរទេស

១-ក្នុងករណីដែលបានកំណត់ចំនួននៃកាតព្វកិច្ចជារូបិយវត្ថុបរទេស កូនបំណុលអាចសងជារូបិយវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ដោយគិតទៅតាមអត្រាប្តូររូបិយប័ណ្ណបរទេស នៅកន្លែងដែលត្រូវអនុវត្តកាតព្វកិច្ចនោះនៅពេលកំណត់អនុវត្ត ។ ប៉ុន្តែ ប្រសិនបើមានការសន្យាពិសេសផ្សេងពីបញ្ញត្តិនេះរវាងម្ចាស់បំណុល និង កូនបំណុល ត្រូវអនុវត្តទៅតាមការសន្យាពិសេសនោះ ។

២-ក្នុងករណីដែលកូនបំណុលដែលមានការយឺតយ៉ាវក្នុងការអនុវត្ត សងជារូបិយវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលសង ដោយគិតទៅតាមអត្រាប្តូររូបិយប័ណ្ណបរទេសនៅពេលកំណត់អនុវត្ត ឬ នៅពេលដែលកូនបំណុលសងបាន ។ ប៉ុន្តែ ប្រសិនបើមានការសន្យាពិសេសផ្សេងពីបញ្ញត្តិនេះ រវាងម្ចាស់បំណុល និង កូនបំណុល ត្រូវអនុវត្តទៅតាមការសន្យាពិសេសនោះ ។

មាត្រា ៣១៨.- អត្រាការប្រាក់ដែលកំណត់ដោយច្បាប់

ចំពោះកាតព្វកិច្ចដែលត្រូវបង្កើតការប្រាក់ ក្នុងករណីដែលគ្មានការកំណត់ផ្សេងទេ ត្រូវគិតអត្រាការប្រាក់ ចំនួន ៥ ភាគរយ (ប្រាំភាគរយ) ក្នុងមួយឆ្នាំ ។

មាត្រា ៣១៩.- ការប្រាក់សមាស

ក្នុងករណីដែលមានការយឺតយ៉ាវមិនបានសងការប្រាក់ សម្រាប់រយៈពេលចាប់ពី ១ (មួយ) ឆ្នាំឡើងទៅ ហើយទោះបីជាម្ចាស់បំណុលបានដាស់តឿនឱ្យសងយ៉ាងណាក៏ដោយក៏កូនបំណុលមិនព្រមសងការប្រាក់នោះ ម្ចាស់បំណុលអាចបូកការប្រាក់បញ្ចូលទៅក្នុងប្រាក់ដើមបាន ។

មាត្រា ៣២០.- កាតព្វកិច្ចអនិយ័ត

ក្នុងករណីដែលកម្មវត្ថុនៃកាតព្វកិច្ច ត្រូវបានកំណត់ដោយការជ្រើសរើសក្នុងចំណោមការ

ផ្តល់ច្រើនប្រភេទ កូនបំណុលត្រូវមានសិទ្ធិជ្រើសរើស ។ ប៉ុន្តែ ភាគីនៃកិច្ចសន្យាអាចឱ្យសិទ្ធិជ្រើសរើសនោះទៅម្ចាស់បំណុល ឬ តតិយជនតាមការកំណត់ផ្សេងបាន ។

មាត្រា ៣២១.- ការអនុវត្តសិទ្ធិជ្រើសរើស

១-សិទ្ធិជ្រើសរើសត្រូវបានអនុវត្តដោយការជូនដំណឹងទៅភាគីម្ខាងទៀត ។ ក្នុងករណីដែលកូនបំណុលមានសិទ្ធិជ្រើសរើស ការផ្តល់នូវកម្មវត្ថុដែលកូនបំណុលបានជ្រើសរើស ត្រូវចាត់ទុកថាបានអនុវត្តនូវសិទ្ធិជ្រើសរើសនោះ ។ ក្នុងករណីដែលតតិយជនមានសិទ្ធិជ្រើសរើស សិទ្ធិនេះត្រូវបានអនុវត្តដោយការជូនដំណឹងទៅឱ្យកូនបំណុល និង ម្ចាស់បំណុល ។

២-ការជ្រើសរើស ត្រូវមានអានុភាពប្រតិសកម្ម ចាប់តាំងពីពេលដែលកាតព្វកិច្ចបានកើតឡើង ។

មាត្រា ៣២២.- ការផ្ទេរសិទ្ធិជ្រើសរើស

១-ក្នុងករណីដែលកាតព្វកិច្ចដល់ពេលកំណត់សង ទោះបីជាកូនបំណុល ឬ ម្ចាស់បំណុលដែលមានសិទ្ធិជ្រើសរើសបានទទួលការដាស់តឿនឱ្យអនុវត្តសិទ្ធិនេះ ក្នុងអំឡុងពេលសមរម្យដែលភាគីម្ខាងទៀតបានកំណត់ក៏ដោយ តែមិនបានជ្រើសរើសក្នុងអំឡុងពេលនោះ សិទ្ធិជ្រើសរើសត្រូវផ្ទេរទៅភាគីម្ខាងទៀត ។

២-ក្នុងករណីដែលតតិយជនមានសិទ្ធិជ្រើសរើស ទោះបីជាតតិយជននោះបានទទួលការដាស់តឿនឱ្យអនុវត្តសិទ្ធិនេះក្នុងអំឡុងពេលសមរម្យដែលកូនបំណុល ឬ ម្ចាស់បំណុលបានកំណត់ក៏ដោយ តែមិនបានជ្រើសរើសក្នុងអំឡុងពេលនោះ សិទ្ធិជ្រើសរើសនោះត្រូវផ្ទេរទៅកូនបំណុលវិញ ។

មាត្រា ៣២៣.- ការកំណត់កាតព្វកិច្ចអនិយ័តដោយអលទ្ធភាព

១-ប្រសិនបើការផ្តល់តាវកាលិកណាមួយក្នុងចំណោមតាវកាលិកច្រើនដែលអាចជាកម្មវត្ថុនៃកាតព្វកិច្ចអនិយ័ត មិនអាចប្រព្រឹត្តទៅបានចាប់តាំងពីពេលបង្កើត ឬ ក្រោយពេលបង្កើតកិច្ចសន្យា ដោយគ្មានកំហុសរបស់ភាគី កម្មវត្ថុនៃកាតព្វកិច្ចត្រូវតែជាតាវកាលិកដែលនៅសល់ ។ បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣២១ (ការអនុវត្តសិទ្ធិជ្រើសរើស) ត្រូវយកមកអនុ-

122/496

វត្ថុដូចគ្នាផងដែរ ចំពោះករណីនេះ ។

២-ប្រសិនបើភាគីដែលមានសិទ្ធិជ្រើសរើស មានកំហុសចំពោះអលទ្ធភាពនៃការផ្តល់តាវកាលិក សិទ្ធិជ្រើសរើសត្រូវផ្ទេរទៅភាគីម្ខាងទៀត ។

៣-ប្រសិនបើកូនបំណុលដែលគ្មានសិទ្ធិជ្រើសរើស មានកំហុសចំពោះអលទ្ធភាពនៃការផ្តល់តាវកាលិក អ្នកដែលមានសិទ្ធិជ្រើសរើសអាចជ្រើសរើសតាវកាលិកដែលមិនអាចប្រព្រឹត្តទៅបាននោះ និង អាចទាមទារសំណងនៃការខូចខាតចំពោះកូនបំណុលនោះបាន ។

៤-ប្រសិនបើម្ចាស់បំណុលដែលគ្មានសិទ្ធិជ្រើសរើស មានកំហុសចំពោះអលទ្ធភាពនៃការផ្តល់តាវកាលិក កូនបំណុលដែលមានសិទ្ធិជ្រើសរើសអាចជ្រើសរើសតាវកាលិក ដែលមិនអាចប្រព្រឹត្តទៅបាននោះ និង អាចរួចផុតពីកាតព្វកិច្ចបាន ។

មាត្រា ៣២៤.- សិទ្ធិលើបំណុល និង កាតព្វកិច្ចដែលមានភាគីច្រើននាក់

១-ក្នុងករណីដែលមានម្ចាស់បំណុលច្រើននាក់ ចំពោះកាតព្វកិច្ចមួយ ប្រសិនបើគ្មានការបង្ហាញឆន្ទៈផ្សេង ម្ចាស់បំណុលម្នាក់ៗមានសិទ្ធិដោយមានភាគស្មើគ្នា ។

២-ក្នុងករណីដែលការអនុវត្តកាតព្វកិច្ច មិនអាចបែងចែកបានតាមលក្ខណៈនៃកាតព្វកិច្ចនេះ ឬ ដោយការបង្ហាញឆន្ទៈរបស់ភាគី ប្រសិនបើមានម្ចាស់បំណុលច្រើននាក់ ម្ចាស់បំណុលម្នាក់ៗអាចទាមទារឱ្យអនុវត្តសម្រាប់ម្ចាស់បំណុលទាំងអស់ ហើយកូនបំណុលអាចអនុវត្តចំពោះម្ចាស់បំណុលម្នាក់ៗសម្រាប់ម្ចាស់បំណុលទាំងអស់បាន ។

៣-ចំពោះកាតព្វកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ សកម្មភាពរបស់ម្ចាស់បំណុលអវិភាគីយ៍ណាម្នាក់ ឬ ហេតុដែលបានកើតឡើងចំពោះម្ចាស់បំណុល អវិភាគីយ៍ណាម្នាក់ មិនត្រូវមានអានុភាពចំពោះម្ចាស់បំណុលអវិភាគីយ៍ផ្សេងទៀតឡើយ ។ ក្នុងករណីដែលកូនបំណុលធ្វើនវកម្មជាមួយម្ចាស់បំណុលអវិភាគីយ៍ណាម្នាក់ ឬ ទទួលការលើកលែងពីម្ចាស់បំណុលអវិភាគីយ៍ណាម្នាក់ ប្រសិនបើកូនបំណុលនោះអនុវត្តកាតព្វកិច្ចទាំងអស់ ឬ មួយភាគ ដោយផ្អែកលើការទាមទាររបស់ម្ចាស់បំណុលអវិភាគីយ៍ផ្សេងទៀត កូនបំណុលអាចទាមទារឱ្យសងមកវិញនូវផលប្រយោជន៍ដែលម្ចាស់បំណុលអវិភាគីយ៍ម្នាក់ នោះត្រូវទទួល ប្រសិនបើម្ចាស់បំណុលអវិភាគីយ៍នោះមិនបានបាត់បង់សិទ្ធិរបស់ខ្លួន ។

៤-ចំពោះកាតព្វកិច្ចដោយសាមគ្គីភាព និង ករណីផ្សេងទៀតដែលមានកូនបំណុលច្រើននាក់ ត្រូវអនុលោមតាមបញ្ញត្តិចាប់ពីមាត្រា ៩២១ (អត្ថន័យនៃកាតព្វកិច្ចដោយសាមគ្គីភាព) ដល់ មាត្រា ៩៣៧ (កាតព្វកិច្ចអវិភាគីយ៍ និង កាតព្វកិច្ចដែលមានលក្ខណៈប្រហាក់ប្រហែលនឹង កាតព្វកិច្ចដោយសាមគ្គីភាព និងកាតព្វកិច្ចវិភាគីយ៍) ។

ផ្នែកទី ៣
លក្ខខណ្ឌ កំណត់ពេល និង អំឡុងពេល
កថាភាគទី ១
លក្ខខណ្ឌ

មាត្រា ៣២៥.- អត្ថន័យនៃលក្ខខណ្ឌ

១-ភាគីនៃកិច្ចសន្យា អាចដាក់លក្ខខណ្ឌលើការបង្កើត ឬ ការរលត់អានុភាពនៃកិច្ចសន្យា នោះ ។ ចំពោះសកម្មភាពឯកតោភាគី ភាគីនោះអាចដាក់លក្ខខណ្ឌបាន លុះត្រាតែមិននាំឱ្យ មានការខូចខាតដោយមិនត្រឹមត្រូវដល់ភាគីម្ខាងទៀត ។

២-លក្ខខណ្ឌគឺជាព្រឹត្តិការណ៍ដែលកើតឡើងនាពេលអនាគតហើយដែលមិនទៀងទាត់ ។

៣-ក្នុងករណីដែលដាក់លក្ខខណ្ឌបង្អង់លើកាតព្វកិច្ច ឬ សិទ្ធិដែលកើតឡើងដោយកិច្ចសន្យា ឬ សកម្មភាពឯកតោភាគី អានុភាពនៃកាតព្វកិច្ច ឬ សិទ្ធិនោះ ត្រូវកើតឡើងចាប់តាំងពី ពេលដែលលក្ខខណ្ឌបង្អង់នោះត្រូវបានបំពេញ ។ ក្នុងករណីដែលដាក់លក្ខខណ្ឌរំលាយកាតព្វកិច្ច ឬ សិទ្ធិដែលកើតឡើងដោយកិច្ចសន្យា ឬ សកម្មភាពឯកតោភាគី អានុភាពនៃកាតព្វកិច្ច ឬ សិទ្ធិនោះត្រូវរលត់នៅពេលដែលលក្ខខណ្ឌរំលាយនោះត្រូវបានបំពេញ ។

មាត្រា ៣២៦.- ការចាត់ចែងសិទ្ធិដែលភ្ជាប់ជាមួយនឹងលក្ខខណ្ឌ

សិទ្ធិដែលភ្ជាប់ជាមួយនឹងលក្ខខណ្ឌ អាចក្លាយជាកម្មវត្ថុនៃសន្តតិកម្ម ឬ ការចាត់ចែង ឬ ប្រាតិភោគបាន ។ រីឯកាតព្វកិច្ចដែលភ្ជាប់ជាមួយនឹងលក្ខខណ្ឌត្រូវបានបន្តដោយយោងទៅតាម បញ្ញត្តិនៃសន្តតិកម្ម និង បញ្ញត្តិផ្សេងទៀត ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

មាត្រា ៣២៧.- ការបំពានសិទ្ធិដែលភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌ

១-ក្នុងករណីដែលមិនទាន់ច្បាស់ថា ល័ក្ខខ័ណ្ឌត្រូវបានបំពេញ ឬ មិនទាន់បានបំពេញ ភាគីនីមួយៗនៃកាតព្វកិច្ចដែលភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌនោះ មិនអាចបំពានផលប្រយោជន៍របស់ភាគីម្ខាងទៀតដែលនឹងកើតឡើងដោយសារល័ក្ខខ័ណ្ឌនោះ ត្រូវបានបំពេញឡើយ ។

២-ក្នុងករណីដែលគតិយជនបានបំពានផលប្រយោជន៍ដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើអំពើនេះជាអំពើអនីត្យានុកូល គតិយជននោះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ។

មាត្រា ៣២៨.- ការចាត់ទុកថាល័ក្ខខ័ណ្ឌត្រូវបានបំពេញ

ប្រសិនបើភាគីដែលនឹងទទួលការខូចផលប្រយោជន៍ដោយសារល័ក្ខខ័ណ្ឌត្រូវបានបំពេញ ហើយភាគីនោះបានរារាំងមិនឱ្យល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញដោយចេតនា ភាគីម្ខាងទៀតអាចចាត់ទុកថាល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញរួចហើយ ។

កថាភាគទី ២
ការកំណត់ពេល

មាត្រា ៣២៩.- អត្ថន័យនៃការកំណត់ពេល

១-ក្នុងករណីដែលមានកំណត់ពេលចាប់ផ្តើម ចំពោះអានុភាពនៃកិច្ចសន្យា អានុភាពនោះមិនត្រូវកើតឡើងរហូតដល់ពេលកំណត់នោះមកដល់ ។ ក្នុងករណីដែលមានកំណត់ពេលចាប់ផ្តើម ចំពោះការអនុវត្តកិច្ចសន្យា ម្ចាស់បំណុលមិនអាចទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចមុនពេលកំណត់នោះបានឡើយ ។

២-ក្នុងករណីដែលមានកំណត់ពេលចប់ ចំពោះអានុភាពនៃកិច្ចសន្យា អានុភាពនោះត្រូវរលត់នៅពេលកំណត់នោះមកដល់ ។

៣-ចំពោះសកម្មភាពឯកតោភាគី ភាគីអាចកំណត់ពេលចាប់ផ្តើមក្នុងន័យនៃកថាខណ្ឌទី ១ ឬ ពេលចប់ក្នុងន័យនៃកថាខណ្ឌទី ២ ខាងលើនេះបាន លុះត្រាតែមិននាំឱ្យមានការខូចខាតដោយមិនត្រឹមត្រូវដល់ភាគីម្ខាងទៀត ។

មាត្រា ៣៣០.- ប្រយោជន៍នៃការកំណត់ពេល

១-ការកំណត់ពេល ត្រូវបានសន្មតថា បានជាប្រយោជន៍របស់កូនបំណុល ។

២-ប្រយោជន៍នៃការកំណត់ពេលនេះអាចបោះបង់ចោលបាន លុះត្រាតែមិននាំឱ្យមានការខូចខាតដោយមិនត្រឹមត្រូវដល់ភាគីម្ខាងទៀត ។ ប៉ុន្តែ ប្រសិនបើការបោះបង់ចោលនោះធ្វើឱ្យមានការខូចខាតផលប្រយោជន៍របស់ភាគីម្ខាងទៀត ភាគីដែលធ្វើឱ្យមានការខូចខាតនោះ ត្រូវសងការខូចខាតដល់ភាគីម្ខាងទៀត ។

មាត្រា ៣៣១.- ការបាត់បង់ផលប្រយោជន៍នៃការកំណត់ពេល

កូនបំណុលត្រូវបាត់បង់ផលប្រយោជន៍នៃការកំណត់ពេល ក្នុងករណីដូចតទៅ :

ក-កូនបំណុលត្រូវបានប្រកាសក្ស័យធន ។

ខ-កូនបំណុលបានធ្វើឱ្យខូចខាតប្រាតិភោគ ។

គ-កូនបំណុលមានករណីយកិច្ចត្រូវដាក់ប្រាតិភោគ ប៉ុន្តែ មិនបានបំពេញករណីយកិច្ចនេះ ។

ឃ-មានហេតុដែលគូភាគីបានព្រមព្រៀងគ្នាបានកើតឡើង ។

កថាភាគទី ៣

អំឡុងពេល

មាត្រា ៣៣២.- របៀបកំណត់អំឡុងពេល

អំឡុងពេលអាចកំណត់ជា ម៉ោង នាទី វិនាទី ថ្ងៃ សប្តាហ៍ ខែ ឬ ឆ្នាំបាន ។

មាត្រា ៣៣៣.- ការគណនាអំឡុងពេលជាម៉ោង នាទី ឬ វិនាទី

ប្រសិនបើបានកំណត់អំឡុងពេលជាម៉ោង នាទី ឬ វិនាទី ត្រូវធ្វើការគណនាពីពេលចាប់ផ្តើមរហូតដល់ពេលចប់នៃអំឡុងពេលនោះ ។

មាត្រា ៣៣៤.- ការគណនាអំឡុងពេលជាថ្ងៃ សប្តាហ៍ ខែ ឬ ឆ្នាំ

១-ប្រសិនបើបានកំណត់អំឡុងពេលជាថ្ងៃ សប្តាហ៍ ខែ ឬ ឆ្នាំវិញ មិនត្រូវគិតបញ្ចូលថ្ងៃ

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ដែលចាប់ផ្ដើមនៃអំឡុងពេលនេះទេ លើកលែងតែអំឡុងពេលនេះបានចាប់ផ្ដើមពីម៉ោងសូន្យទៅ ។

២-ក្នុងករណីដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ អំឡុងពេលត្រូវចប់ពេញលេញនៅពេលផុតថ្ងៃចុងក្រោយនៃអំឡុងពេលនោះ ។

៣-ប្រសិនបើថ្ងៃចុងក្រោយនៃអំឡុងពេលត្រូវជាថ្ងៃបុណ្យ ថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សម្រាកផ្សេងទៀតដែលច្បាប់ ឬ បទដ្ឋានគតិយុត្តបានកំណត់ អំឡុងពេលត្រូវចប់ពេញលេញនៅពេលផុតថ្ងៃធ្វើការបន្ទាប់ពីថ្ងៃឈប់នោះ ។

មាត្រា ៣៣៥.- ការគណនាអំឡុងពេលតាមប្រតិទិនសុរិយគតិ

១-ក្នុងករណីដែលធ្វើការគណនាអំឡុងពេលជាសប្ដាហ៍ ខែ ឬ ឆ្នាំ ត្រូវធ្វើការគណនាតាមប្រតិទិនសុរិយគតិ ។

២-ក្នុងករណីដែលមិនធ្វើការគណនាអំឡុងពេលដោយគិតពីដើមសប្ដាហ៍ ដើមខែ ឬ ដើមឆ្នាំទេ អំឡុងពេលនេះត្រូវចប់ពេញលេញនៅមួយថ្ងៃមុនថ្ងៃដែលត្រូវនឹងថ្ងៃចាប់ផ្ដើមរាប់នៃសប្ដាហ៍ចុងក្រោយ ខែចុងក្រោយ ឬ ឆ្នាំចុងក្រោយនៃអំឡុងពេល ។ ប៉ុន្តែក្នុងករណីដែលត្រូវគណនាអំឡុងពេលជាខែ ឬ ជាឆ្នាំវិញ ប្រសិនបើខែ ឬ ឆ្នាំចុងក្រោយនៃអំឡុងពេលនោះ គ្មានថ្ងៃដែលត្រូវនឹងថ្ងៃដែលអំឡុងពេលបានចាប់ផ្ដើមទេ ថ្ងៃចុងក្រោយនៃខែនោះ ត្រូវជាថ្ងៃដែលអំឡុងពេលត្រូវចប់ពេញលេញ ។

ជំពូកទី ២

ការបង្ហាញឆន្ទៈ និង កិច្ចសន្យា

ផ្នែកទី ១

ការបង្កើតកិច្ចសន្យា

មាត្រា ៣៣៦.- ការបង្កើតកិច្ចសន្យាដោយសំណើ និង ស្វីការ

១-កិច្ចសន្យាមានអានុភាពដោយសារសំណើ និង ស្វីការត្រូវគ្នា ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏កិច្ចសន្យាដែលភាគីម្ខាងទទួលការស្នើយកកិច្ចធ្វើអនុប្បទានទូវកម្មសិទ្ធិលើអចលនវត្ថុ ឬ ករណីយកិច្ចធ្វើលទ្ធកម្មទូវកម្មសិទ្ធិ

លើអចលនវត្ថុ នឹងមានអានុភាព លុះត្រាតែបានធ្វើលិខិតយថាភូត ។

មាត្រា ៣៣៧.- និយមន័យនៃសំណើ និង ស្ទីការ

១-សំណើគឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្តក្នុងករណីដែលមានស្ទីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ ។

២-សំណើត្រូវមានអានុភាពនៅពេលដែលសំណើនោះបានដល់ភាគីម្ខាងទៀត ។ ប៉ុន្តែ ប្រសិនបើដំណឹងអំពីការដកសំណើវិញ ដល់ភាគីម្ខាងទៀត នៅពេលព្រមគ្នានឹងពេលសំណើដល់ ឬ មុនពេលសំណើដល់ នោះអានុភាពសំណើមិនត្រូវកើតឡើយ ។

៣-ស្ទីការគឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ ។

៤-ស្ទីការត្រូវមានអានុភាពនៅពេលដែលស្ទីការនោះបានដល់អ្នកស្នើ ។ ប៉ុន្តែ ប្រសិនបើដំណឹងអំពីការដកស្ទីការវិញដល់អ្នកស្នើ នៅពេលព្រមគ្នានឹងពេលស្ទីការដល់ ឬ មុនពេលស្ទីការដល់ នោះអានុភាពនៃស្ទីការមិនត្រូវកើតឡើយ ។

មាត្រា ៣៣៨.- សំណើដែលមានកំណត់អំឡុងពេលសម្រាប់ស្ទីការ និង ការដកសំណើនោះ

១-សំណើអាចធ្វើឡើងបានដោយកំណត់អំឡុងពេលសម្រាប់ស្ទីការ ។ អំឡុងពេលសម្រាប់ស្ទីការត្រូវគិតចាប់ពីថ្ងៃដែលជូនដំណឹងអំពីសំណើ បើមិនច្បាស់ថា អ្នកស្នើកំណត់ពេលផ្សេង ។

២-សំណើដែលត្រូវបានធ្វើឡើងដោយមានកំណត់អំឡុងពេលសម្រាប់ស្ទីការ មិនអាចដកវិញបានទេ ។

៣-ប្រសិនបើអ្នកស្នើមិនបានទទួលដំណឹងអំពីស្ទីការ ក្នុងអំឡុងពេលដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះទេ សំណើនោះត្រូវបាត់បង់អានុភាពដោយស្វ័យប្រវត្តិនៅពេលផុតអំឡុងពេលសម្រាប់ស្ទីការ ។ ក្នុងករណីដែលដំណឹងអំពីការបដិសេធសំណើបានដល់អ្នកស្នើក្នុងអំឡុងពេលសម្រាប់ស្ទីការនោះ សំណើនោះក៏ត្រូវបាត់បង់អានុភាពដែរ ។

មាត្រា ៣៣៩.- សំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការ និង ការដកសំណើនោះ

១-ចំពោះសំណើដែលត្រូវបានធ្វើឡើងដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការរវាងភាគីដែលកំពុងនិយាយគ្នា នៅក្នុងស្ថានភាពដែលអាចឆ្លើយភ្លាមៗបាន ប្រសិនបើភាគីដែល

ទទួលសំណើមិនបានយល់ព្រមភ្លាមៗទេ សំណើនោះត្រូវបាត់បង់អានុភាព ។

២-ចំពោះសំណើដែលធ្វើរវាងគូភាគីដែលមិននិយាយគ្នា ដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការទេ អ្នកស្នើមិនអាចដកសំណើនោះវិញក្នុងអំឡុងពេលសមរម្យបានឡើយ ។

៣-ការដកសំណើត្រូវមានអានុភាព លុះត្រាតែការជូនដំណឹងអំពីការដកសំណើនោះបានមកដល់ភាគីម្ខាងទៀត មុនពេលភាគីម្ខាងទៀតជូនដំណឹងអំពីស្ទីការ ។

មាត្រា ៣៤០.- ពេលនៃការបង្កើតកិច្ចសន្យា : គោលការណ៍នៃការមកដល់នៃស្ទីការ

កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលដំណឹងអំពីស្ទីការ បានមកដល់អ្នកស្នើ ។

មាត្រា ៣៤១.- ការមកដល់យឺតយ៉ាវនៃស្ទីការ

១-ក្នុងករណីដែលការជូនដំណឹងអំពីស្ទីការ ចំពោះសំណើដែលមានអំឡុងពេលសម្រាប់ស្ទីការមកដល់ភាគីម្ខាងទៀត ក្រោយពេលអំឡុងពេលសម្រាប់ស្ទីការនោះកន្លងផុត ប្រសិនបើអ្នកស្នើស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងថា ភាគីម្ខាងទៀតជូនដំណឹងអំពីស្ទីការនោះនៅពេលដែលអាចមកដល់ក្នុងអំឡុងពេលសម្រាប់ស្ទីការក្នុងករណីធម្មតា នោះអ្នកស្នើត្រូវជូនដំណឹងអំពីការមកដល់ស្ទីការដោយមានការយឺតយ៉ាវនោះ ទៅអ្នកធ្វើស្ទីការដោយគ្មានការយឺតយ៉ាវ ។ ក្នុងករណីដែលអ្នកស្នើធ្វេសប្រហែសក្នុងការជូនដំណឹងអំពីការមកដល់ស្ទីការដោយមានការយឺតយ៉ាវនោះ ស្ទីការដែលមកដល់ដោយមានការយឺតយ៉ាវនោះ មានសុពលភាព ។

២-អ្នកស្នើ អាចចាត់ទុកថា ស្ទីការដែលបានមកដល់អ្នកស្នើក្រោយពេលផុតអំឡុងពេលសម្រាប់ស្ទីការជាសំណើថ្មី ។

មាត្រា ៣៤២.- ស្ទីការដោយមានបន្ថែមការកែប្រែ

១-ស្ទីការដែលអ្នកធ្វើស្ទីការ បានដាក់លក្ខខ័ណ្ឌលើសំណើ ឬ កែប្រែសារជាតុផ្សេងនៃសំណើមិនត្រូវក្លាយជាស្ទីការសុពល តែស្ទីការនោះមានអានុភាពជាសំណើថ្មី ។ កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលអ្នកធ្វើសំណើដើម ធ្វើស្ទីការចំពោះសំណើថ្មីនោះ ។

២-ប្រសិនបើលក្ខខ័ណ្ឌ ឬ ការកែប្រែដែលភ្ជាប់ជាមួយនឹងស្ទីការមិនធ្វើឱ្យមានការកែប្រែសារជាតុនៃសំណើទេ ស្ទីការនោះមានសុពលភាព លុះត្រាតែអ្នកស្នើមិនតវ៉ាភ្លាម ។ អត្ថន័យ

នៃកិច្ចសន្យាដែលត្រូវកើតឡើងដោយស្ទីការនោះ ត្រូវទៅតាមអត្ថន័យនៃស្ទីការ លុះត្រាតែអ្នកស្នើដែលបានទទួលស្ទីការមិនតវ៉ាភ្លាមៗទេ ។

មាត្រា ៣៤៣.- ការបង្កើតកិច្ចសន្យាដោយសកម្មភាពដែលត្រូវបានចាត់ទុកថាជាស្ទីការ

ក្នុងករណីដែលមិនចាំបាច់ឱ្យមានដំណឹងអំពីស្ទីការ ដោយសារឆន្ទៈរបស់អ្នកស្នើ ឬដោយសារទំនៀមទម្លាប់នៃកិច្ចការជំនួញ កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលមានសកម្មភាពអាចទទួលស្គាល់ថាជាស្ទីការ ។

មាត្រា ៣៤៤.- ការដកសំណើចំពោះបុគ្គលដែលមិនបានកំណត់ជាក់លាក់

សំណើចំពោះបុគ្គលដែលមិនបានកំណត់ជាក់លាក់តាមការផ្សាយជាសាធារណៈ ឬតាមវិធីផ្សេងទៀត អាចដកបានតែតាមវិធីដូចគ្នានឹងសំណើនោះ ។

ផ្នែកទី ២

វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា

មាត្រា ៣៤៥.- ការបង្ហាញឆន្ទៈដែលមានវិការៈ

អ្នកដែលបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ តាមបញ្ញត្តិនៃផ្នែកទី ២ (វិការៈក្នុងការបង្ហាញឆន្ទៈ និងសុពលភាពនៃកិច្ចសន្យា) នេះ និងផ្នែកទី ៣ (មោឃភាព និង ការលុបចោល) ក្នុងករណីដូចខាងក្រោមនេះ :

ក-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ ។

ខ-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការឆបោក ឬ ការគម្រាមកំហែង ឬ ការបង្ហាញការមិនពិតរបស់ភាគីម្ខាងទៀត ។

គ-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយអំពើឆ្លៀតឱកាសដោយមានគោលបំណងកេងយកចំណេញហួសហេតុ ។

មាត្រា ៣៤៦.- ការភាន់ច្រឡំ

១-ក្នុងករណីដែលភាគីមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា បើភាគីម្ខាង

ទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំនេះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យា មានការភាន់ច្រឡំអំពីចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬ ចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ និង ការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈនោះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ ។

៣-ក្នុងករណីដែលភាគីទាំងសងខាងមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ឬ ចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬ ចំណុចដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា ទោះបីជាភាគីម្ខាងមិនមានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ ក៏ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដែរដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

៤-ការលុបចោលនូវកិច្ចសន្យាដោយការភាន់ច្រឡំ ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការភាន់ច្រឡំ មិនអាចអះអាងនូវការលុបចោលចំពោះតតិយជននោះបានឡើយ ។

មាត្រា ៣៤៧.- ការឆបោក

១-បុគ្គលដែលបានធ្វើការបង្ហាញឆន្ទៈ ដោយសារការឆបោករបស់ភាគីម្ខាងទៀត អាចលុបចោលនូវកិច្ចសន្យាដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-ក្នុងករណីដែលការបង្ហាញឆន្ទៈបានធ្វើឡើងដោយសារការឆបោករបស់តតិយជន អ្នកបង្ហាញឆន្ទៈអាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ លុះត្រាតែក្នុងករណីដែលភាគីម្ខាងទៀតនៃការបង្ហាញឆន្ទៈនោះ បានដឹង ឬ អាចដឹងអំពីការឆបោកនោះ ។

៣-ការលុបចោលនូវកិច្ចសន្យាដោយការឆបោក ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិតហើយគ្មានកំហុសអំពីការឆបោក មិនអាចអះអាងនូវអានុភាពនៃការលុបចោលចំពោះតតិយជននោះបានឡើយ ។

មាត្រា ៣៤៨.- ព័ត៌មានមិនពិត

១-នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបានបង្ហាញដោយភាគីម្ខាងនោះខុសពីការពិត ហើយភាគីម្ខាងទៀតបានបង្ហាញឆន្ទៈដោយជឿជាក់ថា ហេតុទាំងនោះជាការពិត ប៉ុន្តែប្រសិនបើភាគីនោះដឹងថា ហេតុនោះមិនមែនជាការពិត ខ្លួននឹងមិនបង្ហាញឆន្ទៈទេ ភាគីនោះអាចលុបចោលនូវកិច្ចសន្យាបានដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងភាគីដែលបានបង្ហាញឆន្ទៈក្នុងការទាមទារសំណងនៃការខូចខាតពីបុគ្គលដែលបានបង្ហាញការណ៍មិនពិតនោះទេ ក្នុងករណីដែលបុគ្គលនេះមានកំហុស ។

៣-ការលុបចោលនូវកិច្ចសន្យាដោយព័ត៌មានមិនពិត ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីព័ត៌មានមិនពិត មិនអាចអះអាងនូវអានុភាពនៃការលុបចោល ចំពោះតតិយជននោះបានឡើយ ។

មាត្រា ៣៤៩.- ការរំលោភបំពានលើស្ថានភាព

១-នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើឋានៈខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះអាចលុបចោល នូវកិច្ចសន្យាបានដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-ការលុបចោលនូវកិច្ចសន្យាដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើ នេះ មិនអាចអះអាងចំពោះតតិយជនដែលជាជនសុចរិត ហើយគ្មានកំហុសអំពីការរំលោភបំពានលើស្ថានភាពបានឡើយ ។

មាត្រា ៣៥០.- ការគម្រាមកំហែង

បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារមានការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬ ពីសំណាក់តតិយជន អាចលុបចោលនូវកិច្ចសន្យាបានដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

មាត្រា ៣៥១.- អំពើកេងយកចំណេញហួសហេតុ

ក្នុងករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យា ដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀត កំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ការខ្វះការពិសោធន៍ ហើយបានកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

មាត្រា ៣៥២.- ចំបនីយផ្លូវចិត្ត

ប្រសិនបើកិច្ចសន្យាត្រូវបានបង្កើតឡើង ដោយការបង្ហាញឆន្ទៈដែលភាគីដឹងខ្លួនថាខុសឆន្ទៈពិតរបស់ខ្លួន កិច្ចសន្យានោះមិនត្រូវរារាំងនូវអានុភាពឡើយ ។ ប៉ុន្តែ ក្នុងករណីដែលភាគីម្ខាងទៀតក៏ដឹងថាការបង្ហាញឆន្ទៈនោះ ខុសនឹងឆន្ទៈពិតរបស់អ្នកបង្ហាញឆន្ទៈដែរ អ្នកបង្ហាញឆន្ទៈនោះអាចបដិសេធការអនុវត្តកិច្ចសន្យាបាន ។

មាត្រា ៣៥៣.- ការបង្ហាញឆន្ទៈមិនពិត

១-កិច្ចសន្យាដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិតដែលត្រូវបានធ្វើឡើង ដោយមានការឃុបឃិតជាមួយនឹងភាគីម្ខាងទៀត ត្រូវចាត់ទុកជាមោឃៈ ។

២-មោឃភាពនៃកិច្ចសន្យាដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ មិនអាចអះអាងចំពោះតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍ ដោយយកកិច្ចសន្យាដែលផ្អែកលើការបង្ហាញឆន្ទៈមិនពិតជាមូលដ្ឋានបានឡើយ ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតតិយជននោះជាជនទុច្ចរិត ឬ មិនបានដឹងអំពីការបង្ហាញនូវឆន្ទៈមិនពិត ដោយមានកំហុសធ្ងន់ធ្ងរ ។

មាត្រា ៣៥៤.- ភាពខុសច្បាប់ ឬ ភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ក្នុងអត្ថន័យនៃកិច្ចសន្យា

១-ទោះបីជាភាគីនៃកិច្ចសន្យាបានធ្វើការបង្ហាញឆន្ទៈដោយគ្មានវិការៈក៏ដោយ ក៏កិច្ចសន្យាត្រូវបានចាត់ទុកជាមោឃៈ ក្នុងករណីខាងក្រោមនេះ ៖

ក-អត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ ។

ខ-អត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ។

២-ប្រសិនបើអត្ថន័យនៃកិច្ចសន្យាមានផ្នែកណាមួយដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ហើយទោះបីជាទុកផ្នែកផ្សេងទៀត ក៏មិនធ្វើឱ្យខូចសេចក្តីសង្ឃឹមសមហេតុសមផលរបស់គូភាគីទេ នោះមានតែចំណុចដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អតែប៉ុណ្ណោះទេ ដែលត្រូវទុកជាមោឃៈ ។

មាត្រា ៣៥៥.- អលទ្ធភាពតាំងពីដំបូង

១-ទោះបីជាអត្ថន័យនៃកិច្ចសន្យាមិនអាចសម្រេចបានតាំងពីពេលដែលបង្កើតកិច្ចសន្យានោះក៏ដោយ ក៏កិច្ចសន្យានោះមិនត្រូវបានចាត់ទុកជាមោឃៈដោយយកមូលហេតុនៃអលទ្ធភាពនោះដែរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនរារាំងភាគីក្នុងការលុបចោលនូវកិច្ចសន្យា ដោយយកមូលហេតុនៃការភាន់ច្រឡំឡើយ ក្នុងករណីដែលលក្ខខណ្ឌនៃការភាន់ច្រឡំត្រូវបានបំពេញ ។

២-ក្នុងករណីដែលភាគីដែលគួរតែអាចដឹងថា អត្ថន័យនៃកិច្ចសន្យាមិនអាចសម្រេចតាំងពីដំបូងបាននាំឱ្យមានការខូចខាតដល់ភាគីម្ខាងទៀតដោយសារការបង្កើតកិច្ចសន្យា ភាគីនោះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដល់ភាគីម្ខាងទៀត ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៣៩៨ (លក្ខខណ្ឌនៃការទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាត) នៃក្រមនេះ ។

ផ្នែកទី ៣
មោឃភាព និង ការលុបចោល

មាត្រា ៣៥៦.- និយមន័យនៃសកម្មភាព

ពាក្យ "សកម្មភាព" ក្នុងផ្នែកទី ៣ (មោឃភាព និង ការលុបចោល) នេះ សំដៅទៅលើកិច្ចសន្យា ឬ សកម្មភាពឯកតោភាគី ។

មាត្រា ៣៥៧.- អត្ថន័យនៃមោឃភាព

ប្រសិនបើអត្ថន័យនៃសកម្មភាព ផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្តាប់

ផ្ទុយសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបាន ។ ក្នុងករណីដែលសកម្មភាពត្រូវចាត់ទុកជាមោឃៈ ដោយសារសកម្មភាពនោះផ្ទុយនឹងទម្រង់ដែលត្រូវបានទាមទារឱ្យមានដោយក្រមនេះ ឬ ច្បាប់ផ្សេង ជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបាន ។

មាត្រា ៣៥៨.- សកម្មភាពដែលអាចលុបចោលបាន

១-សកម្មភាពដែលអាចលុបចោលបាន មានសុពលភាពរហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល លុបចោលសកម្មភាពនោះ ។

២-ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានលុបចោលសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនេះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង ។

៣-ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានផ្តល់សច្ចានុមតិលើសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនេះត្រូវមានសុពលភាពជាស្ថាពរ ។

មាត្រា ៣៥៩.- អ្នកដែលមានសិទ្ធិលុបចោល

១-ចំពោះសកម្មភាពដែលអាចលុបចោលបាន ដោយមូលហេតុថា មានវិការៈក្នុងការបង្ហាញឆន្ទៈដែលបានកំណត់ ចាប់ពីមាត្រា ៣៤៦ (ការភាន់ច្រឡំ) ដល់មាត្រា ៣៥១ (អំពើកេងយកចំណេញហួសហេតុ) នៃក្រមនេះ អ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកនោះ អាចលុបចោលនូវសកម្មភាពនោះបាន ។ សន្តតិជនរបស់អ្នកដែលបង្ហាញឆន្ទៈ ឬ អ្នកដែលទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈ ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ ។

២-ចំពោះការលុបចោល ដោយមូលហេតុគ្មានសមត្ថភាពក្នុងការបង្ហាញឆន្ទៈ អនីតិភាព ឬ ការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពផ្សេងទៀត សាមីខ្លួន អ្នកតំណាង ដែលច្បាប់បានកំណត់ ឬ ហិតូបត្ថម្ភកៈនៃជននោះ អាចលុបចោលនូវសកម្មភាពបាន ។ សន្តតិជន ឬ អច្ច័យលាភីសកលរបស់សាមីខ្លួន ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ ។

ROYAUME du CAMBODGE
LE MINISTRE du PALAIS ROYAL

3/65

មាត្រា ៣៦០.- វិធីនៃការលុបចោល ឬ សច្ចានុមតិ

ក្នុងករណីដែលភាគីម្ខាងទៀតនៃសកម្មភាពដែលអាចលុបចោលបាន ត្រូវបានកំណត់ច្បាស់លាស់ ការលុបចោល ឬ សច្ចានុមតិត្រូវធ្វើឡើងដោយការជូនដំណឹងទៅភាគីម្ខាងទៀតនោះ ។ អានុភាពនៃការលុបចោល ឬ សច្ចានុមតិ ត្រូវកើតឡើងនៅពេលដែលដំណឹងនោះបានដល់ភាគីម្ខាងទៀតនោះ ។

មាត្រា ៣៦១.- អ្នកមានសិទ្ធិផ្តល់សច្ចានុមតិ និង លក្ខខណ្ឌនៃការផ្តល់សច្ចានុមតិ

១-អ្នកមានសិទ្ធិលុបចោល អាចផ្តល់សច្ចានុមតិចំពោះសកម្មភាពដែលអាចលុបចោលបាន ។ ប៉ុន្តែ ក្នុងករណីដែលលុបចោលសកម្មភាព ដោយយកការបង្ហាញឆន្ទៈដោយមានវិការៈជាមូលហេតុ អ្នកមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិបាន ចាប់តាំងពីពេលដែលអ្នកមានសិទ្ធិលុបចោលនោះបានដឹងអំពីមូលហេតុនៃការលុបចោល ។ រីឯសកម្មភាពរបស់ជនដែលត្រូវបានកម្រិតសមត្ថភាពវិញ អ្នកមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិបាននៅក្រោយពេលដែលស្ថានភាពដែលជាមូលហេតុនៃការលុបចោលត្រូវរលត់ ។

២-បញ្ញត្តិនៃវាក្យខណ្ឌទី ៣ កថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់ ឬ ហិតូបត្ថម្ភកៈរបស់ជនដែលត្រូវបានកម្រិតសមត្ថភាពផ្តល់សច្ចានុមតិ ។

មាត្រា ៣៦២.- សច្ចានុមតិដែលច្បាប់បានកំណត់

នៅក្រោយពេលដែលអាចផ្តល់សច្ចានុមតិតាមបញ្ញត្តិនៃមាត្រា ៣៦១ (អ្នកមានសិទ្ធិផ្តល់សច្ចានុមតិ និង លក្ខខណ្ឌនៃការផ្តល់សច្ចានុមតិ) ខាងលើ សកម្មភាពដែលអាចលុបចោលបានត្រូវចាត់ទុកថា បានផ្តល់សច្ចានុមតិរួចហើយ ក្នុងករណីមានហេតុដូចខាងក្រោមនេះ :

ក-ការអនុវត្តកាតព្វកិច្ចទាំងមូល ឬ មួយផ្នែក ចំពោះកាតព្វកិច្ចដែលកើតឡើងដោយសកម្មភាពដែលអាចលុបចោលបាន ឬ ការដាក់ប្រាតិភោគដើម្បីធានាកាតព្វកិច្ចនោះ ។

ខ-ការអនុវត្តសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន ឬ ការទាមទារឱ្យភាគីម្ខាងទៀតអនុវត្ត ។

គ-អនុប្បទាន ឬ ការចាត់ចែងផ្សេងទៀតនូវសិទ្ធិទាំងមូល ឬ មួយផ្នែក ចំពោះសិទ្ធិ

ដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន ។

ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ បើមានថបនីយថា ខ្លួនមិនបានផ្តល់សច្ចានុមតិ នៅពេលដែលហេតុដែលបានកំណត់នៅក្នុងករណីទាំងបីខាងលើនោះកើតឡើង ។

មាត្រា ៣៦៣.- អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល

១-ប្រសិនបើអ្នកមានសិទ្ធិលុបចោលមិនអនុវត្តសិទ្ធិនោះក្នុងរយៈពេល ៣ (បី) ឆ្នាំ ចាប់តាំងពីពេលដែលខ្លួនក្លាយទៅជាអ្នកដែលអាចផ្តល់សច្ចានុមតិ នោះសិទ្ធិលុបចោល និង សិទ្ធិទាមទារឱ្យសងសេចក្តីចម្រើនដោយឥតហេតុដែលកើតឡើង ដោយសារការលុបចោលនោះត្រូវរលត់ ។ បញ្ញត្តិស្តីពីការផ្អាកអាជ្ញាយុកាលមិនត្រូវយកមកអនុវត្តឡើយ ចំពោះអំឡុងពេលនេះ ។

២-ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ប្រសិនបើហួសអំឡុងពេល ១០ (ដប់) ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទនៃសកម្មភាព នោះសិទ្ធិលុបចោលក៏ត្រូវរលត់ដែរ ។

៣-ក្នុងករណីដែលបុគ្គលច្រើននាក់មានសិទ្ធិលុបចោលនូវសកម្មភាពតែមួយបញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះត្រូវយកមកអនុវត្ត ចំពោះសិទ្ធិលុបចោលនៃបុគ្គលនីមួយៗនោះ ។

ផ្នែកទី ៤
ការតំណាង

មាត្រា ៣៦៤.- និយមន័យនៃការតំណាង

ការតំណាងសំដៅទៅលើទំនាក់ទំនងគតិយុត្តដែលអានុភាពនៃកិច្ចសន្យាត្រូវមានចំពោះម្ចាស់សិទ្ធិផ្ទាល់ ក្នុងករណីដែលអ្នកតំណាងធ្វើកិច្ចសន្យាជាមួយភាគីម្ខាងទៀតដោយបង្ហាញថា ការធ្វើកិច្ចសន្យានោះគឺធ្វើសម្រាប់ម្ចាស់សិទ្ធិក្នុងទំហំនៃសិទ្ធិតំណាង ។

មាត្រា ៣៦៥.- កំណើតនៃសិទ្ធិតំណាង

សិទ្ធិតំណាងកើតមានឡើងដោយកិច្ចសន្យារវាងម្ចាស់សិទ្ធិ និង អ្នកតំណាង ឬ ដោយបញ្ញត្តិនៃច្បាប់ ។

មាត្រា ៣៦៦.- ទំហំនៃសិទ្ធិតំណាង

១-ទំហំនៃសិទ្ធិតំណាងត្រូវកំណត់ដោយកិច្ចសន្យាដែលប្រគល់សិទ្ធិតំណាងទៅឱ្យអ្នកតំណាង ។ ក្នុងករណីដែលសិទ្ធិតំណាងត្រូវកើតឡើងដោយបញ្ញត្តិនៃច្បាប់ ទំហំនៃសិទ្ធិតំណាងក៏ត្រូវកំណត់ដោយច្បាប់នោះដែរ ។

២-ក្នុងករណីដែលទំហំនៃសិទ្ធិតំណាងមិនបានកំណត់ទេ អ្នកតំណាងត្រូវមានសិទ្ធិចំពោះអំពើថែរក្សា និង អំពើកែលំអ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះអំពើកែលំអ ដែលផ្លាស់ប្តូរលក្ខណៈនៃវត្ថុ ឬ សិទ្ធិដែលជាកម្មវត្ថុនៃការតំណាង ។

មាត្រា ៣៦៧.- ការកម្រិតសិទ្ធិតំណាង

១-ទោះបីក្នុងទំហំនៃសិទ្ធិតំណាងក៏ដោយ ចំពោះអំពើដែលផលប្រយោជន៍របស់អ្នកតំណាង និង របស់ម្ចាស់សិទ្ធិមានភាពផ្ទុយគ្នា អ្នកតំណាងគ្មានសិទ្ធិទេ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានការយល់ព្រមពីម្ចាស់សិទ្ធិ ។

២-ចំពោះកិច្ចការជំនួញរវាងម្ចាស់សិទ្ធិ និង អ្នកតំណាង ត្រូវសន្មតថាផលប្រយោជន៍ម្ចាស់សិទ្ធិ និង ផលប្រយោជន៍អ្នកតំណាងមានភាពផ្ទុយគ្នា ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកតំណាង ធ្វើជាតំណាងឱ្យម្ចាស់សិទ្ធិផង ធ្វើជាតំណាងឱ្យតតិយជនផង ហើយផលប្រយោជន៍ម្ចាស់សិទ្ធិ និង ផលប្រយោជន៍តតិយជន មានភាពផ្ទុយគ្នា ។

មាត្រា ៣៦៨.- មូលហេតុនៃការរលត់សិទ្ធិតំណាង

១-សិទ្ធិតំណាងដែលបានទទួលពីម្ចាស់សិទ្ធិដោយកិច្ចសន្យា ត្រូវរលត់ដោយសារមូលហេតុខាងក្រោមនេះ :

ក-មរណភាព ធនក្ស័យ ឬ ការរំលាយរបស់ម្ចាស់សិទ្ធិ ។

ខ-មរណភាព ធនក្ស័យ ឬ ការកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាពរបស់អ្នកតំណាង ។

គ-ការបញ្ចប់អាណត្តិ កិច្ចសន្យាការងារ ឬ ទំនាក់ទំនងគតិយុត្តផ្សេងទៀតដែលបានប្រគល់សិទ្ធិតំណាង ។

ROYAUME du CAMBODGE

២-ការតំណាងដែលច្បាប់បានកំណត់ ត្រូវរលត់ដោយសារមូលហេតុដែលបានកំណត់ក្នុងច្បាប់ ។

មាត្រា ៣៦៩.- ការតំណាងដោយគ្មានសិទ្ធិ

១-អំពើដែលអ្នកគ្មានសិទ្ធិតំណាងធ្វើក្នុងនាមជាអ្នកតំណាងរបស់អ្នកដទៃ មិនត្រូវបង្កើតអានុភាពចំពោះម្ចាស់សិទ្ធិទេ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលម្ចាស់សិទ្ធិបានផ្តល់សច្ចានុមតិចំពោះអំពើនោះ ។

២-ភាគីម្ខាងទៀតនៃសកម្មភាពនៃការតំណាងដោយគ្មានសិទ្ធិ មិនអាចអះអាងថាអានុភាពនៃសកម្មភាពត្រូវមានចំពោះអ្នកតំណាងដោយគ្មានសិទ្ធិឡើយ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវរារាំងភាគីម្ខាងទៀត ក្នុងការទាមទារឱ្យអ្នកតំណាងដោយគ្មានសិទ្ធិទទួលខុសត្រូវដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៣៧១ (ការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិ) នៃក្រមនេះ ។

មាត្រា ៣៧០.- សច្ចានុមតិចំពោះអំពើតំណាងដោយគ្មានសិទ្ធិ និង សិទ្ធិលុបចោលរបស់ភាគីម្ខាងទៀត

១-ប្រសិនបើមិនបានផ្តល់សច្ចានុមតិចំពោះភាគីម្ខាងទៀតទេ ម្ចាស់សិទ្ធិមិនអាចអះអាងអានុភាពនៃសច្ចានុមតិនោះ ចំពោះភាគីម្ខាងទៀតបានឡើយ ។

២-អំពើតំណាងដោយគ្មានសិទ្ធិ ត្រូវមានសុពលភាពប្រតិសកម្ម ដោយសច្ចានុមតិតាំងពីពេលដែលអំពើនោះ ត្រូវបានធ្វើឡើង ។ ប៉ុន្តែ សច្ចានុមតិនោះមិនអាចធ្វើឱ្យខូចផលប្រយោជន៍តតិយជន ដែលបានកើតឡើងក្នុងអំឡុងពេល ចាប់តាំងពីពេលដែលអំពើតំណាងដោយគ្មានសិទ្ធិនោះត្រូវបានធ្វើឡើង រហូតដល់ពេលផ្តល់សច្ចានុមតិ ។

៣-ភាគីម្ខាងទៀតនៃអំពើតំណាងដោយគ្មានសិទ្ធិ អាចដាស់តឿនឱ្យម្ចាស់សិទ្ធិឆ្លើយអំពីការផ្តល់ ឬ មិនផ្តល់សច្ចានុមតិ ដោយកំណត់អំឡុងពេលមួយសមរម្យដើម្បីឆ្លើយ ។ ប្រសិនបើម្ចាស់សិទ្ធិមិនឆ្លើយក្នុងអំឡុងពេលដែលបានកំណត់នោះទេ ត្រូវចាត់ទុកថាម្ចាស់សិទ្ធិបដិសេធការផ្តល់សច្ចានុមតិ ។

៤-ភាគីម្ខាងទៀតអាចលុបចោលកិច្ចសន្យាដែលត្រូវបានធ្វើដោយអ្នកគ្មានសិទ្ធិតំណាងមុនពេលម្ចាស់សិទ្ធិផ្តល់សច្ចានុមតិបាន ។ នៅក្រោយពេលភាគីម្ខាងទៀតបានលុបចោលកិច្ច

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

១/៥៩៥

សន្យា ម្ចាស់សិទ្ធិមិនអាចផ្តល់សច្ចានុមតិចំពោះអំពើតំណាងដោយគ្មានសិទ្ធិបានឡើយ ។

មាត្រា ៣៧១.- ការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិ

ប្រសិនបើជនដែលធ្វើកិច្ចសន្យាក្នុងនាមជាអ្នកតំណាងសម្រាប់ជនដទៃ មិនអាចបញ្ជាក់នូវសិទ្ធិតំណាង ឬ មិនអាចទទួលសច្ចានុមតិពីសាមីខ្លួនបានទេ ជននោះត្រូវទទួលខុសត្រូវក្នុងការអនុវត្ត ឬ ទទួលខុសត្រូវក្នុងការសងការខូចខាត តាមការជ្រើសរើស របស់ភាគីម្ខាងទៀត ។ ប៉ុន្តែ ប្រសិនបើភាគីម្ខាងទៀតបានដឹងអំពីនត្ថិភាពនៃសិទ្ធិតំណាង អ្នកតំណាងដោយគ្មានសិទ្ធិអាចរួចផុតពីការទទួលខុសត្រូវនោះបាន ។ អ្នកតំណាងដោយគ្មានសិទ្ធិដែលគ្មានកំហុសក្នុងការធ្វើអំពើតំណាងដោយគ្មានសិទ្ធិ ក៏អាចរួចផុតពីការទទួលខុសត្រូវដែលបានកំណត់ក្នុងមាត្រានេះបានដែរ ទោះបីជាភាគីម្ខាងទៀតមិនបានដឹងអំពីនត្ថិភាពនៃសិទ្ធិតំណាង ដោយកំហុសក៏ដោយ ។

មាត្រា ៣៧២.- ការតំណាងដែលមានលក្ខណៈជារូបភាព

១-ក្នុងករណីដែលអ្នកតំណាងធ្វើកិច្ចសន្យា ដោយហួសពីទំហំនៃសិទ្ធិតំណាង ប្រសិនបើភាគីម្ខាងទៀតជឿជាក់ថា អ្នកតំណាងមានសិទ្ធិតំណាងចំពោះកិច្ចសន្យានោះ ហើយគ្មានកំហុសក្នុងការជឿនោះទេ ម្ចាស់សិទ្ធិត្រូវទទួលខុសត្រូវក្នុងការអនុវត្តកិច្ចសន្យានោះ ចំពោះភាគីម្ខាងទៀត ។

២-ក្រោយពីពេលដែលសិទ្ធិតំណាងបានរលត់ ប្រសិនបើភាគីម្ខាងទៀតបានធ្វើកិច្ចសន្យាជាមួយនឹងអ្នកដែលបង្ហាញខ្លួនថា ជាអ្នកតំណាងម្ចាស់សិទ្ធិត្រូវទទួលខុសត្រូវក្នុងការអនុវត្តកិច្ចសន្យានោះចំពោះភាគីម្ខាងទៀត ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីម្ខាងទៀតដឹងអំពីការរលត់នៃសិទ្ធិតំណាងនោះ ឬ មិនដឹងអំពីការរលត់នោះដោយមានកំហុស ។

៣-ក្នុងករណីដែលម្ចាស់សិទ្ធិមិនបានប្រគល់សិទ្ធិតំណាងទៅអ្នកផ្សេង ប៉ុន្តែម្ចាស់សិទ្ធិបានបង្ហាញដូចជាខ្លួនបានប្រគល់សិទ្ធិតំណាងនោះទៅឱ្យអ្នកផ្សេង ឬ អនុញ្ញាតឱ្យអ្នកផ្សេងនោះបង្ហាញថាអ្នកនោះមានសិទ្ធិតំណាង ម្ចាស់សិទ្ធិត្រូវទទួលខុសត្រូវក្នុងការអនុវត្តកិច្ចសន្យាចំពោះភាគីម្ខាងទៀត ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីម្ខាងទៀតដឹងអំពីនត្ថិភាពនៃសិទ្ធិតំណាងនោះ ឬ មិនដឹងអំពីនត្ថិភាពនោះ ដោយមានកំហុស ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

មាត្រា ៣៧៣.- អំពើតំណាងដែលមិនបង្ហាញច្បាស់លាស់

១-ក្នុងករណីដែលអ្នកតំណាងមានឆន្ទៈក្នុងការធ្វើកិច្ចការសម្រាប់ម្ចាស់សិទ្ធិ តែបានធ្វើកិច្ចការនោះ ដោយមិនបង្ហាញថាធ្វើសម្រាប់ម្ចាស់សិទ្ធិទេ ភាគីម្ខាងទៀតអាចអះអាងថាកិច្ចសន្យាត្រូវបានបង្កើតឡើងជាមួយនឹងអ្នកតំណាងនោះបាន ។ ប៉ុន្តែ ប្រសិនបើភាគីម្ខាងទៀតបានដឹងនៅពេលបង្កើតកិច្ចសន្យាថា អ្នកតំណាងធ្វើកិច្ចសន្យានោះសម្រាប់ម្ចាស់សិទ្ធិ ភាគីម្ខាងទៀតនោះអាចអះអាងអំពីការបង្កើតកិច្ចសន្យាតែជាមួយម្ចាស់សិទ្ធិប៉ុណ្ណោះ ។

២-ប្រសិនបើភាគីម្ខាងទៀតបែរជាដឹងអំពីអត្ថិភាពនៃម្ចាស់សិទ្ធិ ក្រោយពេលបង្កើតកិច្ចសន្យាជាមួយនឹងអ្នកតំណាងដែលបានធ្វើកិច្ចការ ដោយមិនបង្ហាញថាធ្វើសម្រាប់ម្ចាស់សិទ្ធិទេ ភាគីម្ខាងទៀតនោះអាចអះអាងការបង្កើតកិច្ចសន្យាជាមួយម្ចាស់សិទ្ធិបាន ។

មាត្រា ៣៧៤.- ទិដ្ឋភាពនៃអំពើតំណាង

១-ក្នុងករណីដែលអានុភាពនៃកិច្ចសន្យាដែលអ្នកបង្ហាញឆន្ទៈបង្កើត ត្រូវទទួលនូវឥទ្ធិពល ដោយសារមានការភាន់ច្រឡំ ការឆបោក ការគម្រាមកំហែង ឬ ដោយសារមានកំហុសក្នុងការដឹង ឬ មិនដឹងហេតុណាមួយ អត្ថិភាព ឬ នត្ថិភាពនៃហេតុនោះ ត្រូវវិនិច្ឆ័យចំពោះអ្នកតំណាង ។

២-ក្នុងការអនុវត្តបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ បើម្ចាស់សិទ្ធិបានប្រគល់ឱ្យអ្នកតំណាងធ្វើកិច្ចសន្យាដែលត្រូវបានកំណត់ពិសេស ម្ចាស់សិទ្ធិមិនអាចអះអាងថា អ្នកតំណាងមិនបានដឹងនូវហេតុណាដែលម្ចាស់សិទ្ធិដឹងនោះបានឡើយ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាដែរ ចំពោះហេតុដែលម្ចាស់សិទ្ធិមិនបានដឹងដោយមានកំហុស ។

មាត្រា ៣៧៥.- សមត្ថភាពនៃអ្នកតំណាង

ម្ចាស់សិទ្ធិក៏អាចប្រគល់សិទ្ធិតំណាងដល់ជនដែលត្រូវបានកម្រិតសមត្ថភាពបានដែរ ។ ក្នុងករណីនេះ ម្ចាស់សិទ្ធិមិនអាចលុបចោលនូវកិច្ចសន្យាដែលត្រូវបានធ្វើឡើង ដោយអ្នកតំណាងដែលជាជនដែលត្រូវបានកម្រិតសមត្ថភាពជាមួយនឹងភាគីម្ខាងទៀត ដោយយកមូលហេតុនៃការកម្រិតសមត្ថភាពរបស់អ្នកតំណាងនោះបានឡើយ ។

មាត្រា ៣៧៦.- អនុតំណាង

អ្នកតំណាងដោយកិច្ចសន្យាជាមួយនឹងម្ចាស់សិទ្ធិ មិនអាចជ្រើសតាំងអនុតំណាងបាន

ឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបានទទួលការយល់ព្រមពីម្ចាស់សិទ្ធិ ឬ មានហេតុដែលជៀសវាងមិនបាន ។

មាត្រា ៣៧៧.- ការទទួលខុសត្រូវរបស់អ្នកតំណាង ក្នុងករណីដែលបានជ្រើសតាំងអនុតំណាង

១-នៅពេលដែលអ្នកតំណាង បានជ្រើសតាំងអនុតំណាង តាមបញ្ញត្តិនៃវាក្យខណ្ឌទី ២ មាត្រា ៣៧៦ (អនុតំណាង) ខាងលើ អ្នកតំណាងត្រូវទទួលខុសត្រូវក្នុងការជ្រើសតាំង និង ត្រួតពិនិត្យអនុតំណាងនោះចំពោះម្ចាស់សិទ្ធិ ។

២-ក្នុងករណីដែលអ្នកតំណាងបានជ្រើសតាំងអនុតំណាង តាមការកំណត់របស់ម្ចាស់សិទ្ធិ អ្នកតំណាងមិនត្រូវទទួលខុសត្រូវនូវអំពើរបស់អនុតំណាងនោះ លើកលែងតែក្នុងករណីដែលអ្នកតំណាងបានដឹងអំពីភាពមិនសមស្រប ឬ ភាពមិនស្មោះត្រង់របស់អនុតំណាង តែមិនបានជូនដំណឹងអំពីភាពនោះទៅម្ចាស់សិទ្ធិ ឬ មិនបានដកអនុតំណាងចេញ ។

៣-ប្រសិនបើអ្នកតំណាងបានជ្រើសតាំងអនុតំណាង ដោយមិនធ្វើតាមបញ្ញត្តិនៃវាក្យខណ្ឌទី ២ មាត្រា ៣៧៦ (អនុតំណាង) ខាងលើទេ អំពើរបស់អនុតំណាងគ្មានអានុភាពទៅលើម្ចាស់សិទ្ធិឡើយ ។ ប៉ុន្តែ ភាគីម្ខាងទៀតដែលមិនបានដឹងថា អនុតំណាងនោះគ្មានសិទ្ធិទេ អាចអះអាងនូវការទទួលខុសត្រូវក្នុងការអនុវត្ត ឬ ក្នុងការសងការខូចខាត ចំពោះអ្នកតំណាងបាន បើខ្លួនគ្មានកំហុសក្នុងការមិនបានដឹងនោះ ។

មាត្រា ៣៧៨.- ឋានៈនៃអនុតំណាង

១-អំពើដែលអនុតំណាងបានធ្វើក្នុងទំហំនៃសិទ្ធិរបស់ខ្លួន ដោយបញ្ជាក់ថាធ្វើសម្រាប់ម្ចាស់សិទ្ធិ ត្រូវជាចំណងចងម្ចាស់សិទ្ធិ ។

២-អនុតំណាងត្រូវមានសិទ្ធិ និង ករណីយកិច្ចចំពោះម្ចាស់សិទ្ធិដូចអ្នកតំណាង ។

៣-បញ្ញត្តិនៃផ្នែកទី ៤ នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះទំនាក់ទំនងរវាងម្ចាស់សិទ្ធិ និង អនុតំណាង ដោយចាត់ទុកថាអនុតំណាងជាអ្នកតំណាង ។

ផ្នែកទី ៥
កិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន

មាត្រា ៣៧៩.- និយមន័យ

១-ភាគីនៃកិច្ចសន្យា អាចឱ្យតតិយជនទទួលសិទ្ធិដែលកើតឡើងដោយកិច្ចសន្យានោះបាន ។ ក្នុងករណីនេះ អ្នកដែលត្រូវផ្តល់តាវកាលិកទៅតតិយជននោះ ហៅថា “អ្នកព្រមផ្តល់” ។ រីឯភាគីម្ខាងទៀតរបស់អ្នកព្រមផ្តល់នោះ ហៅថា “អ្នកទាមទារការផ្តល់” ។ ម្យ៉ាងទៀត តតិយជនដែលនឹងទទួលតាវកាលិក ហៅថា “អ្នកទទួលផលប្រយោជន៍” ។

២-អ្នកទទួលផលប្រយោជន៍ អាចទាមទារអ្នកព្រមផ្តល់ឱ្យផ្តល់តាវកាលិកដោយចំពោះបាន ។

មាត្រា ៣៨០.- អ្នកទទួលផលប្រយោជន៍

នៅពេលធ្វើការសន្យា មិនចាំបាច់មានអត្ថិភាពអ្នកទទួលផលប្រយោជន៍ឡើយ ប្រសិនបើលក្ខខណ្ឌដើម្បីកំណត់អ្នកទទួលផលប្រយោជន៍នោះ មានភាពច្បាស់លាស់ ។ ប៉ុន្តែ ក្នុងករណីដែលគ្មានអ្នកទទួលផលប្រយោជន៍ នៅពេលដែលអ្នកព្រមផ្តល់ត្រូវផ្តល់តាវកាលិក នោះការសន្យាដែលត្រូវផ្តល់តាវកាលិកឱ្យតតិយជន ត្រូវបាត់បង់អានុភាព ហើយអ្នកព្រមផ្តល់អាចរួចផុតពីការទទួលខុសត្រូវបាន ដោយអនុវត្តចំពោះអ្នកទាមទារការផ្តល់ ។

មាត្រា ៣៨១.- ការបង្ហាញឆន្ទៈក្នុងការទទួលផលប្រយោជន៍

១-ក្នុងអំឡុងពេលដែលអ្នកទទួលផលប្រយោជន៍មិនទាន់បង្ហាញឆន្ទៈទទួលផលប្រយោជន៍ចំពោះអ្នកព្រមផ្តល់ ឬ អ្នកទាមទារការផ្តល់ អ្នកទាមទារការផ្តល់អាចដកការសន្យាផ្តល់សិទ្ធិឱ្យទៅអ្នកទទួលផលប្រយោជន៍នោះ នៅពេលណាក៏បានដែរ ដោយជូនដំណឹងទៅអ្នកព្រមផ្តល់ និង អ្នកទទួលផលប្រយោជន៍នោះ ។

២-ក្រោយពីអ្នកទទួលផលប្រយោជន៍បានបង្ហាញឆន្ទៈទទួលផលប្រយោជន៍ ភាគីនៃកិច្ចសន្យាមិនអាចប្តូរ ឬ រំលត់នូវសិទ្ធិរបស់អ្នកទទួលផលប្រយោជន៍នេះបានឡើយ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

(តទៅរាជកិច្ច លេខ ០៣)

មាត្រា ៣៨២.- ការតវ៉ារបស់អ្នកព្រមផ្តល់

អ្នកព្រមផ្តល់អាចអះអាងការតវ៉ាដែលកើតមកពីកិច្ចសន្យា ចំពោះអ្នកទទួលផល-ប្រយោជន៍បាន ។

មាត្រា ៣៨៣.- មោឃភាព ការលុបចោល និង ការរំលាយកិច្ចសន្យា

១-ក្នុងករណីដែលកិច្ចសន្យាមានមូលហេតុនៃមោឃភាព ឬ ការលុបចោល រវាងអ្នក ទាមទារការផ្តល់ និង អ្នកព្រមផ្តល់ ភាគីនៃកិច្ចសន្យាអាចអះអាងនូវមោឃភាពនៃកិច្ចសន្យា ឬ ការលុបចោលកិច្ចសន្យានោះបានតាមបញ្ញត្តិស្តីពីមោឃភាព និង ការលុបចោលក្នុងផ្នែកទី ៣ (មោឃភាព និង ការលុបចោល) នៃជំពូកទី ២ ទោះបីជាមានការសន្យាផ្តល់សិទ្ធិដល់តតិយ-ជនក៏ដោយ ។

២-អ្នកព្រមផ្តល់អាចរំលាយកិច្ចសន្យា ដោយយកមូលហេតុនៃការបំពានកិច្ចសន្យារបស់អ្នកទាមទារការផ្តល់បាន ។ ក្នុងករណីដែលយកការបំពានកិច្ចសន្យារបស់អ្នកព្រមផ្តល់មកជាមូលហេតុនៃការរំលាយ បើមានអ្នកទទួលប្រយោជន៍ដែលបានបង្ហាញឆន្ទៈទទួលផលប្រយោជន៍ អ្នកទាមទារការផ្តល់អាចរំលាយកិច្ចសន្យា ដោយទទួលការយល់ព្រមពីតតិយជននោះ ។

ជំពូកទី ៣
ការអនុវត្តកិច្ចសន្យា

មាត្រា ៣៨៤.- ករណីយកិច្ចរបស់កូនបំណុលក្នុងការអនុវត្តកាតព្វកិច្ច

១-កូនបំណុលត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន ឱ្យស្របទៅតាមខ្លឹមសារនៃកិច្ចសន្យា និង គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ ។

២-ការអនុវត្តតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចាត់ទុកជាការសងដែលនាំឱ្យកាតព្វកិច្ចរលត់ ។

មាត្រា ៣៨៥.- សិទ្ធិរបស់ម្ចាស់បំណុលក្នុងការទាមទារឱ្យអនុវត្តកាតព្វកិច្ច

១-ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចតាមផ្លូវតុលាការ ។

២-ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ម្ចាស់បំណុលមិនអាចទាមទារឱ្យអនុវត្តកាតព្វកិច្ចតាមផ្លូវតុលាការបានឡើយ ក្នុងករណីដែលមានការព្រមព្រៀងគ្នារវាងភាគីនៃកិច្ចសន្យាថា មិនទាមទារឱ្យអនុវត្តតាមផ្លូវតុលាការ ។

៣-ទោះបីជាមានការកម្រិតនូវសិទ្ធិទាមទារឱ្យអនុវត្តកាតព្វកិច្ចតាមផ្លូវតុលាការដោយសារមានករណីត្រូវនឹងកថាខណ្ឌទី ២ ខាងលើនេះក៏ដោយ ប្រសិនបើកូនបំណុលបានអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្តហើយ ម្ចាស់បំណុលអាចទទួល និងរក្សាទុកនូវតាវកាលិកនេះ ដោយចាត់ទុកថាជាការសងបាន ។

មាត្រា ៣៨៦.- ការតវ៉ាឱ្យអនុវត្តព្រមគ្នា

ភាគីនីមួយៗនៃកិច្ចសន្យាអញ្ញមញ្ញអាចប្រកែកមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនរហូតដល់ពេលដែលភាគីម្ខាងទៀតផ្ដល់នូវការអនុវត្តកាតព្វកិច្ច ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកាតព្វកិច្ចរបស់ភាគីម្ខាងទៀត មិនទាន់ដល់ពេលកំណត់ដើម្បីអនុវត្ត ។

មាត្រា ៣៨៧.- ការតវ៉ាដោយមានការបារម្ភ

ភាគីដែលត្រូវអនុវត្តកាតព្វកិច្ចជាមុន នៅក្នុងកិច្ចសន្យាអញ្ញមញ្ញ អាចប្រកែកមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនបាន ក្នុងករណីដែលមានការបារម្ភដែលគួរឱ្យកត់សម្គាល់ថា ភាគីម្ខាងទៀតនឹងមិនអនុវត្តតាមខ្លឹមសារនៃកាតព្វកិច្ច ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីម្ខាងទៀតដាក់ប្រាតិភោគ ឬ ចាត់ចែងវិធានការផ្សេងទៀត ដើម្បីរំលត់ការបារម្ភនោះ ។

មាត្រា ៣៨៨.- ការអនុវត្តតាមបញ្ញត្តិស្ដីពីការសង

ក្រៅពីបញ្ញត្តិនៃជំពូកទី ៣ (ការអនុវត្តកិច្ចសន្យា) នេះ បញ្ញត្តិស្ដីពីការសងដែលបានកំណត់នៅក្នុងផ្នែកទី ១ (ការសង) នៃជំពូកទី ៧ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះការអនុវត្តកិច្ចសន្យា ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

5/456

ជំពូកទី ៤
ការសង្គ្រោះចំពោះការបំពានលើកិច្ចសន្យា

ផ្នែកទី ១
បទប្បញ្ញត្តិទូទៅស្តីពីការមិនអនុវត្តកាតព្វកិច្ច

មាត្រា ៣៨៩.- និយមន័យ និង ទម្រង់នៃការមិនអនុវត្តកាតព្វកិច្ច

ការមិនអនុវត្តកាតព្វកិច្ច សំដៅទៅលើករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ច ដែលកើតឡើងពីកិច្ចសន្យា ។ ទម្រង់នៃការមិនអនុវត្តកាតព្វកិច្ច មានដូចខាងក្រោមនេះ :

ក-កូនបំណុលមិនអាចអនុវត្តកាតព្វកិច្ចឱ្យទាន់ពេលកំណត់ត្រូវអនុវត្ត ដោយសារការយឺតយ៉ាវក្នុងការអនុវត្ត ។

ខ-អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច ។

គ-កូនបំណុលមិនបានអនុវត្តឱ្យបានពេញលេញ តាមខ្លឹមសារនៃកាតព្វកិច្ច ។

ឃ-ករណីផ្សេងទៀតដែលគ្មានការអនុវត្តតាមខ្លឹមសារនៃកាតព្វកិច្ច ។

មាត្រា ៣៩០.- វិធីសង្គ្រោះចំពោះការមិនអនុវត្តកាតព្វកិច្ច

ក្នុងករណីដែលមានការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុល ម្ចាស់បំណុលអាចទាមទារឱ្យអនុវត្តដោយបង្ខំសងសំណងនៃការខូចខាត ឬរំលាយកិច្ចសន្យាដោយយោងតាមបញ្ញត្តិចាប់ពីផ្នែកទី ២ ដល់ផ្នែកទី ៤ នៃជំពូកទី ៤ នេះបាន ។

មាត្រា ៣៩១.- ការយឺតយ៉ាវក្នុងការអនុវត្ត

កូនបំណុលត្រូវបានចាត់ទុកថា មានការយឺតយ៉ាវក្នុងការអនុវត្ត ក្នុងករណីដែលខ្លួនមិនបានអនុវត្តកាតព្វកិច្ច នៅពេលដែលបានកំណត់ដូចខាងក្រោមនេះ :

ក-ប្រសិនបើមានកំណត់ពេលពិតប្រាកដសម្រាប់អនុវត្តកាតព្វកិច្ច នៅពេលដល់កាលកំណត់នោះ ។

ខ-ប្រសិនបើមានកំណត់ពេលមិនពិតប្រាកដសម្រាប់អនុវត្តកាតព្វកិច្ច នៅពេលដែលកូនបំណុលនោះដឹងថា ដល់ពេលកំណត់ហើយ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

46/456

គ-ប្រសិនបើមិនបានកំណត់ពេលសម្រាប់អនុវត្តកាតព្វកិច្ចទេ នៅពេលដែលកូនបំណុលនោះទទួលការទាមទារឱ្យអនុវត្ត ។

មាត្រា ៣៩២.- អលទ្ធភាពក្នុងការអនុវត្ត

១-ប្រសិនបើគ្មានលទ្ធភាពក្នុងការអនុវត្តទេ ការអនុវត្តកាតព្វកិច្ចត្រូវក្លាយជាអលទ្ធភាព ។ អលទ្ធភាពនេះ ត្រូវរាប់បញ្ចូលទាំងករណីដែលការអនុវត្តកាតព្វកិច្ចនោះ ត្រូវបានវាយតម្លៃថា មិនអាចធ្វើកើតតាមស្ថានភាពសង្គម ឬ សេដ្ឋកិច្ច ។

២-ប្រសិនបើការណ៍ដែលមិនអាចអនុវត្តកាតព្វកិច្ចនៅពេលកំណត់ដែលត្រូវអនុវត្តមានពិតប្រាកដមុនពេលកំណត់ដែលត្រូវអនុវត្ត ការអនុវត្តកាតព្វកិច្ចត្រូវក្លាយជាអលទ្ធភាពនៅពេលនោះ ។

មាត្រា ៣៩៣.- ការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ

ការមិនអនុវត្តកាតព្វកិច្ច សំដៅទៅលើករណីដែលកូនបំណុលបានអនុវត្តកាតព្វកិច្ច តែការផ្តល់ការកាលិកមិនពេញលេញ ឬ ករណីដែលបានអនុវត្តតែមួយផ្នែកនៃកាតព្វកិច្ច ឬ ករណីផ្សេងទៀតដែលគ្មានការអនុវត្តឱ្យបានពេញលេញតាមខ្លឹមសារនៃកាតព្វកិច្ច ។

មាត្រា ៣៩៤.- ករណីផ្សេងនៃការមិនអនុវត្តកាតព្វកិច្ច

ក្រៅពីបញ្ញត្តិនៃមាត្រា ៣៩១ (ការយឺតយ៉ាវក្នុងការអនុវត្ត) មាត្រា៣៩២ (អលទ្ធភាពក្នុងការអនុវត្ត) និងមាត្រា ៣៩៣ (ការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ) នៃក្រមនេះ ករណីដែលមានការបំពានករណីយកិច្ចផ្សេងដែលកើតឡើងពីកិច្ចសន្យា ក៏ត្រូវចាត់ជាការមិនអនុវត្តកាតព្វកិច្ចដែរ ។

មាត្រា ៣៩៥.- ពហុមធ្យោបាយសង្គ្រោះ

ក្នុងករណីដែលមធ្យោបាយសង្គ្រោះមានច្រើនយ៉ាងអនុញ្ញាតចំពោះម្ចាស់បំណុល នោះម្ចាស់បំណុលអាចជ្រើសរើសមធ្យោបាយណាមួយ ឬ ច្រើន កុំឱ្យតែមធ្យោបាយទាំងនោះមានភាពផ្ទុយគ្នាទៅវិញទៅមក ។

ផ្នែកទី ២

ការឱ្យអនុវត្តកាតព្វកិច្ចដោយបង្ខំ

មាត្រា ៣៩៦.- ដីកាបង្គាប់ឱ្យអនុវត្តកាតព្វកិច្ចដោយតុលាការ

ក្នុងករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្តទេ ម្ចាស់បំណុលអាចទាមទារឱ្យអនុវត្តកាតព្វកិច្ចដោយបង្ខំបាន លើកលែងតែករណីដែលកាតព្វកិច្ចមានលក្ខណៈមិនអាចអនុវត្តដោយបង្ខំបាន ។ នីតិវិធីនៃការអនុវត្តដោយបង្ខំ ត្រូវអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណី ។

មាត្រា ៣៩៧.- ទំនាក់ទំនងរវាងការទាមទារឱ្យអនុវត្តកាតព្វកិច្ច និង មធ្យោបាយផ្សេងៗ

ក្នុងករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ច ម្ចាស់បំណុលអាចទាមទារឱ្យសងការខូចខាត ជំនួសការទាមទារឱ្យអនុវត្តកាតព្វកិច្ច ឬ ជាមួយការទាមទារឱ្យអនុវត្តកាតព្វកិច្ចក្នុងទំហំដែលមិនមានភាពផ្ទុយគ្នា ។

ផ្នែកទី ៣

សំណងនៃការខូចខាត

មាត្រា ៣៩៨.- លក្ខខណ្ឌនៃការទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាត

១-ក្នុងករណីដែលកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចទេ ម្ចាស់បំណុលអាចទាមទារសំណងនៃការខូចខាតដែលកើតឡើង ដោយសារការមិនអនុវត្តកាតព្វកិច្ចនោះបាន ។ ប៉ុន្តែ ក្នុងករណីដែលកូនបំណុលមានសំអាងបញ្ជាក់ថា ខ្លួនគ្មានកំហុស ចំពោះការមិនអនុវត្តកាតព្វកិច្ចនោះទេ កូនបំណុលនោះត្រូវរួចផុតពីការទទួលខុសត្រូវក្នុងការសងសំណងខូចខាត ។

២-ក្នុងករណីដែលកូនបំណុលឱ្យអ្នកដទៃទៀតធ្វើជាអ្នកជំនួយដើម្បីឱ្យជួយអនុវត្តកាតព្វកិច្ច កូនបំណុលនោះមិនអាចរួចផុតពីការទទួលខុសត្រូវក្នុងការសងសំណងខូចខាតបានទេ លើកលែងតែកូនបំណុលនោះមានសំអាងបញ្ជាក់ថា ខ្លួនគ្មានកំហុសក្នុងការជ្រើសតាំង និងការត្រួតពិនិត្យអ្នកជំនួយទេ ហើយអ្នកជំនួយនោះក៏គ្មានកំហុសដែរ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

មាត្រា ៣៩៩.- បញ្ញត្តិពិសេសអំពីកាតព្វកិច្ចជាប្រាក់

១-ចំពោះកាតព្វកិច្ចដែលមានគោលបំណងសងជាប្រាក់ ទោះបីជាកូនបំណុលមានសំអាងបញ្ជាក់ថា ការយឺតយ៉ាវក្នុងការសងបានកើតឡើងដោយប្រធានសក្តិក៏ដោយ ក៏កូនបំណុលនោះមិនអាចរួចផុតពីការសងការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវនោះបានដែរ ។ ការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវនោះ ត្រូវគណនាតាមអត្រាការប្រាក់ដែលច្បាប់បានកំណត់ ។ បើអត្រាការប្រាក់ក្នុងកិច្ចសន្យា ខ្ពស់ជាងអត្រាការប្រាក់ដែលច្បាប់បានកំណត់នោះត្រូវគណនាតាមអត្រាការប្រាក់ក្នុងកិច្ចសន្យា ។

២-ចំពោះការខូចខាតដែលមានចំនួនលើសពីការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវ ប្រសិនបើកូនបំណុលមានសំអាងបញ្ជាក់ថា ខ្លួនគ្មានកំហុសចំពោះការមិនអនុវត្តកាតព្វកិច្ចនោះទេ នោះកូនបំណុលត្រូវរួចផុតពីការទទួលខុសត្រូវក្នុងការសងការខូចខាតនោះ ។

មាត្រា ៤០០.- ឧបសគ្គអំពីការខូចខាត

១-ម្ចាស់បំណុលអាចទាមទារនូវសំណងនៃការខូចខាតគឺអាចទាមទារនូវសំណងនៃផលប្រយោជន៍ពីការអនុវត្តដែលខ្លួនត្រូវទទួលបានដោយកិច្ចសន្យានោះ ហើយក្រៅពីនេះអាចទាមទារផងដែរនូវចំណាយដែលគ្មានប្រយោជន៍ដោយសារការមិនអនុវត្ត និង ចំណាយ ឬ បន្ទុកដែលបង្កើនឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ក្នុងទំហំដែលមិនជាន់គ្នាជាមួយនឹងសំណងនៃផលប្រយោជន៍ពីការអនុវត្ត ។

២-តុលាការក៏អាចបង្គាប់ឱ្យកូនបំណុលសងសំណងនៃការខូចខាតខាងផ្លូវចិត្ត ដោយផ្អែកលើការទាមទាររបស់ម្ចាស់បំណុលបានដែរ ។ ចំពោះចំនួនសំណងនៃការខូចខាតខាងផ្លូវចិត្ត តុលាការត្រូវសម្រេចដោយគិតពិចារណាអំពីកាលៈទេសៈជុំវិញផ្សេងៗ ។

មាត្រា ៤០១.- ទំហំនៃសំណងការខូចខាត

កូនបំណុលត្រូវសងការខូចខាត ដូចខាងក្រោមនេះ :

ក-ការខូចខាតដែលកើតមានឡើងជាធម្មតាចំពោះម្ចាស់បំណុល ដោយសារការមិនអនុវត្តកាតព្វកិច្ច ។

ខ-ការខូចខាតដែលកើតឡើងចំពោះម្ចាស់បំណុលដោយសារកាលៈទេសៈពិសេស

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

បើគូភាគីនៃកិច្ចសន្យាអាចព្យាករ បាននូវការខូចខាតនោះដែលនឹងអាចកើតឡើងនៅពេលធ្វើកិច្ចសន្យានោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលគូភាគីនៃកិច្ចសន្យា មិនបានគិតពិចារណាអំពីការខូចខាតពិសេសនោះ នៅពេលធ្វើកិច្ចសន្យា ។

គ-ក្នុងករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចដោយមានឆន្ទៈព្យាបាទ ឬ ដោយអំពើមិនស្មោះត្រង់ហួសហេតុ តុលាការអាចបង្គាប់ឱ្យកូនបំណុលសងផលប្រយោជន៍ ដែលកូនបំណុលបានទទួលពីអំពើដែលជាការមិនអនុវត្តកាតព្វកិច្ច ដោយផ្អែកលើការទាមទាររបស់ម្ចាស់បំណុលបាន ទោះបីមានបញ្ញត្តិក្នុងចំណុច ក និង ចំណុច ខ ខាងលើនេះក៏ដោយ ។

មាត្រា ៤០២.- ហេតុដែលនាំឱ្យបន្ថយសំណងនៃការខូចខាត

១-កាលបើការមិនបានអនុវត្តកាតព្វកិច្ច ឬ ការខូចខាតកើតឡើងផ្នែកខ្លះត្រូវបានបង្កឡើងដោយកំហុសរបស់ម្ចាស់បំណុល តុលាការអាចបន្ថយនូវចំនួននៃសំណងការខូចខាតដែលកូនបំណុលត្រូវសងបានតាមកម្រិតនៃការបង្កនោះ ។

២-ក្នុងករណីដែលការខូចខាតបានកើនឡើង ដោយសារម្ចាស់បំណុលធ្វេសប្រហែសក្នុងការសម្រាលការខូចខាតនោះ តុលាការអាចបន្ថយចំនួននៃសំណងការខូចខាតដែលកូនបំណុលត្រូវសងបាន តាមចំនួននៃការខូចខាតដែលម្ចាស់បំណុលអាចសម្រាលបាននោះ ។

មាត្រា ៤០៣.- ការកំណត់ជាមុននូវចំនួននៃសំណង ជាអាទិ៍

១-ម្ចាស់បំណុល និង កូនបំណុល អាចកំណត់ជាមុននូវការសន្យាពិសេសអំពីល័ក្ខខ័ណ្ឌ និង ចំនួនសំណងការខូចខាតបាន ។

២-ការសន្យាពិសេសដែលឱ្យកូនបំណុលរួចផុតជាមុនពីការទទួលខុសត្រូវក្នុងការមិនអនុវត្តកាតព្វកិច្ចដោយចេតនា ឬ ដោយកំហុសធ្ងន់ធ្ងររបស់ខ្លួន មិនមានអានុភាពឡើយ ។

៣-ក្នុងករណីដែលភាគីទាំងសងខាងបានធ្វើការសន្យាពិសេសអំពីចំនួននៃសំណងការខូចខាត តុលាការមិនអាចបន្ថែម ឬ បន្ថយចំនួននោះបានទេ ។ ប៉ុន្តែ ក្នុងករណីដែលចំនួនទឹកប្រាក់ដែលភាគីទាំងសងខាងបានកំណត់ជាមុននោះ ច្រើនហួសហេតុពេក ឬ តិចហួសហេតុពេក បើប្រៀបធៀបទៅនឹងការខូចខាតដែលត្រូវបានកំណត់តាមបញ្ញត្តិនៃមាត្រា ៤០១ (ទំហំនៃសំណងការខូចខាត) ខាងលើនេះ ទើបតុលាការអាចបន្ថែម ឬ បន្ថយនូវប្រាក់សំណងដែលបាន

ROYAUME DU CAMBODGE
LE MINISTERE DU PALAIS ROYAL

កំណត់ជាមុនបាន ។

៤-ការកំណត់ជាមុននូវចំនួននៃសំណង មិនរារាំងការទាមទារឱ្យអនុវត្តកាតព្វកិច្ច ឬ ឱ្យរំលាយកិច្ចសន្យាទេ ។ ក្នុងករណីដែលម្ចាស់បំណុលរំលាយកិច្ចសន្យា ហើយទាមទារសំណងនៃការខូចខាតដែលជាការជំនួសកម្មវត្ថុនៃកិច្ចសន្យា ចំនួនទឹកប្រាក់នៃសំណងដែលភាគីទាំងសងខាងបានព្រមព្រៀងគ្នាដោយគិតជាមុន អំពីការខូចខាតដែលកើតឡើងដោយការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចនោះ មិនត្រូវចងគូភាគីទេ ។

៥-ប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា ត្រូវសន្មតថាជាការកំណត់ជាមុននូវចំនួននៃសំណង ។

មាត្រា ៤០៤.- គោលការណ៍នៃការសងការខូចខាតជាប្រាក់

ចំពោះសំណងនៃការខូចខាតដែលកើតឡើងដោយការមិនអនុវត្តកាតព្វកិច្ច កូនបំណុលត្រូវសងជាប្រាក់ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីទាំងសងខាងបានកំណត់ផ្សេងពីនេះដោយការសន្យាពិសេស ។

មាត្រា ៤០៥.- ឧបាទេសកម្មនៃអ្នកសង

ប្រសិនបើម្ចាស់បំណុលបានទទួលនូវសំណងនៃការខូចខាតដោយការសងតម្លៃនៃវត្ថុ ឬ សិទ្ធិដែលជាអត្ថន័យនៃសិទ្ធិលើបំណុល កូនបំណុលត្រូវទទួលឋានៈដែលម្ចាស់បំណុលធ្លាប់មានចំពោះវត្ថុ ឬ សិទ្ធិនោះដោយស្វ័យប្រវត្តិ ។

មាត្រា ៤០៦.- អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារសំណង

អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យសងការខូចខាតដោយសារការមិនអនុវត្តកាតព្វកិច្ច មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ ក្រោយពីពេលដែលការខូចខាតនោះកើតឡើង ។

ផ្នែកទី ៤

ការរំលាយកិច្ចសន្យា

មាត្រា ៤០៧.- ការរំលាយដោយមូលហេតុមិនអនុវត្តកាតព្វកិច្ច

ភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញអាចរំលាយកិច្ចសន្យាបានភ្លាមៗ ក្នុងករណីដែលភាគី

ROYAUME DE CAMBODGE * LE MINISTRE du PALAIS ROYAL

ម្ខាងទៀតបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ។

មាត្រា ៤០៨.- ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ

១-ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរសំដៅទៅលើករណីដែលភាគីម្ខាងមិនអាចសម្រេចនូវគោលបំណងនៃកិច្ចសន្យាបាន ដោយសារការបំពានរបស់ភាគីម្ខាងទៀត ។ ត្រូវចាត់ទុកថាមានការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ក្នុងករណីដូចខាងក្រោមនេះ :

ក- ភាគីម្ខាងបានដាស់តឿនភាគីម្ខាងទៀតដែលមិនបានអនុវត្តកាតព្វកិច្ច តាមពេលកំណត់ដោយកំណត់អំឡុងពេលសមរម្យដើម្បីឱ្យអនុវត្តកាតព្វកិច្ច ហើយកាតព្វកិច្ចមិនត្រូវបានអនុវត្តក្នុងអំឡុងពេលនោះ ។

ខ-ភាគីមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ក្នុងកិច្ចសន្យាក្នុងករណីដែលគោលបំណងនៃកិច្ចសន្យាមិនបានសម្រេចសោះ បើភាគីមិនអនុវត្តកាតព្វកិច្ចតាមពេលកំណត់នោះ ។

គ-ភាគីមិនអាចអនុវត្តករណីយកិច្ចផ្តល់តាវកាលិកចម្បងរបស់ខ្លួនបានទេ ។

ឃ-ការបំពានកិច្ចសន្យាមានភាពហួសហេតុ ដែលធ្វើឱ្យបាត់បង់នូវទំនុកចិត្តរវាងគូភាគី ហើយមិនអាចជឿជាក់ថានឹងអនុវត្តកាតព្វកិច្ចនាអនាគតបាន ។

២-ភាគីដែលបំពានកិច្ចសន្យា មិនអាចរារាំងការរំលាយកិច្ចសន្យាដោយផ្អែកលើបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ដោយយកមូលហេតុថាខ្លួនគ្មានកំហុសចំពោះការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនបានឡើយ ។

មាត្រា ៤០៩.- វិធីអនុវត្តសិទ្ធិរំលាយកិច្ចសន្យា

១-ភាគីម្ខាងដែលមានសិទ្ធិរំលាយ អាចរំលាយកិច្ចសន្យា ដោយបង្ហាញឆន្ទៈរំលាយចំពោះភាគីម្ខាងទៀតបាន ។ ការបង្ហាញឆន្ទៈរំលាយនេះអាចធ្វើឡើងក្រៅតុលាការបាន ។

២-ការបង្ហាញឆន្ទៈរំលាយនេះ មិនអាចដកវិញបានទេ ។

៣-ការបង្ហាញឆន្ទៈរំលាយនេះ អាចដាក់ល័ក្ខខ័ណ្ឌបង្អង់បាន ។

មាត្រា ៤១០.- ការរំលាយកិច្ចសន្យាដែលភាគីម្ខាងមានច្រើននាក់

១-ក្នុងករណីដែលភាគីម្ខាងមានច្រើននាក់ ការរំលាយកិច្ចសន្យាត្រូវធ្វើឡើងដោយ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

បុគ្គលទាំងអស់នោះចំពោះភាគីម្ខាងទៀត ឬ ដោយភាគីម្ខាងទៀតចំពោះបុគ្គលទាំងអស់នោះ ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើសិទ្ធិរំលាយកិច្ចសន្យាបានរលត់ចំពោះបុគ្គលណាម្នាក់ ក្នុងចំណោមបុគ្គលនៃភាគីដែលមានច្រើននាក់សិទ្ធិរំលាយនោះក៏ត្រូវរលត់ចំពោះបុគ្គលផ្សេងទៀតនៃភាគីនោះដែរ ។

មាត្រា ៤១១.- អានុភាពនៃការរំលាយកិច្ចសន្យា

១-ការរំលាយកិច្ចសន្យានាំឱ្យគូភាគីរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យា លើកលែងតែករណីយកិច្ចសងការខូចខាត ។

២-ភាគីដែលបានទទួលតាវកាលិកនៃកិច្ចសន្យាតែមួយភាគ ឬ ទាំងអស់ ត្រូវមានករណីយកិច្ចសងតាវកាលិកនោះទៅភាគីម្ខាងទៀត ដើម្បីឱ្យភាគីនោះទទួលបដិទានឡើងវិញដោយសារការរំលាយ ។ ក្នុងករណីដែលភាគីទាំងសងខាង មានករណីយកិច្ចធ្វើបដិទានទៅវិញទៅមក ករណីយកិច្ចទាំងនោះត្រូវអនុវត្តនៅពេលជាមួយគ្នា ។

៣-ភាគីដែលមានករណីយកិច្ចសងជាប្រាក់ដោយការរំលាយកិច្ចសន្យាត្រូវសងជាមួយនឹងការប្រាក់ដោយគិតចាប់ពីថ្ងៃដែលបានទទួលប្រាក់ដើមនោះ ។ ភាគីដែលមានករណីយកិច្ចបង្វិលជាវត្ថុ ឬ ជាតាវកាលិកផ្សេងដែលខ្លួនបានទទួលទៅភាគីម្ខាងទៀត ដោយសារការរំលាយត្រូវសងទាំងផលដែលបានទទួលពីវត្ថុ ឬ តាវកាលិកនោះផងដែរ ។

៤-ការរំលាយកិច្ចសន្យាមិនអាចធ្វើឱ្យខូចផលប្រយោជន៍ត្រឹមត្រូវរបស់តតិយជនបានឡើយ ។

មាត្រា ៤១២.- សិទ្ធិរំលាយក្នុងករណីដែលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត ឬ បាត់បង់

១-សិទ្ធិរំលាយត្រូវរលត់ ក្នុងករណីភាគីដែលមានសិទ្ធិរំលាយបានធ្វើឱ្យ មានការខូចខាត ឬ ការបាត់បង់ដល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ឬ មិនអាចសងវត្ថុនោះវិញបាន ដោយឃោតនា ឬ ធ្វើឱ្យវត្ថុនោះក្លាយជាវត្ថុប្រភេទផ្សេង ដោយការកែច្នៃ ឬ ការផ្លាស់ទម្រង់ដោយចេតនា ។

២-ក្នុងករណីដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ បើភាគីបានអនុវត្តសិទ្ធិរំលាយ ភាគីនោះត្រូវសងជាប្រាក់នូវតម្លៃនៃវត្ថុដែលជាកម្មវត្ថុនោះ ត្រឹមកម្រិតតម្លៃដែលបានកំណត់ក្នុងកិច្ចសន្យា ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

៣-ក្នុងករណីដែលភាគីម្ខាងទៀតមានកំហុស ឬ មានមូលហេតុក្នុងការខូចខាត ឬ ការមិនបានសងវត្ថុដែលជាកម្មវត្ថុនោះ ភាគីដែលមានសិទ្ធិរំលាយ គ្មានករណីយកិច្ចក្នុងការសងជាប្រាក់នូវតម្លៃនៃវត្ថុនោះ ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះឡើយ ។

មាត្រា ៤១៣.- អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យា

អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យាដោយមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច និង សិទ្ធិទាមទារបដិទាន មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ ក្រោយពីពេលដែលមិនបានអនុវត្តកាតព្វកិច្ច ។

មាត្រា ៤១៤.- សិទ្ធិរំលាយដែលបានកំណត់ក្នុងកិច្ចសន្យា និង ការរំលាយដោយការព្រមព្រៀងគ្នា

១-គូភាគីនៃកិច្ចសន្យាអាចសន្យាឱ្យភាគីម្ខាង ឬ សងខាងមានសិទ្ធិរំលាយ នៅក្នុងកិច្ចសន្យានោះបាន ។ បញ្ញត្តិពីមាត្រា ៤០៩ (វិធីអនុវត្តសិទ្ធិរំលាយកិច្ចសន្យា) ដល់មាត្រា ៤១២ (សិទ្ធិរំលាយក្នុងករណីដែលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត ឬ បាត់បង់) នៃក្រមនេះស្តីពីការរំលាយដែលច្បាប់បានកំណត់ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះវិធីអនុវត្ត និង អានុភាពនៃសិទ្ធិរំលាយដែលបានកំណត់ដោយកិច្ចសន្យា លើកលែងតែមានការព្រមព្រៀងគ្នាផ្សេង ។

២-ទោះបីជាគ្មានការកំណត់សិទ្ធិរំលាយក្នុងកិច្ចសន្យាក៏ដោយ ក៏គូភាគីអាចរំលាយកិច្ចសន្យាដោយការព្រមព្រៀងគ្នាបានដែរ ។ ប៉ុន្តែ ការរំលាយនោះមិនអាចធ្វើឱ្យខូចផលប្រយោជន៍របស់តតិយជនបានទេ ។

ជំពូកទី ៥

ការទទួលបន្ទុកហានិភ័យ

មាត្រា ៤១៥.- ការរលត់កាតព្វកិច្ចដោយអលទ្ធភាព

បើការអនុវត្តកាតព្វកិច្ចក្លាយជាអលទ្ធភាព ហើយកូនបំណុលគ្មានកំហុសចំពោះអលទ្ធភាពនោះ កាតព្វកិច្ចត្រូវរលត់ ហើយម្ចាស់បំណុលមិនអាចទាមទារតាវកាលិកបានទេ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

មាត្រា ៤១៦.- ការទទួលបន្ទុកហានិភ័យក្នុងកិច្ចសន្យាផ្ទេរកម្មសិទ្ធិលើវត្ថុដែលបានកំណត់ជាក់លាក់

១-ក្នុងកិច្ចសន្យាអញ្ញមញ្ញដែលមានអត្ថន័យផ្ទេរកម្មសិទ្ធិលើវត្ថុដែលបានកំណត់ជាក់លាក់ ក្នុងករណីដែលវត្ថុជាកម្មវត្ថុនៃកិច្ចសន្យា ត្រូវបានបាត់បង់ ឬ ខូចខាត ដោយគ្មានកំហុសរបស់ភាគីទាំងសងខាងទេ កូនបំណុលត្រូវទទួលបន្ទុកហានិភ័យនោះ ហើយមិនអាចទាមទារការកាលិកតបពីម្ចាស់បំណុលបានទេ ។

២-លើកលែងតែមានការកំណត់ផ្សេងទៅក្នុងកិច្ចសន្យា ហានិភ័យដោយសារការបាត់បង់ ឬ ខូចខាតវត្ថុជាកម្មវត្ថុនៃកិច្ចសន្យា ត្រូវផ្ទេរទៅម្ចាស់បំណុលនៅពេលណាមួយក្នុងចំណោមពេលដែលបានកំណត់ដូចខាងក្រោមនេះ :

ក-ពេលដែលប្រគល់វត្ថុជាកម្មវត្ថុទៅម្ចាស់បំណុល ឬ ពេលដែលចុះបញ្ជីផ្ទេរអចលនវត្ថុ ឬ ពេលផ្សេងទៀតដែលយល់ឃើញថា ការគ្រប់គ្រងជាក់ស្តែងលើវត្ថុជាកម្មវត្ថុត្រូវបានផ្ទេរទៅម្ចាស់បំណុល ។

ខ-ពេលដែលកូនបំណុលបានស្នើផ្តល់ការអនុវត្តកាតព្វកិច្ចត្រឹមត្រូវ ។

គ-ពេលដែលម្ចាស់បំណុលប្រកែកមិនព្រមទទួលការអនុវត្តរបស់កូនបំណុលដោយគ្មានមូលហេតុត្រឹមត្រូវ ។

មាត្រា ៤១៧.- ការទទួលបន្ទុកហានិភ័យចំពោះសិទ្ធិផ្សេងទៀត

បញ្ញត្តិនៃមាត្រា ៤១៦ (ការទទួលបន្ទុកហានិភ័យក្នុងកិច្ចសន្យាផ្ទេរកម្មសិទ្ធិលើវត្ថុដែលបានកំណត់ជាក់លាក់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការបង្កើត ឬ ការផ្ទេរសិទ្ធិប្រត្យក្សក្រៅពីកម្មសិទ្ធិ ឬ សិទ្ធិលើបំណុល ឬ សិទ្ធិផ្សេងទៀត ។

មាត្រា ៤១៨.- ករណីដែលកម្មវត្ថុជាវត្ថុដែលមិនបានកំណត់ជាក់លាក់

១-ចំពោះកិច្ចសន្យាអញ្ញមញ្ញដែលមានគោលបំណងផ្ទេរកម្មសិទ្ធិលើវត្ថុដែលមិនបានកំណត់ជាក់លាក់ ក្នុងករណីវត្ថុដែលត្រូវផ្តល់មិនទាន់បានកំណត់ ទោះបីជាវត្ថុដែលខ្លួនបានរៀបចំ ដើម្បីផ្តល់ បាត់បង់ដោយគ្មានកំហុសរបស់ខ្លួនក៏ដោយ ក៏កាតព្វកិច្ចនោះ មិនត្រូវរលត់ដែរ ហើយកូនបំណុលនោះនៅតែមានករណីយកិច្ចអនុវត្ត ។

ROYAUME DU CAMBODGE
រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

២-ក្រោយពេលបានកំណត់កម្មវត្ថុដែលត្រូវផ្តល់ហើយ បញ្ញត្តិនៃមាត្រា ៤១៦ (ការទទួលបន្ទុកហានិភ័យក្នុងកិច្ចសន្យាផ្ទេរកម្មសិទ្ធិលើវត្ថុដែលបានកំណត់ជាក់លាក់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

មាត្រា ៤១៩.- ករណីដែលកិច្ចសន្យាមានល័ក្ខខ័ណ្ឌបង្អង់

ចំពោះកិច្ចសន្យាអញ្ញមញ្ញដែលមានល័ក្ខខ័ណ្ឌបង្អង់ ក្នុងករណីដែលកម្មវត្ថុត្រូវបានបាត់បង់ ឬ ខូចខាត មុនពេលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ ដោយគ្មានកំហុសរបស់កូនបំណុលទេ នោះកូនបំណុលត្រូវទទួលបន្ទុកហានិភ័យ ។ ក្រោយពីល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញហើយបញ្ញត្តិនៃមាត្រា ៤១៦ (ការទទួលបន្ទុកហានិភ័យក្នុងកិច្ចសន្យាផ្ទេរកម្មសិទ្ធិលើវត្ថុដែលបានកំណត់ជាក់លាក់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

មាត្រា ៤២០.- ការទទួលបន្ទុកហានិភ័យចំពោះកិច្ចសន្យាអញ្ញមញ្ញដែលមានអត្ថន័យត្រូវធ្វើ ឬ មិនត្រូវធ្វើ

ចំពោះកិច្ចសន្យាអញ្ញមញ្ញដែលមានអត្ថន័យឱ្យភាគីម្ខាងត្រូវធ្វើ ឬ មិនត្រូវធ្វើ ក្នុងករណីដែលការអនុវត្តកាតព្វកិច្ចនោះ ក្លាយជាអលទ្ធភាព ដោយគ្មានកំហុសរបស់ភាគីទាំងសងខាងទេ កាតព្វកិច្ចនោះត្រូវរលត់ ។ ប៉ុន្តែ កូនបំណុលមិនអាចទាមទារតាវកាលិកតបពីម្ចាស់បំណុលបានទេ ។

មាត្រា ៤២១.- អលទ្ធភាពក្នុងការអនុវត្តដោយកំហុសរបស់ម្ចាស់បំណុល

ក្នុងករណីដែលការអនុវត្តកាតព្វកិច្ចក្លាយជាអលទ្ធភាពដោយគ្មានកំហុសរបស់កូនបំណុល ហើយអលទ្ធភាពនោះកើតឡើងដោយមានកំហុសរបស់ម្ចាស់បំណុលវិញ កូនបំណុលមិនត្រូវបាត់បង់នូវតាវកាលិកតបពីម្ចាស់បំណុលទេ ។ ប៉ុន្តែ ប្រសិនបើកូនបំណុលបានទទួលផលប្រយោជន៍ ដោយការរួចផុតពីកាតព្វកិច្ចរបស់ខ្លួន កូនបំណុលត្រូវប្រគល់ផលប្រយោជន៍នេះទៅម្ចាស់បំណុលវិញ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ជំពូកទី ៦
អានុភាពនៃសិទ្ធិលើបំណុលចំពោះតតិយជន

ផ្នែកទី ១
ឧបាទានសកម្មដោយអ្នកមានសិទ្ធិលើបំណុល

មាត្រា ៤២២.- សិទ្ធិឧបាទានសកម្មរបស់ម្ចាស់បំណុល

១-ក្នុងករណីដែលចាំបាច់ដើម្បីរក្សាការពារសិទ្ធិលើបំណុលរបស់ខ្លួន ម្ចាស់បំណុលអាចអនុវត្តសិទ្ធិដែលកូនបំណុលមានជំនួសកូនបំណុលបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសិទ្ធិផ្តាច់មុខរបស់កូនបំណុលផ្ទាល់ សិទ្ធិដែលកូនបំណុលអាចសម្រេចដោយឆន្ទៈសេរីរបស់ខ្លួនក្នុងការអនុវត្ត និង សិទ្ធិដែលហាមមិនឱ្យរឹបអូស ។

២-ក្នុងករណីដែលចាំបាច់ដើម្បីទទួលការបំពេញចំពោះសិទ្ធិលើបំណុលរបស់ខ្លួន ម្ចាស់បំណុលអាចអនុវត្តសិទ្ធិលើបំណុលរបស់កូនបំណុលដែលមានការទាក់ទងយ៉ាងខ្លាំងនឹងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនោះ ដោយឧបាទានសកម្មបាន ។

មាត្រា ៤២៣.- លក្ខខណ្ឌដើម្បីអនុវត្តសិទ្ធិឧបាទានសកម្ម

១-ដើម្បីអនុវត្តសិទ្ធិដែលបានកំណត់នៅក្នុងមាត្រា ៤២២ (សិទ្ធិឧបាទានសកម្មរបស់ម្ចាស់បំណុល) ខាងលើ កូនបំណុលត្រូវតែមិនទាន់បានអនុវត្តសិទ្ធិរបស់ខ្លួន ។

២-នៅពេលដែលពេលកំណត់នៃសិទ្ធិលើបំណុលរបស់ខ្លួនមិនទាន់ដល់ទេ ម្ចាស់បំណុលមិនអាចអនុវត្តសិទ្ធិរបស់កូនបំណុលដោយឧបាទានសកម្មបានទេ លើកលែងតែករណីដែលបានទទួលការអនុញ្ញាតពីតុលាការ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសកម្មភាពរក្សាទុក ។

មាត្រា ៤២៤.- ការតតាំងនៃកូនបំណុលទី ៣

កូនបំណុលទី ៣ ដែលទទួលការអនុវត្តសិទ្ធិឧបាទានសកម្មរបស់ម្ចាស់បំណុលអាចតតាំងចំពោះម្ចាស់បំណុលដែលធ្វើឧបាទានសកម្ម ដោយយកការតវ៉ាដែលកូនបំណុលទី ៣ នោះមានចំពោះម្ចាស់បំណុលរបស់ខ្លួន ។

មាត្រា ៤២៥.- ទំនាក់ទំនងរវាងម្ចាស់បំណុលដែលធ្វើឱ្យបាទេសកម្ម និង កូនបំណុល

ក្នុងករណីដែលម្ចាស់បំណុលបានជូនដំណឹងទៅកូនបំណុលថា ខ្លួនបានអនុវត្តសិទ្ធិរបស់កូនបំណុលដោយឧបាទេសកម្ម កូនបំណុលមិនអាចអនុវត្តសិទ្ធិចំពោះកូនបំណុលទី ៣ ដោយផ្ទាល់បានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនរារាំងកូនបំណុលក្នុងការទទួលការសងពីកូនបំណុលទី ៣ ឡើយ ។

មាត្រា ៤២៦.- អានុភាពនៃសិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល

១-ក្នុងករណីដែលម្ចាស់បំណុលអនុវត្តសិទ្ធិរបស់កូនបំណុលដោយឧបាទេសកម្ម អានុភាពត្រូវមានលើកូនបំណុលដោយផ្ទាល់ ។

២-ក្នុងករណីដែលកូនបំណុលមិនអាចទទួលតាវកាលិកពីកូនបំណុលទី ៣ បានទេ ម្ចាស់បំណុលដែលអនុវត្តសិទ្ធិឧបាទេសកម្ម អាចទាមទារឱ្យកូនបំណុលទី ៣ នោះផ្តល់តាវកាលិកចំពោះខ្លួនផ្ទាល់បាន ។

មាត្រា ៤២៧.- អានុភាពនៃការអនុវត្តសិទ្ធិឧបាទេសកម្ម និង ម្ចាស់បំណុលផ្សេង

ម្ចាស់បំណុលដែលបានអនុវត្តសិទ្ធិឧបាទេសកម្ម មានករណីយកិច្ចរក្សាទុកនូវតាវកាលិកដែលខ្លួនបានទទួលពីកូនបំណុលទី ៣ សម្រាប់ម្ចាស់បំណុលទាំងអស់ រហូតដល់ពេលប្រគល់តាវកាលិកនោះទៅកូនបំណុល ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៤២២ (សិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល) នៃក្រមនេះ ។

ផ្នែកទី ២
សិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍

មាត្រា ៤២៨.- លក្ខខណ្ឌនៃការលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍

១-ម្ចាស់បំណុលអាចលុបចោលនូវអំពើដែលកូនបំណុលបានធ្វើដោយដឹងថា អំពើនោះធ្វើឱ្យខូចខាតផលប្រយោជន៍ដល់សិទ្ធិលើបំណុលនោះ ហើយទាមទារឱ្យអ្នកដែលបានទទួលផលប្រយោជន៍ពីអំពើរបស់កូនបំណុលនោះសងមកវិញនូវវត្ថុដែលអ្នកនោះ បានទទួលជាតាវកាលិក

ឬ ទឹកប្រាក់ដែលជាតម្លៃនៃវត្ថុនោះ តាមផ្លូវតុលាការបាន ។

២-ប្រសិនបើអ្នកដែលបានទទួលផលប្រយោជន៍ពីអំពើរបស់កូនបំណុល ឬ អ្នកដែលបានទទួលបន្តវត្ថុពីអ្នកនោះ មិនបានដឹងអំពីហេតុដែលធ្វើឱ្យខូចផលប្រយោជន៍របស់ម្ចាស់បំណុល នៅពេលដែលកូនបំណុលធ្វើអំពើនោះ ឬ ពេលដែលខ្លួនបានទទួលបន្តវត្ថុនោះទេ ការលុបចោលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចត្រូវបានអនុញ្ញាតឡើយ ។ ប៉ុន្តែ ចំពោះអ្នកដែលបានទទួលផលប្រយោជន៍ ឬ អ្នកដែលបានទទួលបន្តដោយមិនបង់ថ្លៃទេ ទោះបីជាអ្នកនោះមិនបានដឹងអំពីហេតុដែលធ្វើឱ្យខូចផលប្រយោជន៍ដល់ម្ចាស់បំណុលក៏ដោយ ក៏ម្ចាស់បំណុលនោះអាចអះអាងនូវការលុបចោលបានដែរ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះអំពើដែលមានកម្មវត្ថុមិនមែនជាសិទ្ធិលើទ្រព្យសម្បត្តិទេ ។

មាត្រា ៤២៩.- សិទ្ធិដែលត្រូវបានរក្សាការពារ

បញ្ញត្តិនៃមាត្រា ៤២៨ (ល័ក្ខខ័ណ្ឌនៃការលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍) ខាងលើនេះ ត្រូវយកមកអនុវត្តផងដែរចំពោះម្ចាស់បំណុលដែលមានសិទ្ធិលើបំណុលក្រៅពីសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ។ ប៉ុន្តែ នៅពេលដែលការទាញហេតុផលដោយផ្ទាល់មាត់ដែលទាក់ទងនឹងសាលក្រម ឬ សាលដីកាដែលលុបចោលអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ សិទ្ធិលើបំណុលនេះ ត្រូវប្តូរទៅជាសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់វិញ ។

មាត្រា ៤៣០.- វិធីលុបចោលអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍

ក្នុងករណីដែលគ្មានវិធីសមរម្យផ្សេងដើម្បីឱ្យអ្នកដែលបានទទួលប្រយោជន៍ ឬអ្នកដែលបានទទួលបន្តវត្ថុធ្វើបដិទាន ម្ចាស់បំណុលដែលអនុវត្តសិទ្ធិលុបចោលអាចទាមទារឱ្យអ្នកដែលបានទទួលប្រយោជន៍ ឬ អ្នកដែលបានទទួលបន្តវត្ថុនោះ តម្កល់នូវវត្ថុដែលទទួលបាន ។

មាត្រា ៤៣១.- អានុភាពនៃសិទ្ធិលុបចោលដែលនាំឱ្យខូចខាតផលប្រយោជន៍

ការលុបចោលដែលត្រូវបានធ្វើឡើងតាមបញ្ញត្តិនៃមាត្រា ៤២៨(ល័ក្ខខ័ណ្ឌនៃការលុប

ចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍) នៃក្រមនេះ ត្រូវបង្កើតអានុភាពសម្រាប់ផលប្រយោជន៍របស់ម្ចាស់បំណុលទាំងអស់ ។

មាត្រា ៤៣២.- អំឡុងពេលដែលអាចអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍

១-សិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ដែលបានកំណត់នៅក្នុងមាត្រា ៤២៨ (ល័ក្ខខ័ណ្ឌនៃការលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍) នៃក្រមនេះ នឹងត្រូវរលត់ នៅពេលដែលម្ចាស់បំណុលមិនអនុវត្តសិទ្ធិនោះ ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ បន្ទាប់ពីពេលដែលម្ចាស់បំណុលនោះបានដឹងអំពីមូលហេតុនៃការលុបចោលនោះ ។ សិទ្ធិនោះនឹងត្រូវរលត់ដែរ នៅពេលដែលអំឡុងពេល ៣ (បី) ឆ្នាំ កន្លងផុត បន្ទាប់ពីពេលដែលអំពើត្រូវបានធ្វើឡើង ។

២-បញ្ញត្តិស្តីពីការផ្អាកអាជ្ញាយុកាល មិនត្រូវយកមកអនុវត្តឡើយ ចំពោះអាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

ជំពូកទី ៧

ការរលត់កាតព្វកិច្ច

មាត្រា ៤៣៣.- មូលហេតុនៃការរលត់កាតព្វកិច្ច

កាតព្វកិច្ចត្រូវរលត់ដោយហេតុដូចខាងក្រោមនេះ :

ក-ការសង ការទូទាត់ ការលើកលែង នវកម្ម ឬ ល្បាយកុលភាព ដូចបានកំណត់ពីផ្នែកទី ១(ការសង) ដល់ផ្នែកទី ៥ (ល្បាយកុលភាព) នៃជំពូកទី ៧នេះ ។

ខ-អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចដោយគ្មានកំហុសរបស់កូនបំណុលដូចបានកំណត់ក្នុងជំពូកទី ៥(ការទទួលបន្ទុកហានិភ័យ) នៃគន្ថីនេះ ។

គ-ការបំពេញល័ក្ខខ័ណ្ឌនៃការរំលាយដូចបានកំណត់ក្នុងផ្នែកទី ៣(ល័ក្ខខ័ណ្ឌកំណត់ពេល និង អំឡុងពេល) នៃជំពូកទី ១ ឬ ការរំលាយកិច្ចសន្យាដូចបានកំណត់ក្នុងផ្នែកទី ៤(ការរំលាយកិច្ចសន្យា) នៃជំពូកទី ៤ នៃគន្ថីនេះ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

160/495

ឃ-ការផុតអាជ្ញាយុកាលនៃការរលត់ដូចបានកំណត់ក្នុងជំពូកទី ៨ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល) នៃគន្ថីនេះ ។

ង-ការអនុវត្តសិទ្ធិលុបចោលតាមបញ្ញត្តិនៃផ្នែកទី ៣(មោឃភាព និង ការលុបចោល) ជំពូកទី ២ នៃគន្ថីនេះ។

ផ្នែកទី ១

ការសង

កថាភាគទី ១

គោលការណ៍ទូទៅស្តីពីការសង

មាត្រា ៤៣៤.– អ្នកសង

១-ការសងអាចធ្វើឡើងដោយកូនបំណុលក៏បាន ដោយតតិយជនក៏បាន ។

២-ក្នុងករណីដែលគោលបំណងនៃកាតព្វកិច្ចមិនអាចសម្រេចដោយការសងរបស់តតិយជនបានទេ តតិយជននោះមិនអាចសងបានឡើយ លើកលែងតែមានការយល់ព្រមពីម្ចាស់បំណុល ។

៣-ម្ចាស់បំណុល និង កូនបំណុលអាចព្រមព្រៀងគ្នាមិនទទួលស្គាល់ការសងដោយតតិយជនបាន ។

មាត្រា ៤៣៥.– សមត្ថភាពចាត់ចែងរបស់អ្នកសង ជាអាទិ៍

១-ប្រសិនបើអ្នកសងមិនមែនជាម្ចាស់កម្មសិទ្ធិ ឬ មិនមានសមត្ថភាពចាត់ចែងចំពោះវត្ថុដែលជាកម្មវត្ថុនៃការសងទេ ការសងរបស់អ្នកសងនោះមិនមានសុពលភាពឡើយ ។

២-ក្នុងករណីដែលអ្នកសងមិនមែនជាម្ចាស់កម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការសងទេ អ្នកសងនោះមិនអាចយកវត្ថុនោះមកវិញបានឡើយ លើកលែងតែមានការសងម្តងទៀតដែលមានសុពលភាព ។ ប៉ុន្តែ អ្នកដែលមានកម្មសិទ្ធិលើវត្ថុនោះ អាចយកវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនពីអ្នកទទួលការសងមកវិញបាន ។

៣-ក្នុងករណីដែលអ្នកសងគ្មានសមត្ថភាពចាត់ចែងកម្មវត្ថុនៃការសងទេ អ្នកសងនោះ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

អាចលុបចោលនូវអំពើសងដែលខ្លួនបានធ្វើ ។ ក្នុងករណីនេះ បញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការប្រគល់កម្មវត្ថុនៃការសងវិញ ។

មាត្រា ៤៣៦.- ការប្រើប្រាស់ ឬ អនុប្បទានរបស់ម្ចាស់បំណុល និង ការទទួលដោយសុចរិត

១-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៤៣៥ (សមត្ថភាពចាត់ចែងរបស់អ្នកសង ជាអាទិ៍) ខាងលើនេះ បើកម្មវត្ថុនៃការសងជាចលនវត្ថុ ហើយម្ចាស់បំណុលបានបរិភោគ ឬ ធ្វើអនុប្បទានដោយសុចរិត នូវវត្ថុដែលបានទទួលពីការសង ការសងនោះត្រូវចាត់ទុកថាមានសុពលភាព ហើយអ្នកសងមិនអាចទាមទារឱ្យប្រគល់កម្មវត្ថុនៃការសងនោះ មកវិញបានទេ ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកដែលមានកម្មសិទ្ធិលើកម្មវត្ថុនៃការសងអាចទាមទារនូវសំណងនៃការខូចខាតចំពោះកម្មវត្ថុនៃការសងនោះ ពីអ្នកទទួលការសងបាន លើកលែងតែអ្នកទទួលការសងនោះបានទទួលកម្មសិទ្ធិលើវត្ថុនៃការសងដោយស្របទៅតាមបញ្ញត្តិនៃមាត្រា ១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ ។ ប៉ុន្តែ ម្ចាស់បំណុលដែលបានសងការខូចខាតទៅម្ចាស់កម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការសងនោះ អាចទាមទារឱ្យកូនបំណុលសងជាប្រាក់នូវតម្លៃដែលខ្លួនបានសងនោះវិញបាន ។

មាត្រា ៤៣៧.- សិទ្ធិទទួលការសង

១-ការសងនឹងមានសុពលភាព លុះត្រាតែធ្វើចំពោះម្ចាស់បំណុល ឬ អ្នកដទៃទៀតដែលមានសិទ្ធិទទួលការសង ។

២-បើកូនបំណុលបានសងដល់អ្នកដែលគ្មានសិទ្ធិទទួលការសង កូនបំណុលនោះត្រូវសងទៅម្ចាស់បំណុលជាថ្មីម្តងទៀត តាមការទាមទារពីម្ចាស់បំណុលនោះ ។ ក្នុងករណីនេះ អ្នកសងអាចទាមទារឱ្យអ្នកគ្មានសិទ្ធិដែលបានទទួលការសងនោះ ប្រគល់កម្មវត្ថុនៃការសងមកវិញបាន ។

មាត្រា ៤៣៨.- ការកម្រិតនូវសិទ្ធិទទួលការសងដោយការរឹបអូស

១-ក្នុងករណីដែលសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលត្រូវបានរឹបអូសដោយដីកាសម្រេច

វិបអូសរបស់តុលាការ ម្ចាស់បំណុលនោះមិនមានសិទ្ធិទទួលការសងពីកូនបំណុលរបស់ខ្លួន ហើយកូនបំណុលនោះមិនអាចសងទៅម្ចាស់បំណុលនោះបានឡើយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៤៣៧(សិទ្ធិទទួលការសង) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកូនបំណុលដែលត្រូវបានហាមការសងបានសងទៅម្ចាស់បំណុលរបស់ខ្លួន ។

មាត្រា ៤៣៩.- ការសងដែលបានធ្វើចំពោះខ្ញមភោគីនៃសិទ្ធិលើបំណុល

១-ចំពោះការសងដែលបានធ្វើទៅអ្នកដែលមិនមែនជាម្ចាស់បំណុល តែមើលទៅហាក់ដូចជាម្ចាស់បំណុល ក្នុងករណីដែលអ្នកសងបានជឿជាក់ថា ភាគីដែលខ្លួនបានសងនោះជាម្ចាស់បំណុលពិតប្រាកដ ការសងនោះត្រូវចាត់ទុកថាជាការសងមានសុពលភាព លើកលែងតែការជឿជាក់នោះកើតឡើងដោយសារកំហុសធ្ងន់ធ្ងរ ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ម្ចាស់បំណុលពិតប្រាកដមិនអាចទាមទារឱ្យកូនបំណុលសងម្តងទៀតបានទេ ។ ប៉ុន្តែ ម្ចាស់បំណុលពិតប្រាកដអាចទាមទារឱ្យអ្នកដែលបានទទួលការសងពីកូនបំណុលប្រគល់នូវវត្ថុដែលបានសងនោះឱ្យខ្លួនវិញបាន ។

មាត្រា ៤៤០.- វិធីសង

កូនបំណុលត្រូវសងតាមខ្លឹមសារនៃកាតព្វកិច្ច និង តាមគោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ ។

មាត្រា ៤៤១.- ការសងមួយភាគ

ម្ចាស់បំណុលមិនមានករណីយកិច្ចទទួលការសងមួយភាគនៃកាតព្វកិច្ចទេ ។ ប៉ុន្តែ ក្នុងករណីដែលម្ចាស់បំណុលបានទទួលដោយដឹងថាជាការសងមួយភាគ ការសងនោះមានសុពលភាពត្រឹមទំហំដែលបានសង ។

មាត្រា ៤៤២.- ការសងដោយយកវត្ថុជំនួស

ក្នុងករណីដែលកូនបំណុលផ្តល់តាវកាលិកផ្សេងពីតាវកាលិកដែលជាបន្ទុកដើមរបស់ខ្លួនជាជំនួសវិញ ដោយទទួលការយល់ព្រមពីម្ចាស់បំណុល តាវកាលិកនោះមានអានុភាព

ROYAUME DU CAMBODGE
LE MINISTÈRE du PALAIS ROYAL

ដូចគ្នានឹងការសងដែរ ។

២-ម្ចាស់បំណុល នឹង កូនបំណុលអាចធ្វើការព្រមព្រៀងគ្នាលើតាវកាលិកផ្សេង ជំនួសតាវកាលិកដើមបាន ។ ក្នុងករណីនេះ កូនបំណុលអាចសងដោយជ្រើសរើសតាវកាលិកដើម ឬ តាវកាលិកដោយយកវត្ថុផ្សេងជាជំនួសបាន លើកលែងតែករណីម្ចាស់បំណុលមានសិទ្ធិជ្រើសរើស ។

មាត្រា ៤៤៣.- ពេលនៃការសង ការសងមុនពេលកំណត់

១-កូនបំណុលត្រូវសងនៅពេលកំណត់ត្រូវអនុវត្តកាតព្វកិច្ចដែលមានចែងនៅក្នុងចំណុចនីមួយៗនៃមាត្រា ៣៩១ (ការយឺតយ៉ាវក្នុងការអនុវត្ត) នៃក្រមនេះ ។

២-កូនបំណុលអាចសងមុនពេលកំណត់បាន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៣០ (ប្រយោជន៍នៃការកំណត់ពេល) នៃក្រមនេះ ។

មាត្រា ៤៤៤.- ម៉ោងសង

កូនបំណុលត្រូវសងនៅក្នុងម៉ោងធ្វើការធម្មតា តាមទំនៀមទម្លាប់ និង គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ ។

មាត្រា ៤៤៥.- ទីកន្លែងដែលត្រូវសង

ប្រសិនបើគ្មានការព្រមព្រៀងគ្នាផ្សេងអំពីទីកន្លែងដែលត្រូវសងទេ ការប្រគល់វត្ថុដែលបានកំណត់ជាក់លាក់ត្រូវធ្វើឡើង នៅទីកន្លែងដែលវត្ថុនោះបានស្ថិតនៅនាពេលសិទ្ធិលើបំណុលកើតឡើង ។ ចំពោះកាតព្វកិច្ចក្រៅពីនេះ ការសងត្រូវធ្វើឡើងនៅលំនៅឋានបច្ចុប្បន្នរបស់ម្ចាស់បំណុល ។

មាត្រា ៤៤៦.- សោហ៊ុយនៃការសង

ប្រសិនបើគ្មានការព្រមព្រៀងគ្នាផ្សេងអំពីសោហ៊ុយនៃការសងទេ កូនបំណុលត្រូវទទួលបន្ទុកនូវសោហ៊ុយនោះ ។ ប៉ុន្តែ ប្រសិនបើសោហ៊ុយនៃការសងកើនឡើងដោយសារការផ្លាស់ប្តូរលំនៅឋាន ឬ អំពើផ្សេងរបស់ម្ចាស់បំណុល ម្ចាស់បំណុលត្រូវទទួលបន្ទុកនូវចំនួនកំណើននៃសោហ៊ុយនោះ ។

ROYAUME DU CAMBODGE · LE MINISTÈRE DU PALAIS ROYAL ·

មាត្រា ៤៤៧.- ការចេញលិខិតទទួល

អ្នកសងអាចទាមទារឱ្យអ្នកទទួលការសងចេញលិខិតបញ្ជាក់នូវការទទួលការសងនោះបាន ។

មាត្រា ៤៤៨.- ការប្រគល់មកវិញនូវលិខិតបញ្ជាក់សិទ្ធិលើបំណុល

ក្នុងករណីដែលមានលិខិតបញ្ជាក់សិទ្ធិលើបំណុល អ្នកសងអាចទាមទារឱ្យប្រគល់លិខិតនោះមកវិញបាន នៅពេលដែលខ្លួនបានសងចំពោះកាតព្វកិច្ចរបស់សព្វគ្រប់ហើយ ។

កថាភាគទី ២
ការកាត់បំណុល

មាត្រា ៤៤៩.- ការកាត់បំណុលដោយការជ្រើសរើស

១-ក្នុងករណីដែលកូនបំណុលត្រូវទទួលបន្ទុកនូវកាតព្វកិច្ចច្រើនដែលមានគោលបំណងប្រភេទដូចគ្នា ចំពោះម្ចាស់បំណុលតែម្នាក់ ប្រសិនបើតាវកាលិកដែលត្រូវបានផ្តល់ ជាការសងនៅមិនទាន់គ្រប់គ្រាន់ដើម្បីឱ្យកាតព្វកិច្ចទាំងអស់រលត់នៅឡើយទេ អ្នកសងអាចជ្រើសរើសយកកាតព្វកិច្ចណាដែលត្រូវកាត់ដោយការសងនោះ នៅពេលដែលខ្លួនផ្តល់តាវកាលិកបាន ។

២-ប្រសិនបើអ្នកសងមិនបានជ្រើសរើសដូចដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះទេ អ្នកទទួលការសងអាចជ្រើសរើសយកកាតព្វកិច្ចណាដែលត្រូវកាត់ដោយ ការសងនោះ នៅពេលដែលខ្លួនទទួលការសងបាន ។ ប៉ុន្តែ ប្រសិនបើអ្នកសងបានតវ៉ានឹងការកាត់នោះភ្លាមៗ ការកាត់បំណុលត្រូវធ្វើតាមច្បាប់កំណត់ ។

៣-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះការកាត់បំណុលត្រូវធ្វើឡើង ដោយការជូនដំណឹងទៅភាគីម្ខាងទៀត ។

មាត្រា ៤៥០.- ការកាត់បំណុលតាមច្បាប់កំណត់

ក្នុងករណីដែលអ្នកសង និង អ្នកទទួលការសងមិនបានធ្វើការជ្រើសរើសដើម្បីកាត់បំណុលនោះទេ ការកាត់បំណុលនោះ ត្រូវធ្វើឡើងតាមបញ្ញត្តិដូចខាងក្រោមនេះ :

ក-ក្នុងចំណោមកាតព្វកិច្ចទាំងអស់ ប្រសិនបើមានកាតព្វកិច្ចណាដែលពេលកំណត់ត្រូវសងបានមកដល់ និង កាតព្វកិច្ចណាដែលពេលកំណត់ត្រូវសងមិនទាន់មកដល់ ត្រូវកាត់កាតព្វកិច្ចដែលដល់ពេលកំណត់ជាមុនសិន ។

ខ-ប្រសិនបើពេលកំណត់ដែលត្រូវសងចំពោះកាតព្វកិច្ចទាំងអស់បានមកដល់ហើយ ឬ មិនទាន់មកដល់នៅឡើយ ត្រូវកាត់កាតព្វកិច្ចដែលមានប្រយោជន៍ក្នុងការសងច្រើនជាងគេសម្រាប់កូនបំណុល ។

គ-ប្រសិនបើផលប្រយោជន៍ក្នុងការសងមានភាពស្មើគ្នាចំពោះកូនបំណុលត្រូវកាត់កាតព្វកិច្ចដែលពេលកំណត់ត្រូវសងបានមកដល់មុនគេ ឬ នឹងមកដល់មុនគេ ។

ឃ-ប្រសិនបើកាតព្វកិច្ចទាំងអស់ មានប្រយោជន៍ក្នុងការសងដូចគ្នាចំពោះកូនបំណុល និង មានពេលកំណត់ដែលត្រូវសងដូចគ្នា ត្រូវកាត់ដោយគិតជាសមាមាត្រតាមចំនួនទឹកប្រាក់នៃកាតព្វកិច្ចនីមួយៗ ។

មាត្រា ៤៥១.- លំដាប់នៃការកាត់បំណុល : សោហ៊ុយ ការប្រាក់ និង ប្រាក់ដើម

ក្នុងករណីដែលកូនបំណុលមានករណីយកិច្ចបង់សោហ៊ុយ ការប្រាក់ ព្រមទាំងប្រាក់ដើមចំពោះកាតព្វកិច្ចមួយ ឬ ច្រើន ហើយអ្នកសងផ្តល់ការកាលិកមិនគ្រប់គ្រាន់ ដើម្បីរំលត់កាតព្វកិច្ចទាំងអស់ទេ ត្រូវកាត់តាមលំដាប់ : សោហ៊ុយ ការប្រាក់ និង ប្រាក់ដើមជាចុងក្រោយ ។ ប៉ុន្តែប្រសិនបើមានកិច្ចសន្យាផ្សេងពីនេះរវាងម្ចាស់បំណុល និង កូនបំណុល ត្រូវអនុវត្តតាមកិច្ចសន្យានោះ ។

មាត្រា ៤៥២.- ការកាត់បំណុលក្នុងករណីដែលមានម្ចាស់បំណុលច្រើននាក់

បញ្ញត្តិនៃមាត្រា ៤៤៩ (ការកាត់បំណុលដោយការជ្រើសរើស)មាត្រា ៤៥០(ការកាត់បំណុលតាមច្បាប់កំណត់) និងមាត្រា ៤៥១(លំដាប់នៃការកាត់បំណុល : សោហ៊ុយ ការប្រាក់ និង ប្រាក់ដើម) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកូនបំណុលទទួលបន្ទុកកាតព្វកិច្ចច្រើនចំពោះម្ចាស់បំណុលច្រើននាក់ ហើយមិនច្បាស់លាស់អំពីកាតព្វកិច្ចណាដែលត្រូវកាត់ដោយការសងទេ ។

ROYAUME DU CAMBODGE · LE MINISTÈRE DU PALAIS ROYAL

កថាភាគទី ៣
សំណើផ្តល់ការសង និង ការតម្កល់

មាត្រា ៤៥៣.- អត្ថន័យ និង អានុភាពជាមូលដ្ឋាននៃសំណើផ្តល់ការសង

១-សំណើផ្តល់ការសង សំដៅទៅលើការដែលកូនបំណុលបានរៀបចំចប់សព្វគ្រប់នូវការកាលិកសម្រាប់សង និង ទាមទារឱ្យម្ចាស់បំណុលទទួលការសងនោះ ។

២-ក្នុងករណីដែលកូនបំណុលធ្វើសំណើផ្តល់ការសង តែម្ចាស់បំណុលមិនធ្វើអំពើចាំបាច់ដើម្បីទទួលការសងទេ កូនបំណុលមិនទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ចនេះឡើយ ។

៣-ក្នុងករណីដែលកូនបំណុលមានកាតព្វកិច្ចដែលមានគោលបំណងសងជាប្រាក់និងត្រូវបង់ទាំងការប្រាក់ ហើយបានស្នើផ្តល់ការសង តែម្ចាស់បំណុលមិនទទួលការសងនោះទេ កូនបំណុលមិនចាំបាច់បង់ការប្រាក់សម្រាប់ពេលក្រោយពីពេលនោះទៀតឡើយ ។

មាត្រា ៤៥៤.- វិធីស្នើផ្តល់ការសង

សំណើផ្តល់ការសងត្រូវធ្វើឡើង ដោយស្នើផ្តល់តាវការកាលិកជាក់ស្តែងតាមខ្លឹមសារនៃកាតព្វកិច្ច ។ ប៉ុន្តែ ក្នុងករណីដែលម្ចាស់បំណុលបដិសេធជាមុនក្នុងការទទួលយកសំណើផ្តល់ការសង ឬ ក្នុងករណីដែលម្ចាស់បំណុលចាំបាច់ត្រូវធ្វើអំពើសម្រាប់ការអនុវត្តកាតព្វកិច្ចរបស់កូនបំណុល នោះកូនបំណុលគ្រាន់តែជូនដំណឹងអំពីការបញ្ចប់នូវការរៀបចំការសង និង ដាស់តឿនឱ្យម្ចាស់បំណុលទទួលការសងនោះតែប៉ុណ្ណោះ ជាការគ្រប់គ្រាន់ហើយ ។

មាត្រា ៤៥៥.- អានុភាពនៃសំណើផ្តល់ការសង

ក្នុងករណីដែលម្ចាស់បំណុលមិនទទួលនូវសំណើផ្តល់ការសងទេ ក្រៅពីអានុភាពដែលបានកំណត់ក្នុងមាត្រា ៤៥៣ (អត្ថន័យ និង អានុភាពជាមូលដ្ឋាននៃសំណើផ្តល់ការសង) នៃក្រមនេះ ត្រូវមានអានុភាពផ្សេងទៀតដូចតទៅ :

ក-ក្នុងករណីដែលកូនបំណុលទទួលបន្ទុកហានិភ័យនៅក្នុងកិច្ចសន្យាអញ្ញមញ្ញ ហានិភ័យនេះត្រូវផ្ទេរទៅម្ចាស់បំណុល ។

ខ-ក្នុងកិច្ចសន្យាអញ្ញមញ្ញ សិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នាដែលម្ចាស់បំណុលមានត្រូវបាត់បង់ ។

ROYAUME DU CAMBODGE · LE MINISTRE du PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

គ-កូនបំណុលអាចរួចផុតពីកាតព្វកិច្ចបានដោយការតម្កល់ ។

មាត្រា ៤៥៦.- ការយឺតយ៉ាវក្នុងការទទួល

១-ក្នុងករណីដែលម្ចាស់បំណុលប្រកែកជាមុននូវការទទួលការសង ឬ ករណីដែលកូនបំណុលបានស្នើផ្តល់ការសង តែម្ចាស់បំណុលមិនទទួលការសងនោះដោយមានកំហុសកូនបំណុលអាចទាមទារពីម្ចាស់បំណុលនូវសំណងនៃការខូចខាត ដែលបណ្តាលមកពីការមិនទទួលនោះបាន ។

២-ក្នុងករណីដែលការមិនទទួលសំណើផ្តល់ការសងរបស់ម្ចាស់បំណុល គឺជាការបំពានករណីយកិច្ចដ៏ធ្ងន់ធ្ងរពីម្ចាស់បំណុល នោះកូនបំណុលអាចរំលាយកិច្ចសន្យាបាន ។

មាត្រា ៤៥៧.- ការតម្កល់

១-កូនបំណុលអាចតម្កល់នូវកម្មវត្ថុនៃកាតព្វកិច្ចនៅកន្លែងតម្កល់ដើម្បីឱ្យរួចពីកាតព្វកិច្ចបាន ក្នុងករណីណាមួយដូចខាងក្រោមនេះ :

ក-អ្នកសងបានស្នើផ្តល់ការសង តែម្ចាស់បំណុលបដិសេធមិនទទួល ឬ មិនអាចទទួលការសងនោះបាន ។

ខ-កូនបំណុលមិនអាចដឹងថា អ្នកណាជាម្ចាស់បំណុល ដោយមិនមែនជាកំហុសរបស់ខ្លួន ។

២-នៅពេលដែលម្ចាស់បំណុលមិនព្រមទទួលការតម្កល់ ឬ សាលក្រម ឬ សាលដីកាដែលប្រកាសថាការតម្កល់នោះ មានសុពលភាពមិនទាន់ចូលជាស្ថាពរទេ អ្នកសងអាចយកវត្ថុតម្កល់មកវិញបាន ។ ក្នុងករណីនេះ អ្នកសងត្រូវបានចាត់ទុកថា មិនបានធ្វើការតម្កល់ ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសិទ្ធិលើការបញ្ចាំ ឬ សិទ្ធិលើហ៊ីប៉ូតែកត្រូវបានរលត់ដោយការតម្កល់នោះ ។

៣-សេចក្តីលម្អិតស្តីពីការតម្កល់ ត្រូវកំណត់ក្នុងច្បាប់ស្តីពីការតម្កល់ ។

មាត្រា ៤៥៨.- សិទ្ធិលក់ដោយខ្លួនឯង

ក្នុងករណីវត្ថុដែលជាកម្មវត្ថុនៃការសងមិនសមស្របនឹងការតម្កល់ ឬ មានការបារម្ភខាច

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មានការបាត់បង់ ឬ ខូចខាត តាមការអនុញ្ញាតពីតុលាការ អ្នកសងអាចលក់វត្ថុនោះដោយដេញថ្លៃ ហើយតម្កល់នូវប្រាក់លក់នោះបាន ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដែរ ចំពោះករណីដែលការរក្សាទុកវត្ថុនោះតម្រូវឱ្យចេញសោហ៊ុយច្រើនហួសហេតុ ។

កថាភាគទី ៤

ឧបាទេសកម្មដោយការសង

មាត្រា ៤៥៩.- ឧបាទេសកម្មដោយការសង

១-អ្នកដែលបានរួចផុតពីការទទួលខុសត្រូវ ដោយបានសង ឬ បានចេញចំណាយរបស់ខ្លួនផ្សេងទៀត ហើយបានទទួលសិទ្ធិទាមទារសំណងចំពោះកូនបំណុល អាចស្នងម្ចាស់បំណុលដោយឧបាទេសកម្មបាន ចំពោះសិទ្ធិលើបំណុល និង សិទ្ធិផ្សេងទៀតដែលម្ចាស់បំណុលនោះធ្លាប់មាន ។

២-បញ្ញត្តិនៃមាត្រា ៥០៣ (ល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

៣-ការជូនដំណឹងដែលបានកំណត់នៅក្នុងមាត្រា ៩១៣ (ល័ក្ខខ័ណ្ឌនៃការទាមទារសំណង) និងមាត្រា ៩៣៣ (ការជូនដំណឹងដែលជាល័ក្ខខ័ណ្ឌដើម្បីទាមទារសំណង) នៃក្រមនេះ អាចយកជាជំនួសនឹងការជូនដំណឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះបាន ។ ប៉ុន្តែ ក្នុងករណីដែលចាំបាច់មានលិខិតបញ្ជាក់ដែលមានកាលបរិច្ឆេទស្ថាពរ តាមបញ្ញត្តិដែលត្រូវយកមកអនុវត្តដូចគ្នា ដោយយោងទៅតាមកថាខណ្ឌទី ២ ខាង លើនេះ ការជូនដំណឹងដែលបានកំណត់នៅក្នុងកថាខណ្ឌនេះ ក៏ត្រូវធ្វើដោយលិខិតបញ្ជាក់ ដែលមានកាលបរិច្ឆេទស្ថាពរដែរ ។

មាត្រា ៤៦០.- ទំហំនៃឧបាទេសកម្ម និង ទំនាក់ទំនងគ្នាទៅវិញទៅមករវាងឧបាទេសិក

១-ឧបាទេសិកនៃម្ចាស់បំណុលតាមបញ្ញត្តិនៃមាត្រា ៤៥៩ (ឧបាទេសកម្មដោយការសង) អាចប្រើសិទ្ធិទាំងឡាយដែលជាអានុភាព និង ប្រាតិភោគនៃសិទ្ធិលើបំណុលដែល

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

/466

ម្ចាស់បំណុលធ្លាប់មាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះសិទ្ធិរបស់ម្ចាស់បំណុលដែលបានមកពីឋានៈក្នុងកិច្ចសន្យា ។

២-ឧបាទេសិកត្រូវធ្វើតាមបញ្ញត្តិនៃចំណុចដូចតទៅ :

ក-ប្រសិនបើអ្នកធានាដោយបុគ្គល ឬ អ្នកធានាដោយវត្ថុ មិនបានធ្វើការចុះបន្ថែមជាមុននូវឧបាទេសកម្ម ក្នុងបញ្ជីចុះឯកសិទ្ធិ សិទ្ធិបញ្ចាំអចលនវត្ថុ ឬ ហ៊ីប៉ូតែកដែលយកទ្រព្យរបស់កូនបំណុលមកជាកម្មវត្ថុទេ អ្នកធានា ឬ អ្នកធានាដោយវត្ថុនោះ មិនត្រូវស្នងម្ចាស់បំណុលដោយឧបាទេសកម្ម ចំពោះតតិយជនដែលបានធ្វើលទ្ធកម្មនូវអចលនវត្ថុ ដែលជាកម្មវត្ថុនៃឯកសិទ្ធិ ឬ សិទ្ធិបញ្ចាំអចលនវត្ថុ ឬ ហ៊ីប៉ូតែកនោះទេ ។

ខ-តតិយជនដែលបានធ្វើលទ្ធកម្មនូវវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគពីកូនបំណុលមិនត្រូវស្នងម្ចាស់បំណុលដោយឧបាទេសកម្ម ចំពោះអ្នកធានាទេ ។

គ-តតិយជនម្នាក់ក្នុងចំណោមតតិយជនដែលបានធ្វើលទ្ធកម្មនូវវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគពីកូនបំណុល ត្រូវស្នងម្ចាស់បំណុលដោយឧបាទេសកម្ម ចំពោះតតិយជនផ្សេងទៀតដែលបានធ្វើលទ្ធកម្មនូវវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគពីកូនបំណុលតាមសមាមាត្រនៃតម្លៃវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគនីមួយៗ ។

ឃ-បញ្ញត្តិនៃចំណុច គ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះទំនាក់ទំនងរវាងអ្នកធានាដោយវត្ថុ ដែលបានកំណត់នៅក្នុងមាត្រា ៧៦៦ (និយមន័យនៃអ្នកធានាដោយវត្ថុ និង តតិយជនដែលបានធ្វើលទ្ធកម្ម) នៃក្រមនេះ ។

ង-រវាងអ្នកធានាដោយបុគ្គល និង អ្នកធានាដោយវត្ថុ ត្រូវស្នងម្ចាស់បំណុលដោយឧបាទេសកម្ម ដោយគិតទៅតាមចំនួនអ្នកទាំងនោះ ។ ប៉ុន្តែ ប្រសិនបើអ្នកធានាដោយវត្ថុមានច្រើននាក់ ចំពោះប្រាក់សំណល់ក្រៅពីភាគដែលជាបន្ទុកអ្នកធានាត្រូវស្នង ម្ចាស់បំណុលដោយឧបាទេសកម្ម តាមសមាមាត្រនៃតម្លៃវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគនីមួយៗ ។

មាត្រា ៤៦១.- ឧបាទេសកម្មមួយភាគ

១-ក្នុងករណីដែលមានការសងតែមួយភាគនៃសិទ្ធិលើបំណុលដោយឧបាទេសិក ឧបាទេសិកត្រូវអនុវត្តសិទ្ធិព្រមគ្នានឹងម្ចាស់បំណុល ទៅតាមចំនួនប្រាក់ដែលខ្លួនបានសង ។ ប៉ុន្តែ

ពេលដែលឧបាទេសិកអនុវត្តសិទ្ធិរបស់ខ្លួន អ្នកនោះត្រូវទទួលការយល់ព្រមពីម្ចាស់បំណុល ឬ បើម្ចាស់បំណុលទាមទារ អ្នកនោះត្រូវធ្វើអនុប្បទាននូវសិទ្ធិ ឬ អាទិភាពរបស់ខ្លួន ទៅឱ្យម្ចាស់បំណុលត្រឹមកម្រិតនៃប្រាក់សំណល់នៃសិទ្ធិលើបំណុលនោះ ដោយមិនយកថ្លៃ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មានតែម្ចាស់បំណុលទេ ដែលអាចរំលាយកិច្ចសន្យាបាន ដោយយកមូលហេតុថាមិនបានអនុវត្តកាតព្វកិច្ច ។ ប៉ុន្តែក្នុងករណីនេះ ម្ចាស់បំណុលត្រូវសងនូវប្រាក់ដែលឧបាទេសិកបានសង ព្រមទាំងការប្រាក់ទៅឧបាទេសិកនោះវិញ ។

មាត្រា ៤៦២.- ការសងជំនួស និង លិខិតបញ្ជាក់សិទ្ធិលើបំណុល ឬ វត្ថុប្រាតិភោគ

១-ម្ចាស់បំណុលដែលបានទទួលការសងទាំងអស់ពីឧបាទេសិក ត្រូវប្រគល់នូវលិខិតដែលទាក់ទងនឹងសិទ្ធិលើបំណុលនោះ និង វត្ថុប្រាតិភោគដែលខ្លួនកាន់កាប់នោះទៅឱ្យឧបាទេសិក ។

២-ក្នុងករណីដែលមានការសងតែមួយភាគនៃសិទ្ធិលើបំណុលដោយឧបាទេសិក ម្ចាស់បំណុលត្រូវធ្វើកំណត់បន្ថែមអំពីឧបាទេសកម្មនេះ ក្នុងលិខិតបញ្ជាក់សិទ្ធិលើបំណុល ហើយឱ្យឧបាទេសិកធ្វើការត្រួតពិនិត្យនូវការរក្សាវត្ថុប្រាតិភោគដែលម្ចាស់បំណុលនោះ កាន់កាប់ផងដែរ ។

មាត្រា ៤៦៣.- ករណីយកិច្ចរក្សាប្រាតិភោគសម្រាប់ឧបាទេសិក

ក្នុងករណីមានបុគ្គលដែលអាចធ្វើឧបាទេសកម្មតាមបញ្ញត្តិនៃមាត្រា ៤៥៩(ឧបាទេសកម្មដោយការសង) នៃក្រមនេះ ប្រសិនបើម្ចាស់បំណុលបានធ្វើឱ្យបាត់បង់ ឬ បន្ថយនូវប្រាតិភោគដោយចេតនា ឬ ដោយមានកំហុស បុគ្គលដែលអាចស្នងម្ចាស់បំណុល ដោយឧបាទេសកម្មនោះអាចរួចផុតពីការទទួលខុសត្រូវ ឬ ទាមទារសំណងនៃការខូចខាតបាន ក្នុងកម្រិតដែលខ្លួនមិនអាចទទួលសំណងដោយសារការបាត់បង់ ឬ ការបន្ថយនោះ ។

ផ្នែកទី ២
ការទូទាត់

មាត្រា ៤៦៤.– លក្ខខណ្ឌនៃការទូទាត់ដែលច្បាប់បានកំណត់ និង កិច្ចសន្យាទូទាត់

១-ក្នុងករណីដែលបុគ្គលពីរនាក់ទទួលបន្ទុកនូវកាតព្វកិច្ចដែលមានគោលបំណងប្រភេទដូចគ្នាចំពោះគ្នាទៅវិញទៅមក ប្រសិនបើកាតព្វកិច្ចទាំងពីរត្រូវដល់ពេលកំណត់សងហើយ ភាគីម្ខាងអាចរំលត់កាតព្វកិច្ចទៅវិញទៅមក ដោយយកចំនួនប្រាក់ស្មើគ្នា ដោយបង្ហាញឆន្ទៈឯកតោភាគី ។

២-គូភាគីអាចធ្វើកិច្ចសន្យាទូទាត់ដែលរំលត់កាតព្វកិច្ចទៅវិញទៅមកបាន ទោះបីជាកាតព្វកិច្ចទាំងពីរនោះគ្មានគោលបំណងប្រភេទដូចគ្នាទៅវិញទៅមកក៏ដោយ ។ ប៉ុន្តែ គូភាគីមិនអាចធ្វើឱ្យខូចផលប្រយោជន៍របស់តតិយជនបានឡើយ ។

មាត្រា ៤៦៥.– វិធីទូទាត់

១-ការទូទាត់ត្រូវធ្វើឡើងដោយការបង្ហាញឆន្ទៈទូទាត់ ពីភាគីម្ខាង ទៅភាគីម្ខាងទៀត ។

២-ការបង្ហាញឆន្ទៈទូទាត់ អាចដាក់លក្ខខណ្ឌបង្អង់បាន តែមិនអាចដាក់លក្ខខណ្ឌរំលាយ ឬ កំណត់ពេលបានឡើយ ។

មាត្រា ៤៦៦.– ពេលដែលបង្កើតអានុភាពនៃការទូទាត់

ក្នុងករណីដែលលក្ខខណ្ឌនៃការទូទាត់ត្រូវបានបំពេញ ហើយនៅពេលឆន្ទៈទូទាត់ ត្រូវបានបង្ហាញអានុភាពដែលរំលត់កាតព្វកិច្ចដោយការទូទាត់ ត្រូវកើតឡើងដោយមានប្រតិសកម្មតាំងពីពេលដែលកាតព្វកិច្ចទាំងពីរនោះសមស្របទៅនឹងការទូទាត់ ។

មាត្រា ៤៦៧.– ការហាមឃាត់ចំពោះការទូទាត់

១-ក្នុងករណីដែលលក្ខណៈនៃកាតព្វកិច្ចណាមួយ ឬ ទាំងពីរ មិនអនុញ្ញាតឱ្យធ្វើការទូទាត់ទេ គូភាគីមិនអាចទូទាត់បានទេ ។

២-ក្នុងករណីដែលភាគីទាំងសងខាងធ្វើការសន្យាពិសេសមិនធ្វើការទូទាត់ កូនបំណុលម្ខាងៗមិនអាចទូទាត់បានទេ ។ ប៉ុន្តែ ការសន្យាពិសេសមិនធ្វើការទូទាត់នេះ មិនអាចអះអាង

ចំពោះតតិយជនសុចរិតបានឡើយ ។

មាត្រា ៤៦៨.- ការទូទាត់ដោយយកសិទ្ធិលើបំណុលដែលភ្ជាប់នឹងសិទ្ធិតវ៉ា

១-បើសិទ្ធិលើបំណុលរបស់ភាគីដែលបង្ហាញឆន្ទៈទូទាត់ ភ្ជាប់នឹងសិទ្ធិតវ៉ារបស់ភាគីម្ខាងទៀត ភាគីនោះមិនអាចទូទាត់បានទេ ។

២-ប្រសិនបើសិទ្ធិលើបំណុលដែលផុតអាជ្ញាយុកាល ឬ ផុតអំឡុងពេលដើម្បីអនុវត្តសិទ្ធិ ធ្លាប់នៅសមស្របទៅនឹងការទូទាត់ជាមួយនឹងសិទ្ធិលើបំណុលរបស់ភាគីម្ខាងទៀត នៅមុនពេលផុតអាជ្ញាយុកាល ឬ អំឡុងពេលនោះ ម្ចាស់បំណុលនោះអាចទូទាត់បាន ។

មាត្រា ៤៦៩.- ការទូទាត់ជាមួយនឹងសិទ្ធិលើបំណុលរបស់ភាគីម្ខាងទៀតដែលកើតឡើងដោយអំពើអនីត្យានុកូល

កូនបំណុលដែលទទួលបន្ទុកនូវកាតព្វកិច្ចដែលកើតឡើងដោយអំពើអនីត្យានុកូល ចំពោះភាគីម្ខាងទៀត កូនបំណុលនោះ មិនអាចអះអាងនូវការរលត់កាតព្វកិច្ចនេះដោយការទូទាត់ឡើយ ។

មាត្រា ៤៧០.- សិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស

ក្នុងករណីដែលសិទ្ធិលើបំណុលត្រូវបានហាមឃាត់មិនឱ្យរឹបអូស កូនបំណុលមិនអាចអះអាងនូវការរលត់សិទ្ធិលើបំណុលនោះដោយការទូទាត់ឡើយ ។

មាត្រា ៤៧១.- សិទ្ធិលើបំណុលដែលត្រូវបានរឹបអូស

១-ក្នុងករណីដែលសិទ្ធិលើបំណុលត្រូវតតិយជនរឹបអូស កូនបំណុលអាចទូទាត់កាតព្វកិច្ចរបស់ខ្លួន ដោយយកសិទ្ធិលើបំណុលចំពោះភាគីម្ខាងទៀតដែលខ្លួនបានទទួលមុនពេលតតិយជនរឹបអូស នៅពេលដែលសិទ្ធិលើបំណុលនោះដល់កំណត់សង ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលពេលកំណត់សងនៃសិទ្ធិលើបំណុលរបស់កូនបំណុលដែលអះអាងនូវការទូទាត់ចំពោះភាគីម្ខាងទៀត ត្រូវដល់ក្រោយពេលកំណត់សងនៃសិទ្ធិលើបំណុលរបស់ភាគីម្ខាងទៀតនោះ ។

២-បញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ

ចំពោះករណីដែលគូភាគីធ្វើការសន្យាពិសេសថា អាចទូទាត់គ្នានូវកាតព្វកិច្ចរៀងៗខ្លួនបានដោយ មិនគិតអំពីពេលកំណត់មុន ឬ ក្រោយ ។

មាត្រា ៤៧២.– ការកាត់បំណុលដោយការទូទាត់

ក្នុងករណីដែលភាគីម្ខាង ឬ ទាំងសងខាងមានកាតព្វកិច្ចច្រើនដែលអាចទូទាត់បានអ្នកសុំទូទាត់អាចជ្រើសរើសកាតព្វកិច្ចណាមួយរបស់ខ្លួន និង កាតព្វកិច្ចណាមួយរបស់ភាគីម្ខាងទៀត ដើម្បីរំលត់ដោយការទូទាត់នោះបាន ។ បញ្ញត្តិស្តីពីការកាត់បំណុលដោយការសងត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការទូទាត់ដែលគ្មានការជ្រើសរើស ដូចកំណត់ក្នុងវាក្យខណ្ឌទី ១ នៃមាត្រានេះ ។

ផ្នែកទី ៣

ការលើកលែង

មាត្រា ៤៧៣.– ការលើកលែងកាតព្វកិច្ច

ក្នុងករណីដែលម្ចាស់បំណុលបង្ហាញឆន្ទៈលើកលែងកាតព្វកិច្ចចំពោះកូនបំណុលកាតព្វកិច្ចនោះត្រូវរលត់ ។

មាត្រា ៤៧៤.– ការលើកលែងតែមួយផ្នែក

ម្ចាស់បំណុលអាចលើកលែងកាតព្វកិច្ចតែមួយផ្នែកបាន ។

មាត្រា ៤៧៥.– ករណីដែលកម្រិតការលើកលែង

ក្នុងករណីដែលសិទ្ធិលើបំណុលត្រូវបានរឹបអូសដោយតតិយជន ឬ សិទ្ធិចាត់ចែងរបស់ម្ចាស់បំណុលត្រូវបានកម្រិត ដោយមូលហេតុផ្សេង ម្ចាស់បំណុលមិនអាចលើកលែងកាតព្វកិច្ចបានឡើយ ។

ផ្នែកទី ៤

នវកម្ម

មាត្រា ៤៧៦.– និយមន័យនៃនវកម្ម

នវកម្មសំដៅទៅលើកិច្ចសន្យារវាងម្ចាស់បំណុល និង កូនបំណុលដែលរំលត់កាតព្វ-

កិច្ចដើម និង បង្កើតកាតព្វកិច្ចថ្មី ជំនួសកាតព្វកិច្ចដើមនោះ ។

២-នៅពេលកិច្ចសន្យានវកម្មដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បង្កើតអានុភាព នោះកាតព្វកិច្ចដើមត្រូវរលត់ ។

មាត្រា ៤៧៧.- ការមិនរលត់កាតព្វកិច្ចដើម

ប្រសិនបើកាតព្វកិច្ចថ្មីដែលត្រូវបានបង្កើតឡើងដោយនវកម្ម មិនបានបង្កើតអានុភាព ដោយសារមូលហេតុដែលកូនបំណុលនៃកាតព្វកិច្ចចាស់មិនអាចព្យាករបាន ឬប្រសិនបើកាតព្វ-កិច្ចថ្មីនោះជាអលទ្ធភាពក្នុងការអនុវត្តតាំងពីដើម នោះកាតព្វកិច្ចដើមមិនត្រូវរលត់ឡើយ ។

មាត្រា ៤៧៨.- ការផ្ទេរប្រាតិភោគ

១-សិទ្ធិលើការបញ្ចាំ ហ៊ីប៉ូតែក ឬ ប្រាតិភោគផ្សេងទៀតដែលបានបង្កើតឡើង ដើម្បីធានាកាតព្វកិច្ចដើម អាចផ្ទេរដើម្បីធានាកាតព្វកិច្ចថ្មី ក្នុងទំហំនៃកាតព្វកិច្ចដើម ដោយការព្រមព្រៀងគ្នារបស់គូភាគីនៃកិច្ចសន្យានវកម្មបាន ។ ប៉ុន្តែ ប្រាតិភោគដែលត្រូវបានដាក់ដោយតតិយៈជនមិនត្រូវផ្ទេរឡើយ លើកលែងតែមានការយល់ព្រមពីតតិយជននោះ ។

២-ក្នុងឧបសន្យាខ្ចីបរិភោគវត្ថុ ត្រូវសន្មតថា មានការព្រមព្រៀងដែលបានកំណត់នៅវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ ។

ផ្នែកទី ៥

ព្យាកុលភាព

មាត្រា ៤៧៩.- ព្យាកុលភាពរវាងសិទ្ធិលើបំណុល និង កាតព្វកិច្ច

១-ក្នុងករណីដែលសិទ្ធិលើបំណុល និង កាតព្វកិច្ចធ្លាក់ទៅលើបុគ្គលតែម្នាក់ សិទ្ធិលើបំណុល និង កាតព្វកិច្ចនោះត្រូវរលត់ដោយព្យាកុលភាព ។

២-សិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជន សិទ្ធិនោះមិនត្រូវរលត់ដោយព្យាកុលភាពឡើយ ។

ជំពូកទី ៨

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

មាត្រា ៤៨០.- និយមន័យនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល សំដៅទៅលើការរលត់សិទ្ធិលើបំណុលដោយផ្អែកលើការណ៍ដែលម្ចាស់បំណុលមិនអនុវត្តសិទ្ធិ ក្នុងអំឡុងពេលដែលត្រូវបានកំណត់ ។

មាត្រា ៤៨១.- ពេលចាប់ផ្តើមគិតអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវគិតចាប់ពីពេលដែលអាចអនុវត្តសិទ្ធិលើបំណុលនោះបាន ។

មាត្រា ៤៨២.- អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទូទៅ

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិផ្សេងក្នុងក្រមនេះ ឬ ច្បាប់ឬបទដ្ឋានគតិយុត្តផ្សេង ។

មាត្រា ៤៨៣.- អាជ្ញាយុកាលនៃការរំលត់សិទ្ធិដែលមានអំឡុងពេលខ្លី

ចំពោះសិទ្ធិលើបំណុលអំពីថ្លៃទំនិញដែលផលិតករ ឬ ពាណិជ្ជករលក់ទៅឱ្យអ្នកដែលមិនមែនជាពាណិជ្ជករនិង ថ្លៃសេវាដែលផលិតករ ឬ ពាណិជ្ជករផ្តល់ឱ្យអ្នកដែលមិនមែនជាពាណិជ្ជករ អាជ្ញាយុកាលនៃការរំលត់សិទ្ធិនេះ មានអំឡុងពេល ២ (ពីរ) ឆ្នាំ ។

មាត្រា ៤៨៤.- អំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលចូលជាស្ថាពរ

១-ចំពោះសិទ្ធិលើបំណុលដែលចូលជាស្ថាពរ ដោយសាលក្រម ឬ សាលដីកាស្ថាពរ ឬ ដោយការផ្សះផ្សាតាមផ្លូវតុលាការ ឬ ដោយវិធីផ្សេងដែលមានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ ទោះបីជាមានបញ្ញត្តិដែលកំណត់អំឡុងពេលនៃអាជ្ញាយុកាលតិចជាង ៥ (ប្រាំ) ឆ្នាំក៏ដោយឡែកអាជ្ញាយុកាលនៃការរំលត់សិទ្ធិនោះ ត្រូវមានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលសិទ្ធិលើបំណុលនោះចូលស្ថាពរដែរ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលពេលកំណត់ត្រូវអនុវត្តមិនទាន់ដល់ នៅពេលនៃការចូលជាស្ថាពរ ។

មាត្រា ៤៨៥.- អានុភាពប្រតិសកម្មនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមានអានុភាពប្រតិសកម្ម ចាប់តាំងពីថ្ងៃចាប់ផ្តើមគិតអាជ្ញាយុកាលនោះ ។

មាត្រា ៤៨៦.- ការលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

១-តុលាការមិនអាចសម្រេចសេចក្តីដោយយកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានឡើយ លើកលែងតែភាគីបានលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះ ។

២-ក្រៅពីកូនបំណុល មានតែកូនបំណុលដោយសាមគ្គីភាព អ្នកធានា អ្នកធានាដោយវត្ថុ និង តតិយជនដែលបានធ្វើលទ្ធកម្ម ដែលបានកំណត់នៅក្នុងមាត្រា ៧៦៦ (និយមន័យនៃអ្នកធានាដោយវត្ថុ និង តតិយជនដែលបានធ្វើលទ្ធកម្ម) នៃក្រមនេះ និង បុគ្គលផ្សេងទៀតដែលមានផលប្រយោជន៍ត្រឹមត្រូវតាមផ្លូវច្បាប់ ក្នុងការលើកឡើងនូវអាជ្ញាយុកាលទេ ដែលអាចលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបាន ។

៣-ប្រសិនបើកូនបំណុលលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលតតិយជនក៏នឹងទទួលនូវផលប្រយោជន៍នៃអាជ្ញាយុកាលនេះដែរ ។ ប្រសិនបើអ្នកដែលមិនមែនជាកូនបំណុល តែមានសិទ្ធិលើកឡើងនូវអាជ្ញាយុកាល បានលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនេះ អានុភាពនៃការលើកឡើងនេះ កើតឡើងតែរវាងម្ចាស់បំណុល និង អ្នកដែលលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិតែប៉ុណ្ណោះ ។

មាត្រា ៤៨៧.- ការបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មិនអាចបោះបង់ចោលជាមុនបានទេ ។ មានតែផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលបានសម្រេចហើយទេ ទើបអាចបោះបង់ចោលបាន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
1453

មាត្រា ៤៨៨.- វិសាលភាពនៃជនដែលទទួលអានុភាពនៃការបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាល នៃការរំលត់សិទ្ធិលើបំណុល

ការបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមានអានុភាពតែរវាងម្ចាស់បំណុល និង អ្នកមានសិទ្ធិលើកឡើងដែលបានបោះបង់ចោលនូវផល-ប្រយោជន៍នោះតែប៉ុណ្ណោះ ។

មាត្រា ៤៨៩.- ហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវផ្អាកក្នុងករណីដូចតទៅ :

ក-ការទាមទារតាមផ្លូវតុលាការ ការចូលរួមក្នុងនីតិវិធីធនក្ស័យ ឬ ការអនុវត្តសិទ្ធិដែលមានលក្ខណៈប្រហាក់ប្រហែល ។

ខ-សកម្មភាពអនុវត្តដោយបង្ខំ ឬ សកម្មភាពចាត់ចែងការរក្សាការពារ ។

គ-ការទទួលស្គាល់កាតព្វកិច្ច ដោយការសងមួយផ្នែក ការបង់ការប្រាក់ ការដាក់ប្រាតិភោគ ឬវិធីផ្សេង ។

មាត្រា ៤៩០.- វិសាលភាពនៃជនដែលទទួលអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ប្រសិនបើហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល កើតឡើងចំពោះកូនបំណុល អ្នកដទៃទៀតមិនអាចបដិសេធនូវអានុភាពនៃការផ្អាកនេះបានទេ ។ ប្រសិនបើហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលកើតឡើងចំពោះអ្នកមានសិទ្ធិលើកឡើងក្រៅពីកូនបំណុល អានុភាពនៃការផ្អាកនេះត្រូវកើតឡើង តែរវាងម្ចាស់បំណុល និង អ្នកមានសិទ្ធិលើកឡើងតែប៉ុណ្ណោះ ។

មាត្រា ៤៩១.- ការទាមទារតាមផ្លូវតុលាការ

ការទាមទារតាមផ្លូវតុលាការមិនត្រូវបង្កើតអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ ក្នុងករណីដែលបណ្តឹងត្រូវបានលើកចោល ឬ ត្រូវបានដកវិញ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

178/455

មាត្រា ៤៩២.- ការលុបចោលនូវការចាត់ចែងអនុវត្តដោយបង្ខំ ឬ ការចាត់ចែងរក្សាការពារ

ក្នុងករណីដែលការចាត់ចែងអនុវត្តដោយបង្ខំ ឬ ការរក្សាការពារ ត្រូវបានលុបចោលតាមពាក្យសុំរបស់ភាគី ឬ ដោយការខ្វះល័ក្ខខ័ណ្ឌតាមផ្លូវច្បាប់ ការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ដោយសកម្មភាពអនុវត្តដោយបង្ខំ ឬ ដោយសកម្មភាពចាត់ចែងការរក្សាការ-ពារនេះ ត្រូវចាត់ទុកថាមិនបានកើតឡើងឡើយ ។

មាត្រា ៤៩៣.- សកម្មភាពអនុវត្តដោយបង្ខំ ឬ សកម្មភាពចាត់ចែងការរក្សាការពារ ដែលធ្វើឡើងចំពោះបុគ្គលក្រៅពីកូនបំណុល

សកម្មភាពអនុវត្តដោយបង្ខំ ឬ សកម្មភាពចាត់ចែងការរក្សាការពារដែលធ្វើឡើង ចំពោះបុគ្គលក្រៅពីកូនបំណុល ត្រូវបង្កើតអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល លុះត្រាតែសកម្មភាពនោះ ត្រូវបានជូនដំណឹងទៅកូនបំណុល ។

មាត្រា ៤៩៤.- ដំណើរការនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ក្រោយការផ្អាក

១-អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលត្រូវបានផ្អាក នឹងចាប់ផ្តើមគិតជាថ្មីម្តងទៀត ក្រោយពីហេតុនៃការផ្អាកបានចប់ ។

២-អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលត្រូវបានផ្អាកដោយការទាមទារតាមផ្លូវតុលាការ នឹងចាប់ផ្តើមគិតជាថ្មីម្តងទៀត បន្ទាប់ពីសេចក្តីសម្រេចចូលជាស្ថាពរ ។

មាត្រា ៤៩៥.- ការបង្អង់ការសម្រេចអាជ្ញាយុកាលដោយការដាស់តឿន និង ដោយការដាស់តឿនតាមផ្លូវតុលាការ

១-ប្រសិនបើអ្នកមានសិទ្ធិបានដាស់តឿន នៅពេលណាមួយក្នុងអំឡុង៦ (ប្រាំមួយ) ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលរំលត់សិទ្ធិលើបំណុល អាជ្ញាយុកាលរំលត់សិទ្ធិលើបំណុលនោះមិនត្រូវបានសម្រេចចំពោះអ្នកនោះ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីការដាស់តឿនឡើយ ។ ប៉ុន្តែ ទោះបីជាអ្នកមានសិទ្ធិដាស់តឿនម្តងទៀតក៏ដោយ ក៏មិនអាចពន្យឺតការសម្រេចអាជ្ញាយុកាលរំលត់សិទ្ធិលើបំណុល ដោយការដាស់តឿនម្តងទៀតនោះដែរ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

២-ទោះបីជាការទាមទារតាមផ្លូវតុលាការ មិនបង្កើតអានុភាពនៃការផ្អាកអាជ្ញាយុកាល ដោយសារការលើកចោលបណ្តឹង ឬ ការដកពាក្យបណ្តឹងក៏ដោយ ក៏ត្រូវចាត់ទុកថា អ្នកប្តឹងបានដាស់តឿនជាបន្ត ចាប់ពីពេលដែលពាក្យបណ្តឹងត្រូវបានបញ្ជូនទៅភាគីម្ខាងទៀតរហូតដល់ពេលដែលបណ្តឹងនោះត្រូវបានលើកចោល ឬ ពេលដែលពាក្យបណ្តឹងនោះត្រូវបានដកដែរ ។ ក្នុងករណីនេះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះមិនត្រូវបានសម្រេចចំពោះអ្នកនោះ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីការលើកចោលបណ្តឹង ឬ ការដកពាក្យបណ្តឹងឡើយ ។

៣-ប្រសិនបើអ្នកមានសិទ្ធិបានអះអាងសិទ្ធិរបស់ខ្លួន ក្នុងនាមជាចុងចម្លើយក្នុងបណ្តឹងនោះ ត្រូវចាត់ទុកថាអ្នកនោះដាស់តឿនជាបន្ត ក្នុងពេលដែលបណ្តឹងនោះកំពុងចាត់ការចាប់ពីពេលដែលអ្នកនោះអះអាងសិទ្ធិរបស់ខ្លួន ។ ក្នុងករណីនេះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះមិនត្រូវសម្រេចចំពោះអ្នកនោះ ក្នុងអំឡុងពេល ៦ (ប្រាំ មួយ) ខែ បន្ទាប់ពីសាលក្រម ឬ សាលដីកានៃបណ្តឹងនោះចូលជាស្ថាពរ ។

មាត្រា ៤៩៦.- ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលចំពោះអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ

ប្រសិនបើអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ គ្មានអ្នកតំណាងដែលច្បាប់បានកំណត់នៅពេលណាមួយក្នុងអំឡុង ៦ (ប្រាំមួយ) ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះមិនត្រូវបានសម្រេចចំពោះអ្នកនោះ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីពេលដែលអ្នកនោះក្លាយទៅជាសមត្ថជន ឬ ពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់ត្រូវបានជ្រើសតាំងឡើយ ។

មាត្រា ៤៩៧.- ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលរវាងប្តីប្រពន្ធ

ចំពោះសិទ្ធិដែលសហព័ទ្ធម្ខាងមានលើសហព័ទ្ធម្ខាងទៀត អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មិនត្រូវបានសម្រេចក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ក្រោយពីការរលាយអាពាហ៍ពិពាហ៍ឡើយ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
180/456

មាត្រា ៤៩៨.- ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដោយសារមហន្តរាយធម្មជាតិ

ប្រសិនបើអ្នកមានសិទ្ធិមិនអាចផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដោយសារការជួបប្រទះនូវគ្រោះមហន្តរាយធម្មជាតិ ឬ ប្រធានសក្តិផ្សេង នៅពេលណាមួយក្នុង ៦ (ប្រាំមួយ) ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនេះមិនត្រូវបានសម្រេចក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីប្រធានសក្តិនោះបានកន្លងផុតឡើយ ។

មាត្រា ៤៩៩.- តាវកាលិកដើម្បីបំពេញនូវសិទ្ធិលើបំណុលដែលផុតអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ចំពោះតាវកាលិកដែលត្រូវបានផ្តល់ ដើម្បីបំពេញនូវសិទ្ធិលើបំណុលដែលផុតអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ទោះបីជាអ្នកនោះផ្តល់តាវកាលិក ដោយមិនបានដឹងថាផុតអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលក៏ដោយ ក៏អ្នកនោះមិនអាចទាមទារឱ្យសងតាវកាលិកនោះវិញឡើយ ។

មាត្រា ៥០០.- អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើទ្រព្យសម្បត្តិ ក្រៅពីសិទ្ធិលើបំណុល ឬ កម្មសិទ្ធិ

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើទ្រព្យសម្បត្តិ ក្រៅពីសិទ្ធិលើបំណុល ឬ កម្មសិទ្ធិ មានអំឡុងពេល ១០ (ដប់) ឆ្នាំ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិផ្សេងក្នុងក្រមនេះ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេង ។ បញ្ញត្តិស្តីពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើទ្រព្យសម្បត្តិ ក្រៅពីសិទ្ធិលើបំណុល ឬ កម្មសិទ្ធិ ។

ROYAUME du CAMBODGE
LE MINISTRE du PALAIS ROYAL

1/453

ជំពូកទី ៩
អនុប្បទានសិទ្ធិលើបំណុល ការទទួលភាគពួកិច្ច
ផ្នែកទី ១
អនុប្បទានសិទ្ធិលើបំណុល

មាត្រា ៥០១.– ភាពដែលអាចធ្វើអនុប្បទានសិទ្ធិលើបំណុល និង ការសន្យាពិសេស ហាមមិនឱ្យធ្វើអនុប្បទាន

១-សិទ្ធិលើបំណុលអាចធ្វើអនុប្បទានទៅឱ្យអ្នកផ្សេងបាន លើកលែងតែក្នុងករណីដែលសិទ្ធិនោះមានលក្ខណៈមិនអាចធ្វើអនុប្បទានបាន ។ ក្នុងករណីនេះ អនុប្បទានិកនឹងក្លាយជាម្ចាស់បំណុលថ្មី ។

២-ទោះបីជាសិទ្ធិលើបំណុលមានលក្ខណៈអាចធ្វើអនុប្បទានបានក៏ដោយ ក៏គូភាគី អាចហាមមិនឱ្យធ្វើអនុប្បទាន ដោយការបង្ហាញឆន្ទៈបានដែរ ។

៣-ការបង្ហាញឆន្ទៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ មិនអាចតតាំងចំពោះតតិយជនដែលមិនបានដឹងអំពីការបង្ហាញឆន្ទៈនោះបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតតិយជននោះមានកំហុសដ៏ធ្ងន់ធ្ងរ ។

មាត្រា ៥០២.– ការបង្កើតអនុប្បទានសិទ្ធិលើបំណុល

អនុប្បទានសិទ្ធិលើបំណុល ត្រូវមានអានុភាព តែដោយការព្រមព្រៀងគ្នារវាងម្ចាស់បំណុលដែលមានបំណងធ្វើអនុប្បទានសិទ្ធិលើបំណុល និង អនុប្បទានិកប៉ុណ្ណោះ ។ ប៉ុន្តែ ដើម្បីយកអនុប្បទានសិទ្ធិលើបំណុលនេះទៅតតាំង ចំពោះកូនបំណុល និង តតិយជន ត្រូវមានល័ក្ខខ័ណ្ឌតតាំងដែលបានកំណត់នៅក្នុងមាត្រា ៥០៣ (ល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) ខាងក្រោមនេះ ។

មាត្រា ៥០៣.– ល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ

១-អនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ មិនអាចតតាំងចំពោះកូនបំណុល ឬតតិយជនផ្សេងទៀតបានឡើយ បើអនុប្បទាយីមិនបានជូនដំណឹងទៅកូនបំណុល ឬ កូនបំណុល

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

មិនបានយល់ព្រម ចំពោះអនុប្បទាយី ឬ អនុប្បទានិក ។

២-ការជូនដំណឹង ឬ ការយល់ព្រមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចតតាំងនឹងតតិយជន ក្រៅពីកូនបំណុលបានឡើយ បើមិនបានធ្វើឡើងដោយលិខិតដែលមានកាលបរិច្ឆេទស្លាក ។

មាត្រា ៥០៤.- អាទិភាពនៃអនុប្បទានសិទ្ធិលើបំណុលជាច្រើនដង

១-ក្នុងករណីដែលធ្វើអនុប្បទានសិទ្ធិលើបំណុលតែមួយ ត្រូវបានធ្វើឡើងជាច្រើនដង អាទិភាពនៃអនុប្បទាននោះ ត្រូវកំណត់ទៅតាមលំដាប់នៃពេលដែលការជូនដំណឹងដែលធ្វើឡើងដោយលិខិតដែលមានកាលបរិច្ឆេទស្លាក បានដល់កូនបំណុល ឬ ពេលដែលកូនបំណុលបានយល់ព្រមដោយលិខិតដែលមានកាលបរិច្ឆេទស្លាក ។ ក្នុងករណីនេះ កូនបំណុលត្រូវសងបំណុលទៅអនុប្បទានិកដែលមានអាទិភាព ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើមិនអាចកំណត់លំដាប់នៃពេលដែលការជូនដំណឹងបានដល់ ឬ ពេលដែលកូនបំណុលបានយល់ព្រមទេ ត្រូវចាត់ទុកថា ការជូនដំណឹងនីមួយៗបានដល់កូនបំណុលនៅពេលជាមួយគ្នា ឬ កូនបំណុលបានយល់ព្រមនៅពេលជាមួយគ្នា ។ ក្នុងករណីនេះ អនុប្បទានិកនីមួយៗអាចទាមទារឱ្យកូនបំណុលសងចំពោះសិទ្ធិលើបំណុលទាំងអស់ដែលខ្លួនបានទទួលដោយអនុប្បទាន ។ ពេលដែលកូនបំណុលបានសងចំពោះម្ចាស់បំណុលណាម្នាក់ កាតព្វកិច្ចត្រូវរលត់ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ កូនបំណុលអាចរួចផុតពីកាតព្វកិច្ចបាន ដោយតម្កល់នូវវត្ថុដែលជាកម្មវត្ថុនៃកាតព្វកិច្ចនោះ ។

មាត្រា ៥០៥.- អានុភាពនៃការជូនដំណឹង និង ការយល់ព្រម

១-ប្រសិនបើកូនបំណុលធ្វើការយល់ព្រមដែលបានកំណត់នៅក្នុងមាត្រា ៥០៣ (ល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) នៃក្រមនេះ ដោយគ្មានការតវ៉ា ទោះបីជាខ្លួនមានហេតុដែលអាចតតាំងចំពោះអនុប្បទាយីក៏ដោយ ក៏កូនបំណុលមិនអាចយកហេតុនោះតតាំងចំពោះអនុប្បទាយីបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវរារាំងក្នុងការយកមកវិញ ដើម្បីកូនបំណុលប្រគល់វត្ថុណាឱ្យអនុប្បទាយីដើម្បីរំលត់កាតព្វកិច្ចរបស់ខ្លួន ឬ ក្នុងការ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ចាត់ទុកថា កាតព្វកិច្ចមិនកើតឡើងបើកូនបំណុលទទួលបន្ទុកនូវកាតព្វកិច្ចចំពោះអនុប្បទាយី ដើម្បីរំលត់កាតព្វកិច្ចរបស់ខ្លួន ។

២-ប្រសិនបើអនុប្បទាយីបានជូនដំណឹងអំពីអនុប្បទានតែប៉ុណ្ណោះ កូនបំណុលអាចយកហេតុដែលកើតឡើងចំពោះអនុប្បទាយី រហូតដល់ពេលខ្លួនទទួលដំណឹងនោះទៅតតាំងចំពោះអនុប្បទានិកបាន ។

មាត្រា ៥០៦.- អនុប្បទានសិទ្ធិលើបំណុលដែលត្រូវបានបញ្ជាក់ដោយមូលប័ត្រ

បញ្ញត្តិនៃច្បាប់ពិសេសត្រូវយកមកអនុវត្ត ចំពោះអនុប្បទានសិទ្ធិលើបំណុលដែលកំណត់ការបញ្ជា ឬ សិទ្ធិលើបំណុលផ្សេងដែលត្រូវបានបញ្ជាក់ដោយមូលប័ត្រ ។

ផ្នែកទី ២

ការទទួលកាតព្វកិច្ច

មាត្រា ៥០៧.- ភាពដែលអាចទទួលកាតព្វកិច្ចបាន

១-ចំពោះកាតព្វកិច្ចដែលអាចអនុវត្តបានដោយតតិយជនក្រៅពីកូនបំណុល តតិយជនអាចទទួលកាតព្វកិច្ចនោះបាន ។

២-គូភាគីអាចហាមមិនឱ្យតតិយជនទទួលកាតព្វកិច្ច ដោយការបង្ហាញឆន្ទៈបាន ។

មាត្រា ៥០៨.- ការបង្កើតនូវការទទួលកាតព្វកិច្ច

ការទទួលកាតព្វកិច្ចត្រូវមានអានុភាព ដោយការព្រមព្រៀងគ្នារវាងកូនបំណុល និង អ្នកទទួល ឬ ដោយការព្រមព្រៀងគ្នារវាងម្ចាស់បំណុល និង អ្នកទទួល ។

មាត្រា ៥០៩.- សិទ្ធិរបស់ម្ចាស់បំណុល

១-ទោះបីជាមានការទទួលកាតព្វកិច្ចក៏ដោយ ក៏ម្ចាស់បំណុលមិនបាត់បង់នូវសិទ្ធិចំពោះកូនបំណុលដែរ ។ ក្នុងករណីនេះ កូនបំណុល និង អ្នកទទួលកាតព្វកិច្ច ត្រូវទទួលបន្ទុកកាតព្វកិច្ចដោយសាមគ្គីភាព ចំពោះម្ចាស់បំណុល ។

២-អ្នកទទួលកាតព្វកិច្ច អាចឱ្យកូនបំណុលរួចផុតពីកាតព្វកិច្ច ដោយទទួលការយល់ព្រម

ROYAUME DU CAMBODGE * LE MINISTERE ... ROYAL

ពីម្ចាស់បំណុលបាន ។

មាត្រា ៥១០.- ការតវ៉ា ក្នុងការទទួលកាតព្វកិច្ច

ក្នុងករណីដែលការទទួលកាតព្វកិច្ចត្រូវបានធ្វើឡើង អ្នកទទួលនេះអាចយកហេតុដែលកូនបំណុលធ្លាប់មានរហូតដល់ពេលដែលការទទួលកាតព្វកិច្ចនោះត្រូវបានធ្វើឡើងទៅតតាំងចំពោះម្ចាស់បំណុលបាន ។

មាត្រា ៥១១.- ការទទួលការអនុវត្តកាតព្វកិច្ច

ប្រសិនបើអ្នកទទួលមិនទទួលកាតព្វកិច្ច តែបានទទួលគ្រាន់តែការអនុវត្តកាតព្វកិច្ចតែប៉ុណ្ណោះ តាមការព្រមព្រៀងគ្នារវាងកូនបំណុល និង អ្នកទទួលនោះម្ចាស់បំណុលមិនអាចទាមទារឱ្យអ្នកទទួលនោះ អនុវត្តកាតព្វកិច្ចបានឡើយ ។

ផ្នែកទី ៣

អនុប្បទានឋានៈក្នុងកិច្ចសន្យា

មាត្រា ៥១២.- អនុប្បទានឋានៈក្នុងកិច្ចសន្យា

១-បុគ្គលដែលបានធ្វើកិច្ចសន្យាជាមួយនឹងបុគ្គលផ្សេង អាចធ្វើអនុប្បទានឋានៈរបស់ខ្លួនដែលមានទៅក្នុងកិច្ចសន្យានោះទៅឱ្យតតិយជនបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយចំពោះករណីដែលអនុប្បទានឋានៈនោះមិនអាចធ្វើបានតាមលក្ខណៈនៃកិច្ចសន្យា ។ម្យ៉ាងទៀតគូភាគីនៃកិច្ចសន្យា អាចហាមមិនឱ្យធ្វើអនុប្បទានឋានៈក្នុងកិច្ចសន្យានោះ ដោយការព្រមព្រៀងគ្នាបាន ។ ក្នុងករណីនេះ បញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ៥០១ (ភាពដែលអាចធ្វើអនុប្បទានសិទ្ធិលើបំណុល និង ការសន្យាពិសេសហាមមិនឱ្យធ្វើអនុប្បទាន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

២-ក្នុងករណីដែលអនុប្បទានឋានៈក្នុងកិច្ចសន្យា នឹងធ្វើឱ្យភាគីម្ខាងទៀតនៃកិច្ចសន្យានោះខូចប្រយោជន៍ធ្ងន់ធ្ងរ បុគ្គលដែលមានបំណងធ្វើអនុប្បទានឋានៈក្នុងកិច្ចសន្យានោះ ត្រូវទទួលការយល់ព្រមអំពីអនុប្បទាននោះពីភាគីម្ខាងទៀតនៃកិច្ចសន្យានោះ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

មាត្រា ៥១៣.- ការបង្កើតអនុប្បទានឋានៈក្នុងកិច្ចសន្យា

អនុប្បទានឋានៈក្នុងកិច្ចសន្យា ត្រូវមានអានុភាពតែដោយការព្រមព្រៀងគ្នារវាងភាគីម្ខាងនៃកិច្ចសន្យាដែលមានបំណងធ្វើអនុប្បទានឋានៈនោះ និង អនុប្បទានិកប៉ុណ្ណោះ ។ ប៉ុន្តែ ដើម្បីតតាំងចំពោះភាគីម្ខាងទៀតនៃកិច្ចសន្យា និង តតិយជន អនុប្បទាននេះត្រូវមានល័ក្ខខ័ណ្ឌតតាំងដែលបានកំណត់ក្នុងមាត្រា ៥០៣ (ល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) នៃក្រមនេះ ។

មាត្រា ៥១៤.- អានុភាពនៃអនុប្បទានឋានៈក្នុងកិច្ចសន្យា

ក្នុងករណីដែលអនុប្បទានឋានៈក្នុងកិច្ចសន្យាត្រូវបានធ្វើឡើង សិទ្ធិ និង កាតព្វកិច្ចទាំងអស់ដែលអនុប្បទាយីធ្លាប់មាន ត្រូវផ្ទេរទៅអនុប្បទានិក លើកលែងតែមានការបង្ហាញឆន្ទៈពិសេស ។ ក្នុងករណីនេះ បញ្ញត្តិនៃមាត្រា ៥០៥ (អានុភាពនៃការជូនដំណឹង និងការយល់ព្រម) ស្តីពីអនុប្បទានសិទ្ធិលើបំណុល និងមាត្រា ៥១០(ការតភ៌ក្នុងការទទួលកាតព្វកិច្ច) ស្តីពីការទទួលកាតព្វកិច្ចនៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

គន្ថីទី ៥
កិច្ចសន្យាសំខាន់ៗ និង អំពើអនីត្យានុកូល
ជំពូកទី ១
ការលក់ទិញ
ផ្នែកទី ១
លក្ខណៈនៃការលក់ និង ការបង្កើតកិច្ចសន្យាលក់ទិញ

មាត្រា ៥១៥.- និយមន័យនៃការលក់ទិញ

ការលក់ទិញសំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាងហៅថា អ្នកលក់មានករណីយ-កិច្ចត្រូវផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិឱ្យទៅភាគីម្ខាងទៀតហៅថា អ្នកទិញ ហើយអ្នកទិញមានករណីយកិច្ចត្រូវចេញថ្លៃជាប្រាក់ឱ្យអ្នកលក់ ។

មាត្រា ៥១៦.- ការបង្កើតកិច្ចសន្យាលក់ទិញ

កិច្ចសន្យាលក់ទិញអាចត្រូវបានបង្កើតឡើង ដោយមានការព្រមព្រៀងគ្នារវាងភាគីទាំងសងខាងតែប៉ុណ្ណោះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ ។ ប៉ុន្តែ ភាគីអាចកំណត់ការធ្វើលិខិតយថាភូត ឬ លិខិតឯកជន ជាល័ក្ខខ័ណ្ឌសម្រាប់ការបង្កើតកិច្ចសន្យាបាន ។

មាត្រា ៥១៧.- ការសន្យាលក់ទិញជាមុនដោយឯកតោភាគី

១-ក្នុងករណីដែលភាគីតែម្ខាងសន្យាជាមុនក្នុងការលក់ ឬ ទិញ ការលក់ទិញនេះ នឹងមានអានុភាពចាប់តាំងពីពេលដែលភាគីម្ខាងទៀតបង្ហាញឆន្ទៈបំពេញការទិញ ឬ លក់ចំពោះអ្នកសន្យានោះ ។

២-ប្រសិនបើអំឡុងពេលសម្រាប់ការបង្ហាញឆន្ទៈដែលបានចែងក្នុងកថាខណ្ឌទី ១ នេះ មិនត្រូវបានកំណត់ទេ អ្នកសន្យាជាមុនអាចកំណត់នូវអំឡុងពេលសមរម្យមួយ ហើយអាចដាស់តឿនឱ្យភាគីម្ខាងទៀតបង្ហាញឆន្ទៈថាព្រម ឬ មិនព្រមបំពេញការទិញ ឬ លក់នៅក្នុងអំឡុងពេលនោះ ។ ក្នុងករណីដែលភាគីម្ខាងទៀតមិនបានបង្ហាញឆន្ទៈនៅក្នុងអំឡុងពេលកំណត់ទេ ការសន្យាជាមុននោះ ត្រូវបាត់បង់អានុភាព ។

មាត្រា ៥១៨.- ប្រាក់កក់

បើអ្នកទិញបានបង់ប្រាក់កក់ទៅឱ្យអ្នកលក់ អ្នកទិញអាចរំលាយកិច្ចសន្យាលក់ទិញដោយបោះបង់ចោលប្រាក់កក់នោះបាន រីឯអ្នកលក់អាចរំលាយកិច្ចសន្យាលក់ទិញដោយសងប្រាក់ស្មើនឹងពីរដងនៃប្រាក់កក់នេះមកវិញបានដែរ ។ ប៉ុន្តែ ភាគីមិនអាចរំលាយកិច្ចសន្យាបានឡើយក្រោយពេលភាគីម្ខាងទៀតបានចាប់ផ្តើមអនុវត្តកិច្ចសន្យាហើយ ។

មាត្រា ៥១៩.- ការលក់ដោយមានការភ្លក់សាក

១-ការលក់របស់ណាដែលមានទំនៀមទំលាប់តម្រូវឱ្យមានការភ្លក់សាកមុននឹងទិញត្រូវមានអានុភាពនៅពេលអ្នកទិញបានយល់ព្រម ក្រោយពេលបានភ្លក់សាករួចហើយ ។

២-ក្នុងករណីដែលមិនបានកំណត់អំឡុងពេលសម្រាប់អ្នកទិញដើម្បីយល់ព្រម អ្នកលក់អាចដាស់តឿនឱ្យអ្នកទិញឆ្លើយច្បាស់អំពីការយល់ព្រម ឬ មិនយល់ព្រមដោយកំណត់អំឡុងពេល

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

សមរម្យបាន ។ ក្នុងករណីដែលអ្នកទិញមិនបានឆ្លើយច្បាស់ក្នុងអំឡុងពេលនោះ ត្រូវចាត់ទុកថា អ្នកទិញបដិសេធក្នុងការធ្វើកិច្ចសន្យា ។

មាត្រា ៥២០.- ការលក់ដោយមានការប្រើសាក

១-ចំពោះការលក់ទិញដោយមានការប្រើសាក កិច្ចសន្យាលក់ទិញនោះមានអានុភាព នៅពេលដែលអ្នកទិញបានយល់ព្រមក្នុងអំឡុងពេលប្រើសាក ឬ អំឡុងពេលប្រើសាកនោះ កន្លងហួសដោយអ្នកទិញមិនបានបង្ហាញឆន្ទៈទេ ។ ក្នុងករណីដែលអ្នកទិញបដិសេធមិនទទួលវត្ថុដែលជាកម្មវត្ថុ កិច្ចសន្យាលក់ទិញនោះ ត្រូវចាត់ទុកថាមិនត្រូវបានបង្កើតឡើយ ។

២-ក្នុងករណីដែលមិនបានកំណត់អំឡុងពេលប្រើសាកនៅក្នុងកិច្ចសន្យា អ្នកលក់អាចដាស់តឿនឱ្យអ្នកទិញឆ្លើយច្បាស់អំពីការយល់ព្រម ឬ មិនយល់ព្រម ដោយកំណត់អំឡុងពេលសមរម្យបាន ។ ក្នុងករណីដែលអ្នកទិញមិនបានឆ្លើយច្បាស់ក្នុងអំឡុងពេលនោះ ហើយបន្តប្រើសាកវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យានោះ ត្រូវចាត់ទុកថា អ្នកទិញបានយល់ព្រម ។

មាត្រា ៥២១.- ថ្លៃលក់ទិញ

១-ភាគីនៃកិច្ចសន្យាត្រូវកំណត់ចំនួនប្រាក់នៃថ្លៃលក់ទិញ ឬវិធីកំណត់ចំនួនប្រាក់នោះ នៅក្នុងកិច្ចសន្យា ។

២-ចំនួនប្រាក់នៃថ្លៃលក់ទិញអាចត្រូវបានកំណត់ ដោយយោលទៅតាមតម្លៃនៃទំនិញណាមួយនៅទីផ្សារក្នុងពេលបច្ចុប្បន្ន ឬ អនាគត ឬ ដោយផ្អែកលើការវាយតម្លៃ ដែលធ្វើដោយតតិយជនដែលត្រូវបានជ្រើសរើស តាមរបៀបកំណត់ដោយគូភាគី ។ ក្នុងករណីដែលការវាយតម្លៃរបស់តតិយជនត្រូវបានធ្វើឡើងដោយភាន់ច្រឡំ ឬ ករណីដែលការវាយតម្លៃនោះ ច្បាស់ជាផ្ទុយនឹងសមភាព ភាគីនៃកិច្ចសន្យាដែលទទួលការខូចខាតផលប្រយោជន៍របស់ខ្លួន ដោយសារការវាយតម្លៃនោះ អាចតវ៉ាចំពោះការវាយតម្លៃនោះបាន ។

៣-ភាគីនៃកិច្ចសន្យាអាចកំណត់ចំនួនថ្លៃលក់ទិញដោយបង្ហាញចំនួនថ្លៃដើមពិតប្រាកដ ឬ ដោយឱ្យអ្នកទិញបង់ធនលាភ ដែលមិនកំណត់ពេល ឬ ធនលាភមួយជីវិតបាន ។ ប៉ុន្តែ ក្នុងករណីដែលតតិយជនវាយតម្លៃ ដោយយោលទៅតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ថ្លៃលក់ទិញត្រូវបានកំណត់ដោយបង្ហាញចំនួនថ្លៃដើមពិតប្រាកដ លើកលែងតែករណីដែលគូភាគី

ROYAUME DU CAMBODGE
LE MINISTERE DU PALAIS ROYAL

ប្រគល់សិទ្ធិទៅតតិយជនដោយជាក់លាក់ ។

មាត្រា ៥២២.- សោហ៊ុយក្នុងការលក់ទិញ

ចំពោះសោហ៊ុយធ្វើលិខិត ឬ សោហ៊ុយផ្សេងៗដែលត្រូវចំណាយក្នុងការធ្វើកិច្ចសន្យាលក់ទិញ ភាគីទាំងសងខាងត្រូវចេញស្មើគ្នា លើកលែងតែករណីដែលមានការកំណត់ផ្សេងដោយគូភាគី ។

មាត្រា ៥២៣.- ការអនុវត្តដូចគ្នាចំពោះកិច្ចសន្យាទូទៅដែលយកតម្លៃថ្នូរ

បញ្ញត្តិនៃជំពូកទី ១ (ការលក់ទិញ) នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះកិច្ចសន្យាដែលយកតម្លៃថ្នូរ ក្រៅពីកិច្ចសន្យាលក់ទិញ ។

ផ្នែកទី ២

ភាគីនៃកិច្ចសន្យាលក់ទិញ និង កម្មវត្ថុនៃកិច្ចសន្យាលក់ទិញ

មាត្រា ៥២៤.- ភាគីនៃកិច្ចសន្យាលក់ទិញ

រូបវន្តបុគ្គល ឬ នីតិបុគ្គលទាំងឡាយអាចលក់ ឬ ទិញបាន លើកលែងតែក្នុងករណីដែលច្បាប់ហាមឃាត់ ។

មាត្រា ៥២៥.- បុគ្គលដែលមិនអាចក្លាយជាអ្នកទិញបាន (មួយ)

១-អ្នកគ្រប់គ្រងទ្រព្យសម្បត្តិតាមច្បាប់ តាមផ្លូវតុលាការ ឬ តាមកិច្ចសន្យាមិនអាចក្លាយជាអ្នកទិញ ឬ ជាអ្នកទិញដោយការលក់ដោយបង្ខំ នូវទ្រព្យសម្បត្តិដែលខ្លួនបានទទួលភារកិច្ចលក់ ដោយផ្ទាល់ខ្លួន ឬ តាមរយៈអន្តរការី បានឡើយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះមន្ត្រីរាជការដែលទទួលបន្ទុកចាត់ការ ការលក់ដោយបង្ខំ ឬ ទទួលបន្ទុកគ្រប់គ្រងការលក់ដោយបង្ខំ ។

៣-ចំពោះការលក់ទិញដែលផ្ទុយនឹងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ មានតែកម្មសិទ្ធិករនៃវត្ថុមុនពេលលក់ ឬ សន្តតិជន ឬ ប្រតិសិទ្ធិរបស់កម្មសិទ្ធិករនោះទេ ទើបអាចលុបចោលកិច្ចសន្យានេះបាន ។

មាត្រា ៥២៦.- ចុងចោទដែលមិនអាចក្លាយជាអ្នកទិញបាន (ពីរ)

១-ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី ឬ មន្ត្រីតុលាការផ្សេងទៀត មិនអាចក្លាយជាអ្នកទិញ ឬ ជាអ្នកទិញដោយការលក់ដោយបង្ខំ ដោយផ្ទាល់ខ្លួន ឬ តាមរយៈអន្តរការីនូវវត្ថុ ឬ សិទ្ធិ ដែលជាកម្មវត្ថុនៃវិវាទដែលកំពុងចាត់ការនៅតុលាការដែលខ្លួនបំពេញភារកិច្ចបានទេ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមេធាវី ឬ សារការី ក្លាយជាអ្នកទិញ ឬ ជាអ្នកទិញដោយការលក់ដោយបង្ខំនូវវត្ថុ ឬ សិទ្ធិ ដែលទាក់ទងនឹងរឿងក្ដីដែលខ្លួនទទួលបន្ទុក ។

៣-ចំពោះការលក់ទិញដែលផ្ទុយនឹងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ មានតែអ្នកលក់ ភាគីម្ខាងទៀតដែលមានវិវាទអំពីសិទ្ធិ ឬ សន្តតិជនឬប្រតិសិទ្ធិរបស់អ្នកលក់ឬ ភាគីម្ខាងទៀត ទេ ទើបអាចលុបចោលកិច្ចសន្យានេះបាន ។

មាត្រា ៥២៧.- វត្ថុដែលអាចលក់បាន

វត្ថុ ឬ សិទ្ធិទាំងឡាយណា ទោះបីជាកើតមានឡើងនាពេលអនាគតក៏ដោយ ក៏អាចយក ទៅធ្វើជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញបានដែរ លើកលែងតែវត្ថុ ឬ សិទ្ធិនោះមានលក្ខណៈមិន អាចធ្វើអនុប្បទាន ឬ ច្បាប់ហាមឃាត់មិនឱ្យធ្វើអនុប្បទាន ។

ផ្នែកទី ៣
អានុភាពនៃកិច្ចសន្យាលក់ទិញ

មាត្រា ៥២៨.- ការផ្ទេរកម្មសិទ្ធិ

១-ចំពោះការផ្ទេរកម្មសិទ្ធិលើកម្មវត្ថុក្នុងកិច្ចសន្យាលក់ទិញ ត្រូវអនុវត្តទៅតាមគោល ការណ៍ទូទៅដែលបានកំណត់នៅក្នុងមាត្រា ១៣៣ (ការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិ ប្រត្យក្ស ដោយការព្រមព្រៀង) មាត្រា ១៣៤ (ល័ក្ខខ័ណ្ឌតតាំងនៃការបង្កើត ការផ្ទេរ និង ការ កែប្រែនូវសិទ្ធិប្រត្យក្ស) មាត្រា ១៣៥ (ល័ក្ខខ័ណ្ឌដើម្បីបង្កើតអានុភាពនៃការផ្ទេរកម្មសិទ្ធិលើ អចលនវត្ថុដោយការព្រមព្រៀង) មាត្រា ១៦០ (លទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុ) និងមាត្រា ១៦៧ (លទ្ធកម្មនៃកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

196/495

២-បើកម្មវត្ថុនៃកិច្ចសន្យាលក់ទិញជាសិទ្ធិលើទ្រព្យសម្បត្តិក្រៅពីកម្មសិទ្ធិ ការផ្ទេរសិទ្ធិទាំងនោះ ត្រូវអនុវត្តទៅតាមគោលការណ៍ទូទៅដែលទាក់ទងនឹងការផ្ទេរសិទ្ធិនីមួយៗនោះ ។

កថាភាគទី ១

##ករណីយកិច្ចរបស់អ្នកលក់

មាត្រា ៥២៩.- ករណីយកិច្ចត្រូវពន្យល់របស់អ្នកលក់

អ្នកលក់មានករណីយកិច្ចត្រូវពន្យល់ឱ្យបានច្បាស់លាស់ នូវខ្លឹមសារនៃករណីយកិច្ចដែលអ្នកលក់ទទួលបន្ទុកទំនាក់ទំនងគតិយុត្តដែលទាក់ទងនឹងវត្ថុ ឬ សិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញ ហើយជាពិសេសក្នុងករណីលក់អចលនវត្ថុ ត្រូវពន្យល់ដល់អ្នកទិញឱ្យបានច្បាស់លាស់នូវខ្លឹមសារនៃសិទ្ធិការទទួលបន្ទុក និង ព្រំដែននៃអចលនវត្ថុ ជាអាទិ៍ ។

មាត្រា ៥៣០.- ករណីយកិច្ចទូទៅរបស់អ្នកលក់

អ្នកលក់មានករណីយកិច្ច ត្រូវផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិដែលខ្លួនបានលក់ ត្រូវប្រគល់វត្ថុដែលបានលក់ ត្រូវថែរក្សាទុកនូវវត្ថុដែលបានលក់រហូតដល់ពេលប្រគល់ ព្រមទាំងត្រូវប្រគល់លិខិតផ្សេងៗដែលចាំបាច់ដើម្បីបញ្ជាក់នូវសិទ្ធិចំពោះអ្នកទិញតាមកិច្ចសន្យា និង បញ្ញត្តិនៃក្រមនេះ ។

មាត្រា ៥៣១.- ករណីយកិច្ចត្រូវផ្ទេរសិទ្ធិ និង ការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់

១-អ្នកលក់មានករណីយកិច្ចត្រូវផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការលក់ទិញទៅឱ្យអ្នកទិញ។

២-ប្រសិនបើកម្មវត្ថុនៃការលក់ទិញជាសិទ្ធិរបស់អ្នកដទៃ អ្នកលក់មានករណីយកិច្ច ត្រូវទទួលសិទ្ធិនោះ ហើយត្រូវផ្ទេរសិទ្ធិនោះទៅឱ្យអ្នកទិញ ។

៣-ប្រសិនបើអ្នកលក់មិនអាចផ្ទេរសិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញទៅឱ្យអ្នកទិញបានទេ អ្នកទិញអាចរំលាយកិច្ចសន្យាបាន ។ ក្នុងករណីនេះ ប្រសិនបើអ្នកទិញមិនបានដឹង នៅពេលធ្វើកិច្ចសន្យាថា សិទ្ធិនោះមិនមែនជាសិទ្ធិរបស់អ្នកលក់ទេ អ្នកទិញអាចទាមទារសំណងនៃការខូចខាតបាន ។

ROYAUME DU CAMBODGE LE MINISTERE DU PALAIS ROYAL

មាត្រា ៥៣២.- សិទ្ធិរំលាយកិច្ចសន្យារបស់អ្នកលក់សិទ្ធិអ្នកដទៃ

១-ប្រសិនបើអ្នកលក់មិនបានដឹងថា សិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញមិនមែនជារបស់ខ្លួន នៅពេលធ្វើកិច្ចសន្យាទេ ហើយមិនអាចទទួលយកសិទ្ធិនោះដើម្បីផ្ទេរទៅឱ្យអ្នកទិញបានទេ អ្នកលក់អាចរំលាយកិច្ចសន្យានោះបាន តែត្រូវសងការខូចខាត ។

២-ក្នុងករណីនៃកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើនៅពេលធ្វើកិច្ចសន្យា អ្នកទិញបានដឹងថា សិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញមិនមែនជាសិទ្ធិរបស់អ្នកលក់ទេ អ្នកលក់អាចរំលាយកិច្ចសន្យានោះបាន ដោយមិនចាំបាច់សងការខូចខាត ។

មាត្រា ៥៣៣.- ការទទួលខុសត្រូវក្នុងការធានាចំពោះករណីដែលសិទ្ធិមួយភាគជាសិទ្ធិរបស់អ្នកដទៃ

១-ក្នុងករណីសិទ្ធិមួយភាគក្នុងចំណោមសិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញ គឺជាសិទ្ធិរបស់អ្នកដទៃ ហើយបើអ្នកលក់មិនអាចទទួលសិទ្ធិនៃភាគនោះដើម្បីផ្ទេរទៅឱ្យអ្នកទិញបានទេ អ្នកទិញអាចទាមទារឱ្យបន្ថយនូវតម្លៃ តាមសមាមាត្រនៃភាគនោះបាន ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើនៅពេលធ្វើកិច្ចសន្យា អ្នកទិញមិនបានដឹងថា ភាគខ្វះនោះមិនមែនជារបស់អ្នកលក់ទេ ហើយបើទទួលស្គាល់ថា អ្នកទិញនឹងមិនទិញតែភាគដែលសល់តែប៉ុណ្ណោះទេ អ្នកទិញនោះអាចរំលាយកិច្ចសន្យាបាន ។

៣-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ បើនៅពេលធ្វើកិច្ចសន្យា អ្នកទិញមិនបានដឹងថា សិទ្ធិមួយភាគនោះមិនមែនជារបស់អ្នកលក់ទេ អ្នកទិញក៏អាចទាមទារសំណងនៃការខូចខាតបានដែរ ។

៤-សិទ្ធិដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ទី ២ និង ទី ៣ ខាងលើនេះ ត្រូវអនុវត្តក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលអ្នកទិញបានដឹងការពិត ក្នុងករណីដែលនៅពេលធ្វើកិច្ចសន្យា អ្នកទិញមិនបានដឹងថា សិទ្ធិមួយភាគក្នុងចំណោមសិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញ មិនមែនជារបស់អ្នកលក់ទេ ឬ គិតចាប់ពីពេលធ្វើកិច្ចសន្យា ក្នុងករណីដែលអ្នកទិញបានដឹងថា សិទ្ធិមួយភាគក្នុងចំណោមសិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញមិនមែនជារបស់អ្នកលក់នៅពេលធ្វើកិច្ចសន្យា ។

ROYAL CABINET · LE MINISTRE DU PALAIS ROYAL

មាត្រា ៥៣៤.– ការទទួលខុសត្រូវក្នុងការធានាក្នុងករណីដែលមានសិទ្ធិប្រត្យក្សជាផលុបភោគជាអាទិ៍

១-ក្នុងករណីដែលកម្មវត្ថុនៃការលក់ទិញភ្ជាប់ជាមួយសិទ្ធិជួលជាអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិប្រើប្រាស់ សេវភាព សិទ្ធិជួល សិទ្ធិឃាត់ទុក ឬ សិទ្ធិលើការបញ្ចាំ សម្រាប់តតិយជន ហើយបើអ្នកទិញមិនអាចប្រើប្រាស់ ឬ ទទួលផលពីកម្មវត្ថុទាំងមូល ឬ មួយផ្នែកដោយសារអត្ថិភាពនៃសិទ្ធិនោះ អ្នកទិញដែលមិនបានដឹងអំពីអត្ថិភាពនៃសិទ្ធិនោះ នៅពេលធ្វើកិច្ចសន្យាអាចទាមទារសំណងនៃការខូចខាតពីអ្នកលក់បាន ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើគោលបំណងនៃកិច្ចសន្យាមិនអាចសម្រេចបាន ដោយសារអត្ថិភាពនៃសិទ្ធិនោះ អ្នកទិញដែលមិនបានដឹងអំពីអត្ថិភាពនៃសិទ្ធិនោះនៅពេលធ្វើកិច្ចសន្យា ក៏អាចរំលាយកិច្ចសន្យាបានដែរ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលសេវភាពដែលត្រូវមានសម្រាប់អចលនវត្ថុដែលជាកម្មវត្ថុនៃការលក់ ទិញ បែរជាគ្មានទៅវិញ ។

៤-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ទី ២ ឬ ទី ៣ ខាងលើនេះ ការរំលាយកិច្ចសន្យា ឬ ការទាមទារសំណងនៃការខូចខាត ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលអ្នកទិញបានដឹងការពិត ។

មាត្រា ៥៣៥.– ការទទួលខុសត្រូវក្នុងការធានា ក្នុងករណីដែលមានសិទ្ធិប្រាតិភោគប្រត្យក្ស

១-ក្នុងករណីដែលមានឯកសិទ្ធិ ឬ សិទ្ធិលើការបញ្ចាំដែលកំណត់ថា ម្ចាស់បំណុលមិនប្រើប្រាស់ និង អាស្រ័យផល ឬ មានហ៊ីប៉ូតែកដែលបានដាក់លើអចលនវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ នៅពេលដែលអ្នកទិញបានបាត់បង់កម្មសិទ្ធិលើអចលនវត្ថុនោះ ដោយសារសិទ្ធិប្រាតិភោគប្រត្យក្សនោះត្រូវបានអនុវត្ត អ្នកទិញអាចរំលាយកិច្ចសន្យាបាន ។

២-ក្នុងករណីដែលអ្នកទិញបានធ្វើការចំណាយដើម្បីរក្សាកម្មសិទ្ធិ អ្នកទិញអាចទាមទារឱ្យអ្នកលក់សងថ្លៃចំណាយនោះមកវិញបាន ។

៣-ក្នុងករណីណាមួយដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ ប្រសិន

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

បើអ្នកទិញបានទទួលការខូចខាត អ្នកទិញអាចទាមទារសំណងនៃការខូចខាតនោះបាន ។

៤-ប្រសិនបើអ្នកទិញ បានទិញអចលនវត្ថុដែលភ្ជាប់សិទ្ធិប្រាតិភោគប្រត្យក្សដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងតម្លៃដែលបានដកចេញនូវចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគប្រត្យក្សនោះរួចហើយ អ្នកទិញនោះពុំមានសិទ្ធិដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ទី ២ និង ទី ៣ ខាងលើនេះឡើយ ។

មាត្រា ៥៣៦.- ការទទួលខុសត្រូវក្នុងការធានាក្នុងការលក់ដោយបង្ខំ

១-អ្នកដែលបានទិញតាមរយៈការលក់ដោយបង្ខំ អាចរំលាយកិច្ចសន្យាចំពោះកូនបំណុល ឬ ទាមទារឱ្យបន្ថយតម្លៃបាន ដោយអនុលោមទៅតាមបញ្ញត្តិពីមាត្រា ៥៣១ (ករណីយកិច្ចត្រូវផ្ទេរសិទ្ធិ និង ការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់) ដល់មាត្រា ៥៣៥ (ការទទួលខុសត្រូវក្នុងការធានា ក្នុងករណីដែលមានសិទ្ធិប្រាតិភោគប្រត្យក្ស) នៃក្រមនេះ ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើកូនបំណុលស្ថិតក្នុងភាពអសាធនីយ អ្នកទិញអាចទាមទារឱ្យម្ចាស់បំណុលដែលបានទទួលចំណែកនៃថ្លៃលក់សងប្រាក់ដែលបានមកពីការលក់នោះទាំងអស់ ឬ មួយភាគវិញបាន ។

៣-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ ប្រសិនបើកូនបំណុលបានដឹងអំពីអត្ថិភាពនៃហេតុដែលក្លាយជាមូលហេតុនៃការទទួលខុសត្រូវក្នុងការធានា ហើយមិនបានជូនដំណឹងទៅស្ថាប័នដែលអនុវត្តការលក់ដោយបង្ខំទេ ឬ ម្ចាស់បំណុលបានដឹងហើយ តែនៅតែទាមទារឱ្យលក់ដោយបង្ខំ អ្នកទិញអាចទាមទារនូវសំណងនៃការខូចខាតពីអ្នកទាំងនោះបាន ។

មាត្រា ៥៣៧.- ការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់សិទ្ធិលើបំណុល

១-អ្នកលក់សិទ្ធិលើបំណុលត្រូវទទួលខុសត្រូវចំពោះអត្ថិភាពនៃសិទ្ធិលើបំណុលនោះ ។

២-ក្នុងករណីដែលអ្នកលក់សិទ្ធិលើបំណុលបានធានាសាធនភាពរបស់កូនបំណុលនោះត្រូវសន្មតថា បានធានាសាធនភាពរបស់កូនបំណុលដែលមាននៅពេលធ្វើកិច្ចសន្យានោះ ។

៣-ក្នុងករណីដែលអ្នកលក់សិទ្ធិលើបំណុលដែលមិនទាន់ដល់ពេលកំណត់ត្រូវសងបាន ធានាសាធនភាពអនាគតរបស់កូនបំណុលនោះត្រូវសន្មតថា បានធានាសាធនភាពរបស់កូន

ROYAUME DU CAMBODGE • LE MINISTERE DU PALAIS ROYAL

បំណុលនៅពេលកំណត់ត្រូវសង ។

មាត្រា ៥៣៨.- ការព្រមព្រៀងគ្នាក្នុងការអនុគ្រោះ ឬ កម្រិតនូវការទទួលខុសត្រូវក្នុងការធានា

ទោះបីជាមានការព្រមព្រៀងគ្នាក្នុងការអនុគ្រោះ ឬ កម្រិតនូវការទទួលខុសត្រូវក្នុងការធានាដែលអ្នកលក់ត្រូវមាន តាមបញ្ញត្តិពីមាត្រា ៥៣១ (ករណីយកិច្ចត្រូវផ្ទេរសិទ្ធិ និងការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់) ដល់មាត្រា ៥៣៧ (ការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់សិទ្ធិលើបំណុល) នៃក្រមនេះ ក៏ដោយក៏អ្នកលក់មិនអាចរួចផុតពីការទទួលខុសត្រូវបានដែរ ចំពោះហេតុការណ៍ដែលអ្នកលក់បានដឹងតែមិនបានផ្តល់ដំណឹង ឬ សិទ្ធិដែលខ្លួនបានបង្កើតសម្រាប់តតិយជន ឬ បានធ្វើអនុប្បទានទៅតតិយជន ។

មាត្រា ៥៣៩.- ករណីយកិច្ចផ្តល់វត្ថុដែលគ្មានវិការៈ

១-អ្នកលក់ត្រូវមានករណីយកិច្ចប្រគល់វត្ថុដែលគ្មានវិការៈឱ្យទៅអ្នកទិញ ។

២-លើកលែងតែគូភាគីបានកំណត់ផ្សេង វត្ថុដែលបានប្រគល់ឱ្យទៅអ្នកទិញមានលក្ខណៈណាមួយដូចខាងក្រោមនេះ ត្រូវបានចាត់ទុកថាមានវិការៈ :

ក-វត្ថុនោះមានភាពមិនស្របនឹងចំនួន គុណភាព និង លក្ខណៈដែលបានកំណត់ក្នុងកិច្ចសន្យា ។

ខ-វត្ថុនោះមានភាពផ្សេងពីគំរូដែលអ្នកលក់បានបង្ហាញឱ្យអ្នកទិញមើលចំពោះចំនួន គុណភាព និង លក្ខណៈ ។

គ-វត្ថុនោះមិនស្របនឹងវិធីប្រើដែលអ្នកទិញត្រូវបានបង្ហាញ ដោយជាក់លាក់ ឬ ដោយតុណ្ហីភាព នៅពេលធ្វើកិច្ចសន្យា ។

ឃ-វត្ថុនោះមិនស្របនឹងវិធីប្រើធម្មតានៃវត្ថុប្រភេទដូចគ្នា ។

ង-វត្ថុនោះមិនត្រូវបានខ្ចប់តាមវិធីធម្មតានៃការខ្ចប់វត្ថុប្រភេទដូចគ្នា ឬ តាមវិធីសមរម្យដើម្បីការពារវត្ថុនោះ ។

មាត្រា ៥៤០.- ការទទួលខុសត្រូវក្នុងការធានាវិការៈ

១-នៅពេលដែលហានិភ័យត្រូវផ្ទេរទៅអ្នកទិញ បើវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

មានវិការៈ ទោះបីជាវិការៈនេះត្រូវបានដឹងច្បាស់នៅក្រោយពេលដែលហានិភ័យត្រូវបានផ្ទេរក៏ដោយក៏អ្នកលក់ត្រូវទទួលខុសត្រូវក្នុងការប្រគល់វត្ថុជំនួសការជួសជុលវិការៈ ការរំលាយកិច្ចសន្យា ឬ ការបន្ថយនូវតម្លៃ ស្របតាមកិច្ចសន្យា និង បញ្ញត្តិនៃក្រមនេះដែរ ។

២-ទោះបីជាវិការៈកើតឡើងនៅក្រោយពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ប្រសិនបើវិការៈនោះបានកើតឡើងដោយសារអ្នកលក់ធ្វើខុសនឹងករណីយកិច្ចរបស់ខ្លួន ក៏អ្នកលក់ត្រូវទទួលខុសត្រូវក្នុងការធានាវិការៈដូចបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះដែរ ។

៣-ក្នុងករណីដែលអ្នកលក់ធានាថា វត្ថុដែលជាកម្មវត្ថុនៃការលក់នោះត្រូវស្របនឹងគោលបំណងធម្មតា ឬ គោលបំណងពិសេស ក្នុងអំឡុងពេលដែលបានកំណត់ក្រោយពីការប្រគល់ ឬ ធានាថា វត្ថុដែលជាកម្មវត្ថុនោះត្រូវរក្សាទុកនូវគុណភាពពិសេស ឬ លក្ខណៈពិសេសដដែល ក្នុងអំឡុងពេលដែលបានកំណត់ក្រោយពីការប្រគល់ ហើយបើមានការបំពានលើការធានានោះ អ្នកលក់ត្រូវទទួលខុសត្រូវក្នុងការធានាវិការៈដូចគ្នាដែរ ។

៤-ក្នុងករណីដែលអ្នកទិញបានដឹង ឬ មិនបានដឹងដោយសារកំហុសធ្ងន់ធ្ងររបស់ខ្លួនអំពីវិការៈនៃវត្ថុដែលជាកម្មវត្ថុនោះ នៅពេលធ្វើកិច្ចសន្យាលក់ទិញ អ្នកលក់មិនត្រូវទទួលខុសត្រូវក្នុងការធានាវិការៈនោះទេ ។

មាត្រា ៥៤១.- សិទ្ធិជួសជុលរបស់អ្នកលក់

១-ក្នុងករណីដែលអ្នកលក់ប្រគល់វត្ថុដែលមានវិការៈមុនពេលកំណត់ត្រូវប្រគល់ អ្នកលក់នោះអាចជួសជុលវិការៈរហូតដល់ពេលកំណត់នោះបាន លុះត្រាតែមិនបណ្តាលឱ្យខូចខាតផលប្រយោជន៍ហួសហេតុដល់អ្នកទិញ ។ ប៉ុន្តែ អ្នកទិញមិនត្រូវបានរារាំងក្នុងការអនុវត្តសិទ្ធិទាមទារសំណងនៃការខូចខាតឡើយ ។

២-ទោះបីជាក្រោយពេលកំណត់ត្រូវប្រគល់ក៏ដោយ អ្នកលក់អាចជួសជុលវិការៈទាំងអស់ដោយចេញចំណាយដោយខ្លួនឯងបាន លុះត្រាតែមិនបណ្តាលឱ្យមានការខូចខាតផលប្រយោជន៍ហួសហេតុដល់អ្នកទិញ ។ ប៉ុន្តែ អ្នកទិញមិនត្រូវបានរារាំងក្នុងការអនុវត្តសិទ្ធិរំលាយ និង សិទ្ធិទាមទារសំណងនៃការខូចខាតឡើយ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

មាត្រា ៥៤២.– សិទ្ធិទាមទារឱ្យអនុវត្តពេញលេញរបស់អ្នកទិញ

១-អ្នកទិញអាចទាមទារឱ្យអ្នកលក់អនុវត្តករណីយកិច្ចបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកទិញទាមទារការសង្គ្រោះដែលមិនសមស្របនឹងការទាមទារឱ្យអនុវត្តករណីយកិច្ចនោះ ។

២-ក្នុងករណីដែលកម្មវត្ថុនៃការលក់ទិញមានវិការៈ អ្នកទិញអាចទាមទារឱ្យអ្នកលក់ប្រគល់វត្ថុជំនួសដែលគ្មានវិការៈបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការរៀបចំវត្ថុដែលមានប្រភេទដូចគ្នា ដោយអ្នកលក់នឹងបង្កើតបន្ទុកមិនសមរម្យហួសហេតុ ដោយគិតពិចារណាទូវកាលៈទេសៈជុំវិញទាំងឡាយ ។

៣-ក្នុងករណីដែលកម្មវត្ថុនៃការលក់ទិញមានវិការៈ អ្នកទិញអាចទាមទារឱ្យអ្នកលក់ជួសជុលវត្ថុដែលជាកម្មវត្ថុនោះបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការជួសជុលវត្ថុដែលជាកម្មវត្ថុដោយអ្នកលក់ នឹងបង្កើតបន្ទុកមិនសមរម្យ ហួសហេតុ ដោយគិតពិចារណាទូវកាលៈទេសៈជុំវិញទាំងឡាយ ។

៤-អ្នកទិញអាចកំណត់អំឡុងពេលសមរម្យបន្ថែមដើម្បីឱ្យអ្នកលក់អនុវត្តករណីយកិច្ចបាន ។ អ្នកទិញមិនអាចទាមទារការសង្គ្រោះចំពោះការបំពានកិច្ចសន្យាក្នុងអំឡុងពេលនេះទេ លើកលែងតែករណីដែលអ្នកទិញទទួលដំណឹងពីអ្នកលក់ថា អ្នកលក់មិនអនុវត្តករណីយកិច្ចរបស់ខ្លួនក្នុងអំឡុងពេលនោះ ។ ប៉ុន្តែ អ្នកទិញមិនត្រូវបាត់បង់សិទ្ធិទាមទារសំណងការខូចខាតដែលបានកើតឡើងដោយសារការយឺតយ៉ាវក្នុងការអនុវត្តករណីយកិច្ច តាមពេលកំណត់ដើមទេ ។

មាត្រា ៥៤៣.– សិទ្ធិរំលាយកិច្ចសន្យារបស់អ្នកទិញ

ក្នុងករណីដែលអ្នកទិញមិនអាចសម្រេចគោលបំណងនៃកិច្ចសន្យាលក់ទិញបាន ដោយសារវត្ថុដែលត្រូវបានប្រគល់មានវិការៈ អ្នកទិញនោះអាចរំលាយកិច្ចសន្យានោះបាន ។

មាត្រា ៥៤៤.– សិទ្ធិទាមទារឱ្យបន្ថយថ្លៃលក់របស់អ្នកទិញ

ក្នុងករណីវត្ថុដែលត្រូវបានប្រគល់មានវិការៈ ទោះបីជាថ្លៃលក់ត្រូវបានបង់រួចហើយក៏ដោយ ឬមិនទាន់បង់ក៏ដោយ ក៏អ្នកទិញអាចទាមទារបន្ថយថ្លៃលក់នោះ តាមសមាមាត្រនៃ

ភាពខុសគ្នានៅពេលប្រគល់រវាងតម្លៃនៃវត្ថុដែលគ្មានវិការៈ និង តម្លៃនៃវត្ថុដែលត្រូវបានប្រគល់បានដែរ ។ ប៉ុន្តែ ក្នុងករណីដែលអ្នកលក់ជួសជុលវិការៈនោះដោយស្របទៅតាមមាត្រា ៥៤២ (សិទ្ធិទាមទារឱ្យអនុវត្តពេញលេញរបស់អ្នកទិញ) នៃក្រមនេះ ឬ ករណីដែលអ្នកទិញមិនព្រមទទួលសេចក្តីស្នើផ្តល់ការជួសជុលរបស់អ្នកលក់ដោយគ្មានមូលហេតុត្រឹមត្រូវ នោះអ្នកទិញមិនអាចទាមទារឱ្យបន្ថយថ្លៃលក់បានឡើយ ។

មាត្រា ៥៤៥.- សិទ្ធិទាមទារសំណងនៃការខូចខាតរបស់អ្នកទិញ

អ្នកទិញមិនត្រូវបានរារាំងក្នុងការទាមទារសំណងនៃការខូចខាតដោយស្របទៅតាមបញ្ញត្តិនៃផ្នែកទី ៣ (សំណងនៃការខូចខាត)ជំពូកទី ៤ នៃគន្ថីទី ៤ដោយមិនអនុវត្ត ឬ ដោយអនុវត្តព្រមគ្នានូវសិទ្ធិដែលបានកំណត់នៅក្នុងបញ្ញត្តិពីមាត្រា ៥៤២ (សិទ្ធិទាមទារឱ្យអនុវត្តពេញលេញរបស់អ្នកទិញ) ដល់មាត្រា ៥៤៤ (សិទ្ធិទាមទារឱ្យបន្ថយថ្លៃលក់របស់អ្នកទិញ) នៃក្រមនេះទេ ។

មាត្រា ៥៤៦.- បញ្ញត្តិពិសេសស្តីពីដីដែលមានទំហំខ្វះ ឬ លើស

១-ចំពោះដីដែលបានកំណត់ជាក់លាក់ណាមួយ ក្នុងករណីដែលការលក់ទិញត្រូវបានធ្វើឡើងដោយបញ្ជាក់ទំហំ និង កំណត់នូវតម្លៃតាមខ្នាតដីច្បាស់លាស់ តែតាមការពិតទំហំដីដែលមាននោះមិនគ្រប់នឹងទំហំដែលបានបញ្ជាក់ អ្នកទិញអាចទាមទារឱ្យអ្នកលក់ផ្តល់តាវកាលិកនូវផ្នែកដែលខ្វះ ឬ បន្ថយនូវតម្លៃដីនោះទៅតាមទំហំដីដែលខ្វះ ឬរំលាយកិច្ចសន្យា និង ទាមទារសំណងនៃការខូចខាត តាមបញ្ញត្តិពីមាត្រា ៥៤២ (សិទ្ធិទាមទារឱ្យអនុវត្តពេញលេញរបស់អ្នកទិញ) ដល់មាត្រា ៥៤៥ (សិទ្ធិទាមទារសំណងនៃការខូចខាតរបស់អ្នកទិញ) នៃក្រមនេះបានលើកលែងតែមានការព្រមព្រៀងផ្សេងរវាងភាគី ។

២-ចំពោះដីដែលបានកំណត់ជាក់លាក់ណាមួយ ក្នុងករណីដែលការលក់ទិញត្រូវបានធ្វើឡើងដោយបញ្ជាក់ទំហំ និង កំណត់នូវតម្លៃ តាមខ្នាតដីច្បាស់លាស់ តែតាមការពិតទំហំដីដែលមាននោះលើសពីទំហំដែលបានបញ្ជាក់ អ្នកលក់ដែលមិនបានដឹងអំពីការលើសទំហំនោះ ហើយគ្មានកំហុសក្នុងការមិនបានដឹងនោះ អាចទាមទារឱ្យអ្នកទិញបន្ថែមតម្លៃដីដែលលើសនោះបាន លើកលែងតែមានការព្រមព្រៀងផ្សេងរវាងភាគី ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង

ក៩/០៣

៣-ចំពោះដីដែលបានកំណត់ជាក់លាក់ណាមួយ ក្នុងករណីដែលការលក់ទិញត្រូវបានធ្វើឡើងដោយបញ្ជាក់ទំហំ និង កំណត់តែតម្លៃដីទាំងមូល ទោះបីជាទំហំដីនោះមិនគ្រប់នឹងទំហំដែលបានបញ្ជាក់ក៏ដោយ ក៏អ្នកទិញមិនអាចទាមទារឱ្យអ្នកលក់ផ្តល់តាវកាលិកនូវផ្នែកដែលខ្វះ ឬ បន្ថយនូវតម្លៃដីនោះទៅតាមទំហំដីដែលខ្វះ ឬ រំលាយកិច្ចសន្យា ឬ ទាមទារសំណងនៃការខូចខាតបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកលក់បានដឹងអំពីការខ្វះទំហំដីនោះ ឬ ករណីដែលអ្នកលក់បានធានានូវទំហំដីនោះ ឬ ករណីដែលទំហំខ្វះនោះច្រើនជាង ១ ភាគ ២០ (មួយភាគម្ភៃ) ។

៤-ចំពោះដីដែលបានកំណត់ជាក់លាក់ណាមួយ ក្នុងករណីដែលការលក់ទិញត្រូវបានធ្វើឡើងដោយបញ្ជាក់ទំហំ និង កំណត់តែតម្លៃដីទាំងមូល ទោះបីជាតាមការពិតទំហំដីដែលមាននោះលើសពីទំហំដែលបានបញ្ជាក់ក៏ដោយ ក៏អ្នកលក់មិនអាចទាមទារឱ្យអ្នកទិញបន្ថែមតម្លៃដីបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលទំហំលើសនោះច្រើនជាង ១ ភាគ ២០ (មួយភាគម្ភៃ) ហើយអ្នកលក់មិនបានដឹងអំពីការលើសទំហំ និង ពុំមានកំហុសក្នុងការមិនបានដឹងនោះ ។

៥-ក្នុងករណីដែលអ្នកលក់ទាមទារបន្ថែមតម្លៃ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ ឬ កថាខណ្ឌទី ៤ នៃមាត្រានេះ អ្នកទិញអាចរំលាយកិច្ចសន្យាបាន ។

មាត្រា ៥៤៧.- អំឡុងពេលដែលអាចអនុវត្តសិទ្ធិ

១-សិទ្ធិដែលបានកំណត់ក្នុងមាត្រា ៥៤២ (សិទ្ធិទាមទារឱ្យអនុវត្តពេញលេញរបស់អ្នកទិញ) ដល់មាត្រា ៥៤៤ (សិទ្ធិទាមទារឱ្យបន្ថយថ្លៃលក់របស់អ្នកទិញ) និងមាត្រា ៥៤៦ (បញ្ញត្តិពិសេសស្តីពីដីដែលមានទំហំខ្វះ ឬ លើស) នៃក្រមនេះ ត្រូវអនុវត្តនៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ។ ប៉ុន្តែ ចំពោះសិទ្ធិទាមទារសំណងនៃការខូចខាតដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង វាក្យខណ្ឌទី ២ កថាខណ្ឌទី ៣ នៃមាត្រា ៥៤៦ (បញ្ញត្តិពិសេសស្តីពីដីដែលមានទំហំខ្វះ ឬ លើស) ត្រូវអនុលោមតាមបញ្ញត្តិនៃមាត្រា ៤៨២ (អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទូទៅ) នៃក្រមនេះ ។

២-អំឡុងពេលដែលបានកំណត់ក្នុងវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះត្រូវគិត

ចាប់តាំងពីពេលដែលអ្នកទិញបានដឹង ឬ គួរបានដឹងអំពីវិការៈ និង ការខូចខាតរីឯអ្នកលក់វិញត្រូវគិតចាប់តាំងពីពេលធ្វើកិច្ចសន្យា ។

មាត្រា ៥៤៨.- កិច្ចសន្យាពិសេសដែលអនុគ្រោះ ឬ កម្រិតនូវការទទួលខុសត្រូវក្នុងការធានាវិការៈ

ទោះបីជាមានការព្រមព្រៀងអនុគ្រោះ ឬ កម្រិតនូវការទទួលខុសត្រូវក្នុងការធានាវិការៈដែលអ្នកលក់ត្រូវមាន តាមបញ្ញត្តិនៃមាត្រា ៥៤០ (ការទទួលខុសត្រូវក្នុងការធានាវិការៈ) នៃក្រមនេះ ក៏ដោយ ចំពោះវិការៈដែលអ្នកលក់បានដឹងតែមិនបានប្រាប់ទេ ក៏អ្នកលក់នេះមិនអាចលើកការព្រមព្រៀងអនុគ្រោះ ឬ កម្រិតនូវការទទួលខុសត្រូវនោះមកអះអាងបានឡើយ ។

មាត្រា ៥៤៩.- ករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុ

១-អ្នកលក់ត្រូវមានករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុទៅឱ្យអ្នកទិញ តាមកាលបរិច្ឆេទ និង តាមទីកន្លែងដែលបានកំណត់នៅក្នុងកិច្ចសន្យា ។

២-ក្នុងករណីដែលកំណត់តែពេលត្រូវបង់ថ្លៃលក់ប៉ុណ្ណោះ នោះត្រូវសន្មតថា ពេលកំណត់នៃការប្រគល់វត្ថុដែលជាកម្មវត្ថុ ក៏ដូចពេលកំណត់នៃការបង់ថ្លៃលក់ដែរ ។

៣-ក្នុងករណីដែលមិនបានកំណត់កាលបរិច្ឆេទដែលត្រូវប្រគល់ផង មិនបានកំណត់កាលបរិច្ឆេទដែលត្រូវបង់ថ្លៃលក់ផង អ្នកលក់មានករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុទៅឱ្យអ្នកទិញ នៅពេលដែលអ្នកទិញទាមទារឱ្យប្រគល់ ។

៤-ក្នុងករណីដែលមិនបានកំណត់ទីកន្លែងដែលត្រូវប្រគល់ទេ ចំពោះការលក់វត្ថុដែលបានកំណត់ជាក់លាក់ អ្នកលក់ត្រូវប្រគល់វត្ថុដែលជាកម្មវត្ថុនៅទីកន្លែងដែលវត្ថុនោះស្ថិតនៅនៅពេលធ្វើកិច្ចសន្យា និង ចំពោះករណីក្រៅពីនេះ ត្រូវប្រគល់វត្ថុដែលជាកម្មវត្ថុនោះនៅលំនៅឋានរបស់អ្នកទិញ ។

៥-អ្នកលក់ត្រូវចេញសោហ៊ុយសម្រាប់ប្រគល់ លើកលែងតែមានការព្រមព្រៀងគ្នាពិសេស ។ ប៉ុន្តែ ប្រសិនបើសោហ៊ុយប្រគល់នោះកើនឡើងដោយសារអ្នកទិញបានប្តូរលំនៅឋានឬដោយសារហេតុពីអ្វីមួយរបស់អ្នកទិញ អ្នកទិញត្រូវទទួលបន្ទុកបង់នូវចំនួនកំណើននៃសោហ៊ុយនោះ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

មាត្រា ៥៥០.- វិធីប្រគល់

ការប្រគល់វត្ថុត្រូវធ្វើឡើងតាមវិធីប្រគល់កម្មវត្ថុដោយជាក់ស្តែង វិធីប្រគល់ដោយសង្ខេប វិធីផ្ទេរការកាន់កាប់ដោយបញ្ជា ឬ វិធីប្តូរលក្ខណៈនៃការកាន់កាប់តាមបញ្ញត្តិនៃមាត្រា ២២៩ (ការផ្ទេរការកាន់កាប់) នៃក្រមនេះ ។ ការប្រគល់អចលនវត្ថុអាចធ្វើឡើងបាន ដោយការប្រគល់សោនៃអគារ ឬ ប្រគល់ប័ណ្ណបញ្ជាក់សិទ្ធិ ។

មាត្រា ៥៥១.- សិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា និង សិទ្ធិតវ៉ាដោយមានការបារម្ភ

១-អ្នកលក់អាចប្រកែកមិនព្រមផ្ទេរសិទ្ធិដែលជាកម្មវត្ថុ និង មិនព្រមប្រគល់វត្ថុ ដែលជាកម្មវត្ថុទៅអ្នកទិញបាន រហូតដល់ពេលដែលអ្នកទិញបានផ្តល់ការសង ចំពោះកាតព្វកិច្ចបង់ថ្លៃលក់ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកាតព្វកិច្ចរបស់អ្នកទិញនោះ ពុំទាន់ដល់ពេលកំណត់ត្រូវសង ឬ ករណីដែលមានការព្រមព្រៀងគ្នាអំពីការអនុវត្តករណីយកិច្ចផ្ទេរសិទ្ធិ ឬ កាតព្វកិច្ចប្រគល់ជាមុន ។

២-ទោះបីជាអ្នកលក់បានអនុញ្ញាតឱ្យអ្នកទិញមានពេលកំណត់ដើម្បីសងថ្លៃកម្មវត្ថុក៏ដោយ ប្រសិនបើអ្នកទិញបានក្ស័យធន ឬ បានក្លាយទៅជាមានកង្វះនូវទ្រព្យធន ក្រោយពេលធ្វើកិច្ចសន្យាលក់ទិញ ឬ បានលាក់នូវកង្វះនៃទ្រព្យធន មុនពេលធ្វើកិច្ចសន្យា ក៏អ្នកលក់អាចប្រកែកមិនផ្ទេរសិទ្ធិ និង មិនប្រគល់កម្មវត្ថុនោះបានដែរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកទិញបានដាក់ប្រាតិភោគ ឬ ចាត់ចែងវិធានការដើម្បីរំលត់ការបារម្ភនោះ ។

មាត្រា ៥៥២.- ករណីយកិច្ចរក្សាទុកវត្ថុដែលជាកម្មវត្ថុ

១-អ្នកលក់វត្ថុដែលបានកំណត់ជាក់លាក់ ត្រូវរក្សាទុកវត្ថុនោះដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ រហូតដល់ពេលប្រគល់វត្ថុនោះទៅអ្នកទិញ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះវត្ថុដែលមិនកំណត់ក្រោយពីបានកំណត់វត្ថុនោះជាក់លាក់ហើយ ។

២-ក្នុងករណីដែលអ្នកលក់បានធ្វើឱ្យបាត់បង់ ឬ ធ្វើឱ្យខូចខាតវត្ថុដែលជាកម្មវត្ថុដោយសារខ្លួនធ្វេសប្រហែសមិនបានគោរពករណីយកិច្ចត្រូវប្រុងប្រយ័ត្នដែលបានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើនេះ អ្នកលក់ត្រូវទទួលខុសត្រូវចំពោះអ្នកទិញតាមកិច្ចសន្យា និង បញ្ញត្តិនៃ

MINISTÈRE DU PALAIS ROYAL

1/454

ផ្នែកទី ៣ (សំណងនៃការខូចខាត) ជំពូកទី ៤ គន្ថីទី ៤ នៃក្រមនេះ ។

មាត្រា ៥៥៣.- សិទ្ធិទទួលផល

ក្នុងករណីដែលកម្មវត្ថុនៃការលក់បានបង្កើតផលធម្មជាតិមុនពេលប្រគល់ទៅអ្នកទិញ ផលនេះត្រូវទុកជាកម្មសិទ្ធិរបស់អ្នកលក់ លើកលែងតែមានការព្រមព្រៀងគ្នាពិសេសរវាងគូភាគី ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកម្មវត្ថុនៃការលក់បង្កើតផលស៊ីវិលដូចជាថ្លៃឈ្នួល ជាអាទិ៍ ។

កថាភាគទី ២
ករណីយកិច្ចរបស់អ្នកទិញ

មាត្រា ៥៥៤.- ករណីយកិច្ចទូទៅរបស់អ្នកទិញ

អ្នកទិញត្រូវមានករណីយកិច្ចបង់ថ្លៃជាប្រាក់ដែលសន្យា និង ករណីយកិច្ចទទួលវត្ថុដែលខ្លួនបានទិញ ។

មាត្រា ៥៥៥.- ករណីយកិច្ចបង់ថ្លៃទិញ

១-អ្នកទិញមានករណីយកិច្ចបង់ថ្លៃទិញជាប្រាក់ដែលបានកំណត់ក្នុងកិច្ចសន្យាតាមកាលបរិច្ឆេទ និង នៅទីកន្លែងដែលបានកំណត់ក្នុងកិច្ចសន្យា ។

២-ក្នុងករណីនៃការលក់ចលនវត្ថុដែលមានតែកំណត់ពេលនៃការប្រគល់ចលនវត្ថុដែលជាកម្មវត្ថុនៃការលក់ប៉ុណ្ណោះ ឬ ក្នុងករណីនៃការលក់អចលនវត្ថុដែលមានតែកំណត់ពេលនៃការធ្វើសកម្មភាពចាំបាច់ដើម្បីចុះបញ្ជីអចលនវត្ថុដែលជាកម្មវត្ថុនៃការលក់ប៉ុណ្ណោះ នោះត្រូវសន្មតថា ពេលកំណត់នៃការបង់ថ្លៃទិញ ក៏ដូចពេលកំណត់នៃការប្រគល់ ឬ ការធ្វើសកម្មភាពចាំបាច់ដើម្បីចុះបញ្ជីដែរ។

៣-ក្នុងករណីដែលមិនបានកំណត់ពេលប្រគល់ចលនវត្ថុដែលជាកម្មវត្ថុ ឬ ពេលធ្វើសកម្មភាពចាំបាច់ដើម្បីចុះបញ្ជីអចលនវត្ថុដែលជាកម្មវត្ថុផង មិនបានកំណត់ពេលបង់ថ្លៃផង អ្នកទិញមានករណីយកិច្ចបង់ថ្លៃទៅអ្នកលក់ នៅពេលដែលអ្នកលក់ទាមទារឱ្យអ្នកទិញបង់ ។

៤-ក្នុងករណីដែលមិនបានកំណត់ទីកន្លែងដែលត្រូវបង់ថ្លៃទិញនៅក្នុងកិច្ចសន្យាទេប្រសិន

262/442

បើការបង់ថ្លៃត្រូវធ្វើព្រមគ្នានឹងការប្រគល់ចលនវត្ថុដែលជាកម្មវត្ថុ ឬ ព្រមគ្នានឹងការធ្វើសកម្មភាពចាំបាច់ដើម្បីចុះបញ្ជីអចលនវត្ថុដែលជាកម្មវត្ថុនោះ អ្នកទិញត្រូវបង់ថ្លៃនៅទីកន្លែងដែលអ្នកលក់ត្រូវប្រគល់ចលនវត្ថុដែលជាកម្មវត្ថុ ឬ ត្រូវធ្វើសកម្មភាពចាំបាច់ ដើម្បីចុះបញ្ជីអចលនវត្ថុដែលជាកម្មវត្ថុ ។

មាត្រា ៥៥៦.- ការប្រាក់នៃថ្លៃទិញ និង ប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវ

អ្នកទិញមិនចាំបាច់ត្រូវបង់ការប្រាក់នៃថ្លៃទិញ ឬ ប្រាក់សំណងនៃការខូចខាត ដោយសារការយឺតយ៉ាវរហូតដល់ពេលដែលវត្ថុដែលជាកម្មវត្ថុត្រូវបានប្រគល់ឡើយ ។

មាត្រា ៥៥៧.- សិទ្ធិបដិសេធមិនបង់ថ្លៃទិញ ក្នុងករណីដែលតតិយជនអះអាងសិទ្ធិរបស់ខ្លួនលើវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ

១-ក្នុងករណីដែលមានអ្នកអះអាងសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ ហើយមានការបារម្ភថា អ្នកទិញនឹងបាត់បង់នូវសិទ្ធិទាំងអស់ ឬ មួយភាគដែលខ្លួនបានទិញនោះ អ្នកទិញអាចបដិសេធមិនបង់ថ្លៃទិញទាំងអស់ ឬ មួយភាគ ទៅតាមទំហំនៃហានិភ័យនោះបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកលក់បានដាក់ប្រាតិភោគសមរម្យ ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកលក់អាចទាមទារឱ្យអ្នកទិញតម្កល់ថ្លៃទិញបាន ។

មាត្រា ៥៥៨.- សិទ្ធិតទាំឱ្យអនុវត្តព្រមគ្នា និង សិទ្ធិតទាំដោយមានការបារម្ភ

១-អ្នកទិញអាចមិនព្រមបង់ថ្លៃទិញបាន រហូតដល់ពេលដែលអ្នកលក់បានផ្តល់នូវការសងចំពោះកាតព្វកិច្ចរបស់ខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលកាតព្វកិច្ចរបស់អ្នកលក់មិនទាន់ដល់ពេលកំណត់ត្រូវសង ឬ ករណីដែលមានការព្រមព្រៀងគ្នាអំពីការអនុវត្តកាតព្វកិច្ចបង់ថ្លៃជាមុន ។

២-ទោះបីជាអ្នកទិញបានអនុញ្ញាតឱ្យអ្នកលក់មានពេលកំណត់ដើម្បីអនុវត្តកាតព្វកិច្ចក៏ដោយ ប្រសិនបើមានការបារម្ភយ៉ាងជាក់ស្តែងថា អ្នកលក់នឹងមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនក៏, អ្នកទិញអាចប្រកែកមិនបង់ថ្លៃទិញបានដែរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះ

ROYAUME DU CAMBODGE · LE MINISTÈRE DU PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង

(តទៅរាជកិច្ច លេខ ០៤

/446

ករណីដែលអ្នកលក់បានដាក់ប្រាតិភោគ ឬ ចាត់ចែងវិធានការដើម្បីរំលត់ការ ធារម្ភនោះ ។

មាត្រា ៥៥៩.– ការយឺតយ៉ាវក្នុងការបំពេញករណីយកិច្ចទទួល

១-ក្នុងករណីដែលអ្នកទិញមានការយឺតយ៉ាវក្នុងការបំពេញករណីយកិច្ចទទួល អ្នកលក់អាចទាមទារសំណងនៃការខូចខាត ឬ រំលាយកិច្ចសន្យា តាមបញ្ញត្តិនៃផ្នែកទី ៣ (សំណងនៃការខូចខាត) និងផ្នែកទី ៤(ការរំលាយកិច្ចសន្យា) ជំពូកទី ៤ នៃគន្ថីទី ៤ បាន ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើវត្ថុដែលជាកម្មវត្ថុ ត្រូវបានបាត់បង់ ឬ ខូចខាត ដោយគ្មានកំហុសរបស់អ្នកលក់ អ្នកទិញត្រូវទទួលបន្ទុកហានិភ័យនោះ ។

៣-ក្នុងករណីដែលអ្នកលក់បានផ្តល់នូវការសង តែអ្នកទិញនៅតែមិនព្រមទទួលវត្ថុដែលជាកម្មវត្ថុ អ្នកលក់អាចតម្កល់ ឬ លក់វត្ថុដែលជាកម្មវត្ថុនោះ តាមបញ្ញត្តិនៃមាត្រា ៤៥៧ (ការតម្កល់) និងមាត្រា ៤៥៨ (សិទ្ធិលក់ដោយខ្លួនឯង) នៃក្រមនេះបាន ។

ផ្នែកទី ៤

ការរំលាយកិច្ចសន្យាលក់ទិញដោយអនុវត្តសិទ្ធិលោះ

មាត្រា ៥៦០.– ការសន្យាពិសេសនៃការលោះ

អ្នកលក់អាចរំលាយកិច្ចសន្យាលក់ទិញ ដោយសងប្រាក់ដែលអ្នកទិញបានបង់ និង សងសោហ៊ុយដែលបានកំណត់ក្នុងមាត្រា ៥៦៣ (វិធីអនុវត្តសិទ្ធិលោះ) នៃក្រមនេះ បានដោយផ្អែកលើការសន្យាពិសេសនៃសិទ្ធិលោះដែលបានកំណត់ច្បាស់លាស់ នៅក្នុងលិខិតនៃកិច្ចសន្យា ។

មាត្រា ៥៦១.– អំឡុងពេលនៃការលោះ

១-អំឡុងពេលនៃការលោះ ចំពោះអចលនវត្ថុ គឺមិនអាចឱ្យលើសពី ៥(ប្រាំ) ឆ្នាំបានទេ ចំណែកឯចលនវត្ថុវិញ គឺមិនអាចឱ្យលើសពី ២ (ពីរ) ឆ្នាំ បានទេ ។ ប្រសិនបើបានកំណត់អំឡុងពេលវែងជាងនេះ ត្រូវតែបន្ថយកំណត់នោះដោយស្វ័យប្រវត្តិមកត្រឹម ៥ (ប្រាំ) ឆ្នាំ ចំពោះអចលនវត្ថុ ហើយមកត្រឹម ២ (ពីរ) ឆ្នាំ វិញ ចំពោះចលនវត្ថុ ។

២-ក្នុងករណីដែលគូភាគីបានកំណត់នូវអំឡុងពេលសម្រាប់ការលោះរួចហើយ គូភាគី

ROYAUME DU CAMBODGE LE MINISTERE DU PALAIS ROYAL

1359

នោះមិនអាចពន្យារអំឡុងពេលថែមទៀតបានឡើយ ។

៣-ក្នុងករណីដែលមិនបានកំណត់អំឡុងពេលសម្រាប់ការលោះទេ អ្នកលក់ត្រូវអនុវត្តសិទ្ធិលោះនោះនៅក្នុងអំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

មាត្រា ៥៦២.- ការតតាំងនៃការសន្យាពិសេសនៃការលោះ ជាអាទិ៍

១-អ្នកទិញអាចអនុវត្តសិទ្ធិទាំងឡាយក្នុងនាមជាកម្មសិទ្ធិករ ។ ប៉ុន្តែ ក្នុងករណីដែលការអនុវត្តសិទ្ធិនោះ ផ្ទុយនឹងអត្ថន័យនៃការសន្យាពិសេសនៃការលោះ អ្នកទិញត្រូវទទួលខុសត្រូវក្នុងការមិនអនុវត្តកាតព្វកិច្ចចំពោះអ្នកលក់ ។

២-ការសន្យាពិសេសនៃការលោះនឹងមានអានុភាពចំពោះតតិយជន លុះត្រាតែការសន្យាពិសេសនោះត្រូវបានចុះបញ្ជីព្រមគ្នានឹងកិច្ចសន្យាលក់ទិញ ។

មាត្រា ៥៦៣.- វិធីអនុវត្តសិទ្ធិលោះ

១-អ្នកលក់ត្រូវបង់ថ្លៃលក់ និង បង់សោហ៊ុយក្នុងការធ្វើកិច្ចសន្យា ក្នុងអំឡុងពេលដែលបានកំណត់ ដើម្បីលោះវិញ ។

២-ក្នុងករណីដែលអ្នកទិញ ឬ អ្នកទទួលបន្តវត្ថុពីអ្នកទិញ បានចេញចំណាយសោហ៊ុយចំពោះវត្ថុដែលជាកម្មវត្ថុ អ្នកលក់ត្រូវសងទៅវិញនូវចំណាយជាចាំបាច់សម្រាប់គ្រប់គ្រង និងថែរក្សាវត្ថុទាំងអស់ រីឯការចំណាយបង្កើនតម្លៃវិញ អ្នកលក់ត្រូវសងទៅអ្នកទិញវិញនូវសោហ៊ុយដែលអ្នកទិញ ឬ អ្នកទទួលបន្តវត្ថុពីអ្នកទិញបានចេញ ឬ តម្លៃប្រាក់ ដែលកើននោះទៅតាមការជ្រើសរើសរបស់អ្នកលក់ ក្នុងកម្រិតដែលកំណើនតម្លៃនោះនៅតែមាន ។

មាត្រា ៥៦៤.- ការលក់វត្ថុដែលជាកម្មសិទ្ធិអវិភាគ ដោយមានការសន្យាពិសេសនៃការលោះ

១-ក្នុងករណីដែលម្ចាស់កម្មសិទ្ធិអវិភាគ បានលក់វត្ថុរួមទាំងមូលដោយមានការសន្យាពិសេសនៃការលោះ តាមកិច្ចសន្យាតែមួយ ហើយបុគ្គលម្នាក់ក្នុងចំណោមម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់បានទាមទារឱ្យលោះវត្ថុមួយភាគដែលជាកម្មសិទ្ធិរបស់ខ្លួន ឬ វត្ថុទាំងមូល នោះអ្នកទិញមិនចាំបាច់យល់ព្រមក៏បានដែរ ។

២-ប្រសិនបើម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់ បានលក់ភាគដែលជាកម្មសិទ្ធិរបស់ខ្លួនម្នាក់ៗ

ទៅអ្នកទិញតែម្នាក់ តាមកិច្ចសន្យាដោយឡែក ដោយមានការសន្យាពិសេសនៃការលោះវិញ ម្ចាស់កម្មសិទ្ធិអវិភាគនីមួយៗនោះអាចលោះមកវិញនូវភាគដែលជាកម្មសិទ្ធិរបស់ខ្លួនបាន ។

មាត្រា ៥៦៥.- អានុភាពនៃការមិនអនុវត្តសិទ្ធិលោះ

ប្រសិនបើអ្នកលក់មិនអនុវត្តសិទ្ធិលោះក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងមាត្រា ៥៦១ (អំឡុងពេលនៃការលោះ) នៃក្រមនេះទេ សិទ្ធិលោះត្រូវរលត់ ហើយកម្មសិទ្ធិរបស់អ្នកទិញនឹងក្លាយជាស្ថាពរ ។

ជំពូកទី ២

ការដូរ

មាត្រា ៥៦៦.- អត្ថន័យ

ការដូរ ត្រូវមានអានុភាព តាមការសន្យាដែលភាគីទាំងសងខាងធ្វើការផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិ ក្រៅពីប្រាក់ទៅវិញទៅមក ។

មាត្រា ៥៦៧.- ការយកបញ្ញត្តិនៃការលក់ទិញមកអនុវត្តដូចគ្នា

បញ្ញត្តិស្តីអំពីការលក់ទិញ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះការដូរ ។

ជំពូកទី ៣

ប្រទានកម្ម

មាត្រា ៥៦៨.- និយមន័យ

ប្រទានកម្ម សំដៅទៅលើកិច្ចសន្យាមួយដែលត្រូវមានអានុភាព ដោយភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ទៅឱ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិដោយមិនយកថ្លៃ ហើយភាគីម្ខាងទៀតយល់ព្រមទទួល ។

មាត្រា ៥៦៩.- ការផ្ទេរកម្មសិទ្ធិ

ការផ្ទេរកម្មសិទ្ធិនៃវត្ថុដែលជាកម្មវត្ថុ នៅក្នុងកិច្ចសន្យាប្រទានកម្ម ត្រូវអនុលោមតាមគោលការណ៍ទូទៅដែលកំណត់នៅក្នុងមាត្រា ១៣៣ (ការបង្កើត ការផ្ទេរ និង ការកែប្រែនូវ

សិទ្ធិប្រត្យក្ស ដោយការព្រមព្រៀង) មាត្រា ១៣៤ (ល័ក្ខខ័ណ្ឌតតាំងនៃការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស) មាត្រា ១៣៥ (ល័ក្ខខ័ណ្ឌដើម្បីបង្កើតអានុភាពនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង) មាត្រា ១៦០ (លទ្ធកម្មនៃកម្មសិទ្ធិ លើអចលនវត្ថុ) និង មាត្រា ១៨៧(លទ្ធកម្មនៃកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ ។

មាត្រា ៥៧០.- ប្រទានកម្មដែលមិនធ្វើជាលាយល័ក្ខណ៍អក្សរ

ទោះបីជាបានធ្វើការសន្យាប្រទានកម្មក៏ដោយ ប្រសិនបើមិនបានធ្វើជាលាយល័ក្ខណ៍អក្សរស្តីអំពីប្រទានកម្មទេ ភាគីនៃកិច្ចសន្យាអាចលុបចោលកិច្ចសន្យា ដោយដកការបង្ហាញឆន្ទៈនៃការធ្វើប្រទានកម្មវិញបាន ។ ប៉ុន្តែ ចំពោះផ្នែកដែលបានអនុវត្តហើយមិនអាចដកការបង្ហាញឆន្ទៈនៃការធ្វើប្រទានកម្មវិញបានឡើយ ។

មាត្រា ៥៧១.- ការលុបចោលប្រទានកម្មដោយសារអំពើរំលោភលើទំនុកចិត្ត ជាអាទិ៍

១-ក្នុងករណីដែលបដិគ្គាហកបានធ្វើអំពើរំលោភលើទំនុកចិត្តធ្ងន់ធ្ងរចំពោះទាយក ទាយកអាចលុបចោលប្រទានកម្មបាន ។

២-ចំពោះផ្នែកដែលបានអនុវត្តហើយ ការលុបចោលប្រទានកម្មដែលកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចធ្វើបានតែក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលមានអំពើរំលោភលើទំនុកចិត្តធ្ងន់ធ្ងរនោះ ។

មាត្រា ៥៧២.- ការលុបចោលប្រទានកម្មដោយសារភាពទីទ័លក្ររបស់ទាយក

១-ប្រសិនបើទាយកធ្លាក់ខ្លួនក្នុងស្ថានភាពទីទ័លក្រ មិនអាចរក្សាជីវភាពរស់នៅរបស់ខ្លួនផ្ទាល់ និង បុគ្គលដែលត្រូវមានអាហារកាតព្វកិច្ច ក្រោយពីបានបង្ហាញឆន្ទៈធ្វើប្រទានកម្មហើយទាយកអាចលុបប្រទានកម្មនោះចោលបាន ។

២-ចំពោះផ្នែកដែលបានអនុវត្តហើយ ការលុបចោលប្រទានកម្មដែលកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចធ្វើបានតែក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលមានអំពើនោះ ។

មាត្រា ៥៧៣.- អានុភាពនៃការលុបចោលប្រទានកម្ម

ក្នុងករណីដែលបានលុបចោលប្រទានកម្មតាមបញ្ញត្តិនៃមាត្រា ៥៧១ (ការលុបចោលប្រទានកម្មដោយសារអំពើរំលោភលើទំនុកចិត្តជាអាទិ៍) និងមាត្រា ៥៧២ (ការលុបចោលប្រទាន-កម្មដោយសារភាពទីទ័លក្រូរបស់ទាយក) ខាងលើនេះ ទាយកអាចទាមទារឱ្យសងទ្រព្យសម្បត្តិដែលបានធ្វើប្រទានកម្មនោះ ដោយផ្អែកតាមបញ្ញត្តិស្តីពីការសងនៃសេចក្តីចម្រើនដោយឥតហេតុបាន ។

មាត្រា ៥៧៤.- ការបន្ថយនូវការទទួលខុសត្រូវក្នុងការធានា

ទាយក ពុំមានបន្ទុកទទួលខុសត្រូវក្នុងការធានា ចំពោះវិការៈ ឬ ការខ្វះវត្ថុ ឬ សិទ្ធិដែលជាកម្មវត្ថុនៃប្រទានកម្មឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ បើទាយកបានដឹងអំពីវិការៈ ឬ ការខ្វះនោះហើយ តែមិនបានផ្តល់ដំណឹងទៅបដិគ្គាហក ។

មាត្រា ៥៧៥.- ប្រទានកម្មដោយមានកំណត់ពេល

ប្រទានកម្មដែលធ្វើឡើងក្នុងគោលបំណងផ្តល់តាវកាលិកដោយមានកំណត់ពេលត្រូវបាត់បង់អានុភាព ដោយមរណភាពរបស់ទាយក ឬ បដិគ្គាហក ។

មាត្រា ៥៧៦.- ប្រទានកម្មដែលមានភ្ជាប់បន្ទុក

១-ប្រទានកម្ម ដែលបដិគ្គាហកមានករណីយកិច្ចត្រូវអនុវត្តការផ្តល់តាវកាលិកជាកំណត់ដើម្បីទទួលទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃប្រទានកម្ម ត្រូវហៅថា ប្រទានកម្មដែលមានភ្ជាប់បន្ទុក ។

២-នៅក្នុងប្រទានកម្មដែលមានភ្ជាប់បន្ទុក ទាយកត្រូវទទួលខុសត្រូវលើប្រាតិភោគដូចគ្នានឹងអ្នកលក់ផងដែរ ត្រឹមកម្រិតនៃបន្ទុកនោះ ។

៣-ក្នុងករណីដែលភាគីម្ខាងបានធ្វើការផ្តល់តាវកាលិក នៅក្នុងប្រទានកម្មដែលមានភ្ជាប់បន្ទុក បុគ្គលនោះអាចទាមទារ ចំពោះភាគីម្ខាងទៀតឱ្យផ្តល់តាវកាលិកបាន ។

៤-នៅក្នុងប្រទានកម្មដែលមានភ្ជាប់បន្ទុក បើគ្មានកិច្ចសន្យាពិសេសទេ លុះត្រាតែភាគីម្ខាងទៀតបានធ្វើការផ្តល់តាវកាលិកទេ ទើបភាគីម្ខាងទៀតនៃកិច្ចសន្យាអាចមិនផ្តល់តាវកាលិក

08/455

របស់ខ្លួនបាន ។

៥-ទាយកនៃប្រទានកម្មដែលមានភ្ជាប់បន្ទុក អាចរំលាយកិច្ចសន្យាប្រទានកម្មដែលមានភ្ជាប់បន្ទុកនោះ តាមបញ្ញត្តិនៃការរំលាយកិច្ចសន្យាបាន នៅក្នុងករណីដែលភាគីម្ខាងទៀតមិនបានអនុវត្តបន្ទុក ។

មាត្រា ៥៧៧.- ប្រទានកម្មដោយមូលហេតុមរណភាព

១-ប្រទានកម្មដែលបង្កើតអានុភាពដោយមរណភាពរបស់ទាយក ត្រូវហៅថាប្រទាន-កម្មដោយមូលហេតុមរណភាព ។

២-បញ្ញត្តិនៃអច្ច័យទានត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអានុភាពនៃប្រទាន-កម្មដោយមូលហេតុមរណភាព ។

ជំពូកទី ៤
ការខ្ចីបរិភោគ

ផ្នែកទី ១
និយមន័យ និង ការបង្កើតកិច្ចសន្យាខ្ចីបរិភោគ

មាត្រា ៥៧៨.- និយមន័យនៃការខ្ចីបរិភោគ

ការខ្ចីបរិភោគ សំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាង ហៅថាអ្នកឱ្យខ្ចីមានករណីយកិច្ចប្រគល់ការប្រើប្រាស់ដោយសេរី នូវប្រាក់ ស្បៀងអាហារ ឬវត្ថុជំនួសផ្សេងទៀត ក្នុងអំឡុងពេលដែលមានកំណត់ឱ្យទៅភាគីម្ខាងទៀត ហៅថាអ្នកខ្ចី ហើយនៅក្រោយពេលដែលអំឡុងពេលនោះបានកន្លងផុត អ្នកខ្ចីមានករណីយកិច្ចសងទៅឱ្យអ្នកឱ្យខ្ចីវិញនូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួនស្មើគ្នានឹងវត្ថុដែលបានទទួលពីអ្នកឱ្យខ្ចីនោះ ។

មាត្រា ៥៧៩.- ការបង្កើតកិច្ចសន្យាខ្ចីបរិភោគ

កិច្ចសន្យាខ្ចីបរិភោគត្រូវបង្កើតឡើង ដោយការព្រមព្រៀងរវាងអ្នកឱ្យខ្ចី និង អ្នកខ្ចីតែ

ROYAUME DU CAMBODGE LE MINISTRE

មាត្រា ៥៨០.- ការដកកិច្ចសន្យាខ្ចីបរិភោគមិនយកការប្រាក់ដែលមិនធ្វើជាលិខិតលាយលក្ខណ៍អក្សរ

ចំពោះកិច្ចសន្យាខ្ចីបរិភោគមិនយកការប្រាក់ដែលមិនធ្វើជាលិខិតលាយលក្ខណ៍អក្សរ ភាគីនីមួយៗនៃកិច្ចសន្យា អាចដកកិច្ចសន្យានោះនៅពេលណាក៏បាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះផ្នែកនៃវត្ថុដែលជាកម្មវត្ថុដែលអ្នកឱ្យខ្ចីបានប្រគល់ហើយ ។

មាត្រា ៥៨១.- ការរំលាយដោយការធ្លាក់ចុះនូវទំនុកចិត្តចំពោះអ្នកខ្ចី

១-នៅក្នុងចន្លោះពេលដែលកិច្ចសន្យាបានបង្កើតឡើង រហូតទៅដល់ពេលប្រគល់វត្ថុដែលជាកម្មវត្ថុ ប្រសិនបើស្ថានភាពសេដ្ឋកិច្ចរបស់អ្នកខ្ចី ធ្លាក់ចុះយ៉ាងខ្លាំងដែលនឹងធ្វើឱ្យមានឧបសគ្គដល់ការអនុវត្តកាតព្វកិច្ចសង អ្នកឱ្យខ្ចីអាចរំលាយកិច្ចសន្យាខ្ចីបរិភោគបាន ។

២-បើអ្នកឱ្យខ្ចីបានរំលាយកិច្ចសន្យាដោយផ្អែកតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ នៅក្នុងករណីដែលបានទទួលការប្រាក់កម្រៃជើងសារ ឬ តម្លៃថ្នូរផ្សេងទៀតជាមុនអ្នកឱ្យខ្ចីនោះ ត្រូវសងទៅឱ្យអ្នកខ្ចីវិញ ។

មាត្រា ៥៨២.- ឧបសន្យានៃការខ្ចីបរិភោគ

១-បុគ្គលដែលមានករណីយកិច្ចផ្តល់តាវកាលិកជាប្រាក់ ឬ វត្ថុជំនួសផ្សេងទៀតដោយមូលហេតុក្រៅអំពីការខ្ចីបរិភោគ ប្រសិនបើបានព្រមព្រៀងជាមួយម្ចាស់បំណុលថាយកវត្ថុនោះធ្វើជាកម្មវត្ថុនៃការខ្ចីបរិភោគ ការខ្ចីបរិភោគត្រូវបានបង្កើតឡើងដោយការព្រមព្រៀងនេះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រាតិភោគសម្រាប់កាតព្វកិច្ចចាស់ ត្រូវបានសន្មតថា ត្រូវក្លាយទៅជាប្រាតិភោគសម្រាប់កាតព្វកិច្ចថ្មី ។

ផ្នែកទី ២

ការខ្ចីបរិភោគដោយភ្ជាប់ការប្រាក់

មាត្រា ៥៨៣.- សិទ្ធិលើបំណុលដែលជាការប្រាក់

១-ការប្រាក់ សំដៅទៅលើចំនួនទឹកប្រាក់ ឬ វត្ថុផ្សេងទៀត ដែលត្រូវបានផ្តល់ទៅឱ្យតាមសមាមាត្រនៃអំឡុងពេលនៃការប្រើប្រាស់ ក្នុងនាមជាតម្លៃតបចំពោះការប្រើប្រាស់ប្រាក់

ឬ វត្ថុ ដែលត្រូវបានប្រគល់ឱ្យអ្នកខ្ចី ហើយដែលត្រូវគណនាដោយយកចំនួនទឹកប្រាក់ ឬ វត្ថុ ដែលបានខ្ចី មកគុណជាមួយនឹងអត្រាដែលត្រូវបានកំណត់ ។

២-នៅក្នុងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ វត្ថុដែលត្រូវបានប្រគល់ឱ្យអ្នកខ្ចីហៅថា ប្រាក់ដើម ភាគដែលបានកំណត់ ដែលត្រូវបានដាក់ចូលទៅក្នុងចំនួនទឹកប្រាក់នៃប្រាក់ដើម ហៅថាអត្រាការប្រាក់ ។

៣-ភាគីនៃកិច្ចសន្យាខ្ចីបរិភោគ អាចយកកម្មវត្ថុនៃការសងការប្រាក់មកបង្កើតជាសិទ្ធិលើបំណុលតាមការព្រមព្រៀងបាន ។ ប៉ុន្តែ ចំពោះការព្រមព្រៀងបង្កើតសិទ្ធិលើបំណុលនៃការប្រាក់ ប្រសិនបើពុំបានធ្វើតាមលិខិតជាលាយលក្ខណ៍អក្សរ ដោយមានចុះហត្ថលេខារបស់អ្នកខ្ចីទេ ពុំមានអានុភាពឡើយ ។

៤-នៅក្នុងការព្រមព្រៀងបង្កើតសិទ្ធិលើបំណុលនៃការប្រាក់ ដោយមិនយោលតាមលិខិតជាលាយលក្ខណ៍អក្សរ ដែលមានចុះហត្ថលេខារបស់អ្នកខ្ចី ប្រសិនបើអ្នកខ្ចីបានសងដោយដឹងអំពីការអនុវត្តបញ្ញត្តិវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ៣ ខាងលើនេះ ការសងមានអានុភាពត្រឹមកម្រិតដែលត្រូវបានសងនោះតែប៉ុណ្ណោះ ។

មាត្រា ៥៨៤.- អត្រាការប្រាក់ដែលកំណត់ដោយច្បាប់ និង អត្រាការប្រាក់ក្នុងកិច្ចសន្យា

១-អត្រាការប្រាក់ អាចកំណត់បានតាមបញ្ញត្តិច្បាប់ ឬ ដោយការព្រមព្រៀងរបស់ភាគី ។

២-ក្នុងករណីដែលត្រូវបង់ការប្រាក់ តាមការព្រមព្រៀងរវាងភាគី ឬ បញ្ញត្តិច្បាប់ ប្រសិនបើភាគីពុំបានកំណត់អំពីអត្រាការប្រាក់ទេនោះ ត្រូវអនុលោមតាមអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ដែលបញ្ញត្តនៅក្នុងក្រមនេះ ឬ ច្បាប់ពិសេស ។

៣-អត្រាការប្រាក់ដែលកំណត់តាមការព្រមព្រៀងរបស់ភាគី ហើយដែលហួសអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ពុំមានអានុភាពឡើយ បើពុំបានកំណត់តាមលិខិតជាលាយលក្ខណ៍អក្សរ យោងតាមរូបមន្តដែលកំណត់ក្នុងកថាខណ្ឌទី ៣ មាត្រា ៥៨៣ (សិទ្ធិលើបំណុលដែលជាការប្រាក់) ខាងលើទេ ។

មាត្រា ៥៨៥.- ការកម្រិតការប្រាក់

១-អត្រាការប្រាក់ដែលត្រូវបានកម្រិត សំដៅទៅលើអត្រាការប្រាក់អតិបរមាដែលអាច

កំណត់បានដោយស្របច្បាប់ តាមការព្រមព្រៀងរបស់ភាគី ដែលកំណត់ដោយច្បាប់ និង បរ
ដ្ឋានគតិយុត្តផ្សេងទៀត ។

២-ភាគីអាចកំណត់ការប្រាក់ខ្ពស់ជាងអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ដែលបា បញ្ញត្តក្នុងកថាខណ្ឌទី ២ នៃមាត្រា ៥៨៤ (អត្រាការប្រាក់ដែលកំណត់ដោយច្បាប់ និង អត្រាក ប្រាក់ក្នុងកិច្ចសន្យា) ខាងលើនេះបានតែមិនអាចកំណត់លើសពីអត្រាការប្រាក់ដែលត្រូវបាន កម្រិតបានឡើយ ។

៣-ប្រសិនបើភាគីបានកំណត់អត្រាការប្រាក់លើសពីអត្រាការប្រាក់ដែលត្រូវបានកម្រិ កិច្ចសន្យានៃភាគដែលលើសពីកម្រិតនៃអត្រាការប្រាក់នោះ ត្រូវទុកជាមោឃៈរីឯអ្នកខ្ចីមា ករណីយកិច្ចសងតែចំពោះការប្រាក់ដែលត្រូវបានគណនា តាមអត្រាការប្រាក់ដែលត្រូវបា កម្រិតនោះ តែប៉ុណ្ណោះ ។

៤-នៅក្នុងករណីដែលបានសងការប្រាក់ដែលលើសពីអត្រាការប្រាក់ដែលត្រូវបាន កម្រិតហើយ ត្រូវចាត់ទុកថាភាគដែលលើសពីការកម្រិតនោះ ជាការកាត់បំណុលទៅលើប្រាក់ ដើម ។ នៅក្នុងករណីដែលបានកាត់បំណុលទៅលើប្រាក់ដើម ចំពោះផ្នែកដែលលើសពីការ កម្រិតហើយ តែនៅមានសេសសល់ទៀត អ្នកឱ្យខ្ចីត្រូវសងទៅឱ្យអ្នកខ្ចី ដោយភ្ជាប់ជាមួយនូវ ប្រាក់សំណងនៃការខូចខាត ដោយគណនាតាមអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ដោយ គិតចាប់ពីថ្ងៃដែលបានបង្កើតឱ្យមានការសេសសល់នៃការសងរហូតដល់ថ្ងៃដែលបានសងនោះ ។

៥-ចំពោះការអនុវត្តមាត្រានេះ នៅក្នុងករណីដែលចំនួនប្រាក់ដើមលើកិច្ចសន្យាខុស គ្នាពីចំនួនទឹកប្រាក់នៃវត្ថុដែលអ្នកឱ្យខ្ចីបានប្រគល់ដោយជាក់ស្តែង ដូចជាករណីនៃការប្រគល់ ប្រាក់ដើមដោយដកការប្រាក់ដែលត្រូវបង់នាពេលអនាគត ជាអាទិ៍ ចំនួនទឹកប្រាក់នៃវត្ថុដែល អ្នកឱ្យខ្ចីបានប្រគល់ដោយជាក់ស្តែងទៅឱ្យអ្នកខ្ចីនោះ ត្រូវទុកជាចំនួនប្រាក់ដើម ។

៦-ចំពោះការអនុវត្តមាត្រានេះ ប្រាក់ និង វត្ថុផ្សេងទៀត ដែលអ្នកឱ្យខ្ចីបានទទួល ក្រៅពី ប្រាក់ដើម ទាក់ទងទៅនឹងកិច្ចសន្យាខ្ចីបរិភោគ ទោះបីជាបានទទួលនៅក្នុងនាមជាប្រាក់រង្វាន់ កម្រៃជើងសារ កម្រៃស៊ើបអង្កេត និង កម្រៃផ្សេងៗទៀតក៏ដោយ ត្រូវចាត់ទុកថាជាការប្រាក់ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសោហ៊ុយនៃការធ្វើកិច្ចសន្យា និងសោហ៊ុយ ចែក[illegible] ។

មាត្រា ៥៨៦.- ពេលវេលានៃការបង់ការប្រាក់ និង ការប្រាក់សមាសដែលកំណត់ដោយច្បាប់

១-បើគ្មានការកំណត់ពិសេសទេ ការប្រាក់ត្រូវបង់នៅរៀងរាល់ពេលដែលពេលវេលា ១ (មួយ) ឆ្នាំ បានកន្លងផុត គិតចាប់ពីពេលដែលបានប្រគល់វត្ថុដែលជាកម្មវត្ថុ ។ ប៉ុន្តែ ប្រសិនបើត្រូវសងវត្ថុដែលជាកម្មវត្ថុនោះ នៅមុនពេលដែលពេលវេលា ១ (មួយ) ឆ្នាំ មិនទាន់បានកន្លងផុត ត្រូវបង់ការប្រាក់នៅពេលប្រគល់វត្ថុដែលជាកម្មវត្ថុនោះ ។

២-ក្នុងករណីដែលមានការយឺតយ៉ាវមិនបានសងការប្រាក់ សម្រាប់រយៈពេលចាប់ពី ១ (មួយ) ឆ្នាំ ឡើងទៅ ហើយទោះបីជាអ្នកឱ្យខ្ចីបានដាស់តឿនឱ្យសងយ៉ាងណាក៏ដោយ ក៏អ្នកខ្ចីមិនព្រមសងការប្រាក់នោះ អ្នកឱ្យខ្ចីអាចបូកការប្រាក់បញ្ចូលទៅក្នុងប្រាក់ដើមបាន ។

ផ្នែកទី ៣
ករណីយកិច្ចឱ្យខ្ចីរបស់អ្នកឱ្យខ្ចី

មាត្រា ៥៨៧.- ករណីយកិច្ចឱ្យខ្ចីវត្ថុដែលជាកម្មវត្ថុ

១-អ្នកឱ្យខ្ចី មានករណីយកិច្ចឱ្យអ្នកខ្ចីប្រើប្រាស់វត្ថុ ដោយសមស្របតាមកិច្ចសន្យា ។

២-អ្នកខ្ចី អាចប្រើប្រាស់ អាស្រ័យផល និង ចាត់ចែងវត្ថុ ដោយសេរីបាន ហើយត្រូវទទួលបន្ទុកហានិភ័យ លើការបាត់បង់ ឬ ខូចខាត ចំពោះវត្ថុដែលជាកម្មវត្ថុដែលកើតឡើងដោយសារមូលហេតុដែលមិនមែនជាបន្ទុករបស់អ្នកឱ្យខ្ចី ក្នុងនាមជាកម្មសិទ្ធិករ គិតចាប់ពីថ្ងៃដែលបានទទួលការប្រគល់វត្ថុដែលជាកម្មវត្ថុ ។

មាត្រា ៥៨៨.- ការទទួលខុសត្រូវក្នុងការធានារបស់អ្នកឱ្យខ្ចី ក្នុងការប្រគល់វត្ថុរបស់អ្នកដទៃ

១-នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ អ្នកឱ្យខ្ចីដែលបានប្រគល់វត្ថុដែលមិនស្ថិតនៅក្រោមកម្មសិទ្ធិរបស់ខ្លួន មានករណីយកិច្ចត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិនៃវត្ថុនោះ ហើយផ្ទេរទៅឱ្យអ្នកខ្ចី ឬ ត្រូវប្តូរជាមួយនឹងវត្ថុផ្សេងទៀតដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់ខ្លួន ។ ប៉ុន្តែ នៅក្រោយពេលដែលអ្នកខ្ចីបានបរិភោគវត្ថុនោះរួចហើយពុំអាចទាមទារឱ្យប្រគល់វត្ថុជំនួសបានឡើយ ។

២-ប្រសិនបើអ្នកឱ្យខ្ចី ពុំអាចអនុវត្តកាតព្វកិច្ចដែលបានបញ្ញត្តក្នុងកថាខណ្ឌទី ១ ខាង

លើនេះទេ អ្នកខ្ចីអាចរំលាយកិច្ចសន្យាបាន ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ប្រសិនបើបានទទួលការប្រគល់ដោយពុំបានដឹងថាអ្នកឱ្យខ្ចីនោះគ្មានសិទ្ធិ អ្នកខ្ចីអាចទាមទារឱ្យអ្នកឱ្យខ្ចីសងសំណងនៃការខូចខាតបាន ។

៤-នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដោយគ្មានការប្រាក់ បញ្ញត្តិនៃកថាខណ្ឌទី ១ ទី ២ និង ទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះតែករណីដែលអ្នកឱ្យខ្ចីបានដឹងថាខ្លួនគ្មានសិទ្ធិចាត់ចែងវត្ថុដែលជាកម្មវត្ថុ ហើយបានប្រគល់វត្ថុរបស់អ្នកដទៃនោះ ដោយពុំបានជូនដំណឹងទៅឱ្យអ្នកខ្ចី ។

៥-លើកលែងតែករណីដែលបានទទួលការប្រគល់វត្ថុជំនួស ដោយផ្អែកតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ៤ ខាងលើនេះ ប្រសិនបើអ្នកខ្ចីវត្ថុរបស់អ្នកដទៃ បានសងវត្ថុដែលត្រូវបានផ្តល់ ឬ តម្លៃនៃវត្ថុនោះឱ្យទៅកម្មសិទ្ធិករ អ្នកខ្ចីវត្ថុរបស់អ្នកដទៃនោះ ត្រូវរួចផុតពីភារណីយកិច្ចសងចំពោះអ្នកឱ្យខ្ចី ។

មាត្រា ៥៨៩.- សិទ្ធិរំលាយរបស់អ្នកឱ្យខ្ចីវត្ថុអ្នកដទៃ

អ្នកឱ្យខ្ចីដែលបានប្រគល់វត្ថុដែលជាកម្មវត្ថុ ដោយពុំដឹងថាជាវត្ថុរបស់អ្នកដទៃ ប្រសិនបើពុំអាចធ្វើឱ្យអ្នកខ្ចីបានលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុ ឬ វត្ថុជំនួសទេ អាចរំលាយកិច្ចសន្យាបាន ។ ប៉ុន្តែ ប្រសិនបើអ្នកខ្ចីសុចរិត មានសិទ្ធិទាមទារសំណងនៃការខូចខាត ដោយផ្អែកតាមបញ្ញត្តិនៃមាត្រា ៥៨៨ (ការទទួលខុសត្រូវក្នុងការធានារបស់អ្នកឱ្យខ្ចីក្នុងការប្រគល់វត្ថុរបស់អ្នកដទៃ) ខាងលើនេះ លុះត្រាតែក្នុងករណីដែលបានសងសំណងនៃការខូចខាតនោះ ទើបអាចរំលាយកិច្ចសន្យាបាន ។

មាត្រា ៥៩០.- ការទទួលខុសត្រូវក្នុងការធានារបស់អ្នកឱ្យខ្ចីនូវវត្ថុដែលមានវិការៈ

១-នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ ប្រសិនបើមានវិការៈកំបាំងនៅក្នុងវត្ថុដែលអ្នកឱ្យខ្ចីបានប្រគល់ អ្នកខ្ចីដែលបានទទួលការប្រគល់ដោយមិនបានដឹងអំពីវិការៈនោះ អាចទាមទារឱ្យប្តូរជាមួយនឹងវត្ថុដែលគ្មានវិការៈ និង អាចទាមទារសំណងនៃការខូចខាតបាន ។

២-នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលគ្មានការប្រាក់ អ្នកខ្ចីដែលបានទទួលការប្រគល់វត្ថុដែលមានវិការៈ អាចសងតម្លៃនៃវត្ថុដែលមានវិការៈបាន ។ ប៉ុន្តែ បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកឱ្យខ្ចីបានដឹងអំពីវិការៈនោះហើយ តែពុំបានជូនដំណឹងទៅឱ្យអ្នកខ្ចី ។

ផ្នែកទី ៤
ករណីយកិច្ចសងរបស់អ្នកខ្ចី

មាត្រា ៥៩១.- ករណីយកិច្ចត្រូវសងប្រាក់ដើម និង បង់ការប្រាក់របស់អ្នកខ្ចី

១-អ្នកខ្ចី មានករណីយកិច្ចត្រូវសងទៅអ្នកឱ្យខ្ចី នូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួនស្មើគ្នានឹងវត្ថុដែលបានទទួលការប្រគល់ នៅថ្ងៃដែលត្រូវសង ។

២-អ្នកខ្ចីនៃកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ ត្រូវបង់ការប្រាក់តាមបញ្ញត្តិពីមាត្រា ៥៨៤ (អត្រាការប្រាក់ដែលកំណត់ដោយច្បាប់ និង អត្រាការប្រាក់ក្នុងកិច្ចសន្យា) ដល់មាត្រា ៥៨៦ (ពេលវេលានៃការបង់ការប្រាក់ និង ការប្រាក់សមាសដែលកំណត់ដោយច្បាប់) នៃក្រមនេះ ។

មាត្រា ៥៩២.- ការសងដោយយោលតាមតម្លៃ

១-ប្រសិនបើពុំអាចសងដោយផ្អែកតាមបញ្ញត្តិនៃមាត្រា ៥៩១ (ករណីយកិច្ចត្រូវសងប្រាក់ដើម និង បង់ការប្រាក់របស់អ្នកខ្ចី) ខាងលើបានទេ អ្នកខ្ចីមានករណីយកិច្ចត្រូវបង់ប្រាក់ដែលសមរម្យនឹងតម្លៃនៃវត្ថុដែលជាកម្មវត្ថុ នៅទីកន្លែង និង ថ្ងៃដែលត្រូវសង ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើពុំបានកំណត់ថ្ងៃ ឬ ទីកន្លែងដែលត្រូវសងទេ ត្រូវចាត់ទុកថាត្រូវបង់ចំនួនប្រាក់ដែលសមរម្យនឹងតម្លៃនោះនៅថ្ងៃ និង ទីកន្លែងដែលបានធ្វើកិច្ចសន្យា ។

មាត្រា ៥៩៣.- ការប្រែប្រួលនៃតម្លៃរូបិយវត្ថុ ជាអាទិ៍

ទោះបីជាតម្លៃរូបិយវត្ថុ ឬ តម្លៃនៃវត្ថុ មានការប្រែប្រួល នៅមុនពេលសងក៏ដោយ លើកលែងតែក្នុងករណីដែលមានការព្រមព្រៀងពិសេស អ្នកខ្ចីត្រូវសងនូវចំនួនទឹកប្រាក់ដូចគ្នានឹង

ចំនួនទឹកប្រាក់ដែលទទួលបានពីការប្រគល់ ។

មាត្រា ៥៩៤.– ពេលវេលានៃការសង

១-ប្រសិនបើភាគីបានកំណត់កាលបរិច្ឆេទនៃការសង អ្នកឱ្យខ្ចីមិនអាចទាមទារឱ្យសងវត្ថុដែលជាកម្មវត្ថុបានឡើយ រហូតដល់ពេលកំណត់ត្រូវសង តាមកាលបរិច្ឆេទនៃកិច្ចសន្យា ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលហេតុដែលបានកំណត់នៅក្នុងមាត្រា ៣៣១ (ការបាត់បង់ផលប្រយោជន៍នៃការកំណត់ពេល) នៃក្រមនេះ បានកើតឡើង ។

២-ប្រសិនបើភាគីមិនបានកំណត់កាលបរិច្ឆេទនៃការសងទេ អ្នកឱ្យខ្ចីអាចដាស់តឿនឱ្យសង ដោយកំណត់អំឡុងពេលសមរម្យបាន ។

៣-អ្នកខ្ចីនៃកិច្ចសន្យាខ្ចីបរិភោគដោយគ្មានការប្រាក់អាចសងនៅពេលណាក៏បាន ។

៤-អ្នកខ្ចីនៃកិច្ចសន្យាខ្ចីបរិភោគដែលមានការប្រាក់ អាចសងនៅមុនកាលបរិច្ឆេទសងដែលបានកំណត់ដោយកិច្ចសន្យាបាន ។ ប៉ុន្តែ នៅក្នុងករណីដែលធ្វើឱ្យមានការខូចខាតដល់អ្នកឱ្យខ្ចីដោយសារការសងនោះ អ្នកខ្ចីត្រូវសងសំណងនៃការខូចខាត ដោយផ្អែកតាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៣០ (ប្រយោជន៍នៃការកំណត់ពេល) នៃក្រមនេះ ។

មាត្រា ៥៩៥.– ទីកន្លែងនៃការសង

ប្រសិនបើពុំមានការព្រមព្រៀងរវាងភាគី អំពីទីកន្លែងនៃការសងទេ អ្នកខ្ចីត្រូវយកវត្ថុដែលជាកម្មវត្ថុនោះ ទៅសងនៅលំនៅឋានរបស់អ្នកឱ្យខ្ចី ។

ជំពូកទី ៥

គតិសន្យា

ផ្នែកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ៥៩៦.– និយមន័យនៃគតិសន្យា

១-គតិសន្យា សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាងឱ្យភាគីម្ខាងទៀតប្រើប្រាស់ និង អាស្រ័យផលពីវត្ថុណាមួយដោយយកថ្លៃ ។

២-វត្ថុដែលជាកម្មវត្ថុនៃភតិសន្យាមានចលនវត្ថុ និង អចលនវត្ថុ ។

មាត្រា ៥៩៧.- ការបង្កើតភតិសន្យា

ភតិសន្យា ត្រូវមានអានុភាព ដោយភាគីម្ខាង សន្យាថាឱ្យភាគីម្ខាងទៀតប្រើប្រាស់ និង អាស្រ័យផលពីវត្ថុណាមួយ ចំណែកឯភាគីម្ខាងទៀតសន្យាថាបង់ថ្លៃឈ្នួលចំពោះវត្ថុនោះ ។

មាត្រា ៥៩៨.- លក្ខខណ្ឌតតាំងនៃសិទ្ធិជួលអចលនវត្ថុ

១-ដោយយោងតាមលទ្ធកម្មនៃការកាន់កាប់ និង ការប្រើប្រាស់និងអាស្រ័យផលជាបន្តបន្ទាប់នូវវត្ថុជួល ភតិកៈនៃភតិសន្យាអចលនវត្ថុ អាចតតាំងចំពោះជនដែលបានធ្វើលទ្ធកម្មនូវសិទ្ធិប្រត្យក្សលើអចលនវត្ថុ នៅក្រោយពេលដែលភតិកៈបានទទួលការកាន់កាប់បាន ។

២-ភតិកៈដែលកំពុងតែកាន់កាប់វត្ថុជួល អាចអនុវត្តសិទ្ធិទាមទារឱ្យប្រគល់វិញ សិទ្ធិទាមទារឱ្យបញ្ឈប់ការរារាំង និង សិទ្ធិទាមទារឱ្យបង្ការជាមុននូវការរារាំង ចំពោះការបំពានសិទ្ធិជួលដូចសិទ្ធិដែលកម្មសិទ្ធករមាន ។

មាត្រា ៥៩៩.- អំឡុងពេលដែលភតិសន្យាមានអត្ថិភាព

១-ភតិសន្យា អាចធ្វើឡើងដោយកំណត់ ឬ មិនកំណត់អំឡុងពេលបាន ។

២-ភតិសន្យាអចលនវត្ថុ ដែលមិនបានធ្វើជាលាយល័ក្ខណ៍អក្សរ ត្រូវចាត់ទុកថាជាភតិសន្យាដែលគ្មានកំណត់អំឡុងពេល ។

៣-ភតិសន្យាអចលនវត្ថុដែលមានកំណត់អំឡុងពេលចាប់ពី ១៥ (ដប់ប្រាំ) ឆ្នាំឡើងទៅ ត្រូវអនុលោមតាមបញ្ញត្តិចាប់ពីមាត្រា ២៤៤(និយមន័យនៃសិទ្ធិជួលអចិន្ត្រៃយ៍) ទៅនៃក្រមនេះ ។

ផ្នែកទី ២

អានុភាពនៃភតិសន្យា

មាត្រា ៦០០.- សិទ្ធិ និង ករណីយកិច្ចនៃការប្រើប្រាស់ និង អាស្រ័យផល ផ្អែកតាមវិធីប្រើប្រាស់របស់ភតិកៈ

១-ភតិកៈ មានសិទ្ធិ និង ករណីយកិច្ច លើការប្រើប្រាស់ និង អាស្រ័យផល លើវត្ថុជួល ដោយធ្វើតាមវិធីប្រើប្រាស់ ដែលត្រូវបានកំណត់នៅក្នុងកិច្ចសន្យា ឬ តាមលក្ខណៈនៃវត្ថុ

១៧/៤៦៦

ជួលនោះ ។

២-បើភតិកៈ បានធ្វើខុសនឹងករណីយកិច្ចនៃបញ្ញត្តិកថាខណ្ឌទី ១ ខាងលើនេះ ភតិបតី អាចរំលាយកិច្ចសន្យានោះបាន ។

៣-ភតិបតី មិនត្រូវធ្វើឱ្យរាំងស្ទះក្នុងការប្រើប្រាស់ និង អាស្រ័យផលដែលភតិកៈធ្វើ ដោយផ្អែកតាមវិធីប្រើប្រាស់ឡើយ ។

មាត្រា ៦០១.- ករណីយកិច្ចប្រុងប្រយ័ត្នក្នុងការគ្រប់គ្រងដោយសុចរិតរបស់ភតិកៈ

១-ភតិកៈ មានករណីយកិច្ចគ្រប់គ្រងវត្ថុជួល ដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

២-បើភតិកៈ បានធ្វើខុសនឹងករណីយកិច្ចនៃបញ្ញត្តិកថាខណ្ឌទី ១ ខាងលើនេះ ភតិបតី អាចរំលាយកិច្ចសន្យានោះបាន ។

មាត្រា ៦០២.- ករណីយកិច្ចជួសជុលរបស់ភតិបតី

ភតិបតី មានករណីយកិច្ចធ្វើការជួសជុលដែលចាំបាច់ សម្រាប់ការប្រើប្រាស់ និង អាស្រ័យផលនៃវត្ថុជួលនោះ ។

មាត្រា ៦០៣.- សកម្មភាពថែរក្សារបស់ភតិបតី

១-បើភតិបតី មានបំណងចង់អនុវត្តសកម្មភាពដែលចាំបាច់ក្នុងការថែរក្សាវត្ថុជួលភតិកៈ មិនអាចបដិសេធបានឡើយ ។

២-ក្នុងករណីដែលភតិបតីមានបំណងចង់អនុវត្តសកម្មភាពដែលចាំបាច់ក្នុងការថែរក្សាវត្ថុជួល ផ្ទុយពីឆន្ទៈរបស់ភតិកៈ ប្រសិនបើហេតុនោះ បណ្តាលឱ្យភតិកៈពុំអាចសម្រេចគោលបំណងនៃការជួលទេ ភតិកៈអាចទាមទារឱ្យបន្ថយថ្លៃឈ្នួល ឬ អាចរំលាយកិច្ចសន្យាបាន ។

មាត្រា ៦០៤.- សិទ្ធិទាមទារឱ្យសងវិញ នូវសោហ៊ុយរបស់ភតិកៈ

១-បើភតិកៈបានចំណាយសោហ៊ុយចាំបាច់ ដែលត្រូវជាបន្ទុករបស់ភតិបតី ចំពោះវត្ថុជួល ភតិកៈអាចទាមទារសំណងនោះពីភតិបតីជាបន្ទាន់បាន ។

២-បើភតិកៈ បានចំណាយសោហ៊ុយដើម្បីកែលំអវត្ថុជួល ឬ ចំណាយផ្សេងទៀត ដើម្បី

ROYAUME DU CAMBODGE
LE MINISTRE du PALAIS
21/456

បង្កើនតម្លៃ លុះត្រាតែនៅក្នុងករណីដែលកម្រិតនៃកំណើនតម្លៃនោះនៅតែមាន នាពេលបញ្ចប់ភតិសន្យាតែប៉ុណ្ណោះទេ ទើបភតិកៈអាចទាមទារចំពោះភតិបតី ឱ្យសងវិញនូវប្រាក់ដែលបានចំណាយ ឬ តម្លៃប្រាក់ដែលកើននោះ ដោយផ្អែកតាមការជ្រើសរើសរបស់ភតិបតីបាន ។ ប៉ុន្តែ តុលាការអាចអនុញ្ញាត ដោយកំណត់អំឡុងពេលសមរម្យ ឱ្យសងវិញ យោលតាមការទាមទាររបស់ភតិបតីបាន ។

មាត្រា ៦០៥.- ការទទួលខុសត្រូវរបស់ភតិបតី ចំពោះវិការៈនៃវត្ថុជួល

១-ប្រសិនបើភតិកៈមិនបានពិនិត្យស្ថានភាពនៃវត្ថុដែលជាកម្មវត្ថុនៃភតិសន្យាថា ត្រឹមត្រូវតាមស្ថានភាពដែលបានកំណត់នៅក្នុងលិខិតកិច្ចសន្យា នៅពេលទទួលការប្រគល់វត្ថុដែលជាកម្មវត្ថុនោះ ភតិកៈមិនអាចទាមទារឱ្យភតិបតីទទួលខុសត្រូវបានឡើយ ចំពោះភាពខុសពីស្ថានភាពដែលបានកំណត់នៅក្នុងលិខិតកិច្ចសន្យាដែលខ្លួនអាចដឹងដោយងាយស្រួលបើពិនិត្យ ។

២-នៅក្នុងករណីដែលវត្ថុជួលមានវិការៈកំបាំង បើភតិកៈមិនបានដឹងអំពីវិការៈនោះទេ ភតិកៈអាចទាមទារឱ្យជួសជុលវិការៈនោះ ឬ ឱ្យដូរវត្ថុដែលគ្មានវិការៈ និង អាចទាមទារសំណងនៃការខូចខាតបាន ។

៣-ភតិបតីអាចជួសជុលវិការៈ ដោយសោហ៊ុយខ្លួនបាន លុះត្រាតែមិនធ្វើឱ្យ មានការខូចខាតដោយមិនត្រឹមត្រូវនូវផលប្រយោជន៍របស់ភតិកៈ ។ ប៉ុន្តែ ភតិកៈមិនត្រូវបានរារាំងក្នុងការអនុវត្តសិទ្ធិទាមទារសំណងនៃការខូចខាតឡើយ ។

៤-ជំនួសនឹងការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ ភតិកៈអាចទាមទារឱ្យបន្ថយថ្លៃឈ្នួលដែលសមរម្យនឹងវិការៈបាន ដោយគិតតាំងពីពេលដែលបានប្រគល់ ។

៥-បើពុំអាចសម្រេចនូវគោលបំណងដែលបានធ្វើកិច្ចសន្យា ដោយសារមូលហេតុនៃវិការៈកំបាំងនោះទេ ភតិកៈអាចរំលាយភតិសន្យានោះបាន ។

៦-ការទាមទារឱ្យជួសជុល ឱ្យដូរ ឱ្យបន្ថយថ្លៃឈ្នួល និង ការរំលាយ ត្រូវអនុវត្តនៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលភតិកៈបានដឹង ឬ ពេលដែលត្រូវដឹងអំពីហេតុនោះបាន ។

ROYAUME DU CAMBODGE · LE MINISTRE DE ...

មាត្រា ៦០៦.- សិទ្ធិរំលាយ និង សិទ្ធិទាមទារឱ្យបន្ថយថ្លៃឈ្នួល នៅក្នុងករណីដែលចំណូលថយចុះ

១-បើភតិកៈនៃដីដែលមានគោលបំណងអាស្រ័យផលពីដី ទទួលផលបានតិចជាងថ្លៃឈ្នួលដោយសារករណីប្រធានសក្តិ ភតិកៈអាចទាមទារឱ្យបន្ថយថ្លៃឈ្នួល រហូតដល់ត្រឹមចំនួនទឹកប្រាក់នៃការអាស្រ័យផលនោះបាន ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ បើការទទួលផលបានតិចជាងថ្លៃឈ្នួល លើសពី ២ (ពីរ) ឆ្នាំ ជាបន្តបន្ទាប់ ដោយសារករណីប្រធានសក្តិភតិកៈអាចរំលាយភតិសន្យាបាន ។

មាត្រា ៦០៧.- សិទ្ធិរំលាយ និង សិទ្ធិទាមទារបន្ថយថ្លៃឈ្នួល ដោយសារការបាត់បង់ ឬ វិនាសវត្ថុជួលមួយភាគ

១-បើវត្ថុជួលមួយភាគត្រូវបានបាត់បង់ ឬវិនាស ដោយមិនមែនជាកំហុសរបស់ភតិកៈទេ ភតិកៈអាចទាមទារឱ្យបន្ថយថ្លៃឈ្នួលទៅតាមសមាមាត្រនៃភាគដែលត្រូវបានបាត់បង់ ឬវិនាសនោះបាន ។

២-ក្នុងករណីនៃកថាខណ្ឌទី ១ ខាងលើនេះ បើភតិកៈពុំអាចសម្រេចគោលបំណងដែលបានធ្វើកិច្ចសន្យាជួលទៅលើភាគដែលនៅសេសសល់នោះទេ ភតិកៈអាចរំលាយភតិសន្យាបាន ។

មាត្រា ៦០៨.- អនុប្បទានសិទ្ធិជួល និង ការជួលបន្តនូវវត្ថុជួល

១-បើគ្មានការយល់ព្រមពីភតិបតីទេ ភតិកៈពុំអាចធ្វើអនុប្បទានសិទ្ធិជួល ឬ ជួលបន្តនូវវត្ថុជួលបានឡើយ លើកលែងតែករណីនៃសិទ្ធិជួលអចិន្ត្រៃយ៍ ។

២-បើភតិកៈបានឱ្យតតិយជនប្រើប្រាស់ ឬ អាស្រ័យផលពីវត្ថុជួល ផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ភតិបតីអាចរំលាយកិច្ចសន្យាបាន ។

មាត្រា ៦០៩.- ការជួលបន្ត

១-បើភតិកៈបានជួលបន្ត នូវវត្ថុជួលដោយត្រឹមត្រូវតាមច្បាប់ ភតិកៈបន្តត្រូវមានករណីយកិច្ចដោយផ្ទាល់ ចំពោះភតិបតី ។ ចំពោះករណីយកិច្ចបង់ថ្លៃឈ្នួលជួលបន្ត ភតិកៈបន្តពុំអាចយកការបង់ថ្លៃជាមុនទៅឱ្យភតិកៈ មកតតាំងជាមួយភតិបតីបានឡើយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងដល់ការអនុវត្តសិទ្ធិរបស់ភតិបតីចំពោះភតិកៈឡើយ ។

មាត្រា ៦១០.- ករណីយកិច្ច និង ពេលវេលានៃការបង់ថ្លៃឈ្នួល

១-ភតិកៈ មានករណីយកិច្ចបង់ថ្លៃឈ្នួលទៅឱ្យភតិបតី ទៅតាមពេលវេលាដែលបានកំណត់ ។

២-នៅក្នុងករណីដែលមិនបានកំណត់ជាពិសេសនៅក្នុងកិច្ចសន្យា អំពីពេលវេលាដែលត្រូវបង់ថ្លៃឈ្នួលទេ ចំពោះចលនវត្ថុ និង ផ្ទះ ឬ អគារ ត្រូវបង់នៅរៀងរាល់ចុងខែ ចំពោះដីធ្លីវិញ ត្រូវបង់នៅរៀងរាល់ចុងឆ្នាំ ។ ប៉ុន្តែ ចំពោះវត្ថុដែលមានរដូវប្រមូលផល ត្រូវបង់នៅក្រោយពេលដែលរដូវនោះកន្លងផុត ដោយគ្មានការយឺតយ៉ាវ ។

មាត្រា ៦១១.- ករណីយកិច្ចជូនដំណឹងរបស់ភតិកៈ

បើមានការចាំបាច់លើការជួសជុលវត្ថុជួល ឬ បើមានតតិយជនអះអាងអំពីសិទ្ធិ ចំពោះវត្ថុជួលភតិកៈត្រូវជូនដំណឹងនោះទៅឱ្យភតិបតី ដោយគ្មានការយឺតយ៉ាវ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ បើភតិបតីបានដឹងអំពីហេតុនោះរួចហើយ ។

ផ្នែកទី ៣
ការបញ្ចប់ភតិសន្យា

មាត្រា ៦១២.- ការផុតអំឡុងពេលកំណត់

ភតិសន្យាដែលមានកំណត់អំឡុងពេល ត្រូវបញ្ចប់ដោយការផុតអំឡុងពេលដែលបានកំណត់នោះ ។

មាត្រា ៦១៣.- ការបដិសេធការបន្តជាថ្មី នូវភតិសន្យាអចលនវត្ថុ

ចំពោះភតិសន្យាអចលនវត្ថុ បើភាគីម្ខាងពុំបានបង្ហាញឆន្ទៈបដិសេធការបន្តជាថ្មីនៅមុនរយៈពេល ៣ (បី) ខែ មុនផុតកំណត់អំឡុងពេល ចំពោះផ្ទះ ឬ អគារ ឬ នៅមុនរយៈពេល ១ (មួយ) ឆ្នាំ មុនផុតកំណត់អំឡុងពេល ចំពោះដីធ្លីទៅភាគីម្ខាងទៀតទេ ត្រូវចាត់ទុកថាបាន

យល់ព្រមក្នុងការបន្តជាថ្មី ។ ប៉ុន្តែ ក្នុងករណីនេះ ភតិសន្យាដែលត្រូវបានបន្តជាថ្មីនេះ គឺជាភតិសន្យាដែលពុំមានកំណត់អំឡុងពេល ។

មាត្រា ៦១៤.– ការបន្តជាថ្មីដោយតុណ្ហីភាព

ចំពោះភតិសន្យាចលនវត្ថុ នៅក្នុងករណីដែលភតិកៈបានបន្តការប្រើប្រាស់ ឬ អាស្រ័យផលលើវត្ថុជួលនោះ ទោះនៅក្រោយអំឡុងពេលនៃភតិសន្យាបានផុតកំណត់ហើយក៏ដោយ បើភតិបតីបានដឹងអំពីហេតុនោះហើយ តែមិនបានធ្វើការតវ៉ាទេ ត្រូវសន្មតថាជាភតិសន្យាដែលបានបន្តជាថ្មី ដោយគ្មានកំណត់អំឡុងពេល ហើយមានល័ក្ខខ័ណ្ឌដូចគ្នានឹងកិច្ចសន្យាដែលបានជួលពីមុន លើកលែងតែអំឡុងពេលចេញ ។

មាត្រា ៦១៥.– ការស្នើសុំឱ្យរំលាយភតិសន្យាដែលពុំមានកំណត់អំឡុងពេល

១-បើពុំបានកំណត់អំឡុងពេលជួលនៅក្នុងកិច្ចសន្យាទេ ភាគីនីមួយៗអាចស្នើសុំឱ្យរំលាយកិច្ចសន្យា នៅពេលណាក៏បាន ។ ក្នុងករណីដែលការស្នើសុំឱ្យរំលាយមិនបានបញ្ជាក់អំពីពេលរលាយ និង ក្នុងករណីដែលអំឡុងពេលចាប់ពីពេលស្នើសុំឱ្យរំលាយ រហូតដល់ពេលរលាយដែលបានបញ្ជាក់នៅក្នុងការស្នើសុំឱ្យរំលាយនោះ តិចជាងអំឡុងពេលដូចបានកំណត់ខាងក្រោមនេះ ភតិសន្យាត្រូវរលាយ នៅពេលដែលអំឡុងពេលដូចបានកំណត់ខាងក្រោមនេះ បានកន្លងហួសគិតចាប់ពីពេលស្នើសុំឱ្យរំលាយ ៖

ក-១ (មួយ) ថ្ងៃ ចំពោះចលនវត្ថុ ។

ខ-៣ (បី) ខែ ចំពោះអគារ ។

គ-១ (មួយ) ឆ្នាំ ចំពោះដីធ្លី ។

២-ចំពោះភតិសន្យាដីធ្លីដែលមានរដូវប្រមូលផល ត្រូវធ្វើការស្នើសុំរំលាយកិច្ចសន្យា នៅក្រោយរដូវនោះ មុនការចាប់ផ្តើមការធ្វើកសិកម្មសម្រាប់រដូវបន្ទាប់ ។

មាត្រា ៦១៦.– ការរក្សាទុកសិទ្ធិរំលាយកិច្ចសន្យា

ទោះនៅក្នុងករណីដែលភាគីបានកំណត់អំឡុងពេលនៃភតិសន្យាក៏ដោយ បញ្ញត្តិនៃមាត្រា ៦១៥ (ការស្នើសុំឱ្យរំលាយភតិសន្យាដែលពុំមានកំណត់អំឡុងពេល) ខាងលើនេះ ត្រូវ

យកមកអនុវត្តដូចគ្នាផងដែរ បើភាគីតែម្ខាង ឬ ភាគីទាំងសងខាង បានរក្សាទុកនូវសិទ្ធិអំណាចអនុវត្តការរំលាយកិច្ចសន្យា នៅក្នុងអំឡុងពេលនោះ ។

មាត្រា ៦១៧.- ភាពគ្មានអានុភាពប្រតិសកម្មនៃការរំលាយកិច្ចសន្យា

នៅក្នុងករណីដែលបានរំលាយភតិសន្យា ការរំលាយកិច្ចសន្យានោះ ត្រូវមានអានុភាពឆ្ពោះទៅអនាគតតែប៉ុណ្ណោះ ។

មាត្រា ៦១៨.- ករណីយកិច្ចប្រគល់វត្ថុជួល

១-បើភតិសន្យាត្រូវបានបញ្ចប់ហើយ ភតិកៈមានករណីយកិច្ចធ្វើបដិទានវត្ថុជួលប្រគល់ទៅឱ្យភតិបតីវិញជាបន្ទាន់ ។

២-លើកលែងតែការពាក់បែក ខូចខាតដែលកើតឡើងដោយសារការប្រើប្រាស់ជាធម្មតា ភតិកៈត្រូវផ្ទុសផុលការខូចខាតដែលកើតឡើងដោយសារមូលហេតុជាបន្ទុករបស់ខ្លួនឡើងវិញ ឬ ត្រូវមានករណីយកិច្ចសងសំណងនៃការខូចខាតនោះ ។

មាត្រា ៦១៩.- សិទ្ធិរុះរើចេញរបស់ភតិកៈ

បើភតិសន្យាត្រូវបានបញ្ចប់ហើយ ភតិកៈអាចរុះរើចេញនូវវត្ថុដែលបានភ្ជាប់ជាមួយនឹងវត្ថុជួលនោះ បាន ។

មាត្រា ៦២០.- សិទ្ធិរំលាយកិច្ចសន្យារបស់សន្តតិជន នៅក្នុងករណីដែលភតិកៈទទួលមរណភាព

ប្រសិនបើគ្មានបំណងចង់បន្តភតិសន្យាតទៅទៀតទេ សន្តតិជនរបស់ភតិកៈ អាចរំលាយកិច្ចសន្យានោះបាន ។

មាត្រា ៦២១.- អំឡុងពេលប្រើសិទ្ធិទាមទារសំណងនៃការខូចខាត និង ការទាមទារឱ្យសងសោហ៊ុយមកវិញ

សំណងនៃការខូចខាតដែលកើតឡើងដោយសារភតិកៈក្នុងការប្រើប្រាស់ និង អាស្រ័យផលដែលផ្ទុយនឹងអត្ថន័យដើមនៃកិច្ចសន្យា និង ការសងមកវិញនូវសោហ៊ុយដែលភតិកៈបានចេញ ត្រូវទាមទារនៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលភតិបតីបានទទួលការប្រគល់វត្ថុជួលនោះ ។

ផ្នែកទី ៤
កិច្ចសន្យាប្រវាស់

មាត្រា ៦២២.- អត្ថន័យនៃកិច្ចសន្យាប្រវាស់

កិច្ចសន្យាដែលកម្មសិទ្ធិករឱ្យភតិកៈខ្ចីដី ឬ សត្វពាហនៈ ដើម្បីទាញយកផល ហើយយក ផលនោះ មកបែងចែកគ្នារវាងភតិបតី និង ភតិកៈ ហៅថា កិច្ចសន្យាប្រវាស់ ។

មាត្រា ៦២៣.- របៀបបែងចែកផល

បើពុំបានកំណត់អំពីរបៀបបែងចែកផលទេ ត្រូវចាត់ទុកថា ត្រូវបែងចែកស្មើៗភាគគ្នា ។

មាត្រា ៦២៤.- សិទ្ធិចាត់ចែងផល របស់ភតិកៈ

លុះត្រាតែនៅក្រោយពេលដែលបានបញ្ចប់ការចែកភាគនៃផលទៅឱ្យភតិបតីរួចហើយ ទើបភតិកៈនៃការប្រវាស់ អាចចាត់ចែងផលដែលជាចំណែករបស់ខ្លួនបាន ។

ជំពូកទី ៦
ការខ្ចីប្រើ

មាត្រា ៦២៥.- និយមន័យនៃការខ្ចីប្រើ

ការខ្ចីប្រើ សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាង ឱ្យភាគីម្ខាងទៀត ប្រើប្រាស់ និង អាស្រ័យផលនូវវត្ថុណាមួយ ដោយមិនឱ្យបង់ថ្លៃ ។

មាត្រា ៦២៦.- លក្ខខណ្ឌនៃការបង្កើតការខ្ចីប្រើ

កិច្ចសន្យាខ្ចីប្រើ ត្រូវមានអានុភាពដោយភាគីម្ខាង ទទួលយកវត្ថុណាមួយពីភាគីម្ខាងទៀត ហើយសន្យាថានឹងសងវត្ថុនោះ ក្រោយពីបានប្រើប្រាស់ និង អាស្រ័យផលដោយមិនបង់ថ្លៃ ។

មាត្រា ៦២៧.- ករណីយកិច្ចរបស់អ្នកខ្ចី នៅក្នុងការប្រើប្រាស់ និង អាស្រ័យផល

១-អ្នកខ្ចី ត្រូវរក្សាទុកវត្ថុខ្ចី ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

២-អ្នកខ្ចី ត្រូវប្រើប្រាស់ និង អាស្រ័យផលវត្ថុនោះ តាមកិច្ចសន្យា ឬ ដោយផ្អែកតាម

វិធីប្រើ ដែលត្រូវបានកំណត់តាមនិស្ស័យនៃវត្ថុដែលជាកម្មវត្ថុនោះ ។

៣-បើគ្មានការយល់ព្រមពីអ្នកឱ្យខ្ចីទេ អ្នកខ្ចីពុំអាចឱ្យតតិយជនប្រើប្រាស់ ឬ អាស្រ័យផល ពីវត្ថុខ្ចីនោះបានឡើយ ។

៤-ក្នុងករណីដែលអ្នកខ្ចីធ្វើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ទី ២ ឬ ទី ៣ ខាងលើនេះ អ្នកឱ្យខ្ចីអាចរំលាយកិច្ចសន្យាបាន ។

មាត្រា ៦២៨.- បន្ទុកលើសោហ៊ុយ

១-អ្នកខ្ចី ត្រូវទទួលបន្ទុកលើសោហ៊ុយចាំបាច់ធម្មតា នៃវត្ថុខ្ចី ។

២-ប្រសិនបើអ្នកខ្ចីបានចេញចំណាយសោហ៊ុយចាំបាច់លើការជួសជុលធំៗជាអាទិ៍ ក្រៅពីសោហ៊ុយចាំបាច់ធម្មតា ឬ បានចំណាយប្រាក់ដើម្បីកែលំអ ឬ ចំណាយផ្សេងដើម្បីបង្កើនតម្លៃ នៅពេលដែលការខ្ចីប្រើត្រូវបានបញ្ចប់ អ្នកខ្ចីអាចទាមទារចំពោះអ្នកឱ្យខ្ចី ឱ្យសងវិញនូវប្រាក់ដែលបានចំណាយ ឬ តម្លៃប្រាក់ដែលកើននោះ តាមការជ្រើសរើសរបស់អ្នកឱ្យខ្ចីក្នុងកម្រិតដែលកំណើនតម្លៃនោះនៅតែមាន ។ ប៉ុន្តែ តុលាការអាចអនុញ្ញាតឱ្យសងដោយកំណត់អំឡុងពេលសមរម្យ យោលតាមការទាមទាររបស់អ្នកឱ្យខ្ចីបាន ។

មាត្រា ៦២៩.- ការទទួលខុសត្រូវក្នុងការធានារបស់អ្នកឱ្យខ្ចី

អ្នកឱ្យខ្ចី ពុំទទួលខុសត្រូវក្នុងការធានា ចំពោះវិការៈនៃវត្ថុដែលជាកម្មវត្ថុនៃការខ្ចីប្រើ ឬ ការខ្វះសិទ្ធិទេ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ បើអ្នកឱ្យខ្ចីបានដឹងអំពីវិការៈ ឬ ការខ្វះសិទ្ធិនោះហើយ តែពុំបានជូនដំណឹងទៅអ្នកខ្ចី ។

មាត្រា ៦៣០.- ការបញ្ចប់ការខ្ចីប្រើ យោលតាមការផុតកំណត់អំឡុងពេល ឬ ចប់ការប្រើប្រាស់ និង អាស្រ័យផល

១-ការខ្ចីប្រើដែលមានកំណត់អំឡុងពេល ត្រូវបញ្ចប់ដោយការផុតកំណត់អំឡុងពេល ។

២-នៅក្នុងករណីដែលភាគីមិនបានកំណត់អំឡុងពេល ប្រសិនបើបានកំណត់អំពីគោលបំណងនៃការខ្ចីប្រើ ការខ្ចីប្រើនឹងត្រូវបញ្ចប់ នៅពេលដែលអ្នកខ្ចីបានបញ្ចប់ការប្រើប្រាស់ និង អាស្រ័យផលវត្ថុខ្ចី តាមគោលបំណងនោះ ។ ប៉ុន្តែ ក្នុងករណីដែលអ្នកខ្ចីពុំបានបញ្ចប់ការប្រើ

ប្រាស់ និង អាស្រ័យផល ដោយសារការធ្វេសប្រហែសក្នុងការប្រើប្រាស់ និង អាស្រ័យផលការខ្ចីប្រើនឹងត្រូវបញ្ចប់ បន្ទាប់ពីអំឡុងពេលដែលគ្រប់គ្រាន់ដើម្បី អនុវត្តការប្រើប្រាស់ និង អាស្រ័យផលនោះបានកន្លងផុត ។

មាត្រា ៦៣១.- ការស្នើសុំឱ្យរំលាយកិច្ចសន្យាពីអ្នកឱ្យខ្ចី

១-បើពុំបានកំណត់ទាំងអំឡុងពេល និង គោលបំណងផងទេ អ្នកឱ្យខ្ចីអាចស្នើសុំរំលាយកិច្ចសន្យាខ្ចីប្រើ នៅពេលណាក៏បាន ។

២-ទោះជានៅមុនការផុតកំណត់អំឡុងពេល ឬ នៅមុនការបញ្ចប់ការប្រើប្រាស់ និង អាស្រ័យផលក៏ដោយ ប្រសិនបើមានករណីបន្ទាន់ និង ចាំបាច់កើតមានឡើងចំពោះវត្ថុខ្ចីដែលអ្នកឱ្យខ្ចីពុំអាចព្យាករបានអ្នកឱ្យខ្ចីអាចស្នើសុំរំលាយកិច្ចសន្យាខ្ចីប្រើបាន ។

មាត្រា ៦៣២.- ការស្នើសុំឱ្យរំលាយកិច្ចសន្យាពីអ្នកខ្ចី

ទោះបីបានកំណត់ ឬ មិនបានកំណត់អំឡុងពេលក៏ដោយ អ្នកខ្ចីអាចស្នើសុំរំលាយកិច្ចសន្យាខ្ចីប្រើ នៅពេលណាក៏បាន ។ ប៉ុន្តែ ក្នុងករណីដែលអ្នកឱ្យខ្ចីមានផលប្រយោជន៍ទៅលើអំឡុងពេលនោះ អ្នកខ្ចីមានករណីយកិច្ចសងសំណងនៃការខូចខាតដែលកើតឡើងដោយសារការស្នើសុំរំលាយកិច្ចសន្យានោះ ។

មាត្រា ៦៣៣.- ការបញ្ចប់ការខ្ចីប្រើដោយសារមរណភាពរបស់អ្នកខ្ចី

ការខ្ចីប្រើ នឹងត្រូវបញ្ចប់ដោយសារមរណភាពរបស់អ្នកខ្ចី ។

មាត្រា ៦៣៤.- ករណីយកិច្ចប្រគល់វត្ថុខ្ចី

១-នៅពេលដែលការខ្ចីប្រើត្រូវបានបញ្ចប់ហើយ អ្នកខ្ចីមានករណីយកិច្ចត្រូវធ្វើបដិទានវត្ថុខ្ចីនោះ ហើយប្រគល់ទៅឱ្យអ្នកឱ្យខ្ចីវិញជាបន្ទាន់ ។

២-លើកលែងតែការបាក់បែក ការខូចខាតដែលកើតឡើងដោយសារការប្រើប្រាស់ជាធម្មតា អ្នកខ្ចីត្រូវជួសជុលការខូចខាតដែលកើតឡើងដោយសារមូលហេតុជាបន្ទុករបស់ខ្លួនឡើងវិញ ឬ ត្រូវមានករណីយកិច្ចសងសំណងនៃការខូចខាតនោះ ។

ROYAUME DU CAMBODGE · LE MINISTÈRE DU PALAIS ROYAL

226/455

មាត្រា ៦៣៥.- សិទ្ធិរុះរើចេញរបស់អ្នកខ្ចី

បើកិច្ចសន្យាខ្ចីប្រើ ត្រូវបានបញ្ចប់ហើយ អ្នកខ្ចីអាចរុះរើចេញនូវវត្ថុដែលបានភ្ជាប់ជាមួយនឹងវត្ថុខ្ចីនោះបាន ។

មាត្រា ៦៣៦.- អំឡុងពេលប្រើសិទ្ធិទាមទារសំណងនៃការខូចខាត និង ទាមទារឱ្យសងសោហ៊ុយមកវិញ

សំណងនៃការខូចខាតដែលកើតឡើងដោយសារអ្នកខ្ចី ក្នុងការប្រើប្រាស់ ឬ អាស្រ័យផលដែលផ្ទុយនឹងអត្ថន័យដើមនៃកិច្ចសន្យា និង ការសងមកវិញនូវសោហ៊ុយដែលអ្នកខ្ចី បានចេញ ត្រូវទាមទារនៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលអ្នកឱ្យខ្ចីបានទទួលការសងវត្ថុខ្ចីនោះ ។

ជំពូកទី ៧
អាណត្តិ

មាត្រា ៦៣៧.- និយមន័យនៃអាណត្តិ

អាណត្តិសំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាង ហៅថា អាណត្តិទាយក ប្រគល់សិទ្ធិអំណាចឱ្យភាគីម្ខាងទៀត ហៅថា អាណត្តិគាហក ធ្វើការចាត់ចែងកិច្ចការដើម្បីអាណត្តិទាយក ។

មាត្រា ៦៣៨.- គោលការណ៍នៃអាណត្តិដោយមិនយកកម្រៃ

១-អាណត្តិអាចធ្វើដោយយកកម្រៃ ឬ មិនយកកម្រៃបាន ។ បើពុំបានបង្ហាញឆន្ទៈអំពីការធ្វើដោយយកកម្រៃទេ ត្រូវសន្មតថាជាអាណត្តិដោយមិនយកកម្រៃ ។

២-បញ្ញត្តិនៃមាត្រា ៦៤៤ (សិទ្ធិទាមទារកម្រៃរបស់អាណត្តិគាហក) នៃក្រមនេះ ត្រូវយកមកអនុវត្តចំពោះកម្រៃ នៅក្នុងករណីនៃអាណត្តិដោយយកកម្រៃ ។

មាត្រា ៦៣៩.- ភាពចាំបាច់នៃទម្រង់កិច្ចសន្យា

កិច្ចសន្យាអាណត្តិត្រូវបង្កើតដោយការព្រមព្រៀងរបស់ភាគីតែប៉ុណ្ណោះ ។

ROYAUME du CAMBODGE
LE MINISTÈRE du PALAIS ROYAL

មាត្រា ៦៤០.- ករណីយកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហក

១-អាណត្តិគាហក មានករណីយកិច្ចចាត់ចែងកិច្ចការអាណត្តិ ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងសុចរិត ដោយផ្អែកតាមអត្ថន័យនៃអាណត្តិ ។ ប៉ុន្តែ បញ្ញត្តិនេះមិនរារាំងចំពោះការបន្ធូរករណីយកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហក តាមការព្រមព្រៀងរបស់ភាគីឡើយ ។

២-ក្នុងករណីដែលអាណត្តិគាហក ធ្វើផ្ទុយនឹងករណីយកិច្ចប្រុងប្រយ័ត្ននៃកថាខណ្ឌទី ១ ខាងលើនេះ ហើយបានធ្វើឱ្យមានការខូចខាតដល់អាណត្តិទាយក អាណត្តិទាយកអាចទាមទារសំណងនៃការខូចខាតនោះពីអាណត្តិគាហកបាន ។ នៅក្នុងករណីនេះ ប្រសិនបើជាអាណត្តិដោយមិនយកកម្រៃ តុលាការអាចបន្ថយចំនួនទឹកប្រាក់សំណងនៃការខូចខាតបាន ។

មាត្រា ៦៤១.- ករណីយកិច្ចរាយការណ៍ របស់អាណត្តិគាហក

បើមានការទាមទាររបស់អាណត្តិទាយក អាណត្តិគាហកត្រូវរាយការណ៍អំពីស្ថានភាពនៃកិច្ចការចាត់ចែងអាណត្តិ ទោះបីនៅពេលណាក៏ដោយ ឬ ត្រូវរាយការណ៍អំពីហេតុការណ៍នោះដោយគ្មានការយឺតយ៉ាវ នៅក្រោយពេលដែលបានបញ្ចប់អាណត្តិហើយ ។

មាត្រា ៦៤២.- ករណីយកិច្ចប្រគល់ របស់អាណត្តិគាហក

១-អាណត្តិគាហកត្រូវប្រគល់ប្រាក់ និង វត្ថុផ្សេងៗទៀតដែលទទួលបានតាមការចាត់ចែងកិច្ចការអាណត្តិឱ្យ ទៅអាណត្តិទាយក ។ អាណត្តិគាហកក៏ត្រូវប្រគល់ផលដែលប្រមូលបានឱ្យទៅអាណត្តិទាយកផងដែរ ។

២-សិទ្ធិដែលអាណត្តិគាហកបានលទ្ធកម្មនៅក្នុងនាមរបស់ខ្លួនដើម្បីអាណត្តិទាយក ត្រូវផ្ទេរសិទ្ធិនោះឱ្យទៅអាណត្តិទាយក ។

មាត្រា ៦៤៣.- ករណីយកិច្ចសងសំណងនៃការខូចខាតរបស់អាណត្តិគាហកដែលបានប្រើប្រាក់

ប្រសិនបើអាណត្តិគាហកបានប្រើប្រាក់ដែលត្រូវប្រគល់ទៅឱ្យអាណត្តិទាយក ឬ បានប្រើប្រាក់ដែលទុកប្រើសម្រាប់ផលប្រយោជន៍នោះ ដើម្បីខ្លួនត្រូវបង់ការប្រាក់ដោយគិតចាប់ពីថ្ងៃដែលបានប្រើប្រាក់នោះ ។ ប្រសិនបើមានការខូចខាត ត្រូវទទួលខុសត្រូវសងសំណងនោះ ។

មាត្រា ៦៤៤.- សិទ្ធិទាមទារកម្រៃរបស់អាណត្តិគាហក

១-អាណត្តិគាហក ពុំអាចទាមទារកម្រៃចំពោះអាណត្តិទាយកបានឡើយ ក្នុងករណីដែលពុំបានកំណត់ជាពិសេសក្នុងកិច្ចសន្យា ។

២-នៅក្នុងករណីនៃអាណត្តិដោយយកកម្រៃ អាណត្តិគាហកមិនអាចទាមទារកម្រៃបានឡើយ បើមិនបានបញ្ចប់ការអនុវត្តករណីយកិច្ចដែលត្រូវតាមអាណត្តិនោះរួចហើយទេ ។ ប៉ុន្តែ បើបានកំណត់កម្រៃតាមអំឡុងពេលអាចទាមទារ បាន នៅក្រោយពេលដែលអំឡុងពេលនោះបានកន្លងផុត ។

៣-បើអាណត្តិត្រូវបានបញ្ចាប់ការអនុវត្តនៅពាក់កណ្តាលទី ដោយសារមូលហេតុដែលមិនមែនជាការទទួលខុសត្រូវរបស់អាណត្តិគាហក អាណត្តិគាហកអាចទាមទារកម្រៃបានតាមសមាមាត្រនៃភាគដែលបានអនុវត្តរួចហើយនោះ ។

មាត្រា ៦៤៥.- ករណីយកិច្ចបង់សោហ៊ុយជាមុនរបស់អាណត្តិទាយក

ប្រសិនបើមានតម្រូវការចាំបាច់លើសោហ៊ុយសម្រាប់ការចាត់ចែងកិច្ចការអាណត្តិ អាណត្តិទាយកត្រូវបង់សោហ៊ុយនោះជាមុន តាមការទាមទាររបស់អាណត្តិគាហក ។

មាត្រា ៦៤៦.- សិទ្ធិទាមទារឱ្យសងមកវិញ ជាអាទិ៍ នូវសោហ៊ុយរបស់អាណត្តិគាហក

១-ប្រសិនបើបានចំណាយប្រាក់ដែលទទួលស្គាល់ថាចាំបាច់សម្រាប់ធ្វើការចាត់ចែងកិច្ចការអាណត្តិ អាណត្តិគាហកអាចទាមទារចំពោះអាណត្តិទាយកឱ្យសងមកវិញនូវសោហ៊ុយ និង ការប្រាក់បាន ដោយគិតចាប់ពីក្រោយថ្ងៃដែលបានចំណាយសោហ៊ុយនោះ ។

២-ប្រសិនបើបានទទួលបន្ទុកកាតព្វកិច្ចដែលទទួលស្គាល់ថាចាំបាច់សម្រាប់ធ្វើការចាត់ចែងកិច្ចការអាណត្តិ អាណត្តិគាហកអាចឱ្យអាណត្តិទាយកសងកាតព្វកិច្ចនោះជំនួសខ្លួន ឬ បើពុំទាន់ដល់កំណត់ពេលដែលត្រូវសងកាតព្វកិច្ចនោះទេ អាចឱ្យដាក់ប្រាតិភោគដែលសមរម្យបាន ។

៣-ប្រសិនបើបានទទួលការខូចខាត ដែលមិនមែនបណ្តាលមកពីកំហុសរបស់ខ្លួននៅក្នុងការចាត់ចែងកិច្ចការអាណត្តិទេ អាណត្តិគាហកអាចទាមទារសំណងនោះ ពីអាណត្តិទាយកបាន ។ ប៉ុន្តែ ប្រសិនបើការខូចខាតនោះ កើតឡើងដោយចេតនា ឬ កំហុសរបស់តតិយជន អាណត្តិគាហកអាចទាមទារសំណងចំពោះអាណត្តិទាយកបាន ត្រឹមកម្រិតដែលពុំបានទទួលសំណង

ពីតតិយជននោះតែប៉ុណ្ណោះ ។

មាត្រា ៦៤៧.- ការរំលាយកិច្ចសន្យាអាណត្តិ

១-ភាគីនីមួយៗ អាចរំលាយកិច្ចសន្យាអាណត្តិ នៅពេលណាក៏បាន ។

២-ភាគីម្ខាងត្រូវសងសំណងនៃការខូចខាត ប្រសិនបើបានរំលាយកិច្ចសន្យាអាណត្តិ នៅក្នុងអំឡុងពេលដែលធ្វើឱ្យខូចផលប្រយោជន៍ចំពោះភាគីម្ខាងទៀត ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើមានមូលហេតុដែលមិនអាចជៀសវាងបាន ។

មាត្រា ៦៤៨.- ការរំលាយកិច្ចសន្យាដែលពុំមានអានុភាពប្រតិសកម្ម

នៅក្នុងករណីដែលបានរំលាយកិច្ចសន្យាអាណត្តិ អានុភាពនៃការរំលាយកិច្ចសន្យានោះកើតមានឡើងដោយឆ្ពោះទៅអនាគតតែប៉ុណ្ណោះ ។ ប៉ុន្តែ ករណីនេះពុំរារាំងលើការទាមទារសំណងនៃការខូចខាតចំពោះការរំលាយកិច្ចសន្យានោះឡើយប្រសិនបើភាគីណាម្ខាងមានកំហុស ។

មាត្រា ៦៤៩.- មូលហេតុនៃការបញ្ចប់អាណត្តិ

១-ក្រៅពីការរំលាយកិច្ចសន្យាអាណត្តិដោយបញ្ញត្តិនៃមាត្រា ៦៤៧ (ការរំលាយកិច្ចសន្យាអាណត្តិ) នៃក្រមនេះ អាណត្តិត្រូវបញ្ចប់ដោយមូលហេតុដូចខាងក្រោមនេះ :

ក-ប្រសិនបើអាណត្តិទាយក ឬ អាណត្តិគាហក បានទទួលមរណភាព ។

ខ-ប្រសិនបើអាណត្តិទាយក ឬ អាណត្តិគាហក ត្រូវបានប្រកាសធនក្ស័យ ។

គ-ប្រសិនបើអាណត្តិទាយកត្រូវបានទទួលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ ឬ ការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ ។

ឃ-ប្រសិនបើអាណត្តិគាហក ត្រូវបានទទួលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ ឬ ការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ ។

ង-ប្រសិនបើអាណត្តិទាយក ឬ អាណត្តិគាហកដែលជានីតិបុគ្គលបានរលាយ ។

ច-ប្រសិនបើអាណត្តិទាយក ឬ អាណត្តិគាហកដែលជានីតិបុគ្គល បានរួមបញ្ចូលជាមួយនីតិបុគ្គលផ្សេង ។

ROYAUME DU CAMBODGE • LE MINISTERE DU PALAIS ROYAL

ឆ-ប្រសិនបើមូលហេតុផ្សេងៗដែលបានកំណត់តាមការព្រមព្រៀងរបស់ភាគីបាន កើតឡើង ។

២-ភាគីអាចព្រមព្រៀងអំពីការណ៍ដែលអាណត្តិមិនបញ្ចប់ ទោះបីជាមូលហេតុដែលបាន កំណត់ចាប់ពីចំណុច ក ដល់ ចំណុច ច នៃកថាខណ្ឌទី ១ ខាងលើនេះ បានកើតឡើងក៏ដោយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះមរណភាពរបស់អាណត្តិគាហក ការចាប់ ផ្តើមអាណាព្យាបាលទូទៅសម្រាប់អាណត្តិគាហក ឬ ការរលាយ ឬ ការបញ្ចូលនៃអាណត្តិគាហក ដែលជានីតិបុគ្គល ។

មាត្រា ៦៥០.- ករណីយកិច្ចសង្គ្រោះបន្ទាន់ របស់អាណត្តិគាហក នៅក្រោយពេលបញ្ចប់អាណត្តិ

នៅក្នុងករណីដែលបានបញ្ចប់អាណត្តិហើយ ប្រសិនបើមានស្ថានភាពបន្ទាន់អាណ- ត្តិគាហក សន្តតិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់អាណត្តិគាហកនោះ ត្រូវធ្វើការ ចាត់ចែងដែលចាំបាច់រហូតដល់ពេលដែលអាណត្តិទាយក សន្តតិជន ឬ អ្នកតំណាងដែលច្បាប់ បានកំណត់របស់អាណត្តិទាយកនោះ អាចចាត់ការកិច្ចការនោះបាន ។

មាត្រា ៦៥១.- លំគូខំណគួតតាំងនៃការបញ្ចប់អាណត្តិ

មូលហេតុនៃការបញ្ចប់អាណត្តិ ទោះបីជាមូលហេតុនោះកើតឡើងចំពោះអាណត្តិទាយក ក៏ដោយ ឬ ចំពោះអាណត្តិគាហកក៏ដោយ ពុំអាចយកមកតតាំងជាមួយនឹងភាគីម្ខាងទៀតបាន ឡើយ បើមិនបានជូនដំណឹងទៅឱ្យភាគីម្ខាងទៀត ឬ បើភាគីម្ខាងទៀតពុំបានដឹងអំពីមូលហេតុ នោះទេ ។

ជំពូកទី ៨

កិច្ចសន្យាម៉ៅការ

មាត្រា ៦៥២.- និយមន័យនៃកិច្ចសន្យាម៉ៅការ

កិច្ចសន្យាម៉ៅការ សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាងមានករណីយកិច្ចសម្រេច ការងារដែលបានព្រមព្រៀង ហើយភាគីម្ខាងទៀតមានករណីយកិច្ចផ្តល់កម្រៃ ចំពោះលទ្ធផល នៃការងារដែលបានធ្វើនោះ ។

ROYAUME DU CAMBODGE
LE MINISTRE du PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

មាត្រា ៦៥៣.- ពេលដែលត្រូវបង់កម្រៃ

កម្រៃត្រូវបង់ដំណាលគ្នានឹងការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការងារ ។ បើពុំចាំបាច់ក្នុងការប្រគល់វត្ថុទេ ក្រោយពីបានសម្រេចការងារហើយ អ្នកម៉ៅការអាចទាមទារឱ្យបង់កម្រៃបាន ។

មាត្រា ៦៥៤.- ករណីយកិច្ចសម្រេចការងារដោយគ្មានវិការៈ

១-អ្នកម៉ៅការ មានករណីយកិច្ចសម្រេចការងារដោយគ្មានវិការៈចំពោះម្ចាស់ការ ។

២-បើការងារពុំមានលក្ខណៈដូចបានព្រមព្រៀងទេ ត្រូវចាត់ទុកថា ជាការងារមានវិការៈ ។ ក្នុងករណីដែលមិនបានព្រមព្រៀងអំពីលក្ខណៈ បើការងារនោះពុំត្រឹមត្រូវក្នុងការប្រើប្រាស់ដែលបានសន្មតនៅក្នុងកិច្ចសន្យា ឬ ក្នុងករណីដែលពុំបានសន្មតនៅក្នុងកិច្ចសន្យានៃការប្រើប្រាស់ដែលបានកំណត់ បើការងារនោះមិនត្រឹមត្រូវក្នុងការប្រើប្រាស់ជាប្រក្រតីទេ ត្រូវចាត់ទុកថា ជាការងារមានវិការៈ ។

៣-ប្រសិនបើអ្នកម៉ៅការ បានធ្វើការផ្ទុយនឹងការបញ្ជា ឬ បើការងារដែលបានធ្វើនោះមិនគ្រប់ចំនួនទេ ត្រូវចាត់ទុកថា ជាការងារមានវិការៈ ។

មាត្រា ៦៥៥.- ការទាមទារឱ្យអនុវត្តការងារពេញលេញ

១-បើការងារមានវិការៈ ម្ចាស់ការអាចទាមទារចំពោះអ្នកម៉ៅការឱ្យអនុវត្តការងារពេញលេញ ដោយកំណត់អំឡុងពេលសមរម្យបាន ។ ក្នុងករណីនេះ អ្នកម៉ៅការអាចជួសជុលវិការៈនៃការងារនោះ ឬ អាចធ្វើការងារនោះសាជាថ្មីឡើងវិញ ដោយផ្អែកតាមការជ្រើសរើសបាន ។

២-បើការអនុវត្តការងារឱ្យពេញលេញនេះ ចាំបាច់ត្រូវចំណាយសោហ៊ុយច្រើនហួសហេតុ បើប្រៀបធៀបទៅនឹងការខូចខាតផលប្រយោជន៍ដោយវិការៈនោះ អ្នកម៉ៅការអាចបដិសេធបាន ។

៣-បើអ្នកម៉ៅការ បានចាប់ផ្តើមធ្វើការងារនោះឡើងវិញ អ្នកម៉ៅការនោះអាចទាមទារឱ្យម្ចាស់ការសងការងារដែលមានវិការៈមកវិញបាន ។

មាត្រា ៦៥៦.- ការជួសជុលវិការៈដោយម្ចាស់ការ

១-នៅក្រោយពេលដែលអំឡុងពេលសមរម្យដែលបានកំណត់ដើម្បីអនុវត្តការងារឱ្យ

ពេញលេញនោះបានកន្លងផុតហើយ ម្ចាស់ការអាចជួសជុលវិការៈដោយខ្លួនឯងផ្ទាល់ ហើយអាចទាមទារសោហ៊ុយដែលចាំបាច់លើការជួសជុលវិការៈនោះ ពីអ្នកម៉ៅការ បាន ។

២-ក្នុងករណីដែលការអនុវត្តការងារឱ្យពេញលេញមិនបានសម្រេច ឬ ក្នុងករណីដែលវាយតម្លៃថា ការអនុវត្តការងារឱ្យពេញលេញដោយអ្នកម៉ៅការ នឹងធ្វើឱ្យមានការខូចខាតផលប្រយោជន៍ដោយមិនត្រឹមត្រូវចំពោះម្ចាស់ការ ម្ចាស់ការអាចជួសជុលវិការៈ ដោយខ្លួនឯងហើយអាចទាមទារសោហ៊ុយដែលចាំបាច់ក្នុងការជួសជុលវិការៈពីអ្នកម៉ៅការ បាន ។

៣-ក្នុងករណីនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ម្ចាស់ការអាចទាមទារចំពោះអ្នកម៉ៅការឱ្យបង់សោហ៊ុយដែលចាំបាច់លើការជួសជុលវិការៈជាមុនបាន ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ១ ទី ២ និង ទី ៣ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ បើអ្នកម៉ៅការបានបដិសេធការអនុវត្តការងារឱ្យពេញលេញ យោងតាមបញ្ញត្តិ នៃកថាខណ្ឌទី ២ មាត្រា ៦៥៥ (ការទាមទារឱ្យអនុវត្តការងារពេញលេញ) ខាងលើនេះ ។

មាត្រា ៦៥៧.- សិទ្ធិរំលាយរបស់ម្ចាស់ការ

១-ម្ចាស់ការ អាចរំលាយកិច្ចសន្យាដោយយកមូលហេតុវិការៈនៃការងារផ្អែកតាមបញ្ញត្តិនៃផ្នែកទី ៤ (ការរំលាយកិច្ចសន្យា) ជំពូកទី ៤នៃគន្ថីទី ៤បាន ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលការអនុវត្តការងារឱ្យពេញលេញ មិនបានសម្រេច ឬ ក្នុងករណីដែលវាយតម្លៃថា ការអនុវត្តការងារឱ្យពេញលេញដោយអ្នកម៉ៅការនឹងធ្វើឱ្យមានការខូចខាតផលប្រយោជន៍ដោយមិនត្រឹមត្រូវចំពោះម្ចាស់ការ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តចំពោះអគារ ឬ សំណង់លើដីផ្សេងទៀតឡើយ ។ ប៉ុន្តែ បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តផងដែរ បើសំណង់នោះពុំមានតម្លៃនឹងប្រើប្រាស់ ចំពោះម្ចាស់ការដោយសារវិការៈធ្ងន់ធ្ងរពេក ។

មាត្រា ៦៥៨.- សិទ្ធិទាមទារឱ្យបន្ថយតម្លៃរបស់ម្ចាស់ការ

១-នៅក្រោយពេលដែលអំឡុងពេលសមរម្យដែលបានកំណត់ដើម្បីអនុវត្តការងារឱ្យពេញលេញនោះបានកន្លងផុតហើយ ម្ចាស់ការអាចទាមទារឱ្យបន្ថយថ្លៃ តាមការបង្ហាញឆន្ទៈ

ROYAUME DU CAMBODGE ... LE MINISTERE ...

ចំពោះអ្នកម៉ៅការ ដោយយកវិការៈនៃការងារមកធ្វើជាមូលហេតុបាន ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលការអនុវត្តការងារឱ្យពេញលេញមិនបានសម្រេច ឬ ក្នុងករណីដែលវាយតម្លៃថា ការអនុវត្តការងារឱ្យពេញលេញដោយអ្នកម៉ៅការនឹងធ្វើឱ្យមានការខូចខាតផលប្រយោជន៍ដោយមិនត្រឹមត្រូវចំពោះម្ចាស់ការ ។

២-កម្រៃនឹងត្រូវបានបន្ថយចុះ តាមការទាមទារឱ្យបន្ថយថ្លៃ យោលតាមសមាមាត្រនៃតម្លៃការងារដែលមានភ្ជាប់នូវវិការៈ ជាមួយនឹងតម្លៃនៃការងារដែលគ្មានវិការៈនោះ ។

មាត្រា ៦៥៩.- សិទ្ធិទាមទារសំណងនៃការខូចខាតរបស់ម្ចាស់ការ

១-ម្ចាស់ការ អាចទាមទារសំណងនៃការខូចខាត ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ៣ (សំណងនៃការខូចខាត)ជំពូកទី ៤ នៃគន្ថីទី ៤បាន ដោយមិនអនុវត្ត ឬ ដោយអនុវត្តព្រមគ្នានូវសិទ្ធិដែលបានកំណត់ចាប់ពីមាត្រា ៦៥៥ (ការទាមទារឱ្យអនុវត្តការងារពេញលេញ) រហូតដល់មាត្រា ៦៥៨ (សិទ្ធិទាមទារឱ្យបន្ថយតម្លៃរបស់ម្ចាស់ការ) នៃក្រមនេះ ។ ប៉ុន្តែ ចំពោះការអនុវត្តការងារឱ្យពេញលេញជំនួសសំណងនៃការខូចខាត នៅក្រោយពេលដែលអំឡុងពេលសមរម្យដែលបានកំណត់ដើម្បីអនុវត្តការងារឱ្យពេញលេញនោះបានកន្លងផុតហើយ លុះត្រាតែនៅក្នុងករណីដែលការអនុវត្តការងារឱ្យពេញលេញមិនបានសម្រេច ឬ ក្នុងករណីដែលវាយតម្លៃថា ការអនុវត្តការងារឱ្យពេញលេញដោយ អ្នកម៉ៅការនឹងធ្វើឱ្យមានការខូចខាតផលប្រយោជន៍ដោយមិនត្រឹមត្រូវចំពោះម្ចាស់ការ ទើបអាចទាមទារបាន ។

២-បើការអនុវត្តការងារឱ្យពេញលេញនេះ ចាំបាច់ត្រូវចំណាយសោហ៊ុយច្រើនហួសហេតុ បើប្រៀបធៀបទៅនឹងការខូចខាតផលប្រយោជន៍ដោយវិការៈនោះ ម្ចាស់ការមិនអាចទាមទារចំនួនទឹកប្រាក់ ដែលសមរម្យនឹងសោហ៊ុយដែលចាំបាច់ ក្នុងការជួសជុលវិការៈនោះថាជាសំណងនៃការខូចខាត ដោយយោលតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបានឡើយ ។

មាត្រា ៦៦០.- ការដោះស្រាយ ក្នុងករណីដែលវិការៈកើតឡើងដោយសម្ភារៈ ឬ ដោយការបញ្ជារបស់ម្ចាស់ការ

១-បញ្ញត្តិចាប់ពីមាត្រា ៦៥៥ (ការទាមទារឱ្យអនុវត្តការងារពេញលេញ) រហូតដល់

ROYAUME DU CAMBODGE
LE MINISTERE DU PALAIS ROYAL

មាត្រា ៦៥៩ (សិទ្ធិទាមទារសំណងនៃការខូចខាតរបស់ម្ចាស់ការ) ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើវិការៈនៃការងារនោះកើតឡើងពីលក្ខណៈនៃសម្ភារៈដែលបានផ្តល់ដោយម្ចាស់ការ ឬ ដោយការបញ្ជារបស់ម្ចាស់ការនោះ ។ ការសម្តែងប្រាប់ដែលគ្រាន់តែជាបំណងរបស់ម្ចាស់ការពុំត្រូវចាត់ទុកថាជាការបញ្ជាឡើយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើអ្នកម៉ៅការបានដឹងអំពីសភាពនៃសម្ភារៈ ឬ ភាពមិនត្រឹមត្រូវនៃការបញ្ជានោះតែមិនបានផ្តល់ដំណឹង ។

មាត្រា ៦៦១.- អំឡុងពេលនៃការប្រើសិទ្ធិ

១-សិទ្ធិដែលកំណត់ក្នុងបញ្ញត្តិចាប់ពីមាត្រា ៦៥៥ (ការទាមទារឱ្យអនុវត្តការងារពេញលេញ) រហូតដល់មាត្រា ៦៥៨ (សិទ្ធិទាមទារឱ្យបន្ថយតម្លៃរបស់ម្ចាស់ការ) ខាងលើនេះ ត្រូវយកមកប្រើនៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ។

២-អំឡុងពេលនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវគណនាចាប់ពីពេលដែលម្ចាស់ការបានដឹង ឬ គួរបានដឹង អំពីអត្ថិភាពនៃវិការៈនោះ ។

មាត្រា ៦៦២.- កិច្ចសន្យាពិសេសមិនទទួលខុសត្រូវក្នុងការធានា

បញ្ញត្តិចាប់ពីមាត្រា ៦៥៥ (ការទាមទារឱ្យអនុវត្តការងារពេញលេញ) រហូតដល់មាត្រា ៦៥៩ (សិទ្ធិទាមទារសំណងនៃការខូចខាតរបស់ម្ចាស់ការ) ខាងលើនេះ ទោះបីជាមានកិច្ចសន្យាពិសេសអំពីការអនុគ្រោះ ឬ កម្រិតការទទួលខុសត្រូវក៏ដោយ ចំពោះហេតុដែលបានដឹងហើយតែបែរជាមិនបានរាយការណ៍ប្រាប់ទេនោះ អ្នកម៉ៅការមិនអាចរួចផុតពីការទទួលខុសត្រូវ ឬ ការកម្រិតការទទួលខុសត្រូវបានឡើយ ។

មាត្រា ៦៦៣.- សិទ្ធិរំលាយរបស់ម្ចាស់ការនៅក្នុងពេលដែលការងារមិនទាន់បានសម្រេច

ម្ចាស់ការអាចរំលាយកិច្ចសន្យានៅពេលណាក៏បាន ដោយសងសំណងនៃការខូចខាតរហូតដល់ពេលដែលអ្នកម៉ៅការបានសម្រេចការងារ ។

ជំពូកទី ៩

កិច្ចសន្យាការងារ

មាត្រា ៦៦៤.- កិច្ចសន្យាការងារ

១-កិច្ចសន្យាការងារត្រូវបានបង្កើតឡើង ដោយការសន្យារបស់ភាគីម្ខាងថាធ្វើពលកម្មឱ្យភាគីម្ខាងទៀត ហើយភាគីម្ខាងទៀតសន្យាថា ផ្តល់ប្រាក់ឈ្នួល ទៅលើកិច្ចការពលកម្មនោះ ។

២-ភាគីដែលបានសន្យាថាធ្វើពលកម្ម ហៅថាកម្មករនិយោជិត ឯភាគីម្ខាងទៀតនោះ ហៅថានិយោជក ។

មាត្រា ៦៦៥.- ការបង្ហាញល័ក្ខខ័ណ្ឌជាក់លាក់លើការងារ

១-នៅពេលធ្វើកិច្ចសន្យាការងារ និយោជកត្រូវបង្ហាញជាក់លាក់ នូវប្រាក់ឈ្នួលពេលម៉ោងធ្វើពលកម្ម និង ល័ក្ខខ័ណ្ឌនៃការធ្វើពលកម្មផ្សេងទៀត ចំពោះកម្មករនិយោជិត ។

២-ក្នុងករណីដែលល័ក្ខខ័ណ្ឌនៃការធ្វើពលកម្មដែលត្រូវបានបង្ហាញជាក់លាក់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ខុសពីការពិត កម្មករនិយោជិតអាចរំលាយកិច្ចសន្យាការងារនោះភ្លាមៗបាន ។

មាត្រា ៦៦៦.- ករណីយកិច្ចយកចិត្តទុកដាក់ដល់សុវត្ថិភាព

និយោជក មានករណីយកិច្ចយកចិត្តទុកដាក់ ដល់ការរក្សារូបរាងកាយ សុខភាពជាអាទិ៍ របស់កម្មករនិយោជិតពីគ្រោះថ្នាក់ នៅទីកន្លែងដែលកម្មករនិយោជិតត្រូវធ្វើពលកម្ម សិល្បៈការឬ នៅក្នុងការធ្វើឧបករណ៍ ។

មាត្រា ៦៦៧.- ភាពផ្តាច់មុខលើបុគ្គលនៃកិច្ចសន្យាការងារ

១-បើគ្មានការយល់ព្រមពីកម្មករនិយោជិតទេ និយោជកពុំអាចធ្វើអនុប្បទានសិទ្ធិ នោះឱ្យទៅតតិយជនបានឡើយ ។

២-បើគ្មានការយល់ព្រមពីនិយោជកទេ កម្មករនិយោជិតពុំអាចឱ្យតតិយជនធ្វើពលកម្មជំនួសខ្លួនបានឡើយ ។

៣-ប្រសិនបើភាគីណាមួយនៃកិច្ចសន្យាការងារ បានធ្វើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១

ឬ ទី ២ ខាងលើនេះ ភាគីម្ខាងទៀត អាចរំលាយកិច្ចសន្យានោះបាន ។

មាត្រា ៦៦៨.- ការអនុវត្តច្បាប់ការងារ

ចំពោះកិច្ចសន្យាការងារ ក្រៅពីបញ្ញត្តិដែលកំណត់នៅក្នុងក្រមនេះ ត្រូវអនុវត្តតាមទៅតាមបញ្ញត្តិនៃច្បាប់ការងារ ។

ជំពូកទី ១០

បញ្ញើ

ផ្នែកទី ១

បទប្បញ្ញត្តិទូទៅស្តីពីបញ្ញើ

មាត្រា ៦៦៩.- និយមន័យនៃបញ្ញើ

១-បញ្ញើ សំដៅទៅលើកិច្ចសន្យាដែលភាគីម្ខាងជាអ្នកទទួលបញ្ញើ សន្យាទទួលយកវត្ថុបញ្ញើពីភាគីម្ខាងទៀតជាអ្នកផ្ញើ មករក្សាទុកក្នុងអំឡុងពេលដែលបានកំណត់ ហើយនៅក្រោយពេលដែលអំឡុងពេលរក្សាទុកនោះត្រូវបានបញ្ចប់ ត្រូវសងវត្ថុដដែលនោះទៅឱ្យអ្នកផ្ញើវិញ ។

២-បើគ្មានកិច្ចសន្យាពិសេសទេ អ្នកផ្ញើពុំមានករណីយកិច្ចបង់កម្រៃឱ្យអ្នកទទួលបញ្ញើឡើយ ។ ប៉ុន្តែ ក្នុងករណីដែលអ្នកទទួលបញ្ញើបានធ្វើកិច្ចសន្យានោះជាមួយអ្នកផ្ញើក្នុងនាមជាអាជីវកម្មរបស់ខ្លួន ឬ ប្រសិនបើមានកំណត់ក្នុងច្បាប់ ទោះបីជាពុំបានធ្វើកិច្ចសន្យាពិសេសចំពោះកម្រៃក៏ដោយ អ្នកទទួលបញ្ញើអាចទាមទារកម្រៃសមរម្យពីអ្នកផ្ញើបាន ។

មាត្រា ៦៧០.- ភាពចាំបាច់ក្នុងការទទួលយកវត្ថុនៃកិច្ចសន្យាបញ្ញើ

១-កិច្ចសន្យាបញ្ញើ ត្រូវបានបង្កើតឡើង ដោយអ្នកទទួលបញ្ញើ ទទួលយកកម្មវត្ថុនៃបញ្ញើតាមការព្រមព្រៀង ។

២-ក្នុងករណីដែលអ្នកទទួលបញ្ញើបានកាន់កាប់កម្មវត្ថុនៃបញ្ញើនោះហើយ កិច្ចសន្យាបញ្ញើត្រូវបានបង្កើតឡើងដោយការព្រមព្រៀងបង្កើតទំនាក់ទំនងបញ្ញើនោះ ។ ចំពោះវត្ថុដែលកាន់កាប់ដោយតតិយជន កិច្ចសន្យាបញ្ញើត្រូវបានបង្កើត នៅពេលដែលបានផ្ទេរការកាន់កាប់ដោយផ្តល់បញ្ជា

មាត្រា ៦៧១.- អានុភាពនៃកិច្ចសន្យាបញ្ញើដោយការព្រមព្រៀង

ប្រសិនបើភាគី គ្រាន់តែបានព្រមព្រៀងថានឹងបង្កើតទំនាក់ទំនងបញ្ញើនាពេលអនាគត ភាគីនីមួយៗអាចដកការព្រមព្រៀងនោះចេញ នៅពេលណាក៏បានរហូតដល់ពេលដែលបានប្រគល់កម្មវត្ថុនៃបញ្ញើនោះ ។ ប៉ុន្តែ ក្នុងករណីដែលបានសន្យាបង្កើតកិច្ចសន្យាបញ្ញើដោយឱ្យបង់ថ្លៃវិញ ប្រសិនបើបានធ្វើឱ្យខូចខាតដល់ភាគីម្ខាងទៀត ដោយសារការបដិសេធមិនទទួលវត្ថុបញ្ញើផ្ទុយនឹងការសន្យានោះ ភាគីដែលជាអ្នកទទួលបញ្ញើមានករណីយកិច្ចត្រូវសងសំណងនៃការខូចខាតនោះឱ្យទៅភាគីម្ខាងទៀត ប្រសិនបើការបដិសេធនោះ គ្មានមូលហេតុត្រឹមត្រូវទេ ។

មាត្រា ៦៧២.- កិច្ចសន្យាបញ្ញើដែលបានធ្វើដោយអ្នកគ្មានកម្មសិទ្ធិ

ទោះបីជាអ្នកផ្ញើគ្មានកម្មសិទ្ធិលើវត្ថុផ្ញើក៏ដោយ ក៏កិច្ចសន្យាបញ្ញើនោះ ត្រូវបានបង្កើតអានុភាពដែរ ។ នៅក្នុងករណីនេះ ទោះបីជាមានពាក្យបណ្តឹងទាមទារឱ្យសងវត្ថុរបស់កម្មសិទ្ធិករចំពោះអ្នកទទួលបញ្ញើក៏ដោយក៏អ្នកទទួលបញ្ញើអាចសងវត្ថុបញ្ញើនោះទៅឱ្យអ្នកផ្ញើវិញបានដែរ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបណ្តឹងទាមទារឱ្យសងវត្ថុរបស់កម្មសិទ្ធិករត្រូវបានទទួលស្គាល់ ។

មាត្រា ៦៧៣.- ករណីយកិច្ចរបស់អ្នកទទួលបញ្ញើ

១-អ្នកទទួលបញ្ញើ មានករណីយកិច្ចរក្សាទុកវត្ថុបញ្ញើ ដោយព្យាយាមប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

២-បើគ្មានការយល់ព្រមពីអ្នកផ្ញើទេ អ្នកទទួលបញ្ញើ មិនអាចប្រើវត្ថុបញ្ញើបានឡើយ ។

មាត្រា ៦៧៤.- ការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើ

១-នៅក្នុងករណីដែលបានធ្វើឱ្យបាត់បង់ ឬ បានធ្វើឱ្យបែកបាក់វត្ថុបញ្ញើនោះ អ្នកទទួលបញ្ញើត្រូវសងសំណងនៃការខូចខាតនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ បើអ្នកទទួលបញ្ញើបានបញ្ជាក់អំពីការគ្មានកំហុសចំពោះការធ្វើឱ្យបាត់បង់ ឬ បែកបាក់នោះ ។

២-ក្នុងករណីដែលបញ្ញើត្រូវបានធ្វើឡើង តាមការទាមទាររបស់អ្នកទទួលបញ្ញើ ប្រសិន

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

បើគ្មានការបញ្ជាក់ថាជាករណីប្រធានសក្តិទេ អ្នកទទួលបញ្ញើមិនអាចរួចផុតពីការទទួលខុសត្រូវ ចំពោះការធ្វើឱ្យបាត់បង់ ឬ បែកបាក់បានឡើយ ។

៣-នៅទីកន្លែងដូចជា សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន កន្លែងងូតទឹក សិប្បកម្មផ្សេងទៀតដែលមានភ្ញៀវជួបជុំ ប្រសិនបើកម្មសិទ្ធិករនៃសិប្បកម្មទាំងឡាយនោះ បានទទួលវត្ថុបញ្ញើពីភ្ញៀវ ប្រសិនបើគ្មានការបញ្ជាក់ថាជាករណីប្រធានសក្តិទេ អ្នកទទួលបញ្ញើមិនអាចរួចផុតពីការទទួលខុសត្រូវចំពោះការធ្វើឱ្យបាត់បង់ ឬ បែកបាក់បានឡើយ ។

មាត្រា ៦៧៥.- ការបន្ថយការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើដោយមិនយកកម្រៃ

នៅក្នុងបញ្ញើដោយមិនយកកម្រៃ តុលាការអាចបន្ថយការទទួលខុសត្រូវសងសំណងនៃការខូចខាតរបស់អ្នកផ្ញើ ដោយពិចារណាទៅលើស្ថានភាពនៃទ្រព្យសម្បត្តិភាគីទាំងសងខាង និង កាលៈទេសៈផ្សេងៗទៀតបាន ។

មាត្រា ៦៧៦.- ការសម្រាលការទទួលខុសត្រូវក្នុងករណីដែលមិនបានរាយការណ៍អំពីវត្ថុដែលមានតម្លៃខ្ពស់

នៅក្នុងករណីដែលអ្នកផ្ញើបានផ្ញើប្រាក់ ឧបករណ៍អាចជួញដូរបាន និង វត្ថុដែលមានតម្លៃខ្ពស់ផ្សេងទៀត ប្រសិនបើអ្នកផ្ញើមិនបានរាយការណ៍អំពីប្រភេទ និង តម្លៃនោះទៅឱ្យអ្នកទទួលបញ្ញើទេ តុលាការអាចបន្ថយការទទួលខុសត្រូវសងសំណងនៃការខូចខាតរបស់អ្នកទទួលបញ្ញើបាន ។

មាត្រា ៦៧៧.- ករណីយកិច្ចនៃការរក្សាទុកដោយខ្លួនឯង

១-បើគ្មានការយល់ព្រមពីអ្នកផ្ញើទេ អ្នកទទួលបញ្ញើពុំអាចឱ្យតតិយជនរក្សាទុកវត្ថុបញ្ញើបានឡើយ ។

២-ក្នុងករណីដែលអ្នកទទួលបញ្ញើអាចឱ្យតតិយជនរក្សាទុកវត្ថុបញ្ញើបាន អ្នកទទួលបញ្ញើត្រូវទទួលខុសត្រូវចំពោះការជ្រើសតាំង និង ត្រួតពិនិត្យអ្នកទទួលបញ្ញើដែលត្រូវបានឱ្យរក្សាទុកបន្ត ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

មាត្រា ៦៧៨.- បញ្ញើបន្ត

១-បញ្ញត្តិនៃជំពូកទី ១០(បញ្ញើ) នេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះទំនាក់ទំនងរវាងអ្នកទទួលបញ្ញើ និង អ្នកទទួលបញ្ញើបន្ត ។

២-អ្នកទទួលបញ្ញើបន្ត មានសិទ្ធិ និង ករណីយកិច្ចដូចគ្នានឹងអ្នកទទួលបញ្ញើដែរ ចំពោះអ្នកផ្ញើ ។

៣-ក្នុងករណីដែលបានសងវត្ថុបញ្ញើឱ្យទៅអ្នកផ្ញើហើយ អ្នកទទួលបញ្ញើបន្តត្រូវរួចផុតពីករណីយកិច្ចសងចំពោះអ្នកទទួលបញ្ញើ ។

មាត្រា ៦៧៩.- ករណីយកិច្ចជូនដំណឹងរបស់អ្នកទទួលបញ្ញើ

ប្រសិនបើតតិយជនដែលអះអាងអំពីសិទ្ធិចំពោះវត្ថុបញ្ញើ បានដាក់ពាក្យបណ្ដឹងចំពោះអ្នកទទួលបញ្ញើ ឬ វត្ថុបញ្ញើ ត្រូវបានរឹបអូស អ្នកទទួលបញ្ញើត្រូវជូនដំណឹងអំពីហេតុនោះ ទៅឱ្យអ្នកផ្ញើដោយគ្មានការយឺតយ៉ាវ ។

មាត្រា ៦៨០.- ការទាមទារឱ្យសងពីអ្នកផ្ញើ

ទោះបីជាភាគី បានកំណត់អំឡុងពេលនៃការសងវត្ថុបញ្ញើក៏ដោយ អ្នកផ្ញើអាចទាមទារឱ្យសងវត្ថុបញ្ញើនោះ នៅពេលណាក៏បាន ។

មាត្រា ៦៨១.- ការសងពីអ្នកទទួលបញ្ញើ

១-ប្រសិនបើភាគីពុំបានកំណត់អំឡុងពេលនៃការសងវត្ថុបញ្ញើទេ អ្នកទទួលបញ្ញើអាចសងវត្ថុបញ្ញើនោះ នៅពេលណាក៏បាន ។

២-ប្រសិនបើមានកំណត់អំឡុងពេលដែលត្រូវសង បើគ្មានមូលហេតុដែលពុំអាចជៀសវាងបានទេ អ្នកទទួលបញ្ញើមិនអាចសងវត្ថុបញ្ញើ នៅមុនពេលកំណត់បានឡើយ ។

មាត្រា ៦៨២.- អត្ថន័យនៃករណីយកិច្ចសង

១-អ្នកទទួលបញ្ញើ មានករណីយកិច្ចសងវត្ថុដដែល ដែលបានទទួលនៅពេលផ្ញើ ។

២-នៅក្នុងករណីដែលអ្នកទទួលបញ្ញើ ពុំទទួលខុសត្រូវចំពោះការធ្វើឱ្យបាត់បង់ ឬ បែកវត្ថុបញ្ញើ ប្រសិនបើអ្នកទទួលបញ្ញើបានទទួលប្រាក់ធានារ៉ាប់រង ឬ វត្ថុផ្សេងទៀត ជំនួស

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

វត្ថុបញ្ញើដែលត្រូវបានធ្វើឱ្យបាត់បង់ ឬ បែកបាក់នោះ អ្នកទទួលបញ្ញើមានករណីយកិច្ចត្រូវសង វត្ថុដែលបានធ្វើឱ្យបាត់បង់ ឬ បែកបាក់ ហើយអ្នកទទួលបញ្ញើមិនអាចយកសំណងបានទេ។ ក្នុងករណីដែលទទួលបានសំណងពីតតិយជនសម្រាប់វត្ថុដែលបានធ្វើឱ្យបាត់បង់នោះ ត្រូវប្រគល់វត្ថុ ឬ សំណងនោះឱ្យទៅអ្នកផ្ញើវិញ ។

មាត្រា ៦៨៣.- ការចាត់ចែងផល ជាអាទិ៍

ក្នុងករណីដែលបានទទួលផល ឬ ចំណូលដែលកើតឡើងពីវត្ថុបញ្ញើ អ្នកទទួលបញ្ញើ ត្រូវប្រគល់ផល ឬ ចំណូលនោះឱ្យទៅអ្នកផ្ញើ ។

មាត្រា ៦៨៤.- បញ្ញើជាប្រាក់

១-ប្រសិនបើបានទទួលការផ្ញើជាប្រាក់ អ្នកទទួលបញ្ញើ ត្រូវរក្សាទុក តាមរបៀបដែល បានកំណត់ក្នុងកិច្ចសន្យា ។ នៅក្នុងករណីនេះ បើគ្មានការសន្យាជាពិសេសទេ អ្នកទទួលបញ្ញើ ពុំមានករណីយកិច្ចបង់ការប្រាក់ឡើយ ។

២-ក្នុងករណីដែលអ្នកទទួលបញ្ញើ អាចរក្សាទុកប្រាក់ ដោយដាក់ជាប្រាក់បញ្ញើក្នុង ធនាគារ បញ្ញត្តិនៃមាត្រា ៦៨៣(ការចាត់ចែងផល ជាអាទិ៍) ខាងលើនេះ ត្រូវយកមកអនុវត្ត ផងដែរ ចំពោះការប្រាក់នោះ ។

មាត្រា ៦៨៥.- សោហ៊ុយនៃការសងវត្ថុបញ្ញើ

នៅក្នុងបញ្ញើដោយមិនយកកម្រៃ សោហ៊ុយចាំបាច់នៃការសងវត្ថុបញ្ញើ ត្រូវជាបន្ទុក របស់អ្នកផ្ញើ ។ ប៉ុន្តែ ក្នុងករណីដែលអ្នកទទួលបញ្ញើ បានផ្លាស់ប្តូរកន្លែងផ្ញើ សោហ៊ុយនៃការសង វត្ថុបញ្ញើដែលកើនឡើងដោយសារការផ្លាស់ប្តូរកន្លែងនោះ ត្រូវជាបន្ទុករបស់អ្នកទទួលបញ្ញើ ។

មាត្រា ៦៨៦.- ករណីយកិច្ចសងសោហ៊ុយវិញ របស់អ្នកផ្ញើ

១-អ្នកផ្ញើ ចាំបាច់ត្រូវបង់សោហ៊ុយដែលចាំបាច់ ក្នុងការរក្សាទុកវត្ថុបញ្ញើ ។

២-អ្នកទទួលបញ្ញើ អាចទាមទារសំណងនៃការខូចខាត ដែលបណ្តាលមកពីវត្ថុបញ្ញើ ដោយមិនមែនជាកំហុសរបស់ខ្លួនពីអ្នកផ្ញើបាន ។

មាត្រា ៦៨៧.- កន្លែងសង

ប្រសិនបើមិនបានកំណត់ក្នុងកិច្ចសន្យាការសងវត្ថុបញ្ញើ ចាំបាច់ត្រូវធ្វើនៅកន្លែង ដែល ត្រូវរក្សាទុកវត្ថុបញ្ញើនោះ ។ ប៉ុន្តែ ប្រសិនបើអ្នកទទួលបញ្ញើបានផ្លាស់ប្តូរកន្លែងរក្សាទុកវត្ថុនោះ

ដោយមានមូលហេតុត្រឹមត្រូវការសងអាចធ្វើនៅកន្លែងរក្សាទុកជាក់ស្តែងនាពេលសងបាន ។

មាត្រា ៦៨៨.- សិទ្ធិឃាត់ទុករបស់អ្នកទទួលបញ្ញើ

អ្នកទទួលបញ្ញើ អាចឃាត់ទុកវត្ថុបញ្ញើ រហូតដល់ពេលដែលអ្នកផ្ញើបានបង់សោហ៊ុយ និង សំណងនៃការខូចខាត ដែលបញ្ញត្តនៅក្នុងកថាខណ្ឌទី ១ និង ទី ២ នៃមាត្រា ៦៨៦ (ករណីយ-កិច្ចសងសោហ៊ុយវិញរបស់អ្នកផ្ញើ) នៃក្រមនេះបាន ។

ផ្នែកទី ២
បញ្ញើដោយរួមបញ្ចូលគ្នា

មាត្រា ៦៨៩.- បញ្ញើដោយរួមបញ្ចូលគ្នា

ប្រសិនបើអ្នកទទួលបញ្ញើ ទទួលបញ្ញើ នូវវត្ថុដែលមានប្រភេទដូចគ្នា ពីអ្នកផ្ញើច្រើននាក់ ហើយអាចរក្សាទុករួមបញ្ចូលគ្នា ដោយមិនបាច់បែងចែកវត្ថុបញ្ញើនោះ តាមកិច្ចសន្យាអ្នកផ្ញើនីមួយៗមានសិទ្ធិទៅតាមសមាមាត្រនៃចំនួនវត្ថុផ្ញើរបស់ខ្លួនចំពោះវត្ថុទាំងមូលដែលត្រូវបានរក្សាទុកដោយរួមបញ្ចូលគ្នា ។

ផ្នែកទី ៣
បញ្ញើបរិភោគ

មាត្រា ៦៩០.- បញ្ញើបរិភោគ

នៅក្នុងកិច្ចសន្យាបញ្ញើ បើបានព្រមព្រៀងឱ្យអ្នកទទួលបញ្ញើ អាចបរិភោគវត្ថុបញ្ញើបាន អ្នកទទួលបញ្ញើ មានករណីយកិច្ចសងវត្ថុដែលមានប្រភេទ និងចំនួនដូចគ្នានឹងវត្ថុបញ្ញើនោះ ។

មាត្រា ៦៩១.- ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីការខ្ចីបរិភោគ

បញ្ញត្តិស្តីពីការខ្ចីបរិភោគ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបញ្ញើបរិភោគដែលបានកំណត់នៅក្នុងមាត្រា ៦៩០ (បញ្ញើបរិភោគ) ខាងលើនេះ ។ ប៉ុន្តែ ក្នុងករណីនេះ ប្រសិនបើគ្មានកំណត់អំពីពេលសងនៅក្នុងកិច្ចសន្យាទេអ្នកផ្ញើអាចទាមទារឱ្យសងនៅពេលណាក៏បាន។

ផ្នែកទី ៤
វិសុណ្ឋាប័ន

មាត្រា ៦៩២.- និយមន័យនៃវិសុណ្ឋាប័ន

វិសុណ្ឋាប័ន សំដៅទៅលើកិច្ចសន្យាមួយដែលបុគ្គលច្រើននាក់ មានវិវាទលើសិទ្ធិកាន់កាប់ ឬ កម្មសិទ្ធិនៃវត្ថុ យកវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ ផ្ញើទុកនៅតតិយជនដែលហៅថា វិសុណ្ឋាបនិក រហូតដល់ពេលអ្នកដែលមានសិទ្ធិនោះត្រូវបានកំណត់ជាស្ថាពរ ។

មាត្រា ៦៩៣.- ភាគីនៃវិសុណ្ឋាប័ន

១-ក្នុងករណីដែលបុគ្គលច្រើននាក់ អះអាងអំពីសិទ្ធិរបស់ខ្លួន ចំពោះវត្ថុដែលកាន់កាប់ដោយបុគ្គលដទៃ បុគ្គលដែលមានវិវាទច្រើននាក់នេះ អាចធ្វើកិច្ចសន្យាឱ្យតតិយជនរក្សាទុកវត្ថុដែលជាកម្មវត្ថុនៃវិវាទ ដោយទទួលការយល់ព្រមពីអ្នកកាន់កាប់ ។ ក្នុងករណីនេះ កិច្ចសន្យាវិសុណ្ឋាប័ននេះ ត្រូវមានអានុភាពនៅពេលដែលអ្នកកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃវិវាទបានប្រគល់វត្ថុនោះទៅឱ្យតតិយជន ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បុគ្គលដែលមានវិវាទច្រើននាក់ក៏អាចធ្វើកិច្ចសន្យាបញ្ញើ ដោយយកអ្នកកាន់កាប់ធ្វើជាវិសុណ្ឋាបនិកនោះបាន ។

មាត្រា ៦៩៤.- លក្ខខណ្ឌនៃសុពលភាព

បើគ្មានការយល់ព្រមពីបុគ្គលដែលអះអាងអំពីសិទ្ធិទាំងអស់គ្នាទេ បញ្ញើនៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ពុំមានសុពលភាពឡើយ ។

មាត្រា ៦៩៥.- គោលការណ៍យកកម្រៃ

នៅក្នុងវិសុណ្ឋាប័ន អ្នកផ្ញើមានករណីយកិច្ចត្រូវបង់កម្រៃឱ្យទៅវិសុណ្ឋាបនិក ។ ក្នុងករណីដែលភាគីមិនបានកំណត់អំពីចំនួនទឹកប្រាក់នៃកម្រៃទេ វិសុណ្ឋាបនិកអាចទាមទារចំនួនទឹកប្រាក់ជាកម្រៃដែលសមរម្យពីអ្នកផ្ញើបាន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា ៦៩៦.- ការសងវត្ថុដែលជាកម្មវត្ថុនៃវិវាទ

វិសុណ្ណាបនិកមានករណីយកិច្ចត្រូវសងវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ ចំពោះបុគ្គលដែលត្រូវបានទទួលស្គាល់ថា មានសិទ្ធិនៅក្រោយពេលដែលវិវាទបានបញ្ចប់ ។

មាត្រា ៦៩៧.- ការរំលាយកិច្ចសន្យាវិសុណ្ណាប័ន

វិសុណ្ណាបនិកពុំអាចសងវត្ថុនោះទៅឱ្យអ្នកផ្ញើ នៅមុនពេលវិវាទនោះត្រូវបានដោះស្រាយឡើយ លើកលែងតែករណីមានការយល់ព្រមពីអ្នកផ្ញើទាំងអស់ ។

មាត្រា ៦៩៨.- វិសុណ្ណាប័ន ដោយការបង្គាប់របស់តុលាការ

ក្នុងករណីដែលសិទ្ធិកាន់កាប់វត្ថុ ឬ កម្មសិទ្ធិនៃវត្ថុ ត្រូវបានយកជាកម្មវត្ថុនៃវិវាទនៅក្នុងតុលាការ ទោះបីជាគ្មានការព្រមព្រៀងរវាងភាគីក៏ដោយ តុលាការអាចឱ្យតតិយជនរក្សាទុកវត្ថុដែលជាកម្មវត្ថុនៃវិវាទបាន ។

ជំពូកទី ១១

កិច្ចសន្យាក្រុមហ៊ុន

មាត្រា ៦៩៩.- និយមន័យនៃកិច្ចសន្យាក្រុមហ៊ុន

កិច្ចសន្យាក្រុមហ៊ុន សំដៅទៅលើកិច្ចសន្យាបង្កើតជាក្រុម ដែលគ្មានការរៀបចំលក្ខណៈជានីតិបុគ្គល ដើម្បីប្រកបកិច្ចការដោយសហការគ្នា ដោយភាគីនីមួយៗធ្វើការវិនិយោគទ្រព្យធនរៀងៗខ្លួន ។

មាត្រា ៧០០.- ការបង្កើតកិច្ចសន្យាក្រុមហ៊ុន

១-ក្រុមហ៊ុន គឺជាក្រុមដែលបានបង្កើតដោយការសន្យា ដែលភាគីនីមួយៗ វិនិយោគទ្រព្យធនរៀងៗខ្លួន ហើយប្រកបកិច្ចការដោយសហការគ្នា ។

២-ទ្រព្យធនដែលភាគីនីមួយៗត្រូវវិនិយោគនៅក្នុងកិច្ចសន្យាក្រុមហ៊ុន ក្រៅពីសិទ្ធិលើទ្រព្យសម្បត្តិ អាចយកពលកម្មមកធ្វើជាកម្មវត្ថុបាន ។

៣-ក្នុងករណីដែលភាគីបានយកប្រាក់ធ្វើជាកម្មវត្ថុនៃការវិនិយោគទ្រព្យធន បើមាន

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ការយឺតយ៉ាវក្នុងការបង់ប្រាក់នោះ ក្រៅពីត្រូវបង់ការប្រាក់នៃការយឺតយ៉ាវ ក៏ត្រូវបង់ទៅលើការខូចខាតដែលកើតឡើងដោយសារការយឺតយ៉ាវនោះ ចំពោះក្រុមហ៊ុនផងដែរ ។

៤-ក្នុងករណីដែលសកម្មភាពនៃការបង្កើតក្រុមហ៊ុនរបស់ភាគីណាមួយ ក្នុងចំណោមភាគីដែលបានព្រមព្រៀងបង្កើតក្រុមហ៊ុន ក្លាយទៅជាមោឃៈ ឬ ត្រូវបានលុបចោល ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ២ (វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា)ជំពូកទី ២ នៃគន្ថីទី ៤ ត្រូវចាត់ទុកថា ក្រុមហ៊ុននោះ ត្រូវបានបង្កើតដោយភាគីដទៃទៀត ។ ប៉ុន្តែ ក្នុងករណីដែលក្រុមហ៊ុនពុំអាចសម្រេចគោលបំណងបាន ដោយសារកង្វះភាគីនោះ ត្រូវចាត់ទុកថាក្រុមហ៊ុននោះ ពុំត្រូវបានបង្កើតឡើយ ។

មាត្រា ៧០១.- កម្មសិទ្ធិអវិភាគនៃទ្រព្យសម្បត្តិក្រុមហ៊ុន

១-ទ្រព្យធនវិនិយោគរបស់សមាជិកក្រុមហ៊ុននីមួយៗ និង ទ្រព្យសម្បត្តិក្រុមហ៊ុនផ្សេងៗទៀត ត្រូវស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់សមាជិកក្រុមហ៊ុនទាំងអស់ ។

២-សមាជិកក្រុមហ៊ុនពុំអាចទាមទារឱ្យបែងចែកទ្រព្យសម្បត្តិក្រុមហ៊ុន នៅមុនពេលធ្វើការជម្រះបញ្ជីរបស់ក្រុមហ៊ុនបានឡើយ ។ ប៉ុន្តែ ក្នុងករណីដែលសមាជិកទាំងអស់របស់ក្រុមហ៊ុនមានការព្រមព្រៀង ទោះបីជានៅមុនពេលធ្វើការជម្រះបញ្ជីក៏ដោយ ក៏អាចទាមទារឱ្យបែងចែកបានដែរ ។

៣-ការបែងចែកដែលបានកំណត់ក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២ ខាងលើនេះ ពុំអាចយកមកតតាំងចំពោះតតិយជនដែលបានធ្វើជំនួញជាមួយនឹងក្រុមហ៊ុន នៅមុនពេលធ្វើការបែងចែកនោះបានឡើយ ។

៤-សមាជិកក្រុមហ៊ុន ពុំអាចចាត់ចែងភាគដែលខ្លួនមាន ចំពោះទ្រព្យសម្បត្តិក្រុមហ៊ុននោះបានឡើយ ។

មាត្រា ៧០២.- វិធីអនុវត្តកិច្ចការ

១-ក្នុងករណីដែលពុំបានកំណត់សមាជិកក្រុមហ៊ុន ឬ តតិយជនទទួលអាណត្តិអនុវត្តកិច្ចការនៅក្នុងកិច្ចសន្យាក្រុមហ៊ុនទេ សមាជិកនីមួយៗនៃក្រុមហ៊ុន មានសិទ្ធិអំណាចអនុវត្តកិច្ចការរបស់ក្រុមហ៊ុននោះ ។ ប៉ុន្តែ ការអនុវត្តកិច្ចការក្រុមហ៊ុនត្រូវសម្រេចដោយសំឡេងលើសពី

ROYAUME DU CAMBODGE
LE MINISTRE DU PLANS

ពាក់កណ្តាលនៃចំនួនសមាជិកនោះ ។

២-ប្រសិនបើបានកំណត់ថាសមាជិកក្រុមហ៊ុន ឬ តតិយជនដែលទទួលអាណត្តិអនុវត្តកិច្ចការនៅក្នុងកិច្ចសន្យាក្រុមហ៊ុន ត្រូវមានច្រើននាក់ ការអនុវត្តកិច្ចការក្រុមហ៊ុនត្រូវសម្រេចដោយសំឡេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកនោះ ។

៣-ទោះបីមានបញ្ញត្តិនៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះក៏ដោយ សមាជិកក្រុមហ៊ុននីមួយៗ ឬ អ្នកអនុវត្តកិច្ចការម្នាក់ៗ អាចអនុវត្តកិច្ចការប្រក្រតីរបស់ក្រុមហ៊ុនដោយឯកតោភាគីបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើសមាជិកនៃក្រុមហ៊ុន ឬ អ្នកអនុវត្តកិច្ចការផ្សេងទៀតបានបញ្ចេញមតិតវ៉ា នៅមុនពេលបញ្ចប់កិច្ចការនោះ ។

មាត្រា ៧០៣.- ការយកបញ្ញត្តិនៃអាណត្តិមកអនុវត្តដូចគ្នា

បញ្ញត្តិចាប់ពីមាត្រា ៦៤០ (ករណីយកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហក) រហូតដល់មាត្រា ៦៤៦ (សិទ្ធិទាមទារឱ្យសងមកវិញ ជាអាទិ៍នូវសោហ៊ុយរបស់អាណត្តិគាហក) នៃក្រមនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសមាជិកក្រុមហ៊ុនដែលអនុវត្តកិច្ចការរបស់ក្រុមហ៊ុន ។

មាត្រា ៧០៤.- ការលាឈប់ និង ការបញ្ឈប់សមាជិកក្រុមហ៊ុនដែលអនុវត្តកិច្ចការ

១-ប្រសិនបើគ្មានមូលហេតុត្រឹមត្រូវទេ សមាជិកក្រុមហ៊ុនដែលអនុវត្តកិច្ចការ ពុំអាចលាឈប់ ឬ ត្រូវបញ្ឈប់បានឡើយ ។

២-ដើម្បីបញ្ឈប់សមាជិកដែលអនុវត្តកិច្ចការរបស់ក្រុមហ៊ុន ដោយមានមូលហេតុត្រឹមត្រូវ ត្រូវមានសំឡេងយល់ព្រមលើសពីពាក់កណ្តាលនៃចំនួនសមាជិកផ្សេងទៀតរបស់ក្រុមហ៊ុន ។

មាត្រា ៧០៥.- សិទ្ធិធ្វើការស្រាវជ្រាវលើកិច្ចការ និង ស្ថានភាពទ្រព្យសម្បត្តិ

ទោះបីជាគ្មានសិទ្ធិអំណាចក្នុងការអនុវត្តកិច្ចការរបស់ក្រុមហ៊ុនក៏ដោយ ក៏សមាជិកនីមួយៗរបស់ក្រុមហ៊ុន អាចធ្វើការស្រាវជ្រាវលើកិច្ចការ និង ស្ថានភាពទ្រព្យសម្បត្តិរបស់ក្រុមហ៊ុននោះបានដែរ ។

មាត្រា ៧០៦.- សិទ្ធិទាមទារចែកចំណេញ គោលនៃការបែងចែកការចំណេញខាត

១-សមាជិកក្រុមហ៊ុនត្រូវគណនាការចំណេញ ខាត នៅក្នុងអំឡុងពេលទៀងទាត់ហើយ

ក្នុងករណីដែលមានចំណេញ អាចទាមទារឱ្យបែងចែកផលចំណេញនោះបាន ។

២-ប្រសិនបើសមាជិកក្រុមហ៊ុន មិនបានកំណត់ភាគនៃការបែងចែកការចំណេញខាតទេ ត្រូវកំណត់ទៅតាមសមាមាត្រនៃចំនួនតម្លៃវិនិយោគទ្រព្យធនរបស់សមាជិកនីមួយៗនៃក្រុមហ៊ុននោះ ។

៣-ប្រសិនបើបានកំណត់តែភាគនៃការបែងចែកចំពោះការចំណេញ ខាតណាមួយ ត្រូវសន្មតថាភាគនោះ ដូចគ្នាទៅនឹងការខាតបង់ និងការចំណេញ ។

មាត្រា ៧០៧.- ភាគដែលត្រូវទទួលបន្ទុកនៃការខាតបង់របស់សមាជិកក្រុមហ៊ុន ចំពោះម្ចាស់បំណុល

១-កាតព្វកិច្ចដែលកើតឡើងដោយកិច្ចការរបស់ក្រុមហ៊ុន ជាកាតព្វកិច្ចដោយសាមគ្គីភាព ។ ប៉ុន្តែ កាតព្វកិច្ចនោះ ត្រូវសងដោយទ្រព្យសម្បត្តិក្រុមហ៊ុនសិន ហើយប្រសិនបើមិនអាចសងកាតព្វកិច្ចទាំងអស់ ដោយទ្រព្យសម្បត្តិក្រុមហ៊ុន ទើបសងដោយទ្រព្យដោយឡែករបស់សមាជិកនីមួយៗ ។

២-បន្ទុករបស់សមាជិកនីមួយៗ ត្រូវអនុលោមតាមសមាមាត្រនៃភាគវិនិយោគ លើកលែងតែមានការសន្យាពិសេស ។

មាត្រា ៧០៨.- ការហាមឃាត់មិនឱ្យទូទាត់កាតព្វកិច្ចក្រុមហ៊ុន

កូនបំណុលរបស់ក្រុមហ៊ុន ពុំអាចទូទាត់កាតព្វកិច្ចនោះ ជាមួយនឹងសិទ្ធិលើបំណុលចំពោះសមាជិកនីមួយៗនៃក្រុមហ៊ុនបានឡើយ ។

មាត្រា ៧០៩.- ការដកខ្លួនដោយស្ម័គ្រចិត្ត

១-ប្រសិនបើពុំបានកំណត់អំឡុងពេលនៃអត្ថិភាពរបស់ក្រុមហ៊ុននៅក្នុងកិច្ចសន្យា ក្រុមហ៊ុនទេ ឬ បើបានកំណត់អត្ថិភាពដែលក្រុមហ៊ុនត្រូវមាន ក្នុងរយៈពេលមួយជីវិតរបស់សមាជិកណាម្នាក់ សមាជិកនីមួយៗអាចដកខ្លួនចេញនៅពេលណាក៏បាន ។ ប៉ុន្តែ ការដកខ្លួននេះពុំអាចធ្វើបានឡើយ បើបណ្តាលឱ្យខូចផលប្រយោជន៍ដល់ក្រុមហ៊ុន លើកលែងតែក្នុងករណីដែលពុំអាចជៀសវាងបាន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

២-ទោះបីជាបានកំណត់អំឡុងពេលនៃអត្ថិភាពរបស់ក្រុមហ៊ុនក៏ដោយ នៅក្នុងករណីដែលពុំអាចជៀសវាងបាន សមាជិកនីមួយៗអាចដកខ្លួនបាន ។

៣-ការដកខ្លួនអាចធ្វើទៅបាន ដោយការបង្ហាញឆន្ទៈ ចំពោះសមាជិកផ្សេងទៀតទាំងអស់របស់ក្រុមហ៊ុន ។

មាត្រា ៧១០.- ការដកខ្លួនតាមច្បាប់

ក្រៅពីបញ្ញត្តិដែលបានកំណត់នៅក្នុងមាត្រា ៧០៩ (ការដកខ្លួនដោយស្ម័គ្រចិត្ត) ខាងលើ សមាជិកក្រុមហ៊ុនត្រូវដកខ្លួន ដោយមូលហេតុណាមួយដូចខាងក្រោមនេះ ៖

ក-មរណភាព ។

ខ-ធនក្ស័យ ។

គ-បានទទួលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ ។

ឃ-ការលុបឈ្មោះ ។

មាត្រា ៧១១.- ការលុបឈ្មោះ

ការលុបឈ្មោះសមាជិកក្រុមហ៊ុនអាចអនុវត្តបាន ដោយមតិយល់ព្រមជាឯកច្ឆន្ទពីសមាជិកផ្សេងទៀតទាំងអស់របស់ក្រុមហ៊ុន តែក្នុងករណីដែលមានមូលហេតុត្រឹមត្រូវប៉ុណ្ណោះ ។ ប៉ុន្តែ បើមិនបានជូនដំណឹងពីការលុបឈ្មោះ ដល់សមាជិកក្រុមហ៊ុនដែលត្រូវបានលុបឈ្មោះទេ ពុំអាចយកទៅតតាំងជាមួយនឹងសមាជិកក្រុមហ៊ុនដែលត្រូវបាន លុបឈ្មោះនោះ បានឡើយ ។

មាត្រា ៧១២.- ការសងវិញនូវចំណែករបស់សមាជិកក្រុមហ៊ុនដែលដកខ្លួន

១-ការគណនារវាងសមាជិកក្រុមហ៊ុនដែលបានដកខ្លួន និង សមាជិកផ្សេងទៀតរបស់ក្រុមហ៊ុន ចាំបាច់ត្រូវអនុវត្ត ដោយផ្អែកតាមស្ថានភាពនៃទ្រព្យសម្បត្តិរបស់ក្រុមហ៊ុននៅពេលដែលដកខ្លួននោះ ។

២-ចំណែកដែលសមាជិកក្រុមហ៊ុនដែលបានដកខ្លួននោះមាន អាចសងវិញជាប្រាក់បាន ដោយពុំគិតពីប្រភេទនៃទ្រព្យធនដែលវិនិយោគនោះឡើយ ។

៣-ចំពោះចំណុចដែលពុំទាន់បានបញ្ចប់ នៅពេលដកខ្លួន អាចគណនាបាននៅក្រោយ

ពេលធ្វើការបញ្ចប់នោះ ។

៤-ការសងចំណែកដែលមាន ទៅសមាជិកក្រុមហ៊ុនដែលត្រូវបានលុបឈ្មោះ ត្រូវភ្ជាប់ការប្រាក់ តាមអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ចំពោះអំឡុងពេលគិតចាប់ពីពេលដែលបានជូនដំណឹងអំពីការលុបឈ្មោះ រហូតដល់ពេលដែលបានសងវិញ ។

មាត្រា ៧១៣.- ការរំលាយក្រុមហ៊ុន

១-ក្រុមហ៊ុន ត្រូវរំលាយតាមករណីណាមួយ ដូចកំណត់ខាងក្រោមនេះ :

ក-ការបញ្ចប់កិច្ចការដែលជាកម្មវត្ថុរបស់ក្រុមហ៊ុន ឬ អលទ្ធភាពក្នុងការបំពេញកិច្ចការនោះ ។

ខ-បើមានការព្រមព្រៀងពីសមាជិកទាំងអស់របស់ក្រុមហ៊ុន ។

គ-បើនៅសល់សមាជិកក្រុមហ៊ុនតែម្នាក់ ។

ឃ-បើអំឡុងពេលនៃអត្ថិភាពរបស់ក្រុមហ៊ុន ដែលកំណត់នៅក្នុងកិច្ចសន្យា ក្រុមហ៊ុនត្រូវបានបញ្ចប់ ។

២-ក្នុងករណីដែលមានមូលហេតុមិនអាចជៀសវាងបាន សមាជិកនីមួយៗរបស់ក្រុមហ៊ុនអាចទាមទារឱ្យរំលាយក្រុមហ៊ុនបាន ។

៣-ការទាមទារនៃកថាខណ្ឌទី២ ខាងលើនេះ ត្រូវធ្វើដោយការបង្ហាញឆន្ទៈ ចំពោះសមាជិកផ្សេងទៀតទាំងអស់របស់ក្រុមហ៊ុន ។

មាត្រា ៧១៤.- ភាពគ្មានប្រតិសកម្មនៃការរំលាយ

ការរំលាយក្រុមហ៊ុន ពុំមានអានុភាពប្រតិសកម្មឡើយ ។

មាត្រា ៧១៥.- អ្នកជម្រះបញ្ជី

១-ប្រសិនបើក្រុមហ៊ុនត្រូវបានរំលាយ ការជម្រះបញ្ជីត្រូវធ្វើដោយសហការគ្នារវាងសមាជិកទាំងអស់របស់ក្រុមហ៊ុន ឬ ដោយអ្នកជម្រះបញ្ជី ដែលត្រូវបានជ្រើសតាំង ដោយសមាជិកក្រុមហ៊ុន ។

២-ការជ្រើសតាំងអ្នកជម្រះបញ្ជីនៃកថាខណ្ឌទី ១ ខាងលើនេះ ក្នុងករណីដែលគ្មាន

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

កំណត់ពិសេសនៅក្នុងកិច្ចសន្យាក្រុមហ៊ុនទេ ត្រូវសម្រេចដោយសំឡេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកក្រុមហ៊ុននោះ ។

មាត្រា ៧១៦.- ការអនុវត្តកិច្ចការរបស់អ្នកជម្រះបញ្ជី

បញ្ញត្តិនៃមាត្រា ៧០២ (វិធីអនុវត្តកិច្ចការ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលអ្នកជម្រះបញ្ជីមានចំនួនច្រើននាក់ ។

មាត្រា ៧១៧.- ការលាឈប់ និង ការបញ្ឈប់អ្នកជម្រះបញ្ជី

បញ្ញត្តិនៃមាត្រា ៧០៤ (ការលាឈប់ និង ការបញ្ឈប់សមាជិកក្រុមហ៊ុនដែលអនុវត្តកិច្ចការ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលសមាជិកទាំងអស់របស់ក្រុមហ៊ុនបានព្រមព្រៀងជ្រើសតាំងអ្នកជម្រះបញ្ជីពីក្នុងចំណោមសមាជិកក្រុមហ៊ុននោះ ។

មាត្រា ៧១៨.- មុខងារ និង សិទ្ធិអំណាចរបស់អ្នកជម្រះបញ្ជី វិធីបែងចែកទ្រព្យសម្បត្តិ ដែលនៅសេសសល់

១-បញ្ញត្តិនៃមាត្រា ៧១ (មុខងារ និងសិទ្ធិអំណាចរបស់អ្នកជម្រះបញ្ជី) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះមុខនាទី និង សិទ្ធិអំណាចរបស់អ្នកជម្រះបញ្ជី។

២-ទ្រព្យសម្បត្តិដែលនៅសេសសល់ ត្រូវបែងចែកដោយសមាមាត្រតាមតម្លៃនៃទ្រព្យធនដែលសមាជិកនីមួយៗរបស់ក្រុមហ៊ុនបានវិនិយោគ ។

ជំពូកទី ១២

កិច្ចសន្យាធនលាភសាមយិកមួយជីវិត

មាត្រា ៧១៩.- និយមន័យនៃកិច្ចសន្យាធនលាភសាមយិកមួយជីវិត

១-កិច្ចសន្យាធនលាភសាមយិកមួយជីវិត សំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាងជាកូនបំណុលនៃធនលាភសន្យាថា មានករណីយកិច្ចត្រូវផ្តល់តាវកាលិកជាប្រាក់តាមពេលកំណត់ទៀងទាត់ ទៅឱ្យភាគីម្ខាងទៀតដែលជាម្ចាស់បំណុល ឬ តតិយជននៃធនលាភ រហូតដល់ពេលដែលខ្លួនភាគីម្ខាងទៀត ឬ តតិយជនបានទទួលមរណភាព ហើយភាគីម្ខាងទៀតសន្យាថា

មានករណីយកិច្ចទទួលបន្ទុកផ្តល់ការកាលិកនូវប្រាក់ដើមដែលជាតម្លៃថ្នូរនោះ ។

២-កិច្ចសន្យាធនលាភសាមយិកមួយជីវិត ប្រសិនបើពុំបានធ្វើជាលាយល័ក្ខណ៍អក្សរទេ ពុំមានអានុភាពឡើយ ។

៣-ម្ចាស់បំណុលនៃធនលាភត្រូវទទួលបាននូវឯកសិទ្ធិលើចលនវត្ថុនិងអចលនវត្ថុក្នុងចំណោមប្រាក់ដើមដែលខ្លួនបានផ្តល់ការកាលិកឱ្យទៅភាគីម្ខាងទៀតដើម្បីសិទ្ធិលើបំណុលនៃធនលាភនោះ ។ ឯកសិទ្ធិដែលម្ចាស់បំណុលនៃធនលាភត្រូវទទួល ត្រូវបានចាត់ទុកថាជាឯកសិទ្ធិដែលបានកំណត់នៅក្នុងមាត្រា ៧៩៧ (ឯកសិទ្ធិចំពោះការលក់ចលនវត្ថុ) ឬ មាត្រា ៨០២ (ឯកសិទ្ធិចំពោះការលក់អចលនវត្ថុ) តាមប្រភេទនៃវត្ថុដែលជាកម្មវត្ថុនៃឯកសិទ្ធិនោះ ។

មាត្រា ៧២០.- ការគណនានៃធនលាភសាមយិកមួយជីវិត

ធនលាភសាមយិកមួយជីវិត ត្រូវគណនាដោយគិតតាមចំនួនថ្ងៃ ។

មាត្រា ៧២១.- ការមិនអនុវត្តកាតព្វកិច្ចធនលាភសាមយិក

១-ប្រសិនបើកូនបំណុលនៃធនលាភ បានធ្វេសប្រហែសពុំបានផ្តល់ការកាលិកនៃធនលាភសាមយិក តាមពេលកំណត់ទៀងទាត់ ឬ បើពុំបានអនុវត្តករណីយកិច្ចផ្សេងទៀតទេ ភាគីម្ខាងទៀតអាចរំលាយកិច្ចសន្យា ហើយអាចទាមទារឱ្យធ្វើបដិទាននូវប្រាក់ដើមដែលបានធ្វើការផ្តល់ការកាលិកនោះបាន ។ ប៉ុន្តែ ក្នុងករណីនេះ ភាគីម្ខាងទៀតត្រូវសងនូវចំនួនទាំងអស់នៃធនលាភដែលខ្លួនបានទទួលរហូតដល់ការរំលាយ ដោយដកការប្រាក់នៃប្រាក់ដើមនោះរហូតដល់ការរំលាយឱ្យទៅកូនបំណុលនៃធនលាភវិញ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងលើការទាមទារសំណងនៃការខូចខាតឡើយ ។

មាត្រា ៧២២.- មរណភាព ដែលជាមូលហេតុនៃការទទួលខុសត្រូវរបស់កូនបំណុលនៃធនលាភសាមយិក

ប្រសិនបើមរណភាពរបស់បុគ្គលដែលធ្វើជាមូលដ្ឋាននៃកំណត់ពេលចប់នៃកិច្ចសន្យាធនលាភសាមយិក បានកើតឡើង ដោយសារមូលហេតុដែលជាការទទួលខុសត្រូវរបស់កូន

បំណុលនៃធនលាភសាមយិក តុលាការអាចប្រកាសថា សិទ្ធិលើបំណុលបន្តមានអត្ថិភាពក្នុងអំឡុងពេលសមរម្យ តាមការទាមទាររបស់ម្ចាស់បំណុលនៃធនលាភសាមយិក ឬ សន្តតិជនរបស់បុគ្គលនោះបាន ។

មាត្រា ៧២៣.- ធនលាភសាមយិកមួយជីវិត ដោយអច្ច័យទាន

បញ្ញត្តិនៃជំពូកទី ១២(កិច្ចសន្យាធនលាភសាមយិកមួយជីវិត) នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអច្ច័យទានដែលភ្ជាប់បន្ទុកនៃធនលាភសាមយិកមួយជីវិត ។

ជំពូកទី ១៣

ការសះជា

មាត្រា ៧២៤.- និយមន័យ

ការសះជា សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីបានព្រមព្រៀងបញ្ចប់វិវាទដែលមានរវាងគ្នានឹងគ្នាដោយធ្វើសម្បទានទៅវិញទៅមក ។

មាត្រា ៧២៥.- វត្ថុដែលជាកម្មវត្ថុនៃការសះជា

១-ដើម្បីធ្វើការសះជា ភាគីត្រូវមានសិទ្ធិអំណាចចាត់ចែងវត្ថុដែលជាកម្មវត្ថុមាននៅក្នុងការសះជានោះ ។

២-ការសះជា ដើម្បីធ្វើឱ្យទំនាក់ទំនងគតិយុត្តដែលមោឃៈ ដោយសារភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ឬ ទំនៀមទម្លាប់ល្អ ឬ បញ្ញត្តិដែលអនុវត្តដោយបង្ខំ ឱ្យមានអានុភាពឡើងនោះ ត្រូវទុកជាមោឃៈ ។

មាត្រា ៧២៦.- ខសន្យាអំពីប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា

ក្នុងកិច្ចសន្យាសះជា អាចបន្ថែមខសន្យាអំពីប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យាចំពោះបុគ្គលដែលមិនអនុវត្តកិច្ចសន្យានោះបាន ។

មាត្រា ៧២៧.- អានុភាពនៃការសះជា

ក្នុងករណីដែលទទួលស្គាល់ថាភាគីម្ខាងមានសិទ្ធិ ឬ បានទទួលស្គាល់ថាភាគីម្ខាងទៀត

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

គ្មានសិទ្ធិលើកម្មវត្ថុនៃវិវាទ ដោយការសះជា ហើយបើបានរកឃើញភស្តុតាងដែលសន្និដ្ឋានបានថា ភាគីនោះគ្មានសិទ្ធិនោះតាំងពីដើមមក ឬ បើបានរកឃើញភស្តុតាងដែលសន្និដ្ឋានបានថាភាគីម្ខាងទៀតមានសិទ្ធិនោះ ត្រូវចាត់ទុកថាសិទ្ធិនោះត្រូវបានផ្ទេរទៅឱ្យភាគីនោះ ដោយការសះជា ឬ ត្រូវចាត់ទុកថាសិទ្ធិរបស់ភាគីម្ខាងទៀត ត្រូវបានរលត់ ។

មាត្រា ៧២៨.- ការភាន់ច្រឡំដែលទាក់ទងទៅនឹងសិទ្ធិដែលជាកម្មវត្ថុនៃវិវាទ ជាអាទិ៍

ទោះបីជាក្នុងករណីដែលបានសះជា ដោយភាគីម្ខាងភាន់ច្រឡំអំពីម្ចាស់សិទ្ធិ ឬ អង្គហេតុដែលជាមូលដ្ឋាននៃការគណនាតម្លៃនៃកម្មវត្ថុក៏ដោយ ប្រសិនបើការសះជានោះបានធ្វើដោយសម្បទានគ្នាទៅវិញទៅមកអំពីម្ចាស់សិទ្ធិ ឬ អត្ថិភាព នត្ថិភាពនៃអង្គហេតុ ឬ ការវាយតម្លៃជាអាទិ៍ ភាគីពុំអាចយកមូលហេតុនៃការភាន់ច្រឡំពីម្ចាស់សិទ្ធិ ឬ អត្ថិភាព នត្ថិភាពនៃអង្គហេតុ ឬ ការវាយតម្លៃ ជាអាទិ៍ មកលុបចោលការសះជាបានឡើយ ។

ជំពូកទី ១៤

ការគ្រប់គ្រងដោយឈឺឆ្អាល

មាត្រា ៧២៩.- ករណីយកិច្ចគ្រប់គ្រងរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

១-ទោះបីជាគ្មានសិទ្ធិអំណាចក៏ដោយ ការចាប់ផ្តើមគ្រប់គ្រងកិច្ចការដើម្បីបុគ្គលដទៃ ហៅថា ការគ្រប់គ្រងដោយឈឺឆ្អាល ។ បុគ្គលដែលធ្វើការគ្រប់គ្រងដោយឈឺឆ្អាល ហៅថា អ្នកគ្រប់គ្រងដោយឈឺឆ្អាល ។

២-អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវគ្រប់គ្រងដោយព្យាយាមប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត តាមវិធីដែលសមរម្យជាងគេ ដើម្បីផលប្រយោជន៍របស់សាមីខ្លួន ផ្អែកតាមលក្ខណៈនៃកិច្ចការនោះ ។

៣-ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានដឹងអំពីឆន្ទៈរបស់សាមីខ្លួន ឬ ប្រសិនបើអាចដឹងអំពីឆន្ទៈនោះបាន ត្រូវធ្វើការគ្រប់គ្រងដោយផ្អែកតាមឆន្ទៈនោះ ។

មាត្រា ៧៣០.- ការគ្រប់គ្រងដោយឈឺឆ្អាលក្នុងភាពបន្ទាន់

ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានធ្វើការគ្រប់គ្រងដោយឈឺឆ្អាល ដើម្បីជៀស

វាងគ្រោះថ្នាក់ នៅក្នុងសភាពបន្ទាន់ ចំពោះរូបកាយសាមីខ្លួន កិត្តិយស ឬ ទ្រព្យសម្បត្តិ លុះត្រាតែគ្មានគំនិតទុច្ចរិត ឬ កំហុសធ្ងន់ធ្ងរ តែប៉ុណ្ណោះទេ ទើបអ្នកគ្រប់គ្រងដោយឈឺឆ្អាលពុំមានការទទួលខុសត្រូវលើសំណងនៃការខូចខាត ដែលកើតឡើងដោយសារការគ្រប់គ្រងនោះ ។

មាត្រា ៧៣១.- ករណីយកិច្ចជូនដំណឹងរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវជូនដំណឹងអំពីការបានចាប់ផ្ដើមការគ្រប់គ្រងដោយឈឺឆ្អាលទៅឱ្យសាមីខ្លួន ដោយគ្មានការយឺតយ៉ាវ ។ ប៉ុន្តែ ក្នុងករណីដែលសាមីខ្លួនបានដឹងអំពីការគ្រប់គ្រងនោះហើយ ការជូនដំណឹងនេះពុំចាំបាច់ឡើយ ។

មាត្រា ៧៣២.- ករណីយកិច្ចបន្តការគ្រប់គ្រងរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវបន្តការគ្រប់គ្រងនោះរហូតដល់ពេលដែលសាមីខ្លួន សន្តតិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់សាមីខ្លួននោះ អាចធ្វើការគ្រប់គ្រងបាន ។ ប៉ុន្តែ ប្រសិនបើការបន្តការគ្រប់គ្រងនោះ ផ្ទុយនឹងឆន្ទៈរបស់សាមីខ្លួន ឬ ប្រសិនបើច្បាស់ថានឹងធ្វើឱ្យខូចផលប្រយោជន៍សាមីខ្លួន ត្រូវបញ្ឈប់ការគ្រប់គ្រងនោះ ។

មាត្រា ៧៣៣.- ការយកបញ្ញត្តិនៃអាណត្តិមកអនុវត្តដូចគ្នា

បញ្ញត្តិចាប់ពីមាត្រា ៦៤១ (ករណីយកិច្ចរាយការណ៍របស់អាណត្តិគាហក) រហូតដល់មាត្រា ៦៤៣ (ករណីយកិច្ចសងសំណងនៃការខូចខាតរបស់អាណត្តិគាហកដែលបានប្រើប្រាក់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ នៅក្នុងការគ្រប់គ្រងដោយឈឺឆ្អាល ។

មាត្រា ៧៣៤.- សិទ្ធិទាមទារសងសោហ៊ុយចំណាយរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

១-ប្រសិនបើបានចេញចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សាវត្ថុ ឬ ចំណាយបង្កើនតម្លៃ ដើម្បីសាមីខ្លួន អ្នកគ្រប់គ្រងដោយឈឺឆ្អាលអាចទាមទារ ចំពោះសាមីខ្លួនឱ្យសងវិញបាន ។

២-បញ្ញត្តិកថាខណ្ឌទី ២ នៃមាត្រា ៦៤៦ (សិទ្ធិទាមទារឱ្យសងមកវិញជាអាទិ៍នូវសោហ៊ុយរបស់អាណត្តិគាហក) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាលបានទទួលបន្ទុកកាតព្វកិច្ចដែលជាសោហ៊ុយដែលបានបង្កើនតម្លៃដើម្បីសាមីខ្លួន ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្ត ត្រឹមតែកម្រិតនៃផលប្រយោជន៍ដែលសាមីខ្លួនបានទទួលជាក់ស្តែង ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាលបានធ្វើការគ្រប់គ្រងផ្ទុយពីឆន្ទៈរបស់សាមីខ្លួន ។

មាត្រា ៧៣៥.- សិទ្ធិទាមទារកម្រៃរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

ក្នុងករណីដែលការគ្រប់គ្រងដោយឈឺឆ្អាលនោះរួមបញ្ចូលនៅក្នុងវិជ្ជាជីវៈ ឬ អាជីវកម្មរបស់អ្នកគ្រប់គ្រង ចំពោះកិច្ចការដែលនៅតែធ្វើបន្ត ក្រោយពេលដែលសាមីខ្លួនបានដឹងអំពីការគ្រប់គ្រងដោយឈឺឆ្អាលនោះរួចហើយ អ្នកគ្រប់គ្រងដោយឈឺឆ្អាល អាចទាមទារកម្រៃដែលត្រូវបង់ជាទូទៅ ចំពោះការគ្រប់គ្រងដោយឈឺឆ្អាលនោះបាន ។

ជំពូកទី ១៥
សេចក្តីចម្រើនដោយឥតហេតុ

មាត្រា ៧៣៦.- លក្ខខណ្ឌ និង អានុភាពនៃសេចក្តីចម្រើនដោយឥតហេតុ

១-ទោះបីជាគ្មានមូលហេតុលើផ្លូវច្បាប់ក៏ដោយ បុគ្គលដែលបានទទួលផលប្រយោជន៍ដោយសារទ្រព្យសម្បត្តិ ឬ ពលកម្មរបស់អ្នកដទៃ ហើយធ្វើឱ្យកើតមានការបាត់បង់ផលប្រយោជន៍ដល់អ្នកដទៃ ដោយសារការទទួលនោះ មានករណីយកិច្ចត្រូវសងផលប្រយោជន៍នោះ ត្រឹមកម្រិតដែលផលប្រយោជន៍នោះមាន ។

២-នៅក្នុងករណីដែលបានទទួលការផ្តល់តាវកាលិកពីអ្នកដទៃ ដោយយោលតាមកិច្ចសន្យា ប្រសិនបើកិច្ចសន្យានោះពុំមានអានុភាព ឬ ត្រូវបានបាត់បង់អានុភាពបុគ្គលដែលបានទទួលការផ្តល់តាវកាលិកនោះ មានករណីយកិច្ចត្រូវសងផលប្រយោជន៍ ដែលខ្លួនទទួលបានដោយសារការផ្តល់តាវកាលិកនោះ ឱ្យទៅអ្នកដទៃដែលបានផ្តល់តាវកាលិក នោះវិញដូចគ្នានឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះដែរ ។

មាត្រា ៧៣៧.- ករណីយកិច្ចសងរបស់អ្នកទទួលផលប្រយោជន៍ដោយគំនិតទុច្ចរិត

១-បុគ្គលដែលបានទទួលផលប្រយោជន៍ ដូចបានកំណត់នៅក្នុងមាត្រា ៧៣៦ (លក្ខខណ្ឌ និង អានុភាពនៃសេចក្តីចម្រើនដោយឥតហេតុ) ខាងលើនេះ ក្នុងករណីដែលបានដឹងថា

គ្មានមូលហេតុលើផ្លូវច្បាប់ ឬ ដឹងថាកិច្ចសន្យានោះពុំមានអានុភាព បុគ្គលដែលបានទទួលផលប្រយោជន៍មានករណីយកិច្ចត្រូវសងផលប្រយោជន៍ដែលមាននៅពេលដែលបានដឹង និង ការប្រាក់ គិតចាប់ពីពេលដែលបានដឹងរហូតដល់ពេលសង ។

២-បើបុគ្គលដែលបានទទួលផលប្រយោជន៍ មានចេតនា ឬ កំហុស ចំពោះអានុភាពនៃកិច្ចសន្យាដែលត្រូវបានបាត់បង់ បុគ្គលដែលបានទទួលផលប្រយោជន៍នោះ មានករណីយកិច្ចត្រូវសងផលប្រយោជន៍នោះ ដោយភ្ជាប់ជាមួយនឹងការប្រាក់ដូចគ្នានឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះដែរ ។

៣-បើបុគ្គលដែលត្រូវបានបាត់បង់ផលប្រយោជន៍ ទទួលការខូចខាត ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ បុគ្គលដែលបានទទួលផលប្រយោជន៍ត្រូវទទួលខុសត្រូវលើសំណងនៃការខូចខាតនោះ ។

មាត្រា ៧៣៨.- ការសងដោយគ្មានកាតព្វកិច្ច

បុគ្គលដែលបានសងកាតព្វកិច្ចដែលខ្លួនគ្មាន អាចទាមទារឱ្យសងតាវកាលិកនៃការសងនោះ មកវិញបាន ។ ប៉ុន្តែ ក្នុងករណីដែលដឹងថា គ្មានកាតព្វកិច្ចនៅពេលសងនោះទេ បុគ្គលដែលបានសង មិនអាចទាមទារឱ្យសងតាវកាលិកនៃការសងនោះ មកវិញបានឡើយ ។

មាត្រា ៧៣៩.- ការសងនៅមុនកំណត់ពេល

ក្នុងករណីដែលបានផ្តល់តាវកាលិកនៃការសង ចំពោះកាតព្វកិច្ចដែលមិនទាន់ដល់កំណត់ពេលសងនៅឡើយ កូនបំណុលពុំអាចទាមទារឱ្យសងតាវកាលិកដែលត្រូវបានផ្តល់នោះមកវិញបានឡើយ ។ ប៉ុន្តែ ក្នុងករណីដែលកូនបំណុលបានសង ដោយពុំបានដឹងអំពីកំណត់ពេលសងដែលមិនទាន់មកដល់នៅឡើយ ម្ចាស់បំណុលមានករណីយកិច្ច ត្រូវសងផលប្រយោជន៍ដែលបានទទួលដោយសារការសងនៅមុនកំណត់ពេលនោះ ។

មាត្រា ៧៤០.- ការសងកាតព្វកិច្ចរបស់អ្នកដទៃ

១-ក្នុងករណីដែលបុគ្គលក្រៅពីកូនបំណុលបានផ្តល់តាវកាលិកនៃការសង ដោយភាន់ច្រឡំកាតព្វកិច្ចរបស់អ្នកដទៃថាជាកាតព្វកិច្ចរបស់ខ្លួន អាចទាមទារឱ្យសងតាវកាលិកនោះ

មកវិញបាន ។ ប៉ុន្តែ ក្នុងករណីដែលម្ចាស់បំណុលពុំបានដឹងថា ការផ្តល់តាវកាលិកនោះ បណ្តាលមកពីការភាន់ច្រឡំរបស់បុគ្គលដែលបានផ្តល់តាវកាលិកនៃការសងនោះទេ ហើយបានបំផ្លាញលិខិតលាយល័ក្ខណ៍អក្សរដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិលើបំណុល ឬ បានបោះបង់ប្រាតិភោគចោល ដោយបានជឿជាក់ថាជាការសងដែលមានសុពលភាព បុគ្គលដែលបានផ្តល់តាវកាលិកនោះ មិនអាចទាមទារឱ្យសងតាវកាលិកនោះ មកវិញបានឡើយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងការអនុវត្តសិទ្ធិទាមទារសំណងរបស់បុគ្គលដែលបានផ្តល់តាវកាលិកនៃការសងចំពោះកូនបំណុលឡើយ ។

មាត្រា ៧៤១.- ការផ្តល់តាវកាលិកដោយមូលហេតុខុសច្បាប់

នៅក្នុងជំពូកទី ១៥(សេចក្តីចម្រើនដោយឥតហេតុ) នេះ ក្នុងករណីដែលការទាមទាររបស់បុគ្គលដែលត្រូវបានខូចខាតផលប្រយោជន៍ ចំពោះបុគ្គលដែលបានទទួលផលប្រយោជន៍នោះ ផ្ទុយនឹងរបៀបរៀបរយសាធារណៈ ឬ ទំនៀមទម្លាប់ល្អ ឬ ច្បាប់ដែលទាក់ទងទៅនឹងសណ្តាប់ធ្នាប់សាធារណៈ ការទាមទារឱ្យសងនោះ ពុំត្រូវបានអនុញ្ញាតឡើយ ។

ជំពូកទី ១៦

អំពើអនីត្យានុកូល

មាត្រា ៧៤២.- និយមន័យនៃកំហុសចេតនា និង អចេតនា

នៅក្នុងជំពូកទី ១៦(អំពើអនីត្យានុកូល) នេះ អំពើដោយមានកំហុសចេតនា ឬ អចេតនា សំដៅទៅលើ អំពើដែលត្រូវនឹងចំណុចណាមួយខាងក្រោមនេះ :

ក-ធ្វើអំពើបំពានដោយព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផល ហើយដោយទទួលយកការកើតឡើងនៃលទ្ធផលនោះ ។

ខ-ធ្វើអំពើដែល បើតាមប្រក្រតី បុគ្គលដែលមានឋានៈនៃការងារ ឬ បទពិសោធន៍ស្មើគ្នានឹងអ្នកធ្វើអំពើនោះ អាចព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផល ក៏ដោយ ក៏អ្នកធ្វើអំពើនោះនៅតែពុំបានព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផលនោះដោយសារការធ្វេសប្រហែសមិនប្រុងប្រយ័ត្ន ហើយទោះជាមានករណីយកិច្ចជៀសវាងនូវលទ្ធផលនោះក៏ដោយ

ក៏នៅតែប្រព្រឹត្តផ្ទុយនឹងករណីយកិច្ចនោះ ។

មាត្រា ៧៤៣.- លក្ខខណ្ឌ និង ការទទួលខុសត្រូវក្នុងការបញ្ជាក់បង្ហាញនៃអំពើអនីត្យានុកូលទូទៅ

១-បុគ្គលដែលបំពានដោយខុសច្បាប់នូវសិទ្ធិ ឬ ផលប្រយោជន៍របស់ជនដទៃ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ដែលកើតឡើងដោយអំពើនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះករណីដែលការខូចខាតបានកើតឡើង ដោយសារមានករណីយកិច្ចធ្វើអំពើណាមួយតែមិនបានធ្វើអំពើនោះ ។

៣-ចំពោះកំហុសចេតនា ឬ កំហុសអចេតនារបស់ចារីនេះ ទំនាក់ទំនងនៃហេតុផលរវាងអំពើរបស់អ្នកប្រព្រឹត្តអំពើបំពាន និង ការកើតឡើងនៃការខូចខាត និង ការខូចខាតដែលកើតមានឡើងលើជនរងគ្រោះ បុគ្គលដែលទាមទារសំណងការខូចខាតនោះ ត្រូវបញ្ជាក់បង្ហាញ លើកលែងតែមានបញ្ញត្តិពិសេសនៅក្នុងក្រមនេះ ឬ ច្បាប់ផ្សេងទៀត ។

មាត្រា ៧៤៤.- សំណងនៃការខូចខាតដែលមិនមែនជាទ្រព្យសម្បត្តិ

បុគ្គលដែលទទួលខុសត្រូវតាមបញ្ញត្តិនៃមាត្រា ៧៤៣ (លក្ខខណ្ឌ និង ការទទួលខុសត្រូវក្នុងការបញ្ជាក់បង្ហាញនៃអំពើអនីត្យានុកូលទូទៅ) ខាងលើនេះ ត្រូវសងការខូចខាតចំពោះអ្វីដែលមិនមែនជាទ្រព្យសម្បត្តិផងដែរ ។

មាត្រា ៧៤៥.- អសមត្ថភាពក្នុងការទទួលខុសត្រូវ

១-ជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលទេ ។

២-បុគ្គលដែលស្ថិតក្នុងស្ថានភាពដែលមិនអាចយល់ដឹង និងវិនិច្ឆ័យបានអំពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន នៅពេលដែលខ្លួនបានប្រព្រឹត្តអំពើបំពាននោះ ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ឬ មូលហេតុផ្សេងទៀត មិនត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលឡើយ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលស្ថានភាពនោះបណ្តាល

ROYAUME DU CAMBODGE - LE MINISTERE ROYAL
ក្រសួងមហាវាំង

មកដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ។

មាត្រា ៧៤៦.- ការទទួលខុសត្រូវរបស់អ្នកមានករណីយកិច្ចត្រួតពិនិត្យ

១-បុគ្គលដែលមានករណីយកិច្ចដែលបានកំណត់ដោយច្បាប់ក្នុងការត្រួតពិនិត្យអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ឬ បុគ្គលដែលស្ថិតក្នុងស្ថានភាពដែលមិនអាចយល់ដឹង និងវិនិច្ឆ័យបានអំពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ឬ មូលហេតុផ្សេងទៀត មានករណីយកិច្ចត្រូវសងការខូចខាតរបស់ អ្នកដទៃ ដែលកើតឡើងដោយអំពើបំពានរបស់បុគ្គលនៅក្រោមការត្រួតពិនិត្យរបស់ខ្លួននេះ ។

២-បុគ្គលដែលមានករណីយកិច្ចដែលបានកំណត់ដោយច្បាប់ក្នុងការត្រួតពិនិត្យអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពជាមួយអនីតិជន ចំពោះការខូចខាតរបស់អ្នកដទៃដែលកើតឡើង ដោយអំពើអនីត្យានុកូលរបស់អនីតិជននោះ ។

៣-បុគ្គលដែលមានករណីយកិច្ចត្រួតពិនិត្យដែលទទួលខុសត្រូវក្នុងការសងការខូចខាតតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ អាចរួចខ្លួនពីការទទួលខុសត្រូវក្នុងការសងការខូចខាតបានដោយបញ្ជាក់បង្ហាញថា ខ្លួនបានបំពេញករណីយកិច្ចត្រួតពិនិត្យជាប្រក្រតី ។

មាត្រា ៧៤៧.- ការទទួលខុសត្រូវរបស់និយោជក

១-បុគ្គលដែលប្រើនិយោជិតដើម្បីអនុវត្តកិច្ចការ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ដែលនិយោជិតបានបង្កដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា នៅក្នុងការអនុវត្តកិច្ចការនោះ ។

២-បុគ្គលដែលស្ថិតក្នុងឋានៈត្រូវត្រួតពិនិត្យនិយោជិតជំនួសនិយោជក ត្រូវទទួលខុសត្រូវដូចគ្នានឹងនិយោជកដែរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបុគ្គលនោះបានត្រួតពិនិត្យដោយត្រឹមត្រូវ ។

៣-និយោជក ឬ អ្នកត្រួតពិនិត្យជំនួស អាចទាមទារសំណងពីនិយោជិតបាន ដោយយោងទៅតាមកម្រិតនៃកំហុសរបស់និយោជិតនោះ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

មាត្រា ៧៤៨.- អំពើអនីត្យានុកូលរបស់នីតិបុគ្គល

១-នីតិបុគ្គលត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ដែលសមាជិកគណៈកម្មការនាយក ឬ អ្នកតំណាងឯទៀត បានបង្កដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ក្នុងការអនុវត្តភារកិច្ច ។

២-បើបានសងការខូចខាតតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ នីតិបុគ្គលអាចទាមទារសំណងពីអ្នកតំណាងដែលបានប្រព្រឹត្តអំពើបង្កការខូចខាតនោះ ។

មាត្រា ៧៤៩.- អំពើអនីត្យានុកូលរបស់មន្ត្រីរាជការ

១-បើមន្ត្រីរាជការដែលទទួលការអនុវត្តនូវអំណាចសាធារណៈរបស់រដ្ឋ ឬ ស្ថាប័នសាធារណៈ បានបង្កការខូចខាតដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនាក្នុងការអនុវត្តភារកិច្ចរបស់ខ្លួននោះ រដ្ឋ ឬ ស្ថាប័នសាធារណៈ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើកម្រិតនៃការបំពានករណីយកិច្ចរបស់មន្ត្រីរាជការ ក្នុងការជៀសវាងនូវលទ្ធផល មានភាពធ្ងន់ធ្ងរ រដ្ឋ ឬ ស្ថាប័នសាធារណៈអាចទាមទារសំណងពីមន្ត្រីរាជការនោះបាន ។

មាត្រា ៧៥០.- ការទទួលខុសត្រូវរបស់អ្នកកាន់កាប់សត្វ

បុគ្គលដែលកាន់កាប់សត្វ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើង ដល់អ្នកដទៃ ដោយសត្វដែលខ្លួនកាន់កាប់ ។

មាត្រា ៧៥១.- ការទទួលខុសត្រូវចំពោះផលិតផលរបស់អ្នកផលិតវត្ថុ

១-ក្នុងករណីដែលមានវិការៈនាំឱ្យមានគ្រោះថ្នាក់មិនសមហេតុផលក្នុងចលនវត្ថុដែលត្រូវបានផលិត ហើយបានបណ្តាលឱ្យមានការខូចខាតដល់អ្នកដទៃដោយវិការៈនោះ ផលិតករនៃចលនវត្ថុនោះត្រូវទទួលខុសត្រូវក្នុងការសងនូវការខូចខាតនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះករណីដែលមិនអាចប្រមាណនូវវិការៈនោះ តាមកម្រិតវិទ្យាសាស្ត្រនៃបច្ចេកទេសដែលមាននៅសម័យដែលផលិតនោះ ។

២-អ្នកដែលផលិតចលនវត្ថុដែលផ្គុំដោយគ្រឿង ឬ វត្ថុធាតុដើមដែលមានវិការៈ ត្រូវទទួលខុសត្រូវក្នុងការសងនូវការខូចខាត ក្នុងនាមជាផលិតករផងដែរ ។

៣-ក្នុងខ្លឹមសារនៃមាត្រានេះ ចំពោះចលនវត្ថុដែលនាំចូល អ្នកនាំចូលត្រូវចាត់ទុកថាជាផលិតករ ។

៤-ក្នុងខ្លឹមសារនៃមាត្រានេះ បុគ្គលដែលបានដាក់សញ្ញាណនៃនាមករណ៍របស់ខ្លួនជាផលិតករ ឬ អ្នកលក់ នៅលើចលនវត្ថុ ត្រូវចាត់ទុកថាជាផលិតករនៃចលនវត្ថុនោះ ។

មាត្រា ៧៥២.- ការទទួលខុសត្រូវចំពោះវត្ថុគ្រោះថ្នាក់

បុគ្គលជាកម្មសិទ្ធិករ ឬ អ្នកគ្រប់គ្រងរថយន្ត គ្រឿងចក្រសម្រាប់ដឹកជញ្ជូនផ្សេងទៀត គ្រឿងផ្ទុះ វត្ថុធាតុវិទ្យុសកម្ម វត្ថុធាតុគីមីដែលមានជាតិពុល អតិសុខុមប្រាណឧត្បាត ឬ គ្រឿងដែលមានកម្រិតគ្រោះថ្នាក់ខ្ពស់ផ្សេងទៀត ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលបង្កដល់អ្នកដទៃ ដោយសារវត្ថុគ្រោះថ្នាក់ដែលខ្លួនមានកម្មសិទ្ធិ ឬ គ្រប់គ្រង ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការខូចខាតនោះកើតមានឡើងបណ្តាលមកពីប្រធានសក្តិ ឬ ករណីដែលការគ្រប់គ្រងវត្ថុគ្រោះថ្នាក់គ្មានវិការៈ ហើយការខូចខាតបានកើតឡើងដោយសារអំពើរបស់ជនរងគ្រោះ ឬ តតិយជន ។

មាត្រា ៧៥៣.- ការទទួលខុសត្រូវចំពោះសំណង់ដែលជាប់នឹងដី

១-ក្នុងករណីដែលការសាងសង់សំណង់ដែលជាប់នឹងដី ឬ ការគ្រប់គ្រងសំណង់នោះមានវិការៈ ហើយបានបណ្តាលឱ្យមានការខូចខាតដល់អ្នកដទៃ អ្នកគ្រប់គ្រងសំណង់ និង កម្មសិទ្ធិករនៃសំណង់នោះត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ក្នុងការសងការខូចខាតនោះ ។ ប៉ុន្តែក្នុងករណីដែលអ្នកគ្រប់គ្រងបានបញ្ជាក់ថា ខ្លួនបានគ្រប់គ្រងដោយត្រឹមត្រូវ អ្នកគ្រប់គ្រងនោះអាចរួចផុតពីការទទួលខុសត្រូវបាន ។

២-បន្ទុករបស់កម្មសិទ្ធិករនៃសំណង់ដែលជាប់នឹងដី និង អ្នកគ្រប់គ្រងសំណង់នោះ ត្រូវកំណត់នៅតាមកម្រិតនៃការបង្កឱ្យមានវិការៈ នៃការសាងសង់ ឬ ការគ្រប់គ្រង ។

មាត្រា ៧៥៤.- អំពើអនីត្យានុកូលរួម

១-បើការខូចខាតបានកើតឡើង ដោយសារអំពើរបស់បុគ្គលច្រើននាក់រួមគ្នា អ្នកប្រព្រឹត្តអំពើបំពាននីមួយៗត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដោយសាមគ្គីភាព ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើអ្នកប្រព្រឹត្តអំពើបំពាននីមួយៗ បានបញ្ជាក់អំពីភាគនៃអំពើដែលខ្លួនបានបង្កឱ្យមានការខូចខាត ជននោះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត តាមសមាមាត្រនៃភាគដែលខ្លួនបានបង្ក ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលទទួលស្គាល់ថា មានការសមគំនិត ឬ មានទំនាក់ទំនងសហការយ៉ាងជិតស្និទ្ធក្នុងចំណោមអ្នកប្រព្រឹត្តអំពើបំពាន ។

៣-បើជនម្នាក់ក្នុងចំណោមអ្នកប្រព្រឹត្តអំពើអនីត្យានុកូលរួម បានសងការខូចខាតទាំងអស់ ដោយចេញចំណាយរបស់ខ្លួន ជននោះអាចទាមទារសំណងពីអ្នកផ្សេងទៀតដែលប្រព្រឹត្តអំពើអនីត្យានុកូលរួមនោះបាន តាមសមាមាត្រនៃភាគដែលជនម្នាក់ៗបានបង្ក ។

មាត្រា ៧៥៥.- និយមន័យនៃការការពារខ្លួនស្របច្បាប់ និង ស្ថានភាពចាំបាច់

១-អំពើការពារជាធម្មានុរូប សំដៅទៅលើអំពើរំលោភដែលពុំអាចជៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ អ្នកដទៃ ចំពោះអំពើបំពានមិនត្រឹមត្រូវ ហើយដែលស្ថិតក្នុងករណីដែលពេលវេលានៃអំពើបំពាន និង អំពើរំលោភនោះស្ថិតជិតគ្នា និង មានតុល្យភាពរវាងវិធីការពារនិងកម្រិតនៃអំពើបំពាននោះ ។

២-អំពើដោយសារស្ថានភាពចាំបាច់ សំដៅទៅលើអំពើរំលោភដែលពុំអាចជៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ អ្នកដទៃ ចំពោះគ្រោះថ្នាក់បច្ចុប្បន្ន ឬ អច្ចាសន្ន ហើយដែលស្ថិតក្នុងករណីមានតុល្យភាពរវាងវិធីការពារ និង កម្រិតគ្រោះថ្នាក់នោះ ។

មាត្រា ៧៥៦.- មូលហេតុនៃការរួចផុតពីភាពផ្ទុយច្បាប់

១-អ្នកប្រព្រឹត្តអំពើបំពានត្រូវរួចផុតពីការទទួលខុសត្រូវ ក្នុងករណីដែលមានការយល់ព្រម ឬ ការទទួលយកគ្រោះថ្នាក់ ពីសំណាក់អ្នករងគ្រោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការយល់ព្រម ឬ ការទទួលយកគ្រោះថ្នាក់នោះ មិនត្រូវបានសង្គមទទួលស្គាល់ថាសមហេតុផល ។

២-ចំពោះការខូចខាតដែលកើតមានឡើងដោយសារអំពើការពារជាធម្មានុរូប ឬ អំពើដោយសារស្ថានភាពចាំបាច់ អ្នកដែលបានប្រព្រឹត្តអំពើការពារ ឬ អំពើដោយសារស្ថានភាពចាំបាច់ ពុំត្រូវទទួលខុសត្រូវឡើយ ។ ក្នុងករណីនេះ បុគ្គលដែលបានប្រព្រឹត្តអំពើផ្ទុយច្បាប់ដែលជាមូលហេតុនៃអំពើនោះ ត្រូវទទួលខុសត្រូវ ។

៣-ចំពោះការខូចខាតដោយសារអំពើដែលត្រូវសង្គមទទួលស្គាល់ថា សមហេតុផល អ្នកប្រព្រឹត្តអំពើបំពានមិនត្រូវទទួលខុសត្រូវឡើយ ។

មាត្រា ៧៥៧.- គោលការណ៍សងការខូចខាតជាប្រាក់ និង ករណីលើកលែង

១-ជាគោលការណ៍ សំណងនៃការខូចខាតត្រូវសងជាប្រាក់ ។

២-ក្នុងករណីដែលមិនអាចទទួលការសង្គ្រោះត្រឹមត្រូវដោយសំណងជាប្រាក់ ជនរងគ្រោះអាចទាមទារឱ្យធ្វើបដិទាន ឬ អាចទាមទារឱ្យហាមឃាត់មិនឱ្យធ្វើអំពើណាមួយបាន ។

៣-ចំពោះការបរិហារកេរ្តិ៍ ក្រៅពីសំណងនៃការខូចខាត ជនរងគ្រោះអាចទាមទារវិធានការស្តារកិត្តិយសឡើងវិញ ដូចជាការផ្សព្វផ្សាយសេចក្តីសុំអភ័យទោសជាសាធារណៈបាន ។

មាត្រា ៧៥៨.- ការគណនាចំនួនទឹកប្រាក់នៃការខូចខាត

១-ក្នុងការគណនាចំនួនទឹកប្រាក់នៃការខូចខាតលើទ្រព្យសម្បត្តិដោយសារអំពើអនីត្យានុកូល ភាពខុសគ្នារវាងស្ថានភាពនៃទ្រព្យសម្បត្តិដែលត្រូវបានសន្មតថានឹងមាន ប្រសិនបើគ្មានអំពើអនីត្យានុកូល និង ស្ថានភាពនៃទ្រព្យសម្បត្តិជាក់ស្តែង ក្រោយពេលដែលអំពើអនីត្យានុកូលបានកើតឡើង ត្រូវបានវាយតម្លៃ ដោយប្រើប្រាស់នូវស្ថិតិ និង ឯកសារផ្សេងទៀត ។

២-ក្នុងការគណនាចំនួនទឹកប្រាក់នៃការខូចខាតសតិអារម្មណ៍ដោយសារអំពើអនីត្យានុកូល ចំនួនទឹកប្រាក់នៃជម្ងឺចិត្ត ត្រូវបានវាយតម្លៃ ដោយគិតពិចារណានូវស្ថានភាពផ្សេងៗ ដូចជាកម្រិតនៃកំហុសចេតនា ឬ អចេតនារបស់អ្នកប្រព្រឹត្តអំពើបំពានប្រភេទ និង កម្រិតនៃការរងគ្រោះ អំពើរបស់អ្នកប្រព្រឹត្តអំពើបំពាននៅក្រោយអំពើបង្កឱ្យមានការរងគ្រោះនោះ ។

មាត្រា ៧៥៩.- ការទាមទារសំណងនៃការខូចខាតដោយសារការបាក់បែកវត្ថុ

នៅពេលដែលវត្ថុបានបាក់បែក ដោយអំពើអនីត្យានុកូល អ្នករងគ្រោះអាចទាមទារ

សំណង ដូចជាតម្លៃនៃវត្ថុដែលបាក់បែក ឬ សោហ៊ុយជួសជុលវត្ថុនោះ ជាអាទិ៍ ។

មាត្រា ៧៦០.- ការទាមទារសំណងនៃការខូចខាតដោយការបំពានលើជីវិត

១-បើជនរងគ្រោះទទួលមរណភាព ដោយអំពើអនីត្យានុកូល អ្នករងគ្រោះអាចទទួលសិទ្ធិទាមទារសំណងចំពោះការខូចខាតលើទ្រព្យសម្បត្តិ និង ការខូចខាតសតិអារម្មណ៍ដែលបានកើតឡើងចំពោះខ្លួន រហូតដល់មរណភាព ។ ការខូចខាតលើទ្រព្យសម្បត្តិ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នេះ ត្រូវរួមបញ្ចូលទាំងសោហ៊ុយព្យាបាល និង សោហ៊ុយចំណាយផ្សេងទៀតដែលជនរងគ្រោះបានបង់ ឬ មានករណីយកិច្ចត្រូវបង់ ចាប់ពីក្រោយអំពើបង្កឱ្យមានការរងគ្រោះ រហូតដល់ពេលទទួលមរណភាព ប្រាក់ចំណូលដែលជនរងគ្រោះមិនបានទទួល ចាប់ពីក្រោយអំពើបង្កឱ្យមានការរងគ្រោះ រហូតដល់ពេលទទួលមរណភាព ជាអាទិ៍ ។

២-បើបុគ្គលដែលមានករណីយកិច្ចផ្តល់អាហារកាតព្វកិច្ច ដោយច្បាប់ ទំនៀមទំលាប់ ឬ ដោយកិច្ចសន្យា បានទទួលមរណភាព ដោយអំពើអនីត្យានុកូល បុគ្គលដែលទទួលជីវព្រឹត្តិអាចទាមទារសំណងការខូចខាតលើទ្រព្យសម្បត្តិ ដែលបានកើតឡើងចំពោះខ្លួន ដោយសារមរណភាពរបស់ជនរងគ្រោះ ។ ការខូចខាតលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នេះ ត្រូវរួមបញ្ចូលទាំងប្រាក់ជីវព្រឹត្តិដែលបុគ្គលដែលទទួលជីវព្រឹត្តិលែងបានទទួលដោយសារមរណភាពនៃជនរងគ្រោះ សោហ៊ុយដែលចេញជំនួសជនរងគ្រោះ សោហ៊ុយធ្វើបុណ្យសពជាអាទិ៍ ។

៣-បើជនរងគ្រោះទទួលមរណភាព ដោយអំពើអនីត្យានុកូល សហព័ទ្ធ ញាតិនៅក្នុង ១ (មួយ) ថ្នាក់ និង ញាតិដែលរស់នៅជាមួយជនរងគ្រោះ អាចទាមទារសំណងនៃការខូចខាតសតិអារម្មណ៍ដែលបានកើតឡើង ដោយសារមរណភាពរបស់ជនរងគ្រោះនោះបាន ។

មាត្រា ៧៦១.- ការទាមទារសំណងនៃការខូចខាតដោយការបំពានលើរូបរាងកាយ

បើមានការបំពានលើរូបរាងកាយ ដោយអំពើអនីត្យានុកូល ជនរងគ្រោះអាចទាមទារសំណងនៃការខូចខាតលើទ្រព្យសម្បត្តិ និង ការខូចខាតសតិអារម្មណ៍ដែលបានកើតឡើងចំពោះខ្លួន ។ ការខូចខាតលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងមាត្រានេះ ត្រូវរួមបញ្ចូលទាំងសោ-ហ៊ុយព្យាបាលដែលបានចំណាយហើយ ឬ សោហ៊ុយព្យាបាលដែលប្រមាណថានឹងត្រូវចំណាយ

នាពេលអនាគត ប្រាក់ចំណូលដែលមិនអាចទទួលបាននៅពេលកំពុងព្យាបាល និង ប្រាក់ចំណូលដែលមិនអាចទទួលបាននៅពេលអនាគតដោយសារផលវិបាកដែលបន្សល់ក្រោយពីការព្យាបាលជាអាទិ៍ ។ ការខូចខាតដែលបានកំណត់នៅក្នុងមាត្រានេះ ត្រូវរួមបញ្ចូលទាំងការឈឺចាប់ផ្នែកសតិអារម្មណ៍នៅពេលព្យាបាល និង ពេលអនាគត ជាអាទិ៍ ។

មាត្រា ៧៦២.- ការទាមទារសំណងនៃការខូចខាតផ្នែកសតិអារម្មណ៍ដោយសារការបរិហារកេរ្តិ៍

បើមានការបរិហារកេរ្តិ៍ ដោយអំពើអនីត្យានុកូល ជនរងគ្រោះអាចទាមទារសំណងនៃការខូចខាតសតិអារម្មណ៍ ដោយសារការអាប់ឱនកេរ្តិ៍ឈ្មោះក្នុងសង្គម ។

មាត្រា ៧៦៣.- ការទូទាត់ប្រាក់ចំណេញ និង ខាត

ប្រសិនបើជនរងគ្រោះបានទទួលផលចំណេញដោយសារអំពើអនីត្យានុកូល ចំនួនប្រាក់ចំណេញនោះត្រូវដកចេញ នៅពេលធ្វើការគណនាចំនួនទឹកប្រាក់នៃការខូចខាត ។

មាត្រា ៧៦៤.- ការទូទាត់នូវកំហុស

បើកំហុសរបស់ជនរងគ្រោះ ឬ កំហុសរបស់អ្នកដែលមានករណីយកិច្ចត្រូវត្រួតពិនិត្យជនរងគ្រោះ បានរួមចំណែកក្នុងការកើតឡើង ឬរីករាលដាលនៃការខូចខាត តុលាការអាចគិតពិចារណានូវកម្រិតនៃការរួមចំណែកនោះ នៅពេលធ្វើការគណនាចំនួនទឹកប្រាក់នៃការខូចខាត ។

មាត្រា ៧៦៥.- អាជ្ញាយុកាលនៃការរំលត់

សិទ្ធិទាមទារសំណងនៃការខូចខាតដោយអំពើអនីត្យានុកូល ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ៣ (បី) ឆ្នាំ បានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះ ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់ជនរងគ្រោះនោះបានដឹងថា អាចទាមទារសំណងការខូចខាតចំពោះអ្នកប្រព្រឹត្តអំពើបំពាន ឬ បើអំឡុងពេល ១០ (ដប់) ឆ្នាំ បានកន្លងហួស បន្ទាប់ពីអំពើអនីត្យានុកូលនោះត្រូវបានប្រព្រឹត្តឡើង ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

គន្ថីទី ៦

ការធានាកាតព្វកិច្ច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ៧៦៦.- និយមន័យនៃអ្នកធានាដោយវត្ថុ និង តតិយជនដែលបានធ្វើលទ្ធកម្ម

១-បុគ្គលដែលបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើទ្រព្យសម្បត្តិរបស់ខ្លួន ដើម្បីធានាកាតព្វកិច្ចរបស់អ្នកដទៃ ត្រូវហៅថា អ្នកធានាដោយវត្ថុ ។

២-បុគ្គលដែលបានធ្វើលទ្ធកម្មនូវវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគប្រត្យក្ស ដែលបង្កើតឡើងដោយកូនបំណុល ដើម្បីធានាកាតព្វកិច្ចរបស់ខ្លួន ត្រូវហៅថាតតិយជនដែលបានធ្វើលទ្ធកម្ម ។

មាត្រា ៧៦៧.- ប្រភេទនៃសិទ្ធិប្រាតិភោគប្រត្យក្ស

១-ប្រភេទនៃសិទ្ធិប្រាតិភោគប្រត្យក្សត្រូវកម្រិតតែប្រភេទដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ឬ ច្បាប់ពិសេសតែប៉ុណ្ណោះ ហើយក្រៅពីនេះមិនអាចបង្កើតបានឡើយ ។

២-សិទ្ធិប្រាតិភោគប្រត្យក្សដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីនេះ មាន ៥ (ប្រាំ) ប្រភេទ គឺ សិទ្ធិឃាត់ទុក ឯកសិទ្ធិ សិទ្ធិលើការបញ្ចាំ ហ៊ីប៉ូតែក និង សិទ្ធិប្រាតិភោគ ដោយអនុប្បទាន ។

មាត្រា ៧៦៨.- វត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគប្រត្យក្ស

សិទ្ធិប្រាតិភោគប្រត្យក្សមិនអាចយកវត្ថុ ឬ សិទ្ធិណាដែលមិនអាចធ្វើអនុប្បទានបានមកធ្វើជាកម្មវត្ថុបានទេ ។ ប៉ុន្តែ បញ្ញត្តិនេះមិនរារាំងការបង្កើតសិទ្ធិឃាត់ទុកលើវត្ថុ ដែលមិនអាចធ្វើអនុប្បទានបានឡើយ ។

មាត្រា ៧៦៩.- ភាពបន្ទាប់បន្សំនៃសិទ្ធិប្រាតិភោគប្រត្យក្ស

១-សិទ្ធិប្រាតិភោគប្រត្យក្ស ត្រូវបានបង្កើតឡើង ដើម្បីធានាកាតព្វកិច្ចដែលមានអត្ថិភាព ហើយទោះបីជាកាតព្វកិច្ចដែលនឹងកើតឡើងនាពេលអនាគតក៏ដោយ ក្នុងករណីដែល

166/466

អាចកំណត់កាតព្វកិច្ចបាន ក៏សិទ្ធិប្រាតិភោគប្រត្យក្សអាចបង្កើតបានដែរ ដោយយកកាតព្វកិច្ចនោះមកធ្វើជាកាតព្វកិច្ចដែលត្រូវបានធានា ។

២-ក្នុងករណីដែលសិទ្ធិលើបំណុលដែលត្រូវបានធានាមិនត្រូវបានបង្កើតឡើង ដោយសារខ្វះល័ក្ខខ័ណ្ឌ សិទ្ធិប្រាតិភោគប្រត្យក្សក៏មិនត្រូវបានបង្កើតឡើងដែរ ។

៣-ក្នុងករណីដែលសិទ្ធិលើបំណុលដែលត្រូវបានធានាត្រូវបានចាត់ទុកជាមោឃៈដោយសារមានវិការៈក្នុងការបង្ហាញឆន្ទៈ ឬ ដោយសារហេតុផ្សេងទៀត ឬ ក្នុងករណីដែលសិទ្ធិលើបំណុលដែលត្រូវបានធានាត្រូវបានលុបចោលសិទ្ធិប្រាតិភោគប្រត្យក្សក៏មិនត្រូវមានអានុភាពឡើយ ។

៤-ក្នុងករណីដែលសិទ្ធិលើបំណុលដែលត្រូវបានធានាបានរលត់ ដោយសារការសង ឬ អាជ្ញាយុកាលនៃការរំលត់សិទ្ធិ ឬ ហេតុផ្សេងទៀត សិទ្ធិប្រាតិភោគប្រត្យក្សក៏ត្រូវរលត់ដែរ ។

៥-បញ្ញត្តិនៃកថាខណ្ឌទី ១ ទី ២ ទី ៣ និង កថាខណ្ឌទី ៤ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដែលត្រូវបានបង្កើតឡើង ដើម្បីធានាសិទ្ធិលើបំណុលច្រើនដែលកើតឡើងដោយកិច្ចសន្យាបន្តបន្ទាប់ ។

មាត្រា ៧៧០.- ភាពទៅជាមួយគ្នានៃសិទ្ធិប្រាតិភោគប្រត្យក្ស

១-ក្នុងករណីដែលសិទ្ធិលើបំណុលដែលសិទ្ធិប្រាតិភោគប្រត្យក្សត្រូវបានបង្កើត ត្រូវបានផ្ទេរ បើគ្មានការបង្ហាញឆន្ទៈផ្សេងទេ សិទ្ធិប្រាតិភោគប្រត្យក្សនោះក៏ត្រូវបានផ្ទេរទៅឱ្យអ្នកដែលទទួលសិទ្ធិលើបំណុលនេះដែរ ។ ប៉ុន្តែ ក្នុងករណីដែលចាំបាច់តម្រូវឱ្យម្ចាស់សិទ្ធិលើប្រាតិភោគកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគនោះ អ្នកទទួលការផ្ទេរសិទ្ធិលើបំណុលក៏ចាំបាច់ត្រូវទទួលនូវការកាន់កាប់វត្ថុដែលជាកម្មវត្ថុនោះដែរ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានា ដោយសិទ្ធិលើការបញ្ចាំដើម្បីធានាបំណុលអណ្តែត ឬ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ។

មាត្រា ៧៧១.- អវិភាគភាពនៃសិទ្ធិប្រាតិភោគប្រត្យក្ស

អវិភាគភាពនៃសិទ្ធិប្រាតិភោគប្រត្យក្សត្រូវមានលើវត្ថុ ឬ សិទ្ធិដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិ-

ROYAUME DU CAMBODGE LE MINISTERE DU PALAIS ROYAL

ភោគប្រត្យក្សទាំងអស់ រហូតដល់ពេលដែលម្ចាស់សិទ្ធិប្រាតិភោគបានទទួលសំណងនៃសិទ្ធិលើបំណុលទាំងអស់ ។

មាត្រា ៧៧២.- អានុភាពតាមនៃសិទ្ធិប្រាតិភោគប្រត្យក្ស

ក្នុងករណីដែលវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគប្រត្យក្សត្រូវបានធ្វើអនុប្បទានទៅតតិយជន ម្ចាស់សិទ្ធិប្រាតិភោគនោះ អាចយកអានុភាពនៃសិទ្ធិប្រាតិភោគប្រត្យក្សមកតតាំងចំពោះតតិយជននោះបាន លើកលែងតែករណីដែលបានកំណត់នៅក្នុងមាត្រា ៨០៧ (អានុភាពតាមចំពោះតតិយជនដែលបានធ្វើលទ្ធកម្ម) ស្តីពីឯកសិទ្ធិ និងមាត្រា ៨៩៤ (ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយអ្នកបង្កើត) ស្តីពីប្រាតិភោគដោយអនុប្បទាននៃក្រមនេះ ។ ប៉ុន្តែតម្រូវឱ្យម្ចាស់សិទ្ធិប្រាតិភោគនោះមានគ្រប់គ្រាន់នូវល័ក្ខខ័ណ្ឌតតាំង ។

មាត្រា ៧៧៣.- ការអនុវត្តសិទ្ធិប្រាតិភោគប្រត្យក្ស

ប្រសិនបើម្ចាស់សិទ្ធិប្រាតិភោគមិនបានទទួលសំណងនៃសិទ្ធិលើបំណុលទេ អ្នកនោះអាចអនុវត្តសិទ្ធិប្រាតិភោគប្រត្យក្សនេះ តាមនីតិវិធីដែលច្បាប់បានកំណត់បាន ។

ជំពូកទី ២

សិទ្ធិឃាត់ទុក

មាត្រា ៧៧៤.- អត្ថន័យនៃសិទ្ធិឃាត់ទុក

១-ប្រសិនបើអ្នកកាន់កាប់វត្ថុរបស់អ្នកដទៃ មានសិទ្ធិលើបំណុលដែលបានកើតឡើងដោយទាក់ទងនឹងវត្ថុនោះ អ្នកនោះអាចឃាត់ទុកនូវវត្ថុនោះបានរហូតដល់ពេលដែលខ្លួនទទួលការសងចំពោះសិទ្ធិលើបំណុលនោះ ។ ប៉ុន្តែ សិទ្ធិឃាត់ទុកមិនត្រូវកើតមានឡើយ ប្រសិនបើសិទ្ធិលើបំណុលនោះមិនទាន់ដល់ពេលកំណត់ត្រូវសង ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការកាន់កាប់ត្រូវបានចាប់ផ្តើមដោយអំពើអនីត្យានុកូល ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

មាត្រា ៧៧៥.- សិទ្ធិទទួលសំណងពីផលដោយមានអាទិភាព

១-ម្ចាស់សិទ្ធិឃាត់ទុក អាចទទួលផលពីវត្ថុដែលឃាត់ទុក និង អាចយកផលនោះ មកកាត់សិទ្ធិលើបំណុល ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតបាន ។

២-ផលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកកាត់ការប្រាក់នៃសិទ្ធិលើបំណុលជាមុនសិន ហើយប្រសិនបើមានសំណល់ ត្រូវយកមកកាត់ប្រាក់ដើម ។

មាត្រា ៧៧៦.- ករណីយកិច្ចរបស់ម្ចាស់សិទ្ធិឃាត់ទុកក្នុងការរក្សាគ្រប់គ្រងវត្ថុដែលឃាត់ទុក

១-ម្ចាស់សិទ្ធិឃាត់ទុក ត្រូវកាន់កាប់វត្ថុដែលឃាត់ទុកនោះ ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

២-ម្ចាស់សិទ្ធិឃាត់ទុក មិនអាចយកវត្ថុដែលឃាត់ទុកនោះ ទៅប្រើប្រាស់ ឬ ជួល ឬ ដាក់ជាប្រាតិភោគបានទេ បើគ្មានការយល់ព្រមពីសំណាក់កូនបំណុល ។ ប៉ុន្តែ ម្ចាស់សិទ្ធិឃាត់ទុកអាចប្រើប្រាស់វត្ថុដែលឃាត់ទុកបានត្រឹមកម្រិតដែលចាំបាច់ក្នុងការរក្សានូវវត្ថុឃាត់ទុកនោះ ។

៣-ប្រសិនបើម្ចាស់សិទ្ធិឃាត់ទុកបានធ្វើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ កូនបំណុលអាចទាមទារឱ្យរំលត់នូវសិទ្ធិឃាត់ទុកនោះបាន ។

មាត្រា ៧៧៧.- សិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិឃាត់ទុក

១-ប្រសិនបើម្ចាស់សិទ្ធិឃាត់ទុកបានចេញចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និងថែរក្សាវត្ថុ ចំពោះវត្ថុដែលឃាត់ទុក ម្ចាស់សិទ្ធិឃាត់ទុកនោះ អាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងចំណាយវិញបាន ។

២-ប្រសិនបើម្ចាស់សិទ្ធិឃាត់ទុកបានចេញចំណាយបង្កើនតម្លៃ ចំពោះវត្ថុដែលឃាត់ទុក ម្ចាស់សិទ្ធិឃាត់ទុកនោះ អាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងចំណាយទាំងអស់ដែលខ្លួនបានចេញ ឬ តម្លៃប្រាក់កំណើនដែលមានអត្ថិភាព តាមការជ្រើសរើសរបស់កម្មសិទ្ធិករបាន ក្នុងករណីដែលកំណើនតម្លៃនោះនៅតែមាន ។ ប៉ុន្តែ តុលាការអាចកំណត់ពេលសមរម្យដើម្បីសងតាមការទាមទាររបស់កម្មសិទ្ធិករបាន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

មាត្រា ៧៧៨.- អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ការអនុវត្តសិទ្ធិឃាត់ទុក មិនរារាំងដំណើរការនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ ។

មាត្រា ៧៧៩.- ការរំលត់សិទ្ធិឃាត់ទុក ដោយការផ្តល់នូវប្រាតិភោគ

កូនបំណុលអាចទាមទារឱ្យរំលត់នូវសិទ្ធិឃាត់ទុកបាន ដោយផ្តល់នូវប្រាតិភោគដ៏សមរម្យ ។

មាត្រា ៧៨០.- ការរំលត់សិទ្ធិឃាត់ទុក ដោយការបាត់បង់នូវការកាន់កាប់

១-សិទ្ធិឃាត់ទុកត្រូវរលត់ ពេលណាម្ចាស់សិទ្ធិឃាត់ទុកបានបាត់បង់នូវការកាន់កាប់វត្ថុឃាត់ទុកនោះ ។ ប៉ុន្តែ ក្នុងករណីដែលម្ចាស់សិទ្ធិឃាត់ទុកបានយកវត្ថុនោះទៅជួល ឬ ដាក់បញ្ចាំ ដោយទទួលការយល់ព្រមពីកូនបំណុល តាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៧៧៦ (ករណីយកិច្ចរបស់ម្ចាស់សិទ្ធិឃាត់ទុកក្នុងការរក្សាគ្រប់គ្រងវត្ថុដែលឃាត់ទុក) នៃក្រមនេះ សិទ្ធិឃាត់ទុកនេះមិនត្រូវរលត់ឡើយ ។

២-ទោះបីជាម្ចាស់សិទ្ធិឃាត់ទុកបានបាត់បង់នូវការកាន់កាប់វត្ថុឃាត់ទុកក៏ដោយ ប្រសិនបើម្ចាស់សិទ្ធិឃាត់ទុកនោះ បានការកាន់កាប់នោះមកវិញតាមបញ្ញត្តិនៃមាត្រា ២៣៧ (សិទ្ធិទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ) នៃក្រមនេះ ការកាន់កាប់នោះ ត្រូវបានចាត់ទុកថាបានបន្តរហូតមក ។

ជំពូកទី ៣
ឯកសិទ្ធិ
ផ្នែកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ៧៨១.- អត្ថន័យនៃឯកសិទ្ធិ

១-ម្ចាស់បំណុលដែលមានឯកសិទ្ធិ អាចទទួលការសងពីទ្រព្យដែលជាកម្មវត្ថុនៃឯកសិទ្ធិ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតបាន ។

២-ឯកសិទ្ធិដែលម្ចាស់បំណុលមានលើទ្រព្យទាំងអស់របស់កូនបំណុល ត្រូវហៅថា ជាឯកសិទ្ធិទូទៅ ។

៣-ឯកសិទ្ធិដែលម្ចាស់បំណុលមានលើទ្រព្យរបស់កូនបំណុលដែលកំណត់ជាក់លាក់ ត្រូវហៅថាជាឯកសិទ្ធិពិសេស ។ ក្នុងករណីនេះ ឯកសិទ្ធិដែលម្ចាស់បំណុលមានលើចលនវត្ថុ ដែលកំណត់ជាក់លាក់ ត្រូវហៅថាជាឯកសិទ្ធិលើចលនវត្ថុ រីឯ ឯកសិទ្ធិដែលម្ចាស់បំណុលមានលើអចលនវត្ថុដែលកំណត់ជាក់លាក់ ត្រូវហៅថាជាឯកសិទ្ធិលើអចលនវត្ថុ ។

មាត្រា ៧៨២.- ឧបាទេសកម្មលើវត្ថុ

១-ឯកសិទ្ធិអាចអនុវត្តបានចំពោះប្រាក់ ឬ វត្ថុផ្សេងទៀតដែលកូនបំណុលត្រូវទទួល ដោយការលក់ ការជួល ការបាត់បង់ ឬ ការខូចខាតនូវវត្ថុដែលជាកម្មវត្ថុ ។ ប៉ុន្តែ អ្នកមានឯកសិទ្ធិពុំអាចអនុវត្តឯកសិទ្ធិរបស់ខ្លួនបានឡើយ នៅក្រោយពេលដែលប្រាក់ត្រូវបានបង់ ឬ វត្ថុផ្សេងត្រូវបានប្រគល់ទៅឱ្យកូនបំណុល ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះតម្លៃថ្លូវនឹងសិទ្ធិប្រត្យក្សដែលបង្កើតឡើង ដោយកូនបំណុល លើវត្ថុដែលជាកម្មវត្ថុនៃឯកសិទ្ធិ ។

ផ្នែកទី ២

ឯកសិទ្ធិទូទៅ

មាត្រា ៧៨៣.- អត្ថន័យនៃឯកសិទ្ធិទូទៅ

បុគ្គលដែលមានសិទ្ធិលើបំណុលដែលកើតឡើងដោយសារមូលហេតុណាមួយដូចខាងក្រោមនេះ មានឯកសិទ្ធិលើទ្រព្យទាំងអស់របស់កូនបំណុល :

ក-សោហ៊ុយចំណាយសម្រាប់ប្រយោជន៍រួម ។

ខ-សិទ្ធិលើបំណុលរបស់កម្មករនិយោជិត ។

គ-សោហ៊ុយសម្រាប់បុណ្យសព ។

ឃ-ការផ្គត់ផ្គង់នូវវត្ថុសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ ។

មាត្រា ៧៨៤.- ឯកសិទ្ធិចំពោះសោហ៊ុយចំណាយសម្រាប់ប្រយោជន៍រួម

១-ឯកសិទ្ធិចំពោះសោហ៊ុយចំណាយសម្រាប់ប្រយោជន៍រួម មានអត្ថិភាពចំពោះសោហ៊ុយចំណាយដើម្បីថែរក្សាទ្រព្យ ឬ ជម្រះបញ្ជី ឬ ចែកចំណែកទ្រព្យ ដែលបានចេញសម្រាប់ប្រយោជន៍រួមរបស់ម្ចាស់បំណុលនីមួយៗ ។

២-ក្នុងចំណោមសោហ៊ុយចំណាយដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះសោហ៊ុយចំណាយដែលមានប្រយោជន៍ដល់ម្ចាស់បំណុលតែមួយចំនួន ឯកសិទ្ធិចំពោះសោហ៊ុយចំណាយនោះ មានអត្ថិភាពចំពោះតែម្ចាស់បំណុលដែលបានទទួលប្រយោជន៍ពីសោហ៊ុយចំណាយនោះតែប៉ុណ្ណោះ។

មាត្រា ៧៨៥.- ឯកសិទ្ធិចំពោះសិទ្ធិលើបំណុលរបស់កម្មករនិយោជិត

ឯកសិទ្ធិចំពោះសិទ្ធិលើបំណុលរបស់កម្មករនិយោជិត មានអត្ថិភាពចំពោះសិទ្ធិលើបំណុលទាំងអស់ ដែលកម្មករនិយោជិតត្រូវទទួលពីនិយោជក ដោយផ្អែកលើកិច្ចសន្យាការងារ ។

មាត្រា ៧៨៦.- ឯកសិទ្ធិចំពោះសោហ៊ុយសម្រាប់បុណ្យសព

១-ឯកសិទ្ធិចំពោះសោហ៊ុយសម្រាប់បុណ្យសព មានអត្ថិភាពចំពោះសោហ៊ុយសម្រាប់បុណ្យសពដែលបានធ្វើឡើងទៅតាមឋានៈរបស់កូនបំណុលដែលបានទទួលមរណភាព ។

២-ក្នុងករណីដែលញាតិរបស់កូនបំណុលដែលមានអាហារកិច្ចបានទទួលមរណភាព ឯកសិទ្ធិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក៏មានអត្ថិភាពចំពោះសោហ៊ុយសម្រាប់បុណ្យសពដែលកូនបំណុលបានធ្វើឡើងទៅតាមឋានៈរបស់ញាតិនោះដែរ ។

មាត្រា ៧៨៧.- ឯកសិទ្ធិចំពោះការផ្តល់នូវវត្ថុសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ

ឯកសិទ្ធិចំពោះការផ្តល់នូវវត្ថុប្រើប្រាស់ប្រចាំថ្ងៃ មានអត្ថិភាពចំពោះការផ្តល់ចំណីអាហារ និង វត្ថុប្រើប្រាស់ផ្សេងៗរៀងរាល់ថ្ងៃ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែចុងក្រោយ ដែលចាំបាច់សម្រាប់ជីវភាពរបស់កូនបំណុល ឬ ញាតិដែលរស់នៅជាមួយកូនបំណុល ហើយដែលកូនបំណុលនោះមានអាហារកិច្ច និង អ្នកបម្រើ ។

ផ្នែកទី ៣
ឯកសិទ្ធិលើចលនវត្ថុ

មាត្រា ៧៨៨.- អត្ថន័យនៃឯកសិទ្ធិលើចលនវត្ថុ

បុគ្គលដែលមានសិទ្ធិលើបំណុលដែលកើតឡើងដោយមូលហេតុណាមួយដូចខាងក្រោម នេះ មានឯកសិទ្ធិលើចលនវត្ថុជាក់លាក់ដែលបានកំណត់ជាក់លាក់របស់កូនបំណុល :

ក-ការជួលអចលនវត្ថុ ។

ខ-ការដឹកជញ្ជូនអ្នកដំណើរ ឬ ទំនិញ ។

គ-ការរក្សាទុកចលនវត្ថុ ។

ឃ-ការលក់ចលនវត្ថុ ។

ង-ការផ្តល់គ្រាប់ពូជ កូនរុក្ខជាតិ ឬ ជី និង ពូជ កូនសត្វ ឬ ចំណីសត្វ ។

មាត្រា ៧៨៩.- ឯកសិទ្ធិចំពោះការជួលអចលនវត្ថុ

ឯកសិទ្ធិចំពោះការជួលអចលនវត្ថុ មានអត្ថិភាពលើចលនវត្ថុរបស់ភតិកៈ ចំពោះថ្លៃឈ្នួលអចលនវត្ថុ និង កាតព្វកិច្ចផ្សេងទៀតរបស់ភតិកៈដែលកើតឡើងដោយទំនាក់ទំនងនៃការជួលអចលនវត្ថុនោះ ។

មាត្រា ៧៩០.- ទំហំនៃវត្ថុដែលជាកម្មវត្ថុនៃឯកសិទ្ធិចំពោះការជួលអចលនវត្ថុ ក្នុងករណីធម្មតា

១-ឯកសិទ្ធិរបស់ភតិបតីនៃដី មានអត្ថិភាពទៅលើចលនវត្ថុដែលបានបំពាក់លើដីជួល ឬ នៅនឹងអគារសម្រាប់ប្រើដីជួលនោះ ចលនវត្ថុដែលបានផ្តល់ប្រយោជន៍សម្រាប់ប្រើដីនោះ និង ផលនៃដីនោះដែលស្ថិតនៅក្រោមការកាន់កាប់របស់ភតិកៈ ។

២-ឯកសិទ្ធិរបស់ភតិបតីនៃអគារ មានអត្ថិភាពលើចលនវត្ថុដែលភតិកៈបានបំពាក់នៅនឹងអគារនោះ ។

មាត្រា ៧៩១.- ទំហំនៃវត្ថុដែលជាកម្មវត្ថុនៃឯកសិទ្ធិចំពោះការជួលអចលនវត្ថុ ក្នុងករណីអនុប្បទាន នូវសិទ្ធិជួល ឬ ជួលបន្ត

ក្នុងករណីអនុប្បទាននូវសិទ្ធិជួល ឬ ជួលបន្ត ឯកសិទ្ធិរបស់ភតិបតី មានអានុភាពលើ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ក្រសួងព្រះបរមរាជវាំង

ចលនវត្ថុរបស់អនុប្បទានិក ឬ ភតិកៈបន្ត ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះប្រាក់ដែលអនុប្បទានិក ឬ ភតិកៈបន្តនោះទទួល ។

មាត្រា ៧៩២.- ទំហំនៃអានុភាពនៃឯកសិទ្ធិចំពោះការជួលអចលនវត្ថុ

ក្នុងករណីជម្រះបញ្ជីទ្រព្យសរុបទាំងអស់របស់ភតិកៈ ឯកសិទ្ធិរបស់ភតិបតីមានអត្ថិភាពលើថ្លៃឈ្នួល និង កាតព្វកិច្ចផ្សេងទៀតក្នុងគ្រាមុន គ្រាបច្ចុប្បន្ន និង គ្រាបន្ទាប់ និង សំណងនៃការខូចខាតដែលបានកើតមានឡើងក្នុងគ្រាមុន និង គ្រាបច្ចុប្បន្ន ។

មាត្រា ៧៩៣.- ឯកសិទ្ធិក្នុងការជួលអចលនវត្ថុ ក្នុងករណីដែលមានប្រាក់កក់ដើម្បីធានា

ក្នុងករណីដែលភតិបតីបានទទួលប្រាក់កក់ដើម្បីធានា ភតិបតីនោះមានឯកសិទ្ធិត្រឹមតែចំពោះផ្នែកនៃសិទ្ធិលើបំណុល ដែលមិនអាចទទួលការសងដោយប្រាក់កក់ដើម្បីធានានោះតែប៉ុណ្ណោះ ។

មាត្រា ៧៩៤.- ឯកសិទ្ធិចំពោះការដឹកជញ្ជូន

ឯកសិទ្ធិចំពោះការដឹកជញ្ជូន មានអត្ថិភាពលើវត្ថុដែលអ្នកដឹកជញ្ជូនកាន់កាប់ ចំពោះថ្លៃដឹកជញ្ជូនអ្នកដំណើរ ឬ វត្ថុ និង ថ្លៃសោហ៊ុយផ្សេងៗដែលទាក់ទងនឹងការដឹកជញ្ជូន ។

មាត្រា ៧៩៥.- លទ្ធកម្មដោយសុចរិត

បញ្ញត្តិនៃមាត្រា ១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះស្តីពីលទ្ធកម្មដោយសុចរិត ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះឯកសិទ្ធិដែលបានកំណត់ពីមាត្រា ៧៨៩ (ឯកសិទ្ធិចំពោះការជួលអចលនវត្ថុ) ដល់មាត្រា ៧៩៤ (ឯកសិទ្ធិចំពោះការដឹកជញ្ជូន) នៃក្រមនេះ ។

មាត្រា ៧៩៦.- ឯកសិទ្ធិចំពោះការរក្សាទុកចលនវត្ថុ

១-ឯកសិទ្ធិចំពោះការរក្សាទុកចលនវត្ថុ មានអត្ថិភាពលើចលនវត្ថុដែលត្រូវបានរក្សាទុក ចំពោះសោហ៊ុយសម្រាប់រក្សាទុកចលនវត្ថុនោះ ។

២-ឯកសិទ្ធិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មានអត្ថិភាពផងដែរ ចំពោះសោហ៊ុយចាំបាច់ដែលបានចេញដើម្បីឱ្យរក្សា ផ្តល់សច្ចានុមតិ ឬ អនុវត្តសិទ្ធិ ដែលទាក់

ទងនឹងចលនវត្ថុនោះ ។

មាត្រា ៧៩៧.- ឯកសិទ្ធិចំពោះការលក់ចលនវត្ថុ

ឯកសិទ្ធិចំពោះការលក់ចលនវត្ថុ មានអត្ថិភាពលើចលនវត្ថុនោះ ចំពោះប្រាក់ថ្លៃលក់ចលនវត្ថុនោះ និង ការប្រាក់ ។

មាត្រា ៧៩៨.- ឯកសិទ្ធិចំពោះការផ្តល់គ្រាប់ពូជ កូនរុក្ខជាតិ ឬ ជី និង ពូជ កូនសត្វ ឬ ចំណីសត្វ

១-ឯកសិទ្ធិចំពោះការផ្តល់គ្រាប់ពូជ កូនរុក្ខជាតិ ឬ ជី មានអត្ថិភាពលើផលដែលបានមកពីដីក្នុង ១ (មួយ) ឆ្នាំ បន្ទាប់ពីបានប្រើគ្រាប់ពូជ កូនរុក្ខជាតិ ឬ ជីនោះ ចំពោះថ្លៃគ្រាប់ពូជ កូនរុក្ខជាតិ ឬ ជី និង ការប្រាក់.។

២-ឯកសិទ្ធិចំពោះការផ្តល់ពូជ កូនសត្វ ឬ ចំណីសត្វ មានអត្ថិភាពលើសត្វ និង ផលដែលបានមកពីសត្វនោះ ក្នុង ១ (មួយ) ឆ្នាំ បន្ទាប់ពីបានប្រើសត្វ និង ចំណីដើម្បីចិញ្ចឹមសត្វនោះ ចំពោះថ្លៃពូជ កូនសត្វ និង ចំណីនោះ និង ការប្រាក់ ។

៣-ឯកសិទ្ធិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ក៏មានអត្ថិភាពលើផលដែលបានមកពីពូជដង្កូវនាង ឬ ស្លឹកមន ចំពោះថ្លៃពូជដង្កូវនាង ឬ ស្លឹកមនដើម្បីចិញ្ចឹមដង្កូវនាងនោះផងដែរ ។

ផ្នែកទី ៤
ឯកសិទ្ធិលើអចលនវត្ថុ

មាត្រា ៧៩៩.- ឯកសិទ្ធិលើអចលនវត្ថុ

បុគ្គលដែលមានសិទ្ធិលើបំណុល ដែលកើតឡើងដោយសារមូលហេតុណាមួយដូចខាងក្រោមនេះ មានឯកសិទ្ធិលើអចលនវត្ថុដែលបានកំណត់ជាក់លាក់របស់កូនបំណុល ៖

ក-ការរក្សាទុកនូវអចលនវត្ថុ ។

ខ-ការងារលើអចលនវត្ថុ ។

គ-ការលក់អចលនវត្ថុ ។

មាត្រា ៨០០.- ឯកសិទ្ធិចំពោះការរក្សាទុកនូវអចលនវត្ថុ

១-ឯកសិទ្ធិចំពោះការរក្សាទុកនូវអចលនវត្ថុ មានអត្ថិភាពលើអចលនវត្ថុ ចំពោះសោហ៊ុយរក្សាទុកអចលនវត្ថុនោះ ។

២-ឯកសិទ្ធិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក៏មានអត្ថិភាពផងដែរ ចំពោះសោហ៊ុយចាំបាច់ដែលបានចេញដើម្បីឱ្យរក្សា ផ្តល់សច្ចានុមតិ ឬ អនុវត្តសិទ្ធិ ដែលទាក់ទងនឹងអចលនវត្ថុនោះ ។

មាត្រា ៨០១.- ឯកសិទ្ធិចំពោះការងារលើអចលនវត្ថុ

១-ឯកសិទ្ធិចំពោះការងារលើអចលនវត្ថុ មានអត្ថិភាពលើអចលនវត្ថុរបស់កូនបំណុល ចំពោះសោហ៊ុយចំណាយសម្រាប់ការងារ ដែលបានធ្វើលើអចលនវត្ថុនោះដោយសិប្បករ អ្នកបច្ចេកទេស និង អ្នកម៉ៅការ ។

២-ឯកសិទ្ធិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មានអត្ថិភាពចំពោះតែចំនួនប្រាក់កំណើនតម្លៃ ក្នុងករណីដែលកំណើនតម្លៃអចលនវត្ថុដោយការងារ នោះនៅតែមានប៉ុណ្ណោះ ។

មាត្រា ៨០២.- ឯកសិទ្ធិចំពោះការលក់អចលនវត្ថុ

ឯកសិទ្ធិចំពោះការលក់អចលនវត្ថុមានអត្ថិភាពលើអចលនវត្ថុ ចំពោះប្រាក់ថ្លៃលក់អចលនវត្ថុនោះ និង ការប្រាក់ ។

ផ្នែកទី ៥
លំដាប់នៃឯកសិទ្ធិ

មាត្រា ៨០៣.- លំដាប់នៃឯកសិទ្ធិទូទៅ

១-ក្នុងករណីដែលឯកសិទ្ធិទូទៅប្រជែងគ្នា លំដាប់នៃឯកសិទ្ធិទាំងនោះត្រូវអនុលោមតាមលំដាប់ដែលបានកំណត់នៅក្នុងមាត្រា ៧៨៣(អត្ថន័យនៃឯកសិទ្ធិទូទៅ) នៃក្រមនេះ ។

២-ប្រសិនបើឯកសិទ្ធិទូទៅប្រជែងគ្នានឹងឯកសិទ្ធិពិសេស ឯកសិទ្ធិពិសេសត្រូវមានអាទិ-

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ភាពជាងឯកសិទ្ធិទូទៅ ។ ប៉ុន្តែ ឯកសិទ្ធិចំពោះសោហ៊ុយចំណាយសម្រាប់ប្រយោជន៍រួមវិញ មានអាទិភាពចំពោះម្ចាស់បំណុលទាំងឡាយដែលបានទទួលប្រយោជន៍នោះ ។

មាត្រា ៨០៤.- លំដាប់នៃឯកសិទ្ធិលើចលនវត្ថុ

១-ក្នុងករណីដែលមានឯកសិទ្ធិពិសេសប្រជែងគ្នាចំពោះចលនវត្ថុតែមួយ លំដាប់នៃឯកសិទ្ធិទាំងនោះត្រូវអនុលោមតាមលំដាប់ដូចខាងក្រោមនេះ :

ទី ១ :ឯកសិទ្ធិចំពោះការជួលអចលនវត្ថុ និង ចំពោះការដឹកជញ្ជូន ។

ទី ២ :ឯកសិទ្ធិចំពោះការរក្សាទុកនូវចលនវត្ថុ ប៉ុន្តែ ប្រសិនបើមានអ្នករក្សាច្រើននាក់ អ្នកដែលរក្សាក្រោយ មានអាទិភាពជាងអ្នករក្សាមុន ។

ទី ៣ :ឯកសិទ្ធិចំពោះការលក់ចលនវត្ថុ ឯកសិទ្ធិចំពោះការផ្តល់គ្រាប់ពូជ កូនរុក្ខជាតិ ឬ ជី និង ពូជ កូនសត្វ ឬ ចំណីសត្វ ។

២-ប្រសិនបើម្ចាស់ឯកសិទ្ធិដែលមានអាទិភាពក្នុងលំដាប់ទី ១ បានដឹងថា មានម្ចាស់ឯកសិទ្ធិដែលមានអាទិភាពក្នុងលំដាប់ទី ២ ឬ លំដាប់ទី ៣ នៅពេលដែលខ្លួនបានទទួលសិទ្ធិលើបំណុល ម្ចាស់ឯកសិទ្ធិដែលមានអាទិភាពក្នុងលំដាប់ទី ១ នោះត្រូវមានលំដាប់ក្រោយម្ចាស់ឯកសិទ្ធិទាំងអស់ដែលមានអាទិភាពក្នុងលំដាប់ទី ២ ឬ ទី ៣ នោះវិញ ។ ម្ចាស់ឯកសិទ្ធិដែលមានអាទិភាពក្នុងលំដាប់ទី ១ នោះ ក៏ត្រូវមានលំដាប់ក្រោយបុគ្គលដែលរក្សាវត្ថុដើម្បីម្ចាស់ឯកសិទ្ធិនោះដែរ ។

៣-ចំពោះផល លំដាប់ទី ១ ធ្លាក់លើអ្នកផ្តល់គ្រាប់ពូជ កូនរុក្ខជាតិ ឬ ជី ហើយលំដាប់ទី ២ ធ្លាក់លើភតិបតីនៃដី ។

មាត្រា ៨០៥.- លំដាប់នៃឯកសិទ្ធិលើអចលនវត្ថុ

១-ក្នុងករណីដែលមានឯកសិទ្ធិពិសេសប្រជែងគ្នាចំពោះអចលនវត្ថុតែមួយ លំដាប់នៃឯកសិទ្ធិទាំងនោះត្រូវអនុលោមតាមលំដាប់ដែលបានកំណត់នៅក្នុងមាត្រា ៧៩៩(ឯកសិទ្ធិលើអចលនវត្ថុ) នៃក្រមនេះ ។

២-ប្រសិនបើមានការលក់ជាបន្តបន្ទាប់ ចំពោះអចលនវត្ថុតែមួយ លំដាប់នៃសិទ្ធិអាទិភាពរបស់អ្នកលក់ទាំងនោះ ត្រូវគិតទៅតាមពេលវេលាមុន និង ក្រោយនៃការលក់នោះ ។

មាត្រា ៨០៦.- ឯកសិទ្ធិដែលមានអាទិភាពស្មើគ្នា

ក្នុងករណីដែលមានម្ចាស់ឯកសិទ្ធិច្រើននាក់ដែលមានអាទិភាពស្មើគ្នាលើវត្ថុដែលជាកម្មវត្ថុតែមួយ ម្ចាស់ឯកសិទ្ធិនីមួយៗ ត្រូវទទួលនូវការសង តាមសមាមាត្រនៃសិទ្ធិលើបំណុលរៀងៗខ្លួន ។

ផ្នែកទី ៦
អានុភាពនៃឯកសិទ្ធិ

មាត្រា ៨០៧.- អានុភាពតាមចំពោះតតិយជនដែលបានធ្វើលទ្ធកម្ម

ក្រោយពេលដែលកូនបំណុលបានប្រគល់ចលនវត្ថុរបស់ខ្លួនដែលជាកម្មវត្ថុនៃឯកសិទ្ធិទៅឱ្យតតិយជនដែលបានធ្វើលទ្ធកម្មហើយ នោះម្ចាស់ឯកសិទ្ធិមិនអាចអនុវត្តឯកសិទ្ធិរបស់ខ្លួនចំពោះចលនវត្ថុនោះបានឡើយ ។

មាត្រា ៨០៨.- ទំនាក់ទំនងនឹងសិទ្ធិលើការបញ្ចាំចលនវត្ថុ

ក្នុងករណីដែលឯកសិទ្ធិប្រជែងជាមួយនឹងសិទ្ធិលើការបញ្ចាំចលនវត្ថុ ម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុមានសិទ្ធិដូចគ្នានឹងម្ចាស់ឯកសិទ្ធិដែលមានអាទិភាពក្នុងលំដាប់ទី ១ ដែលបានកំណត់នៅក្នុងមាត្រា ៨០៤(លំដាប់នៃឯកសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ ។

មាត្រា ៨០៩.- អានុភាពនៃឯកសិទ្ធិទូទៅ

១-ម្ចាស់ឯកសិទ្ធិទូទៅ មិនអាចទទួលការសងដោយអចលនវត្ថុបានទេ លើកលែងតែខ្លួនបានទទួលការសងដោយទ្រព្យផ្សេងទៀតក្រៅពីអចលនវត្ថុនោះជាមុនសិន ហើយនៅតែមិនគ្រប់ ។

២-ចំពោះអចលនវត្ថុ ម្ចាស់ឯកសិទ្ធិទូទៅត្រូវទទួលការសងដោយអចលនវត្ថុដែលមិនមែនជាកម្មវត្ថុនៃប្រាតិភោគពិសេស ជាមុនសិន ។

៣-ប្រសិនបើម្ចាស់ឯកសិទ្ធិទូទៅធ្វេសប្រហែសមិនបានចូលរួមក្នុងការចែកចំណែកតាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះទេ ម្ចាស់ឯកសិទ្ធិទូទៅនោះមិនអាចអនុវត្តឯកសិទ្ធិ

ROYAUME DU CAMBODGE
LE MINISTRE ... PALAIS ROYAL

នេះ ចំពោះតតិយជនដែលបានចុះបញ្ជីបានឡើយ ក្នុងកម្រិតនៃចំណែករបស់ខ្លួនដែលត្រូវបានទទួល ប្រសិនបើខ្លួនបានចូលរួមក្នុងការចែកចំណែកនោះ ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ១ ទី ២ និង កថាខណ្ឌទី ៣ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការចែកចំណែកនូវប្រាក់ដែលជាតម្លៃនៃអចលនវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគពិសេសត្រូវបានធ្វើឡើង មុនការចែកចំណែកនូវប្រាក់ដែលជាតម្លៃនៃទ្រព្យក្រៅពីអចលនវត្ថុ ។

មាត្រា ៨១០.- អានុភាពនៃឯកសិទ្ធិទូទៅចំពោះតតិយជន

ម្ចាស់ឯកសិទ្ធិទូទៅអាចយកឯកសិទ្ធិនេះទៅតតាំងចំពោះម្ចាស់បំណុលដែលគ្មានប្រាតិភោគពិសេសបាន ទោះជាពុំបានចុះបញ្ជីឯកសិទ្ធិចំពោះអចលនវត្ថុក៏ដោយ ។ ប៉ុន្តែ ចំពោះតតិយជនដែលបានចុះបញ្ជីវិញ ម្ចាស់ឯកសិទ្ធិទូទៅ ពុំអាចយកឯកសិទ្ធិនេះទៅតតាំងបានឡើយ ។

មាត្រា ៨១១.- អានុភាពចំពោះតតិយជននៃឯកសិទ្ធិចំពោះការរក្សាទុកអចលនវត្ថុ

១-ឯកសិទ្ធិចំពោះការរក្សាទុកអចលនវត្ថុ មិនអាចតតាំងចំពោះតតិយជនបានឡើយ បើពុំបានចុះបញ្ជីភ្លាមៗ ក្រោយពីបានបញ្ចប់សកម្មភាពរក្សាទុកទេ ។

២-កំណើនតម្លៃនៃអចលនវត្ថុដែលបានកើតឡើងដោយសារការរក្សាទុក ត្រូវធ្វើការវាយតម្លៃដោយអ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការ នៅពេលចូលរួមក្នុងការចែកចំណែក ។

មាត្រា ៨១២.- អានុភាពចំពោះតតិយជននៃឯកសិទ្ធិចំពោះការងារលើអចលនវត្ថុ

១-ឯកសិទ្ធិចំពោះការងារលើអចលនវត្ថុ មិនអាចតតាំងចំពោះតតិយជនបានឡើយ បើមិនបានចុះបញ្ជីភ្លាមៗ ក្រោយពីបានបញ្ចប់ការងារនោះ ។

២-កំណើនតម្លៃនៃអចលនវត្ថុដែលបានកើតឡើងដោយសារការងារ ត្រូវធ្វើការវាយតម្លៃដោយអ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការ នៅពេលចូលរួមក្នុងការចែកចំណែក ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

-៧២-

មាត្រា ៨១៣.- ទំនាក់ទំនងរវាងឯកសិទ្ធិចំពោះការរក្សាទុកអចលនវត្ថុ ឯកសិទ្ធិចំពោះការងារលើអចលនវត្ថុ និង ហ៊ីប៉ូតែក

ឯកសិទ្ធិដែលបានចុះបញ្ជី តាមបញ្ញត្តិនៃមាត្រា ៨១១ (អានុភាពចំពោះតតិយជននៃឯកសិទ្ធិចំពោះការរក្សាទុកអចលនវត្ថុ) និងមាត្រា ៨១២ (អានុភាពចំពោះតតិយជននៃឯកសិទ្ធិចំពោះការងារលើអចលនវត្ថុ) នៃក្រមនេះ អាចអនុវត្តដោយមានអាទិភាពជាងហ៊ីប៉ូតែកបាន ។

មាត្រា ៨១៤.- អានុភាពចំពោះតតិយជននៃឯកសិទ្ធិចំពោះការលក់អចលនវត្ថុ

ឯកសិទ្ធិចំពោះការលក់អចលនវត្ថុមិនអាចតតាំងចំពោះតតិយជនបានឡើយ បើមិនបានចុះបញ្ជីបញ្ជាក់ថា មិនទាន់បានសងថ្លៃទិញ ឬ ការប្រាក់ ព្រមគ្នានឹងពេលធ្វើកិច្ចសន្យាលក់ទិញទេ ។

មាត្រា ៨១៥.- ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីហ៊ីប៉ូតែក

ក្រៅពីបញ្ញត្តិក្នុងជំពូកទី ៣ (ឯកសិទ្ធិ) នេះ បញ្ញត្តិពីមាត្រា ៨៤៦ (ទំហំនៃអានុភាពហ៊ីប៉ូតែក) ដល់មាត្រា ៨៤៨ (អានុភាពនៃហ៊ីប៉ូតែក ចំពោះផល) បញ្ញត្តិនៃមាត្រា ៨៥១ (លំដាប់នៃហ៊ីប៉ូតែក) មាត្រា ៨៥២ (ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា) មាត្រា ៨៥៣ (ការលក់ដោយបង្គំនូវអចលនវត្ថុហ៊ីប៉ូតែក) និង បញ្ញត្តិពីមាត្រា ៨៥៩ (ហ៊ីប៉ូតែកបន្ត) ដល់មាត្រា ៨៦៣ (លំដាប់នៃការចាត់ចែងហ៊ីប៉ូតែក) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអានុភាពនៃឯកសិទ្ធិ ។

ជំពូកទី ៤
សិទ្ធិលើការបញ្ចាំ
ផ្នែកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ៨១៦.- អត្ថន័យនៃសិទ្ធិលើការបញ្ចាំ

ម្ចាស់សិទ្ធិលើការបញ្ចាំ មានសិទ្ធិកាន់កាប់វត្ថុដែលបានទទួលពីកូនបំណុល ឬ តតិយជនជាការធានាសិទ្ធិលើបំណុលរបស់ខ្លួន និង ទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនពី

វត្ថុនោះ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត ។

មាត្រា ៨១៧.- ឧបាទេសកម្មលើវត្ថុ

១-សិទ្ធិលើការបញ្ចាំអាចអនុវត្តបានចំពោះទឹកប្រាក់ ឬ វត្ថុផ្សេងទៀតដែលអ្នកបង្កើតត្រូវទទួលដោយការលក់ ការបាត់បង់ ឬ ការខូចខាតនូវវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ។ ប៉ុន្តែម្ចាស់សិទ្ធិលើការបញ្ចាំពុំអាចអនុវត្តសិទ្ធិរបស់ខ្លួនបានឡើយ នៅក្រោយពេលដែលទឹកប្រាក់ត្រូវបានបង់ ឬ វត្ថុផ្សេងត្រូវបានប្រគល់ទៅឱ្យអ្នកបង្កើត ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះតម្លៃថ្នូរនឹងសិទ្ធិប្រត្យក្សដែលបង្កើតឡើង ដោយអ្នកបង្កើតសិទ្ធិលើការបញ្ចាំលើវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ ។

មាត្រា ៨១៨.- ការបង្កើតសិទ្ធិលើការបញ្ចាំ និង ការប្រគល់វត្ថុជាចាំបាច់

១-សិទ្ធិលើការបញ្ចាំត្រូវកើតឡើង ដោយកូនបំណុល ឬ តតិយជនដែលបង្កើតសិទ្ធិលើការបញ្ចាំនោះ ប្រគល់នូវវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ។

២-ការប្រគល់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវរាប់បញ្ចូលទាំងការប្រគល់ដោយសង្ខេប ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រា ២២៩ (ការផ្ទេរការកាន់កាប់) នៃក្រមនេះ ។

មាត្រា ៨១៩.- ការហាមការកាន់កាប់ដោយផ្ទាល់ ដោយអ្នកបង្កើតសិទ្ធិលើការបញ្ចាំ

ម្ចាស់សិទ្ធិលើការបញ្ចាំមិនអាចឱ្យអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះកាន់កាប់ដោយផ្ទាល់លើវត្ថុបញ្ចាំនោះបានឡើយ ។

មាត្រា ៨២០.- ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

សិទ្ធិលើការបញ្ចាំត្រូវធានានូវ ប្រាក់ដើម ការប្រាក់ ប្រាក់ពិន័យនៃសងក្នុងករណីមិនគោរព.កិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិលើការបញ្ចាំ សោហ៊ុយដើម្បីថែរក្សាវត្ថុបញ្ចាំព្រមទាំងសំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬ វិការៈកំបាំងនៃវត្ថុបញ្ចាំ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានកំណត់ផ្សេងក្នុង

សកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំនោះ ។

មាត្រា ៨២១.- អានុភាពនៃការឃាត់ទុក

ម្ចាស់សិទ្ធិលើការបញ្ចាំអាចឃាត់ទុកវត្ថុបញ្ចាំបាន រហូតដល់ពេលដែលទទួលការសង ចំពោះសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងមាត្រា ៨២០ (ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា) ខាងលើនេះ ។ ប៉ុន្តែ សិទ្ធិនេះមិនអាចតតាំង ចំពោះម្ចាស់បំណុលដែលមានអាទិភាពជាងខ្លួនបានឡើយ ។

មាត្រា ៨២២.- សិទ្ធិទទួលការសងពីផលដោយមានអាទិភាព

១-ម្ចាស់សិទ្ធិលើការបញ្ចាំអាចទទួលផលដែលកើតពីវត្ថុបញ្ចាំ និង អាចយកផលនោះមកកាត់សិទ្ធិលើបំណុលរបស់ខ្លួន ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតបាន ។

២-ផលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកកាត់ការប្រាក់នៃសិទ្ធិលើបំណុលជាមុនសិន ហើយប្រសិនបើមានសំណល់ ត្រូវយកទៅកាត់ប្រាក់ដើម ។

មាត្រា ៨២៣.-ករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំក្នុងការរក្សាទុកនូវវត្ថុបញ្ចាំ

១-ម្ចាស់សិទ្ធិលើការបញ្ចាំ ត្រូវកាន់កាប់វត្ថុបញ្ចាំនោះដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

២-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានធ្វើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ កូនបំណុលអាចទាមទាររំលត់សិទ្ធិលើការបញ្ចាំនោះបាន ។

មាត្រា ៨២៤.- សិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

១-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានចេញចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សាវត្ថុ ចំពោះវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះ អាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងនូវចំណាយនោះវិញបាន ។

២-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានចេញចំណាយបង្កើនតម្លៃនៃវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះអាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងនូវចំណាយទាំងអស់ដែលខ្លួនបានចេញ ឬ សងនូវតម្លៃប្រាក់ដែលកើននោះវិញ តាមការជ្រើសរើសរបស់ខ្លួនបានក្នុងករណី

ដែលកំណើនតម្លៃនោះនៅតែមាន ។ ប៉ុន្តែ តុលាការអាចកំណត់ពេលសមរម្យដើម្បីសងតាមការទាមទាររបស់កម្មសិទ្ធិករបាន ។

មាត្រា ៨២៥.- អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ការប្រើសិទ្ធិលើការបញ្ចាំ មិនរារាំងដំណើរការនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ ។

មាត្រា ៨២៦.- ការបញ្ចាំបន្ត

១-ម្ចាស់សិទ្ធិលើការបញ្ចាំអាចយកវត្ថុបញ្ចាំនោះទៅដាក់បញ្ចាំបន្តទៀតបានដោយទទួលការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះ ដើម្បីធានានូវកាតព្វកិច្ចរបស់ខ្លួន ។

២-ក្នុងអំឡុងពេលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំ ម្ចាស់សិទ្ធិនោះអាចយកវត្ថុបញ្ចាំនោះទៅដាក់បញ្ចាំបន្តទៀត ក្រោមការទទួលខុសត្រូវរបស់ខ្លួនបាន ។ ក្នុងករណីនេះ ម្ចាស់សិទ្ធិលើការបញ្ចាំនោះក៏ត្រូវទទួលខុសត្រូវ ចំពោះការខូចខាតដោយប្រធានសក្តិ ដែលមិនអាចកើតមានឡើងប្រសិនបើមិនបានដាក់បញ្ចាំបន្តទេ ។

៣-នៅពេលចែកចំណែកថ្លៃលក់ដោយបង្ខំនៃវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំបន្តអាចទទួលនូវការសងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនទាំងអស់ ដោយមានកម្រិតនៃចំនួនទឹកប្រាក់ដែលត្រូវចែកចំណែកទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ។ ប៉ុន្តែ ប្រសិនបើសិទ្ធិលើបំណុលរបស់ខ្លួនមិនទាន់ដល់ពេលកំណត់ត្រូវសងទេ ម្ចាស់សិទ្ធិលើការបញ្ចាំបន្ត គ្រាន់តែអាចទាមទារឱ្យតម្កល់នូវចំនួនទឹកប្រាក់ដែលខ្លួនអាចទទួលការសងបានប៉ុណ្ណោះ ។

មាត្រា ៨២៧.- ការហាមកិច្ចសន្យាបញ្ចាំផ្តាច់

បើពុំមានបញ្ញត្តិពិសេសនៅក្នុងក្រមនេះ ឬ ច្បាប់ផ្សេងទៀតទេ អ្នកដែលបង្កើតសិទ្ធិលើការបញ្ចាំ មិនអាចព្រមព្រៀងឱ្យម្ចាស់សិទ្ធិលើការបញ្ចាំទទួលកម្មសិទ្ធិលើវត្ថុបញ្ចាំ ឬ ចាត់ចែងវត្ថុបញ្ចាំ តាមវិធីផ្សេងពីវិធីដែលច្បាប់បានកំណត់ដោយសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ ឬ ដោយកិច្ចសន្យាដែលធ្វើមុនកំណត់ពេលត្រូវសងបានទេ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

(តទៅរាជកិច្ច លេខ ០៥)

7/456

មាត្រា ៨២៨.- សិទ្ធិទាមទារសំណងរបស់អ្នកធានាដោយវត្ថុ

ប្រសិនបើអ្នកដែលបង្កើតសិទ្ធិលើការបញ្ចាំដើម្បីធានាកាតព្វកិច្ចរបស់អ្នកដទៃបានសងចំពោះកាតព្វកិច្ចនោះ ឬ បានបាត់បង់នូវកម្មសិទ្ធិលើវត្ថុបញ្ចាំដោយសារការអនុវត្តសិទ្ធិលើការបញ្ចាំនោះ អ្នកនោះត្រូវមានសិទ្ធិទាមទារសំណងចំពោះកូនបំណុល ដោយយោងទៅតាមបញ្ញត្តិស្តីពីការធានា ។

ផ្នែកទី ២
ការបញ្ចាំចលនវត្ថុ

មាត្រា ៨២៩.- លក្ខខណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំ

ម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ មិនអាចតតាំងសិទ្ធិលើការបញ្ចាំនោះចំពោះតតិយជនបានឡើយ ប្រសិនបើខ្លួនមិនបានកាន់កាប់ជានិរន្តរ៍នូវវត្ថុបញ្ចាំនោះ ។

មាត្រា ៨៣០.- ករណីដែលការកាន់កាប់ត្រូវបានដកយក

ក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុត្រូវបានដកយកនូវការកាន់កាប់វត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះ អាចយកវត្ថុបញ្ចាំមកវិញបាន តាមរយៈបណ្តឹងទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ តែប៉ុណ្ណោះ ។

មាត្រា ៨៣១.- ការប្រើប្រាស់ និង អាស្រ័យផលពីវត្ថុបញ្ចាំ ដោយម្ចាស់សិទ្ធិលើការបញ្ចាំ

១-បើពុំមានការយល់ព្រមពីសំណាក់កូនបំណុលទេ ម្ចាស់សិទ្ធិលើការបញ្ចាំមិនអាចប្រើប្រាស់ ឬ ជួលវត្ថុបញ្ចាំបានឡើយ ។ ប៉ុន្តែ ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើប្រាស់បានត្រឹមតែកម្រិតដែលចាំបាច់ក្នុងការរក្សាវត្ថុបញ្ចាំនោះ ។

២-បើម្ចាស់សិទ្ធិលើការបញ្ចាំបានប្រព្រឹត្តផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១-ខាងលើនេះ កូនបំណុលអាចទាមទារឱ្យរំលត់សិទ្ធិលើការបញ្ចាំបាន ។

មាត្រា ៨៣២.- ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប

១-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុមិនបានទទួលការសងចំពោះសិទ្ធិលើ

បំណុលរបស់ខ្លួនទេ ម្ចាស់សិទ្ធិនោះអាចទាមទារទៅតុលាការឱ្យយកវត្ថុបញ្ចាំមកសងផ្ទាល់តែម្តង តាមការវាយតម្លៃរបស់អ្នកវាយតម្លៃបាន លុះត្រាតែមានមូលហេតុត្រឹមត្រូវ ។ ក្នុងករណីនេះ ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវជូនដំណឹងអំពីការទាមទារនោះទៅកូនបំណុលជាមុន ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើចំនួនទឹកប្រាក់ដែលវាយតម្លៃដោយអ្នកវាយតម្លៃនោះ លើសពីចំនួននៃកាតព្វកិច្ចដែលត្រូវសងម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ ត្រូវសងនូវចំនួនទឹកប្រាក់ដែលនៅសល់ ទៅកម្មសិទ្ធិករនៃវត្ថុបញ្ចាំនោះវិញ ។

មាត្រា ៨៣៣.- លំដាប់នៃសិទ្ធិលើការបញ្ចាំចលនវត្ថុ

ក្នុងករណីដែលបានបង្កើតសិទ្ធិលើការបញ្ចាំលើចលនវត្ថុតែមួយ ដើម្បីធានាសិទ្ធិលើបំណុលច្រើន លំដាប់នៃសិទ្ធិលើការបញ្ចាំទាំងនោះត្រូវអនុលោមតាមពេលវេលាដែលបានបង្កើតនោះ ។

ផ្នែកទី ៣
ការបញ្ចាំអចលនវត្ថុ

មាត្រា ៨៣៤.- សិទ្ធិប្រើប្រាស់ និង អាស្រ័យផលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

១-ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុអាចប្រើប្រាស់ និង អាស្រ័យផលពីអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ តាមវិធីប្រើប្រាស់នៃអចលនវត្ថុនោះ ។

២-ចំពោះដីដែលសិទ្ធិលើការបញ្ចាំបានបង្កើតដើម្បីធានាសិទ្ធិលើបំណុលដែលគ្មានពេលកំណត់ក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំប្រើដីនោះដើម្បីធ្វើកសិកម្ម ទោះបីជាសិទ្ធិលើបំណុលរលត់ដោយការសងក៏ដោយ បើរដូវប្រមូលផលពីដំណាំដែលម្ចាស់សិទ្ធិបំណុលបានសាប ឬ ដាំពីមុន នឹងដល់នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក៏ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើដីនោះ រហូតដល់ពេលដល់រដូវប្រមូលផលនោះ ។

៣-ចំពោះដីដែលសិទ្ធិលើការបញ្ចាំបានបង្កើតដើម្បីធានាសិទ្ធិលើបំណុលដែលមានពេលកំណត់ ក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំប្រើដីនោះដើម្បីធ្វើកសិកម្ម ទោះបីជាសិទ្ធិលើបំណុលរលត់ដោយការសងនៅមុនពេលកំណត់ក៏ដោយ បើរដូវប្រមូលផលពីដំណាំដែល

ម្ចាស់សិទ្ធិបំណុលបានសាប ឬ ដាំពីមុន នឹងផល់នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក៏ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើដីនោះ រហូតដល់ពេលដល់រដូវប្រមូលផលនោះ ។ ប៉ុន្តែ ទោះបីជារដូវប្រមូលផលនោះ នឹងដល់នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក្រោយការសងនៅមុនពេលកំណត់ក៏ដោយ បើរដូវប្រមូលផលនោះ នឹងដល់ក្រោយពេលកំណត់នៃការសងកាតព្វកិច្ច ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវប្រគល់ដីវិញភ្លាម ក្រោយពេលទទួលការសង ។

មាត្រា ៨៣៥.- បន្ទុកសោហ៊ុយគ្រប់គ្រង

ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុត្រូវចេញសោហ៊ុយគ្រប់គ្រង និង ត្រូវទទួលបន្ទុកផ្សេងៗចំពោះអចលនវត្ថុនោះ ។

មាត្រា ៨៣៦.- ការប្រាក់នៃសិទ្ធិលើបំណុល

ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ មិនអាចទាមទារការប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនបានទេ ។

មាត្រា ៨៣៧.- អានុភាពនៃការសន្យាពិសេស

បញ្ញត្តិនៃមាត្រា ៨៣៤ (សិទ្ធិប្រើប្រាស់ និង អាស្រ័យផលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ) មាត្រា ៨៣៥ (បន្ទុកសោហ៊ុយគ្រប់គ្រង) និង មាត្រា ៨៣៦ (ការប្រាក់នៃសិទ្ធិលើបំណុល) ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានការសន្យាពិសេសនៅក្នុងសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ ។

មាត្រា ៨៣៨.- អំឡុងពេលដែលមានអត្ថិភាព

១-អំឡុងពេលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុ មិនអាចលើសពី ៥ (ប្រាំ) ឆ្នាំបានឡើយ ។ ប្រសិនបើបានបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុលើសពីអំឡុងពេលនេះ អំឡុងពេលត្រូវបន្ថយមកត្រឹម ៥ (ប្រាំ) ឆ្នាំ ។

២-កិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុអាចធ្វើបន្តទៀតបាន ។ ប៉ុន្តែ អំឡុងពេលនៃការបន្តនេះមិនអាចធ្វើឱ្យលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលបន្តបានឡើយ ។

មាត្រា ៨៣៩.- ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីហ៊ីប៉ូតែក

ក្រៅពីបញ្ញត្តិនៃផ្នែកទី ៣ (ការបញ្ចាំអចលនវត្ថុ) នេះ បញ្ញត្តិនៃជំពូកទី ៥(ហ៊ីប៉ូតែក) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការបញ្ចាំអចលនវត្ថុ ។

ផ្នែកទី ៤

ការបញ្ចាំសិទ្ធិ

មាត្រា ៨៤០.- កម្មវត្ថុនៃការបញ្ចាំសិទ្ធិ

១-សិទ្ធិលើការបញ្ចាំអាចមានកម្មវត្ថុជាសិទ្ធិលើទ្រព្យសម្បត្តិបាន ។

២-ក្រៅពីបញ្ញត្តិនៃផ្នែកទី ៤(ការបញ្ចាំសិទ្ធិ) នេះ បញ្ញត្តិនៃផ្នែកទី ២(ការបញ្ចាំចលនវត្ថុ) និងផ្នែកទី ៣(ការបញ្ចាំអចលនវត្ថុ) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសិទ្ធិលើការបញ្ចាំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

មាត្រា ៨៤១.- លក្ខខណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ

១-ក្នុងករណីដែលយកសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ មកធ្វើជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ សិទ្ធិលើការបញ្ចាំនេះ មិនអាចតតាំងចំពោះកូនបំណុលទី ៣ និង តតិយជនផ្សេងទៀតបានឡើយ លើកលែងតែករណីដែលបានជូនដំណឹងអំពីការបង្កើតសិទ្ធិលើការបញ្ចាំដល់កូនបំណុលទី ៣ ឬ មានការយល់ព្រមពីកូនបំណុលទី ៣ នោះ ។

២-ការជូនដំណឹង ឬ ការយល់ព្រមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចតតាំងចំពោះតតិយជន ក្រៅពីកូនបំណុលទី ៣ បានឡើយ ប្រសិនបើមិនបានធ្វើឡើងដោយលិខិតដែលមានកាលបរិច្ឆេទស្លាក ។

មាត្រា ៨៤២.- ការអនុវត្តសិទ្ធិលើការបញ្ចាំដោយប្រមូលសិទ្ធិលើបំណុល

១-ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រមូលសិទ្ធិលើបំណុលដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំបាន ។

២-ប្រសិនបើកម្មវត្ថុនៃសិទ្ធិលើបំណុលជាប្រាក់ ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រមូលសិទ្ធិលើបំណុល ត្រឹមតែភាគដែលស្មើនឹងចំនួនប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនប៉ុណ្ណោះ ។

ROYAUME DU CAMBODGE · LE MINISTÈRE DU PALAIS ROYAL

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បើកំណត់ពេលត្រូវសងនៃសិទ្ធិលើបំណុលបានមកដល់ មុនកំណត់ពេលត្រូវសងនៃសិទ្ធិលើបំណុលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនេះអាចឱ្យកូនបំណុលទី ៣ តម្កល់ប្រាក់សងនេះបាន ។ ក្នុងករណីនេះ សិទ្ធិលើការបញ្ចាំមានអត្ថិភាពលើប្រាក់តម្កល់នោះ ។

៤-ប្រសិនបើកម្មវត្ថុនៃសិទ្ធិលើបំណុលមិនមែនជាប្រាក់ទេ ម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិលើការបញ្ចាំលើវត្ថុដែលខ្លួនបានទទួលជាការសង ។

ជំពូកទី ៥
ហ៊ីប៉ូតែក
ផ្នែកទី ១
អត្ថន័យនៃហ៊ីប៉ូតែក

មាត្រា ៨៤៣.- អត្ថន័យនៃហ៊ីប៉ូតែក

១-ម្ចាស់បំណុលហ៊ីប៉ូតែកមានសិទ្ធិទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត ចំពោះអចលនវត្ថុដែលបានដាក់ជាប្រាតិភោគនៃកាតព្វកិច្ច ដោយកូនបំណុល ឬ តតិយជនមិនផ្ទេរការកាន់កាប់ ។

២-សិទ្ធិជួលអចិន្ត្រៃយ៍ និង ផលុបភោគ ក៏អាចយកមកធ្វើជាកម្មវត្ថុនៃហ៊ីប៉ូតែកបានដែរ ។ ក្នុងករណីនេះ បញ្ញត្តិនៃជំពូកទី ៥ (ហ៊ីប៉ូតែក) នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

៣-ក្នុងករណីដែលច្បាប់ពិសេសទទួលស្គាល់ការយកទ្រព្យសម្បត្តិផ្សេងក្រៅពីអចលនវត្ថុ មកធ្វើជាកម្មវត្ថុនៃហ៊ីប៉ូតែក បញ្ញត្តិនៃច្បាប់ពិសេសនោះត្រូវយកមកអនុវត្ត ។

ផ្នែកទី ២
ការបង្កើតហ៊ីប៉ូតែក

មាត្រា ៨៤៤.- ការបង្កើតហ៊ីប៉ូតែក

ហ៊ីប៉ូតែកនឹងត្រូវបានបង្កើតឡើង ដោយការព្រមព្រៀងគ្នារវាងម្ចាស់បំណុល និង កូន

ROYAUME DU CAMBODGE · LE MINISTÈRE ... ROYAL · ក្រសួងព្រះបរមរាជវាំង

បំណុល ឬ តតិយជនដែលយកអចលនវត្ថុរបស់ខ្លួនមកដាក់ជាប្រាតិភោគ ។

មាត្រា ៨៤៥.- ការតតាំងនៃហ៊ីប៉ូតែក

ម្ចាស់បំណុលហ៊ីប៉ូតែកមិនអាចយកហ៊ីប៉ូតែកនោះមកតតាំងចំពោះតតិយជន ក្រៅពីអ្នកដែលបង្កើតហ៊ីប៉ូតែកបានឡើយ ប្រសិនបើមិនបានធ្វើកិច្ចសន្យាបង្កើតហ៊ីប៉ូតែកនោះ ដោយលិខិតយថាភូត និង មិនបានចុះបញ្ជីនៅក្នុងសៀវភៅបញ្ជីដីធ្លីទេ ។

ផ្នែកទី ៣
អានុភាពនៃហ៊ីប៉ូតែក

មាត្រា ៨៤៦.- ទំហំនៃអានុភាពហ៊ីប៉ូតែក

១-ហ៊ីប៉ូតែកមានអានុភាពលើវត្ថុដែលភ្ជាប់នឹងដីដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក និង ជាផ្នែកមួយនៃដីដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកនោះ នៅពេលបង្កើតហ៊ីប៉ូតែក រួមទាំងអគារដែលមាននៅលើដីហ៊ីប៉ូតែកនោះ ។ អានុភាពនេះក៏មានលើវត្ថុ ដែលត្រូវបានភ្ជាប់នៅក្រោយពេលបង្កើតហ៊ីប៉ូតែកផងដែរ ។

២-ភាគីពុំអាចកំណត់ផ្សេងពីបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ នៅក្នុងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកបានឡើយ ។

មាត្រា ៨៤៧.- អានុភាពនៃហ៊ីប៉ូតែកលើដីចំពោះអគារដែលជាកម្មសិទ្ធិរបស់តតិយជន

ក្នុងករណីដែលតតិយជនមានកម្មសិទ្ធិលើអគារនៅលើដីដែលបានដាក់ជាហ៊ីប៉ូតែក ដោយផ្អែកលើសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ឬ សិទ្ធិជួល ហ៊ីប៉ូតែកនេះពុំមានអានុភាពលើអគារនោះឡើយ ។

មាត្រា ៨៤៨.- អានុភាពនៃហ៊ីប៉ូតែក ចំពោះផល

បញ្ញត្តិនៃមាត្រា ៨៤៦ (ទំហំនៃអានុភាពហ៊ីប៉ូតែក) ខាងលើនេះ មិនត្រូវយកមកអនុវត្តចំពោះផលឡើយ ។ ប៉ុន្តែ បញ្ញត្តិនៃវាក្យខណ្ឌទី ១ នេះមិនត្រូវយកមកអនុវត្តឡើយ នៅក្រោយពេលដែលអចលនវត្ថុហ៊ីប៉ូតែកនោះត្រូវបានរឹបអូស ។

មាត្រា ៨៤៩.- ខ្ទាះនៃសកម្មុះលើវត្ថុ

១-ហ៊ីប៉ូតែកអាចអនុវត្តបានចំពោះទឹកប្រាក់ ឬ វត្ថុផ្សេងទៀតដែលអ្នកបង្កើតហ៊ីប៉ូតែកត្រូវទទួលដោយសារការលក់ ការបាត់បង់ ឬ ការខូចខាតនូវវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកនោះ ។ ប៉ុន្តែ ម្ចាស់ហ៊ីប៉ូតែកពុំអាចអនុវត្តហ៊ីប៉ូតែករបស់ខ្លួនបានឡើយ នៅក្រោយពេលដែលប្រាក់ត្រូវបានបង់ ឬ វត្ថុផ្សេងត្រូវបានប្រគល់ទៅឱ្យអ្នកបង្កើត ។

២-ហ៊ីប៉ូតែកក៏អាចអនុវត្តបានផងដែរ ចំពោះផលដែលកើតឡើងក្រោយការរឹបអូសអចលនវត្ថុហ៊ីប៉ូតែកនោះ ។

មាត្រា ៨៥០.- សិទ្ធិទាមទារសំណងរបស់អ្នកធានាដោយវត្ថុ

ប្រសិនបើអ្នកដែលបានបង្កើតហ៊ីប៉ូតែកដើម្បីធានាកាតព្វកិច្ចរបស់អ្នកដទៃបានសងចំពោះកាតព្វកិច្ចនោះ ឬ បានបាត់បង់នូវកម្មសិទ្ធិលើដីហ៊ីប៉ូតែក ដោយសារការអនុវត្តហ៊ីប៉ូតែកនោះ អ្នកនោះត្រូវមានសិទ្ធិទាមទារសំណងពីកូនបំណុល ដោយយោងទៅតាមបញ្ញត្តិស្តីពីការធានា ។

មាត្រា ៨៥១.- លំដាប់នៃហ៊ីប៉ូតែក

ក្នុងករណីដែលបានបង្កើតហ៊ីប៉ូតែកនៅលើអចលនវត្ថុតែមួយ ដើម្បីធានាសិទ្ធិលើបំណុលច្រើន លំដាប់នៃហ៊ីប៉ូតែកនោះត្រូវអនុលោមតាមពេលវេលាដែលបានចុះបញ្ជី ។

មាត្រា ៨៥២.- ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

១-ក្នុងករណីដែលម្ចាស់បំណុលហ៊ីប៉ូតែកមានសិទ្ធិទាមទារការប្រាក់ ឬ ផលលាភផ្សេងទៀត ម្ចាស់បំណុលហ៊ីប៉ូតែកអាចអនុវត្តហ៊ីប៉ូតែកនោះបានតែចំពោះចំនួននៃការសងដែលដល់កំណត់ពេលសម្រាប់អំឡុងពេល ២ (ពីរ) ឆ្នាំចុងក្រោយតែប៉ុណ្ណោះ ។ ប៉ុន្តែ ចំពោះផលលាភដែលមានពីមុនមក ប្រសិនបើបានចុះបញ្ជីពិសេស ក្រោយពីបានដល់ពេលកំណត់ត្រូវសង-ហ៊ីប៉ូតែកនេះអាចអនុវត្តបានចាប់ពីពេលដែលបានចុះបញ្ជីនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះក៏ត្រូវយកមកអនុវត្តផងដែរ ចំពោះប្រាក់ដែលត្រូវបង់សម្រាប់អំឡុងពេល ២ (ពីរ) ឆ្នាំចុងក្រោយ ក្នុងករណីដែលម្ចាស់បំណុលហ៊ីប៉ូតែកមាន

សិទ្ធិទាមទារឱ្យសងសំណងនៃការខូចខាតដែលបានកើតឡើង ដោយការមិនអនុវត្តកាតព្វកិច្ច ។ ប៉ុន្តែ ក្នុងករណីនេះ ចំនួនសរុបនៃសំណងការខូចខាត ព្រមទាំងការប្រាក់ និង ផលលាភផ្សេងទៀត មិនអាចលើសចំនួនសរុបសម្រាប់អំឡុងពេល ២ (ពីរ) ឆ្នាំ បានឡើយ ។

ផ្នែកទី ៤
ការអនុវត្តហ៊ីប៉ូតែក

មាត្រា ៨៥៣.- ការលក់ដោយបង្ខំនូវអចលនវត្ថុហ៊ីប៉ូតែក

បើកាតព្វកិច្ចពុំបានអនុវត្តទេ ម្ចាស់បំណុលហ៊ីប៉ូតែកអាចដាក់ពាក្យសុំឱ្យលក់ដោយបង្ខំនូវអចលនវត្ថុហ៊ីប៉ូតែក ទៅតុលាការបាន ។

មាត្រា ៨៥៤.- ការលក់ដោយបង្ខំនូវអគារជាកម្មសិទ្ធិរបស់តតិយជន

១-បើអ្នកបង្កើតហ៊ីប៉ូតែក មានកម្មសិទ្ធិលើអគារដែលអ្នកបង្កើតហ៊ីប៉ូតែកនោះ ឬ តតិយជនបានសាងសង់នៅលើដីហ៊ីប៉ូតែក នៅក្រោយពេលហ៊ីប៉ូតែកនោះត្រូវបានបង្កើត ហើយ ម្ចាស់បំណុលហ៊ីប៉ូតែកអាចលក់ដោយបង្ខំនូវអគារនោះ ព្រមជាមួយនឹងដីហ៊ីប៉ូតែកនោះបាន ។ ប៉ុន្តែបើចំនួនថ្លៃលក់ដី និង អគារនោះ ទាបជាងថ្លៃលក់ដីដែលគ្មានអគារលើនោះ ម្ចាស់បំណុលហ៊ីប៉ូតែក អាចទាមទារឱ្យអ្នកបង្កើតហ៊ីប៉ូតែករុះរើអគារនោះ មុនពេលលក់ដោយបង្ខំ ។

២-ក្នុងករណីដែលតតិយជនមានកម្មសិទ្ធិលើអគារលើដីហ៊ីប៉ូតែក ដោយផ្អែកលើសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ឬ សិទ្ធិជួល បើតតិយជននោះមិនអាចយកសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ឬ សិទ្ធិជួលរបស់ខ្លួន មកតតាំងចំពោះម្ចាស់បំណុលហ៊ីប៉ូតែក ម្ចាស់បំណុលហ៊ីប៉ូតែកអាចលក់ដោយបង្ខំនូវអគារនោះ ព្រមជាមួយនឹងដីហ៊ីប៉ូតែកបាន ។

មាត្រា ៨៥៥.- ការស្នើសុំទិញដោយតតិយជនដែលបានធ្វើលទ្ធកម្ម

តតិយជនដែលបានធ្វើលទ្ធកម្មនូវអចលនវត្ថុហ៊ីប៉ូតែក អាចក្លាយជាអ្នកទិញក្នុងការលក់ដោយបង្ខំបាន ។

មាត្រា ៨៥៦.- សិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់តតិយជនដែលបានធ្វើលទ្ធកម្ម

ក្នុងករណីដែលតតិយជនដែលបានធ្វើលទ្ធកម្មនូវអចលនវត្ថុហ៊ីប៉ូតែក បានចេញចំណាយ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ជាចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សាវត្ថុ ឬ ចំណាយបង្កើនតម្លៃ ចំពោះអចលនវត្ថុហ៊ីប៉ូតែកនោះ តតិយជននោះអាចទទួលសំណងនៃចំណាយនោះ ពីថ្លៃលក់ដោយបង្ខំនូវអចលនវត្ថុនោះ ដោយមានអាទិភាពជាងម្ចាស់បំណុលហ៊ីប៉ូតែក ។

មាត្រា ៨៥៧.- ការចែកចំណែកព្រមគ្នា និង ការចែកចំណែកមិនព្រមគ្នា ក្នុងករណីនៃហ៊ីប៉ូតែករួម

១-ក្នុងករណីដែលម្ចាស់បំណុលមានហ៊ីប៉ូតែកលើអចលនវត្ថុច្រើនដើម្បីធានាសិទ្ធិលើបំណុលតែមួយ បើចែកចំណែកនូវប្រាក់ដែលបានមកពីការលក់ដោយបង្ខំនៅពេលជាមួយគ្នា បន្ទុកនៃសិទ្ធិលើបំណុលត្រូវចែក ទៅតាមសមាមាត្រនៃតម្លៃអចលនវត្ថុនីមួយៗនោះ ។

២-បើចែកចំណែកតែប្រាក់ដែលបានពីការលក់ដោយបង្ខំនូវអចលនវត្ថុណាមួយ ម្ចាស់បំណុលហ៊ីប៉ូតែកអាចទទួលការសង ចំពោះសិទ្ធិលើបំណុលទាំងអស់ ដោយប្រាក់ដែលបានមកពីការលក់ដោយបង្ខំនោះបាន ។ ក្នុងករណីនេះ ម្ចាស់បំណុលហ៊ីប៉ូតែកដែលមានលំដាប់បន្ទាប់ អាចអនុវត្តហ៊ីប៉ូតែករបស់ម្ចាស់បំណុលហ៊ីប៉ូតែកដែលមានលំដាប់នៅ ខាងលើដោយឧបាទេសកម្មបាន រហូតដល់ចំនួនទឹកប្រាក់ដែលម្ចាស់បំណុលហ៊ីប៉ូតែក ដែលមានលំដាប់ខ្ពស់ជាងនោះ ត្រូវទទួលការសងចំពោះអចលនវត្ថុផ្សេងទៀត ដោយយោងទៅតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

មាត្រា ៨៥៨.- ហ៊ីប៉ូតែករួម - ការចុះបញ្ជីឧបាទេសកម្ម

អ្នកដែលអនុវត្តហ៊ីប៉ូតែកដោយឧបាទេសកម្ម ដោយយោងទៅតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៨៥៧ (ការចែកចំណែកព្រមគ្នា និង ការចែកចំណែកមិនព្រមគ្នាក្នុងករណីនៃហ៊ីប៉ូតែករួម) ខាងលើនេះ ត្រូវចុះបញ្ជីអំពីឧបាទេសកម្មនេះ នៅក្នុងបញ្ជីដែលចុះហ៊ីប៉ូតែក ។

ផ្នែកទី ៥
ការចាត់ចែងហ៊ីប៉ូតែក

មាត្រា ៨៥៩.- ហ៊ីប៉ូតែកបន្ត

១-ម្ចាស់បំណុលហ៊ីប៉ូតែកអាចយកហ៊ីប៉ូតែកនេះធ្វើជាប្រាតិភោគសម្រាប់កាតព្វកិច្ចរបស់ខ្លួន ឬ តតិយជនបាន ។ ករណីនេះហៅថាហ៊ីប៉ូតែកបន្ត ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL ·

២-នៅពេលចែកចំណែកនូវប្រាក់ដែលបានមកពីការលក់ដោយបង្ខំនូវអចលនវត្ថុហ៊ីប៉ូតែក ម្ចាស់បំណុលហ៊ីប៉ូតែកបន្ត អាចទទួលការសងចំពោះសិទ្ធិលើបំណុលទាំងអស់បានត្រឹមកម្រិតនៃចំនួនទឹកប្រាក់នៃចំណែកដែលត្រូវចែកទៅឱ្យម្ចាស់បំណុលហ៊ីប៉ូតែក ។ ប៉ុន្តែ បើសិទ្ធិលើបំណុលនោះមិនទាន់ដល់កំណត់ពេលត្រូវសងទេ ម្ចាស់បំណុលហ៊ីប៉ូតែកបន្ត គ្រាន់តែអាចទាមទារឱ្យតម្កល់ចំនួនទឹកប្រាក់ដែលខ្លួនអាចទទួលការសងនោះប៉ុណ្ណោះ ។

មាត្រា ៨៦០.- អនុប្បទាន ឬ ការបោះបង់នូវហ៊ីប៉ូតែក

១-ម្ចាស់បំណុលហ៊ីប៉ូតែក អាចធ្វើអនុប្បទាន ឬ បោះបង់នូវហ៊ីប៉ូតែកបាន ដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុលផ្សេងទៀតចំពោះកូនបំណុលតែម្នាក់ ។

២-អនុប្បទានិកនៃហ៊ីប៉ូតែក អាចអនុវត្តហ៊ីប៉ូតែកដែលខ្លួនបានទទួល ដោយយកមកធ្វើជាប្រាតិភោគនៃសិទ្ធិលើបំណុលរបស់ខ្លួនបាន ។ ក្នុងករណីនេះ បញ្ញត្តិនៃកថាខណ្ឌ ទី ២ នៃមាត្រា ៨៥៩ (ហ៊ីប៉ូតែកបន្ត) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

៣-បុគ្គលដែលបានបោះបង់ហ៊ីប៉ូតែក ពុំអាចអះអាងអានុភាពនៃហ៊ីប៉ូតែកនោះ ចំពោះបុគ្គលដែលបានទទួលនូវការបោះបង់នោះឡើយ ។

មាត្រា ៨៦១.- អនុប្បទាន ឬ ការបោះបង់ និង ការផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែក

១-ម្ចាស់បំណុលហ៊ីប៉ូតែក អាចធ្វើអនុប្បទាន ឬ បោះបង់លំដាប់នៃហ៊ីប៉ូតែកបាន ដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុលផ្សេងទៀតចំពោះកូនបំណុលតែម្នាក់ ។ ម្ចាស់បំណុលហ៊ីប៉ូតែក ក៏អាចផ្លាស់ប្តូរលំដាប់នៃហ៊ីប៉ូតែកនោះបាន ដោយការព្រមព្រៀងជាមួយម្ចាស់បំណុលហ៊ីប៉ូតែកផ្សេងទៀត ។ ប៉ុន្តែ បើមានបុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ចំពោះការផ្លាស់ប្តូរនោះ ម្ចាស់បំណុលហ៊ីប៉ូតែកត្រូវទទួលការយល់ព្រម អំពីបុគ្គលនោះ ។

២-ម្ចាស់បំណុលហ៊ីប៉ូតែកដែលទទួលអនុប្បទាននូវលំដាប់នៃហ៊ីប៉ូតែក អាចទទួលការសង ដោយមានអាទិភាពជាងម្ចាស់បំណុលហ៊ីប៉ូតែកដែលបានធ្វើអនុប្បទាននូវលំដាប់នោះ នូវចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលទាំងអស់ ពីប្រាក់ដែលបានមកពីការលក់ដោយបង្ខំនូវអចលនវត្ថុហ៊ីប៉ូតែកនោះ ត្រឹមកម្រិតនៃចំនួនទឹកប្រាក់សរុបនៃចំណែកដែលត្រូវចែកឱ្យ ទៅម្ចាស់បំណុលហ៊ីប៉ូតែកទាំងពីរនោះ ។

៣-ម្ចាស់បំណុលហ៊ីប៉ូតែកដែលទទួលនូវការបោះបង់លំដាប់នៃហ៊ីប៉ូតែក អាចទទួលការសងដោយមានសមភាពជាមួយម្ចាស់បំណុលដែលបានលះបង់លំដាប់ហ៊ីប៉ូតែកនោះតាមសមាមាត្រនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល នៅក្នុងទំហំនៃចំនួនទឹកប្រាក់សរុបនៃចំណែកដែលត្រូវចែកឱ្យទៅម្ចាស់បំណុលហ៊ីប៉ូតែកទាំងពីរនោះ ។

៤-ម្ចាស់បំណុលហ៊ីប៉ូតែកដែលបានព្រមព្រៀងក្នុងការផ្លាស់ប្តូរលំដាប់ហ៊ីប៉ូតែក អាចអនុវត្តហ៊ីប៉ូតែកបានតាមការព្រមព្រៀងនោះ ។

មាត្រា ៨៦២.- អានុភាពនៃការចាត់ចែងហ៊ីប៉ូតែក

១-ការចាត់ចែងហ៊ីប៉ូតែកដែលបានកំណត់នៅក្នុងមាត្រា ៨៥៩ (ហ៊ីប៉ូតែកបន្ត) មាត្រា ៨៦០ (អនុប្បទាន ឬ ការបោះបង់នូវហ៊ីប៉ូតែក) និងមាត្រា ៨៦១ (អនុប្បទាន ឬ ការបោះបង់ និង ការផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែក) ខាងលើនេះ មិនមានអានុភាពឡើយ បើមិនធ្វើឡើងដោយលិខិតយថាភូត និង មិនបានចុះបញ្ជីបន្ថែមអំពីការចាត់ចែងនោះ ។

២-ការចាត់ចែងហ៊ីប៉ូតែកមិនអាចតតាំងចំពោះកូនបំណុលដែលមានកាតព្វកិច្ចចម្បង អ្នកធានា អ្នកបង្កើតហ៊ីប៉ូតែក និង ប្រតិសិទ្ធិរបស់ជនទាំងនោះបានឡើយ បើម្ចាស់បំណុលហ៊ីប៉ូ-តែកមិនបានជូនដំណឹងទៅកូនបំណុលដែលមានកាតព្វកិច្ចចម្បង ឬ ទទួលការយល់ព្រមពីកូនបំណុលនោះទេ ។

៣-បើកូនបំណុលដែលមានកាតព្វកិច្ចចម្បងបានទទួលដំណឹង ឬ ផ្តល់ការយល់ព្រមដូចបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ការសងដែលបានធ្វើឡើងចំពោះ អ្នកចាត់ចែងហ៊ីប៉ូតែក ដោយគ្មានការយល់ព្រមពីអ្នកដែលទទួលផលប្រយោជន៍ពីការចាត់ចែងហ៊ីប៉ូ-តែក មិនអាចតតាំងចំពោះអ្នកដែលទទួលផលប្រយោជន៍បានឡើយ ។

មាត្រា ៨៦៣.- លំដាប់នៃការចាត់ចែងហ៊ីប៉ូតែក

ក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ៨៥៩ (ហ៊ីប៉ូតែកបន្ត) មាត្រា ៨៦០ (អនុប្បទាន ឬ ការបោះបង់នូវហ៊ីប៉ូតែក) និងមាត្រា ៨៦១ (អនុប្បទាន ឬ ការបោះបង់ និង ការផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែក) ខាងលើនេះ បើម្ចាស់បំណុលហ៊ីប៉ូតែកបានចាត់ចែងហ៊ីប៉ូតែកសំរាប់បុគ្គលច្រើននាក់ លំដាប់នៃសិទ្ធិរបស់បុគ្គលដែលទទួលផលប្រយោជន៍ ពីការចាត់ចែងនោះ

ROYAUME DU CAMBODGE LE MINISTERE DU PALAIS ROYAL ក្រសួងព្រះបរមរាជវាំង

ត្រូវអនុលោមទៅតាមពេលវេលានៃការចុះបញ្ជីបន្ថែមនៅក្នុងបញ្ជី ដែលចុះហ៊ីប៉ូតែកនោះ ។

ផ្នែកទី ៦

ការរលត់នៃហ៊ីប៉ូតែក

កថាភាគទី ១

ការរលត់ដោយការទាមទារ

មាត្រា ៨៦៤.- ការសងដោយថ្លៃលក់

ក្នុងករណីដែលតតិយជនដែលទិញកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ ចំពោះអចលនវត្ថុហ៊ីប៉ូតែក បានសងថ្លៃលក់នោះទៅម្ចាស់បំណុលហ៊ីប៉ូតែក តាមការទាមទាររបស់ម្ចាស់បំណុលហ៊ីប៉ូតែកហើយ ហ៊ីប៉ូតែកត្រូវរលត់សម្រាប់តតិយជននោះ ។

កថាភាគទី ២

ការរលត់ដោយអាជ្ញាយុកាល

មាត្រា ៨៦៥.- អាជ្ញាយុកាលនៃការរលត់ហ៊ីប៉ូតែក

ហ៊ីប៉ូតែកមិនត្រូវរលត់ដោយអាជ្ញាយុកាល ចំពោះកូនបំណុល និង អ្នកដែលបានបង្កើតហ៊ីប៉ូតែកឡើយ ប្រសិនបើសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកនោះ មិនរលត់ព្រមគ្នាទេ ។

មាត្រា ៨៦៦.- ការរលត់ហ៊ីប៉ូតែកដោយលទ្ធកម្មនូវអចលនវត្ថុហ៊ីប៉ូតែកដោយអាជ្ញាយុកាល

ពេលដែលបុគ្គលក្រៅពីកូនបំណុល ឬ ក្រៅពីអ្នកដែលបានបង្កើតហ៊ីប៉ូតែក បានកាន់កាប់អចលនវត្ថុហ៊ីប៉ូតែក ដោយមានល័ក្ខខ័ណ្ឌចាំបាច់សម្រាប់អាជ្ញាយុកាលនៃការទទួលសិទ្ធិ ហ៊ីប៉ូតែកនោះត្រូវរលត់ ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតតិយជនដែលបានធ្វើលទ្ធកម្មនូវអចលនវត្ថុហ៊ីប៉ូតែកនោះ បានដឹងនៅពេលដែលខ្លួនបានធ្វើលទ្ធកម្មថា ហ៊ីប៉ូតែកត្រូវបានបង្កើតលើអចលនវត្ថុនោះ ។

ផ្នែកទី ៧

ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត

មាត្រា ៨៦៧.– និយមន័យនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត

១-ហ៊ីប៉ូតែកអាចបង្កើតដើម្បីធានាកាតព្វកិច្ចមិនកំណត់ ដែលអាចកើតមានឡើងរវាងម្ចាស់បំណុល និង កូនបំណុល ដោយសារការផ្ញើរជានិរន្តរ៍ដែលមានប្រភេទជាកំណត់ក្នុងកម្រិតនៃចំនួនអតិបរមាបាន ។ ហ៊ីប៉ូតែកបែបនេះ ត្រូវហៅថា ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត ។

២-ចំពោះទំហំនៃសិទ្ធិលើបំណុលមិនកំណត់ ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ដើម្បីធានាបំណុលអណ្ដែត ត្រូវកំណត់នៅក្នុងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត ។

មាត្រា ៨៦៨.– ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត អាចអនុវត្តហ៊ីប៉ូតែកនោះ ក្នុងកម្រិតនៃចំនួនអតិបរមាបាន ចំពោះប្រាក់ដើមដែលបានកំណត់ជាស្ថាពរ ការប្រាក់ និង ផលលាភផ្សេង និង សំណងការខូចខាតទាំងអស់ដែលបានកើតឡើង ដោយសារការមិនអនុវត្តកាតព្វកិច្ច ។

មាត្រា ៨៦៩.– ការកែប្រែទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

១-ក្នុងចន្លោះពេលទៅទល់នឹងពេលដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ភាគីនៃកិច្ចសន្យាបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែតអាចកែប្រែទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត តាមការព្រមព្រៀងបាន ។

២-ដើម្បីធ្វើការកែប្រែដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំចាំបាច់ទទួលការយល់ព្រមពីម្ចាស់បំណុលហ៊ីប៉ូតែកដែលមានអាទិភាពទាបជាង និង តតិយជនឯទៀតឡើយ ។

៣-ការកែប្រែដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចុះបញ្ជីនៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ។

ROYAUME DU CAMBODGE * LE MINISTÈRE ... PALAIS ROYAL
ព្រះបរមរាជវាំង

មាត្រា ៨៧០.- ការកែប្រែចំនួនអតិបរមា

១-ភាគីនៃកិច្ចសន្យាបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចកែប្រែចំនួនអតិបរមានៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត តាមការព្រមព្រៀងបាន ។

២-ដើម្បីធ្វើការកែប្រែដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវទទួលការយល់ព្រមពីសំណាក់ជនដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ ។

៣-ការកែប្រែដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំអាចតតាំងជាមួយនឹងតតិយជនក្រៅពីជនដែលបានយល់ព្រមតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះឡើយបើមិនបានចុះបញ្ជី ។

មាត្រា ៨៧១.- កាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ

១-ចំពោះប្រាក់ដើមដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតអាចកំណត់កាលបរិច្ឆេទដែលប្រាក់ដើមនោះត្រូវបានកំណត់ជាស្ថាពរ ហើយក៏អាចប្តូរកាលបរិច្ឆេទដែលត្រូវបានកំណត់រួចហើយនោះបានដែរ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៨៦៩ (ការកែប្រែទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

៣-កាលបរិច្ឆេទដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវស្ថិតនៅក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីថ្ងៃដែលបានកំណត់ ឬ ប្តូរកាលបរិច្ឆេទនោះ ។

៤-ចំពោះការប្តូរកាលបរិច្ឆេទដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចុះបញ្ជីនៅមុនកាលបរិច្ឆេទនោះ ។

មាត្រា ៨៧២.- អនុប្បទានសិទ្ធិលើបំណុលដែលត្រូវបានធានា ឬ ការទទួលភារកាតព្វកិច្ច

១-ជនដែលបានធ្វើលទ្ធកម្មនូវសិទ្ធិលើបំណុលពីម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត នៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ពុំអាចអនុវត្តហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតចំពោះសិទ្ធិលើបំណុលនោះបានឡើយ ។ ជនដែលបានសងដើម្បីកូនបំណុល ឬ ជំនួសកូនបំណុល នៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ក៏ពុំអាចអនុវត្ត

ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដោយឧបាទេសកម្មដោយការសងបានឡើយ ។

៦-បើមានការទទួលកាតព្វកិច្ចមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ពុំអាចអនុវត្តហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះចំពោះកាតព្វកិច្ចរបស់អ្នកទទួលបានឡើយ ។

មាត្រា ៨៧៣.- សន្តតិកម្មពីម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ឬ កូនបំណុល

១-បើសន្តតិកម្មបានចាប់ផ្តើមចំពោះម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត នៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះ ត្រូវធានានូវសិទ្ធិលើបំណុលដែលមានអត្ថិភាពនៅពេលសន្តតិកម្មបានចាប់ផ្តើម ។ ម្យ៉ាងទៀត ហ៊ីប៉ូតែកនោះត្រូវធានានូវសិទ្ធិលើបំណុលដែលនឹងត្រូវបានធ្វើលទ្ធកម្ម នៅក្រោយពេលសន្តតិកម្មបានចាប់ផ្តើម ដោយសន្តតិជនដែលត្រូវបានកំណត់តាមការព្រមព្រៀងរវាងសន្តតិជន និង អ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ។

២-បើសន្តតិកម្មបានចាប់ផ្តើមចំពោះកូនបំណុល នៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះ ត្រូវធានានូវកាតព្វកិច្ចដែលមានអត្ថិភាពនៅពេលសន្តតិកម្មបានចាប់ផ្តើម ។ ម្យ៉ាងទៀត ហ៊ីប៉ូតែកនោះ ត្រូវធានានូវកាតព្វកិច្ចដែលនឹងត្រូវបានទទួលបន្ទុក នៅក្រោយពេលសន្តតិកម្មបានចាប់ផ្តើម ដោយសន្តតិជនដែលត្រូវបានកំណត់តាមការព្រមព្រៀងរវាងម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត និង អ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៨៦៩ (ការកែប្រែទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលធ្វើការព្រមព្រៀងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ។

៤-ចំពោះការព្រមព្រៀងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ បើមិនបានចុះបញ្ជីក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ក្រោយពេលសន្តតិកម្មបានចាប់ផ្តើមទេ ប្រាក់ដើមដែលត្រូវបានធានា ត្រូវចាត់ទុកថាបានកំណត់ជាស្ថាពរ នៅពេលសន្តតិកម្មបានចាប់ផ្តើម ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា ៤៧៤.- ការរួមបញ្ចូលម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ឬ កូនបំណុល

១-បើមានការរួមបញ្ចូលម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដែលជានីតិបុគ្គល នៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតត្រូវធានានូវសិទ្ធិលើបំណុលដែលមានអត្ថិភាពនៅពេលរួមបញ្ចូល ហើយក្រៅពីនោះ ត្រូវធានានូវសិទ្ធិលើបំណុលដែលនឹងត្រូវបានធ្វើលទ្ធកម្មនៅក្រោយការរួមបញ្ចូល ដោយនីតិបុគ្គលដែលបន្តអត្ថិភាពក្រោយការរួមបញ្ចូល ឬ នីតិបុគ្គលដែលត្រូវបានបង្កើតឡើងដោយការរួមបញ្ចូល ។

២-បើមានការរួមបញ្ចូលកូនបំណុលដែលជានីតិបុគ្គល នៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតត្រូវធានានូវកាតព្វកិច្ច ដែលមានអត្ថិភាពនៅពេលរួមបញ្ចូល ហើយក្រៅពីនោះត្រូវធានានូវកាតព្វកិច្ចដែលនឹងត្រូវទទួលបន្ទុកនៅក្រោយការរួមបញ្ចូល ដោយនីតិបុគ្គលដែលបន្តអត្ថិភាពក្រោយការរួមបញ្ចូល ឬ នីតិបុគ្គលដែលត្រូវបានបង្កើតឡើងដោយការរួមបញ្ចូល ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ អ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចទាមទារឱ្យកំណត់ប្រាក់ដើមដែលត្រូវបានធានាជាស្ថាពរបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ហើយកូនបំណុលនោះ ជាអ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ។

៤-បើមានការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ប្រាក់ដើមដែលត្រូវបានធានា ត្រូវចាត់ទុកថាបានកំណត់ជាស្ថាពរនៅពេលរួមបញ្ចូល ។

៥-ការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ មិនអាចធ្វើបានឡើយ បើអំឡុងពេល ២ (ពីរ) សប្តាហ៍ បានកន្លងហួស គិតចាប់ពីថ្ងៃដែលអ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតបានដឹងអំពីការរួមបញ្ចូលនោះ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអំឡុងពេល ១ (មួយ) ខែ បានកន្លងហួស គិតចាប់ពីថ្ងៃរួមបញ្ចូល ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា ៨៧៥.- ការបំបែកម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ឬ កូនបំណុល

១-បើមានការបំបែកម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដែលជានីតិបុគ្គល នៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ត្រូវធានានូវសិទ្ធិលើបំណុលដែលមានអត្ថិភាពនៅពេលបំបែក ហើយក្រៅពីនោះត្រូវធានានូវសិទ្ធិលើបំណុលដែលនឹងត្រូវបានធ្វើលទ្ធកម្មនៅក្រោយការបំបែក ដោយនីតិបុគ្គលដែលត្រូវបានបំបែក និង នីតិបុគ្គលដែលត្រូវបានបង្កើតឡើងដោយការបំបែក ឬ ដោយនីតិបុគ្គលដែលត្រូវបានបំបែក និង នីតិបុគ្គលដែលទទួលបន្តអាជីវកម្ម ។

២-បើមានការបំបែកកូនបំណុលដែលជានីតិបុគ្គល នៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ត្រូវធានានូវកាតព្វកិច្ចដែលមានអត្ថិភាពនៅពេលបំបែក ហើយក្រៅពីនោះ ត្រូវធានានូវកាតព្វកិច្ចដែលនឹងត្រូវទទួលបន្ទុកនៅក្រោយការបំបែក ដោយនីតិបុគ្គលដែលត្រូវបានបំបែក និង នីតិបុគ្គលដែលត្រូវបានបង្កើតឡើងដោយការបំបែក ឬ ដោយនីតិបុគ្គលដែលត្រូវបានបំបែក និង នីតិបុគ្គលដែលទទួលបន្តអាជីវកម្ម ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ៣ ទី ៤ និង ទី ៥ នៃមាត្រា ៨៧៤ (ការរួមបញ្ចូលម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ឬ កូនបំណុល) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបញ្ញត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ នៃមាត្រានេះ ។

មាត្រា ៨៧៦.- ការចាត់ចែងហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

១-នៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត មិនអាចធ្វើការចាត់ចែងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៨៦០ (អនុប្បទាន ឬ ការបោះបង់នូវហ៊ីប៉ូតែក) ឬ កថាខណ្ឌទី ១ នៃមាត្រា ៨៦១ (អនុប្បទាន ឬ ការបោះបង់ និង ការផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែក) ខាងលើនេះឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនរារាំងក្នុងការធ្វើការចាត់ចែងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៨៥៩ (ហ៊ីប៉ូតែកបន្ត) នៃក្រមនេះឡើយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ៨៦២ (អានុភាពនៃការចាត់ចែងហ៊ីប៉ូតែក) នៃក្រមនេះមិនត្រូវយកមកអនុវត្តឡើយចំពោះការសងដែលបានធ្វើឡើងមុនពេលប្រាក់ដើមត្រូវបាន

កំណត់ជាស្ថាពរ នៅក្នុងករណីដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌ ទី ១ នៃមាត្រា នេះ ។

មាត្រា ៨៧៧.- អនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

១-នៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចធ្វើអនុប្បទាននូវហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះ ដោយទទួលការយល់ព្រមពីអ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតបាន ។

២-ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចបែងចែកហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះជាពីរផ្នែក ហើយអាចធ្វើអនុប្បទានផ្នែកណាមួយ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។ ក្នុងករណីនេះ ប្រសិនបើហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះ ជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជន សិទ្ធិរបស់តតិយជននោះត្រូវរលត់ចំពោះផ្នែកនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដែលត្រូវបានធ្វើអនុប្បទាន ។

៣-ដើម្បីធ្វើអនុប្បទានដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ត្រូវទទួលការយល់ព្រមពីតតិយជនដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២ដដែលនេះ ។

មាត្រា ៨៧៨.- អនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតមួយផ្នែក

នៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតអាចធ្វើអនុប្បទាននូវហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតមួយផ្នែកដោយទទួលការយល់ព្រមពីអ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ហើយអាចធ្វើជាម្ចាស់សិទ្ធិរួមជាមួយអនុប្បទានិកបាន ។

មាត្រា ៨៧៩.- សិទ្ធិរួមលើហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

១-ម្ចាស់សិទ្ធិរួមលើហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ត្រូវទទួលនូវការសងតាមសមាមាត្រនៃសិទ្ធិលើបំណុលនីមួយៗ ។ ប៉ុន្តែ បើកំណត់ចំណែកភាគផ្សេងពីករណីខាងលើមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ឬ បើកំណត់ថាជនណាម្នាក់អាចទទួលការសងដោយ

មានអាទិភាពជាងជនឯទៀត ត្រូវអនុលោមតាមការកំណត់នោះ ។

២-ម្ចាស់សិទ្ធិរួមលើហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចធ្វើអនុប្បទាននូវសិទ្ធិរបស់ខ្លួន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៨៧៧ (អនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត) ខាងលើនេះ ដោយទទួលការយល់ព្រមពីម្ចាស់សិទ្ធិរួមឯទៀត ។

មាត្រា ៨៨០.- អានុភាពនៃអនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដោយម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដែលបានទទួលអនុប្បទាន ឬ ការបោះបង់លំដាប់នៃហ៊ីប៉ូតែក

បើម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដែលបានទទួលអនុប្បទាន ឬ ការបោះបង់លំដាប់នៃហ៊ីប៉ូតែក បានធ្វើអនុប្បទាននូវហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះទាំងស្រុង ឬ មួយផ្នែក អនុប្បទានិកត្រូវទទួលផលប្រយោជន៍នៃអនុប្បទាន ឬ ការបោះបង់លំដាប់នោះ ។

មាត្រា ៨៨១.- ហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត

បញ្ញត្តិនៃមាត្រា ៨៥៧ (ការចែកចំណែកព្រមគ្នា និង ការចែកចំណែកមិនព្រមគ្នាក្នុងករណីនៃហ៊ីប៉ូតែករួម) និងមាត្រា ៨៥៨ (ហ៊ីប៉ូតែករួម - ការចុះបញ្ជីឧបាទេសកម្ម) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត តែក្នុងករណីដែលបានចុះបញ្ជីអំពីការណ៍ដែលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ត្រូវបានបង្កើតលើអចលនវត្ថុច្រើនដើម្បីធានាសិទ្ធិលើបំណុលតែមួយ ព្រមគ្នានឹងពេលបង្កើតហ៊ីប៉ូតែកនោះ ។

មាត្រា ៨៨២.- ការកែប្រែ អនុប្បទាន និង ការកំណត់ជាស្ថាពរ នូវហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត

១-ការកែប្រែទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដែលមានការចុះបញ្ជីដែលបានកំណត់នៅក្នុងមាត្រា ៨៨១ (ហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត) ខាងលើនេះ ការផ្លាស់ប្តូរកូនបំណុល ការកែប្រែចំនួនអតិបរមា ឬ អនុប្បទានហ៊ីប៉ូតែកនោះទាំងស្រុង ឬ មួយផ្នែក មិនត្រូវបង្កើតអានុភាពឡើយ បើមិនបានចុះបញ្ជី

អំពីការកែប្រែ ឬ អនុប្បទាននោះ ចំពោះអចលនវត្ថុទាំងអស់ទេ ។

២-ប្រាក់ដើមដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដែលមានការចុះបញ្ជីដែលបានកំណត់នៅក្នុងមាត្រា ៨៨១ (ហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត) ខាងលើនេះ ត្រូវកំណត់ជាស្ថាពរដែរ ទោះបីជាហេតុដែលនាំឱ្យកំណត់ប្រាក់ដើមជាស្ថាពរបានកើតឡើងចំពោះអចលនវត្ថុតែមួយក៏ដោយ ។

មាត្រា ៨៨៣.- ហ៊ីប៉ូតែកតម្រួតដើម្បីធានាបំណុលអណ្តែត

ជនដែលមានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតលើអចលនវត្ថុច្រើន អាចអនុវត្តសិទ្ធិអាទិភាពចំពោះប្រាក់ថ្លៃលក់នៃអចលនវត្ថុនីមួយៗ រហូតដល់ចំនួនអតិបរមានីមួយៗបាន លើកលែងតែករណីដែលបានកំណត់នៅក្នុងមាត្រា ៨៨១ (ហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត) ខាងលើនេះ ។

មាត្រា ៨៨៤.- ការទាមទារឱ្យកំណត់ប្រាក់ដើមជាស្ថាពរ

១-បើអំឡុងពេល ៣ (បី) ឆ្នាំបានកន្លងហួស គិតចាប់ពីពេលដែលបានបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតអាចទាមទារឱ្យកំណត់ប្រាក់ដើមដែលត្រូវបានធានាជាស្ថាពរបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានការកំណត់អំពីកាលបរិច្ឆេទដែលត្រូវកំណត់ប្រាក់ដើមជាស្ថាពរ ។

២-បើប្រាក់ដើមដែលត្រូវបានធានាលែងកើតមានទៀត ដោយសារការផ្លាស់ប្តូរទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ការបញ្ចប់ការជួញដូរ ឬ ហេតុផ្សេងទៀត អ្នកបង្កើតហ៊ីប៉ូ-តែកដើម្បីធានាបំណុលអណ្តែត អាចទាមទារឱ្យកំណត់ប្រាក់ដើមដែលត្រូវបានធានាជាស្ថាពរបាន ។

៣-ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតអាចទាមទារឱ្យកំណត់ប្រាក់ដើមដែលត្រូវបានធានាជាស្ថាពរបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានការកំណត់អំពីកាលបរិច្ឆេទដែលត្រូវកំណត់ប្រាក់ដើមជាស្ថាពរ ។

៤-បើមានការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ទី ២ ឬ ទី ៣ ខាងលើនេះ ប្រាក់ដើមដែលត្រូវបានធានា ត្រូវកំណត់ជាស្ថាពរ នៅពេលដែលអំឡុងពេល ២ (ពីរ)សប្តាហ៍

បានកន្លងផុត គិតចាប់ពីពេលទាមទារនោះ ។

មាត្រា ៨៨៥.- ហេតុដែលនាំឱ្យកំណត់ប្រាក់ដើមជាស្ថាពរ

១-ក្រៅពីករណីដែលមានការទាមទារឱ្យកំណត់ប្រាក់ដើមជាស្ថាពរ តាមបញ្ញត្តិនៃមាត្រា ៨៨៤ (ការទាមទារឱ្យកំណត់ប្រាក់ដើមជាស្ថាពរ) ខាងលើ ប្រាក់ដើមដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ត្រូវកំណត់ជាស្ថាពរក្នុងករណីដូចខាងក្រោមនេះ :

ក-បើម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត បានដាក់ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុដែលបានដាក់ជាហ៊ីប៉ូតែក ។ ប៉ុន្តែ បញ្ញត្តិនេះត្រូវយកមកអនុវត្ត ចំពោះតែករណីដែលនីតិវិធីនៃការលក់ដោយបង្ខំ បានចាប់ផ្តើមប៉ុណ្ណោះ ។

ខ-បើម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត បានរឹបអូសចំពោះអចលនវត្ថុហ៊ីប៉ូតែក ដោយយោងតាមការចាត់ចែងចំពោះពន្ធគឺងទារ ។

គ-បើអំឡុងពេល ២ (ពីរ) សប្តាហ៍កន្លងហួស ចាប់ពីពេលដែលម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត បានដឹងអំពីការចាប់ផ្តើមនីតិវិធីនៃការលក់ដោយបង្ខំ ឬ ការរឹបអូសដោយយោងតាមការចាត់ចែងចំពោះពន្ធគឺងទារ ចំពោះអចលនវត្ថុហ៊ីប៉ូតែក ។

ឃ-បើកូនបំណុល ឬ អ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត បានទទួលសេចក្តីប្រកាសអំពីធនក្ស័យ ។

២-បើអានុភាពនៃនីតិវិធីលក់ដោយបង្ខំ ឬ ការរឹបអូសដែលបានកំណត់នៅក្នុងចំណុច គ នៃកថាខណ្ឌទី ១ ខាងលើនេះ ឬ អានុភាពនៃសេចក្តីប្រកាសអំពីធនក្ស័យ ដែលបានកំណត់នៅក្នុងចំណុច ឃ នៃកថាខណ្ឌដដែលបានរលត់ ប្រាក់ដើមដែលត្រូវបានធានា ត្រូវចាត់ទុកថាពុំបានកំណត់ជាស្ថាពរឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានបុគ្គល ដែលបានទទួលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះ ឬ សិទ្ធិដែលយកហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះជាកម្មវត្ថុដោយឈរលើមូលដ្ឋានថាប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ។

មាត្រា ៨៨៦.- ការទាមទារបន្ថយចំនួនអតិបរមា

១-នៅក្រោយពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ អ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានា

បំណុលអណ្តែត អាចទាមទារឱ្យបន្ថយចំនួនអតិបរមានៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះ មកត្រឹមចំនួននៃកាតព្វកិច្ចដែលមានអត្ថិភាពបច្ចុប្បន្ន បូកនឹងចំនួននៃការប្រាក់ និង ផលលាភផ្សេងទៀត ព្រមទាំងចំនួននៃសំណងការខូចខាតដោយសារការមិនអនុវត្តកាតព្វកិច្ចដែលត្រូវកើតឡើងក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ ក្រោយពេលប្រាក់ដើម ត្រូវបានកំណត់ជាស្ថាពរ ។

២-ចំពោះការបន្ថយចំនួនអតិបរមានៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដែលមានការចុះបញ្ជីដែលបានកំណត់នៅក្នុងមាត្រា ៨៨១ (ហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត) នៃក្រមនេះ ការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ គ្រាន់តែធ្វើឡើងចំពោះអចលនវត្ថុតែមួយជាការគ្រប់គ្រាន់ ។

មាត្រា ៨៨៧.- ការទាមទារឱ្យរំលត់ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

១-បើចំនួននៃកាតព្វកិច្ចដែលមានអត្ថិភាពនៅក្រោយពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ លើសពីចំនួនអតិបរមានៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អ្នកដែលបានបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដើម្បីធានាកាតព្វកិច្ចរបស់ជនដទៃ ឬ តតិយជន ដែលបានធ្វើលទ្ធកម្មនូវកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ សិទ្ធិជួលដែលអាចតតាំងនឹងតតិយជន ចំពោះអចលនវត្ថុហ៊ីប៉ូតែក អាចទាមទារឱ្យរំលត់ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះ ដោយបង់ជាប្រាក់ដែលស្មើនឹងចំនួនអតិបរមានោះ ឬ ដោយតម្កល់ប្រាក់នោះបាន ។ ក្នុងករណីនេះ ការបង់ ឬ ការតម្កល់នោះ មានអានុភាពជាការសង ។

២-ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដែលមានការចុះបញ្ជីដែលបានកំណត់នៅក្នុងមាត្រា ៨៨១ (ហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត) នៃក្រមនេះ ត្រូវរលត់នៅពេលដែលមានការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះអចលនវត្ថុមួយ ។

៣-កូនបំណុលដែលមានកាតព្វកិច្ចចម្បង អ្នកធានា និង ប្រតិសិទ្ធិ មិនអាចធ្វើការទាមទារឱ្យរំលត់ ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបានឡើយ ។

៤-តតិយជនដែលបានធ្វើលទ្ធកម្មនូវកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀត ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដោយភ្ជាប់នឹងល័ក្ខខ័ណ្ឌបង្អង់ មិនអាចធ្វើការទាមទារឱ្យរំលត់ដូចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនេះបានឡើយ នៅក្នុងពេលដែលពុំទាន់ដឹងថាល័ក្ខខ័ណ្ឌ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

០៧/៤៥៣

នោះត្រូវបានបំពេញ ឬ មិនទាន់បានបំពេញ ។

ជំពូកទី ៦
ប្រាតិភោគដោយអនុប្បទាន

ផ្នែកទី ១
និយមន័យនៃប្រាតិភោគដោយអនុប្បទាន

មាត្រា ៤៨៨.- និយមន័យនៃប្រាតិភោគដោយអនុប្បទាន

១-ប្រាតិភោគដោយអនុប្បទាន សំដៅទៅលើករណីដែលកូនបំណុល ឬ តតិយជនធ្វើអនុប្បទាននូវចលនវត្ថុរបស់ខ្លួនជាកំណត់ ទៅឱ្យម្ចាស់បំណុល ដើម្បីធានាកាតព្វកិច្ច ។ ក្នុងករណីនេះបើកាតព្វកិច្ចត្រូវបានសងរួចហើយ កម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុ ត្រូវផ្ទេរទៅអ្នកបង្កើត ។

២-ចលនវត្ថុច្រើន ដែលត្រូវបានកំណត់ទំហំតាមមាត្រដ្ឋាន ដូចជាប្រភេទ ឬ កន្លែងស្ថិតនៅនៃចលនវត្ថុ អាចយកមកធ្វើជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ដោយចាត់ទុកជាចលនវត្ថុផ្តុំគ្នាតែមួយបាន ទោះបីជាចលនវត្ថុនីមួយៗដែលផ្តុំគ្នានោះ មានការប្រែប្រួលក៏ដោយ ។

ផ្នែកទី ២
ការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន

មាត្រា ៤៨៩.- ការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន

សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវបានបង្កើតឡើង ដោយការព្រមព្រៀងរវាងម្ចាស់បំណុល និងកូនបំណុល ឬ តតិយជន ដែលផ្តល់ចលនវត្ថុសម្រាប់ប្រាតិភោគដោយអនុប្បទាន ។

មាត្រា ៤៩០.- អានុភាពតតាំងនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចតតាំងសិទ្ធិប្រាតិភោគដោយអនុប្បទាននោះចំពោះតតិយជនក្រៅពីអ្នកបង្កើតបានឡើយ បើមិនបានទទួលការផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុ ដោយយោងតាមបញ្ញត្តិនៃមាត្រា ២២៩ (ការផ្ទេរការកាន់កាប់) នៃក្រមនេះទេ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ផ្នែកទី ៣

អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

មាត្រា ៨៩១.- ទំហំដែលមានអានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

១-សិទ្ធិប្រាតិភោគដោយអនុប្បទាន មានអានុភាពលើវត្ថុដែលភ្ជាប់នឹងវត្ថុដែលជាកម្មវត្ថុ និង ជាផ្នែកមួយនៃវត្ថុដែលជាកម្មវត្ថុនោះ នៅពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ។ អានុភាពនេះក៏មានលើវត្ថុដែលត្រូវបានភ្ជាប់នៅក្រោយពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានផងដែរ ។

២-ភាគីអាចកំណត់ផ្សេងពីបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបាន នៅក្នុងកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ។

មាត្រា ៨៩២.- អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទានចំពោះផល

១-ក្នុងករណីដែលអ្នកបង្កើត ឬ តតិយជនដែលបានទទួលការបញ្ជាពីអ្នកបង្កើតនោះ កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ បញ្ញត្តិនៃមាត្រា ៨៩១ (ទំហំដែលមានអានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន) ខាងលើនេះ មិនត្រូវយកមកអនុវត្តចំពោះផលឡើយ ។ ប៉ុន្តែ បញ្ញត្តិនៃវាក្យខណ្ឌទី ១ នេះមិនត្រូវយកមកអនុវត្តឡើយ នៅក្រោយពេលដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន បានទាមទារឱ្យប្រគល់វត្ថុដែលជាកម្មវត្ថុ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៨៩៨ (ការចាត់ចែងប្តូរជាប្រាក់ ឬ អនុប្បទានជាស្ថាពរ) នៃក្រមនេះ ។

២-ក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានទទួលការបញ្ជាពីម្ចាស់សិទ្ធិនោះ កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ បញ្ញត្តិនៃមាត្រា ៨២២ (សិទ្ធិទទួលការសងពីផលដោយមានអាទិភាព) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះផលដែលកើតឡើងពីវត្ថុដែលជាកម្មវត្ថុនោះ ។

មាត្រា ៨៩៣.- ឧបនេសកម្មលើវត្ថុ

១-ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចអនុវត្តសិទ្ធិរបស់ខ្លួនបាន ចំពោះទឹកប្រាក់ ឬ វត្ថុដទៃ ដែលអ្នកបង្កើតត្រូវទទួល ដោយការលក់ ការបាត់បង់ ឬ ការខូចខាតនូវវត្ថុដែល

ជាកម្មវត្ថុ ។ ប៉ុន្តែ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចអនុវត្តសិទ្ធិរបស់ខ្លួនបានឡើយ នៅក្រោយពេលដែលប្រាក់ត្រូវបានបង់ ឬ វត្ថុផ្សេងត្រូវបានប្រគល់ទៅឱ្យអ្នកបង្កើត ។

២-ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បើវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ជាចលនវត្ថុដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៨៨៨ (និយមន័យនៃប្រាតិភោគដោយអនុប្បទាន) នៃក្រមនេះ ហើយបើអ្នកបង្កើតមានគម្រោងនឹងលក់វត្ថុដែលជាកម្មវត្ថុនេះទៅជនដទៃ សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចអនុវត្តចំពោះទឹកប្រាក់ដែលបានមកពីការលក់នោះឡើយ ។

មាត្រា ៨៩៤.- ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយអ្នកបង្កើត

១-បើអ្នកបង្កើតដែលបន្តការកាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន នៅក្រោយពេលបង្កើតសិទ្ធិនោះ បានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ឬ បានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើវត្ថុនោះដើម្បីតតិយជន ប្រសិនបើតតិយជននោះបំពេញគ្រប់ល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងមាត្រា ១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ តតិយជននោះអាចយកសិទ្ធិរបស់ខ្លួនទៅតតាំងចំពោះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបាន ។

២-ចំពោះចលនវត្ថុដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ នៃមាត្រា ៨៨៨ (និយមន័យនៃប្រាតិភោគដោយអនុប្បទាន) នៃក្រមនេះ ហើយដែលអ្នកបង្កើតមានគម្រោងនឹងលក់ទៅជនដទៃ ក្នុងករណីដែលអ្នកបង្កើតដែលបន្តការកាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ នៅក្រោយពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានបានលក់វត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចយកសិទ្ធិប្រាតិភោគ ដោយអនុប្បទាននោះទៅតតាំងចំពោះតតិយជននោះបានឡើយ ទោះបីជាតតិយជននោះបំពេញ ឬ មិនបំពេញគ្រប់ល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងមាត្រា ១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ ក៏ដោយ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកដទៃដែលទទួលការបញ្ជាពីអ្នកបង្កើត បន្តការកាន់កាប់ដោយចំពោះនូវ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

វត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន នៅក្រោយពេលបង្កើតសិទ្ធិនោះ ហើយ អ្នកបង្កើតបានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ឬ បានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើវត្ថុនោះដើម្បីតតិយជន ។

មាត្រា ៨៩៥.- ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវធានានូវប្រាក់ដើម ការប្រាក់ ប្រាក់ជានាសង ក្នុងករណីមិនគោរពកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទានសោហ៊ុយដើម្បីថែរក្សាវត្ថុដែលជាកម្មវត្ថុ ព្រមទាំងសំណងនៃការខូចខាតដែលកើតឡើង ដោយសារការមិនអនុវត្តកាតព្វកិច្ច ឬវិការៈកំបាំងនៃវត្ថុដែលជាកម្មវត្ថុ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានកំណត់ផ្សេងក្នុងសកម្មភាពបង្កើតនោះ ។

មាត្រា ៨៩៦.- បញ្ញត្តិពិសេសក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានកាន់កាប់វត្ថុដែលជាកម្មវត្ថុ

បញ្ញត្តិនៃមាត្រា ៨២១ (អានុភាពនៃការឃាត់ទុក) មាត្រា ៨២៣ (ករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំក្នុងការរក្សាទុកនូវវត្ថុបញ្ចាំ) និងមាត្រា ៨២៤ (សិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានទទួលការបញ្ចាពីម្ចាស់សិទ្ធិនោះ កាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ ។

មាត្រា ៨៩៧.- ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន

១-បើម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានដែលកាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ បានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ឬ បានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើវត្ថុនោះដើម្បីតតិយជន ប្រសិនបើតតិយជននោះ បំពេញគ្រប់លក្ខខណ្ឌដែលបានកំណត់នៅក្នុងមាត្រា ១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ តតិយជននោះអាចយកសិទ្ធិរបស់ខ្លួនទៅតតាំងចំពោះអ្នកបង្កើតបាន ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះករណី

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ដែលអ្នកដទៃដែលទទួលការបញ្ជាពីម្ចាស់សិទ្ធិប្រាតិភោគ កាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ ហើយម្ចាស់សិទ្ធិនោះបានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ឬ បានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើវត្ថុនោះដើម្បីតតិយជន ។

ផ្នែកទី ៤

ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន

មាត្រា ៨៩៨.- ការចាត់ចែងប្តូរជាប្រាក់ ឬ អនុប្បទានជាស្ថាពរ

១-បើកាតព្វកិច្ចពុំត្រូវបានអនុវត្ត ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចប្តូរវត្ថុដែលជាកម្មវត្ថុនោះជាប្រាក់ ដោយផ្ទាល់ខ្លួន ឬ ធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុជាស្ថាពរបានដោយជូនដំណឹងទៅអ្នកបង្កើត ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានទទួលការបញ្ជាពីអ្នកបង្កើតនេះ កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចទាមទារឱ្យជននោះប្រគល់វត្ថុដែលជាកម្មវត្ថុនោះបាន ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើតម្លៃនៃវត្ថុដែលជាកម្មវត្ថុមានចំនួនលើសពីចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលត្រូវសង ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានត្រូវបង់ចំនួនទឹកប្រាក់ដែលលើសនោះទៅឱ្យអ្នកបង្កើត ដោយចាត់ជាប្រាក់ជម្រះ ។

មាត្រា ៨៩៩.- សិទ្ធិទទួលយកមកវិញរបស់អ្នកបង្កើត

ទោះបីជាពេលកំណត់ត្រូវសងកាតព្វកិច្ចបានកន្លងផុតក៏ដោយ ក៏អ្នកបង្កើតអាចទទួលយកមកវិញនូវវត្ថុដែលជាកម្មវត្ថុ ដោយផ្តល់នូវកាតព្វកិច្ចគ្រប់ចំនួន និង បង្ហាញអំពីការផ្តល់នោះទៅម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបាន នៅមុនពេលមានការផ្តល់ប្រាក់ជម្រះដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រា ៨៩៨(ការចាត់ចែងប្តូរជាប្រាក់ ឬ អនុប្បទានជាស្ថាពរ) ខាងលើនេះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីតម្លៃវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាននោះ មិនលើសពីចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែល

ត្រូវសង ក្រោយពេលដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន បានជូនដំណឹងអំពីចំនួនដែលមិនលើសនោះ ទៅឱ្យអ្នកបង្កើតហើយ ។

ជំពូកទី ៧

ការធានា

ផ្នែកទី ១

ការបង្កើតកិច្ចសន្យាធានា

មាត្រា ៩០០.- ការបង្កើតកិច្ចសន្យាធានា

១-កិច្ចសន្យាធានាត្រូវបង្កើតឡើង ដោយសារបុគ្គលដែលមានបំណងធ្វើជាអ្នកធានា បានសន្យាជាមួយនឹងម្ចាស់បំណុលថា ខ្លួននឹងអនុវត្តកាតព្វកិច្ចមួយផ្នែក ឬ ទាំងមូលជាមួយនឹងកូនបំណុលដែលមានកាតព្វកិច្ចចម្បង នៅក្នុងករណីដែលកូនបំណុលមានកាតព្វកិច្ចចម្បងនោះពុំអនុវត្តកាតព្វកិច្ចរបស់ខ្លួន ហើយម្ចាស់បំណុលបានយល់ព្រមអំពីការសន្យានោះ ។

២-ក្នុងកិច្ចសន្យាធានា ភាគីអាចធ្វើការសន្យាពិសេសដែលធានាការខូចខាត ដែលអ្នកធានាត្រូវទទួលបន្ទុកនូវកាតព្វកិច្ចធានាឯករាជ្យពីកាតព្វកិច្ចចម្បងបាន ។ ប៉ុន្តែ កាតព្វកិច្ចនៃការសន្យាពិសេសដែលធានាការខូចខាត អាចកើតបានលុះត្រាតែអ្នកដែលទទួលបន្ទុកកាតព្វកិច្ចនៃការសន្យាពិសេសដែលធានាការខូចខាតនោះ មានអាជីវកម្មរបស់ខ្លួនជាការធានាការខូចខាត ឬ ការធានា ។

៣-ក្នុងករណីដែលអ្នកដែលមានបំណងធ្វើជាអ្នកធានា មិនមែនជាអ្នកដែលមានអាជីវកម្មធានា ម្ចាស់បំណុលត្រូវផ្តល់នូវព័ត៌មានសំខាន់ៗស្តីពីការណ៍ដែលអ្នកនោះក្លាយជាអ្នកធានា ទៅឱ្យអ្នកដែលមានបំណងធ្វើជាអ្នកធានានោះ និង ត្រូវផ្តល់ឱកាសឱ្យអ្នកនោះគិតពិចារណាឱ្យបានហ្មត់ចត់ ។

៤-ក្នុងករណីដែលម្ចាស់បំណុលប្រព្រឹត្តផ្ទុយនឹងកថាខណ្ឌទី ៣ ខាងលើនេះ អ្នកធានាអាចលុបចោលនូវកិច្ចសន្យាធានានោះបាន ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

មាត្រា ៩០១.- ទម្រង់ចាំបាច់នៃកិច្ចសន្យាធានា

១-ការធានាដោយគ្មានលិខិតជាលាយល័ក្ខណ៍អក្សរ អាចដកវិញនៅពេលណាក៏បាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកធានាបានចាប់ផ្តើមអនុវត្តកាតព្វកិច្ចធានានោះដោយស្ម័គ្រចិត្ត ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាដែរ ចំពោះករណីដែលចំនួនទឹកប្រាក់នៃកាតព្វកិច្ចធានា មិនត្រូវបានសរសេរជាអក្សរដោយផ្ទាល់ដៃរបស់អ្នកធានាក្នុងការធានាកាតព្វកិច្ចដែលមានគោលបំណងសងជាប្រាក់ ។

៣-លិខិតជាលាយល័ក្ខណ៍អក្សរនៃការធានា ត្រូវបញ្ជាក់ឱ្យច្បាស់លាស់អំពីខ្លឹមសារនៃកាតព្វកិច្ចធានា ។

មាត្រា ៩០២.- ការធានាបំណុលអណ្តែត

១-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៩០១ (ទម្រង់ចាំបាច់នៃកិច្ចសន្យាធានា) ខាងលើនេះក៏ដោយ ក៏កិច្ចសន្យាធានាបំណុលអណ្តែតដែលធានាកាតព្វកិច្ចមិនកំណត់ដែលអាចកើតមានឡើងនៅពេលអនាគត ដោយសារទំនាក់ទំនងគតិយុត្តជានិរន្តរ៍ណាមួយនោះនឹងមានសុពលភាព លុះត្រាតែបញ្ជាក់ច្បាស់នូវទំនាក់ទំនងគតិយុត្តជានិរន្តរ៍ដែលជាមូលដ្ឋាននៃការបង្កើតកាតព្វកិច្ចចម្បង ។

២-បើកិច្ចសន្យាធានាបំណុលអណ្តែត មិនបានកំណត់អំឡុងពេលនៃការធានាទេ អ្នកធានាបំណុលអណ្តែតអាចរំលាយកិច្ចសន្យាធានាបំណុលអណ្តែតនោះឆ្ពោះទៅអនាគតបានក្រោយពីហួសអំឡុងពេលសមរម្យចាប់តាំងពីពេលដែលបានបង្កើតកិច្ចសន្យានោះ ។

៣-ចំពោះកិច្ចសន្យាធានាបំណុលអណ្តែត នៅក្នុងករណីដែលស្ថានភាពនៃកិច្ចការជំនួញ ឬ ទ្រព្យសម្បត្តិរបស់កូនបំណុល ដែលមានកាតព្វកិច្ចចម្បងធ្លាក់អន់ថយយ៉ាងខ្លាំង បើប្រៀបធៀបទៅនឹងពេលបង្កើតកិច្ចសន្យាធានាបំណុលអណ្តែតនោះ អ្នកធានាបំណុលអណ្តែត អាចរំលាយកិច្ចសន្យាធានាបំណុលអណ្តែតនោះឆ្ពោះទៅអនាគតដោយភ្លាមៗបាន ។

៤-ចំពោះកិច្ចសន្យាធានាបំណុលអណ្តែត បើអ្នកធានាបំណុលអណ្តែតបានទទួលមរណភាព អ្នកស្នងមរតកទទួលតែកាតព្វកិច្ចធានាបំណុលអណ្តែត ចំពោះកាតព្វកិច្ចចម្បងដែលបានកើតឡើងមក

ត្រឹមពេលអ្នកធានានោះទទួលមរណភាពទេ ទើបត្រូវបន្តដោយសន្តតិកម្ម ។

ផ្នែកទី ២

អានុភាពនៃការធានា

មាត្រា ៩០៣.- ទំហំនៃកាតព្វកិច្ចធានា

១-កាតព្វកិច្ចធានាត្រូវរាប់បញ្ចូល ទាំងការប្រាក់ ប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា និង សំណងការខូចខាត ដែលទាក់ទងនឹងកាតព្វកិច្ចចម្បង និង អ្វីដែលកើតឡើងបន្ទាប់បន្សំពីកាតព្វកិច្ចចម្បងនោះ ។

២-កិច្ចសន្យាធានា អាចកំណត់នូវចំនួនទឹកប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា ឬ ប្រាក់សំណងការខូចខាត ចំពោះការមិនអនុវត្តកាតព្វកិច្ចធានាបាន ។

មាត្រា ៩០៤.- លក្ខណៈនៃការធានា

១-កិច្ចសន្យាធានាមិនអាចកើតឡើងបានឡើយ នៅក្នុងករណីដែលគ្មានកាតព្វកិច្ចចម្បងទេ ។ ប៉ុន្តែ កិច្ចសន្យាធានាអាចកើតឡើងបាន ចំពោះកាតព្វកិច្ចដែលនឹងកើតមានឡើងនៅពេលអនាគត ឬ កាតព្វកិច្ចដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌ ។

២-ក្នុងករណីដែលបន្ទុករបស់អ្នកធានាធ្ងន់ជាងកាតព្វកិច្ចចម្បង ដោយគិតទាំងកម្មវត្ថុ ឬ ល័ក្ខខ័ណ្ឌ នោះត្រូវបន្ថយបន្ទុករបស់អ្នកធានាត្រឹមកម្រិតនៃកាតព្វកិច្ចចម្បង ។

៣-ក្នុងករណីដែលកាតព្វកិច្ចចម្បងរលត់ កាតព្វកិច្ចធានាក៏ត្រូវរលត់ផងដែរ ។

៤-ការផ្អាកអាជ្ញាយុកាលដោយការទាមទារចំពោះកូនបំណុលដែលមានកាតព្វកិច្ចចម្បង ឬ ដោយមូលហេតុផ្សេងៗទៀត ក៏មានអានុភាពចំពោះអ្នកធានាផងដែរ ។

៥-ក្នុងករណីដែលសិទ្ធិលើបំណុលចំពោះកូនបំណុលដែលមានកាតព្វកិច្ចចម្បង ត្រូវបានធ្វើអនុប្បទាន នោះសិទ្ធិលើបំណុលចំពោះអ្នកធានាក៏ត្រូវចាត់ទុកថាបានធ្វើអនុប្បទានផងដែរ លើកលែងតែមានការសន្យាពិសេស ។

មាត្រា ៩០៥.- សិទ្ធិរបស់អ្នកធានា

១-អ្នកធានាអាចលើកឡើងអំពីការរលត់កាតព្វកិច្ចចម្បង ដោយអាជ្ញាយុកាលបាន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

២-បើកូនបំណុលដែលមានកាតព្វកិច្ចចម្បង បានបោះបង់ចោលផលប្រយោជន៍នៃអាជ្ញាយុកាល អានុភាពនេះពុំមានចំពោះអ្នកធានាឡើយ ។

៣-អ្នកធានាអាចលើកឡើងនូវសិទ្ធិតវ៉ារបស់កូនបំណុលដែលមានកាតព្វកិច្ចចម្បងមកប្រើបាន ។

៤-បើកូនបំណុលដែលមានកាតព្វកិច្ចចម្បង មានសិទ្ធិលុបចោល ឬ សិទ្ធិរំលាយ នោះអ្នកធានាអាចបដិសេធនូវការអនុវត្តកាតព្វកិច្ចធានាបាន ។

៥-បើកូនបំណុលដែលមានកាតព្វកិច្ចចម្បង ស្ថិតនៅក្នុងឋានៈដែលខ្លួនអាចទូទាត់កាតព្វកិច្ចរបស់ខ្លួន ដោយយកសិទ្ធិលើបំណុល ចំពោះម្ចាស់បំណុលបាននោះអ្នកធានាអាចបដិសេធនូវការអនុវត្តកាតព្វកិច្ចធានាបាន ត្រឹមតែកម្រិតដែលកាតព្វកិច្ចចម្បងត្រូវរលត់ដោយសារការទូទាត់នោះ ។

មាត្រា ៩០៦.- ការធានាចំពោះកាតព្វកិច្ចដែលអាចលុបចោលបាន

ក្នុងករណីដែលអ្នកធានាដែលមានអាជីវកម្មរបស់ខ្លួន ជាការធានាការខូចខាត ឬ ការធានា បានធានាកាតព្វកិច្ចដែលអាចលុបចោលបាន ដោយបានដឹងអំពីមូលហេតុនៃការលុបចោល អ្នកធានានោះត្រូវបានសន្មតថា បានទទួលបន្ទុកនូវកាតព្វកិច្ចឯករាជ្យមួយផ្សេងដែលមានគោលបំណងដូចគ្នានឹងកាតព្វកិច្ចចម្បង ។

មាត្រា ៩០៧.- លក្ខណសម្បត្តិរបស់អ្នកធានា

១-ក្នុងករណីដែលកូនបំណុលទទួលបន្ទុកនូវករណីយកិច្ចត្រូវរកអ្នកធានា អ្នកធានានោះត្រូវតែជាសមត្ថជន និង ត្រូវមានសាធនភាពដើម្បីសងបំណុល ។

២-ក្នុងករណីដែលអ្នកធានាបានបាត់បង់នូវលក្ខណសម្បត្តិ ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលរកអ្នកធានាផ្សេងទៀត ដែលមានលក្ខណសម្បត្តិ ដូចបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ មកជំនួសបាន ។

៣-ក្នុងករណីដែលកូនបំណុលមិនអាចរកអ្នកធានាដែលមានលក្ខណសម្បត្តិ ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបានទេ ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលដាក់ប្រាតិភោគផ្សេងទៀតបាន ។

ROYAUME DU CAMBODGE
LE MINISTERE DU PALAIS ROYAL

៤-បញ្ញត្តិនៃមាត្រានេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលម្ចាស់បំណុលបាន ជ្រើសតាំងអ្នកធានា ។

មាត្រា ៩០៨.- អត្ថន័យនៃការធានាដោយសាមគ្គីភាព និង គោលការណ៍នៃការធានាដោយសាមគ្គីភាព

១-បុគ្គលដែលទទួលបន្ទុកកាតព្វកិច្ចត្រូវធានាដោយសាមគ្គីភាពជាមួយនឹងកូនបំណុល ដែលមានកាតព្វកិច្ចចម្បង មិនអាចទាមទារឱ្យម្ចាស់បំណុលទាមទារពីកូនបំណុល ដែលមានកាតព្វកិច្ចចម្បងជាមុនសិន ឬ មិនអាចរួចផុតពីការអនុវត្តចំពោះខ្លួនផ្ទាល់ ដោយសំអាងថាកូនបំណុលមានសាធនភាពគ្រប់គ្រាន់ដើម្បីសង និង អាចអនុវត្តចំពោះកូនបំណុលនោះដោយងាយស្រួលបានឡើយ ។

២-អ្នកធានាមានកាតព្វកិច្ចត្រូវធានាដោយសាមគ្គីភាពជាមួយនឹងកូនបំណុល លើកលែងតែមានការព្រមព្រៀងពិសេស ។

មាត្រា ៩០៩.- អានុភាពនៃហេតុដែលកើតឡើងចំពោះអ្នកធានា

ហេតុទាំងឡាយដែលកើតឡើងចំពោះអ្នកធានា ពុំមានអានុភាពចំពោះកូនបំណុលដែលមានកាតព្វកិច្ចចម្បងឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះការទាមទារ ឬ ហេតុផ្សេងនៃការផ្អាកអាជ្ញាយុកាល ចំពោះអ្នកធានាដែលទទួលអាណត្តិពីកូនបំណុលដែលមានកាតព្វកិច្ចចម្បង ។

មាត្រា ៩១០.- ការធានារួម

១-ក្នុងកិច្ចសន្យាដែលមានអ្នកធានាច្រើននាក់ អ្នកធានាម្នាក់ៗមានករណីយកិច្ចចំពោះចំនួនទឹកប្រាក់ទាំងអស់នៃកាតព្វកិច្ចចម្បង ។

២-ភាគនៃបន្ទុករបស់អ្នកធានារួមដែលគ្មានការសន្យាពិសេសអំពីការបែងចែកបន្ទុក ត្រូវបានសន្មតថាស្មើគ្នា ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ផ្នែកទី ៣

សិទ្ធិទាមទារសំណង

មាត្រា ៩៦១.- សិទ្ធិទាមទារសំណងរបស់អ្នកធានាដែលទទួលអាណត្តិ

១-ក្នុងករណីដែលអ្នកធានាបានធានាដោយទទួលអាណត្តិពីកូនបំណុលដែលមានកាតព្វកិច្ចចម្បង ប្រសិនបើអ្នកធានាបានធ្វើឱ្យរលត់នូវកាតព្វកិច្ច ដោយបានសង ឬ បានចេញចំណាយផ្សេងទៀតរបស់ខ្លួន ជំនួសកូនបំណុលដែលមានកាតព្វកិច្ចចម្បង នោះអ្នកធានាត្រូវទទួលសិទ្ធិទាមទារឱ្យកូនបំណុលដែលមានកាតព្វកិច្ចចម្បងសងសំណងមកខ្លួនវិញ ។

២-អ្នកធានាដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចទាមទារសំណងនូវចំនួនទឹកប្រាក់ដែលខ្លួនបានចេញចំណាយ និង ចំនួនការប្រាក់លើប្រាក់ចំណាយដែលខ្លួនបានចេញ ដោយគិតពីថ្ងៃដែលខ្លួនបានចេញ និង ចំនួនប្រាក់នៃការខូចខាតបាន ។

៣-អ្នកធានាដែលបានទទួលអាណត្តិពីកូនបំណុលដែលមានកាតព្វកិច្ចចម្បង អាចទាមទារសំណងជាមុនបាន ក្នុងករណីដូចខាងក្រោមនេះ :

ក-អ្នកធានាបានទទួលសាលក្រម ឬ សាលដីកាដែលបង្គាប់ឱ្យអ្នកធានាសងទៅម្ចាស់បំណុល ដោយគ្មានកំហុស ហើយសាលក្រម ឬ សាលដីកានោះបានចូលជាស្ថាពរ ។

ខ-កូនបំណុលដែលមានកាតព្វកិច្ចចម្បងបានក្ស័យធន ហើយម្ចាស់បំណុលពុំបានចូលរួមក្នុងការចែកចំណែក ។

គ-កាតព្វកិច្ចចម្បងដល់ពេលកំណត់ត្រូវសង ។

ឃ-ពេលកំណត់ត្រូវអនុវត្តកាតព្វកិច្ចចម្បងនោះមិនច្បាស់លាស់ ហើយមិនអាចកំណត់បានអំពីរយៈពេលដែលវែងជាងគេ និង អំឡុងពេល ៥ (ប្រាំ) ឆ្នាំ បានកន្លងហួសគិតពីថ្ងៃដែលបានធ្វើកិច្ចសន្យាធានា ។

៤-ក្នុងករណីដែលម្ចាស់បំណុលមិនទាន់បានទទួលសំណងទាំងអស់នៅឡើយ នោះកូនបំណុលដែលមានកាតព្វកិច្ចចម្បង ដែលទទួលការទាមទារសំណងពីអ្នកធានាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចទាមទារឱ្យអ្នកធានាដាក់ប្រាតិភោគ ឬ អាចទាមទារឱ្យខ្លួនរួចផុតពីកាតព្វកិច្ចបាន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

៥-ក្នុងករណីដែលបានកំណត់នៅកថាខណ្ឌទី ៤ ខាងលើនេះ កូនបំណុលដែលមានកាតព្វកិច្ចចម្បង អាចរួចផុតពីការទាមទារសំណងបាន ដោយតម្កល់ ឬ ដាក់ប្រាតិភោគទៅឱ្យអ្នកធានា ឬ ធ្វើឱ្យអ្នកធានារួចផុតពីកាតព្វកិច្ច ។

មាត្រា ៩១២.- សិទ្ធិទាមទារសំណងរបស់អ្នកធានាដោយគ្មានអាណត្តិ

ក្នុងករណីដែលការធានាពុំមានអាណត្តិពីកូនបំណុលដែលមានកាតព្វកិច្ចចម្បងទេ តែអ្នកធានានោះបានធ្វើឱ្យកូនបំណុលដែលមានកាតព្វកិច្ចចម្បងរួចផុតពីកាតព្វកិច្ចនោះ ដោយបានសងជំនួសកូនបំណុល ឬ ចេញចំណាយផ្សេងទៀតរបស់ខ្លួន កូនបំណុលនោះត្រូវសងតាមការទាមទារសំណង ត្រឹមតែកម្រិតនៃផលប្រយោជន៍ដែលខ្លួនបានទទួល ។ ប៉ុន្តែ ប្រសិនបើការធានានេះត្រូវបានធ្វើឡើងដោយផ្ទុយពីឆន្ទៈរបស់កូនបំណុលដែលមានកាតព្វកិច្ចចម្បង កូនបំណុលគ្រាន់តែត្រូវសង តាមការទាមទារសំណងត្រឹមតែកម្រិតនៃផលប្រយោជន៍ជាក់ស្តែងដែលនៅតែមានប៉ុណ្ណោះ ។

មាត្រា ៩១៣.- លក្ខខណ្ឌនៃការទាមទារសំណង

១-ក្នុងករណីដែលអ្នកធានាបានរួចផុតពីកាតព្វកិច្ចដោយបានសងជំនួសកូនបំណុល ឬ ចេញចំណាយផ្សេងទៀតរបស់ខ្លួន ដោយពុំបានឱ្យដំណឹងទៅកូនបំណុលដែលមានកាតព្វកិច្ចចម្បងអំពីការណ៍ដែលខ្លួនបានទទួលការទាមទារពីម្ចាស់បំណុលទេ ហើយប្រសិនបើកូនបំណុលដែលមានកាតព្វកិច្ចចម្បង មានហេតុណាមួយដែលអាចតតាំងជាមួយនឹងម្ចាស់បំណុល នោះកូនបំណុលដែលមានកាតព្វកិច្ចចម្បង អាចយកហេតុនោះទៅតតាំងនឹងការទាមទាររបស់អ្នកធានាបាន ។ ប៉ុន្តែ បើហេតុនោះជាការទូទាត់ អ្នកធានាអាចទាមទារឱ្យម្ចាស់បំណុលអនុវត្តកាតព្វកិច្ចដែលនឹងត្រូវរលត់ ដោយសារការទូទាត់នេះបាន ។

២-ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចចម្បងបានសងទៅម្ចាស់បំណុល ឬ រួចផុតពីកាតព្វកិច្ចដោយចេញចំណាយផ្សេងទៀតដោយសុចរិត ដោយហេតុថាអ្នកធានាធ្វេសប្រហែសពុំបានឱ្យដំណឹងទៅកូនបំណុលថា ខ្លួនបានរួចផុតពីកាតព្វកិច្ចដោយចេញចំណាយរបស់ខ្លួនផ្ទាល់ទេ កូនបំណុលដែលមានកាតព្វកិច្ចចម្បងអាចចាត់ទុកថា សំណងរបស់ខ្លួន ឬ ការរួចផុតពីកាតព្វកិច្ចនោះមានសុពលភាពបាន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

មាត្រា ៩១៤.- សិទ្ធិទាមទារសំណងរបស់អ្នកធានាចំពោះកូនបំណុលម្នាក់ក្នុងចំណោមកូនបំណុលច្រើន

អ្នកដែលបានធានាកូនបំណុលតែម្នាក់ក្នុងចំណោមកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាព ឬ កាតព្វកិច្ចអវិភាគីយ៍ អាចទាមទារសំណងពីកូនបំណុលផ្សេងទៀតបានត្រឹមតែចំណែកជាបន្ទុករបស់កូនបំណុលផ្សេងនោះប៉ុណ្ណោះ ។

មាត្រា ៩១៥.- សិទ្ធិទាមទារសំណងរបស់អ្នកធានារួម

១-ក្នុងករណីដែលអ្នកធានារួមម្នាក់ក្នុងចំណោមអ្នកធានារួម បានរួចផុតពីកាតព្វកិច្ច ហើយធ្វើឱ្យអ្នកធានារួមផ្សេងទៀត បានរួចផុតពីកាតព្វកិច្ចដោយបានសង ឬ បានចេញចំណាយផ្សេងទៀតរបស់ខ្លួន អ្នកធានានោះអាចទាមទារឱ្យអ្នកធានារួមផ្សេងទៀតសងសំណងតាមចំណែកជាបន្ទុករៀងៗខ្លួន មកខ្លួនវិញបាន ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកធានានោះ អាចទាមទារឱ្យអ្នកធានារួមឯទៀតៗ សងនូវប្រាក់ដែលខ្លួនបានចេញចំណាយការប្រាក់ និង ការខូចខាតបាន ។

៣-បញ្ញត្តិនៃមាត្រា ៩១២ (សិទ្ធិទាមទារសំណងរបស់អ្នកធានាដោយគ្មានអាណត្តិ) មាត្រា ៩១៣ (ល័ក្ខខ័ណ្ឌនៃការទាមទារសំណង) និងមាត្រា ៩១៤ (សិទ្ធិទាមទារសំណងរបស់អ្នកធានាចំពោះកូនបំណុលម្នាក់ក្នុងចំណោមកូនបំណុលច្រើន) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលការធានារួមមានភ្ជាប់ជាមួយនឹងការសន្យាពិសេសអំពីការបែងចែកបន្ទុក ហើយមានអ្នកធានារួមណាម្នាក់បានរួចផុតពីកាតព្វកិច្ច ហើយធ្វើឱ្យអ្នកធានារួមផ្សេងទៀតបានរួចផុតពីកាតព្វកិច្ច ដោយបានសង ឬ បានចេញចំណាយផ្សេងទៀតលើសពីចំណែកជាបន្ទុករបស់ខ្លួន ។

ផ្នែកទី ៤

ឧបាទេសកម្ម

មាត្រា ៩១៦.- ឧបាទេសកម្មដោយការសង

អ្នកធានាដែលបានរួចផុតពីកាតព្វកិច្ចចម្បង ដោយបានសង ឬ ចេញចំណាយផ្សេង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ទៀតរបស់ខ្លួន ត្រូវទទួលពីម្ចាស់បំណុលនូវសិទ្ធិលើបំណុលដែលជាកម្មវត្ថុនៃការធានា ហើយអាចប្រើសិទ្ធិប្រាតិភោគដែលបានធានាសិទ្ធិលើបំណុលនោះ ជំនួសម្ចាស់បំណុលបាន ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកធានាដែលបានរួចផុតពីកាតព្វកិច្ចមួយភាគ អាចប្រើសិទ្ធិជាមួយម្ចាស់បំណុលតាមសមាមាត្រ និង ចំនួនប្រាក់ដែលខ្លួនបានរួចផុតនោះ ។ ក្នុងករណីនេះ មានតែម្ចាស់បំណុលប៉ុណ្ណោះដែលអាចប្រើសិទ្ធិរំលាយបាន ។ ប៉ុន្តែ ក្នុងករណីនេះ ម្ចាស់បំណុលត្រូវសងទៅវិញនូវចំនួនប្រាក់ ដែលឧបាទេសិកបានរួចផុតពីកាតព្វកិច្ច និង ការប្រាក់ទៅឧបាទេសិកនោះ ។

មាត្រា ៩១៧.- ករណីយកិច្ចប្រគល់លិខិតបញ្ជាក់សិទ្ធិលើបំណុល

១-ម្ចាស់បំណុលដែលបានទទួលការជម្រះសិទ្ធិលើបំណុលទាំងអស់ ដោយសារអ្នកធានាបានសង ឬ បានចេញចំណាយផ្សេងទៀត ត្រូវប្រគល់លិខិតបញ្ជាក់សិទ្ធិលើបំណុល និង វត្ថុប្រាតិភោគដែលនៅក្រោមការកាន់កាប់របស់ខ្លួន ទៅឱ្យអ្នកធានាដែលបានសង ឬ បានចេញចំណាយផ្សេងទៀតនោះ ។

២-ម្ចាស់បំណុលដែលបានទទួលការជម្រះសិទ្ធិលើបំណុលតែមួយភាគ ដោយសារអ្នកធានាបានសង ឬ បានចេញចំណាយផ្សេងទៀត ត្រូវកត់ត្រាអំពីឧបាទេសកម្មនោះលើលិខិតបញ្ជាក់សិទ្ធិលើបំណុល ហើយត្រូវឱ្យអ្នកធានានោះត្រួតពិនិត្យលើការថែរក្សាវត្ថុប្រាតិភោគដែលនៅក្រោមការកាន់កាប់របស់ខ្លួន ។

មាត្រា ៩១៨.- ករណីយកិច្ចថែរក្សាប្រាតិភោគ

ម្ចាស់បំណុលដែលបានទទួលការជម្រះសិទ្ធិលើបំណុល ដោយសារអ្នកធានាបានសង ឬ បានចេញចំណាយផ្សេងទៀត មានករណីយកិច្ចត្រូវថែរក្សាប្រាតិភោគ សម្រាប់អ្នកធានាដែលបានសង ឬ បានចេញចំណាយផ្សេងទៀតនោះ ។

មាត្រា ៩១៩.- លំដាប់នៃឧបាទេសកម្ម

១-អ្នកធានាមិនអាចល្បងម្ចាស់បំណុលដោយឧបាទេសកម្ម ចំពោះតតិយជនដែលបានផ្ទេរកម្មសិទ្ធិអចលនវត្ថុដែលជាវត្ថុប្រាតិភោគ បានឡើយ ប្រសិនបើខ្លួនមិនបានចុះបញ្ជីក្រោយ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ពីបានសង ឬ ចេញចំណាយផ្សេងទៀត ។

២-រវាងអ្នកធានាដោយបុគ្គល និង អ្នកធានាដោយវត្ថុ ត្រូវស្នងដោយឧបាទេសកម្ម ដោយគិតទៅតាមចំនួនអ្នកទាំងនោះ ។

មាត្រា ៩២០.- ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្ដីពីឧបាទេសកម្មដោយការសង

ក្រៅពីបញ្ញត្តិនៃផ្នែកទី ៤(ឧបាទេសកម្ម) នេះ បញ្ញត្តិនៃកថាភាគទី ៤(ឧបាទេសកម្មដោយការសង)ផ្នែកទី ១ ជំពូកទី ៧ នៃគន្ថីទី ៤ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះឧបាទេសកម្មដោយការសង ឬ ចេញចំណាយផ្សេងទៀតរបស់អ្នកធានា ។

ជំពូកទី ៨

ភាគពហុកិច្ចដោយសាមគ្គីភាព

ផ្នែកទី ១

ការបង្កើតភាគពហុកិច្ចដោយសាមគ្គីភាព

មាត្រា ៩២១.- អត្ថន័យនៃភាគពហុកិច្ចដោយសាមគ្គីភាព

១-ក្នុងករណីដែលបុគ្គលច្រើននាក់ទទួលបន្ទុកនូវកាតព្វកិច្ចសាមគ្គីភាព ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលណាម្នាក់ អនុវត្តកាតព្វកិច្ចទាំងអស់ ឬ មួយភាគ ឬ ឱ្យកូនបំណុលទាំងអស់អនុវត្តកាតព្វកិច្ចទាំងអស់ ឬ មួយភាគ ដោយព្រមគ្នា ឬ ដោយបន្តបន្ទាប់ ។

២-ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចទាំងអស់ ឬ កូនបំណុលណាម្នាក់ត្រូវបានប្រកាសក្ស័យធន ម្ចាស់បំណុលអាចចូលរួម ក្នុងការចែកចំណែកនៅក្នុងនីតិវិធីក្ស័យធនរបស់កូនបំណុលនីមួយៗ ចំពោះចំនួនប្រាក់ទាំងអស់នៃសិទ្ធិលើបំណុលរបស់ខ្លួន ។

មាត្រា ៩២២.- ការបង្កើតភាគពហុកិច្ចដោយសាមគ្គីភាព

១-ក្រៅពីករណីដែលមានបញ្ញត្តិនៅក្នុងច្បាប់ កាតព្វកិច្ចដោយសាមគ្គីភាពត្រូវបានបង្កើតឡើង ដោយការព្រមព្រៀង ដោយជាក់លាក់ ឬ ដោយតុណ្ហីភាព រវាងម្ចាស់បំណុល និង កូនបំណុលច្រើននាក់ដែលឆន្ទៈសាមគ្គីភាពរួមគ្នាទៅវិញទៅមក ត្រូវបានទទួលស្គាល់ ។

២-ការព្រមព្រៀងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចធ្វើឡើងរវាង

ម្ចាស់បំណុល និង កូនបំណុលនីមួយៗដោយព្រមគ្នា ឬ ដោយបន្តបន្ទាប់ ។

៣-ម្ចាស់បំណុលអាចលើកលែងសាមគ្គីភាព ចំពោះកូនបំណុលណាមួយ ដោយមិនចាំបាច់មានការយល់ព្រមពីកូនបំណុលផ្សេងទៀតបាន ។

៤-ក្រោយពេលលើកលែងសាមគ្គីភាព កូនបំណុលដែលបានទទួលការលើកលែង ត្រូវទទួលបន្ទុកនូវកាតព្វកិច្ច ត្រឹមតែចំនួនប្រាក់ដែលស្មើនឹងបន្ទុកដែលខ្លួនធ្លាប់មានមុនពេលលើកលែង ។

៥-ភាគនៃបន្ទុករបស់កូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពនីមួយៗ ត្រូវបានសន្មតថាស្មើគ្នា ។

មាត្រា ៩២៣.- មោឃភាព និង ការលុបចោល ចំពោះកូនបំណុល

ទោះបីជាមានមូលហេតុនៃមោឃភាព ឬ ការលុបចោលសកម្មភាព ចំពោះកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ក៏ដោយ ក៏ការណ៍នេះមិនមានឥទ្ធិពលដល់អានុភាពនៃកាតព្វកិច្ចរបស់កូនបំណុលផ្សេងទៀតឡើយ ។

ផ្នែកទី ២
អានុភាពនៃហេតុដែលកើតឡើងចំពោះកូនបំណុលដែលមានកាតព្វកិច្ច ដោយសាមគ្គីភាពណាម្នាក់

មាត្រា ៩២៤.- អានុភាពដាច់ខាតនៃការទាមទារ និង ហេតុដែលផ្អាកអាជ្ញាយុកាលផ្សេងទៀត

ការទាមទារឱ្យកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់អនុវត្តនិងហេតុដែលផ្អាកអាជ្ញាយុកាលផ្សេងទៀត ដែលកើតឡើងចំពោះកូនបំណុលនោះ ត្រូវមានអានុភាពចំពោះកូនបំណុលផ្សេងទៀតផងដែរ ។

មាត្រា ៩២៥.- អានុភាពដាច់ខាតនៃការសង ជាអាទិ៍

ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ បានសង ឬ សងជំនួស ឬ តម្កល់ អានុភាពនៃការរំលត់កាតព្វកិច្ចដែលបានកើតឡើង ដោយការណ៍នោះ ត្រូវមានចំពោះកូនបំណុលផ្សេងទៀតផងដែរ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា ៥២៦.- អានុភាពដាច់ខាតនៃការទូទាត់

១-ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ មានសិទ្ធិលើបំណុលចំពោះម្ចាស់បំណុល ហើយកូនបំណុលនោះបានលើកឡើងនូវការទូទាត់សិទ្ធិលើបំណុលត្រូវរលត់ សម្រាប់ផលប្រយោជន៍របស់កូនបំណុលទាំងអស់ ។

២-នៅក្នុងពេលដែលកូនបំណុលដែលមានសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនទាន់លើកឡើងនូវការទូទាត់ កូនបំណុលផ្សេងទៀត អាចបដិសេធការសង ចំពោះបន្ទុករបស់ខ្លួនបាន ។

មាត្រា ៥២៧.- អានុភាពដាច់ខាតនៃនវកម្ម

ក្នុងករណីដែលនវកម្មត្រូវបានធ្វើឡើង រវាងកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ និង ម្ចាស់បំណុល សិទ្ធិលើបំណុលត្រូវរលត់សម្រាប់ផលប្រយោជន៍របស់កូនបំណុលទាំងអស់ ។

មាត្រា ៥២៨.- អានុភាពដាច់ខាតនៃល្បាយកុលភាព

ក្នុងករណីដែលល្បាយកុលភាពបានកើតឡើង រវាងកូនបំណុលដែលមានកាតព្វកិច្ច ដោយសាមគ្គីភាពណាម្នាក់ និង ម្ចាស់បំណុល កូនបំណុលនោះត្រូវបានចាត់ទុកថាបានសង ។

មាត្រា ៥២៩.- អានុភាពដាច់ខាតនៃការលើកលែង

១-ការលើកលែងកាតព្វកិច្ចទាំងអស់ដែលបានធ្វើឡើង ចំពោះកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ ត្រូវមានអានុភាពចំពោះតែបន្ទុករបស់កូនបំណុលនោះ សម្រាប់ផលប្រយោជន៍របស់កូនបំណុលផ្សេងទៀត ។

២-ក្នុងករណីដែលការលើកលែងបានធ្វើឡើងចំពោះតែកាតព្វកិច្ចមួយភាគ ចំពោះកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ អានុភាពនៃការលើកលែង ចំពោះកូនបំណុលផ្សេងទៀត ត្រូវកើតឡើងតាមសមាមាត្រនៃចំនួនប្រាក់ ក្នុងករណីដែលមានការលើកលែងកាតព្វកិច្ចទាំងអស់ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា ៩៣០.- អានុភាពដាច់ខាតនៃអាជ្ញាយុកាល

១-ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់បានលើកឡើងនូវអាជ្ញាយុកាលដែលត្រូវបានសម្រេចចំពោះខ្លួន កូនបំណុលផ្សេងទៀតក៏ត្រូវរួចផុតពីកាតព្វកិច្ច ត្រឹមបន្ទុករបស់កូនបំណុលដែលបានលើកឡើងនូវអាជ្ញាយុកាលនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ នៅក្នុងពេលដែលអាជ្ញាយុកាលត្រូវបានសម្រេច តែមិនទាន់ត្រូវបានលើកឡើង កូនបំណុលផ្សេងទៀត អាចលើកឡើងនូវអាជ្ញាយុកាលនោះ ចំពោះបន្ទុករបស់កូនបំណុលដែលអាចលើកឡើងនូវអាជ្ញាយុកាលនោះ ។

មាត្រា ៩៣១.- គោលការណ៍នៃអានុភាពមិនដាច់ខាត

ហេតុដែលបានកើតឡើងចំពោះកូនបំណុល ដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ មិនត្រូវមានអានុភាពចំពោះកូនបំណុលផ្សេងទៀតឡើយ លើកលែងតែហេតុដែលបានកំណត់ពីមាត្រា ៩២៤ (អានុភាពដាច់ខាតនៃការទាមទារ និង ហេតុដែលផ្អាកអាជ្ញាយុកាលផ្សេងទៀត) ដល់មាត្រា ៩៣០ (អានុភាពដាច់ខាតនៃអាជ្ញាយុកាល) ខាងលើនេះ ។

ផ្នែកទី ៣

ការទាមទារសំណង

មាត្រា ៩៣២.- សិទ្ធិទាមទារសំណងរបស់កូនបំណុលដែលបានសង

១-ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់បានរួចផុតពីកាតព្វកិច្ច ដោយបានសង ឬ បានចេញចំណាយផ្សេងទៀតរបស់ខ្លួន ហើយធ្វើឱ្យកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពផ្សេងទៀតរួចផុតពីកាតព្វកិច្ច កូនបំណុលនោះត្រូវទទួលសិទ្ធិទាមទារសំណងពីកូនបំណុលផ្សេងទៀត ចំពោះបន្ទុករៀងៗខ្លួន ។ ក្នុងករណីដែលការសង ឬ ចំណាយផ្សេងទៀតរបស់កូនបំណុលដែលមាន កាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់មានចំពោះតែកាតព្វកិច្ចមួយភាគ ហើយកូនបំណុលនោះ និង កូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពផ្សេងទៀត បានទទួលការរួចផុតពីកាតព្វកិច្ច តាមកម្រិតនៃភាគនោះ កូនបំណុល

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

នោះអាចទាមទារសំណងតាមសមាមាត្រនៃបន្ទុករបស់កូនបំណុលផ្សេងទៀតបាន ។

២-ការទាមទារសំណងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចធ្វើបាន ដោយរាប់បញ្ចូលការប្រាក់ដែលច្បាប់បានកំណត់ ដោយគិតពីថ្ងៃរួចផុតពីកាតព្វកិច្ច ដោយបានសង ឬ បានចេញចំណាយផ្សេងទៀតរបស់ខ្លួន និង សោហ៊ុយឬការខូចខាតផ្សេងទៀតដែលមិនអាចជៀសវាងបាន ។

មាត្រា ៩៣៣.- ការជូនដំណឹងដែលជាល័ក្ខខ័ណ្ឌដើម្បីទាមទារសំណង

១-ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់បានរួចផុតពីកាតព្វកិច្ច ដោយបានសង ឬ បានចេញចំណាយផ្សេងទៀតរបស់ខ្លួន ហើយបានធ្វើឱ្យកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពផ្សេងទៀតរួចផុតពីកាតព្វកិច្ច ដោយពុំបានជូនដំណឹងទៅឱ្យកូនបំណុលផ្សេងទៀតថា ខ្លួនបានទទួលការទាមទារពីម្ចាស់បំណុល បើកូនបំណុលផ្សេងទៀតណាមួយ មានហេតុដែលអាចតតាំងចំពោះម្ចាស់បំណុល កូនបំណុលនោះអាចយកហេតុនេះមកតតាំងចំពោះការទាមទារសំណងពីកូនបំណុលដែលបានទទួលការរួចផុត ដោយបានសង ឬ ចេញចំណាយបាន ។ ប៉ុន្តែ បើហេតុដែលអាច តតាំងជាការទូទាត់កូនបំណុលដែលត្រូវបានតតាំង អាចទាមទារឱ្យម្ចាស់បំណុលអនុវត្តកាតព្វកិច្ចដែលនឹងត្រូវរលត់ ដោយការទូទាត់ ។

២-ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ បានធ្វើឱ្យខ្លួន និង កូនបំណុលផ្សេងទៀតរួចផុតពីកាតព្វកិច្ច ដោយបានសង ឬ ចេញចំណាយផ្សេងទៀតរបស់ខ្លួនតែមិនបានជូនដំណឹងអំពីហេតុនោះ ទៅកូនបំណុលផ្សេងទៀត បើកូនបំណុលផ្សេងទៀតបានរួចផុតពីកាតព្វកិច្ច ដោយបានសង ឬ ចេញចំណាយផ្សេងទៀតរបស់ខ្លួន ដោយមិនបានដឹងអំពីហេតុនោះ កូនបំណុលដែលបានរួចផុតពីកាតព្វកិច្ចពេលក្រោយនោះ អាចចាត់ទុកថាការសង ឬ សកម្មភាពផ្សេងទៀតរបស់ខ្លួនដែលធ្វើឱ្យរួចផុតពីកាតព្វកិច្ចនោះមានសុពលភាព ។

៣-ក្នុងករណីដែលការសង ឬ សកម្មភាពដែលធ្វើឱ្យរួចផុតពីកាតព្វកិច្ចដោយចេញចំណាយផ្សេងទៀតរបស់ខ្លួន ត្រូវបានធ្វើឡើងដោយកូនបំណុលច្រើនក្នុងចំណោមកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាព ហើយបើការជូនដំណឹងដែលបានកំណត់នៅក្នុងកថា-

ROYAUME DU CAMBODGE · LE MINISTÈRE ROYAL

ខណ្ឌទី ១ និង ទី ២ ខាងលើនេះ មិនបានធ្វើឡើង នោះការសង ឬ សកម្មភាពដែលឱ្យរួចផុតពីកាតព្វកិច្ចដោយចេញចំណាយផ្សេងទៀតរបស់ខ្លួនដែលកូនបំណុលណាបានធ្វើមុន ត្រូវបានចាត់ទុកថា មានសុពលភាព ។

មាត្រា ៩៣៤.- ការទាមទារសំណងក្នុងករណីដែលមានអ្នកជាអសាធនីយ៍ក្នុងការសង

បើមានអ្នកដែលស្ថិតនៅក្នុងស្ថានភាពអសាធនីយ៍ក្នុងការសង ក្នុងចំណោមកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាព ផ្នែកដែលមិនអាចសងបាននោះ ត្រូវជាបន្ទុករបស់អ្នកដែលទាមទារសំណង និង អ្នកដែលជាសាធនីយ៍ តាមសមាមាត្រនៃបន្ទុករៀងៗខ្លួន ។ ប៉ុន្តែ បើអ្នកដែលទាមទារសំណងមានកំហុស អ្នកនោះមិនអាចទាមទារឱ្យកូនបំណុលផ្សេងទៀតទទួលបន្ទុកឡើយ ។

មាត្រា ៩៣៥.- ការលើកលែងសាមគ្គីភាព និង បន្ទុករបស់អ្នកដែលជាអសាធនីយ៍ក្នុងការសង

ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ក្នុងចំណោមកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាព បានទទួលការលើកលែងសាមគ្គីភាព បើមានអ្នកដែលជាអសាធនីយ៍ក្នុងការសងក្នុងចំណោមកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពផ្សេងទៀត ម្ចាស់បំណុលត្រូវទទួលបន្ទុកនូវផ្នែកដែលអ្នកដែលបានទទួលការលើកលែងសាមគ្គីភាពត្រូវទទួលបន្ទុក ចំពោះផ្នែកដែលអ្នកដែលជាអសាធនីយ៍នោះមិនអាចឆ្លើយតបនឹងការទាមទារសំណងបាន ។

ផ្នែកទី ៤

ឧបាទេសកម្មដោយការសង

មាត្រា ៩៣៦.- ឧបាទេសកម្ម

១-ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ទទួលសិទ្ធិទាមទារសំណង ចំពោះកូនបំណុលផ្សេងទៀត អ្នកទាមទារសំណងត្រូវស្នងម្ចាស់បំណុលដោយឧបាទេសកម្ម ចំពោះសិទ្ធិលើបំណុលដែលម្ចាស់បំណុលធ្លាប់មាន ចំពោះកូនបំណុលផ្សេងទៀត និង សិទ្ធិប្រាតិភោគដើម្បីធានាសិទ្ធិលើបំណុលនោះ ក្នុងទំហំនៃការទាមទារសំណងនោះ ។

២-ក្រៅពីបញ្ញត្តិនៃមាត្រានេះ បញ្ញត្តិនៃកថាភាគទី ៤ (ឧបាទេសកម្មដោយការសង) ផ្នែកទី ១ ជំពូកទី ៧ នៃគន្ថីទី ៤ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះឧបាទេសកម្មរបស់អ្នកទាមទារសំណង ។

ផ្នែកទី ៥

ប្រភេទផ្សេងទៀតនៃកាតព្វកិច្ចដែលមានកូនបំណុលច្រើននាក់

មាត្រា ៩៣៧.- កាតព្វកិច្ចអវិភាគីយ៍ និង កាតព្វកិច្ចដែលមានលក្ខណៈប្រហាក់ប្រហែលនឹងកាតព្វកិច្ចដោយសាមគ្គីភាព និង កាតព្វកិច្ចវិភាគីយ៍

១-បញ្ញត្តិនៃមាត្រា ៩២១ (អត្ថន័យនៃកាតព្វកិច្ចដោយសាមគ្គីភាព) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកូនបំណុលច្រើននាក់ទទួលកាតព្វកិច្ចដែលមានគោលបំណងដូចគ្នា ចំពោះម្ចាស់បំណុលតែម្នាក់ ហើយឆន្ទៈសាមគ្គីភាពរួមគ្នាទៅវិញទៅមកមិនត្រូវបានទទួលស្គាល់រវាងកូនបំណុលទាំងនេះ ។ ប៉ុន្តែ ក្នុងករណីដែលតាវកាលិកនៃកាតព្វកិច្ចនោះ អាចបែងចែកបាន ហើយការបែងចែកនោះមិនខូចខាតដល់ផលប្រយោជន៍របស់ម្ចាស់បំណុលនោះ កូនបំណុលនីមួយៗត្រូវទទួលកាតព្វកិច្ចដែលត្រូវបានបែងចែកតាមសមាមាត្រនៃបន្ទុករៀងៗខ្លួន ។ បើបន្ទុករបស់កូនបំណុលម្នាក់ៗមិនច្បាស់លាស់ បន្ទុកនោះត្រូវបានសន្មតថាស្មើៗគ្នា ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ ហេតុដែលបានកើតឡើងចំពោះកូនបំណុលម្នាក់ មិនត្រូវមានឥទ្ធិពលដល់កូនបំណុលផ្សេងទៀត លើកលែងតែករណីដែលបានកំណត់នៅក្នុងមាត្រា ៩២៥ (អានុភាពដាច់ខាតនៃការសងជាអាទិ៍) និង កថាខណ្ឌទី ១ នៃមាត្រា ៩២៦ (អានុភាពដាច់ខាតនៃការទូទាត់) ខាងលើនេះ ។

៣-ក្នុងករណីដែលកូនបំណុលណាម្នាក់ ក្នុងចំណោមកូនបំណុលដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ បានរួចផុតពីកាតព្វកិច្ច ដោយបានសង ឬ ចេញចំណាយផ្សេងទៀតរបស់ខ្លួន ហើយធ្វើឱ្យកូនបំណុលផ្សេងទៀតរួចផុតពីកាតព្វកិច្ច បើមានភាពចាំបាច់ត្រូវការសមភាពរវាងកូនបំណុលដែលបានចេញចំណាយ និង កូនបំណុលផ្សេងទៀត អ្នកដែលបានចេញចំណាយ ត្រូវទទួលសិទ្ធិទាមទារសំណង ចំពោះកូនបំណុលផ្សេងទៀតក្នុង

កម្រិតដែលអាចធ្វើឱ្យមានសមភាពនោះ ។

គន្ថីទី ៧

ញាតិ

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ៩៣៨.- ទំហំរបស់ញាតិ

បុគ្គលដែលបានកំណត់ដូចខាងក្រោមនេះ គឺជាញាតិ :

ក-ញាតិលោហិតក្នុង ៦ (ប្រាំមួយ) ថ្នាក់ ។

ខ-សហព័ទ្ធ ។

គ-ញាតិពន្ធក្នុង៣ (បី)ថ្នាក់ ។

មាត្រា ៩៣៩.- ការគណនាថ្នាក់ញាតិ

១-ថ្នាក់ញាតិ ត្រូវកំណត់ដោយគណនាចំនួននៃតំណពូជរវាងញាតិ ។

២-ដើម្បីកំណត់ថ្នាក់ញាតិនៃសាខាញាតិ ត្រូវគណនាចំនួននៃតំណពូជ គិតចាប់ពីជននោះ ឬ សហព័ទ្ធរបស់ជននោះ ឡើងទៅដល់បុព្វជនដូចគ្នា និង ចំនួននៃតំណពូជគិតចាប់ពីបុព្វជនរបស់ជននោះ ចុះរហូតមកដល់ជនម្នាក់ទៀត ។

មាត្រា ៩៤០.- ការកើតមានឡើងនូវទំនាក់ទំនងញាតិភាពដោយការសុំកូន

ទំនាក់ទំនងរវាងកូនចិញ្ចឹម និង ឪពុក ម្តាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមនោះ នឹងត្រូវបង្កើតនូវញាតិភាព ដូចគ្នានឹងញាតិលោហិត គិតចាប់ពីថ្ងៃដែលបានសុំកូន ។

មាត្រា ៩៤១.- ការរលត់ទំនាក់ទំនងញាតិពន្ធ

១-ទំនាក់ទំនងញាតិពន្ធ ត្រូវបញ្ចប់ដោយការលែងលះគ្នា ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសហព័ទ្ធណាម្ខាង បានទទួលមរណភាព ហើយសហព័ទ្ធដែលនៅរស់ បានរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ឬ បានបង្ហាញឆន្ទៈបញ្ចប់ទំនាក់ទំនងញាតិពន្ធ ។

មាត្រា ៩៥២.- ការរលត់ញាតិភាព ដោយការកាត់កាល់ ឬ លែងទទួលស្គាល់

ញាតិភាពរវាងកូនចិញ្ចឹម សហព័ទ្ធរបស់ជននោះ បច្ឆាញាតិផ្ទាល់ និង សហព័ទ្ធរបស់បច្ឆាញាតិផ្ទាល់នោះ ជាមួយនឹងឪពុកម្តាយចិញ្ចឹម និង ញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមនោះ ត្រូវបានបញ្ចប់ដោយការកាត់កាល់ ឬ លែងទទួលស្គាល់ ។

មាត្រា ៩៥៣.- ករណីយកិច្ចគោរពគ្នារវាងញាតិ និង ការបង្ការអំពើហិង្សាក្នុងគ្រួសារ

១-សមាជិកម្នាក់ៗនៅក្នុងក្រុមគ្រួសារ ត្រូវគោរពសិទ្ធិ និង សេរីភាពរវាងគ្នាទៅវិញទៅមក ហើយត្រូវសង្គ្រោះគ្នាទៅវិញទៅមក ។

២-សមាជិកម្នាក់ៗនៅក្នុងក្រុមគ្រួសារ ត្រូវបង្ការកុំឱ្យកើតមានអំពើហិង្សាក្នុងគ្រួសារ និង ត្រូវធ្វើយ៉ាងណាកុំឱ្យកើតមានឡើងនូវការរំលោភសិទ្ធិមនុស្ស ។

ជំពូកទី ២

កំជាប់ពាក្យ

មាត្រា ៩៥៤.- ការបង្កើតកំជាប់ពាក្យ

កំជាប់ពាក្យ ត្រូវបង្កើតឡើង តាមសេចក្តីសន្យារវាងបុរស នារី ថានឹងរៀបអាពាហ៍ពិពាហ៍រវាងគ្នា នាពេលអនាគត និង ដោយធ្វើពិធីកំជាប់ពាក្យ ។

មាត្រា ៩៥៥.- ការសងជំនូន

ក្នុងករណីដែលកំជាប់ពាក្យបានរលាយ ភាគីដែលបានលើកជំនូននៅពេលកំជាប់ពាក្យដោយសង្ឃឹមថានឹងបានរៀបអាពាហ៍ពិពាហ៍ អាចទាមទារឱ្យភាគីម្ខាងទៀតសងជំនូននោះមកវិញបាន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា ៩៤៦.- ការទទួលខុសត្រូវចំពោះការបដិសេធចោលដោយមិនត្រឹមត្រូវ

ក្នុងករណីដែលភាគីណាម្ខាងបានបដិសេធកំជាប់ពាក្យដែលបានភ្ជាប់រវាងភាគី ចោលដោយគ្មានមូលហេតុត្រឹមត្រូវ ភាគីម្ខាងទៀតអាចទាមទារសំណងនៃការខូចខាតដែលកើតឡើងដោយសារការបដិសេធចោលនោះបាន ។

មាត្រា ៩៤៧.- អំឡុងពេលដាក់ពាក្យបណ្តឹង

បណ្តឹងដែលទាក់ទងទៅនឹងមាត្រា ៩៤៥ (ការសងជំនូន) ឬ មាត្រា ៩៤៦ (ការទទួលខុសត្រូវចំពោះការបដិសេធចោលដោយមិនត្រឹមត្រូវ) ខាងលើនេះ ត្រូវប្តឹងនៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលកំជាប់ពាក្យនោះ បានរលាយ ។

ជំពូកទី ៣

អាពាហ៍ពិពាហ៍

ផ្នែកទី ១

ការបង្កើតអាពាហ៍ពិពាហ៍

កថាភាគទី ១

លក្ខខណ្ឌនៃអាពាហ៍ពិពាហ៍

មាត្រា ៩៤៨.- អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍

បុរស និង នារី ដែលមិនទាន់ដល់នីតិភាព មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ ។ប៉ុន្តែ ក្នុងករណីដែលភាគីម្ខាងបានដល់នីតិភាព ហើយភាគីម្ខាងទៀតជាអនីតិជនដែលមានអាយុមិនតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បាន ដោយទទួលការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់អនីតិជននោះ ។

មាត្រា ៩៤៩.- ការហាមឃាត់មិនឱ្យមានទ្វេពន្ធភាព

បុគ្គលដែលមានសហព័ទ្ធហើយ ពុំអាចរៀបអាពាហ៍ពិពាហ៍ទៀតបានឡើយ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា ៩៥០.- អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត

១-នារីពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានឡើយ ប្រសិនបើអំឡុងពេល ១២០ (មួយរយម្ភៃ) ថ្ងៃ ពុំទាន់បានកន្លងផុត គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុន ត្រូវបានរំលាយ ឬ លុបចោល ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលនារីមានផ្ទៃពោះនៅមុនពេលដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬ លុបចោលហើយបានសម្រាលកូន ឬ ចំពោះករណីដែលមានលិខិតបញ្ជាក់ពីការគ្មានផ្ទៃពោះពីវេជ្ជបណ្ឌិត ។

មាត្រា ៩៥១.- ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិត

១-អាពាហ៍ពិពាហ៍ មិនអាចធ្វើបានឡើយ រវាងញាតិលោហិតផ្ទាល់ ឬ សាខាញាតិលោហិតក្នុង ៣ (បី) ថ្នាក់ រាប់ទាំង ថ្នាក់ទី ៣ (បី) ផង ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរនៅក្រោយពេលដែលទំនាក់ទំនងញាតិ ត្រូវបានបញ្ចប់ ដោយបញ្ញត្តិនៃមាត្រា ១០១៤ (ការបញ្ចប់នូវញាតិភាពជាមួយនឹងឪពុកម្ដាយបង្កើត) មាត្រា ១០១៦ (ការកាត់កាល់នៃសុំកូនពេញលេញ) ឬ មាត្រា ១០៣២(អានុភាពនៃការកាត់កាល់សុំកូនធម្មតា) នៃក្រមនេះ ។

មាត្រា ៩៥២.- ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ

១-អាពាហ៍ពិពាហ៍ពុំអាចធ្វើបានឡើយ រវាងញាតិពន្ធនៃខ្សែផ្ទាល់ ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាដែរ នៅក្រោយពេលដែលបានបញ្ចប់ទំនាក់ទំនងញាតិពន្ធ ដោយបញ្ញត្តិមាត្រា ៩៤១(ការរលត់ទំនាក់ទំនងញាតិពន្ធ) ឬ មាត្រា ១០១៦(ការកាត់កាល់នៃសុំកូនពេញលេញ) នៃក្រមនេះ ។

២-អាពាហ៍ពិពាហ៍ពុំអាចធ្វើបានឡើយ រវាងសាខាញាតិពន្ធ នៅក្នុង ៣ (បី) ថ្នាក់ រាប់ទាំងថ្នាក់ទី ៣ (បី) ផង ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្រោយពេលបានបញ្ចប់ទំនាក់ទំនងញាតិពន្ធ តាមបញ្ញត្តិនៃមាត្រា ៩៤១(ការរលត់ទំនាក់ទំនងញាតិពន្ធ) ខាងលើនេះ ។ ប៉ុន្តែ បើសហព័ទ្ធណាម្ខាងបានទទួលមរណភាព សហព័ទ្ធដែលនៅរស់ អាចរៀបអាពាហ៍ពិពាហ៍ជាមួយបុគ្គលដែលធ្លាប់ជាសាខាញាតិពន្ធ នៅក្នុង ៣ (បី) ថ្នាក់បាន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា ៩៥៣.- ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន

១- ក្នុងករណីដែលភាគីម្ខាងក្នុងចំណោមភាគីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាអនីតិជន អនីតិជននោះចាំបាច់ត្រូវមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបា ឬ អាណាព្យាបាលសម្រាប់អនីតិជននោះ ។

២- បើអ្នកដែលមានអំណាចមេបាណាម្ខាងមិនយល់ព្រមទេ គ្រាន់តែមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបាម្ខាងជាការគ្រប់គ្រាន់ហើយ ។

៣- ក្នុងករណីដែលអ្នកមានអំណាចមេបា ឬ អាណាព្យាបាលសម្រាប់អនីតិជនបដិសេធការយល់ព្រមដោយគ្មានមូលហេតុសមរម្យ អនីតិជនដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍អាចទាមទារទៅតុលាការឱ្យសម្រេចសេចក្តីជំនួសការយល់ព្រមនោះបាន ។

មាត្រា ៩៥៤.- ការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ

ជននៅក្រោមអាណាព្យាបាលទូទៅអាចរៀបអាពាហ៍ពិពាហ៍បាន ក្នុងករណីដែលមានសមត្ថភាពបង្ហាញឆន្ទៈក្នុងកម្រិតអប្បបរិមា ដែលចាំបាច់ដើម្បីរៀបអាពាហ៍ពិពាហ៍ ។ ក្នុងករណីនេះ មិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅឡើយ ។

មាត្រា ៩៥៥.- ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និង ការចុះបញ្ជីអាពាហ៍ពិពាហ៍

១- អាពាហ៍ពិពាហ៍នឹងមានអានុភាព ដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និង ការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

២- ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើដោយផ្អែកតាមនីតិវិធីដែលបានកំណត់នៅក្នុងបទប្បញ្ញត្តិស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន ។

មាត្រា ៩៥៦.- ការទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍

ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ពុំអាចទទួលយកបានឡើយ បើបានទទួលស្គាល់ថាអាពាហ៍

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ពិពាហ៍នោះ ផ្ទុយនឹងបញ្ញត្តិ ចាប់ពីមាត្រា ៩៤៨(អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍) រហូតដល់មាត្រា ៩៥៤ (ការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ) ខាងលើនេះ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ។

មាត្រា ៩៥៧.- ទម្រង់នៃអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរដែលរស់នៅបរទេស

១-បើមានបំណងចង់រៀបអាពាហ៍ពិពាហ៍រវាងគ្នា ពលរដ្ឋខ្មែរដែលរស់នៅបរទេស អាចដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ជូនដំណឹងជាសាធារណៈ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និង ចុះបញ្ជីអាពាហ៍ពិពាហ៍នោះ នៅចំពោះមុខឯកអគ្គរាជទូត ភារធារី ឬ កុងស៊ុលរបស់ព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅប្រទេសនោះ ។

២-ការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើដោយបិទនៅបញ្ចររបស់ស្ថានទូត ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ។

កថាភាគទី ២

មោឃភាព និង ការលុបចោលអាពាហ៍ពិពាហ៍

មាត្រា ៩៥៨.- មោឃភាពនៃអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ នឹងត្រូវចាត់ទុកជាមោឃៈ តែក្នុងករណីដូចកំណត់ខាងក្រោមនេះ:

ក-ប្រសិនបើគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ រវាងភាគី ដោយសារការភាន់ច្រឡំលើមនុស្ស ការបង្ខំ និង មូលហេតុផ្សេងៗទៀត ។

ខ-ប្រសិនបើភាគី មិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ឬ មិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ។ ប៉ុន្តែ ប្រសិនបើគ្រាន់តែមានវិការៈតែបន្តិចបន្តួចលើនីតិវិធីប៉ុណ្ណោះទេ អានុភាពនៃអាពាហ៍ពិពាហ៍នេះ មិនត្រូវបានរារាំងដោយសារហេតុនោះឡើយ ។

មាត្រា ៩៥៩.- ការលុបចោលអាពាហ៍ពិពាហ៍

ការលុបចោលអាពាហ៍ពិពាហ៍ ត្រូវធ្វើដោយយោងតាមបញ្ញត្តិចាប់ពីមាត្រា ៩៦០ (ការ

ROYAUME DU CAMBODGE

លុបចោលអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវតាមច្បាប់ ជាអាទិ៍) ដល់មាត្រា ៩៦៣ (ការលុបចោលអាពាហ៍ពិពាហ៍ដោយការឆបោក ឬ ការគំរាម) ខាងក្រោមនេះ ។

មាត្រា ៩៦០.- ការលុបចោលអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវតាមច្បាប់ ជាអាទិ៍

១-អាពាហ៍ពិពាហ៍ដែលបានធ្វើផ្ទុយនឹងបញ្ញត្តិចាប់ពីមាត្រា ៩៤៨(អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍) រហូតដល់មាត្រា ៩៥២ (ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ) នៃក្រមនេះ ភាគីនីមួយៗ ញាតិសន្តានរបស់ជននោះ ឬ តំណាងអយ្យការ អាចទាមទារទៅតុលាការឱ្យលុបចោលបាន ។ ប៉ុន្តែ នៅក្រោយពេលដែលភាគីណាម្ខាង បានទទួលមរណភាពហើយ តំណាងអយ្យការពុំអាចទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបានឡើយ ។

២-ចំពោះអាពាហ៍ពិពាហ៍ដែលបានធ្វើផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៩៤៩ (ការហាមឃាត់មិនឱ្យមានទ្វេពន្ធភាព) ឬ មាត្រា ៩៥០ (អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត) នៃក្រមនេះ សហព័ទ្ធរបស់ភាគី ឬ សហព័ទ្ធមុននោះ ក៏អាចទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបានដែរ ។

មាត្រា ៩៦១.- ការរលត់សិទ្ធិលុបចោលអាពាហ៍ពិពាហ៍ដែលភាគីមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍

១-អាពាហ៍ពិពាហ៍ដែលបានធ្វើផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៩៤៨(អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍) នៃក្រមនេះ ប្រសិនបើជនដែលមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍បានគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ហើយ ពុំអាចទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបានឡើយ ។

២-ក្រោយពេលជនដែលមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍ បានគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ហើយ ជននោះក៏នៅតែអាចទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបាននៅក្នុងអំឡុងពេល ៣ (បី) ខែ ចាប់ពីពេលដែលជននោះបានគ្រប់អាយុ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើជននោះបានធ្វើសច្ចានុមតិ បន្ទាប់ពីបានគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ហើយ ។

មាត្រា ៩៦២.- ការលុបចោលអាពាហ៍ពិពាហ៍ធ្វើនៅក្នុងអំឡុងពេលហាមឃាត់មិនឱ្យរៀប អាពាហ៍ពិពាហ៍ថ្មីទៀត

អាពាហ៍ពិពាហ៍ដែលបានធ្វើផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៩៥០ (អំឡុងពេលហាមឃាត់ មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត) នៃក្រមនេះ ពុំអាចទាមទារឱ្យលុបចោលបានឡើយ ប្រសិនបើរយៈពេល ១២០ (មួយរយម្ភៃ) ថ្ងៃ បានកន្លងផុត គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬ លុបចោល ឬ ប្រសិនបើនារីមានផ្ទៃពោះ ក្រោយពីបានរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ។

មាត្រា ៩៦៣.- ការលុបចោលអាពាហ៍ពិពាហ៍ដោយការឆបោក ឬ ការគំរាម

១-បុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ ដោយការឆបោក ឬ ការគំរាម អាចទាមទារទៅតុលាការ ឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបាន ។

២-សិទ្ធិលុបចោលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវរលត់ បើភាគីបានរកឃើញការឆបោក ឬ បើអំឡុងពេល ៣ (បី) ខែ បានកន្លងផុត ក្រោយពីបានរួចខ្លួនផុតពីការគំរាម ឬ បើបានធ្វើសច្ចានុមតិ ។

មាត្រា ៩៦៤.- អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍

១-ការលុបចោលអាពាហ៍ពិពាហ៍ ពុំមានអានុភាពទៅលើអតីតកាលឡើយ ។

២-ភាគីដែលមិនបានដឹងអំពីមូលហេតុនៃការលុបចោល នៅពេលរៀបអាពាហ៍ពិពាហ៍ ប្រសិនបើបានទទួលទ្រព្យសម្បត្តិ ដោយការរៀបអាពាហ៍ពិពាហ៍ ត្រូវសងទ្រព្យសម្បត្តិនោះត្រឹមកម្រិតនៃផលប្រយោជន៍ដែលបានទទួល ។

៣-ភាគីដែលបានដឹងអំពីមូលហេតុនៃការលុបចោល នៅពេលរៀបអាពាហ៍ពិពាហ៍ ត្រូវសងផលប្រយោជន៍ទាំងអស់ដែលបានទទួលដោយការរៀបអាពាហ៍ពិពាហ៍នោះ ។ ប្រសិនបើភាគីម្ខាងទៀតសុចរិតវិញ ត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាតនោះ ។

៤-បញ្ញត្តិនៃមាត្រា ៩៨៨ (ការសន្មតបិតុភាព) នៃក្រមនេះ ត្រូវយកមកអនុវត្តផងដែរចំពោះកូនដែលមានកំណើតរវាងភាគីនៃអាពាហ៍ពិពាហ៍ដែលអាចលុបចោលបាន ។

៥-បញ្ញត្តិនៃមាត្រា ៩៨០ (ការបែងចែកទ្រព្យសម្បត្តិ) នៃក្រមនេះ ត្រូវយកមកអនុវត្តផងដែរចំពោះករណីនៃការរំលាយអាពាហ៍ពិពាហ៍ដែលអាចលុបចោលបាន ។

ផ្នែកទី ២

អានុភាពនៃអាពាហ៍ពិពាហ៍

មាត្រា ៩៦៥.- នាមត្រកូលរបស់ប្តី ប្រពន្ធ

ផ្អែកតាមការកំណត់នៅពេលរៀបអាពាហ៍ពិពាហ៍ ប្តី ប្រពន្ធ អាចប្រើនាមត្រកូលរបស់ប្តី ឬ ប្រពន្ធ ឬ អាចប្រើនាមត្រកូលដើមរៀងៗខ្លួន ដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍បាន ។

មាត្រា ៩៦៦.- ករណីយកិច្ចរួមរស់នឹងគ្នា សហការ និង សង្គ្រោះគ្នាទៅវិញទៅមក

ប្តីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការសង្គ្រោះគ្នាទៅវិញទៅមក ។

មាត្រា ៩៦៧.- សេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ និង សិទ្ធិចូលរួមក្នុងសកម្មភាពសង្គម

ប្តី ប្រពន្ធមានសេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ ហើយអាចចូលរួមក្នុងសកម្មភាពនយោបាយ វប្បធម៌ សង្គម រៀងៗខ្លួនបាន ។

មាត្រា ៩៦៨.- ការចាត់ទុកជានីតិជន ដោយអាពាហ៍ពិពាហ៍

ប្រសិនបើអនីតិជនបានរៀបអាពាហ៍ពិពាហ៍ អនីតិជននោះត្រូវបានចាត់ទុកថាបានដល់នីតិភាពដោយអាពាហ៍ពិពាហ៍នោះ ក្នុងការអនុវត្តក្រមរដ្ឋប្បវេណីនេះ ។

ផ្នែកទី ៣

ប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ

កថាភាគទី ១

ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា

មាត្រា ៩៦៩.- កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និង ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់

១- ប្តីប្រពន្ធ អាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិ នៅមុន ឬ ក្រោយអាពាហ៍ពិពាហ៍បាន ។ ប៉ុន្តែ កិច្ចសន្យានេះ មិនអាចធ្វើផ្ទុយនឹងបញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារកាតព្វកិច្ច

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

និង ភាគបម្រុងបានឡើយ ។

២-បើប្តី ប្រពន្ធមិនបានធ្វើកិច្ចសន្យាពិសេសចំពោះទ្រព្យសម្បត្តិនោះទេ ទំនាក់ទំនងទ្រព្យសម្បត្តិនោះ ត្រូវអនុលោមតាមបញ្ញត្តិនៃកថាភាគទី ២ (ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់) ។

មាត្រា ៩៧០.- ភាពចាំបាច់នៃការធ្វើជាលាយលក្ខណ៍អក្សរនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តី ប្រពន្ធ និង លក្ខខណ្ឌតតាំង

១-កិច្ចសន្យាទ្រព្យសម្បត្តិប្តី ប្រពន្ធ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

២-ក្នុងករណីដែលប្តី ប្រពន្ធបានធ្វើកិច្ចសន្យា ផ្សេងពីប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ បើមិនបានចុះបញ្ជីទេ មិនអាចយកកិច្ចសន្យានោះមកតតាំងជាមួយនឹងតតិយជនបានឡើយ ។

កថាភាគទី ២

ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់

មាត្រា ៩៧១.- ចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍

ប្តីប្រពន្ធ ត្រូវមានចំណែកបន្ទុកលើសោហ៊ុយដែលកើតចេញពីអាពាហ៍ពិពាហ៍ដោយពិចារណាទៅលើទ្រព្យសម្បត្តិ ប្រាក់ចំណូល និង ស្ថានភាពផ្សេងៗទៀត ។

មាត្រា ៩៧២.- ទ្រព្យសម្បត្តិដោយឡែក

ទ្រព្យសម្បត្តិដែលកំណត់ដូចខាងក្រោមនេះ គឺជាទ្រព្យសម្បត្តិដោយឡែក ដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់សហព័ទ្ធណាម្នាក់ :

ក-ទ្រព្យសម្បត្តិ ដែលសហព័ទ្ធមាន នៅមុនពេលរៀបអាពាហ៍ពិពាហ៍ ។

ខ-ទ្រព្យសម្បត្តិ ដែលសហព័ទ្ធទទួលបាន ដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ។

គ-ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដែលមានចែងក្នុងចំណុច ក និង ចំណុច ខ ខាងលើនេះ ។

មាត្រា ៩៧៣.- ទ្រព្យសម្បត្តិរួម

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយដែលប្តីប្រពន្ធទាំងសងខាង ឬ តែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដែលកំណត់ក្នុងចំណុច ខ និង ចំណុច គ នៃមាត្រា ៩៧២ (ទ្រព្យសម្បត្តិដោយឡែក) ខាងលើនេះ ។

មាត្រា ៩៧៤.- ការគ្រប់គ្រង និង ការប្រើប្រាស់ទ្រព្យសម្បត្តិ

១-ប្តីប្រពន្ធ មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និង គ្រប់គ្រងទ្រព្យសម្បត្តិរួម ។ សហព័ទ្ធនីមួយៗ មានសិទ្ធិប្រើប្រាស់ ទទួលផលប្រយោជន៍ និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនរៀងៗខ្លួនបាន ។

២-សហព័ទ្ធ មានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិរួម នៅក្នុងទំហំដែលចាំបាច់ ដោយផ្អែកលើការចាំបាច់នៅក្នុងជីវភាព ។

៣-សហព័ទ្ធត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួម ដោយសហការគ្នា ។ សហព័ទ្ធម្ខាងអាចទាមទារចំពោះភាគីម្ខាងទៀតឱ្យធ្វើចំណាត់ការដែលចាំបាច់ដើម្បីគ្រប់គ្រង និង រក្សាទុកនូវទ្រព្យសម្បត្តិរួមបាន ។

៤-បើការពិភាក្សាអំពីការគ្រប់គ្រង ឬ ប្រើប្រាស់ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធមិនបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ ភាគីម្ខាងទៀតអាចទាមទារទៅតុលាការឱ្យធ្វើការចាត់ចែងចំពោះការគ្រប់គ្រង និង ប្រើប្រាស់ទ្រព្យសម្បត្តិរួមបាន ។

មាត្រា ៩៧៥.- ការទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ច

ប្តីប្រពន្ធត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ចដែលកំណត់ខាងក្រោមនេះ :

ក-សោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ប្តីប្រពន្ធ និង សោហ៊ុយដើម្បីការអប់រំ ឬ ការព្យាបាល ថែទាំកូន ជាអាទិ៍ ។

ខ-កាតព្វកិច្ច និង ករណីយកិច្ចផ្សេងៗទៀត ដែលប្តីប្រពន្ធទាំងសងខាង បានព្រមព្រៀងគ្នាតាមលិខិតជាលាយល័ក្ខណ៍អក្សរជាមួយម្ចាស់បំណុល នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍

គ-កាតព្វកិច្ច និង ករណីយកិច្ចផ្សេងៗទៀត ដែលប្តី ឬ ប្រពន្ធណាម្ខាងបានទទួលបន្ទុកដោយមាន

ការយល់ព្រមតាមលិខិតជាលាយល័ក្ខណ៍អក្សរពីប្រពន្ធ ឬ ប្តី ម្ខាងទៀត នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ។

គ-សោហ៊ុយដើម្បីគ្រប់គ្រង និង រក្សាទ្រព្យសម្បត្តិរួម ។

មាត្រា ៩៧៦.- ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ

១-បើគ្មានការយល់ព្រមពីប្តីប្រពន្ធទាំងសងខាងទេ ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ មិនអាចយកទៅលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀតបានឡើយ ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើក៏ដោយ បើមានស្ថានភាពមិនអាចជៀសវាងបាន សម្រាប់ការថែទាំជីវភាពរួមក្នុងអាពាហ៍ពិពាហ៍ និង ដើម្បីរក្សាជីវភាពរស់នៅនោះប្តីប្រពន្ធណាម្ខាង អាចលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀតនូវទ្រព្យសម្បត្តិរួមបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

៣-ក្នុងករណីដែលប្តី ឬ ប្រពន្ធណាម្ខាងបានលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀតនូវទ្រព្យសម្បត្តិរួម ដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតផង និង គ្មានការអនុញ្ញាតពីតុលាការផង សហព័ទ្ធដែលមិនបានផ្តល់ការយល់ព្រមអាចទាមទារឱ្យលុបចោលនូវការចាត់ចែងនោះទៅតុលាការបាន នៅក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជាអចលនវត្ថុ និង នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជាទ្រព្យសម្បត្តិផ្សេង ។

មាត្រា ៩៧៧.- ការអាស្រ័យនៅទ្រព្យសម្បត្តិដោយឡែក

១-ប្តីប្រពន្ធម្ខាងអាចអាស្រ័យនៅអចលនវត្ថុដែលជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀត ហើយដែលត្រូវបានប្រើសម្រាប់ការអាស្រ័យនៅរបស់គ្រួសារបាន ។

២-ក្នុងករណីដែលប្តីប្រពន្ធម្ខាងអាស្រ័យនៅអចលនវត្ថុដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ទោះបីជាសហព័ទ្ធម្ខាងទៀតបានចាត់ចែងអចលនវត្ថុនោះ ក៏ដោយ ក៏អាចបន្តអាស្រ័យនៅអចលនវត្ថុនោះបានដែរ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ផ្នែកទី ៤

ការលែងលះគ្នា

កថាភាគទី ១

មូលហេតុនៃការលែងលះគ្នា

មាត្រា ៩៧៨.- មូលហេតុនៃការលែងលះគ្នា

១-ប្តី ឬ ប្រពន្ធ អាចដាក់ពាក្យបណ្តឹងលែងលះគ្នាបាន តែក្នុងករណីដែលកំណត់ខាងក្រោមនេះ :

ក-បើបានប្រព្រឹត្តអំពើផិត ទៅលើសហព័ទ្ធ ។

ខ-បើបានបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ ។

គ-បើមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬ រស់ អស់រយៈពេលជាង ១ (មួយ) ឆ្នាំ ។

ឃ-បើសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង ១ (មួយ) ឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ ។

ង-ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន ។

២-ទោះបីជាក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ប្រសិនបើយល់ឃើញថា ការលែងលះគ្នានោះនឹងបណ្តាលឱ្យការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ ឬ កូនក្រលំបាកយ៉ាងខ្លាំង ឬ មានការឈឺចាប់ដែលពុំអាចទ្រាំទ្របាន តុលាការអាចច្រានចោលការទាមទារលែងលះគ្នា ដោយពិចារណាទៅលើស្ថានភាពទាំងឡាយបាន ។

៣-ក្នុងករណីដែលមានមូលហេតុដូចបានកំណត់នៅក្នុងចំណុច ឃ ឬ ចំណុច ង នៃកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថា ការទាមទារនោះផ្ទុយនឹងភាពសុចរិត ដោយជនដែលទាមទារឱ្យលែងលះគ្នានោះ ធ្វេសប្រហែសយ៉ាងខ្លាំងក្នុងការសហប្រតិបត្តិ និង ជួយសង្គ្រោះចំពោះសហព័ទ្ធ តុលាការអាចច្រានចោលការទាមទារលែងលះគ្នានោះ ដោយឆន្ទានុសិទ្ធិបាន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

មាត្រា ៩៧៩.- ការលែងលះដោយការព្រមព្រៀង

ភាគីនៃអាពាហ៍ពិពាហ៍ អាចដាក់ពាក្យបណ្ដឹងលែងលះទៅតុលាការបាន ក្នុងករណីដែលភាគីសងខាងបានព្រមព្រៀងអំពីការលែងលះគ្នា ។ ប៉ុន្តែ តុលាការអាចឱ្យលែងលះគ្នាបានក្រោយពីបានយល់ឃើញថា ភាគីសងខាងមានបំណងពិតប្រាកដក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ ។

មាត្រា ៩៨០.- ការបែងចែកទ្រព្យសម្បត្តិ

១-ក្នុងករណីដែលប្ដីប្រពន្ធលែងលះគ្នា ត្រូវបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌ ផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង ។

២-ក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងប្ដីប្រពន្ធបានទេ ត្រូវបែងចែកទ្រព្យសម្បត្តិដោយផ្អែកតាមចំណុចនីមួយៗ ដូចកំណត់ខាងក្រោមនេះ :

ក-សហព័ទ្ធនីមួយៗ ត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែកដែលបានកំណត់នៅក្នុងមាត្រា ៩៧២ (ទ្រព្យសម្បត្តិដោយឡែក) ។

ខ-បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែក សហព័ទ្ធនីមួយៗមានសិទ្ធិទទួលយក ១ ភាគ ២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរួម ។ ប៉ុន្តែ បើមានករណីពិសេស និង មានការទាមទាររបស់ប្ដីប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជាទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើនទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍កម្រិតជីវភាពរស់នៅនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្តនិងផ្លូវកាយ វិជ្ជាជីវៈប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និង ផលប្រយោជន៍របស់កូនជាអាទិ៍ ។

៣-គេហកិច្ច ត្រូវចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះដែរ ។

មាត្រា ៩៨១.- ការលែងលះគ្នា និង នាមត្រកូល

ប្ដី ឬ ប្រពន្ធ ដែលបានប្ដូរនាមត្រកូលថ្មី ដោយអាពាហ៍ពិពាហ៍ អាចប្រើនាមត្រកូលដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍វិញបាន ឬ អាចប្រើនាមត្រកូលដែលបានប្រើនៅក្រោយពេលលែងលះគ្នាក៏បាន ។

កថាភាគទី ២
នីតិវិធីនៃការលែងលះគ្នា

មាត្រា ៩៨២.- បណ្តឹងនៃការលែងលះគ្នា

១-ពាក្យបណ្តឹងលែងលះគ្នា អាចដាក់ទៅតុលាការដែលមានសមត្ថកិច្ច ដោយយោងតាមបញ្ញត្តិមាត្រា ១០(សមត្ថកិច្ចសាលាជម្រះក្តីពិសេសលើរឿងក្តីលែងលះគ្នា និង រឿងក្តីអំពីបុគ្គភាព) នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន ។

២-ភាគីអាចដាក់ពាក្យសុំលែងលះគ្នា ទៅក្រុមប្រឹក្សាឃុំសង្កាត់ ខាងលំនៅឋាន ឬទីសំណាក់ ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ និងទី ៣ នៃមាត្រា ១០ (សមត្ថកិច្ចសាលាជម្រះក្តីពិសេសលើរឿងក្តីលែងលះគ្នា និងរឿងក្តីអំពីបុគ្គភាព) នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន ។ ក្នុងករណីនេះ ក្រុមប្រឹក្សាឃុំសង្កាត់ អាចធ្វើការបញ្ចុះបញ្ចូលឱ្យសះជាគ្នាបាន ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំនោះ ។ បើមិនអាចបញ្ចុះបញ្ចូលឱ្យសះជាគ្នាបានទេ ត្រូវចាត់ទុកថាមានពាក្យបណ្តឹងលែងលះគ្នា ហើយក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវបញ្ជូនពាក្យបណ្តឹងនោះ ទៅតុលាការជាបន្ទាន់ ។

មាត្រា ៩៨៣.- ការចាត់ចែងរក្សាការពារ

តុលាការដែលទទួលពាក្យបណ្តឹងលែងលះគ្នា ក្នុងករណីចាំបាច់ អាចចេញដីកាសម្រេចបង្គាប់ឱ្យធ្វើការចាត់ចែងរក្សាការពារ ចំពោះការបំបែកលំនៅ ការគ្រប់គ្រងថែរក្សាកូន ការគ្រប់គ្រងរក្សាទ្រព្យសម្បត្តិ អាហារកាតព្វកិច្ចរបស់សហព័ទ្ធ បន្ទុកនៃសោហ៊ុយ អាពាហ៍ពិពាហ៍ និងសោហ៊ុយចិញ្ចឹមបីបាច់កូន ជាអាទិ៍ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិបាន ។

មាត្រា ៩៨៤.- ការសាកល្បងផ្សះផ្សា ដោយតុលាការ

១-ទោះបីជាភាគីម្ខាងទាមទារយ៉ាងខ្លាំង ចំពោះការលែងលះគ្នាក៏ដោយ តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន ។

២-បើការផ្សះផ្សាពុំអាចសម្រេចបានទេ តុលាការត្រូវយកបណ្តឹងលែងលះគ្នាមកធ្វើការវិនិច្ឆ័យ ដើម្បីធ្វើការប្រកាសសាលក្រម ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ជំពូកទី ៤

ឪពុកម្តាយ និង កូន

ផ្នែកទី ១

បុត្តភាព

កថាភាគទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ៩៨៥._ ករណីយកិច្ចនៃការសុំចុះកំណើត

១-ឪពុក ឬ ម្តាយរបស់កូន ត្រូវសុំចុះកំណើតរបស់កូន នៅសាលាឃុំសង្កាត់នៃលំនៅឋានរបស់ឪពុក ឬ ម្តាយ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពី ថ្ងៃដែលកូននោះកើត ។ ប្រសិនបើឪពុក ឬ ម្តាយមិនអាចសុំចុះបានទេ ញាតិជានីតិជនដែលរស់នៅជាមួយឪពុកម្តាយនៃកូន ត្រូវសុំចុះកំណើតរបស់កូននោះឱ្យ បានឆាប់រហ័ស ។

២-ក្នុងករណីដែលឪពុកម្តាយបានធ្វេសប្រហែសនឹងករណីយកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដោយគ្មានមូលហេតុត្រឹមត្រូវនឹងត្រូវពិន័យស៊ីវិលជាប្រាក់មិនលើសពី ១០.០០០ (មួយម៉ឺន) រៀល ។

មាត្រា ៩៨៦._ វិធីគណនាអាយុ

១-អាយុត្រូវគណនាដោយគិតចាប់ពីថ្ងៃកំណើត ។

២-បញ្ញត្តិនៃមាត្រា ៣៣៩ (ការគណនាអំឡុងពេលតាមប្រតិទិនសុរិយគតិ) នៃក្រមនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការគណនាអាយុ ។

កថាភាគទី ២

ការសម្រេចអំពីបុត្តភាព

មាត្រា ៩៨៧._ មាតុភាព

ស្ត្រីដែលបានសម្រាលកូន គឺជាម្តាយរបស់កូន ។

មាត្រា ៩៨៨.- ការសន្មតបិតុភាព

១-ទារកនៅក្នុងគភ៌ប្រពន្ធដែលមាននៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ត្រូវសន្មតថាជាកូនរបស់ប្តី ។

២-កូនដែលបានកើតនៅក្រោយអំឡុងពេល ១៨០ (មួយរយប៉ែតសិប) ថ្ងៃ គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍ ត្រូវបានបង្កើត ឬ ក្នុងអំឡុងពេល ៣០០ (បីរយ) ថ្ងៃ គិតចាប់ពីថ្ងៃដែលបានរំលាយ ឬ លុបចោលអាពាហ៍ពិពាហ៍ ត្រូវសន្មតថាមានគភ៌នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍នោះ ។

៣-ក្នុងករណីដែលស្ត្រីបានរៀបអាពាហ៍ពិពាហ៍ថ្មីទៀតផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៩៥០ (អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត) នៃក្រមនេះ បានបង្កើតកូនប្រសិនបើមិនអាចកំណត់ឪពុករបស់កូននោះ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ខាងលើនេះទេ ត្រូវសន្មតថា កូននោះជាកូនរបស់ប្តីដែលបានរៀបអាពាហ៍ពិពាហ៍ក្រោយ ។

មាត្រា ៩៨៩.- ការបដិសេធបិតុភាព

នៅក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ៩៨៨ (ការសន្មតបិតុភាព) ខាងលើនេះ ជនដែលត្រូវបានសន្មតថាជាឪពុក ឬ កូន អាចបដិសេធបិតុភាពបាន ។

មាត្រា ៩៩០.- បណ្តឹងបដិសេធបិតុភាពពីជនដែលត្រូវបានសន្មតថាជាឪពុក

១-សិទ្ធិបដិសេធរបស់ជនដែលត្រូវបានសន្មតថាជាឪពុកដែលបានកំណត់នៅក្នុងមាត្រា ៩៨៩(ការបដិសេធបិតុភាព) ខាងលើនេះ ត្រូវអនុវត្តដោយបណ្តឹងចំពោះកូន ។

២-ជនដែលត្រូវបានសន្មតថាជាឪពុក ត្រូវដាក់ពាក្យបណ្តឹងបដិសេធបិតុភាពក្នុងអំឡុងពេល៦ (ប្រាំមួយ) ខែ គិតចាប់ពីពេលដែលខ្លួនបានដឹងអំពីកំណើតរបស់កូន ។

៣-នៅពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះបានកន្លងផុត បើជនដែលត្រូវបានសន្មតថាជាឪពុក ជាជនដែលនៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេលនោះត្រូវគណនា ដោយគិតចាប់ពីពេលដែលមានការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ២៧(ការលុបចោល ការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

(តទៅរាជកិច្ច លេខ ០៦)

មាត្រា ៩៩១.- បណ្តឹងបដិសេធបិតុភាពពីកូន

១-សិទ្ធិបដិសេធរបស់កូន ដែលបានកំណត់នៅក្នុងមាត្រា ៩៨៩ (ការបដិសេធបិតុភាព) នៃក្រមនេះ ត្រូវអនុវត្តដោយបណ្តឹងចំពោះជនដែលត្រូវបានសន្មតថាជាឪពុក ។

២-ក្នុងករណីដែលកូនដែលជាអនីតិជន ប្រើសិទ្ធិបដិសេធ បើកូននោះគ្មានម្តាយ ដែលអនុវត្តអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនទេ តុលាការត្រូវជ្រើសតាំងអ្នកតំណាងពិសេស ។

៣-កូន មិនអាចអនុវត្តសិទ្ធិបដិសេធបានឡើយ ប្រសិនបើអំឡុងពេល ៦ (ប្រាំមួយ) ខែ បានកន្លងផុត គិតចាប់ពីពេលដែលខ្លួនបានក្លាយជានីតិជន ។

៤-នៅពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ បានកន្លងផុត បើកូនជាជននៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេលនោះត្រូវគណនា ដោយគិតចាប់ពីពេលដែលមានការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅដែលបានកំណត់នៅក្នុងមាត្រា ២៧ (ការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

មាត្រា ៩៩២.- អានុភាពប្រតិសកម្មនៃបណ្តឹងបដិសេធបិតុភាព

ការបដិសេធបិតុភាព ត្រូវបង្កើតអានុភាពប្រតិសកម្មតាំងពីពេលកំណើតរបស់កូន ។

កថាភាគទី ៣

ការទទួលស្គាល់

មាត្រា ៩៩៣.- ការទទួលស្គាល់ដោយស្ម័គ្រចិត្ត

ឪពុករបស់កូន អាចទទួលស្គាល់កូនបាន ។ ប៉ុន្តែ ប្រសិនបើកូននោះមានឪពុកតាមផ្លូវច្បាប់រួចហើយ ពុំអាចទទួលស្គាល់បានឡើយ ។

មាត្រា ៩៩៤.- សមត្ថភាពក្នុងការទទួលស្គាល់

ដើម្បីទទួលស្គាល់ ទោះបីជាឪពុកជាអនីតិជន ឬ ជាជននៅក្រោមអាណាព្យាបាលទូទៅក៏ដោយ ក៏ពុំចាំបាច់មានការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់ឡើយ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

មាត្រា ៩៩៥.- ការទទួលស្គាល់របស់ឪពុក

១-ឪពុកអាចទទួលស្គាល់កូនដែលជាអនីតិជនបាន ។

២-ទោះជាទារកនៅក្នុងគភ៌ក៏ដោយ ក៏ឪពុកអាចទទួលស្គាល់កូននោះបានដោយទទួលការយល់ព្រមពីម្ដាយ ។

មាត្រា ៩៩៦.- ការទទួលស្គាល់កូនជានីតិជន និង កូនដែលបានទទួលមរណភាព

១-ឪពុកដែលមានបំណងចង់ទទួលស្គាល់កូនដែលជានីតិជន មិនអាចទទួលស្គាល់បានឡើយ បើគ្មានការយល់ព្រមពីកូននោះ ។

២-ឪពុកអាចទទួលស្គាល់កូនដែលបានទទួលមរណភាពបាន តែក្នុងករណីដែលកូននោះមានបច្ឆាញាតិផ្ទាល់ ។ ក្នុងករណីនេះ បើបច្ឆាញាតិផ្ទាល់នោះជានីតិជន ត្រូវទទួលការយល់ព្រមពីជននោះ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៩៩៧ (ទម្រង់នៃការទទួលស្គាល់) ខាងក្រោមនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការយល់ព្រមដែលបានកំណត់នៅ ក្នុងកថាខណ្ឌទី ១ និង ទី ២ នៃមាត្រានេះ ។

មាត្រា ៩៩៧.- ទម្រង់នៃការទទួលស្គាល់

១-ការទទួលស្គាល់ នឹងត្រូវធ្វើឡើងដោយការជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាន ។ ការទទួលស្គាល់ ក៏អាចធ្វើតាមមតកសាសន៍ក៏បានដែរ ។

២-ការយល់ព្រមរបស់ម្ដាយដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ នៃមាត្រា ៩៩៥ (ការទទួលស្គាល់របស់ឪពុក) ខាងលើនេះ អាចធ្វើបាន ដោយចុះហត្ថលេខាលើលិខិតទទួលស្គាល់នោះ ។

មាត្រា ៩៩៨.- អានុភាពនៃការចុះកំណើតនៅក្នុងសៀវភៅកំណើតនិងការទទួលស្គាល់

បើបុគ្គលណាម្នាក់បានសុំចុះកំណើតរបស់កូន បានចុះឈ្មោះខ្លួនជាឪពុក ហើយបានចុះហត្ថលេខា ឬ ផ្តិតមេដៃ នៅក្នុងសៀវភៅកំណើត បុគ្គលនោះត្រូវចាត់ទុកថាបានទទួលស្គាល់កូននោះ នៅពេលដែលបានសុំចុះកំណើត ។

ROYAUME DU CAMBODGE
LE MINISTRE du PALAIS ROYAL

មាត្រា ៩៩៩.- អានុភាពប្រតិសកម្មនៃការទទួលស្គាល់

ការទទួលស្គាល់កូន ត្រូវមានអានុភាពប្រតិសកម្មតាំងពីពេលកំណើតរបស់កូននោះ ។ ប៉ុន្តែ ការទទួលស្គាល់ពុំអាចបំពានសិទ្ធិដែលតតិយជនបានធ្វើលទ្ធកម្មរួចហើយឡើយ ។

មាត្រា ១០០០.- ការហាមឃាត់មិនឱ្យដកការទទួលស្គាល់ចេញ

ឪពុកដែលបានទទួលស្គាល់កូនហើយពុំអាចលុបចោលការទទួលស្គាល់នោះបានឡើយ ។

មាត្រា ១០០១.- បណ្តឹងទាមទារឱ្យទទួលស្គាល់

១-កូន អាចដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់បាន ។ ប៉ុន្តែ កូនដែលមិនបានយល់ព្រម តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៩៩៦ (ការទទួលស្គាល់កូនជានីតិជន និង កូនដែលបានទទួលមរណភាព) នៃក្រមនេះ ពុំអាចទាមទារឱ្យទទួលស្គាល់បានឡើយ ។

២-ប្រសិនបើកូនបានទទួលមរណភាព បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់បាន ។

៣-កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់បានក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ដោយគិតចាប់ពីពេលដែលបានដឹងថាជាឪពុក ។

៤-ក្នុងករណីដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ ជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ នៅពេលដែលខ្លួនបានដឹងថាជាឪពុក អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវគណនា គិតចាប់ពីពេលដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ បានក្លាយជានីតិជន ឬ ពេលដែលមានការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ២៧ (ការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

៥-កូន ឬ បច្ឆាញាតិផ្ទាល់របស់កូន អាចដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់បាន នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃមរណភាពរបស់ឪពុក ប្រសិនបើបានដឹងថាជាឪពុកនៅក្រោយមរណភាពរបស់ឪពុក ។

៦-បណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ អ្នកតំណាងដែលច្បាប់[illegible]របស់កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ទទួលស្គាល់ ជំនួសជនទាំងនោះបាន ។

កថាភាគទី ៤
បណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព

មាត្រា ១០០២.- បណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព

១-កូន អាចដាក់ពាក្យបណ្តឹងទៅតុលាការ ឱ្យបញ្ជាក់អំពីនត្ថិភាពនៃបិតុភាព ឬ មាតុភាព ចំពោះជនដែលត្រូវបានចុះជាឪពុកនៅក្នុងសៀវភៅកំណើត ទោះជាមិនបានទទួលការសន្មតថាជាឪពុកក៏ដោយ ឬ ជនដែលត្រូវបានចុះជាម្តាយនៅក្នុងសៀវភៅកំណើត ទោះជាគ្មានហេតុដែលបានសម្រាលក៏ដោយ ។

២-ជនដែលត្រូវបានចុះជាឪពុកនៅក្នុងសៀវភៅកំណើត ទោះជាមិនបានទទួលការសន្មតថាជាឪពុកក៏ដោយ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបិតុភាពជាមួយកូនបាន ។

៣-ជនដែលត្រូវបានចុះជាម្តាយនៅក្នុងសៀវភៅកំណើត ទោះជាមិនបានសម្រាលកូននោះក៏ដោយ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃមាតុភាពជាមួយកូនបាន ។

៤-បណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ និង ទី ៣ ខាងលើនេះ ពុំអាចដាក់បានឡើយ ប្រសិនបើបិតុភាព ឬ មាតុភាពតាមផ្លូវច្បាប់ កើតឡើងដោយចេតនា ឬ កំហុសធ្ងន់ធ្ងររបស់ជនដែលត្រូវបានចុះជាឪពុក ឬ ម្តាយ នៅក្នុងសៀវភៅ ឬ បើអំឡុងពេល ២០ (ម្ភៃ) ឆ្នាំបានកន្លងផុត គិតចាប់ពីថ្ងៃកំណើតរបស់កូន ឬ ថ្ងៃដែលអានុភាព នៃការទទួលស្គាល់បានកើតឡើង ។

៥-ប្រសិនបើកូនជាអនីតិជន ឪពុក ឬ ម្តាយ ដែលមិនមែនជាភាគីម្ខាងទៀតនៃបណ្តឹង ត្រូវធ្វើជាតំណាងឱ្យកូន ។ បើគ្មានឪពុកម្តាយ បើឪពុកម្តាយមិនអាចធ្វើជាតំណាងបាន ឬ បើបណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាពត្រូវបានធ្វើឡើងចំពោះឪពុកម្តាយទាំងសងខាងជាភាគីម្ខាងទៀតនៃបណ្តឹង តុលាការត្រូវជ្រើសតាំងអ្នកតំណាងពិសេស ។

មាត្រា ១០០៣.- អានុភាពប្រតិសកម្មនៃការបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព

ការបញ្ជាក់នត្ថិភាពនៃបុត្តភាព ត្រូវមានអានុភាពប្រតិសកម្ម តាំងពីពេលកំណើតរបស់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

កូននោះ ។ ប៉ុន្តែ អានុភាពប្រតិសកម្មនោះ ពុំអាចបំពានសិទ្ធិដែលតតិយជនបានលទ្ធកម្មរួចហើយ ឡើយ ។

កថាភាគទី ៥
បណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព

មាត្រា ១០០៤.- បណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ពីកូន

១-កូនអាចដាក់ពាក្យបណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ចំពោះស្ត្រីដែលបានបង្កើតខ្លួនបាន ។

២-ប្រសិនបើកូន បានទទួលមរណភាព បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ។

៣-កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ដោយគិតចាប់ពីពេលដែលបានដឹងថាជាម្តាយ ។

៤-ក្នុងករណីដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ ជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ នៅពេលដែលបានដឹងថាជាម្តាយ អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ បានក្លាយជានីតិជន ឬ ពេលដែលមានការលុបចោល ការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ២៧ (ការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

៥-កូន ឬ បច្ឆាញាតិផ្ទាល់របស់កូន អាចដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃមរណភាពរបស់ម្តាយ ប្រសិនបើបានដឹងថាជាម្តាយ នៅក្រោយមរណភាពរបស់ម្តាយ ។

៦-បណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ អ្នកតំណាងដែលបានតាមច្បាប់របស់កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ជំនួសជនទាំងនោះបាន ។

ROYAUME DU CAMBODGE LE MINISTRE du PALAIS ROYAL

មាត្រា ១០០៥.- បណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពពីម្តាយ

១-ម្តាយ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យ បញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ចំពោះកូនដែលខ្លួនបានបង្កើតបាន ។

២-ម្តាយអាចដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះចំពោះកូនដែលបានទទួលមរណភាព បាន តែក្នុងករណីដែលកូននោះមានបច្ឆាញាតិផ្ទាល់ ។

៣-ម្តាយ ត្រូវដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បានក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ដោយគិតចាប់ពីពេលដែលខ្លួនបានដឹងថាជាកូន ។

៤-ម្តាយ អាចដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បាននៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃមរណភាពរបស់កូន ប្រសិនបើបានដឹងថាជាកូននៅក្រោយមរណភាពរបស់កូន ។

៥-ប្រសិនបើម្តាយជាជននៅក្រោមអាណាព្យាបាលទូទៅ នៅពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌ ទី ៣ និង ទី ៤ ខាងលើនេះ បានកន្លងផុត អំឡុងពេលនៃកថា-ខណ្ឌទី ៣ និង ទី ៤ ខាងលើនេះ ត្រូវគណនា ដោយគិតចាប់ពីពេលដែលមានការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ២៧ (ការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

៦-ក្នុងករណីដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូន ដែលជាភាគីម្ខាងនៃបណ្តឹងជានីតិជន បើគ្មានការយល់ព្រមពីកូន ឬ បច្ឆាញាតិផ្ទាល់នោះទេ ម្តាយមិនអាចដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បានឡើយ ។

៧-ទោះបីជាក្នុងករណីដែលអង្គហេតុនៃការបង្កើតកូន ត្រូវបានបញ្ជាក់ក៏ដោយ ប្រសិនបើការបញ្ជាក់មាតុភាពផ្ទុយនឹងផលប្រយោជន៍របស់កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ តុលាការអាចលើកចោលបណ្តឹងរបស់ម្តាយបាន ។

មាត្រា ១០០៦.- អានុភាពប្រតិសកម្មនៃការបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព

ការបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពត្រូវមានអានុភាពប្រតិសកម្ម តាំងពីពេលកំណើតរបស់កូននោះ ។ ប៉ុន្តែ អានុភាពប្រតិសកម្មនោះ ពុំអាចបំពានសិទ្ធិដែលតតិយជនបានលទ្ធកម្មហើយនោះឡើយ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ផ្នែកទី ២

សុំកូន

កថាភាគទី ១

សុំកូនពេញលេញ

មាត្រា ១០០៧.– ឧក្រិដ្ឋនៃការបង្កើតសុំកូនពេញលេញ

បើយល់ឃើញថា មានល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងបញ្ញត្តិចាប់ពីមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្ដីប្រពន្ធ) ដល់មាត្រា ១០១២ (មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ) ខាងក្រោមនេះ តុលាការអាចបង្កើតសុំកូនពេញលេញ ដោយបញ្ចប់ញាតិភាពជាមួយនឹងញាតិលោហិតនៃឪពុកម្ដាយបង្កើត តាមពាក្យសុំរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមបាន ។

មាត្រា ១០០៨.– សុំកូនដោយសហការរវាងប្ដីប្រពន្ធ

១-បុគ្គលដែលក្លាយជាឪពុក ឬ ម្ដាយចិញ្ចឹម ត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ ។

២-ប្ដី ឬ ប្រពន្ធតែម្ខាង ពុំអាចក្លាយជាឪពុក ឬ ម្ដាយចិញ្ចឹមបានឡើយ ប្រសិនបើសហព័ទ្ធម្ខាងទៀត មិនក្លាយជាម្ដាយ ឬ ឪពុកចិញ្ចឹម ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលប្ដីប្រពន្ធណាម្ខាង ក្លាយជាឪពុក ឬ ម្ដាយចិញ្ចឹមរបស់កូនបង្កើតនៃសហព័ទ្ធម្ខាងទៀត ។

មាត្រា ១០០៩.– អាយុរបស់ឪពុកម្ដាយចិញ្ចឹម

ឪពុកម្ដាយចិញ្ចឹម ត្រូវមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ)ឆ្នាំ ឡើងទៅ ហើយត្រូវមានអាយុច្រើនជាងកូនសុំយ៉ាងតិច ២០ (ម្ភៃ) ឆ្នាំ ។

មាត្រា ១០១០.– អាយុរបស់កូនសុំ

ជាគោលការណ៍ កូនសុំត្រូវមានអាយុតិចជាង ៨ (ប្រាំបី) ឆ្នាំ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

មាត្រា ១០១១.- ការយល់ព្រមរបស់ឪពុកម្តាយ

ដើម្បីបង្កើតសុំកូនពេញលេញ ត្រូវមានការយល់ព្រមពីឪពុកម្តាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន របស់កុមារដែលនឹងក្លាយជាកូនសុំនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលឪពុកម្តាយនោះ មិនអាចបង្ហាញឆន្ទៈបាន ឬ ករណីដែលមានការធ្វើបាបដោយឪពុកម្តាយ ការបោះបង់កូនចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀត ដែលបំពានផលប្រយោជន៍របស់កុមារដែលនឹងក្លាយជាកូនសុំនោះយ៉ាងធ្ងន់ធ្ងរ ។

មាត្រា ១០១២.- មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ

សុំកូនពេញលេញ ត្រូវបានបង្កើតឡើង នៅក្នុងករណីដែលមានការពិបាកយ៉ាងខ្លាំង ឬ មិនសមរម្យ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ដោយឪពុក ម្តាយបង្កើត ឬ មានស្ថានភាពពិសេសផ្សេងៗទៀត បើយល់ឃើញថាមានភាពចាំបាច់ ពិសេសដើម្បីផលប្រយោជន៍របស់កូននោះ ។

មាត្រា ១០១៣.- អំឡុងពេលសាកល្បងចិញ្ចឹម

ដើម្បីបង្កើតសុំកូនពេញលេញ តុលាការត្រូវពិចារណាលើស្ថានភាពដែលបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមបានធ្វើក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំជាគោលការណ៍ យ៉ាងតិច ៦ (ប្រាំមួយ) ខែ ។

មាត្រា ១០១៤.- ការបញ្ចប់នូវញាតិភាពជាមួយនឹងឪពុកម្តាយបង្កើត

ញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះ ត្រូវបញ្ចប់ ដោយសុំកូនពេញលេញ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះញាតិភាពជាមួយនឹងឪពុកម្តាយម្ខាងទៀត និង ញាតិលោហិតរបស់ឪពុកម្តាយម្ខាងទៀតនោះ ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ២ នៃមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្តីប្រពន្ធ) នៃក្រមនេះ ។

មាត្រា ១០១៥.- អានុភាពនៃសុំកូនពេញលេញ

ដោយបង្កើតសុំកូនពេញលេញ កូនសុំត្រូវទទួលបាននូវឋានៈដូចគ្នានឹងកូនបង្កើត

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

របស់ឪពុកម្តាយចិញ្ចឹម និង ត្រូវទទួលបាននូវសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្តាយចិញ្ចឹម ។

២-កូនសុំ អាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬ នាមត្រកូលមុនស្មុំកូនបាន ។

៣-កូនសុំ ត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម ។ ប៉ុន្តែ ក្នុងករណីដែលប្តីប្រពន្ធណាម្ខាង ក្លាយជាឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹមរបស់កូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុកបង្កើត ឬ ម្តាយបង្កើត និង ឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម ។

មាត្រា ១០១៦.- ការកាត់កាល់នៃស្មុំកូនពេញលេញ

១-បើយល់ឃើញថាមានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់កូនសុំ តុលាការអាចកាត់កាល់ភាគីនៃស្មុំកូនបាន តាមពាក្យសុំរបស់កូនសុំ ឪពុកម្តាយបង្កើត ឬ តំណាងអយ្យការ លុះត្រាតែក្នុងករណីដែលត្រូវនឹងចំណុចទាំងអស់ ដែលកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-បើមានការធ្វើបាបដោយឪពុកម្តាយចិញ្ចឹម បោះបង់កូនសុំចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀតដែលបំពានផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ ។

ខ-បើឪពុកម្តាយបង្កើតអាចគ្រប់គ្រងថែរក្សាដោយសមរម្យ ។

២-ការកាត់កាល់ ពុំអាចធ្វើបានឡើយ ក្រៅពីយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ខាងលើនេះ ។

មាត្រា ១០១៧.- អានុភាពនៃការកាត់កាល់ស្មុំកូនពេញលេញ

ញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះ ដែលត្រូវបានបញ្ចប់ ដោយស្មុំកូនពេញលេញ ត្រូវកើតឡើងវិញ គិតចាប់ពីថ្ងៃកាត់កាល់ ។

មាត្រា ១០១៨.- ការចុះបញ្ជី និង ការរក្សាការសម្ងាត់នៃស្មុំកូនពេញលេញ

ប្រសិនបើបានបង្កើតស្មុំកូនពេញលេញ បញ្ជីកំណើតរបស់កូនសុំត្រូវធ្វើជាថ្មី ។ ប៉ុន្តែ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

នៅក្នុងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្រកំណើត ឬ ឯកសារដកស្រង់នៃបញ្ជីកំណើតមិនត្រូវសរសេរចំណុចស្តីពីសុំកូនឡើយ ។

មាត្រា ១០១៩.- សិទ្ធិដឹងអំពីកំណើតខ្លួនរបស់កូនសុំពេញលេញ

កូនសុំពេញលេញ ដែលបានក្លាយជានីតិជន អាចទាមទារឱ្យបង្ហាញនូវព័ត៌មានក្នុងទំហំដែលចាំបាច់ ចំពោះតុលាការដែលរក្សាទុកនូវសំណុំរឿងស្តីពីសុំកូនបាន ។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានគោលបំណងមិនត្រឹមត្រូវ ។ ចំពោះការរក្សាទុកសំណុំរឿង និង វិធីទាមទារឱ្យបង្ហាញជាអាទិ៍ត្រូវកំណត់នៅក្នុងបទប្បញ្ញត្តិរបស់តុលាការ ។

កថាភាគទី ២

សុំកូនធម្មតា

មាត្រា ១០២០.- ពាក្យសុំនៃសុំកូនធម្មតា

១-បុគ្គលដែលមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ) ឆ្នាំ ឡើងទៅ អាចដាក់ពាក្យសុំជាមួយនឹងបុគ្គលដែលនឹងក្លាយជាកូនសុំ ទៅតុលាការ ឱ្យបង្កើតសុំកូនធម្មតាបាន ។ ប៉ុន្តែ បុគ្គលដែលនឹងក្លាយជាកូនសុំ មិនត្រូវជាបុព្វញាតិរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយ ចិញ្ចឹម ឬ បុគ្គលដែលមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមឡើយ ។

២-ក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ត្រូវដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងនាមជាអ្នកតំណាងដែលច្បាប់បានកំណត់ ។

មាត្រា ១០២១.- ករណីដែលបុគ្គលដែលនឹងក្លាយជាឪពុក ឬ ម្តាយចិញ្ចឹមមានសហព័ទ្ធ

បើបុគ្គលដែលមានសហព័ទ្ធ សុំកូនដែលជាអនីតិជន បុគ្គលនោះត្រូវដាក់ពាក្យសុំដែលបានកំណត់នៅក្នុងមាត្រា ១០២០ (ពាក្យសុំនៃសុំកូនធម្មតា) ខាងលើនេះ ជាមួយនឹងសហព័ទ្ធរបស់ខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលយកកូនរបស់សហព័ទ្ធមកធ្វើជាកូនសុំ ឬ ករណីដែលសហព័ទ្ធមិនអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ក្រសួងព្រះបរមរាជវាំង

មាត្រា ១០២២.- ការយល់ព្រមរបស់សហព័ទ្ធ

ចំពោះបុគ្គលដែលមានសហព័ទ្ធ ដើម្បីដាក់ពាក្យសុំនៃសុំកូនធម្មតា ត្រូវទទួលការយល់ព្រមពីសហព័ទ្ធរបស់ខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលដាក់ពាក្យសុំដែលបានកំណត់នៅក្នុងមាត្រា ១០២០(ពាក្យសុំនៃសុំកូនធម្មតា) ខាងលើនេះ ជាមួយនឹងសហព័ទ្ធ ឬ ករណីដែលសហព័ទ្ធមិនអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន ។

មាត្រា ១០២៣.- មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនធម្មតា

១-តុលាការ អាចឱ្យបង្កើតសុំកូនបាន លុះត្រាតែករណីដែលអាចបញ្ជាក់អំពីឆន្ទៈពិតប្រាកដរបស់ភាគី ក្នុងការបង្កើតទំនាក់ទំនងរវាងឪពុកម្តាយ និង កូន ។

២-តុលាការមិនត្រូវឱ្យបង្កើតសុំកូនឡើយ បើយល់ឃើញថា សុំកូនត្រូវបានបំពានក្នុងគោលបំណងរៀបអាពាហ៍ពិពាហ៍ រវាងភេទផ្សេងគ្នា ឬ ភេទដូចគ្នា ឬ ក្នុងគោលបំណងមិនត្រឹមត្រូវផ្សេងទៀត ។

មាត្រា ១០២៤.- ករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន

១-បើបុគ្គលដែលនឹងក្លាយជាកូនសុំជាអនីតិជន តុលាការអាចឱ្យបង្កើតសុំកូនបាន លុះត្រាតែយល់ឃើញថា មានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់អនីតិជននោះ ។

២-ក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំជាអនីតិជន បើឪពុកម្តាយបង្កើតរបស់បុគ្គលនោះបានលែងលះហើយ តុលាការត្រូវសួរយោបល់របស់ឪពុក ឬ ម្តាយ ដែលមិនមែនជាអ្នកមានអំណាចមេបា ដើម្បីវិនិច្ឆ័យអំពីចំណុចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

៣-បើអនីតិជនបានដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ដើម្បីបង្កើតសុំកូន ត្រូវទទួលការយល់ព្រមពីអនីតិជននោះ ។ ទោះបីជាអនីតិជននោះមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ក៏ដោយ បើអនីតិជននោះអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន តុលាការត្រូវសួរយោបល់របស់អនីតិជននោះ ដើម្បីវិនិច្ឆ័យអំពីចំណុចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា ១០២៥.- ស្មុំកូន រវាងអ្នកអាណាព្យាបាល និង ជននៅក្រោមអាណាព្យាបាល

ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដាក់ពាក្យសុំឱ្យបង្កើតស្មុំកូនដោយយកអនីតិជននៅក្រោមអាណាព្យាបាលរបស់ខ្លួនមកធ្វើជាកូនសុំ ឬ ក្នុងករណីដែលអ្នកអាណាព្យាបាលទូទៅ ដាក់ពាក្យសុំឱ្យបង្កើតស្មុំកូន ដោយយកជននៅក្រោមអាណាព្យាបាលទូទៅរបស់ខ្លួនមកធ្វើជាកូនសុំ តុលាការអាចឱ្យបង្កើតស្មុំកូនបាន លុះត្រាតែក្នុងករណីដែលបានអនុវត្តត្រឹមត្រូវ ក្នុងការគ្រប់គ្រងថែរក្សាជននៅក្រោមអាណាព្យាបាល និង ការគ្រប់គ្រងទ្រព្យសម្បត្តិ ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលតួនាទីរបស់អ្នកអាណាព្យាបាលបានចប់ តែមិនទាន់បានបញ្ចប់ការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រង ។

មាត្រា ១០២៦.- អានុភាពនៃស្មុំកូនធម្មតា ចំពោះបុត្តភាព

១-ទោះបីជាមានការបង្កើតស្មុំកូនធម្មតាក៏ដោយ ញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើត ត្រូវបន្តអត្ថិភាព ហើយកូនសុំ និង ឪពុកម្តាយបង្កើតមានសិទ្ធិធ្វើសន្តតិកម្មគ្នាទៅវិញទៅមក ។

២-កូនសុំ និង ឪពុកម្តាយបង្កើត មានសិទ្ធិទាមទារ និង ករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច ។

មាត្រា ១០២៧.- អានុភាពនៃស្មុំកូន ក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្តាយចិញ្ចឹម ជាអាទិ៍

១-បញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ១០១៥ (អានុភាពនៃស្មុំកូនពេញលេញ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះស្មុំកូនធម្មតា ។

២-កូនសុំ អាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬ នាមត្រកូលមុនស្មុំកូនបាន ។

៣-ក្នុងករណីដែលកូនសុំជាអនីតិជន កូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម ឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម ។ ប៉ុន្តែ ក្នុងករណីដែលយកកូនបង្កើតរបស់សហព័ទ្ធមកធ្វើជាកូនសុំ កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុក ឬ ម្តាយចិញ្ចឹម និង សហព័ទ្ធនោះ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

មាត្រា ១០២៨.- ពាក្យសុំឱ្យកាត់កាល់សុំកូនធម្មតា

១-ភាគីនៃសុំកូន អាចដាក់ពាក្យសុំទៅតុលាការឱ្យកាត់កាល់សុំកូនបាន ក្នុងករណីដែលភាគីសងខាងព្រមព្រៀងអំពីការកាត់កាល់នោះ ។

២-ក្នុងករណីដែលកូនសុំជាអនីតិជន ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើង ដោយឪពុកម្តាយចិញ្ចឹម និង បុគ្គលដែលត្រូវក្លាយជាអ្នកតំណាងដែលច្បាប់បានកំណត់ ក្រោយពេលកាត់កាល់ ។ ប៉ុន្តែ បើកូនសុំដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ហើយ ត្រូវទទួលការយល់ព្រមពីកូនសុំនោះ ។ ទោះបីជាអនីតិជននោះមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ក៏ដោយ បើអនីតិជននោះអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន តុលាការត្រូវសួរយោបល់របស់អនីតិជននោះ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បើឪពុកម្តាយបង្កើតរបស់កូនសុំបានលែងលះគ្នាហើយ ឪពុកម្តាយបង្កើតរបស់កូនសុំនោះ ត្រូវពិភាក្សា និង កំណត់ថា ឪពុក ឬ ម្តាយបង្កើតជាបុគ្គលដែលត្រូវក្លាយជាអ្នកមានអំណាចមេបា នៅក្រោយពេលកាត់កាល់ ។

៤-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់បុគ្គលដែលត្រូវក្លាយជាអ្នកមានអំណាចមេបា ដោយគិតពិចារណាទៅលើផលប្រយោជន៍របស់កូន ។

មាត្រា ១០២៩.- ការកាត់កាល់រវាងប្តីប្រពន្ធដែលបានសុំកូនដោយសហការនិងកូនសុំជាអនីតិជន

ក្នុងករណីដែលប្តីប្រពន្ធដែលបានសុំកូនដោយសហការគ្នាជាឪពុកម្តាយចិញ្ចឹម ដើម្បីកាត់កាល់កូនសុំជាអនីតិជន ប្តីប្រពន្ធត្រូវដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១០២៨ (ពាក្យសុំឱ្យកាត់កាល់សុំកូនធម្មតា) ខាងលើនេះ ជាមួយគ្នា ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះប្តីប្រពន្ធណាម្ខាងមិនអាចបង្ហាញឆន្ទៈរបស់ខ្លួន ។

មាត្រា ១០៣០.- ការវិនិច្ឆ័យអំពីការកាត់កាល់សុំកូនធម្មតា

បើមានពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១០២៨ (ពាក្យសុំឱ្យកាត់កាល់សុំកូនធម្មតា) ខាងលើនេះ តុលាការអាចសម្រេចឱ្យកាត់កាល់សុំកូនបាន លុះត្រា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

តែបានបញ្ជាក់ថា ភាគីសងខាងមានបំណងពិតប្រាកដ ក្នុងការរំលាយទំនាក់ទំនងរវាងឪពុកម្តាយ និង កូន ។

មាត្រា ១០៣១.- មូលហេតុនៃការកាត់កាល់

១-ភាគីម្ខាងនៃសុំកូន អាចដាក់ពាក្យបណ្តឹងទាមទារឱ្យកាត់កាល់បាន លុះត្រាតែក្នុងករណីខាងក្រោមនេះ :

ក-បើត្រូវបានបោះបង់ចោល ដោយភាគីម្ខាងទៀត ដោយទុច្ចរិត ។

ខ-បើមិនច្បាស់ ក្នុងអំឡុងពេលយ៉ាងតិច ១ (មួយ) ឆ្នាំ ថាភាគីម្ខាងទៀតនៅរស់ ឬ ទទួលមរណភាព ។

គ-បើមានហេតុធ្ងន់ធ្ងរផ្សេងទៀត ដែលបណ្តាលឱ្យមានការពិបាកក្នុងការបន្តសុំកូន ។

២-ក្នុងអំឡុងពេលដែលកូនសុំពុំទាន់ក្លាយជានីតិជន ឪពុកម្តាយចិញ្ចឹម មិនអាចដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះកូនសុំបានឡើយ ។

៣-បើកូនសុំជាអនីតិជន បញ្ញត្តិចាប់ពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ នៃមាត្រា១០២៨ (ពាក្យសុំឱ្យកាត់កាល់សុំកូនធម្មតា) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះករណីដែលកូនសុំដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះឪពុកម្តាយចិញ្ចឹម ។

មាត្រា ១០៣២.- អានុភាពនៃការកាត់កាល់សុំកូនធម្មតា

១-អានុភាពទាំងឡាយនៃសុំកូនធម្មតា ត្រូវបញ្ចប់ឆ្ពោះទៅអនាគត ដោយការកាត់កាល់ ។

២-ក្រោយការកាត់កាល់ កូនសុំអាចទទួលវិញ នូវនាមត្រកូលមុនសុំកូនក៏បាន ឬ អាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹមក៏បាន ។

មាត្រា ១០៣៣.- ការចុះបញ្ជីនៃសុំកូនធម្មតា និង លិខិតបញ្ជាក់កំណើត

ប្រសិនបើបានបង្កើតសុំកូនធម្មតា ត្រូវសរសេរការបង្កើតសុំកូនធម្មតានៅលើរឹមទំព័រនៃបញ្ជីកំណើតដើមរបស់កូនសុំនោះ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ជំពូកទី ៥
អំណាចមេបា
ផ្នែកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ១០៣៤.- អត្ថន័យនៃអំណាចមេបា

អ្នកដែលមានអំណាចមេបា មានសិទ្ធិ និង ករណីយកិច្ច ត្រូវបីបាច់រក្សារូបកាយរបស់កូនដែលជាអនីតិជន និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ ។

មាត្រា ១០៣៥.- អំណាចមេបាលើកូនសុំ

អ្នកដែលមានអំណាចមេបាលើកូនសុំ គឺឪពុកម្តាយចិញ្ចឹម ។

មាត្រា ១០៣៦.- គោលការណ៍នៃការសហការប្រើប្រាស់អំណាចមេបា

ឪពុកម្តាយដែលមានចំណងអាពាហ៍ពិពាហ៍ ត្រូវប្រើប្រាស់អំណាចមេបាដោយសហការគ្នា ។ ប៉ុន្តែ បើឪពុក ឬ ម្តាយណាម្ខាង ពុំអាចប្រើប្រាស់អំណាចមេបាបានទេ ឪពុក ឬ ម្តាយម្ខាងទៀតត្រូវប្រើអំណាចមេបានោះ ។

ផ្នែកទី ២
ការសម្រេចអំពីអ្នកមានអំណាចមេបា ក្នុងករណីលែងលះគ្នា និង ការទទួលស្គាល់

មាត្រា ១០៣៧.- ការសម្រេចអំពីអ្នកមានអំណាចមេបា នៅពេលលែងលះគ្នា

១-បើឪពុកម្តាយលែងលះគ្នា ត្រូវកំណត់យកឪពុក ឬ ម្តាយណាម្ខាង ជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយ ។

២-ក្នុងករណីដែលឪពុកម្តាយបានលែងលះគ្នានៅមុនកំណើតរបស់កូន ម្តាយគឺជាអ្នកមានអំណាចមេបាចំពោះកូនដែលបានកើតមកនោះ ។ ប៉ុន្តែ នៅក្រោយកំណើតរបស់កូនអាចកំណត់យកឪពុកជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយបាន ។

៣-បើការពិភាក្សានៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ ខាងលើនេះ ពុំបានសម្រេច ឬ បើ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់អ្នកមានអំណាចមេបា ដោយពិចារណាទៅលើផលប្រយោជន៍របស់កូននោះ ។

មាត្រា ១០៣៨.- ទំនាក់ទំនងរវាងការទទួលស្គាល់ និង អំណាចមេបា

១-អ្នកមានអំណាចមេបាលើកូន ដែលម្តាយមិនទាន់បានរៀបអាពាហ៍ពិពាហ៍បានបង្កើត គឺម្តាយ ។

២-ឪពុក អាចប្រើប្រាស់អំណាចមេបា ចំពោះកូនដែលខ្លួនបានទទួលស្គាល់បានតែក្នុងករណីដែលការពិភាក្សារបស់ឪពុកម្តាយបានកំណត់យកឪពុកនោះ ជាអ្នកមានអំណាចមេបា ។

៣-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចធ្វើការពិភាក្សានោះបានទេ តុលាការត្រូវកំណត់អ្នកមានអំណាចមេបាតាមការទាមទាររបស់ឪពុក ឬ ម្តាយ ។

៤-ក្រោយពេលដែលឪពុកបានទទួលស្គាល់កូនហើយ ប្រសិនបើឪពុកម្តាយបានរៀបអាពាហ៍ពិពាហ៍ ឪពុកម្តាយត្រូវអនុវត្តអំណាចមេបា ដោយសហការគ្នា ។

មាត្រា ១០៣៩.- ការផ្លាស់ប្តូរអ្នកដែលមានអំណាចមេបា

នៅក្នុងករណីនៃបញ្ញត្តិមាត្រា ១០៣៧ (ការសម្រេចអំពីអ្នកមានអំណាចមេបា នៅពេលលែងលះគ្នា) និង មាត្រា ១០៣៨ (ទំនាក់ទំនងរវាងការទទួលស្គាល់ និង អំណាចមេបា) ខាងលើនេះ តុលាការអាចផ្លាស់ប្តូរអ្នកដែលមានអំណាចមេបា តាមការទាមទាររបស់ញាតិនៅក្នុង ៤ (បួន) ថ្នាក់របស់កូនបាន ប្រសិនបើទទួលស្គាល់ថាចាំបាច់ ដើម្បីផលប្រយោជន៍របស់កូន ។

មាត្រា ១០៤០.- សិទ្ធិ និង ករណីយកិច្ចរបស់ឪពុកម្តាយដែលមិនរស់នៅជាមួយកូន

១-ឪពុក ឬ ម្តាយ ដែលពុំមានអំណាចមេបា ក្រោយពេលលែងលះគ្នា មានសិទ្ធិចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន និង មានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយ ដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ។

២-ឪពុកម្តាយដែលមានបំណងចង់លែងលះគ្នា ត្រូវពិភាក្សា និង កំណត់អំពីរបៀបចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន និង សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
1455

ថែរក្សាកូន ។

៣-ឪពុកដែលមិនបានរស់នៅជាមួយកូនដែលបានទទួលស្គាល់អាចពិភាក្សា និងកំណត់ជាមួយម្តាយ អំពីរបៀបចូលជួបប្រាស្រ័យទាក់ទង និង សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូនបាន ។

៤-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ និង ទី ៣ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចធ្វើការពិភាក្សាបានទេ តុលាការត្រូវកំណត់អំពីរបៀបចូលជួបប្រាស្រ័យទាក់ទង និង សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូនតាមការទាមទាររបស់ឪពុក ឬ ម្តាយ ។

៥-បើទទួលស្គាល់ថាចាំបាច់ដើម្បីផលប្រយោជន៍របស់កូន តុលាការអាចផ្លាស់ប្តូររបៀបចូលជួបប្រាស្រ័យទាក់ទង និង សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូនតាមការទាមទាររបស់ឪពុក ឬ ម្តាយបាន ។

៦-នៅក្នុងការសម្រេចសេចក្តីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ និង ទី ៥ ខាងលើនេះ តុលាការត្រូវកំណត់អំពីការចូលជួបប្រាស្រ័យទាក់ទងដោយយកផលប្រយោជន៍របស់កូនជាអាទិភាព និង ត្រូវកំណត់អំពីសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន ដោយគិតពិចារណាទៅលើស្ថានភាពនៃជីវភាព និង ស្ថានភាពសេដ្ឋកិច្ចរបស់ឪពុកម្តាយ ។

៧-ប្រសិនបើឪពុក ឬ ម្តាយ មិនអាចពិភាក្សា ឬ មិនអាចទាមទារទៅតុលាការបានទេ ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់កូនអាចធ្វើការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ និង ទី ៥ ខាងលើនេះបាន ។

មាត្រា ១០៤១.- សិទ្ធិទាមទារឱ្យរាយការណ៍អំពីស្ថានភាពរបស់កូន

១-ឪពុក ឬ ម្តាយ ដែលពុំមានអំណាចមេបាលើកូន អាចទាមទារឱ្យអ្នកដែលមានអំណាចមេបា រាយការណ៍អំពីស្ថានភាពរបស់កូននោះបាន ។

២-ចំពោះខ្លឹមសារ និង របៀបរបបនៃការរាយការណ៍ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវកំណត់តាមការពិភាក្សារវាងឪពុកម្តាយ ។ ប៉ុន្តែ បើការពិភាក្សាពុំបានសម្រេច ឬ បើពុំអាចធ្វើការពិភាក្សាបានទេ តុលាការអាចសម្រេចសេចក្តី ជំនួសការពិភាក្សា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
៣០០/៤៨

តាមការទាមទាររបស់ឪពុក ឬ ម្តាយបាន ។

៣-ញាតិក្នុង ៤ (បួន) ថ្នាក់ របស់កូន អាចទាមទារឱ្យរាយការណ៍អំពីស្ថានភាពរបស់កូនចំពោះអ្នកមានអំណាចមេបាបាន ។

មាត្រា ១០៤២.- ករណីយកិច្ចពិភាក្សាអំពីចំណុចសំខាន់ៗទាក់ទងទៅនឹងកូន

លើកលែងតែករណីដែលមានភាពចាំបាច់បន្ទាន់ អ្នកដែលមានអំណាចមេបា ត្រូវពិភាក្សាជាមួយឪពុក ឬ ម្តាយ ដែលពុំមានអំណាចមេបា អំពីចំណុចដែលទាក់ទងទៅនឹងកូនដូចមានកំណត់ខាងក្រោមនេះ :

ក-ការអប់រំរបស់កូនដែលហួសពីកម្រិតនៃកាតព្វកិច្ចអប់រំដែលជាករណីយកិច្ចកំណត់ដោយច្បាប់ ។

ខ-ការផ្លាស់ប្តូរទីសំណាក់របស់កូន ពីខេត្ត-ក្រុងមួយ ទៅខេត្ត-ក្រុងមួយទៀត ។

គ-វិជ្ជាជីវៈ ឬ អាជីវកម្មរបស់កូន ។

ឃ-សកម្មភាពព្យាបាល ដែលទាក់ទងដល់អាយុជីវិតរបស់កូន ។

ង-ការចាត់ចែងទ្រព្យសម្បត្តិសំខាន់របស់កូន ។

ច-ចំណុចសំខាន់ៗផ្សេងទៀត ដែលទាក់ទងទៅនឹងការគ្រប់គ្រងថែរក្សាកូន និង ទ្រព្យសម្បត្តិរបស់កូន ។

ផ្នែកទី ៣
សិទ្ធិ និង ករណីយកិច្ចរបស់អ្នកដែលមានអំណាចមេបា

មាត្រា ១០៤៣.- ការអប់រំកូន

អ្នកមានអំណាចមេបា មានសិទ្ធិ និង ករណីយកិច្ចអប់រំកូន ។

មាត្រា ១០៤៤.- ទីសំណាក់របស់កូន

ទីសំណាក់របស់កូន ត្រូវកំណត់នៅទីកន្លែងដែលអ្នកមានអំណាចមេបាបានកំណត់ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

មាត្រា ១០៤៥.- ការដាក់ទណ្ឌកម្មកូន

អ្នកមានអំណាចមេបា អាចដាក់ទណ្ឌកម្មកូនដោយខ្លួនឯង នៅក្នុងទំហំដែលចាំបាច់បាន ។

មាត្រា ១០៤៦.- ការអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈ និង អាជីវកម្ម

១-កូន មិនអាចប្រកបវិជ្ជាជីវៈបានឡើយ បើមិនបានទទួលការអនុញ្ញាតពីអ្នកមានអំណាចមេបា ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ២ មាត្រា ២០ (អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម) នៃក្រមនេះ អ្នកមានអំណាចមេបា អាចលុបចោល ឬ កម្រិតការអនុញ្ញាត ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ នេះបាន ។

មាត្រា ១០៤៧.- ការទាមទារឱ្យប្រគល់កូន

១-អ្នកមានអំណាចមេបា អាចទាមទារឱ្យតតិយជន ដែលមិនព្រមប្រគល់កូន ដោយផ្ទុយនឹងច្បាប់ប្រគល់កូនបាន ។

២-អ្នកមានអំណាចមេបា អាចទាមទារឱ្យឪពុក ឬ ម្តាយ ដែលពុំមានអំណាចមេបាប្រគល់កូនបាន ។

ផ្នែកទី ៤
ការព្យួរ និង ការដកហូតអំណាចមេបា

មាត្រា ១០៤៨.- ការប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបា

បើឪពុក ឬ ម្តាយដែលអនុវត្តអំណាចមេបា បានបំពានសិទ្ធិអំណាចក្នុងនាមជាអ្នកមានអំណាចមេបា ឬ បើបានធ្វេសប្រហែសក្នុងការបំពេញករណីយកិច្ចក្នុងនាមជាអ្នកមានអំណាចមេបា តុលាការអាចប្រកាសព្យួរ ឬ ការដកហូតអំណាចមេបា តាមការទាមទាររបស់ញាតិក្នុង ៤ (បួន) ថ្នាក់ របស់កូន មេឃុំ ឬ ចៅសង្កាត់ នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការបាន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា ១០៤៩.- ការលុបចោលនូវការប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបា

បើមូលហេតុដែលបានកំណត់ក្នុងមាត្រា ១០៤៨ (ការប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបា) ខាងលើនេះ បានបញ្ចប់ហើយ តុលាការអាចលុបចោលការប្រកាសការព្យួរ ឬ ការដកហូតសិទ្ធិអំណាចក្នុងនាមជាអ្នកមានអំណាចមេបា តាមការទាមទាររបស់សាមីជនដែលបានទទួលការប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបា ឬ ញាតិក្នុង ៤ (បួន) ថ្នាក់របស់ជននោះបាន ។

មាត្រា ១០៥០.- ការលាឈប់ និង បដិទានរបស់អ្នកមានអំណាចមេបា

១-បើមានមូលហេតុដែលពុំអាចជៀសវាងបាន ឪពុក ឬ ម្តាយ ដែលអនុវត្តអំណាចមេបាអាចលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបាបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

២-បើមូលហេតុដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានបញ្ចប់ហើយ ឪពុក ឬ ម្តាយ ដែលបានលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា អាចទទួលបដិទាននូវអំណាចមេបានោះវិញបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

មាត្រា ១០៥១.- ការផ្លាស់ប្តូរអ្នកមានអំណាចមេបា

១-ក្នុងករណីដែលឪពុកម្តាយតែម្ខាង ជាអ្នកមានអំណាចមេបា ហើយកូនបានធ្លាក់ទៅក្នុងស្ថានភាពដែលពុំមានអ្នកមានអំណាចមេបា ដោយសារអ្នកនោះត្រូវបានប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបា ឬ បានលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា តុលាការអាចយកឪពុក ឬ ម្តាយ ដែលពុំមានអំណាចមេបាមកធ្វើជាអ្នកមានអំណាចមេបារបស់កូនបាន ។

២-ប្រសិនបើមានការចាំបាច់ ញាតិក្នុង ៤ (បួន) ថ្នាក់ របស់កូន អាចទាមទារឱ្យធ្វើការប្រកាសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ។

៣-នៅពេលលែងលះគ្នា ប្រសិនបើឪពុក ឬ ម្តាយ ដែលធ្វើជាអ្នកមានអំណាចមេបារបស់កូនតាមការពិភាក្សា បានទទួលមរណភាព ប្រសិនបើកូនពុំមានអ្នកមានអំណាចមេបាទេ ឪពុក ឬ ម្តាយ ដែលពុំបានធ្វើជាអ្នកមានអំណាចមេបា ត្រូវក្លាយជាអ្នកមានអំណាចមេបា ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា ១០៥២.- ការចាប់ផ្តើមអាណាព្យាបាលសម្រាប់អនីតិជន

១-បើមានស្ថានភាពដែលពុំមានអ្នកមានអំណាចមេបា ចំពោះកូន តាមបញ្ញត្តិនៃមាត្រា ១០៤៨(ការប្រកាសការល្បួរ ឬ ការដកហូតអំណាចមេបា) ឬ កថាខណ្ឌទី ១ នៃមាត្រា ១០៥០ (ការលាឈប់ និង បដិទានរបស់អ្នកមានអំណាចមេបា) ហើយបើពុំបានផ្លាស់ប្តូរអ្នកមានអំណាចមេបា តាមបញ្ញត្តិនៃមាត្រា ១០៥១(ការផ្លាស់ប្តូរអ្នកមានអំណាចមេបា) ខាងលើនេះទេ អាណាព្យាបាលសម្រាប់អនីតិជនចំពោះកូននោះ ត្រូវចាប់ផ្តើមតាមបញ្ញត្តិនៃមាត្រា ១០៦៧ (មូលហេតុនៃការចាប់ផ្តើមអាណាព្យាបាលសម្រាប់អនីតិជន) ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ មាត្រា ១០៦៨ (អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានកំណត់ អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំង និង មូលដ្ឋាននៃការជ្រើសតាំង) ។

ផ្នែកទី ៥

សិទ្ធិអំណាចគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន

មាត្រា ១០៥៣.- ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង

អ្នកមានអំណាចមេបា មានសិទ្ធិ និង ករណីយកិច្ច ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន និង ក្នុងការតំណាងឱ្យកូននោះ ចំពោះសកម្មភាពដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិនោះ ។ ប៉ុន្តែ បើសកម្មភាពរបស់អ្នកមានអំណាចមេបាបង្កើតកាតព្វកិច្ចដែលមានកម្មវត្ថុជាសកម្មភាពរបស់កូននោះ អ្នកមានអំណាចមេបា ត្រូវទទួលការយល់ព្រមពីកូននោះ ។

មាត្រា ១០៥៤.- សកម្មភាពដែលអ្នកមានអំណាចមេបាតែម្ខាងបានធ្វើក្នុងនាមជាអ្នកមានអំណាចមេបាទាំងសងខាង

១-បើឪពុក ឬ ម្តាយណាម្ខាង ក្នុងចំណោមអ្នកមានអំណាចមេបារួម ធ្វើសកម្មភាពណាមួយដោយគ្មានសិទ្ធិ ក្នុងនាមជាអ្នកមានអំណាចមេបាទាំងសងខាង ទោះជាសកម្មភាពនោះផ្ទុយនឹងឆន្ទៈរបស់ឪពុក ឬ ម្តាយម្ខាងទៀតក៏ដោយ អានុភាពនៃសកម្មភាពនោះពុំត្រូវបានរាំងខ្ទប់ឡើយ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

14/456

ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីម្ខាងទៀតនៃសកម្មភាពនោះមានបំណងទុច្ចរិត ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលឪពុក ឬ ម្តាយណាម្ខាង ក្នុងចំណោមអ្នកមានអំណាចមេបារួមបានយល់ព្រមឱ្យកូនធ្វើសកម្មភាពណាមួយ ទោះបីជាសកម្មភាពនោះផ្ទុយនឹងឆន្ទៈរបស់ឪពុក ឬ ម្តាយម្ខាងទៀតក៏ដោយ ។

មាត្រា ១០៥៥.- ករណីយកិច្ចប្រុងប្រយ័ត្ន នៅក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ

អ្នកមានអំណាចមេបា ត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

មាត្រា ១០៥៦.- ការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ

បើកូន បានក្លាយជានីតិជនហើយ អ្នកមានអំណាចមេបា ត្រូវគណនានូវចំណូល ចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ ដោយគ្មានការយឺតយ៉ាវ ។ ប៉ុន្តែ សោហ៊ុយចិញ្ចឹមបីបាច់កូននោះ និង សោហ៊ុយគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ ត្រូវចាត់ទុកថាបានទូទាត់ជាមួយនឹងផលចំណូលពីទ្រព្យសម្បត្តិរបស់កូននោះ ។

មាត្រា ១០៥៧.- បញ្ញត្តិពិសេស

បញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃមាត្រា ១០៥៦ (ការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ) ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះទ្រព្យសម្បត្តិដែលត្រូវបានផ្តល់ដោយមិនគិតថ្លៃទៅឱ្យកូន ដោយតតិយជនដែលបានបង្ហាញឆន្ទៈផ្ទុយនឹង វាក្យខណ្ឌទី ២ នៃមាត្រា ១០៥៦ នោះ ។

មាត្រា ១០៥៨.- ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យកូន

១-ប្រសិនបើតតិយជនដែលបានផ្តល់ទ្រព្យសម្បត្តិឱ្យទៅកូនដោយមិនគិតថ្លៃ បានបង្ហាញឆន្ទៈថា មិនឱ្យឪពុកម្តាយណាម្ខាង ឬ ទាំងសងខាង ដែលអនុវត្តអំណាចមេបាគ្រប់គ្រងទ្រព្យសម្បត្តិនោះទេ ទ្រព្យសម្បត្តិនោះ ពុំត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឪពុកម្តាយណាម្ខាង ឬ ទាំងសងខាងឡើយ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

២-ក្នុងករណីដែលអ្នកមានអំណាចមេបា ពុំបានអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើតតិយជនពុំបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិនោះទេ តុលាការអាចជ្រើសតាំងអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិនោះ តាមការទាមទាររបស់កូន ញាតិក្នុង ៤ (បួន) ថ្នាក់ របស់កូន ឬ តំណាងអយ្យការបាន ។

៣-ទោះបីជាតតិយជនបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិក៏ដោយ បញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាដែរ នៅក្នុងករណីដែលសិទ្ធិអំណាចរបស់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិនោះបានរលត់ ឬ មានការចាំបាច់ ត្រូវផ្លាស់ប្តូរអ្នកនោះ តែតតិយជននោះ មិនបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិផ្សេងទៀត ។

៤-បញ្ញត្តិចាប់ពីមាត្រា ៣៧(ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយតុលាការ) រហូតដល់មាត្រា ៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ និងទី ៣ ខាងលើនេះ ។

មាត្រា ១០៥៩.- ការអនុវត្តដូចគ្នានៃបញ្ញត្តិស្តីពីអាណត្តិ

បញ្ញត្តិនៃមាត្រា ៦៥០(ករណីយកិច្ចសង្គ្រោះបន្ទាន់របស់អាណត្តិគាហក នៅក្រោយពេលបញ្ចប់អាណត្តិ) និងមាត្រា ៦៥១ (ល័ក្ខខ័ណ្ឌតតាំងនៃការបញ្ចប់អាណត្តិ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកមានអំណាចមេបា ជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន និង ករណីដែលបានកំណត់នៅក្នុងមាត្រា ១០៥៨ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យកូន) ខាងលើនេះ ។

មាត្រា ១០៦០.- អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិ រវាងឪពុកម្តាយ និង កូន

១-សិទ្ធិលើបំណុលដែលកើតឡើងរវាងអ្នកមានអំណាចមេបា និង កូន ចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិ ត្រូវរលត់ដោយអាជ្ញាយុកាល បើពុំបានអនុវត្តសិទ្ធិនោះ ក្នុងអំឡុងពេល ៣(បី) ឆ្នាំ គិតចាប់ពីពេលដែលសិទ្ធិអំណាចនៃការអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិបានរលត់ ។

២-ក្នុងករណីដែលសិទ្ធិអំណាចក្នុងការអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិបានរលត់ នៅក្នុងពេលដែលកូនពុំទាន់ក្លាយជានីតិជន បើកូនពុំមានអ្នកតំណាងដែលច្បាប់បានកំណត់អំឡុង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវគណនាអំឡុងពេល ដោយគិតចាប់ពីពេលដែលកូននោះក្លាយជានីតិជន ឬ ពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់ដែលស្នងបន្តនោះ បានឡើងកាន់តំណែង ។

ផ្នែកទី ៦

ការព្យួរ និង ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ

មាត្រា ១០៦១.- ការប្រកាសការព្យួរ ឬ ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ

បើអ្នកមានអំណាចមេបា បានធ្វើឱ្យអន្តរាយដល់ទ្រព្យសម្បត្តិរបស់កូន ដោយសារការគ្រប់គ្រងមិនត្រឹមត្រូវ តុលាការអាចប្រកាសព្យួរ ឬ ដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រង តាមការទាមទាររបស់ញាតិក្នុង ៤ (បួន) ថ្នាក់ របស់កូន មេឃុំ ឬ ចៅសង្កាត់ នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការបាន ។

មាត្រា ១០៦២.- ការលុបចោលការប្រកាសការព្យួរ និង ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ

បើមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ១០៦១ (ការប្រកាសការព្យួរ ឬ ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ) ខាងលើនេះ បានបញ្ចប់ហើយ តុលាការអាចលុបចោលការប្រកាសការព្យួរ ឬ ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ តាមការទាមទាររបស់សាមីជនដែលបានទទួលការប្រកាសការព្យួរ ឬ ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ ឬ ញាតិក្នុង ៤ (បួន) ថ្នាក់ របស់ជននោះបាន ។

មាត្រា ១០៦៣.- ការលាឈប់ និង បដិទាននៃការគ្រប់គ្រងទ្រព្យសម្បត្តិ

១-បើមានមូលហេតុពុំអាចជៀសវាងបាន អ្នកមានអំណាចមេបា អាចលាឈប់ពីសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

២-បើមូលហេតុដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បានបញ្ចប់ហើយ អ្នកមានអំណាចមេបាដែលបានលាឈប់ពីសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិអាចទទួល

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

បដិទានន្ទូវសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិនោះវិញបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

មាត្រា ១០៦៤.- ករណីដែលពុំមានអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិ

បើពុំមានអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិ តាមបញ្ញត្តិនៃមាត្រា ១០៦១ (ការប្រកាសការព្យួរ ឬ ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ) ឬ កថាខណ្ឌទី ១ នៃមាត្រា ១០៦៣ (ការលាឈប់ និង បដិទាននៃការគ្រប់គ្រងទ្រព្យសម្បត្តិ) ខាងលើនេះទេ តុលាការត្រូវសម្រេចសេចក្តីជ្រើសតាំងអ្នកតំណាងពិសេសឱ្យកូន ។

មាត្រា ១០៦៥.- ករណីដែលផលប្រយោជន៍របស់អ្នកមានអំណាចមេបា និង កូនមានភាពផ្ទុយគ្នា

១-ចំពោះសកម្មភាពដែលផលប្រយោជន៍របស់អ្នកមានអំណាចមេបា និង កូនមានភាពផ្ទុយគ្នា អ្នកមានអំណាចមេបា ត្រូវទាមទារឱ្យតុលាការជ្រើសតាំងអ្នកតំណាងពិសេសសម្រាប់កូន ។

២-ក្នុងករណីដែលអ្នកមានអំណាចមេបា អនុវត្តអំណាចមេបាចំពោះកូនច្រើននាក់ ចំពោះសកម្មភាពដែលផលប្រយោជន៍របស់កូនម្នាក់នោះ និង កូនផ្សេងទៀត មានភាពផ្ទុយគ្នា អ្នកមានអំណាចមេបា ត្រូវទាមទារឱ្យតុលាការជ្រើសតាំងអ្នកតំណាងពិសេសសម្រាប់កូនណាម្នាង ។

ផ្នែកទី ៧

ការយកមកអនុវត្តដូចគ្នានៃជំពូកនេះ

មាត្រា ១០៦៦.- អ្នកជំនួសអំណាចមេបា

ចំពោះកូនរបស់អនីតិជនដែលមិនទាន់បានរៀបអាពាហ៍ពិពាហ៍ អ្នកមានអំណាចមេបារបស់អនីតិជននោះ ត្រូវអនុវត្តអំណាចមេបាជំនួស ។ ក្នុងករណីនេះ បញ្ញត្តិនៃជំពូកទី ៥ (អំណាចមេបា) នេះត្រូវយកមកអនុវត្តផងដែរ ចំពោះអ្នកដែលអនុវត្តអំណាចមេបាជំនួស ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ជំពូកទី ៦

អាណាព្យាបាល

ផ្នែកទី ១

អាណាព្យាបាលសម្រាប់អនីតិជន

កថាភាគទី ១

ការចាប់ផ្ដើមអាណាព្យាបាលសម្រាប់អនីតិជន

មាត្រា ១០៦៧.- មូលហេតុនៃការចាប់ផ្ដើមអាណាព្យាបាលសម្រាប់អនីតិជន

ប្រសិនបើគ្មានអ្នកអនុវត្តអំណាចមេបាចំពោះអនីតិជនទេ អាណាព្យាបាលសម្រាប់អនីតិជន ត្រូវចាប់ផ្ដើម ។

កថាភាគទី ២

អ្នកអាណាព្យាបាលសម្រាប់អនីតិជន

មាត្រា ១០៦៨.- អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានកំណត់អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំង និង មូលដ្ឋាននៃការជ្រើសតាំង

១-អ្នកដែលអនុវត្តអំណាចមេបាចុងក្រោយបង្អស់ចំពោះអនីតិជន អាចកំណត់អ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមមតកសាសន៍បាន ។

២-ប្រសិនបើគ្មានអ្នកត្រូវធ្វើជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះទេ តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមការទាមទាររបស់ញាតិនៅក្នុង ៤(បួន) ថ្នាក់ របស់អនីតិជន មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់អនីតិជន នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការបាន ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលខ្វះអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

៣- ដើម្បីជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន តុលាការត្រូវគិតពិចារណាអំពីស្ថានភាពផ្លូវកាយ និង ផ្លូវចិត្ត និង ស្ថានភាពជីវភាព និង ទ្រព្យសម្បត្តិរបស់អនីតិជនវិជ្ជា-

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ជីវៈ និង ប្រវត្តិរូបរបស់អ្នកដែលត្រូវធ្វើជាអ្នកអាណាព្យាបាលសម្រាប់ អនីតិជន និង អត្ថិភាព ឬ នត្ថិភាព នៃទំនាក់ទំនងទៅនឹងផលប្រយោជន៍ រវាងអ្នកធ្វើជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អនីតិជន យោបល់របស់អនីតិជន និង ស្ថានភាពផ្សេងទៀតទាំងស្រុង ។

មាត្រា ១០៦៩.- ករណីយកិច្ចជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន

ប្រសិនបើខ្វះអ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំងតាមបញ្ញត្តិ នៃកថាខណ្ឌទី ២ មាត្រា ១០៥២ (ការចាប់ផ្តើមអាណាព្យាបាលសម្រាប់អនីតិជន) នៃក្រមនេះ តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនថ្មីទៀតឱ្យបានឆាប់រហ័ស ។

មាត្រា ១០៧០.- ចំនួននៃអ្នកអាណាព្យាបាលសម្រាប់អនីតិជន

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានតែម្នាក់ ។ ប៉ុន្តែ ចំពោះអនីតិជននៅក្រោមអាណាព្យាបាលដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី បើត្រូវចាប់ផ្តើមអាណាព្យាបាលទូទៅតាមមាត្រា ២៤ (ការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមនេះ អ្នកអាណាព្យាបាលទូទៅម្នាក់អាចត្រូវបានជ្រើសតាំងបាន ក្រៅពីអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

២-បញ្ញត្តិស្តីពីអាណាព្យាបាលទូទៅ នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអាណាព្យាបាលទូទៅសម្រាប់អនីតិជន លើកលែងតែមាត្រា ១១២០ (ករណីដែលអ្នកអាណាព្យាបាលទូទៅ មានច្រើននាក់) ។

មាត្រា ១០៧១.- ការលាឈប់នៃអ្នកអាណាព្យាបាលសម្រាប់អនីតិជន

ប្រសិនបើមានមូលហេតុត្រឹមត្រូវ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចលាឈប់បាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

មាត្រា ១០៧២.- ករណីយកិច្ចជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន

ប្រសិនបើអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានលាឈប់ តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនថ្មីទៀតឱ្យបានឆាប់រហ័ស ។

ROYAUME DU CAMBODGE * MINISTRE DU PALAIS ROYAL *

មាត្រា ១០៧៣.- ការបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន

ប្រសិនបើអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានធ្វើអំពើពុំត្រឹមត្រូវ ឬ មានហេតុផ្សេងទៀតដែលមិនសមរម្យនឹងភារកិច្ចជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន តុលាការអាចបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះបាន តាមការទាមទាររបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ញាតិនៅក្នុង ៤ (បួន) ថ្នាក់របស់អនីតិជន នៅក្រោមអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការ ឬ អាចបញ្ឈប់ដោយឆន្ទានុសិទ្ធិបាន ។

មាត្រា ១០៧៤.- បុគ្គលដែលមិនអាចក្លាយជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន

បុគ្គលដែលកំណត់ក្នុងចំណុចខាងក្រោមនេះ ពុំអាចធ្វើជាអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានឡើយ :

ក-អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិត្តូបត្ថម្ភ ។

ខ-អ្នកតំណាងដែលច្បាប់បានកំណត់ និង ហិត្តូបត្ថម្ភកៈ ព្រមទាំងអ្នកត្រួតពិនិត្យជនទាំងនោះ ដែលធ្លាប់ត្រូវបានតុលាការដកចេញ ។

គ-ជនដែលក្ស័យធន ។

ឃ-ជនដែលគ្មានដំណឹងអំពីទីរស់នៅ ។

កថាភាគទី ៣

អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន

មាត្រា ១០៧៥.- អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានកំណត់ និង អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដែលត្រូវបានជ្រើសតាំង

-១-អ្នកមានអំណាចមេបាដែលអាចកំណត់អ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចកំណត់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមមតកសាសន៍បាន ។

71/646.

២-ប្រសិនបើទទួលស្គាល់ថាចាំបាច់ នៅក្នុងករណីដែលគ្មានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដែលត្រូវបានកំណត់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះទេ តុលាការអាចជ្រើសតាំងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមការទាមទាររបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អនីតិជននៅក្រោមអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់អនីតិជន នៅក្រោមអាណាព្យាបាល នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការ ឬ ដោយឆន្ទានុសិទ្ធិបាន ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលខ្វះអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

មាត្រា ១០៧៦.- បុគ្គលដែលមិនអាចក្លាយជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន

សហព័ទ្ធ និង ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អនីតិជននៅក្រោមអាណាព្យាបាលពុំអាចធ្វើជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានឡើយ ។

មាត្រា ១០៧៧.- តួនាទីរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន

អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន មានតួនាទីដូចកំណត់ខាងក្រោមនេះ :

ក-ត្រួតពិនិត្យតួនាទីរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

ខ-ទាមទារឱ្យតុលាការជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនថ្មីទៀតដោយគ្មានការយឺតយ៉ាវ ក្នុងករណីដែលខ្វះអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

គ-ធ្វើការចាត់ចែងចាំបាច់ ចំពោះការគ្រប់គ្រងថែរក្សាអនីតិជននៅក្រោមអាណាព្យាបាល និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជននោះក្នុងករណីដែលមានស្ថានភាពបន្ទាន់ ។

ឃ-តំណាងឱ្យអនីតិជននៅក្រោមអាណាព្យាបាល ចំពោះសកម្មភាពដែលផលប្រយោជន៍របស់អនីតិជននៅក្រោមអាណាព្យាបាល និង អ្នកអាណាព្យាបាលសម្រាប់អនីតិជនមានភាពផ្ទុយគ្នា ។

ROYAUME du CAMBODGE
LE MINISTERE du PALAIS ROYAL

១៣៧/៤៤

មាត្រា ១០៧៨.- បញ្ញត្តិដែលត្រូវយកមកអនុវត្តដូចគ្នា

បញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ១០៦៨(អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានកំណត់ អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំង និង មូលដ្ឋាននៃការជ្រើសតាំង) មាត្រា ១០៧១(ការលាឈប់នៃអ្នកអាណាព្យាបាលសម្រាប់ អនីតិជន) មាត្រា ១០៧៣(ការបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) មាត្រា ១០៧៤(បុគ្គលដែលមិនអាចក្លាយជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន) កថាខណ្ឌទី ២ នៃមាត្រា ១០៨៧ (គម្រោងនៃចំនួនប្រាក់ចំណាយ និង សោហ៊ុយនៃអាណាព្យាបាលសម្រាប់ អនីតិជន) មាត្រា ១០៨៨ (កម្រៃរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) មាត្រា ១០៩៣(ករណីយកិច្ចប្រុងប្រយ័ត្នរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) មាត្រា ១១០០(ករណីយកិច្ចសង្គ្រោះបន្ទាន់របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ជាអាទិ៍ នៅក្រោយពេលបញ្ចប់អាណាព្យាបាលសម្រាប់អនីតិជន) និង មាត្រា ១១០១(ល័ក្ខខ័ណ្ឌតតាំងនៃការបញ្ចប់អាណាព្យាបាលសម្រាប់អនីតិជន ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

កថាភាគទី ៤
តួនាទីរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន

មាត្រា ១០៧៩.- សិទ្ធិ និង ករណីយកិច្ចរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន មានសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងអ្នកមានអំណាចមេបា ចំពោះចំណុចដែលបានកំណត់នៅក្នុងផ្នែកទី ៣(សិទ្ធិ និង ករណីយកិច្ចរបស់អ្នកដែលមានអំណាចមេបា) ជំពូកទី ៥ នៃគន្ថីទី ៧នេះ ។ ប៉ុន្តែ ដើម្បីផ្លាស់ប្តូរវិធីអប់រំ និង ទីសំណាក់ដែលត្រូវបានកំណត់ដោយអ្នកមានអំណាចមេបា ដាក់ទណ្ឌកម្មលើអនីតិជននៅក្រោមអាណាព្យាបាល អនុញ្ញាតឱ្យប្រកបអាជីវកម្ម លុបចោលការអនុញ្ញាតឱ្យប្រកបអាជីវកម្ម ឬ កម្រិតអាជីវកម្ម បើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវទទួលការយល់ព្រមពីអ្នកត្រួតពិនិត្យ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

២-ប្រសិនបើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវពិភាក្សាជាមួយនឹងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ចំពោះចំណុចដែលបានកំណត់នៅក្នុងមាត្រា ១០៤២ (ករណីយកិច្ចពិភាក្សាអំពីចំណុចសំខាន់ៗទាក់ទងនឹងកូន) នៃក្រមនេះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានភាពចាំបាច់បន្ទាន់ ។

មាត្រា ១០៨០.- ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជននៅក្រោមអាណាព្យាបាល ហើយត្រូវធ្វើជាតំណាងឱ្យអនីតិជននៅក្រោមអាណាព្យាបាល ចំពោះសកម្មភាពដែលទាក់ទងនឹងទ្រព្យសម្បត្តិរបស់អនីតិជននោះ ។

២-បញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃមាត្រា ១០៥៣ (ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

មាត្រា ១០៨១.- ការស្រាវជ្រាវទ្រព្យសម្បត្តិ និង ការធ្វើបញ្ជីសារពើភ័ណ្ឌ

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវចាប់ផ្តើមស្រាវជ្រាវទ្រព្យសម្បត្តិរបស់អនីតិជននៅក្រោមអាណាព្យាបាល ដោយគ្មានការយឺតយ៉ាវ នៅក្រោយពេលបានកាន់តំណែង ហើយត្រូវបញ្ចប់ការស្រាវជ្រាវនោះ នៅក្នុងអំឡុងពេល ៣ (បី) ខែ និង ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិនោះ ។ ប៉ុន្តែ អំឡុងពេលនេះ អាចពន្យារបាននៅតុលាការ ។

២-ប្រសិនបើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ការស្រាវជ្រាវទ្រព្យសម្បត្តិ និង ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិនោះ ពុំមានអានុភាពឡើយ បើគ្មានវត្តមានរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះទេ ។

មាត្រា ១០៨២.- សិទ្ធិអំណាចនៅមុនពេលធ្វើបញ្ជីសារពើភ័ណ្ឌ

រហូតដល់ពេលបញ្ចប់ការធ្វើបញ្ជីសារពើភ័ណ្ឌ អ្នកអាណាព្យាបាលសម្រាប់អនីតិជន មានសិទ្ធិអំណាច ចំពោះតែសកម្មភាពដែលមានភាពចាំបាច់បន្ទាន់ប៉ុណ្ណោះ ។ ប៉ុន្តែ សកម្មភាព

នេះមិនអាចតតាំងនឹងតតិយជនដែលសុចរិតបានឡើយ ។

មាត្រា ១០៨៣.- ការរាយការណ៍អំពីសិទ្ធិលើបំណុល និង កាតព្វកិច្ចរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ដែលមានចំពោះអនីតិជននៅក្រោម អាណាព្យាបាល

១-ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជន មានសិទ្ធិលើបំណុល ឬ កាតព្វកិច្ច ចំពោះអនីតិជននៅក្រោមអាណាព្យាបាល ប្រសិនបើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ត្រូវរាយការណ៍ជូនអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនអំពីសិទ្ធិលើបំណុល ឬ កាតព្វកិច្ចនោះ នៅមុនពេលចាប់ផ្តើមការស្រាវជ្រាវទ្រព្យសម្បត្តិ ។

២-ប្រសិនបើអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានដឹងថាមានសិទ្ធិលើបំណុល ចំពោះអនីតិជននៅក្រោមអាណាព្យាបាល តែបើមិនបានរាយការណ៍ទេ អ្នកអាណាព្យាបាលនោះ ត្រូវបាត់បង់សិទ្ធិលើបំណុលនោះ ។

មាត្រា ១០៨៤.- ការយកមកអនុវត្តដូចគ្នា ចំពោះករណីដែលអនីតិជននៅក្រោមអាណាព្យាបាល បានទទួលឆ្លកម្មនូវទ្រព្យសម្បត្តិសកល

បញ្ញត្តិនៃមាត្រា ១០៨១ (ការស្រាវជ្រាវទ្រព្យសម្បត្តិ និង ការធ្វើបញ្ជីសារពើភ័ណ្ឌ) មាត្រា ១០៨២ (សិទ្ធិអំណាចនៅមុនពេលធ្វើបញ្ជីសារពើភ័ណ្ឌ) និង មាត្រា ១០៨៣ (ការរាយការណ៍អំពីសិទ្ធិលើបំណុល និង កាតព្វកិច្ចរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ដែលមានចំពោះអនីតិជននៅក្រោមអាណាព្យាបាល) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអនីតិជននៅក្រោមអាណាព្យាបាល បានទទួលឆ្លកម្មនូវទ្រព្យសម្បត្តិសកល នៅក្រោយពេលដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានកាន់តំណែង ។

មាត្រា ១០៨៥.- ការអនុញ្ញាតឱ្យគ្រប់គ្រងទ្រព្យសម្បត្តិ

ដើម្បីលក់ ជួល រំលាយភតិសន្យា បង្កើតហ៊ីប៉ូតែក ឬ ធ្វើការចាត់ចែងផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា នូវអចលនវត្ថុដែលប្រើជាលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល ជំនួសអនីតិជននៅក្រោមអាណាព្យាបាល អ្នកអាណាព្យាបាលសម្រាប់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

5/៤៥៤

អនីតិជន ត្រូវទទួលការអនុញ្ញាតពីតុលាការ ។

មាត្រា ១០៨៦.- សកម្មភាពដែលផលប្រយោជន៍របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជននិង អនីតិជននៅក្រោមអាណាព្យាបាល មានភាពផ្ទុយគ្នា

បញ្ញត្តិនៃមាត្រា ១០៦៥ (ករណីដែលផលប្រយោជន៍របស់អ្នកមានអំណាចមេបា និង កូន មានភាពផ្ទុយគ្នា) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះអ្នកអាណាព្យាបាល សម្រាប់អនីតិជន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានអ្នក ត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

មាត្រា ១០៨៧.- គម្រោងនៃចំនួនប្រាក់ចំណាយ និង សោហ៊ុយនៃអាណាព្យាបាលសម្រាប់អនីតិជន

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវធ្វើគម្រោងចំនួនប្រាក់ដែលត្រូវចំណាយ ជារៀងរាល់ឆ្នាំ ដើម្បីគ្រប់គ្រងថែរក្សាអនីតិជននៅក្រោមអាណាព្យាបាល និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជននោះ នៅដំណាក់ដំបូងនៃពេលដែលបានចាប់ផ្ដើមកាន់តំណែង ។

២-សោហ៊ុយចាំបាច់ ដើម្បីអ្នកអាណាព្យាបាលសម្រាប់អនីតិជនបំពេញតួនាទីអាណាព្យាបាលសម្រាប់អនីតិជន ត្រូវចំណាយចេញពីទ្រព្យសម្បត្តិរបស់អនីតិជននៅក្រោមអាណាព្យាបាល ។

មាត្រា ១០៨៨.- កម្រៃរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន

តុលាការ អាចផ្ដល់កម្រៃសមរម្យ ពីក្នុងចំណោមទ្រព្យសម្បត្តិរបស់អនីតិជននៅក្រោមអាណាព្យាបាល ឱ្យទៅអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដោយគិតពិចារណាទៅលើលទ្ធភាពទ្រព្យធនរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អនីតិជននៅក្រោមអាណាព្យាបាល ព្រមទាំងស្ថានភាពផ្សេងទៀតបាន ។

មាត្រា ១០៨៩.- ការត្រួតពិនិត្យតួនាទីរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន

១-អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ តុលាការ អាចទាមទារឱ្យអ្នកអាណាព្យាបាលនោះ រាយការណ៍អំពីតួនាទីរបស់ខ្លួន ឬ ដាក់បញ្ជីសារពើភ័ណ្ឌ ឬ អាចស្រាវជ្រាវអំពីអនីតិជននៅក្រោមអាណាព្យាបាល ឬ ស្ថានភាពទ្រព្យសម្បត្តិរបស់អនីតិជននោះ នៅ

ពេលណាក៏បាន ។

២-តុលាការ អាចបង្គាប់ឱ្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនធ្វើការចាត់ចែងចាំបាច់ដែលទាក់ទងនឹងការគ្រប់គ្រងថែរក្សាអនីតិជននៅក្រោមអាណាព្យាបាល ឬ ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជននោះ ឬ ការចាត់ចែងចាំបាច់ផ្សេងទៀតដែលទាក់ទងទៅនឹងអាណាព្យាបាលសម្រាប់អនីតិជន តាមការទាមទាររបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អនីតិជននោះ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់អនីតិជននោះ នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការ ឬ ដោយឯកឯងក៏បាន ។

មាត្រា ១០៩០.- ការកម្រិតសិទ្ធិតំណាងដែលច្បាប់បានកំណត់ និង សិទ្ធិយល់ព្រម

ប្រសិនបើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដើម្បីធ្វើអាជីវកម្ម ឬ ធ្វើសកម្មភាពដែលបានកំណត់នៅក្នុងមាត្រា ៣០ (សិទ្ធិលុបចោលសកម្មភាព) នៃក្រមនេះ ជំនួសអនីតិជននៅក្រោមអាណាព្យាបាល ឬ ដើម្បីយល់ព្រមឱ្យអនីតិជននៅក្រោមអាណាព្យាបាលប្រកបអាជីវកម្ម ឬ ធ្វើសកម្មភាពនោះ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវទទួលការយល់ព្រមពីអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះការទទួលប្រាក់ដើម ។

មាត្រា ១០៩១.- អានុភាពនៃការអនុវត្តផ្ទុយនឹងមាត្រា ១០៩០

១-សកម្មភាពដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានធ្វើ ឬ សកម្មភាពដែលបានផ្តល់ការយល់ព្រម ដោយផ្ទុយនឹងបញ្ញត្តិនៃមាត្រា ១០៩០ (ការកម្រិតសិទ្ធិតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិយល់ព្រម) ខាងលើនេះ មានតែអនីតិជននៅក្រោមអាណាព្យាបាល ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនទេ ដែលអាចលុបចោលបាន ។ ក្នុងករណីនេះ បញ្ញត្តិនៃមាត្រា ៣២ (សិទ្ធិដាស់តឿន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងក្នុងការអនុវត្តបញ្ញត្តិនៃមាត្រា ៣៥៨ (សកម្មភាពដែលអាចលុបចោលបាន) និង បញ្ញត្តិចាប់ពីមាត្រា ៣៦០ (វិធីនៃការលុបចោលឬអនុម័ត) រហូតដល់មាត្រា ៣៦៣ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល) នៃក្រម

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

នេះឡើយ ។

មាត្រា ១០៩២.- ការទទួលអនុប្បទាននូវទ្រព្យសម្បត្តិ ជាអាទិ៍ ពីអនីតិជននៅក្រោមអាណាព្យាបាល

១-ប្រសិនបើអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានទទួលអនុប្បទាននូវទ្រព្យសម្បត្តិរបស់អនីតិជននៅក្រោមអាណាព្យាបាល ឬ សិទ្ធិរបស់តតិយជនចំពោះអនីតិជន នៅក្រោមអាណាព្យាបាល អនីតិជននៅក្រោមអាណាព្យាបាលនោះ អាចលុបចោលនូវអនុប្បទាននោះបាន ។ ក្នុងករណីនេះ បញ្ញត្តិនៃមាត្រា ៣២ (សិទ្ធិដាស់តឿន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងនូវការអនុវត្តបញ្ញត្តិនៃមាត្រា ៣៥៨ (សកម្មភាពដែលអាចលុបចោលបាន) និង បញ្ញត្តិចាប់ពីមាត្រា ៣៦០ (វិធីនៃការលុបចោល ឬ សច្ចានុមតិ) រហូតដល់មាត្រា ៣៦៣ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល) នៃក្រមនេះឡើយ ។

មាត្រា ១០៩៣.- ករណីយកិច្ចប្រុងប្រយ័ត្នរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន មានករណីយកិច្ចបំពេញតួនាទីអាណាព្យាបាលសម្រាប់អនីតិជន ដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

២-ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានធ្វើឱ្យមានការខូចខាតដល់អនីតិជននៅក្រោមអាណាព្យាបាល ដោយធ្វើផ្ទុយនឹងករណីយកិច្ចប្រុងប្រយ័ត្នដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អនីតិជននៅក្រោមអាណាព្យាបាលអាចទាមទារសំណងនៃការខូចខាតនោះ ពីអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះបាន ។

មាត្រា ១០៩៤.- ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យអនីតិជននៅក្រោមអាណាព្យាបាល

១-ប្រសិនបើតតិយជនដែលបានផ្តល់ទ្រព្យសម្បត្តិឱ្យទៅអនីតិជននៅក្រោមអាណាព្យាបាល ដោយមិនគិតថ្លៃ បានបង្ហាញឆន្ទៈថា មិនឱ្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនគ្រប់គ្រង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ទ្រព្យសម្បត្តិនោះទេ ទ្រព្យសម្បត្តិនោះពុំត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនឡើយ ។

២-ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជន ពុំបានអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើតតិយជនពុំបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិទេ តុលាការអាចជ្រើសតាំងអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិនោះ តាមការទាមទាររបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់ អនីតិជន ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អនីតិជននៅក្រោមអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់អនីតិជននោះ នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់ សុខុមាលភាពកុមារ ឬតំណាងអយ្យការបាន ។

៣-ទោះបីជាតតិយជនបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិក៏ដោយបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសិទ្ធិអំណាចរបស់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិនោះ បានរលត់ ឬ មានការចាំបាច់ត្រូវផ្លាស់ប្តូរអ្នកនោះ តែតតិយជនមិនបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិផ្សេងទៀត ។

៤-បញ្ញត្តិចាប់ពីមាត្រា ៣៧ (ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយតុលាការ) រហូតដល់មាត្រា ៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ និង ទី ៣ ខាងលើនេះ ។

កថាភាគទី ៥

ការរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន

មាត្រា ១០៩៥.- លក្ខខណ្ឌនៃការរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន

១-ក្នុងករណីដែលអនីតិជននៅក្រោមអាណាព្យាបាលដែលបានគ្រប់អាយុ ១៦ (ដប់ប្រាំមួយ) ឆ្នាំ ទ្រទ្រង់ជីវភាពខ្លួនឯង ដោយឯករាជ្យបាន តុលាការអាចប្រកាសឱ្យរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន តាមពាក្យសុំរបស់អនីតិជននៅក្រោមអាណាព្យាបាលបាន បើយល់ឃើញថា ការរួចផុតនោះស្របនឹងផលប្រយោជន៍របស់អនីតិជន នៅក្រោមអាណាព្យាបាលនោះ ។ ក្នុងករណីនេះតុលាការត្រូវសួរយោបល់ពីអ្នកអាណាព្យាបាលសម្រាប់អនីតិជន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ក្រសួងព្រះបរមរាជវាំង

បើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន តុលាការក៏ត្រូវសួរយោបល់ពីអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលនោះផងដែរ ។

២-អនីតិជននៅក្រោមអាណាព្យាបាលដែលបានរៀបអាពាហ៍ពិពាហ៍ ត្រូវរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ដោយគ្មានការប្រកាសរបស់តុលាការ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ទោះបីជាភាគីបានលែងលះនៅពេលក្រោយក៏ដោយ ក៏អានុភាពនៃការរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជនមិនត្រូវរលត់ឡើយ ។

មាត្រា ១០៩៦.- អានុភាពនៃការរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន

អនីតិជននៅក្រោមអាណាព្យាបាល ដែលបានរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ត្រូវបានចាត់ទុកថា បានដល់នីតិភាព ។

មាត្រា ១០៩៧.- ការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ វត្តមានរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន

១-ប្រសិនបើបានបញ្ចប់តួនាទីរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនហើយ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ សន្តតិជនរបស់អ្នកនោះ ត្រូវធ្វើការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ នៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់តួនាទីនោះ ។ ប៉ុន្តែ អំឡុងពេលនេះ អាចពន្យារបាននៅតុលាការ ។

២-បើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ការគណនាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវអនុវត្តដោយមានវត្តមានរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ។

មាត្រា ១០៩៨.- ការលុបចោលកិច្ចសន្យារវាងអនីតិជននៅក្រោមអាណាព្យាបាល និង អ្នកអាណាព្យាបាលសម្រាប់អនីតិជន

១-អនីតិជននៅក្រោមអាណាព្យាបាល អាចលុបចោលកិច្ចសន្យាដែលខ្លួនបានធ្វើជាមួយនឹងអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ សន្តតិជនរបស់អ្នកអាណាព្យាបាល សម្រាប់

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL ព្រះបរមរាជវាំង
280/៤៩៤

អនីតិជននោះ នៅក្រោយពេលដែលខ្លួនបានក្លាយជានីតិជនហើយ និង នៅមុនពេលបញ្ចប់ការគណនានូវចំណូលចំណាយក្នុងកិច្ចការអាណាព្យាបាលបាន ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសកម្មភាពឯកតោភាគីដែលអនីតិជននោះបានធ្វើចំពោះអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ សន្តតិជនរបស់អាណាព្យាបាលសម្រាប់ អនីតិជននោះ ។

២-បញ្ញត្តិនៃមាត្រា ៣៥៨(សកម្មភាពដែលអាចលុបចោលបាន) និង បញ្ញត្តិចាប់ពីមាត្រា ៣៦០(វិធីនៃការលុបចោល ឬ សច្ចានុមតិ) រហូតដល់មាត្រា ៣៦៣ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

មាត្រា ១០៩៩.- ករណីយកិច្ចបង់ការប្រាក់របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអនីតិជននៅក្រោមអាណាព្យាបាល

១-ចំនួនទឹកប្រាក់ដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវសងទៅឱ្យអនីតិជននៅក្រោមអាណាព្យាបាល និង ចំនួនទឹកប្រាក់ដែលអនីតិជននៅក្រោមអាណាព្យាបាល ត្រូវសងទៅឱ្យអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ត្រូវគិតការប្រាក់ ចាប់ពីពេលដែលបានបញ្ចប់ការគណនានូវចំណូលចំណាយក្នុងកិច្ចការអាណាព្យាបាលសម្រាប់អនីតិជនរួចហើយ ។

២-ប្រសិនបើអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានប្រើប្រាស់ប្រាក់របស់អនីតិជននៅក្រោមអាណាព្យាបាល ដើម្បីខ្លួនឯងផ្ទាល់នោះ ត្រូវគិតការប្រាក់ ចាប់ពីពេលដែលបានប្រើប្រាស់ប្រាក់នោះ ។ បើមានការខូចខាត អ្នកអាណាព្យាបាលសម្រាប់ អនីតិជនត្រូវទទួលខុសត្រូវសងសំណងនៃការខូចខាតនោះ ។

មាត្រា ១១០០.- ករណីយកិច្ចសង្គ្រោះបន្ទាន់របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ជាអាទិ៍ នៅក្រោយពេលបញ្ចប់អាណាព្យាបាលសម្រាប់អនីតិជន

១-ប្រសិនបើមានស្ថានភាពបន្ទាន់ នៅក្នុងករណីដែលបានបញ្ចប់អាណាព្យាបាលសម្រាប់អនីតិជនហើយ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ សន្តតិជនរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ត្រូវធ្វើការចាត់ចែងចាំបាច់ រហូតដល់ពេលដែលអនីតិជននៅក្រោម

ROYAUME DU CAMBODGE LE MINISTRE ... PALAIS ROYAL
ព្រះបរមរាជវាំង

អាណាព្យាបាល សន្តតិជនរបស់អនីតិជននៅក្រោមអាណាព្យាបាល នោះ ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់អនីតិជននៅក្រោមអាណាព្យាបាលនោះ អាចចាត់ការកិច្ចការនោះបាន ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិដែលត្រូវបានកំណត់ ឬ ជ្រើសតាំង ដោយយោងតាមបញ្ញត្តិនៃមាត្រា ១០៩៤(ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យអនីតិជននៅក្រោមអាណាព្យាបាល) ។

មាត្រា ១១០១.- លក្ខខណ្ឌតតាំងនៃការបញ្ចប់អាណាព្យាបាលសម្រាប់អនីតិជន ជាអាទិ៍

១-មូលហេតុនៃការបញ្ចប់អាណាព្យាបាលសម្រាប់អនីតិជន ទោះបីជាមូលហេតុនោះកើតឡើងចំពោះអនីតិជននៅក្រោមអាណាព្យាបាលក៏ដោយ ឬ ចំពោះអ្នកអាណាព្យាបាលសម្រាប់អនីតិជនក៏ដោយ ពុំអាចយកទៅតតាំងជាមួយនឹងភាគីម្ខាងទៀតបានឡើយ បើមិនបានជូនដំណឹងទៅឱ្យភាគីម្ខាងទៀត ឬ បើភាគីម្ខាងទៀត ពុំបានដឹងអំពីមូលហេតុនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃមាត្រា ១០៩៤(ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យអនីតិជននៅក្រោមអាណាព្យាបាល) នៃក្រមនេះ ។

មាត្រា ១១០២.- អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលទាក់ទងនឹងអាណាព្យាបាលសម្រាប់អនីតិជន

១-បញ្ញត្តិនៃមាត្រា ១០៦០ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលទាក់ទងទៅនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរវាងឪពុកម្តាយ និង កូន) នៃក្រមនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសិទ្ធិលើបំណុលដែលបានកើតឡើង ដោយទាក់ទងនឹងអាណាព្យាបាលសម្រាប់អនីតិជន រវាងអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អនីតិជននៅក្រោមអាណាព្យាបាល ។

២-ក្នុងករណីដែលបានលុបចោលសកម្មភាព ដោយបញ្ញត្តិនៃមាត្រា ១០៩៨ (ការលុបចោលកិច្ចសន្យារវាងអនីតិជននៅក្រោមអាណាព្យាបាល និង អ្នកអាណាព្យាបាលសម្រាប់អនីតិជន) នៃក្រមនេះ អាជ្ញាយុកាលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាង លើនេះ ត្រូវ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS

គណនាដោយគិតចាប់ពីពេលដែលបានលុបចោលនោះ ។

កថាភាគទី ៦

ការយកមកអនុវត្តដូចគ្នា ចំពោះកូនរបស់អនីតិជននៅក្រោមអាណាព្យាបាល

មាត្រា ១១០៣.- ការអនុវត្តអំណាចមេបាជំនួសអនីតិជននៅក្រោមអាណាព្យាបាល

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវអនុវត្តអំណាចមេបា ចំពោះកូនរបស់អនីតិជននៅក្រោមអាណាព្យាបាល ជំនួសអនីតិជននៅក្រោមអាណាព្យាបាលនោះ ។

២-បញ្ញត្តិចាប់ពីមាត្រា ១០៧៩(សិទ្ធិ និង ករណីយកិច្ចរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) រហូតដល់មាត្រា ១១០២ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលទាក់ទងនឹងអាណាព្យាបាលសម្រាប់អនីតិជន) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

ផ្នែកទី ២

អាណាព្យាបាលទូទៅ

កថាភាគទី ១

ការចាប់ផ្តើមអាណាព្យាបាលទូទៅ

មាត្រា ១១០៤.- ការចាប់ផ្តើមអាណាព្យាបាលទូទៅ

អាណាព្យាបាលទូទៅ ត្រូវចាប់ផ្តើម ដោយបញ្ញត្តិនៃមាត្រា ២៤(ការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

កថាភាគទី ២

អ្នកអាណាព្យាបាលទូទៅ

មាត្រា ១១០៥.- ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ

១-បើប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ តុលាការត្រូវជ្រើសតាំងអ្នកអាណា-

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ព្យាបាលទូទៅ ដោយឆន្ទានុសិទ្ធិ ។

២-ប្រសិនបើខ្វះអ្នកអាណាព្យាបាលទូទៅ តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ តាមការទាមទាររបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ជននៅក្រោមអាណាព្យាបាលទូទៅ សហព័ទ្ធរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ញាតិនៅក្នុង ៤ (បួន) ថ្នាក់របស់ជននៅក្រោមអាណាព្យាបាលទូទៅ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋាន របស់ជននៅក្រោមអាណាព្យាបាលទូទៅ តំណាងអយ្យការ ឬ បុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ ឬ ដោយឆន្ទានុសិទ្ធិ ។

៣-ទោះបីជា បានជ្រើសតាំងអ្នកអាណាព្យាបាលទូទៅហើយក៏ដោយ បើយល់ឃើញថាចាំបាច់ តុលាការអាចជ្រើសតាំងអ្នកអាណាព្យាបាលទូទៅថែមទៀត តាមការទាមទាររបស់បុគ្គលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ឬ អ្នកអាណាព្យាបាលទូទៅ ឬដោយឆន្ទានុសិទ្ធិបាន ។

៤-ដើម្បីជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ តុលាការត្រូវគិតពិចារណាអំពីស្ថានភាពផ្លូវកាយនិងផ្លូវចិត្ត និង ស្ថានភាពជីវភាព និង ទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ វិជ្ជាជីវៈ និង ប្រវត្តិរូប របស់អ្នកដែលត្រូវធ្វើជាអ្នកអាណាព្យាបាលទូទៅ និង អត្ថិភាព ឬ នត្ថិភាព នៃទំនាក់ទំនងទៅនឹងផលប្រយោជន៍ រវាងអ្នកអាណាព្យាបាលទូទៅ និង ជននៅក្រោមអាណាព្យាបាលទូទៅ និង យោបល់របស់ជននៅក្រោមអាណាព្យាបាលទូទៅ និង ស្ថានភាពផ្សេងទៀតទាំងស្រុង ។ ប្រសិនបើអ្នកអាណាព្យាបាលទូទៅជានីតិបុគ្គល តុលាការត្រូវគិតពិចារណាផងដែរអំពីប្រភេទ និង ខ្លឹមសារនៃកិច្ចការរបស់នីតិបុគ្គល និង អត្ថិភាព ឬ នត្ថិភាពនៃទំនាក់ទំនងទៅនឹងផលប្រយោជន៍ រវាងនីតិបុគ្គល និងអ្នកតំណាងរបស់នីតិបុគ្គលនោះ និងជននៅក្រោមអាណាព្យាបាលទូទៅ ។

៥-ក្នុងករណីដែលជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ ចំពោះអនីតិជន តុលាការអាចយកអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន មកជ្រើសតាំងជាអ្នកអាណាព្យាបាលទូទៅបាន ។ ក្នុងករណីដែលតុលាការយកជនក្រៅពីអ្នកមានអំណាចមេបារបស់អនីតិជន ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន មកជ្រើសតាំងជាអ្នកអាណាព្យាបាលទូទៅ តុលាការត្រូវកំណត់អំពីការបែងចែកកិច្ចការរបស់អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាល

ROYAUME DU CAMBODGE · LE MINISTRE · PALAIS ROYAL

សម្រាប់អនីតិជន និង អ្នកអាណាព្យាបាលទូទៅ ។

មាត្រា ១១០៦.- ការលាឈប់របស់អ្នកអាណាព្យាបាលទូទៅ

ប្រសិនបើមានមូលហេតុត្រឹមត្រូវ អ្នកអាណាព្យាបាលទូទៅ អាចលាឈប់បានដោយទទួលការអនុញ្ញាតពីតុលាការ ។

មាត្រា ១១០៧.- ករណីយកិច្ចជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ

ប្រសិនបើអ្នកអាណាព្យាបាលទូទៅ បានលាឈប់ តុលាការត្រូវជ្រើសតាំងអ្នកអាណា-ព្យាបាលទូទៅថ្មីទៀតឱ្យបានឆាប់រហ័ស ។

មាត្រា ១១០៨.- ការបញ្ឈប់អ្នកអាណាព្យាបាលទូទៅ

ប្រសិនបើអ្នកអាណាព្យាបាលទូទៅ បានធ្វើសកម្មភាពពុំត្រឹមត្រូវ ឬ មានហេតុផ្សេងទៀតដែលមិនសមរម្យនឹងភារកិច្ចជាអ្នកអាណាព្យាបាលទូទៅ តុលាការអាចបញ្ឈប់អ្នកអាណា-ព្យាបាលទូទៅនោះបាន តាមការទាមទាររបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ជននៅក្រោមអាណាព្យាបាលទូទៅ សហព័ទ្ធរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់ជននៅក្រោមអាណាព្យាបាលទូទៅ មេឃុំ ឬ ចៅសង្កាត់ នៃលំនៅឋានរបស់ជននៅក្រោមអាណាព្យាបាលទូទៅតំណាងអយ្យការ ឬ បុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងទៅនឹងផលប្រយោជន៍ ឬ ដោយឆន្ទានុសិទ្ធិបាន ។

មាត្រា ១១០៩.- បុគ្គលដែលមិនអាចក្លាយជាអ្នកអាណាព្យាបាលទូទៅ

បុគ្គលដែលកំណត់ក្នុងចំណុចខាងក្រោមនេះ ពុំអាចធ្វើជាអ្នកអាណាព្យាបាលទូទៅបានឡើយ :

ក-អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភ ។

ខ-អ្នកតំណាងដែលច្បាប់បានកំណត់ និង ហិតូបត្ថម្ភកៈ ព្រមទាំងអ្នកត្រួតពិនិត្យជនទាំងនោះ ដែលធ្លាប់ត្រូវបានតុលាការដកចេញ ។

គ-ជនដែលក្ស័យធន ។

ឃ-ជនដែលគ្មានដំណឹងអំពីទីរស់នៅ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL ·

កថាភាគទី ៣
អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ

មាត្រា ១១១០.- អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ

ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការអាចជ្រើសតាំងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ តាមការទាមទាររបស់អ្នកអាណាព្យាបាលទូទៅ ជននៅក្រោមអាណាព្យាបាលទូទៅ សហព័ទ្ធរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់ជននៅក្រោមអាណាព្យាបាលទូទៅ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជន នៅក្រោមអាណាព្យាបាលទូទៅ តំណាងអយ្យការ ឬ បុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ ឬ ដោយឆន្ទានុសិទ្ធិបាន ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលខ្វះអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ។

មាត្រា ១១១១.- បុគ្គលដែលមិនអាចក្លាយជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ

សហព័ទ្ធ និង ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់ជននៅក្រោមអាណាព្យាបាលទូទៅ ពុំអាចធ្វើជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅបានឡើយ ។

មាត្រា ១១១២.- តួនាទីរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ

អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ មានតួនាទីដូចកំណត់ខាងក្រោមនេះ :

ក-ត្រួតពិនិត្យតួនាទីរបស់អ្នកអាណាព្យាបាលទូទៅ ។

ខ-ទាមទារឱ្យតុលាការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅថ្មីទៀត ដោយគ្មានការយឺតយ៉ាវ ក្នុងករណីដែលខ្វះអ្នកអាណាព្យាបាលទូទៅ ។

គ-ធ្វើការចាត់ចែងចាំបាច់ ចំពោះជីវភាព ការថែទាំព្យាបាល និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ក្នុងករណីដែលមានស្ថានភាពបន្ទាន់ ។

ឃ-តំណាងឱ្យជននៅក្រោមអាណាព្យាបាលទូទៅ ចំពោះសកម្មភាព ដែលផលប្រយោជន៍របស់អ្នកអាណាព្យាបាលទូទៅ ឬ ជនដែលអ្នកអាណាព្យាបាលទូទៅនោះធ្វើតំណាងឱ្យ និង ជននៅក្រោមអាណាព្យាបាលទូទៅមានភាពផ្ទុយគ្នា ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

384/456

មាត្រា ១១១៣.- បញ្ញត្តិដែលត្រូវយកមកអនុវត្តដូចគ្នា

បញ្ញត្តិកថាខណ្ឌទី ៤ នៃមាត្រា ១១០៥ (ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ) មាត្រា ១១០៦ (ការលាឈប់របស់អ្នកអាណាព្យាបាលទូទៅ) មាត្រា ១១០៨ (ការបញ្ឈប់អ្នកអាណាព្យាបាលទូទៅ) មាត្រា ១១០៩ (បុគ្គលដែលមិនអាចក្លាយជាអ្នកអាណាព្យាបាលទូទៅ) មាត្រា ១១២០ (ករណីដែលអ្នកអាណាព្យាបាលទូទៅមានច្រើននាក់) មាត្រា ១១២១ (ការអនុញ្ញាតឱ្យគ្រប់គ្រងទ្រព្យសម្បត្តិ) កថាខណ្ឌទី ២ នៃមាត្រា ១១២៣ (គម្រោងនៃចំនួនប្រាក់ចំណាយ និងសោហ៊ុយនៃអាណាព្យាបាលទូទៅ) មាត្រា ១១២៤ (កម្រៃរបស់អ្នកអាណាព្យាបាលទូទៅ) មាត្រា ១១២៩ (ករណីយកិច្ចប្រុងប្រយ័ត្នរបស់អ្នកអាណាព្យាបាលទូទៅ) មាត្រា ១១៣៣ (ករណីយកិច្ចសង្គ្រោះបន្ទាន់របស់អ្នកអាណាព្យាបាលទូទៅ ជាអាទិ៍ នៅក្រោយពេលបញ្ចប់អាណាព្យាបាលទូទៅ) និង មាត្រា ១១៣៤ (ល័ក្ខខ័ណ្ឌតតាំងនៃ ការបញ្ចប់អាណាព្យាបាលទូទៅជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ។

កថាភាគទី ៤

តួនាទីរបស់អ្នកអាណាព្យាបាលទូទៅ

មាត្រា ១១១៤.- ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង

១-អ្នកអាណាព្យាបាលទូទៅ ត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ហើយត្រូវធ្វើជាតំណាងឱ្យជននៅក្រោមអាណាព្យាបាលទូទៅ ចំពោះសកម្មភាពដែលទាក់ទងនឹងទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ។

២-បញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃមាត្រា ១០៥៣ (ការគ្រប់គ្រងទ្រព្យសម្បត្តិ និងការតំណាង) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

មាត្រា ១១១៥.- ការស្រាវជ្រាវទ្រព្យសម្បត្តិ និង ការធ្វើបញ្ជីសារពើភ័ណ្ឌ

១-អ្នកអាណាព្យាបាលទូទៅ ត្រូវចាប់ផ្តើមស្រាវជ្រាវទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ដោយគ្មានការយឺតយ៉ាវនៅក្រោយពេលបានកាន់តំណែង ហើយត្រូវបញ្ចប់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ការស្រាវជ្រាវនោះ នៅក្នុងអំឡុងពេល ៣ (បី) ខែ និង ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិនោះ ។ ប៉ុន្តែ អំឡុងពេលនេះ អាចពន្យារបាននៅតុលាការ ។

២-ប្រសិនបើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ការស្រាវជ្រាវទ្រព្យសម្បត្តិ និង ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិនោះ ពុំមានអានុភាពឡើយ បើគ្មានវត្តមានរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅនោះទេ ។

មាត្រា ១១១៦.- សិទ្ធិអំណាចនៅមុនពេលធ្វើបញ្ជីសារពើភ័ណ្ឌ

រហូតដល់ពេលបញ្ចប់ការធ្វើបញ្ជីសារពើភ័ណ្ឌ អ្នកអាណាព្យាបាលទូទៅមានសិទ្ធិអំណាចចំពោះតែសកម្មភាពដែលមានភាពចាំបាច់បន្ទាន់ប៉ុណ្ណោះ ។ ប៉ុន្តែ សកម្មភាពនេះ មិនអាចតតាំងនឹងតតិយជនដែលសុចរិតបានឡើយ ។

មាត្រា ១១១៧.- ការរាយការណ៍អំពីសិទ្ធិលើបំណុល និង កាតព្វកិច្ចរបស់អ្នកអាណាព្យាបាលទូទៅដែលមានចំពោះជននៅក្រោមអាណាព្យាបាលទូទៅ

១-ក្នុងករណីដែលអ្នកអាណាព្យាបាលទូទៅ មានសិទ្ធិលើបំណុល ឬ កាតព្វកិច្ច ចំពោះជននៅក្រោមអាណាព្យាបាលទូទៅ ប្រសិនបើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅអ្នកអាណាព្យាបាលទូទៅនោះ ត្រូវរាយការណ៍ជូនអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ អំពីសិទ្ធិលើបំណុល ឬ កាតព្វកិច្ចនោះ នៅមុនពេលចាប់ផ្តើមធ្វើការស្រាវជ្រាវទ្រព្យសម្បត្តិ ។

២-ប្រសិនបើអ្នកអាណាព្យាបាលទូទៅ បានដឹងថាមានសិទ្ធិលើបំណុលចំពោះជននៅក្រោមអាណាព្យាបាលទូទៅ តែមិនបានធ្វើការរាយការណ៍ទេ អ្នកអាណាព្យាបាលទូទៅនោះ ត្រូវបាត់បង់សិទ្ធិលើបំណុលនោះ ។

មាត្រា ១១១៨.- ការយកមកអនុវត្តដូចគ្នា ចំពោះករណីដែលជននៅក្រោមអាណាព្យាបាលទូទៅបានធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិសកល

បញ្ញត្តិនៃមាត្រា ១១១៥(ការស្រាវជ្រាវទ្រព្យសម្បត្តិ និង ការធ្វើបញ្ជីសារពើភ័ណ្ឌ) មាត្រា ១១១៦(សិទ្ធិអំណាចនៅមុនពេលធ្វើបញ្ជីសារពើភ័ណ្ឌ) និង មាត្រា ១១១៧(ការរាយការណ៍អំពីសិទ្ធិលើបំណុល និង កាតព្វកិច្ចរបស់អ្នកអាណាព្យាបាលទូទៅដែលមានចំពោះជន

នៅក្រោមអាណាព្យាបាលទូទៅ) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលជននៅក្រោមអាណាព្យាបាលទូទៅបានធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិសកល នៅក្រោយពេលដែលអ្នកអាណាព្យាបាលទូទៅបានកាន់តំណែង ។

មាត្រា ១១១៩.- ការគោរពឆន្ទៈរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ជាអាទិ៍

១-ក្នុងការអនុវត្តកិច្ចការដែលទាក់ទងទៅនឹងជីវភាព ការថែទាំព្យាបាល និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ អ្នកអាណាព្យាបាលទូទៅត្រូវគោរពឆន្ទៈរបស់ជននៅក្រោមអាណាព្យាបាលទូទៅ និង ត្រូវគិតពិចារណាដល់ស្ថានភាពផ្លូវកាយនិងផ្លូវចិត្ត និង ស្ថានភាពជីវភាពរបស់ជននោះ ។

២-អ្នកអាណាព្យាបាលទូទៅ គប្បីថែទាំព្យាបាលជននៅក្រោមអាណាព្យាបាលទូទៅតាមទ្រព្យធនរបស់ជននៅក្រោមអាណាព្យាបាលទូទៅ និង អ្នកអាណាព្យាបាលទូទៅព្រមទាំងទំនាក់ទំនងរវាងអ្នកទាំងពីរនោះ ។

មាត្រា ១១២០.- ករណីដែលអ្នកអាណាព្យាបាលទូទៅ មានច្រើននាក់

១-ប្រសិនបើអ្នកអាណាព្យាបាលទូទៅមានច្រើននាក់ តុលាការអាចកំណត់ដោយឆន្ទានុសិទ្ធិ តម្រូវឱ្យអ្នកអាណាព្យាបាលទូទៅដែលមានច្រើននាក់នោះ ប្រើសិទ្ធិអំណាចដោយសហការគ្នា ឬ បែងចែកកិច្ចការគ្នាបាន ។

២-តុលាការអាចលុបចោលការកំណត់ដែលបានបញ្ញត្តនៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដោយឆន្ទានុសិទ្ធិបាន ។

៣-ប្រសិនបើអ្នកអាណាព្យាបាលទូទៅមានច្រើននាក់ ចំពោះការបង្ហាញឆន្ទៈរបស់តតិយជន ដែលបានធ្វើចំពោះជនណាម្នាក់នោះ គឺជាការគ្រប់គ្រាន់ ។

មាត្រា ១១២១.- ការអនុញ្ញាតឱ្យគ្រប់គ្រងទ្រព្យសម្បត្តិ

ដើម្បីលក់ ផ្តល់ វិលាយភតិសន្យា បង្កើតហ៊ីប៉ូតែក ឬ ធ្វើការចាត់ចែងផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ជំនួសជននៅក្រោមអាណាព្យាបាលទូទៅ ចំពោះអគារដែលប្រើសម្រាប់ជាលំនៅឋានរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ឬ ដីដែលអគារ នោះតាំងនៅអ្នក

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

អាណាព្យាបាលទូទៅ ត្រូវទទួលការអនុញ្ញាតពីតុលាការ ។

មាត្រា ១១២២.- សកម្មភាពដែលផលប្រយោជន៍របស់អ្នកអាណាព្យាបាលទូទៅ និង ជននៅក្រោមអាណាព្យាបាលទូទៅ មានភាពផ្ទុយគ្នា

បញ្ញត្តិនៃមាត្រា ១០៦៥ (ករណីដែលផលប្រយោជន៍របស់អ្នកមានអំណាចមេបា និង កូនមានភាពផ្ទុយគ្នា) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកអាណាព្យាបាលទូទៅ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ។

មាត្រា ១១២៣.- គម្រោងនៃចំនួនប្រាក់ចំណាយ និង សោហ៊ុយនៃអាណាព្យាបាលទូទៅ

១-អ្នកអាណាព្យាបាលទូទៅ ត្រូវធ្វើគម្រោងចំនួនប្រាក់ដែលត្រូវចំណាយជារៀងរាល់ឆ្នាំ ដើម្បីជីវភាព ការថែទាំព្យាបាល និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ នៅដំណាក់ដំបូងនៃពេលដែលបានចាប់ផ្តើមកាន់តំណែង ។

២-សោហ៊ុយចាំបាច់ ដើម្បីអ្នកអាណាព្យាបាលទូទៅបំពេញតួនាទីអាណាព្យាបាលទូទៅ ត្រូវចំណាយចេញពីទ្រព្យសម្បត្តិ របស់ជននៅក្រោមអាណាព្យាបាលទូទៅ ។

មាត្រា ១១២៤.- កម្រៃរបស់អ្នកអាណាព្យាបាលទូទៅ

តុលាការ អាចផ្តល់កម្រៃសមរម្យពីក្នុងចំណោមទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅឱ្យទៅអ្នកអាណាព្យាបាលទូទៅ ដោយគិតពីចារណាទៅលើលទ្ធភាពទ្រព្យធនរបស់អ្នកអាណាព្យាបាលទូទៅ និង ជននៅក្រោមអាណាព្យាបាលទូទៅ ព្រមទាំងស្ថានភាពផ្សេងទៀតបាន ។

មាត្រា ១១២៥.- ការត្រួតពិនិត្យតួនាទីរបស់អ្នកអាណាព្យាបាលទូទៅ

១-អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ឬ តុលាការ អាចទាមទារឱ្យអ្នកអាណាព្យាបាលទូទៅ រាយការណ៍អំពីតួនាទីរបស់ខ្លួន ឬ ដាក់បញ្ជីសារពើភ័ណ្ឌ ឬ អាចស្រាវជ្រាវអំពីជីវភាព ការថែទាំព្យាបាល ឬ ស្ថានភាពទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅនៅពេលណាក៏បាន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL
ព្រះរាជវាំង

២៩០/៤៤៤

២-តុលាការ អាចបង្គាប់ឱ្យអ្នកអាណាព្យាបាលទូទៅ ធ្វើការចាត់ចែងចាំបាច់ដែលទាក់ទងនឹងជីវភាព ការថែទាំព្យាបាល ឬ ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ឬ ការចាត់ចែងចាំបាច់ផ្សេងទៀតដែលទាក់ទងនឹងអាណាព្យាបាលទូទៅ តាមការទាមទាររបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ជននៅក្រោមអាណាព្យាបាលទូទៅសហព័ទ្ធរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់ជននៅក្រោមអាណាព្យាបាលទូទៅ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននៅក្រោមអាណាព្យាបាលទូទៅនោះ តំណាងអយ្យការ ឬ បុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងទៅនឹងផលប្រយោជន៍ ឬ ដោយឆន្ទានុសិទ្ធិបាន ។

មាត្រា ១១២៦.- ការកម្រិតសិទ្ធិតំណាងដែលច្បាប់បានកំណត់ និង សិទ្ធិយល់ព្រម

ប្រសិនបើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ដើម្បីធ្វើអាជីវកម្ម ឬ ធ្វើសកម្មភាពដែលបានកំណត់នៅក្នុងមាត្រា ៣០(សិទ្ធិលុបចោលសកម្មភាព) នៃក្រមនេះ ជំនួសជននៅក្រោមអាណាព្យាបាលទូទៅ ឬ ដើម្បីយល់ព្រមឱ្យជននៅក្រោមអាណាព្យាបាលទូទៅ ប្រកបអាជីវកម្ម ឬ ធ្វើសកម្មភាពនោះ អ្នកអាណាព្យាបាលទូទៅ ត្រូវទទួលការយល់ព្រមពីអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះការទទួលប្រាក់ដើម ។

មាត្រា ១១២៧.- អានុភាពនៃការអនុវត្តផ្ទុយនឹងមាត្រា ១១២៦

១-សកម្មភាពដែលអ្នកអាណាព្យាបាលទូទៅបានធ្វើ ឬ បានផ្តល់ការយល់ព្រម ដោយផ្ទុយនឹងបញ្ញត្តិនៃមាត្រា ១១២៦(ការកម្រិតសិទ្ធិតំណាងដែលច្បាប់បានកំណត់ និង សិទ្ធិយល់ព្រម) ខាងលើនេះ មានតែជននៅក្រោមអាណាព្យាបាលទូទៅ ឬ អ្នកអាណាព្យាបាលទូទៅទេ ដែលអាចលុបចោលបាន ។ ក្នុងករណីនេះ បញ្ញត្តិនៃមាត្រា ៣២(សិទ្ធិដាស់តឿន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងក្នុងការអនុវត្តបញ្ញត្តិនៃមាត្រា ៣៥៨ (សកម្មភាពដែលអាចលុបចោលបាន) និង បញ្ញត្តិចាប់ពីមាត្រា ៣៦០(វិធីនៃការលុបចោល ឬ អនុម័តឡើងវិញ) ដល់មាត្រា ៣៦៣ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល) នៃក្រមនេះ

ROYAUME du CAMBODGE * LE MINISTRE du PALAIS ROYAL

1455.

ឡើយ ។

មាត្រា ១១២៨.- ការទទួលអនុប្បទាននូវទ្រព្យសម្បត្តិ ជាអាទិ៍ ពីជននៅក្រោមអាណាព្យាបាលទូទៅ

១-ប្រសិនបើអ្នកអាណាព្យាបាលទូទៅ បានទទួលអនុប្បទាននូវទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ឬ សិទ្ធិរបស់តតិយជនចំពោះជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមអាណាព្យាបាលទូទៅនោះ អាចលុបចោលនូវអនុប្បទាននោះបាន ។ ក្នុងករណីនេះបញ្ញត្តិនៃមាត្រា ៣២ (សិទ្ធិដាស់តឿន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងនូវការអនុវត្តបញ្ញត្តិនៃមាត្រា ៣៥៨ (សកម្មភាពដែលអាចលុបចោលបាន) និង បញ្ញត្តិចាប់ពីមាត្រា ៣៦០ (វិធីនៃការលុបចោល ឬ សច្ចានុមតិ) រហូតដល់មាត្រា ៣៦៣ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល) នៃក្រមនេះឡើយ ។

មាត្រា ១១២៩.- ករណីយកិច្ចប្រុងប្រយ័ត្នរបស់អ្នកអាណាព្យាបាលទូទៅ

១-អ្នកអាណាព្យាបាលទូទៅ មានករណីយកិច្ចបំពេញតួនាទីអាណាព្យាបាលទូទៅ ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

២-ក្នុងករណីដែលអ្នកអាណាព្យាបាលទូទៅ បានធ្វើឱ្យមានការខូចខាតដល់ជននៅក្រោមអាណាព្យាបាលទូទៅ ដោយធ្វើផ្ទុយនឹងករណីយកិច្ចប្រុងប្រយ័ត្នដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ជននៅក្រោមអាណាព្យាបាលទូទៅ អាចទាមទារសំណងនៃការខូចខាតនោះ ពីអ្នកអាណាព្យាបាលទូទៅបាន ។

មាត្រា ១១៣០.- ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យជននៅក្រោមអាណាព្យាបាលទូទៅ

១-ប្រសិនបើតតិយជនដែលបានផ្តល់ទ្រព្យសម្បត្តិឱ្យទៅជននៅក្រោមអាណាព្យាបាលទូទៅ ដោយមិនគិតថ្លៃ បានបង្ហាញឆន្ទៈថា មិនឱ្យអ្នកអាណាព្យាបាលទូទៅគ្រប់គ្រងទ្រព្យសម្បត្តិនោះទេ ទ្រព្យសម្បត្តិនោះពុំត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកអាណាព្យាបាលទូទៅឡើយ ។

២-ក្នុងករណីដែលអ្នកអាណាព្យាបាលទូទៅ ពុំបានអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិ

ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើតតិយជនពុំបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិទេ តុលាការអាចជ្រើសតាំងអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិនោះតាមការទាមទាររបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ជននៅក្រោមអាណាព្យាបាលទូទៅ សហព័ទ្ធរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ញាតិនៅក្នុង ៤ (បួន) ថ្នាក់របស់ជននៅក្រោមអាណាព្យាបាលទូទៅ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននៅក្រោមអាណាព្យាបាលទូទៅនោះ ឬ តំណាងអយ្យការបាន ។

៣-ទោះបីជាតតិយជនបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិក៏ដោយ បញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសិទ្ធិអំណាចរបស់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិនោះ បានរលត់ ឬ មានការចាំបាច់ត្រូវផ្លាស់ប្តូរអ្នកនោះ តែតតិយជនមិនបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិផ្សេងទៀត ។

៤-បញ្ញត្តិចាប់ពីមាត្រា ៣៧(ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយតុលាការ) រហូតដល់មាត្រា ៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ និង ទី ៣ ខាងលើនេះ ។

ការបញ្ចប់អាណាព្យាបាលទូទៅ

កថាភាគទី ៥

មាត្រា ១១៣១.- ការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ និង វត្តមានរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ

១-ប្រសិនបើបានបញ្ចប់តួនាទីរបស់អ្នកអាណាព្យាបាលទូទៅហើយ អ្នកអាណាព្យាបាលទូទៅ ឬ សន្តតិជនរបស់អ្នកនោះ ត្រូវធ្វើការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិនោះ នៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់តួនាទីនោះ ។ ប៉ុន្តែ អំឡុងពេលនេះ អាចពន្យារបាននៅតុលាការ ។

២-បើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ការគណនាដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ ត្រូវអនុវត្តដោយមានវត្តមានរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅនោះ ។

ROYAUME DU CAMBODGE · MINISTÈRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

មាត្រា ១១៣២.- ករណីយកិច្ចបង់ការប្រាក់ របស់អ្នកអាណាព្យាបាលទូទៅ និង ជននៅក្រោមអាណាព្យាបាលទូទៅ

១-ចំនួនទឹកប្រាក់ដែលអ្នកអាណាព្យាបាលទូទៅត្រូវសងទៅឱ្យជននៅក្រោមអាណាព្យាបាលទូទៅ និង ចំនួនទឹកប្រាក់ដែលជននៅក្រោមអាណាព្យាបាលទូទៅត្រូវសងទៅឱ្យអ្នកអាណាព្យាបាលទូទៅ ត្រូវគិតការប្រាក់ ចាប់ពីពេលដែលបានបញ្ចប់ការគណនាទូទាត់ចំណូលចំណាយក្នុងកិច្ចការអាណាព្យាបាលទូទៅរួចហើយ ។

២-ប្រសិនបើអ្នកអាណាព្យាបាលទូទៅ បានប្រើប្រាស់ប្រាក់របស់ជននៅក្រោមអាណាព្យាបាលទូទៅ ដើម្បីខ្លួនឯងផ្ទាល់នោះ ត្រូវគិតការប្រាក់ ចាប់ពីពេលដែលបានប្រើប្រាស់ប្រាក់នោះ ។ បើមានការខូចខាត អ្នកអាណាព្យាបាលទូទៅ ត្រូវទទួលខុសត្រូវសងសំណងនៃការខូចខាតនោះ ។

មាត្រា ១១៣៣.- ករណីយកិច្ចសង្គ្រោះបន្ទាន់របស់អ្នកអាណាព្យាបាលទូទៅ ជាអាទិ៍នៅក្រោយពេលបញ្ចប់អាណាព្យាបាលទូទៅ

១-ប្រសិនបើមានស្ថានភាពបន្ទាន់ នៅក្នុងករណីដែលបានបញ្ចប់អាណាព្យាបាលទូទៅហើយ អ្នកអាណាព្យាបាលទូទៅ ឬ សន្តតិជនរបស់អ្នកអាណាព្យាបាលទូទៅនោះ ឬអ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកអាណាព្យាបាលទូទៅនេះ ត្រូវធ្វើការចាត់ចែងដែលចាំបាច់រហូតដល់ពេលដែលជននៅក្រោមអាណាព្យាបាលទូទៅ សន្តតិជនរបស់ជននៅក្រោមអាណាព្យាបាលទូទៅនោះ ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់ជននៅក្រោមអាណាព្យាបាលទូទៅនោះ អាចចាត់ការកិច្ចការនោះបាន ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិ ដែលត្រូវបានកំណត់ ឬ ជ្រើសតាំង ដោយយោងតាមបញ្ញត្តិនៃមាត្រា ១១៣០ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យជន នៅក្រោមអាណាព្យាបាលទូទៅ) ។

មាត្រា ១១៣៤.- លក្ខខណ្ឌតតាំងនៃការបញ្ចប់អាណាព្យាបាលទូទៅ ជាអាទិ៍

១-មូលហេតុនៃការបញ្ចប់អាណាព្យាបាលទូទៅ ទោះបីជាមូលហេតុនោះកើតឡើង

ROYAUME DU CAMBODGE · MINISTERE DU PALAIS ROYAL

ចំពោះជននៅក្រោមអាណាព្យាបាលទូទៅក៏ដោយ ឬ ចំពោះអ្នកអាណាព្យាបាលទូទៅ ក៏ដោយ ពុំអាចយកទៅតតាំងជាមួយនឹងភាគីម្ខាងទៀតបានឡើយ បើមិនបានជូនដំណឹងទៅឱ្យភាគីម្ខាងទៀត ឬ បើភាគីម្ខាងទៀតពុំបានដឹងអំពីមូលហេតុនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃមាត្រា ១១៣០ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យជននៅក្រោមអាណាព្យាបាលទូទៅ) ។

មាត្រា ១១៣៥.- អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលទាក់ទងទៅនឹងអាណាព្យាបាលទូទៅ

បញ្ញត្តិនៃមាត្រា ១០៦០ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលទាក់ទងទៅនឹងការគ្រប់គ្រងទ្រព្យសម្បត្តិ រវាងឪពុកម្តាយ និង កូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសិទ្ធិលើបំណុលដែលបានកើតឡើង ដោយទាក់ទងនឹងអាណាព្យាបាលទូទៅ រវាងអ្នកអាណាព្យាបាលទូទៅ ឬ អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ និង ជននៅក្រោមអាណាព្យាបាលទូទៅ ។

ជំពូកទី ៧
ហិតូបត្ថម្ភ

មាត្រា ១១៣៦.- ការចាប់ផ្តើមហិតូបត្ថម្ភ

ហិតូបត្ថម្ភ ត្រូវចាប់ផ្តើមដោយបញ្ញត្តិនៃមាត្រា ២៨(ការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ) នៃក្រមនេះ ។

មាត្រា ១១៣៧.- ការជ្រើសតាំងហិតូបត្ថម្ភកៈ

១-ប្រសិនបើប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ តុលាការត្រូវជ្រើសតាំងហិតូបត្ថម្ភកៈ ដោយឆន្ទានុសិទ្ធិ ។

២-បញ្ញត្តិចាប់ពីកថាខណ្ឌទី ២ រហូតដល់កថាខណ្ឌទី ៤ នៃមាត្រា ១១០៥(ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ) និង បញ្ញត្តិចាប់ពីមាត្រា ១១០៦(ការលាឈប់របស់អ្នកអាណាព្យា-

បាលទូទៅ) រហូតដល់មាត្រា ១១០៩ (បុគ្គលដែលមិនអាចក្លាយជាអ្នកអាណាព្យាបាលទូទៅ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះហិតូបត្ថម្ភកៈ។

៣-ចំពោះសកម្មភាពដែលផលប្រយោជន៍របស់ហិតូបត្ថម្ភកៈ ឬ ជនដែលហិតូបត្ថម្ភកៈនោះធ្វើតំណាងឱ្យ និង ជននៅក្រោមហិតូបត្ថម្ភ មានភាពផ្ទុយគ្នា ហិតូបត្ថម្ភកៈត្រូវទាមទារឱ្យតុលាការជ្រើសតាំងហិតូបត្ថម្ភកៈជាបណ្តោះអាសន្ន ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសកម្មភាពដែលផលប្រយោជន៍ផ្ទុយគ្នា រវាងជននៅក្រោមហិតូបត្ថម្ភច្រើននាក់ ដែលស្ថិតនៅក្រោមហិតូបត្ថម្ភកៈដូចគ្នា ។

មាត្រា ១១៣៨.- អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ

១-ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការអាចជ្រើសតាំងអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ តាមការទាមទាររបស់ហិតូបត្ថម្ភកៈ ជននៅក្រោមហិតូបត្ថម្ភ សហព័ទ្ធរបស់ជន នៅក្រោមហិតូបត្ថម្ភ ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់ជននៅក្រោមហិតូបត្ថម្ភ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននៅក្រោមហិតូបត្ថម្ភ តំណាងអយ្យការ ឬ បុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ ឬ ដោយឆន្ទានុសិទ្ធិបាន ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលខ្វះអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ ។

២-បញ្ញត្តិកថាខណ្ឌទី ៤ នៃមាត្រា ១១០៥(ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ) មាត្រា ១១០៦ (ការលាឈប់របស់អ្នកអាណាព្យាបាលទូទៅ) មាត្រា ១១០៨ (ការបញ្ឈប់អ្នកអាណាព្យាបាលទូទៅ) មាត្រា ១១០៩ (បុគ្គលដែលមិនអាចក្លាយជាអ្នកអាណាព្យាបាលទូទៅ) មាត្រា ១១១១ (បុគ្គលដែលមិនអាចក្លាយជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ) មាត្រា ១១២០(ករណីដែលអ្នកអាណាព្យាបាលទូទៅមានច្រើននាក់) កថាខណ្ឌទី ២ នៃមាត្រា ១១២៣ (គម្រោងនៃចំនួនប្រាក់ចំណាយ និង សោហ៊ុយនៃអាណាព្យាបាលទូទៅ) និង មាត្រា ១១២៤ (កម្រៃរបស់អ្នកអាណាព្យាបាលទូទៅ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL ·

396/452

៣-អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ អាចយល់ព្រមឱ្យជននៅក្រោមហិតូបត្ថម្ភធ្វើសកម្មភាពចំពោះសកម្មភាពដែលផលប្រយោជន៍របស់ហិតូបត្ថម្ភកៈ ឬ ជនដែលហិតូបត្ថម្ភកៈនោះធ្វើតំណាងឱ្យ និង ជននៅក្រោមហិតូបត្ថម្ភ មានភាពផ្ទុយគ្នា ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះសកម្មភាពដែលផលប្រយោជន៍ផ្ទុយគ្នា រវាងជននៅក្រោមហិតូបត្ថម្ភច្រើននាក់ ដែលស្ថិតនៅក្រោមហិតូបត្ថម្ភកៈដូចគ្នា ។

មាត្រា ១១៣៩.- តួនាទីរបស់ហិតូបត្ថម្ភកៈ

១-ហិតូបត្ថម្ភកៈ មានសិទ្ធិអំណាចក្នុងការយល់ព្រមឱ្យជននៅក្រោមហិតូបត្ថម្ភធ្វើសកម្មភាពដែលបានកំណត់នៅក្នុងមាត្រា ៣០ (សិទ្ធិលុបចោលសកម្មភាព) នៃក្រមនេះ ឬ លុបចោលសកម្មភាពទាំងនោះ ដែលជននៅក្រោមហិតូបត្ថម្ភបានធ្វើ ដោយគ្មានការយល់ព្រមពីហិតូបត្ថម្ភកៈ ។

២-ក្នុងការអនុវត្តកិច្ចការដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ហិតូបត្ថម្ភកៈត្រូវគោរពឆន្ទៈរបស់ជននៅក្រោមហិតូបត្ថម្ភ និង ត្រូវគិតពិចារណាដល់ស្ថានភាពផ្លូវកាយនិងផ្លូវចិត្ត និង ស្ថានភាពជីវភាពរបស់ជននោះ ។

៣-បញ្ញត្តិនៃមាត្រា ១១២០ (ករណីដែលអ្នកអាណាព្យាបាលទូទៅ មានច្រើននាក់) កថាខណ្ឌទី ២ នៃមាត្រា ១១២៣ (គម្រោងនៃចំនួនប្រាក់ចំណាយ និង សោហ៊ុយនៃអាណាព្យាបាលទូទៅ) មាត្រា ១១២៤ (កម្រៃរបស់អ្នកអាណាព្យាបាលទូទៅ) និង មាត្រា ១១២៥ (ការត្រួតពិនិត្យតួនាទីរបស់អ្នកអាណាព្យាបាលទូទៅ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះតួនាទីរបស់ហិតូបត្ថម្ភកៈ ។

៤-បញ្ញត្តិនៃមាត្រា ១០៦០ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលទាក់ទងទៅនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរវាងឪពុកម្តាយ និង កូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសិទ្ធិលើបំណុលដែលបានកើតឡើង ដោយទាក់ទងនឹងហិតូបត្ថម្ភរវាងហិតូបត្ថម្ភកៈ ឬ អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ និង ជននៅក្រោមហិតូបត្ថម្ភ ។

ជំពូកទី ៨
អាហារកាតព្វកិច្ច

មាត្រា ១១៤០.- ទំហំ និង លំដាប់ នៃជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច

១-ញាតិ ក្លាយជាជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច តាមទំហំ និង លំដាប់ ដូចខាងក្រោមនេះ :

ទី ១ ញាតិដែលរស់នៅជាមួយគ្នា ។

ទី ២ ញាតិលោហិតខ្សែផ្ទាល់ ។

ទី ៣ បងប្អូនបង្កើត ។

២-ក្រៅពីជនដែលបញ្ញត្តនៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអាចឱ្យញាតិនៅក្នុងថ្នាក់ទី ៣ (បី) ទទួលបន្ទុកករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចបាន បើមានស្ថានភាពពិសេស ។ នៅក្នុងករណីដែលអាពាហ៍ពិពាហ៍បានរលាយ ដោយសារមរណភាពរបស់សហព័ទ្ធម្ខាង បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអាហារកាតព្វកិច្ចរវាងសហព័ទ្ធដែលនៅរស់ និង ញាតិរបស់សហព័ទ្ធដែលបានទទួលមរណភាព ។

៣-ក្រោយពីបានសម្រេចសេចក្តីតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ បើមានការផ្លាស់ប្តូរស្ថានភាព តុលាការអាចលុបចោលនូវសេចក្តីសម្រេចនោះបាន ។

មាត្រា ១១៤១.- ការកំណត់ជាក់លាក់ អំពីជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច និង ជនដែលទទួលអាហារកាតព្វកិច្ច

១-ប្រសិនបើជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច មានច្រើននាក់ ជនទាំងនោះត្រូវកំណត់ជាក់លាក់ អំពីជនម្នាក់ ឬ ច្រើននាក់ ដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ដោយការពិភាក្សា ។

២-បើការពិភាក្សារវាងភាគីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះមិនបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់ជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចជាក់លាក់ ដោយគិតពិចារណាទៅលើលទ្ធភាពទ្រព្យធន អាយុ ស្ថានភាពផ្លូវកាយ និង ផ្លូវចិត្តរបស់ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ទំនាក់ទំនងបុគ្គលរបស់ភាគី និង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ស្ថានភាពផ្សេងទៀតទាំងអស់ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះករណីដែលបានកំណត់ជាក់លាក់អំពីជនដែលត្រូវទទួលអាហារកាតព្វកិច្ច នៅពេលដែលជនមានសិទ្ធិទទួលអាហារកាតព្វកិច្ចមានចំនួនច្រើននាក់ ហើយលទ្ធភាពទ្រព្យធនរបស់ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ពុំគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់ចំពោះជនទាំងអស់នោះទេ ។

មាត្រា ១១៤២.- កម្រិត ឬ របៀបនៃការផ្គត់ផ្គង់អាហារកាតព្វកិច្ច

បើការពិភាក្សាមិនបានសម្រេច ឬ បើពុំអាចពិភាក្សាអំពីកម្រិត ឬ របៀបនៃការផ្គត់ផ្គង់អាហារកាតព្វកិច្ចបានទេ តុលាការត្រូវកំណត់ ដោយគិតពិចារណាទៅលើសេចក្តីត្រូវការចាំបាច់ក្នុងជីវភាពរស់នៅរបស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច លទ្ធភាពទ្រព្យធនរបស់ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច និង ស្ថានភាពផ្សេងទៀតទាំងអស់ ។

មាត្រា ១១៤៣.- ការផ្លាស់ប្តូរ ឬ លុបចោលទំនាក់ទំនងនៃអាហារកាតព្វកិច្ច

១-ប្រសិនបើមានការផ្លាស់ប្តូរស្ថានភាព ក្រោយពីបានពិភាក្សា ឬ ក្រោយពីមានការសម្រេចសេចក្តី ចំពោះជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចជាក់លាក់ ឬ ជនដែលទទួលអាហារកាតព្វកិច្ចជាក់លាក់ ឬ កម្រិត ឬ របៀបនៃការផ្គត់ផ្គង់អាហារកាតព្វកិច្ច ភាគីអាចផ្លាស់ប្តូរទំនាក់ទំនងនៃអាហារកាតព្វកិច្ច ដោយការពិភាក្សាបាន ។

២-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ ភាគីអាចទាមទារទៅតុលាការឱ្យលុបចោល ឬ ផ្លាស់ប្តូរការពិភាក្សា ឬ ការសម្រេចសេចក្តីដែលធ្វើមុនបាន ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ១១៤១ (ការកំណត់ជាក់លាក់អំពីជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច និង ជនដែលទទួលអាហារកាតព្វកិច្ច) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលតុលាការបង្គាប់ឱ្យលុបចោល ឬ ផ្លាស់ប្តូរតាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រានេះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា ១១៤៤.- ការហាមឃាត់នូវការចាត់ចែងសិទ្ធិទាមទារអាហារកាតព្វកិច្ច

សិទ្ធិទាមទារអាហារកាតព្វកិច្ច គឺជាសិទ្ធិផ្តាច់មុខរបស់បុគ្គលដែលត្រូវការចាំបាច់នូវអាហារកាតព្វកិច្ច ហើយពុំអាចយកមកធ្វើជាកម្មវត្ថុនៃអនុប្បទាន ប្រទានកម្ម ឬ ការបង្កើតសិទ្ធិប្រាតិភោគសម្រាប់តតិយជន ឬ ជំនួញផ្សេងៗទៀតបានឡើយ ។

គន្ថីទី ៨

សន្តតិកម្ម

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

ផ្នែកទី ១

ការចាប់ផ្តើមធ្វើសន្តតិកម្ម

មាត្រា ១១៤៥.- មូលហេតុនៃការចាប់ផ្តើមធ្វើសន្តតិកម្ម

១-សន្តតិកម្ម ត្រូវចាប់ផ្តើមដោយមរណភាពរបស់មតកជន ។

២-សន្តតិកម្ម ត្រូវធ្វើឡើងដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ឬ ដោយផ្អែកតាមឆន្ទៈរបស់មតកជន ។ សន្តតិកម្មដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ហៅថាសន្តតិកម្មតាមច្បាប់សន្តតិកម្មដោយផ្អែកតាមឆន្ទៈរបស់មតកជន ហៅថាសន្តតិកម្មមានបណ្តាំ ។

មាត្រា ១១៤៦.- ទីកន្លែងចាប់ផ្តើមសន្តតិកម្ម

សន្តតិកម្ម ត្រូវចាប់ផ្តើមនៅលំនៅឋានរបស់មតកជន នាពេលទទួលមរណភាព ។

ផ្នែកទី ២

អានុភាពនៃសន្តតិកម្ម

មាត្រា ១១៤៧.- ការទទួលបន្តនូវមត៌ក

១-សន្តតិជន ត្រូវទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ចទាំងអស់ ដែលស្ថិតនៅក្រោម

ទ្រព្យសម្បត្តិរបស់មតកជន ចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្ម ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសិទ្ធិ និង ករណីយកិច្ចផ្តាច់មុខទាំងស្រុងរបស់មតកជន ។

២-ចំពោះកម្មសិទ្ធិលើវត្ថុសម្រាប់ជំនឿសាសនា និង ចេតិយ ឬ ចលនវត្ថុដែលជារតនសម្បត្តិគ្រួសារនៃបុព្វជន បើមានជនដែលត្រូវទទួលបន្តកម្មសិទ្ធិទាំងនោះ ដូចជាជនដែលត្រូវដឹកនាំពិធីបុណ្យនៃបុព្វជន ដោយយោងតាមការកំណត់របស់មតកជន ជននោះត្រូវទទួលបន្ត ។ បើមតកជនពុំបានកំណត់ទេ ជនដែលត្រូវដឹកនាំពិធីបុណ្យនៃបុព្វជន ត្រូវទទួលបន្តនូវកម្មសិទ្ធិទាំងនោះ ដោយយោងតាមទំនៀមទម្លាប់ ។ ប្រសិនបើទំនៀមទម្លាប់មិនច្បាស់លាស់ទេ តុលាការត្រូវកំណត់ជនដែលត្រូវទទួលបន្តនោះ ។

មាត្រា ១១៤៨.- ការទទួលបន្តសិទ្ធិលើទ្រព្យសម្បត្តិ ក្នុងករណីដែលមានសន្តតិជនច្រើននាក់

១-ប្រសិនបើមានសន្តតិជនច្រើននាក់ សហសន្តតិជនម្នាក់ៗ ត្រូវទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ច តាមសមាមាត្រនៃចំណែកមត៌កនោះ ។ ប៉ុន្តែ សិទ្ធិ ឬ ករណីយកិច្ចដែលមិនអាចបែងចែកបាន តាមលក្ខណៈនៃសិទ្ធិ ឬ ករណីយកិច្ចនោះ ត្រូវទទួលបន្តដោយអវិភាគីយ៍ ។

២-មត៌កនេះ នឹងត្រូវស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់សហសន្តតិជន ។

ផ្នែកទី ៣

ភាពគ្រប់លក្ខណសម្បត្តិជាសន្តតិជន

មាត្រា ១១៤៩.- បុគ្គលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ជាសន្តតិជនជាអាទិ៍

១-មានតែជនដែលមានជីវិតរស់នៅ នាពេលចាប់ផ្តើមសន្តតិកម្ម ក្រៅពីបុគ្គលដែលបញ្ញត្តចាប់ពីមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) រហូតដល់មាត្រា ១១៥២ (ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍) ខាងក្រោមនេះទេ ទើបអាចទទួលសន្តតិកម្មបាន ។

២-ទោះមានបញ្ញត្តិដូចកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៩(ទារកនៅក្នុងគភ៌) នៃក្រមនេះ ត្រូវយកមកអនុវត្តចំពោះទារកដែលនៅក្នុងគភ៌ ។

ROYAUME du CAMBODGE
LE MINISTRE du PALAIS ROYAL
1/456

មាត្រា ១១៥០.- អសមត្ថភាពនៃសន្តតិកម្ម ជាអាទិ៍

បុគ្គលដែលបានកំណត់ដូចខាងក្រោមនេះ ពុំអាចក្លាយជាសន្តតិជន ឬ ពុំអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បានឡើយ :

ក-បុគ្គលដែលបានទទួលទោស ដោយមានចេតនាធ្វើឃាត ឬ ប៉ុនប៉ងធ្វើឃាតលើមតកជន ឬ លើជនដែលមានលំដាប់សន្តតិកម្មមុន ឬ លំដាប់ស្មើគ្នា ទោះដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី ។

ខ-បុគ្គលដែលដឹងអំពីការសម្លាប់មតកជន តែមិនបានរាយការណ៍ ឬ មិនបានប្តឹង ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបុគ្គលនោះ មិនអាចវិនិច្ឆ័យអំពើល្អ ឬ អាក្រក់បាន ឬ ករណីដែលអ្នកសម្លាប់ជាសហព័ទ្ធ ឬ ញាតិលោហិតខ្សែផ្ទាល់របស់បុគ្គលនោះ ។

គ-បុគ្គលដែលបានរារាំងមតកជនក្នុងការធ្វើលុបចោល ឬ កែប្រែមតកសាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែង ។

ឃ-បុគ្គលដែលបានឱ្យមតកជនធ្វើលុបចោល ឬ កែប្រែមតកសាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែង ។

ង-បុគ្គលដែលបានក្លែង កែបន្ថំ បំផ្លាញចោល ឬ លាក់ទុកនូវលិខិតមតកសាសន៍ស្តីពីសន្តតិកម្មរបស់មតកជន ។

មាត្រា ១១៥១.- ការផ្តាច់មត៌កពីសន្តតិជន

១-មតកជន កាលនៅរស់ អាចដាក់ពាក្យសុំទៅតុលាការ ឱ្យផ្តាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ មិនឱ្យទទួលសន្តតិកម្មបាន បើជនដែលត្រូវបានសន្មតថាជាសន្តតិជនដែលមានភាគបម្រុង បានប្រព្រឹត្តនូវសកម្មភាពដែលបានកំណត់ខាងក្រោមនេះ :

ក-បើបានធ្វើបាបចំពោះមតកជន ។

ខ-បើបានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ ។

គ-បើអាចមកមើលថែទាំមតកជននៅពេលដែលមានជម្ងឺ ប៉ុន្តែមិនមកថែទាំ ។

ឃ-បើត្រូវបានទទួលសាលក្រម ឬ សាលដីកាផ្តន្ទាទោសឱ្យជាប់ពន្ធនាគារមួយ

ជីវិត ។

ង-បើបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឱ្យកត់សំគាល់ ជាអាទិ៍ ។

មតកជនក៏អាចបង្ហាញឆន្ទៈអំពីការផ្តាច់មត៌កនេះ តាមមតកសាសន៍បានដែរ ។

២-ជនដែលត្រូវបានសន្មតថាជាសន្តតិជនដែលបានទទួលការទាមទារផ្តាច់មត៌កនេះ អាចធ្វើវិវាទអំពីអត្ថិភាព ឬ នត្ថិភាព នៃមូលហេតុនៃការផ្តាច់មត៌កនេះ នៅក្នុងការសម្រេចសេចក្តីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ។

មាត្រា ១១៥២.- ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍

បើមតកជនបានធ្វើមតកសាសន៍ដូចបានកំណត់នៅក្នុងមាត្រា ១១៥១ (ការផ្តាច់មត៌កពីសន្តតិជន) ខាងលើនេះ អ្នកប្រតិបត្តិមតកសាសន៍ ត្រូវដាក់ពាក្យសុំទៅតុលាការឱ្យផ្តាច់មត៌កពីសន្តតិជន ដោយគ្មានការយឺតយ៉ាវ នៅក្រោយពេលដែលមតកសាសន៍នោះបានបង្កើតអានុភាព ។ ក្នុងករណីនេះ ការផ្តាច់មត៌កពីសន្តតិជននោះ មានអានុភាពប្រតិសកម្មចាប់ពីពេលដែលមតកជនបានទទួលមរណភាព ។

មាត្រា ១១៥៣.- ការកាន់កាប់មត៌ក ដោយអភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍

បើបុគ្គលដែលជាអភ័ព្វបុគ្គលនៃសន្តតិកម្ម ឬ បុគ្គលដែលមិនអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បាន តាមបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) ឬ បុគ្គលដែលត្រូវបានកាត់ផ្តាច់ពីសន្តតិកម្ម តាមបញ្ញត្តិនៃមាត្រា ១១៥១ (ការផ្តាច់មត៌កពីសន្តតិជន) និងមាត្រា ១១៥២ (ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍) ខាងលើនេះ កំពុងកាន់កាប់មត៌ក បុគ្គលនោះត្រូវបានចាត់ទុកថាជាអ្នកកាន់កាប់ដោយទុច្ចរិត គិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម ។

មាត្រា ១១៥៤.- ការលុបចោលនូវការផ្តាច់មត៌កពីសន្តតិជន

១-មតកជន កាលនៅរស់ អាចដាក់ពាក្យសុំទៅតុលាការ ឱ្យលុបចោលនូវការផ្តាច់មត៌កពីជន ដែលត្រូវបានសន្មតថាជាសន្តតិជន នៅពេលណាក៏បាន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

២-បញ្ញត្តិនៃមាត្រា ១១៥២ (ការផ្តាច់មត៌កពីសន្តតិជន ដោយមូតកសាសន៍) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការលុបចោលនូវការផ្តាច់មត៌កពីសន្តតិជន ។

មាត្រា ១១៥៥.- ករណីដែលសន្តតិជនជាអាទិ៍ ជាជនជាតិបរទេស

១-បើសន្តតិជន ឬ បុគ្គលដែលទទួលទ្រព្យសម្បត្តិតាមមតកសាសន៍ ពុំមានសញ្ជាតិជាខ្មែរទេ ជននោះពុំអាចទទួលដីធ្លី តាមសន្តតិកម្ម ឬ តាមអច្ច័យទាន បានឡើយ ។

២-បើសហសន្តតិជនម្នាក់ ឬ ច្រើននាក់ ពុំមានសញ្ជាតិជាខ្មែរទេ មត៌កត្រូវបែងចែកដោយពិចារណាយ៉ាងហ្មត់ចត់ទៅលើបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

៣-បើសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់ ពុំមានសញ្ជាតិជាខ្មែរទេ ដីធ្លីនៅក្នុងចំណោមមត៌ក ត្រូវក្លាយជានីតិបុគ្គល ហើយការគ្រប់គ្រង និង ការចាត់ចែងដីធ្លីនោះត្រូវធ្វើឡើងដោយសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ ។

៤-បើសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់ បានលក់ដីធ្លី ក្នុងនាមជាម្ចាស់សិទ្ធិចាត់ចែងមត៌ក ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ បានយល់ព្រមទាំងស្រុង ឬ បានយល់ព្រមដោយមានកម្រិត ថ្លៃលក់ដីធ្លីនោះ ត្រូវក្លាយជាមត៌ក ហើយនីតិបុគ្គលមត៌កដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើ នេះ ត្រូវរលត់ ។

៥-បើសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់ មិនបានលក់ដីធ្លី ក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ បានយល់ព្រមទាំងស្រុង ឬ បានយល់ព្រមដោយមានកម្រិត ដោយយោង តាមបញ្ញត្តិនៃកថាខណ្ឌទី ៤ ខាងលើនេះ កម្មសិទ្ធិលើដីធ្លីនោះ ត្រូវបានធ្វើសន្តតិកម្មដោយសន្តតិជនដែលមានលំដាប់ក្រោយបន្ទាប់ ហើយដែលមានសញ្ជាតិជាខ្មែរ ។ ក្នុងករណីនេះ នីតិបុគ្គលមត៌កដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវបានចាត់ទុកថាគ្មានអត្ថិភាព ។

(តទៅរាជកិច្ច លេខ ០៧)

ជំពូកទី ២

សន្តតិកម្មតាមច្បាប់

ផ្នែកទី ១

សន្តតិជន

មាត្រា ១១៥៦.- សន្តតិជនដែលមានលំដាប់ទី ១

១-កូនរបស់មតកជន ត្រូវក្លាយជាសន្តតិជនដែលមានលំដាប់ទី ១ ។

២-កូនរបស់មតកជន ទោះបីជាកូនបង្កើតក្តី ឬ កូនសុំក្តី ត្រូវមានចំណែកមត៌កស្មើៗគ្នា ។

មាត្រា ១១៥៧.- សន្តតិកម្មជំនួស

១-បើកូនរបស់មតកជន បានទទួលមរណភាព នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិសន្តតិកម្ម ដោយត្រូវនឹងល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) ខាងលើនេះ ឬ ដោយការផ្តាច់មត៌កកូនរបស់បុគ្គលនោះ ត្រូវក្លាយទៅជាសន្តតិជនជំនួស ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះបុគ្គលដែលមិនមែនជាបច្ឆាញាតិផ្ទាល់របស់មតកជន ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តជាបន្តបន្ទាប់ ចំពោះករណីដែលមានមូលហេតុដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនេះ ចំពោះអ្នកទទួលសន្តតិកម្មជំនួស ។

មាត្រា ១១៥៨.- ចំណែកមត៌ក ក្នុងករណីនៃសន្តតិកម្មជំនួស

ចំណែកមត៌ក របស់បច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជន ដោយយោងតាមបញ្ញត្តិនៃមាត្រា ១១៥៧(សន្តតិកម្មជំនួស) ខាងលើនេះ ត្រូវដូចគ្នានឹងចំណែកមត៌ក ដែលបុព្វញាតិផ្ទាល់របស់បច្ឆាញាតិផ្ទាល់នោះត្រូវទទួលបាន ។ ប្រសិនបើបច្ឆាញាតិផ្ទាល់មានចំនួនច្រើននាក់ ចំណែកមត៌កដែលបុព្វញាតិផ្ទាល់របស់បច្ឆាញាតិផ្ទាល់រៀងៗខ្លួននោះ ត្រូវទទួលបានត្រូវបែងចែកស្មើៗគ្នារវាងបច្ឆាញាតិទាំងឡាយនោះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា ១១៥៩.– សន្តតិជនដែលមានលំដាប់ទី ២

១-បើមតកជនពុំមានបច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ បុព្វញាតិផ្ទាល់របស់មតកជននោះ ត្រូវក្លាយជាសន្តតិជន ។ ប៉ុន្តែ រវាងបុគ្គលដែលមានថ្នាក់ញាតិខុសគ្នា ត្រូវយកបុព្វញាតិដែលនៅជិតជាងជាមុន ។

២-ប្រសិនបើបុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជន មានចំនួនច្រើននាក់ បុព្វញាតិផ្ទាល់នីមួយៗត្រូវទទួលចំណែកមត៌កស្មើៗគ្នា ។

មាត្រា ១១៦០.– សន្តតិជនដែលមានលំដាប់ទី ៣

១-បើមតកជនពុំមានទាំងបច្ឆាញាតិផ្ទាល់ ទាំងបុព្វញាតិផ្ទាល់ ដែលត្រូវក្លាយជាសន្តតិជនទេ បងប្អូនបង្កើតរបស់មតកជននោះ ត្រូវក្លាយជាសន្តតិជន ។

២-បើបងប្អូនបង្កើតមានចំនួនច្រើននាក់ បងប្អូនបង្កើតម្នាក់ៗត្រូវបានចំណែកមត៌កភាគស្មើៗគ្នា ។ ប៉ុន្តែ ចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុក ឬ ម្តាយតែម្ខាងដូចគ្នាត្រូវមាន ១ ភាគ ២ (មួយភាគពីរ) នៃចំណែកមត៌ករបស់បងប្អូនដែលមាន ឪពុក និង ម្តាយទាំងសងខាងដូចគ្នា ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស) និង បញ្ញត្តិនៃមាត្រា ១១៥៨ (ចំណែកមត៌កក្នុងករណីនៃសន្តតិកម្មជំនួស) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបងប្អូនបង្កើតរបស់មតកជនដែលត្រូវក្លាយជាសន្តតិជន យោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ បានទទួលមរណភាព នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ។

ផ្នែកទី ២

សន្តតិកម្មរបស់សហព័ន្ធ

មាត្រា ១១៦១.– សន្តតិកម្មរបស់សហព័ន្ធ

១-សហព័ន្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច ។

២-នៅក្នុងករណីដែលសហព័ន្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជន បើមានបុគ្គលផ្សេង

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ទៀតក្រៅពីសហព័ទ្ធ ត្រូវជាសន្តតិជនដែរ ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) ខាងលើនេះ សហព័ទ្ធនោះត្រូវមានលំដាប់ស្មើគ្នានឹងបុគ្គលនោះ ។

មាត្រា ១១៦២.- ចំណែកមត៌ក ក្នុងករណីដែលមានសហព័ទ្ធ

ក្នុងករណីដែលសហព័ទ្ធរបស់មតកជន និង បុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវក្លាយជាសន្តតិជន ចំណែកមត៌ករបស់សន្តតិជននឹងត្រូវមានតាមកំណត់ដូចខាងក្រោមនេះ :

ក-បើសហព័ទ្ធ និង បច្ឆាញាតិផ្ទាល់របស់មតកជននោះ ជាសន្តតិជន សហព័ទ្ធ និង កូននីមួយៗ របស់មតកជននោះ នឹងត្រូវទទួលចំណែកមត៌កស្មើគ្នា ។

ខ-បើសហព័ទ្ធ និង ឪពុក ម្តាយរបស់មតកជនជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធ ត្រូវជា ១ ភាគ ៣ (មួយភាគបី) ឯចំណែកមត៌ករបស់ឪពុក ម្តាយ ត្រូវជា ២ ភាគ ៣ (ពីរភាគបី) ។ ប៉ុន្តែ បើឪពុក ឬ ម្តាយ របស់មតកជនតែម្នាក់នៅរស់ ឪពុក ម្តាយនោះ និង សហព័ទ្ធ ត្រូវបានចំណែកមត៌កស្មើគ្នា ។

គ-បើសហព័ទ្ធ និង បុព្វញាតិផ្ទាល់ក្រៅពីឪពុក ម្តាយរបស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសបុគ្គលទាំងនោះ ជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធត្រូវជា ១ ភាគ ២ (មួយភាគពីរ) ឯចំណែកមត៌ករបស់បុព្វញាតិផ្ទាល់ ក្រៅពីឪពុក ម្តាយរបស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្ម ជំនួសនោះ ត្រូវជា ១ ភាគ ២ (មួយភាគពីរ) ។

ផ្នែកទី ៣

ការសម្រួលចំណែកមត៌ក

មាត្រា ១១៦៣.- ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស

១-នៅក្នុងចំណោមសហសន្តតិជនទាំងអស់ បើមានបុគ្គលណាដែលបានទទួលប្រទានកម្ម នៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬ ហេតុការណ៍ផ្សេងទៀត ឬ ដើម្បីមូលធននៃជីវភាពរស់នៅ ឬ ដែលបានទទួលអច្ច័យទានពីមតកជននោះ តម្លៃសរុបនៃមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ដោយបូកបញ្ចូលនូវតម្លៃនៃប្រទានកម្ម ត្រូវបានចាត់ទុកថាជាមត៌ក ហើយចំនួន

ទឹកប្រាក់ដែលនៅសល់ ក្រោយពីដកតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាននោះ ចេញពីចំណែកមត៌ក ដែលត្រូវបានគណនាតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) និង ផ្នែកទី ២ (សន្តតិកម្មរបស់សហព័ទ្ធ) គឺជាចំណែកមត៌ករបស់បុគ្គលនោះ ។

២-បើតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាន ស្មើគ្នានឹងតម្លៃនៃចំណែកមត៌ក ឬ លើសពីតម្លៃនៃចំណែកមត៌ក សហសន្តតិជននោះពុំអាចទទួលយកចំណែកមត៌កនោះបានឡើយ ។

មាត្រា ១១៦៤.- តម្លៃនៃប្រទានកម្ម

បើបដិគ្គាហក បានបាត់បង់ទ្រព្យសម្បត្តិដែលខ្លួនទទួលដោយប្រទានកម្ម នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ បើទ្រព្យសម្បត្តិនោះត្រូវបានបាត់ ឬវិនាស នៅមុនពេលចាប់ផ្តើមសន្តតិកម្ម តម្លៃនៃប្រទានកម្មដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) ខាងលើនេះ ត្រូវគណនា ដោយគិតតម្លៃនៅពេលដែលបានបាត់បង់ ឬ នៅពេលបាត់បង់ ឬវិនាសនោះ ។ ប្រសិនបើតម្លៃនៃ ប្រទានកម្មនោះត្រូវបានផ្លាស់ប្តូរដោយសារលទ្ធផលដែលបដិគ្គាហក បានផ្លាស់ប្តូរទ្រព្យសម្បត្តិនោះមួយផ្នែក តម្លៃនៃប្រទានកម្មនោះត្រូវគណនាដោយចាត់ទុកថាមានស្ថានភាពដើម នៅពេលចាប់ផ្តើមសន្តតិកម្ម ។ ការប្រាក់ និងផលចំណេញដែលកើតចេញពីប្រទានកម្ម ដែលសន្តតិជននោះបានទទួល ពុំត្រូវគណនាចូលក្នុងតម្លៃនោះឡើយ ។

មាត្រា ១១៦៥.- ករណីដែលតម្លៃទទួលផលប្រយោជន៍ពិសេសនោះ លើសពីតម្លៃនៃចំណែកមត៌ក

១-ទោះបីជាតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាន ដែលសហសន្តតិជនបានទទួលមានចំនួនលើសពីតម្លៃនៃចំណែកមត៌កក៏ដោយ សហសន្តតិជននោះ ពុំចាំបាច់បង្វិលមកវិញនូវទ្រព្យសម្បត្តិដែលទាក់ទងនឹងប្រទានកម្ម ដើម្បីសហសន្តតិជនផ្សេងទៀតឡើយ លើកលែងតែត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំណែកមត៌ករបស់សហសន្តតិជនផ្សេងទៀត ត្រូវមានចំនួនទឹកប្រាក់តាមការគណនាដោយយកមត៌ក ដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ទៅបែងចែកតាមសមាមាត្រនៃចំណែកមត៌ករបស់សហសន្តតិជននីមួយៗ ដែលត្រូវបានកំណត់ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ១១៦៣

(ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) ខាងលើនេះ ។

មាត្រា ១១៦៦.- ភាគនៃវិភាគទាន

១-ក្នុងចំណោមសហសន្តតិជនទាំងឡាយ បើមានបុគ្គលណាបានធ្វើវិភាគទានពិសេស ដើម្បីថែរក្សា ឬ បង្កើនទ្រព្យសម្បត្តិរបស់មតកជន ដោយការផ្តល់សេវាកម្មលើកិច្ចការរបស់មតកជន ឬ ដោយការផ្តល់តាវកាលិកលើទ្រព្យសម្បត្តិ ឬ ដោយការថែទាំ ព្យាបាលមតកជន ឬ ដោយវិធីផ្សេងទៀត តម្លៃដែលដកភាគនៃវិភាគទានរបស់បុគ្គលនោះ ដែលបានកំណត់តាមការពិភាក្សារបស់សហសន្តតិជន ចេញពីតម្លៃមត៌កដែលមតកជន មាននៅពេលចាប់ផ្តើមសន្តតិ-កម្ម ត្រូវចាត់ទុកថាជាមត៌ក ហើយចំនួនទឹកប្រាក់នៃភាគ នៅក្នុងសន្តតិកម្ម ដែលបានគណនាតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) និងផ្នែកទី ២ (សន្តតិកម្មរបស់សហព័ទ្ធ) បូកនឹងភាគវិភាគទាន ត្រូវជាចំណែកមត៌ករបស់ជននោះ ។

២-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់ភាគនៃវិភាគទាន តាមពាក្យសុំរបស់បុគ្គលដែលបានធ្វើវិភាគទានដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នោះ ដោយ ពិចារណាទៅលើពេល វិធី និង កម្រិតនៃវិភាគទាននោះ ចំនួនទឹកប្រាក់នៃមត៌ក និង ស្ថានភាពទាំងអស់ផ្សេងទៀត ។

៣-ភាគនៃវិភាគទាន មិនអាចឱ្យលើសពីចំនួនទឹកប្រាក់ដែលបានដកចេញនូវតម្លៃនៃអច្ច័យទាន និង តម្លៃនៃទ្រព្យសម្បត្តិ ដែលមតកជនបានកំណត់ថាជាចំណែកមត៌ករបស់សហ-សន្តតិជន ឬ ជាវិធីបែងចែកមត៌កពីចំនួនតម្លៃនៃមត៌ក ដែលមតកជនមាន នៅពេលចាប់ផ្តើមសន្តតិកម្មឡើយ ។

៤-ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ អាចធ្វើបានក្នុងករណីដែលមានពាក្យសុំ ដោយយោងតាមកថាខណ្ឌទី ១ នៃមាត្រា ១២៧០ (ការបែងចែកដោយតុលា-ការ) ឬ មានពាក្យបណ្តឹង ដោយយោងតាមមាត្រា ១២៧៤ (ការទាមទាររបស់ជនដែលត្រូវបានទទួលស្គាល់ក្រោយការបែងចែកមត៌ក) ។

មាត្រា ១១៦៧.- ទំនាក់ទំនងជាមួយនឹងតតិយជន

ត្រូវផ្លាស់ប្តូរចំណែកមត៌កដែលយោងតាមបញ្ញត្តិនៃផ្នែកទី ៣ (ការសម្រួលចំណែក

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

មត៌ក) នេះ មិនអាចយកមកអះអាងនឹងតតិយជនបានឡើយ បើមិនមានល័ក្ខខ័ណ្ឌតតាំង ចំពោះលទ្ធផលនៃការបែងចែកមត៌ក ដោយផ្អែកលើការសម្រួលនោះទេ ។

ជំពូកទី ៣

សន្តតិកម្មតាមមតកសាសន៍

ផ្នែកទី ១

សមត្ថភាពក្នុងការធ្វើមតកសាសន៍

មាត្រា ១១៦៨.- បុគ្គលដែលអាចធ្វើមតកសាសន៍បាន

១-បុគ្គលដែលជានីតិជន និង អនីតិជនដែលបានអត្តាធីនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬ អំណាចមេបា អាចធ្វើមតកសាសន៍បាន ។

២-បញ្ញត្តិនៃមាត្រា ២៦ (សិទ្ធិលុបចោលសកម្មភាព) និង មាត្រា ៣០ (សិទ្ធិលុបចោលសកម្មភាព) នៃក្រមនេះ មិនត្រូវយកមកអនុវត្តចំពោះមតកសាសន៍ឡើយ ។

មាត្រា ១១៦៩.- សមត្ថភាពនាពេលធ្វើមតកសាសន៍

១-ម្ចាស់បណ្តាំ ត្រូវមានសមត្ថភាព នៅពេលធ្វើមតកសាសន៍ ។

២-បុគ្គលដែលអះអាងអំពីការខ្វះសមត្ថភាពរបស់ម្ចាស់បណ្តាំ ត្រូវបញ្ជាក់ភស្តុតាងអំពីហេតុនោះ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបានកំណត់នៅក្នុងមាត្រា ១១៧៦ (មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

ផ្នែកទី ២

ទម្រង់នៃមតកសាសន៍

មាត្រា ១១៧០.- ភាពចាំបាច់នៃទម្រង់មតកសាសន៍

១-មតកសាសន៍ ពុំអាចធ្វើបានឡើយ បើពុំផ្អែកតាមទម្រង់ដែលបានកំណត់ក្នុងក្រមនេះទេ ។

២-មតកសាសន៍ដែលធ្វើមិនត្រូវនឹងទម្រង់ណាមួយក្នុងបញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកជាមោឃៈ ។ ប៉ុន្តែ មតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ ត្រូវចាត់ទុកថាមានសុពលភាព លុះ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ត្រាតែមតកសាសន៍នោះ មិនផ្ទុយនឹងមតកសាសន៍ផ្សេងទៀតដែលបានធ្វើដោយម្ចាស់បណ្តាំដូចគ្នានេះ ។ នៅក្នុងករណីដែលមតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំមានចំនួនច្រើន ហើយបើមតកសាសន៍ទាំងនេះ ផ្ទុយនឹងគ្នាអានុភាពនៃមតកសាសន៍ទាំងនោះ ត្រូវកាត់បន្ថយគ្នាទៅវិញទៅមក ។

មាត្រា ១១៧១.- សុពលភាពនៃទម្រង់

មតកសាសន៍ដែលត្រូវនឹងទម្រង់ណាមួយដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវចាត់ទុកថាមានសុពលភាពចំពោះទម្រង់ ។

មាត្រា ១១៧២.- បុគ្គលដែលមិនអាចក្លាយជាសាក្សី ជាអាធិ៍

បុគ្គលដែលកំណត់ដូចខាងក្រោមនេះ មិនអាចធ្វើជាសាក្សី ឬ ជាអ្នកសង្កេតការណ៍ នៅពេលធ្វើមតកសាសន៍បានឡើយ :

ក-អនីតិជន ឬ ជននៅក្រោមអាណាព្យាបាលធម្មតា ។

ខ-ជនដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី ហើយនិងសហព័ទ្ធ និង ញាតិលោហិតខ្សែផ្ទាល់ របស់ជនទាំងនោះ ។

គ-បើសារការីជាអ្នកពាក់ព័ន្ធក្នុងការធ្វើមតកសាសន៍ជាលិខិតយថាភូត ឬ ជាលិខិតមតកសាសន៍សម្ងាត់ សហព័ទ្ធរបស់សារការី ញាតិលោហិតខ្សែផ្ទាល់ ក្រឡាបញ្ជី និង និយោជិតរបស់សារការីនោះ ។

មាត្រា ១១៧៣.- មតកសាសន៍ដោយលិខិតយថាភូត

១-មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើងដោយម្ចាស់បណ្តាំ នៅចំពោះមុខសារការី តាមទម្រង់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងក្រោមនេះ ។

២-មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ :

ក-ត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិច ២ (ពីរ) នាក់ ។

ខ-ម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់ នូវខ្លឹមសារនៃមតកសាសន៍ ចំពោះសារការី ។

ROYAUME DU CAMBODGE
LE MINISTRE du PALAIS ROYAL

គ-សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះ ជាលាយលក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្តាំ និង សាក្សីនោះស្តាប់ ។

ឃ-បន្ទាប់ពីម្ចាស់បណ្តាំ និង សាក្សី បានទទួលស្គាល់ថាកំណត់ជាលាយលក្ខណ៍អក្សរនោះត្រឹមត្រូវហើយ ជននីមួយៗនោះត្រូវធ្វើឱ្យមានភាពច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ និង លំនៅឋាន ហើយត្រូវចុះហត្ថលេខារៀងៗខ្លួន ។ ប៉ុន្តែ បើម្ចាស់បណ្តាំមិនអាចសរសេរអក្សរ ឬ មិនអាចចុះហត្ថលេខាបានទេ សារការីអាចជំនួសការសរសេរ និង ហត្ថលេខាដូចកំណត់ខាងលើនេះ ដោយសរសេរឈ្មោះ អាយុ និង លំនៅឋានរបស់ជននោះ ហើយត្រូវសរសេរបន្ថែមនូវហេតុនោះផង ។

ង-សារការីត្រូវសរសេរថ្ងៃខែឆ្នាំ ហើយត្រូវចុះហត្ថលេខា ។

មាត្រា ១១៧៤.- មតកសាសន៍ដោយលិខិតឯកជន

១-មតកសាសន៍ដោយលិខិតឯកជន ត្រូវធ្វើឡើង ដោយម្ចាស់បណ្តាំសរសេរពាក្យទាំងអស់ និង ចុះថ្ងៃខែឆ្នាំ ដោយខ្លួនឯង ហើយត្រូវចុះហត្ថលេខាលើលិខិតនោះ ។ មតកសាសន៍ដោយលិខិតឯកជនដែលត្រូវបានសរសេរជំនួសដោយអ្នកដទៃ ឬ ដែលត្រូវបានសរសេរដោយប្រើម៉ាស៊ីនដូចជាអង្គុលីលេខ ជាអាទិ៍ នឹងត្រូវចាត់ទុកជាមោឃៈ ។

២-ការបន្ថែម ការលុប ឬ ការកែប្រែផ្សេងទៀត នៅក្នុងមតកសាសន៍ដោយលិខិតឯកជន ពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំមិនបានបង្ហាញនូវកន្លែង ហើយសរសេរបន្ថែមនូវហេតុនៃការកែប្រែនោះ ជាពិសេសបើមិនបានចុះហត្ថលេខាទេ ។

មាត្រា ១១៧៥.- មតកសាសន៍ដោយលិខិតសម្ងាត់

មតកសាសន៍ដោយលិខិតសម្ងាត់ ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ :

ក-ម្ចាស់បណ្តាំត្រូវចុះហត្ថលេខាលើលិខិតនោះ ។

ខ-ម្ចាស់បណ្តាំត្រូវដាក់លិខិតនោះក្នុងស្រោមបិទជិត ហើយត្រូវចុះហត្ថលេខា ឬ សរសេរសញ្ញាសំគាល់ ឬ មធ្យោបាយផ្សេងទៀតដែលអាចវិនិច្ឆ័យបានអំពីការបានបើក ឬ មិនបានបើកស្រោមលិខិតនោះ នៅមាត់ស្រោមលិខិតនោះ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

គ-ម្ចាស់បណ្តាំត្រូវដាក់លិខិតដែលបានបិទជិតនោះ នៅចំពោះមុខសារការីម្នាក់ និង សាក្សី ២ (ពីរ) នាក់ និង ធ្វើសេចក្តីថ្លែងការណ៍ថា លិខិតនេះជាលិខិតមតកសាសន៍របស់ខ្លួន ហើយបើមានជនក្រៅពីសាមីខ្លួនបានសរសេរ ត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីឈ្មោះ និង លំនៅឋានរបស់ជនដែលបានសរសេរនោះ ។

ឃ-សារការីត្រូវចុះថ្ងៃខែឆ្នាំដែលសាមីខ្លួនបានដាក់លិខិតនោះ និង សរសេរសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំ នៅលើលិខិតដែលបិទជិតនោះ ហើយត្រូវចុះហត្ថលេខាលើលិខិតនោះ ជាមួយគ្នានឹងសាក្សី និង ម្ចាស់បណ្តាំ ។

មាត្រា ១១៧៦.- មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ

១-ដើម្បីធ្វើមតកសាសន៍ នៅពេលដែលជននៅក្រោមអាណាព្យាបាលទូទៅ បានសះស្បើយមួយរយៈឡើងវិញនូវសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ត្រូវមានវត្តមានរបស់វេជ្ជបណ្ឌិតយ៉ាងតិច ២ (ពីរ) នាក់ ។

២-វេជ្ជបណ្ឌិតដែលមានវត្តមាននៅពេលធ្វើមតកសាសន៍ ត្រូវសរសេរបញ្ជាក់បន្ថែមលើលិខិតមតកសាសន៍នោះថា នៅពេលដែលម្ចាស់បណ្តាំបានធ្វើមតកសាសន៍នោះ ម្ចាស់បណ្តាំពុំបានស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិស្មារតីទេ ហើយត្រូវចុះហត្ថលេខា ដោយបញ្ជាក់ថាខ្លួនជាវេជ្ជបណ្ឌិតផងដែរ ។

មាត្រា ១១៧៧.- មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត

១-ប្រសិនបើជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ដោយសារជម្ងឺ ឬ ហេតុផ្សេងទៀត មានបំណងចង់ធ្វើមតកសាសន៍ មតកសាសន៍នេះអាចធ្វើបាន ដោយតម្រូវឱ្យមានវត្តមានរបស់សាក្សីយ៉ាងតិច ៣ (បី) នាក់ ហើយដោយប្រកាសខ្លឹមសារនៃមតកសាសន៍នោះ ដោយផ្ទាល់មាត់ ចំពោះជនម្នាក់ក្នុងចំណោមសាក្សីនោះ ។ នៅក្នុងករណីនេះ ជនដែលបានទទួលការប្រកាសដោយផ្ទាល់មាត់នោះ ត្រូវសរសេរជាលាយល័ក្ខណ៍អក្សរ ហើយអានឱ្យសាក្សីស្តាប់ ឬ ឱ្យមើល ហើយនៅក្រោយពេលដែលសាក្សីនីមួយៗបានទទួលស្គាល់ថាការសរសេរនោះត្រឹមត្រូវហើយ សាក្សីនីមួយៗនោះ ត្រូវចុះហត្ថលេខាលើលិខិតនោះ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

២-មតកសាសន៍ដែលបានធ្វើតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ បើសាក្សីណាម្នាក់ ឬ បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ពុំបានដាក់ពាក្យសុំទៅតុលាការ នៅក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានធ្វើមតកសាសន៍នោះ ហើយពុំបានទទួលការបញ្ជាក់ទេ ។

៣-តុលាការមិនអាចធ្វើការបញ្ជាក់មតកសាសន៍បានឡើយ ប្រសិនបើពុំមានជំនឿទុកចិត្តថាមតកសាសន៍នោះ ចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ ។

មាត្រា ១១៧៨.- មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង ជាអាទិ៍

១-បុគ្គលដែលជាប់ឃុំឃាំងនៅទីកន្លែងដាច់ដោយឡែក ដោយសាលក្រម ឬ សាលដីកា ឬ ដោយសារការចាត់ចែងផ្នែករដ្ឋបាល អាចធ្វើលិខិតមតកសាសន៍បានដោយត្រូវឱ្យមានវត្តមានរបស់នគរបាល ឬ មន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ និង សាក្សី យ៉ាងតិច ២ (ពីរ) នាក់ ។

២-បុគ្គលដែលនៅក្នុងនាវា ឬ យន្តហោះ អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវឱ្យមានវត្តមានមេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះម្នាក់ និងសាក្សីយ៉ាងតិច ២ (ពីរ) នាក់ ។

៣-នៅពេលធ្វើមតកសាសន៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍ ដោយផ្ទាល់មាត់ ចំពោះនគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះបាន ។

៤-បញ្ញត្តិពីចំណុច ខ ដល់ចំណុច ង កថាខណ្ឌទី ២ នៃមាត្រា ១១៧៣ (មតកសាសន៍ដោយលិខិតយថាភូត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ។ ក្នុងករណីនេះ ពាក្យសារការីត្រូវបានបកស្រាយថាជានគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះ ។

៥-មតកសាសន៍ដែលត្រូវបានធ្វើឡើង ដោយយោងតាមបញ្ញត្តិពីកថាខណ្ឌទី ១ ដល់កថាខណ្ឌទី ៤ ខាងលើនេះ ពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំបន្តនៅរស់ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីពេលដែលម្ចាស់បណ្តាំនោះ បែរជាអាចធ្វើមតកសាសន៍បានតាមទម្រង់

-ទៀត-

ណាមួយដែលបានកំណត់ចាប់ពីមាត្រា ១១៧៣ (មតកសាសន៍ដោយ លិខិតយថាភូត) ដល់មាត្រា ១១៧៥ (មតកសាសន៍ដោយលិខិតសម្ងាត់) នៃក្រមនេះ ក្រោយពេលខ្លួនត្រូវបានដោះលែងពីមន្ទីរឃុំឃាំង ឬ ចុះពីនាវា ឬ យន្តហោះ ។

មាត្រា ១១៧៩.- ការធ្វើមតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន ជាអាទិ៍

១-នៅក្នុងករណីដែលបុគ្គលមិនអាចនិយាយបាន ធ្វើមតកសាសន៍តាមទម្រង់ដែលបានកំណត់នៅក្នុងមាត្រា ១១៧៣ (មតកសាសន៍ដោយលិខិតយថាភូត) មាត្រា ១១៧៥ (មតក-សាសន៍ដោយលិខិតសម្ងាត់) មាត្រា ១១៧៧(មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះ-ថ្នាក់បន្ទាន់ដល់អាយុជីវិត) នៃក្រមនេះ ម្ចាស់បណ្តាំនោះអាចជំនួសការប្រាប់បាន ដោយធ្វើសេចក្តីថ្លែងការណ៍អំពីខ្លឹមសារនៃមតកសាសន៍ ឬ សេចក្តីថ្លែងការណ៍ថា លិខិតនោះជាលិខិតមតក-សាសន៍ តាមការបកប្រែរបស់អ្នកបកប្រែ ឬ សរសេរដោយដៃខ្លួនផ្ទាល់ នៅចំពោះមុខសារការី ឬ សាក្សី ។

២-ក្នុងករណីដែលសារការី ឬ បុគ្គលផ្សេងទៀតដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវអានឱ្យម្ចាស់បណ្តាំ ឬ សាក្សី ស្តាប់នូវអត្ថន័យនៃមតកសាសន៍ ក្រោយពេលបានសរសេរជាលាយល័ក្ខណ៍អក្សរនូវខ្លឹមសារនៃមតកសាសន៍នោះ បើម្ចាស់បណ្តាំ និង សាក្សីនោះបែរជាមនុស្សថ្លង់មិនអាចស្តាប់បានទេ សារការី ឬ បុគ្គលផ្សេងទៀតដែលត្រូវបានកំណត់នៅក្នុងក្រមនេះ អាចជំនួសការអានឱ្យស្តាប់បាន ដោយប្រាប់អំពីអត្ថន័យដែលខ្លួនបានសរសេរនោះ តាមការបកប្រែរបស់អ្នកបកប្រែទៅម្ចាស់បណ្តាំ ឬ សាក្សីនោះ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ សារការី ឬ បុគ្គលផ្សេងទៀតដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវសរសេរអំពីហេតុនោះ ចូលទៅក្នុងលិខិតនោះ ។

មាត្រា ១១៨០.- ការសរសេរនាមត្រកូល និង នាមខ្លួន និង ការផ្តិតម្រាមដៃ ជំនួសឱ្យការចុះហត្ថលេខា

ក្នុងករណីដែលសារការី និង សាក្សី ត្រូវចុះហត្ថលេខា សារការី និង សាក្សី គ្រាន់តែសរសេរនាមត្រកូល និង នាមខ្លួន និង ផ្តិតម្រាមដៃ ជាការគ្រប់គ្រាន់ហើយ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

មាត្រា ១១៨១.- បទប្បញ្ញត្តិពិសេសចំពោះមតកសាសន៍របស់ជនជាតិខ្មែរដែលរស់នៅបរទេស

បើជនជាតិខ្មែរមានបំណងចង់ធ្វើមតកសាសន៍ដោយលិខិតយថាភូត ឬ លិខិតសម្ងាត់ នៅកន្លែងដែលមានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅកុងស៊ុលនោះ ត្រូវអនុវត្តមុខនាទីរបស់សារការី ។

ផ្នែកទី ៣
ចំណុចនៃមតកសាសន៍

មាត្រា ១១៨២.- ការកំណត់ចំណែកមត៌ក

១-មតកជនអាចកំណត់ចំណែកមត៌ករបស់សហសន្តតិជនតាមមតកសាសន៍ ឬ អាចបង្ហាញឆន្ទៈផ្ទុយពីបញ្ញត្តិនៃមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) នៃក្រមនេះ ស្តីពីចំណែកមត៌ករបស់បុគ្គលដែលបានទទួលផលប្រយោជន៍ពិសេសបាន ។ ប៉ុន្តែ ការកំណត់ចំណែកមត៌កដែលបំពានភាគបម្រុង ត្រូវអនុលោមតាមបញ្ញត្តិស្តីពីភាគបម្រុង ។

២-បើមតកជនបានកំណត់ចំណែកមត៌ក ចំពោះសន្តតិជនតែម្នាក់ ឬ ច្រើននាក់ ក្នុងចំណោមសហសន្តតិជនទាំងអស់ ចំណែកមត៌ករបស់សហសន្តតិជនផ្សេងទៀត ត្រូវកំណត់ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ៣(ការសម្រួលចំណែកមត៌ក) ជំពូកទី ២។

មាត្រា ១១៨៣.- ការកំណត់នូវវិធីបែងចែកដោយមតកសាសន៍ ជាអាទិ៍

មតកជន អាចកំណត់នូវវិធីបែងចែកតាមមតកសាសន៍ ឬ អាចប្រគល់អាណត្តិឱ្យតតិយ-ជនកំណត់វិធីនោះ ឬ អាចហាមឃាត់មិនឱ្យបែងចែកនៅក្នុងអំឡុងពេលដែលមិនលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្មនោះបាន ។

មាត្រា ១១៨៤.- អនុប្បទានទ្រព្យសម្បត្តិ

ម្ចាស់បណ្តាំអាចធ្វើប្រទានកម្មនូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែក ឬ អាចធ្វើប្រទានកម្មដោយមតកសាសន៍ តាមវិធីដែលបានកំណត់នៅក្នុងមាត្រា ១១៩៩(និយមន័យនៃអច្ច័យទាន) នៃក្រមនេះបាន នៅក្នុងលក្ខខណ្ឌដែលអនុលោមតាមបញ្ញត្តិស្តីពីភាគបម្រុង ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

មាត្រា ១១៨៥.- អនុប្បទានទ្រព្យសម្បត្តិចំពោះសន្តតិជន

១-បើមតកជនបានធ្វើមតកសាសន៍ដែលមានអត្ថន័យជាការធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬ ច្រើន ឱ្យទៅសហសន្តតិជនតែម្នាក់ ឬ ច្រើននាក់ មតកសាសន៍នោះ ត្រូវបានសន្មតថាបានកំណត់នូវវិធីបែងចែកមត៌ក លើកលែងតែនៅក្នុងករណីដែលមតកសាសន៍នោះមានអត្ថន័យជាអច្ច័យទានយ៉ាងច្បាស់លាស់ ដូចជាអច្ច័យទានដែលភ្ជាប់ជាមួយនឹងបន្ទុកជាអាទិ៍ ហើយបើតម្លៃនៃទ្រព្យសម្បត្តិដែលបានកំណត់នោះ មានចំនួនលើសពីចំណែកមត៌ករបស់សន្តតិជន នោះត្រូវសន្មតថាបានកំណត់ចំណែកមត៌កផងដែរ ។

២-ក្នុងករណីដែលមតកជនបានធ្វើមតកសាសន៍ ចំពោះទ្រព្យសម្បត្តិតែមួយភាគនៅក្នុងចំណោមមត៌ក បើតម្លៃនៃទ្រព្យសម្បត្តិនោះ មានចំនួនតិចជាងចំណែកមត៌ក ដែលសន្តតិជននោះត្រូវទទួល លុះត្រាតែពុំមានការបង្ហាញឆន្ទៈផ្សេងទៀតនៅក្នុងមតកសាសន៍នោះត្រូវសន្មតថាបានកំណត់ត្រឹមតែវិធីបែងចែកមត៌កដែលត្រូវធ្លាក់ទៅលើសន្តតិជននោះ តែប៉ុណ្ណោះ ។

មាត្រា ១១៨៦.- ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍

ម្ចាស់បណ្តាំអាចកំណត់អ្នកប្រតិបត្តិមតកសាសន៍ម្នាក់ ឬ ច្រើននាក់ ឬ អាចប្រគល់អាណត្តិឱ្យតតិយជនកំណត់អ្នកប្រតិបត្តិនោះ តាមមតកសាសន៍បាន ។

មាត្រា ១១៨៧.- ចំណុចផ្សេងៗ

ក្រៅពីធ្វើមតកសាសន៍តាមចំណុចដែលបានកំណត់នៅក្នុងក្រមនេះ ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍ដោយផ្តល់ដំបូន្មាន ឬ យោបល់ ដើម្បីឱ្យមានភាពសុខដុមរមនាដល់ក្រុមគ្រួសារ និង ចំណុចផ្សេងៗទៀតបាន ។ នៅក្នុងករណីនេះ សន្តតិជនជាអាទិ៍ ត្រូវគោរពទៅតាមមតកសាសន៍នោះ ។

ផ្នែកទី ៤

ការលុបចោលនូវមតកសាសន៍

មាត្រា ១១៨៨.- ពេល និង ទម្រង់នៃការលុបចោលនូវមតកសាសន៍

ម្ចាស់បណ្តាំអាចលុបចោលនូវមតកសាសន៍ មួយភាគ ឬ ទាំងមូល នៅពេលណាក៏បាន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ៤ (ការលុបចោលនូវមតកសាសន៍) នេះ ។

មាត្រា ១១៨៩.- ការលុបចោលដោយទម្រង់នៃមតកសាសន៍

១-ម្ចាស់បណ្តាំអាចលុបចោលនូវមតកសាសន៍ មួយភាគ ឬ ទាំងមូលបាន តាមទម្រង់នៃមតកសាសន៍ ។

២-បើមតកសាសន៍ដែលបានធ្វើក្រោយនេះ មានភាពផ្ទុយនឹងមតកសាសន៍ដែលបានធ្វើមុន ត្រូវចាត់ទុកថា មតកសាសន៍ដែលបានធ្វើក្រោយនោះ បានលុបចោលមតកសាសន៍ដែលបានធ្វើមុន ចំពោះផ្នែកដែលផ្ទុយគ្នានោះ ។

មាត្រា ១១៩០.- ការលុបចោលមតកសាសន៍ ដោយការចាត់ចែងនាពេលនៅរស់

បើម្ចាស់បណ្តាំបានធ្វើអនុប្បទាន ឬ បានធ្វើសកម្មភាពផ្សេងទៀត ចំពោះវត្ថុដែលជាកម្មវត្ថុនៃមតកសាសន៍ នាពេលនៅរស់ ត្រូវចាត់ទុកថា ម្ចាស់បណ្តាំបានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលផ្ទុយនឹងអនុប្បទាន ឬ សកម្មភាពផ្សេងនោះ ។

មាត្រា ១១៩១.- ការលុបចោលដោយការបដិសេធលិខិតមតកសាសន៍ ជាអាទិ៍

បើម្ចាស់បណ្តាំបានបំផ្លាញច្បាប់ដើមនៃមតកសាសន៍ ដោយចេតនា ត្រូវចាត់ទុកថាបានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលត្រូវបានបំផ្លាញនោះ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់បណ្តាំបានបំផ្លាញវត្ថុដែលជាកម្មវត្ថុនៃមតកសាសន៍ដោយចេតនា ។

មាត្រា ១១៩២.- ការបោះបង់សិទ្ធិលុបចោលមតកសាសន៍

ម្ចាស់បណ្តាំមិនអាចបោះបង់សិទ្ធិលុបចោលមតកសាសន៍បានឡើយ ។

មាត្រា ១១៩៣.- ការលុបចោលអច្ច័យទានដែលភ្ជាប់បន្ទុក

បើអច្ច័យលាភីពុំបានអនុវត្តករណីយកិច្ចដែលម្ចាស់បណ្តាំបានតម្រូវឱ្យអច្ច័យលាភីនោះទទួលបន្ទុកជាថ្នូរនឹងអច្ច័យទានទេ អ្នកប្រតិបត្តិមតកសាសន៍ ឬ បើគ្មានអ្នកប្រតិបត្តិមតកសាសន៍នោះទេ សាមីជនអាចដាស់តឿនឱ្យអច្ច័យលាភីនោះ អនុវត្តករណីយកិច្ចនោះ ដោយកំណត់អំឡុងពេលសមរម្យ ហើយប្រសិនបើអច្ច័យលាភីនោះ មិនបានអនុវត្តករណីយកិច្ចនៅក្នុងអំឡុង

ពេលនោះទេ អ្នកប្រតិបត្តិមតកសាសន៍ ឬ សន្តតិជននោះ អាចទាមទារទៅតុលាការឱ្យលុបចោលអច្ច័យទាននោះបាន ។

ផ្នែកទី ៥
អានុភាពនៃមតកសាសន៍

មាត្រា ១១៩៤.- ពេលដែលមតកសាសន៍បង្កើតអានុភាព

១-មតកសាសន៍ ត្រូវបង្កើតអានុភាព ចាប់ពីពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ។

២-នៅក្នុងករណីដែលមតកសាសន៍ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ បើល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញនៅក្រោយពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព មតកសាសន៍នោះ ត្រូវមានអានុភាព ចាប់ពីពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ ។

មាត្រា ១១៩៥.- អានុភាពនៃការកំណត់ចំណែកមត៌ក ជាអាទិ៍

១-បើមតកជនបានកំណត់ចំណែកមត៌ក ឬវិធីបែងចែកមត៌ក ដោយធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬ ច្រើន ឱ្យចំពោះសន្តតិជនតែម្នាក់ ឬ ច្រើននាក់ ដោយមតកសាសន៍ ទ្រព្យសម្បត្តិជាក់លាក់នោះ ត្រូវផ្ទេរទៅសន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះ ដោយស្វ័យប្រវត្តិ ព្រមគ្នានឹងពេលមតកសាសន៍នោះបង្កើតអានុភាព ។

២-នៅក្នុងករណីដែលមតកសាសន៍ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ បើល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញនៅក្រោយពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចាត់ទុកថាត្រូវបានផ្ទេរទៅសន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះ ដោយប្រតិសកម្ម គឺតចាប់តាំងពីពេល ដែលមតកជននោះ បានទទួលមរណភាព ។

មាត្រា ១១៩៦.- មរណភាពនៃជនដែលត្រូវបានសន្មតថាជាសន្តតិជន ជាអាទិ៍

១-នៅក្នុងករណីដែលមតកជនបានកំណត់ចំណែកមត៌ករបស់សន្តតិជន ឬវិធីនៃការបែងចែកមត៌កដោយមតកសាសន៍ បើជនដែលត្រូវបានសន្មតថាជាសន្តតិជន បានទទួលមរណ-

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ភាព នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិសន្តតិកម្ម ដោយត្រូវនឹងបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) នៃក្រមនេះ ឬ ដោយការកាត់កាល់សន្តតិជន ការកំណត់នោះត្រូវបានចាត់ទុកថា បានធ្វើចំពោះអ្នកទទួលសន្តតិកម្មជំនួសរបស់ជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើគ្មានអ្នកទទួលសន្តតិកម្មជំនួសជនដែលត្រូវបានសន្មតថាជាសន្តតិជននោះទេ ការកំណត់ចំពោះជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ ពុំត្រូវបង្កើតអានុភាពឡើយ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសន្តតិជនបានបោះបង់សន្តតិកម្ម ។

៣-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះក៏ដោយ បើមតកជនបានបង្ហាញឆន្ទៈផ្សេង ក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

មាត្រា ១១៩៧.- ការកម្រិតនូវមតកសាសន៍ ចំពោះអ្នកអាណាព្យាបាល ជាអាទិ៍

១-បើជនដែលនៅក្រោមអាណាព្យាបាលទូទៅ បានធ្វើមតកសាសន៍ ដែលជាផលប្រយោជន៍ដល់អ្នកអាណាព្យាបាល ឬ សហព័ទ្ធ ឬ បច្ឆាញាតិផ្ទាល់របស់អ្នកអាណាព្យាបាលនោះ នៅមុនពេលបញ្ចប់ការគណនានូវចំណូលចំណាយក្នុងកិច្ចការអាណាព្យាបាល មតកសាសន៍នោះត្រូវចាត់ទុកជាមោឃៈ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលញាតិលោហិតផ្ទាល់ សហព័ទ្ធ ឬ បងប្អូនបង្កើត ជាអ្នកអាណាព្យាបាលទូទៅ ។

មាត្រា ១១៩៨.- សិទ្ធិទទួលទ្រព្យសម្បត្តិ ក្នុងករណីដែលអច្ច័យទានមោឃៈ ជាអាទិ៍

បើអច្ច័យទានពុំបានបង្កើតអានុភាព ដោយសារអច្ច័យលាភីជាអភ័ព្វបុគ្គល ឬ ទទួលមរណភាព ឬ ដោយសារហេតុផ្សេងទៀត ឬ បើពុំបានបង្កើតអានុភាពដោយសារការបោះបង់ទ្រព្យដែលអច្ច័យលាភីត្រូវទទួលនោះ ត្រូវធ្លាក់ទៅសន្តតិជនរបស់មតកជន ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ផ្នែកទី ៦
អច្ច័យទាន

មាត្រា ១១៩៩.- និយមន័យនៃអច្ច័យទាន

អច្ច័យទានសកល គឺជាប្រទានកម្មដែលម្ចាស់បណ្ដាំផ្ញើទៅឱ្យមនុស្សម្នាក់ ឬ ច្រើននាក់ នូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែកដែលកំណត់ទៅតាមភាគ រីឯអច្ច័យទានមានកំណត់ គឺជាប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ ទៅឱ្យមនុស្សម្នាក់ ឬ ច្រើននាក់ ដោយមតកសាសន៍ ។

មាត្រា ១២០០.- មរណភាពរបស់អច្ច័យលាភី

១-អច្ច័យទាន ពុំបង្កើតអានុភាពឡើយ បើអច្ច័យលាភីបានទទួលមរណភាព នៅមុន ឬ ក្នុងពេលដែលម្ចាស់បណ្ដាំទទួលមរណភាព ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះករណីដែលអច្ច័យទានភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ ហើយអច្ច័យលាភីបានទទួលមរណភាពនៅមុនពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បើម្ចាស់បណ្ដាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

៣-ក្នុងករណីដែលសន្តតិជនដែលត្រូវបានសន្មត ជាអច្ច័យលាភី បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងចំពោះការយកបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ១១៩៦ (មរណភាពនៃជនដែលត្រូវបានសន្មតថាជាសន្តតិជន ជាអាទិ៍) នៃក្រមនេះមកអនុវត្តឡើយ ។

មាត្រា ១២០១.- ការបោះបង់អច្ច័យទាន

១-នៅក្រោយពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព អច្ច័យលាភីអាចបោះបង់អច្ច័យទាន នៅពេលណាក៏បាន ។ ប៉ុន្តែ ចំពោះការបោះបង់អច្ច័យទានសកល ត្រូវអនុលោមតាមបញ្ញត្តិស្ដីពីការបោះបង់សន្តតិកម្ម ។

២-ការបោះបង់អច្ច័យទាន ត្រូវមានអានុភាពប្រតិសកម្ម ចាប់ពីពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព ។

មាត្រា ១២០២.- ការដាស់តឿន របស់ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍

បុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធទៅនឹងអច្ច័យទាន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ អាចដាស់តឿនឱ្យអច្ច័យលាភីទទួលស្គាល់ ឬ បោះបង់អច្ច័យទាន បានដោយកំណត់អំឡុងពេលសមរម្យ ។ បើអច្ច័យលាភីមិនបានបង្ហាញឆន្ទៈ ចំពោះបុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធទៅនឹងអច្ច័យទាន នៅក្នុងអំឡុងពេលដែលបានកំណត់នោះទេ ត្រូវចាត់ទុកថា អច្ច័យលាភីបានទទួលស្គាល់អច្ច័យទាននោះ ។

មាត្រា ១២០៣.- ការបោះបង់ ឬ ការទទួលស្គាល់ ដោយសន្តតិជនរបស់អច្ច័យលាភី

បើអច្ច័យលាភីបានទទួលមរណភាព ដោយមិនបានទទួលស្គាល់ ឬ បោះបង់អច្ច័យទានទេ សន្តតិជនរបស់អច្ច័យលាភីនោះ អាចទទួលស្គាល់ ឬ បោះបង់អច្ច័យទាន បានត្រឹមទំហំនៃសិទ្ធិលើសន្តតិកម្មរបស់ខ្លួន ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈ ផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

មាត្រា ១២០៤.- ការលុបចោលនូវការទទួលស្គាល់ ឬ ការបោះបង់

១-ការទទួលស្គាល់ ឬ ការបោះបង់អច្ច័យទាន ពុំអាចលុបចោលវិញបានទេ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១២៥២ (ការលុបចោលការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការទទួលស្គាល់ និង ការបោះបង់អច្ច័យទាននេះ ។

មាត្រា ១២០៥.- ការទទួលស្គាល់ ឬ បោះបង់ ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន

១-ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន បើបានបោះបង់សន្តតិកម្ម បុគ្គលនោះ ត្រូវបានចាត់ទុកថា បានបោះបង់អច្ច័យទានផងដែរ ។ អច្ច័យលាភីនោះ មិនអាចទទួលស្គាល់អច្ច័យទាន ដោយបោះបង់សន្តតិកម្មបានឡើយ ។

២-ទោះបីបានទទួលស្គាល់សន្តតិកម្មហើយក៏ដោយ ក៏អច្ច័យលាភីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចបោះបង់អច្ច័យទានមានកំណត់ បានដែរ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

22/458

មាត្រា ១២០៦.- សិទ្ធិទទួលផលរបស់អច្ច័យលាភី

អច្ច័យលាភីអាចទទួលផល ចាប់តាំងពីពេលដែលខ្លួនអាចទាមទារឱ្យអនុវត្តអច្ច័យទានបាន ។ ប៉ុន្តែ បើម្ចាស់បណ្ដាំ បានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

មាត្រា ១២០៧.- អច្ច័យទាននៃសិទ្ធិដែលមិនស្ថិតនៅក្នុងមតិក

អច្ច័យទាន ពុំមានអានុភាពឡើយ បើសិទ្ធិដែលជាកម្មវត្ថុនៃអច្ច័យទាននោះ ពុំស្ថិតនៅក្នុងមតិក នៅពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព ។

មាត្រា ១២០៨.- អច្ច័យទាននៃវត្ថុ ឬ សិទ្ធិដែលភ្ជាប់ជាមួយនឹងសិទ្ធិរបស់តតិយជន

បើវត្ថុ ឬ សិទ្ធិ ដែលជាកម្មវត្ថុនៃអច្ច័យទាន ជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជន នៅពេលដែលម្ចាស់បណ្ដាំទទួលមរណភាព អច្ច័យលាភីមិនអាចទាមទារឱ្យរំលត់សិទ្ធិនោះ ចំពោះជនដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទានបានឡើយ ។

មាត្រា ១២០៩.- ឧបាទេសកម្មលើវត្ថុ

១-បើម្ចាស់បណ្ដាំមានសិទ្ធិទាមទារប្រាក់សំណង ចំពោះតតិយជន ដោយការបាត់បង់ ឬ កែបន្លំវត្ថុដែលជាកម្មវត្ថុនៃអច្ច័យទាន ឬ បាត់បង់ការកាន់កាប់វត្ថុនោះ ត្រូវសន្មតថាបានយកសិទ្ធិនោះ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

២-ក្នុងករណីដែលវត្ថុដែលជាកម្មវត្ថុនៃអច្ច័យទាន មានភាពជាប់គ្នា លាយគ្នា ឬច្របល់គ្នានឹងវត្ថុផ្សេងទៀត បើម្ចាស់បណ្ដាំបានក្លាយជាកម្មសិទ្ធិករតែឯង ឬ ជាម្ចាស់កម្មសិទ្ធិអវិភាគនៃវត្ថុដែលបានផ្សំ ដោយយោងតាមបញ្ញត្តិនៃមាត្រា ១៨៦ (ការជាប់គ្នារវាងចលនវត្ថុ និង អចលនវត្ថុ) ឬ មាត្រា ១៩៨ (ការជាប់គ្នា ការលាយច្របល់គ្នានៃចលនវត្ថុ) នៃក្រមនេះ ត្រូវសន្មតថាម្ចាស់បណ្ដាំបានយកកម្មសិទ្ធិទាំងអស់ ឬ កម្មសិទ្ធិ អវិភាគនោះ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

មាត្រា ១២១០.- ឧបាទេសកម្មលើវត្ថុនៃអច្ច័យទាននៃសិទ្ធិលើបំណុល

១-ក្នុងករណីដែលសិទ្ធិលើបំណុលត្រូវបានយកមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន បើម្ចាស់បណ្ដាំបានទទួលសំណង ហើយបើវត្ថុដែលបានទទួលនោះ នៅតែមានក្នុងមតិក ត្រូវសន្មតថា

បានយកវត្ថុនោះមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

២-ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ត្រូវសន្មតថា បានយកប្រាក់ និង ប្រាក់បញ្ញើ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ត្រឹមកម្រិតនៃប្រាក់ដែលមាននៅក្នុងមត៌ក និង ប្រាក់ដែលបានបញ្ចូលក្នុងប្រាក់បញ្ញើ ក្រោយពីបានសង ។

មាត្រា ១២១១.- ការទទួលខុសត្រូវរបស់អច្ច័យលាភី នៅក្នុងអច្ច័យទានភ្ជាប់បន្ទុក

១-ជនដែលបានទទួលអច្ច័យទានភ្ជាប់បន្ទុក ត្រូវទទួលខុសត្រូវក្នុងការអនុវត្តករណីយកិច្ចដែលខ្លួនទទួលបន្ទុក ត្រឹមតែកម្រិតដែលមិនលើសពីតម្លៃនៃកម្មវត្ថុនៃអច្ច័យទាននោះប៉ុណ្ណោះ ។

២-បើតម្លៃនៃកម្មវត្ថុនៃអច្ច័យទានភ្ជាប់បន្ទុក បានចុះថយ ដោយសារការទទួលស្គាល់សន្តតិកម្មដោយមានកម្រិត ឬ ដោយសារការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង អច្ច័យលាភីត្រូវរួចផុតពីករណីយកិច្ចដែលខ្លួនត្រូវទទួលបន្ទុក តាមសមាមាត្រនៃភាគដែលចុះថយនោះ ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

មាត្រា ១២១២.- សិទ្ធិ និង ករណីយកិច្ចរបស់អច្ច័យលាភីសកល

១-អច្ច័យលាភីសកល មានសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងសន្តតិជន ។

២-បើមត៌កទាំងអស់ត្រូវបានធ្វើអច្ច័យទានសកលឱ្យទៅបុគ្គលផ្សេងដែលមិនមែនជាសន្តតិជន សន្តតិជនត្រូវបានចាត់ទុកថាមិនបានទទួលសន្តតិកម្ម លើកលែងតែសិទ្ធិលើភាគបម្រុង ។

ផ្នែកទី ៧
ការប្រតិបត្តិមតកសាសន៍

មាត្រា ១២១៣.- ការពិនិត្យបញ្ជាក់ និង ការបើកលិខិតមតកសាសន៍

១-អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ ត្រូវដាក់ពាក្យសុំការបញ្ជាក់លិខិតនោះដោយភ្ជាប់លិខិតមតកសាសន៍នោះ ជូនទៅតុលាការដោយគ្មានការយឺតយ៉ាវ ក្រោយពីខ្លួនបានដឹងអំពីការចាប់ផ្តើមសន្តតិកម្ម ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែល

ROYAUME DU CAMBODGE · LE MINISTERE DU PALAIS ROYAL

គ្មានអ្នកថែរក្សាគ្រប់គ្រង ក្រោយពេលដែលសន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ផ្សេងទៀត បានរកឃើញលិខិតមតកសាសន៍នោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះមតកសាសន៍ដែលបានធ្វើដោយលិខិតយថាភូត ។

៣-លិខិតមតកសាសន៍ដែលបិទដោយប្រថាប់ត្រា អាចបើកបានតែនៅតុលាការ ដោយមានវត្តមានរបស់អ្នកសង្កេតការណ៍ជាសន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ឬអ្នកតំណាងរបស់ជននោះ ។

៤-បុគ្គលដែលបានបើកលិខិតមតកសាសន៍ នៅក្រៅតុលាការដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ នឹងត្រូវពិន័យស៊ីវិលជាប្រាក់មិនលើសពី ១.០០០.០០០ (មួយលាន) រៀល ។

៥-ចំពោះលិខិតមតកសាសន៍ ទោះបីជាបានបើកនៅក្រៅតុលាការដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ក៏ដោយ មិនត្រូវបាត់បង់អានុភាព ដោយសារតែមូលហេតុនោះឡើយ ។

មាត្រា ១២១៤.- ការកំណត់អ្នកប្រតិបត្តិមតកសាសន៍

១-បើម្ចាស់បណ្តាំបានប្រគល់អាណត្តិឱ្យតតិយជនកំណត់អ្នកប្រតិបត្តិមតកសាសន៍តាមមតកសាសន៍ ជនដែលបានទទួលអាណត្តិ ត្រូវកំណត់អ្នកប្រតិបត្តិមតកសាសន៍ ហើយត្រូវជូនដំណឹងនោះទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

២-បើជនដែលបានទទួលអាណត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មានបំណងលាឈប់ពីអាណត្តិនោះ ជននោះត្រូវជូនដំណឹងអំពីហេតុនោះ ទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

មាត្រា ១២១៥.- ការកាន់មុខងាររបស់អ្នកប្រតិបត្តិមតកសាសន៍

បើអ្នកប្រតិបត្តិមតកសាសន៍ បានយល់ព្រមកាន់មុខងារហើយ អ្នកប្រតិបត្តិមតកសាសន៍នោះ ត្រូវអនុវត្តភារកិច្ចនោះភ្លាមៗ ។

មាត្រា ១២១៦.- ការដាស់តឿនឱ្យអ្នកប្រតិបត្តិមតកសាសន៍កាន់មុខងារ

១-សន្តតិជន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ផ្សេងទៀត អាចកំណត់អំឡុងពេលសមរម្យ ហើយដាស់តឿន ចំពោះជនដែលត្រូវបានកំណត់ជាអ្នកប្រតិបត្តិមតកសាសន៍ឱ្យឆ្លើយបញ្ជាក់ច្បាស់ក្នុងអំឡុងពេលនោះ អំពីការយល់ព្រម ឬ មិនយល់ព្រមកាន់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍បាន ។ បើអ្នកប្រតិបត្តិមតកសាសន៍ មិនបានឆ្លើយបញ្ជាក់ច្បាស់ក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា បានលាឈប់ពីការងារនោះ ។

២-បញ្ញត្តិនៃវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលតតិយជន ដែលត្រូវបានប្រគល់អាណត្តិឱ្យកំណត់អ្នកប្រតិបត្តិមតកសាសន៍ ពុំបានកំណត់អ្នកប្រតិបត្តិមតកសាសន៍ឱ្យបានឆាប់រហ័ស ។ ក្នុងករណីនេះ បើតតិយជននោះមិនបានកំណត់អ្នកប្រតិបត្តិមតកសាសន៍ នៅក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថាបានលាឈប់ពីអាណត្តិនោះ ។

មាត្រា ១២១៧.- បុគ្គលដែលមិនអាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍

ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិរញ្ញបាលក្ខ អនីតិជន និង ជនធនក្ស័យពុំអាចធ្វើជាអ្នកប្រតិបត្តិមតកសាសន៍បានឡើយ ។

មាត្រា ១២១៨.- ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍

បើគ្មានអ្នកប្រតិបត្តិមតកសាសន៍ទេ ឬ បើបាត់បង់អ្នកប្រតិបត្តិមតកសាសន៍ តុលាការអាចជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍បាន តាមការទាមទាររបស់សន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ។

មាត្រា ១២១៩.- ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ

១-អ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ ហើយប្រគល់បញ្ជីសារពើភ័ណ្ឌនោះទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

២-សន្តតិជន អាចមានវត្តមាន នៅពេលដែលអ្នកប្រតិបត្តិមតកសាសន៍ ធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិបាន ។

មាត្រា ១២២០.- សិទ្ធិអំណាច មុខនាទី នៃអ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិ និង ករណីយកិច្ចក្នុងការគ្រប់គ្រងមតិក និង ធ្វើនូវរាល់សកម្មភាពផ្សេងទៀតដែលចាំបាច់ ដើម្បីប្រតិបត្តិមតកសាសន៍ ។

មាត្រា ១២២១.- ការបាត់បង់នូវសិទ្ធិចាត់ចែងរបស់សន្តតិជន

១-បើមានអ្នកប្រតិបត្តិមតកសាសន៍ សន្តតិជនពុំអាចចាត់ចែងមតិក ឬ ធ្វើសកម្មភាពផ្សេងទៀតដែលនាំឱ្យរារាំងដល់ការប្រតិបត្តិមតកសាសន៍បានឡើយ ។

២-ការចាត់ចែងដែលបានធ្វើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ ។

មាត្រា ១២២២.- ការប្រតិបត្តិមតកសាសន៍ ចំពោះទ្រព្យសម្បត្តិដែលបានកំណត់ជាក់លាក់

ក្នុងករណីមតកសាសន៍ទាក់ទងនឹងទ្រព្យសម្បត្តិដែលបានកំណត់ជាក់លាក់ បញ្ញត្តិចាប់ពីមាត្រា ១២១៩ (ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ) រហូតដល់មាត្រា ១២២១ (ការបាត់បង់នូវសិទ្ធិចាត់ចែងរបស់សន្តតិជន) នៃក្រមនេះ ត្រូវយកមកអនុវត្តចំពោះតែទៅលើទ្រព្យសម្បត្តិនោះប៉ុណ្ណោះ ។

មាត្រា ១២២៣.- ឋានៈនៃអ្នកប្រតិបត្តិមតកសាសន៍

១-អ្នកប្រតិបត្តិមតកសាសន៍ ត្រូវធ្វើសកម្មភាព នៅក្នុងនាមជាអ្នកប្រតិបត្តិមតកសាសន៍ចំពោះមតិកដែលខ្លួនត្រូវប្រតិបត្តិ ។

២-សកម្មភាពដែលអ្នកប្រតិបត្តិមតកសាសន៍បានធ្វើជាមុខនាទី ត្រូវមានអានុភាពផ្ទាល់ចំពោះសន្តតិជន ។

មាត្រា ១២២៤.- សិទ្ធិជ្រើសតាំងបន្ត របស់អ្នកប្រតិបត្តិមតកសាសន៍

១-បើគ្មានមូលហេតុដែលពុំអាចជៀសវាងបានទេ អ្នកប្រតិបត្តិមតកសាសន៍ ពុំអាចឱ្យតតិយជនអនុវត្តភារកិច្ចរបស់ខ្លួនបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេង នៅក្នុងមតកសាសន៍ ។

២-ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍ បានឱ្យតតិយជនអនុវត្តភារកិច្ចរបស់ខ្លួន

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

៣/៤៥

ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកប្រតិបត្តិមតកសាសន៍នោះ ត្រូវទទួលខុសត្រូវក្នុងការជ្រើសតាំង និង ការត្រួតពិនិត្យជននោះ ចំពោះអច្ច័យលាភី និង សន្តតិជន ។ បើអ្នកប្រតិបត្តិមតកសាសន៍បានឱ្យតតិយជនអនុវត្តភារកិច្ចនោះ ដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសងសំណងនៃការខូចខាតដែលកើតឡើង ដោយសារហេតុនោះចំពោះអច្ច័យលាភី និង សន្តតិជន ។

មាត្រា ១២២៥.- សហអ្នកប្រតិបត្តិមតកសាសន៍

១-ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍មានច្រើននាក់ ការអនុវត្តភារកិច្ចនោះ ត្រូវសម្រេចដោយសំឡេងលើសពីពាក់កណ្តាល ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ អ្នកប្រតិបត្តិមតកសាសន៍នីមួយៗ អាចធ្វើសកម្មភាពរក្សាទុកបាន ។

មាត្រា ១២២៦.- កម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍

១-អ្នកប្រតិបត្តិមតកសាសន៍ អាចទទួលកម្រៃដែលបានកំណត់នៅក្នុងមតកសាសន៍បាន ។

២-ក្នុងករណីដែលមតកសាសន៍ពុំបានកំណត់កម្រៃទេ តុលាការត្រូវកំណត់ចំនួនទឹកប្រាក់នៃកម្រៃនោះ តាមពាក្យសុំរបស់អ្នកប្រតិបត្តិមតកសាសន៍ បើយល់ឃើញថាសមរម្យក្នុងការបង់កម្រៃ ដោយពិចារណាទៅលើស្ថានភាពនៃមតិកទំនាក់ទំនងរវាងម្ចាស់បណ្តាំ និង អ្នកប្រតិបត្តិមតកសាសន៍ និង ស្ថានភាពផ្សេងទៀត ។

មាត្រា ១២២៧.- ការលាឈប់ និង ការបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍

១-បើមានមូលហេតុត្រឹមត្រូវ អ្នកប្រតិបត្តិមតកសាសន៍ អាចលាឈប់ពីភារកិច្ចបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

២-បើអ្នកប្រតិបត្តិមតកសាសន៍ បានធ្វេសប្រហែសក្នុងភារកិច្ច ឬ បើមានមូលហេតុត្រឹមត្រូវផ្សេងទៀត អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ អាចដាក់ពាក្យសុំទៅតុលាការឱ្យបញ្ឈប់ជននោះ

បាន ។

មាត្រា ១២២៨.- សោហ៊ុយនៃការប្រតិបត្តិមតកសាសន៍

សោហ៊ុយដែលទាក់ទងទៅនឹងការប្រតិបត្តិមតកសាសន៍ ត្រូវជាបន្ទុកនៃមតិក ។ ប៉ុន្តែមិនអាចបន្ថយភាគបម្រុង ដោយសារបន្ទុកនេះឡើយ ។

មាត្រា ១២២៩.- ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីអាណត្តិ

បញ្ញត្តិស្តីពីអាណត្តិ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះមុខនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍ លើកលែងតែមានភាពផ្ទុយនឹងលក្ខណៈនៃតួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍នោះ ។

ជំពូកទី ៤

ភាគបម្រុង

ផ្នែកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១២៣០.- អ្នកមានសិទ្ធិលើភាគបម្រុង

១-បច្ឆាញាតិផ្ទាល់ ឬ ឪពុកម្តាយ ឬ ជីដូនជីតា និង សហព័ទ្ធរបស់មតកជនអាចធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិ ដូចខាងក្រោមនេះ :

ក-១ ភាគ ៣ (មួយភាគបី) នៃទ្រព្យសម្បត្តិរបស់មតកជនក្នុងករណីដែលមានតែសន្តតិជនជាឪពុកម្តាយ ឬ ជីដូន ជីតាប៉ុណ្ណោះ ។

ខ-១ ភាគ ២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរបស់មតកជន ក្នុងករណីផ្សេង ។

២-ក្នុងករណីដែលមានសន្តតិជនច្រើននាក់ អ្នកមានសិទ្ធិលើភាគបម្រុងនីមួយៗអាចទទួលភាគបម្រុង តាមសមាមាត្រនៃចំណែកមតិកបាន ។

៣-បញ្ញត្តិនៃមាត្រា ១១៥៧(សន្តតិកម្មជំនួស) និង មាត្រា ១១៥៨(ចំណែកមតិកក្នុងករណីនៃសន្តតិកម្មជំនួស) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះភាគបម្រុង ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

មាត្រា ១២៣១.- ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

១-ភាគបម្រុង ត្រូវគណនាដោយយកទ្រព្យសម្បត្តិដែលមតកជនមាននៅពេលចាប់ផ្តើមធ្វើសន្តតិកម្ម បូកតម្លៃនៃផលប្រយោជន៍ពិសេស ដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) និង តម្លៃនៃទ្រព្យសម្បត្តិប្រទានកម្ម ដែលបានកំណត់ក្នុងមាត្រា ១២៣២ (ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង) នៃក្រមនេះ ហើយដកនូវចំនួនប្រាក់សរុបនៃកាតព្វកិច្ចចេញ ។

២-សិទ្ធិដែលភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌ ឬ សិទ្ធិដែលអំឡុងពេលមានអត្ថិភាពមិនច្បាស់លាស់ ត្រូវកំណត់តម្លៃនោះ ដោយផ្អែកតាមការវាយតម្លៃរបស់អ្នកវាយតម្លៃ ដែលត្រូវបានជ្រើសតាំងដោយតុលាការ ។

៣-កាតព្វកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវរាប់បញ្ចូលផងដែរនូវសោហ៊ុយបុណ្យសពតាមឋានៈរបស់មតកជន ។

មាត្រា ១២៣២.- ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

១-ប្រទានកម្មដែលបានកំណត់ដូចខាងក្រោមនេះ ត្រូវក្លាយជាមូលដ្ឋានក្នុងការគណនាភាគបម្រុង លើកលែងតែផលប្រយោជន៍ពិសេសដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) នៃក្រមនេះ :

ក- ប្រទានកម្មដែលបានធ្វើក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ។

ខ- ក្រៅពីប្រទានកម្មដែលបានកំណត់ក្នុងចំណុច ក ខាងលើនេះ ប្រទានកម្មដែលត្រូវបានធ្វើឡើង ដោយភាគីសងខាងបានដឹងថានឹងបណ្តាលឱ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង ។

២-នៅក្នុងជំពូកទី ៤ (ភាគបម្រុង) នេះ ការលើកលែងកាតព្វកិច្ចដោយមិនយកតម្លៃថ្នូរ ត្រូវចាត់ទុកថាជាប្រទានកម្ម ។

មាត្រា ១២៣៣.- ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

ប្រសិនបើការកំណត់ចំណែកមត៌កតាមមតកសាសន៍ ការទទួលផលប្រយោជន៍ពិសេស

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

និង ប្រទានកម្មដែលបានកំណត់នៅក្នុងមាត្រា ១២៣២ (ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង) ខាងលើនេះ គឺជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ។ ប៉ុន្តែ ក្នុងករណីដែលអច្ច័យទានចំពោះសន្តតិជន ការកំណត់ចំណែកមត៌ក និង ការទទួលផលប្រយោជន៍ពិសេស ត្រូវក្លាយជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងកម្មវត្ថុនៃការកាត់បន្ថយនោះ មានត្រឹមតែផ្នែកដែលលើសពីចំនួនទឹកប្រាក់នៃភាគបម្រុងរបស់សន្តតិជននោះប៉ុណ្ណោះ ។

មាត្រា ១២៣៤.- ចំនួនទឹកប្រាក់នៃការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

ចំនួនទឹកប្រាក់ដែលអ្នកមានសិទ្ធិលើភាគបម្រុងអាចទាមទារបានដោយការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺជាចំនួនទឹកប្រាក់ដែលត្រូវបានគណនា ដោយយកចំនួនទឹកប្រាក់នៃភាគបម្រុង ដកចំនួនសរុបនៃទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលដោយសន្តតិកម្ម និង ចំនួននៃផលប្រយោជន៍ពិសេស ហើយបូកបញ្ចូលនូវចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលបុគ្គលនោះត្រូវទទួលបន្ទុកដោយសន្តតិកម្ម ។

ផ្នែកទី ២
វិធីកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

មាត្រា ១២៣៥.- ការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

អ្នកមានសិទ្ធិលើភាគបម្រុង និង អ្នកទទួលបន្តនោះ អាចទាមទារឱ្យធ្វើការកាត់បន្ថយអច្ច័យទាន ជាអាទិ៍ ចំពោះជនដែលបានទទួលទ្រព្យសម្បត្តិ ឬ ផលប្រយោជន៍ដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន ត្រឹមកម្រិតដែលចាំបាច់ដើម្បីរក្សាភាគបម្រុងនោះ ។

មាត្រា ១២៣៦.- លំដាប់នៃការកាត់បន្ថយ

ប្រទានកម្ម និង ការទទួលផលប្រយោជន៍ពិសេស ពុំអាចកាត់បន្ថយបានឡើយ បើមិនបានកាត់បន្ថយអច្ច័យទាន និង ចំណែកមត៌កដែលបានកំណត់តាមមតកសាសន៍ជាមុនទេ ។

មាត្រា ១២៣៧.- ការកាត់បន្ថយអច្ច័យទាន ជាអាទិ៍

១-ដំបូង ត្រូវធ្វើការកាត់បន្ថយពីអច្ច័យទាន និង ចំណែកមត៌កដែលបានកំណត់ចំពោះសន្តតិជន នៅក្នុងពេលជាមួយគ្នា ហើយប្រសិនបើនៅតែខ្វះត្រូវធ្វើការកាត់បន្ថយពីអច្ច័យទានដែលបានធ្វើចំពោះបុគ្គលផ្សេងក្រៅពីសន្តតិជន ។

២-អច្ច័យទាន ត្រូវធ្វើការកាត់បន្ថយទៅតាមសមាមាត្រនៃតម្លៃរបស់កម្មវត្ថុនោះ ។ បញ្ញត្តិនេះក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះចំណែកមត៌កដែលបានកំណត់តាមវិធីធ្វើអនុប្បទានទ្រព្យសម្បត្តិដែលមានកំណត់តែមួយចំណុច ឬ ច្រើនចំណុច ។ ប៉ុន្តែ ក្នុងករណីដែលអច្ច័យទានដែលធ្វើចំពោះសន្តតិជន និង ចំណែកមត៌កដែលបានកំណត់នោះ ជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងផ្នែកដែលលើសពីចំនួនប្រាក់នៃភាគបម្រុងរបស់សន្តតិជននោះ ត្រូវចាត់ទុកថាជាតម្លៃនៃកម្មវត្ថុ ។

៣-ចំណែកមត៌កតាមមតកសាសន៍ ដែលបានកំណត់ជាភាគនៃមត៌ក ត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ដោយធ្វើការផ្លាស់ប្តូរភាគនោះ ។

៤-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ទី ២ និង ទី ៣ ខាងលើនេះក៏ដោយ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈពិសេសផ្សេង ក្នុងមតកសាសន៍ ត្រូវអនុលោមទៅតាមឆន្ទៈនោះ ។

មាត្រា ១២៣៨.- លំដាប់នៃការកាត់បន្ថយប្រទានកម្ម ជាអាទិ៍

១-ការកាត់បន្ថយប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេស ត្រូវចាប់ផ្តើមពីប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើក្រោយគេ បន្ទាប់មកត្រូវធ្វើចំពោះប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើពីមុនមកជាបន្តបន្ទាប់ ។

២-បើបានធ្វើប្រទានកម្ម ឬ ទទួលផលប្រយោជន៍ពិសេសលើសពី ២០ (ម្ភៃ) ឆ្នាំ នៅមុនពេលចាប់ផ្តើមសន្តតិកម្ម បដិគ្គាហក ឬ សន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេសនោះ អាចបដិសេធនូវការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន ។

មាត្រា ១២៣៩.- ការសងផលមកវិញ

សហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក ក្រៅពីទ្រព្យសម្បត្តិ ឬ ប្រាក់សំណង ដែលត្រូវសងមកវិញនោះ ត្រូវសងមកវិញផងដែរនូវផលដែលកើតឡើងក្រោយពីថ្ងៃដែលបានទាម

ទារឱ្យធ្វើការកាត់បន្ថយ ។

មាត្រា ១២៤០.- បន្ទុកនៃការខាតបង់ ដោយអសាធនភាព

ការខាតបង់ដែលកើតឡើងដោយសារអសាធនភាព របស់សហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក ដែលត្រូវទទួលការកាត់បន្ថយ ត្រូវធ្លាក់ជាបន្ទុករបស់អ្នកមានសិទ្ធិលើភាគបម្រុង ។

មាត្រា ១២៤១.- ការកាត់បន្ថយប្រទានកម្មដែលមានភ្ជាប់បន្ទុក

ចំពោះប្រទានកម្មដែលមានភ្ជាប់បន្ទុក ដែលបានដកតម្លៃនៃបន្ទុកចេញពីក្នុងតម្លៃនៃកម្មវត្ថុនោះ អាចទាមទារឱ្យធ្វើការកាត់បន្ថយបាន ។

មាត្រា ១២៤២.- ការកាត់បន្ថយចំពោះកិច្ចសន្យា ជាអាទិ៍ ដែលត្រូវចាត់ទុកថាជាប្រទានកម្ម

១-កិច្ចសន្យាដែលបានធ្វើដោយយកតម្លៃថ្នូរមិនត្រឹមត្រូវ ត្រូវចាត់ទុកថាជាប្រទានកម្ម តែក្នុងករណីដែលត្រូវបានធ្វើឡើង ដោយភាគីទាំងសងខាងបានដឹងថា នឹងបណ្តាលឱ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុងប៉ុណ្ណោះ ។ ក្នុងករណីនេះ បើអ្នកមានសិទ្ធិលើភាគបម្រុងទាមទារឱ្យធ្វើការកាត់បន្ថយនោះ អ្នកនោះត្រូវសងតម្លៃថ្នូរនោះមកវិញ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការលើកលែងកាតព្វកិច្ច ដោយយកតម្លៃថ្នូរមិនត្រឹមត្រូវ ។

មាត្រា ១២៤៣.- ការកាត់បន្ថយក្នុងករណីដែលបានចាត់ចែងកម្មវត្ថុនៃប្រទានកម្ម

១-បើសហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក ដែលត្រូវទទួលការកាត់បន្ថយបានធ្វើអនុប្បទាននូវកម្មវត្ថុនៃប្រទានកម្ម ទៅឱ្យអ្នកដទៃ ជននោះត្រូវសងចំនួនទឹកប្រាក់ក្នុងកម្រិតនៃតម្លៃនៅពេលដែលបានចាត់ចែងនោះ ទៅឱ្យអ្នកមានសិទ្ធិលើភាគបម្រុង ។ ប៉ុន្តែ ប្រសិនបើអនុប្បទានិកនោះបានដឹងថា នឹងបណ្តាលឱ្យខូចខាតដល់អ្នកមានសិទ្ធិលើ ភាគបម្រុងនៅពេលធ្វើអនុប្បទាន អ្នកមានសិទ្ធិលើភាគបម្រុងក៏អាចទាមទារឱ្យកាត់បន្ថយចំពោះអនុប្បទានិកនោះបានដែរ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក បានបង្កើតសិទ្ធិលើកម្មវត្ថុនៃប្រទានកម្មនោះ ។

មាត្រា ១២៤៤.- សំណងដោយបង់តម្លៃ

១-សហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក អាចរួចផុតពីកាតព្វកិច្ចនៃការសងបាន ដោយបង់តម្លៃនៃចំណែកមត៌កដែលបានកំណត់ តម្លៃនៃកម្មវត្ថុនៃអច្ច័យទាន ឬ តម្លៃនៃកម្មវត្ថុនៃប្រទានកម្មទៅឱ្យអ្នកដែលមានសិទ្ធិលើភាគបម្រុង ត្រឹមកម្រិតដែលត្រូវទទួលការកាត់បន្ថយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រា ១២៤៣(ការកាត់បន្ថយក្នុងករណីដែលបានចាត់ចែងកម្មវត្ថុនៃប្រទានកម្ម) ខាងលើនេះ ។

ផ្នែកទី ៣

ការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយ

មាត្រា ១២៤៥.- អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយ

សិទ្ធិទាមទារឱ្យកាត់បន្ថយ ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ១ (មួយ) ឆ្នាំបានកន្លងហួស គិតចាប់ពីពេលដែលអ្នកមានសិទ្ធិលើភាគបម្រុងបានដឹងអំពីការចាប់ផ្តើមសន្តតិកម្ម និង ការកំណត់ចំណែកមត៌ក អច្ច័យទាន ប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសដែលត្រូវកាត់បន្ថយ ។ សិទ្ធិទាមទារឱ្យកាត់បន្ថយ ក៏ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ៥ (ប្រាំ) ឆ្នាំ បានកន្លងហួសគិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម ។

មាត្រា ១២៤៦.- ការបោះបង់ភាគបម្រុង

ភាគបម្រុង អាចបោះបង់ចោលទាំងអស់ ឬ មួយផ្នែកបាន ។ ប៉ុន្តែ ការបោះបង់ភាគបម្រុងនៅមុនពេលចាប់ផ្តើមសន្តតិកម្ម មានអានុភាព លុះត្រាតែបានទទួលការអនុញ្ញាតពីតុលាការ ។

មាត្រា ១២៤៧.- ករណីជាសហសន្តតិជន

ការរលត់ដោយអាជ្ញាយុកាល នៃសិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងរបស់សន្តតិជនណាម្នាក់ ឬ ការបោះបង់ភាគបម្រុងដោយសហសន្តតិជនណាម្នាក់ ពុំមានឥទ្ធិពលទៅលើភាគបម្រុងរបស់សហសន្តតិជនផ្សេងទៀតទេ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

434/456

ជំពូកទី ៥
ការយល់ព្រម និង ការបោះបង់សន្តតិកម្ម
ផ្នែកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ១២៤៨.- អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់

១-សន្តតិជន ត្រូវធ្វើការយល់ព្រម ឬ ការបោះបង់សន្តតិកម្ម ទាំងស្រុង ឬ ដោយកម្រិត នៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម ។ ប៉ុន្តែ អំឡុងពេលនេះ អាចពន្យារទៀតបាន តាមពាក្យសុំរបស់សន្តតិជនទៅតុលាការ ។

២-សន្តតិជន អាចធ្វើការស្រាវជ្រាវមត៌កបាន នៅមុនពេលធ្វើការយល់ព្រម ឬ ការបោះបង់ ។

មាត្រា ១២៤៩.- ករណីពិសេសនៃអំឡុងពេល បើសន្តតិជនទទួលមរណភាព

បើសន្តតិជនបានទទួលមរណភាព នៅមុនពេលធ្វើការយល់ព្រម ឬ ការបោះបង់អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨(អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជនរបស់ជននោះបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម ។

មាត្រា ១២៥០.- ករណីពិសេសនៃអំឡុងពេល បើសន្តតិជនជាអនីតិជន ជាអាទិ៍

បើសន្តតិជន ជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨(អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់នោះបានដឹងថា សន្តតិកម្មចំពោះជនដែលជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅនោះបានចាប់ផ្តើម ។

មាត្រា ១២៥១.- ករណីពិសេសនៃអំឡុងពេល បើសន្តតិជនមិនដឹងអំពីអត្ថិភាពនៃកាតព្វកិច្ច

ក្នុងករណីដែលមតកជនមានកាតព្វកិច្ចដែលមានចំនួនទឹកប្រាក់ច្រើន ហើយមិន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
135/455

អាចយកមតិកទៅសងឱ្យគ្រប់ចំនួនបានទេ បើសន្តតិជនមិនអាចដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ តាមស្ថានភាពនៃជីវភាពរបស់មតកជន ស្ថានភាពនៃទ្រព្យសម្បត្តិរបស់មតកជន ឬ ស្ថានភាពផ្សេងៗទៀត អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជនបានដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសន្តតិជនបានចាត់ចែងមតិកដើម្បីសងកាតព្វកិច្ចផ្សេង ដែលត្រូវបានទទួលតាមរយៈសន្តតិកម្ម នៅមុនពេលបានដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនេះ បញ្ញត្តិនៃចំណុច ក មាត្រា ១២៥៥(ការយល់ព្រមទាំងស្រុងតាមច្បាប់) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ។

មាត្រា ១២៥២.– ការលុបចោលការយល់ព្រម ឬ ការបោះបង់

១-ការយល់ព្រម និង ការបោះបង់សន្តតិកម្ម មិនអាចលុបចោលបានឡើយ ទោះជានៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨(អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ក៏ដោយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងចំពោះការលុបចោលនូវការយល់ព្រម ឬ បោះបង់សន្តតិកម្ម ដោយយកមូលហេតុមានវិការៈក្នុងការបង្ហាញឆន្ទៈឡើយ ។ ប៉ុន្តែ សិទ្ធិលុបចោលនេះ ត្រូវរលត់បើពុំបានអនុវត្តនៅក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែគិតចាប់ពីពេលដែលអាចផ្តល់សច្ចានុមតិបាន ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលពុំបានអនុវត្តសិទ្ធិលុបចោលនៅក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្តើមធ្វើសន្តតិកម្ម ។

៣-បុគ្គលដែលមានបំណងចង់លុបចោល ការយល់ព្រមដោយកម្រិត ឬ ការបោះបង់តាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវដាក់ពាក្យសុំលុបចោលនោះ ទៅតុលាការ ។

មាត្រា ១២៥៣.– ការហាមឃាត់មិនឱ្យធ្វើបណ្តឹងចំពោះសន្តតិជន នៅមុនការយល់ព្រម

សិទ្ធិទាមទារចំពោះបេតិកភ័ណ្ឌ ពុំអាចយកមកអះអាងក្នុងបណ្តឹងចំពោះសន្តតិជន នៅមុនពេលដែលផ្តើមលើសន្តតិកម្មបានឡើយ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

c/066

ផ្នែកទី ២
ការយល់ព្រម

មាត្រា ១២៥៤.- ការយល់ព្រមទាំងស្រុង

បើសន្តតិជនបានយល់ព្រមទាំងស្រុង ត្រូវទទួលបន្តដោយគ្មានកម្រិតនូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជននោះ ។

មាត្រា ១២៥៥.- ការយល់ព្រមទាំងស្រុងតាមច្បាប់

ក្នុងករណីដែលកំណត់ដូចខាងក្រោមនេះ ត្រូវចាត់ទុកថា សន្តតិជនបានយល់ព្រមទាំងស្រុងតាមច្បាប់ :

ក-បើសន្តតិជនបានចាត់ចែងមត៌កនោះទាំងអស់ ឬ មួយភាគ ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសកម្មភាពរក្សា និង សកម្មភាពត្រឹមតែជាការគ្រប់គ្រង ។

ខ-បើសន្តតិជនមិនបានយល់ព្រមដោយកម្រិត ឬ បោះបង់ នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ។

គ-ទោះបីជាសន្តតិជនបានយល់ព្រមដោយកម្រិត ឬ បោះបង់ ក៏ដោយ បើសន្តតិជនបានលាក់មត៌កទាំងអស់ ឬ មួយភាគ ឬ បានប្រើប្រាស់មត៌កនោះដើម្បីខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ នៅក្រោយពេលដែលជនដែលបានក្លាយជាសន្តតិជនដោយសារការបោះបង់របស់សន្តតិជនលំដាប់មុនបានយល់ព្រម ។

មាត្រា ១២៥៦.- ការយល់ព្រមដោយមានកម្រិត

១-សន្តតិជនអាចយល់ព្រម ដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និង អច្ច័យទានរបស់មតកជនបាន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្ម តែប៉ុណ្ណោះ ។

២-បើសន្តតិជនមានច្រើននាក់ ការយល់ព្រមដោយកម្រិតនេះ អាចធ្វើបាន លុះត្រាតែសហសន្តតិជននោះបានធ្វើដោយរួមគ្នាទាំងអស់ ។

មាត្រា ១២៥៧.- វិធីនៃការយល់ព្រមដោយកម្រិត

សន្តតិជនដែលមានបំណងចង់យល់ព្រមដោយកម្រិត ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌ ហើយត្រូវដាក់ពាក្យសុំអំពីការយល់ព្រមដោយកម្រិតនោះ ទៅតុលាការ នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ។

មាត្រា ១២៥៨.- អានុភាពនៃការយល់ព្រមដោយកម្រិត

១-ក្នុងករណីដែលសន្តតិជនបានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជនពុំអាចតាមទាមទារឱ្យសន្តតិជនទទួលខុសត្រូវ ចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជននោះបានឡើយ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ សិទ្ធិ និង កាតព្វកិច្ចរបស់សន្តតិជនដែលមានចំពោះមតកជននោះ ត្រូវចាត់ទុកថាមិនបានរលត់ដោយល្បាយកុលភាពឡើយ ។

មាត្រា ១២៥៩.- ករណីដែលហេតុនៃការយល់ព្រមតាមច្បាប់ កើតឡើង ក្រោយការយល់ព្រមដោយកម្រិត

១-ក្នុងករណីដែលជនដែលបានធ្វើសន្តតិកម្មតែម្នាក់ឯង បានយល់ព្រមដោយកម្រិត បើសន្តតិជននោះមិនបានសរសេរទ្រព្យសម្បត្តិទាំងអស់ ឬ មួយភាគ នៅក្នុងបញ្ជីសារពើភ័ណ្ឌដោយទុច្ចរិត ឬ បើមានហេតុដែលបានកំណត់នៅក្នុងចំណុច ក ឬ គ នៃមាត្រា ១២៥៥ (ការយល់ព្រមទាំងស្រុងតាមច្បាប់) នៃក្រមនេះ កើតឡើងចំពោះសន្តតិជននោះ ត្រូវចាត់ទុកថាសន្តតិជននោះបានយល់ព្រមទាំងស្រុង ហើយសេចក្តីថ្លែងការណ៍ នៃការយល់ព្រមដោយកម្រិតមិនបង្កើតអានុភាព តាំងពីដំបូងមក ។

២-បើមានមូលហេតុដូចកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះសហសន្តតិ-ជនម្នាក់ ឬ ច្រើននាក់ ដែលបានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជន អាចអនុវត្តសិទ្ធិរបស់ខ្លួនទៅលើសហសន្តតិជនម្នាក់ ឬ ច្រើននាក់នោះ ចំពោះចំនួនទឹកប្រាក់នៃសិទ្ធិលើសំណងដែលខ្លួនពុំអាចទទួលការសងដោយមត៌ក តាមចំណែកមត៌កនីមួយៗនោះបាន ។

ផ្នែកទី ៣

ការបោះបង់

មាត្រា ១២៦០.- ការបោះបង់សន្តតិកម្ម

បុគ្គលដែលមានបំណងបោះបង់សន្តតិកម្ម ត្រូវដាក់ពាក្យសុំការបោះបង់សន្តតិកម្មនោះទៅតុលាការ ។

មាត្រា ១២៦១.- អានុភាពនៃការបោះបង់

បុគ្គលដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា បុគ្គលនោះមិនមែនជាសន្តតិជនតាំងពីដំបូងមក ។

ជំពូកទី ៦

ការគ្រប់គ្រង និង ការបែងចែកមត៌ក

ផ្នែកទី ១

ការគ្រប់គ្រងមត៌ក

មាត្រា ១២៦២.- ការរក្សាទុក និង ការគ្រប់គ្រងមត៌ក

១-សន្តតិជនដែលកាន់កាប់មត៌ក នៅពេលមតកជនបានទទួលមរណភាព ត្រូវរក្សាទុក និង គ្រប់គ្រងមត៌កនោះ រហូតដល់ពេលធ្វើការបែងចែកមត៌ក ។ ប៉ុន្តែ ការរក្សាទុក និង ការគ្រប់គ្រងនេះ ត្រូវអនុលោមតាមបញ្ញត្តិនៃមាត្រា ១២៦៣(ការរក្សាទុកដោយអ្នកប្រតិបត្តិមតកសាសន៍) ខាងក្រោមនេះ ។

២-ទោះបីជានៅមុនពេលយល់ព្រម ឬ បោះបង់សន្តតិកម្មក៏ដោយ សន្តតិជនត្រូវគ្រប់គ្រងមត៌កនោះ ដោយប្រុងប្រយ័ត្ន ដូចគ្នានឹងទ្រព្យសម្បត្តិផ្ទាល់ខ្លួនផងដែរ ។ ទោះបីជានៅក្រោយពេលបោះបង់សន្តតិកម្មក៏ដោយ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ រហូតដល់ពេលបុគ្គលដែលបានក្លាយជាសន្តតិជន ដោយសារការបោះបង់នោះ អាចចាប់ផ្តើមធ្វើការគ្រប់គ្រងមត៌កនេះបាន ។

មាត្រា ១២៦៣.- ការគ្រប់គ្រងដោយអ្នកប្រតិបត្តិមតកសាសន៍

បើបានកាន់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍ហើយ អ្នកប្រតិបត្តិមតកសាសន៍នោះ ត្រូវធ្វើការគ្រប់គ្រងមត៌ក ។ ប៉ុន្តែ ប្រសិនបើមតកសាសន៍ទាក់ទងនឹងទ្រព្យសម្បត្តិដែលមានកំណត់ត្រូវគ្រប់គ្រងតែទ្រព្យសម្បត្តិនោះប៉ុណ្ណោះ ។

មាត្រា ១២៦៤.- អ្នកគ្រប់គ្រងមត៌កជាបណ្ដោះអាសន្ន

១-បើគ្មានអ្នកប្រតិបត្តិមតកសាសន៍ គ្រប់គ្រងមត៌កទាំងមូលទេ សន្តតិជន អច្ច័យលាភី ឬ ម្ចាស់បំណុលរបស់មតកជន អាចដាក់ពាក្យសុំទៅតុលាការឱ្យធ្វើការជ្រើសតាំងអ្នកគ្រប់គ្រងមត៌កជាបណ្ដោះអាសន្នបាន រហូតដល់ពេលធ្វើការបែងចែកមត៌ក ។

២-ទោះបីជាមានបញ្ញត្តិនៃមាត្រា ១២៥៣ (ការហាមឃាត់មិនឱ្យធ្វើបណ្ដឹងចំពោះសន្តតិជននៅមុនការយល់ព្រម) នៃក្រមនេះក៏ដោយ អ្នកគ្រប់គ្រងជាបណ្ដោះអាសន្ន ដែលត្រូវបានជ្រើសតាំងដោយបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ គឺជាអ្នកទទួលបន្ទុកក្នុងបណ្ដឹងនោះចំពោះសិទ្ធិទាមទារដែលទាក់ទងនឹងមត៌ក នៅក្នុងនាមជាអ្នកទទួលបន្ទុកក្នុងបណ្ដឹងរបស់សន្តតិជននៃមតកជន ដោយបញ្ជាក់ឈ្មោះមតកជននោះផង រហូតដល់ពេលដែលសន្តតិជនយល់ព្រមទទួលសន្តតិកម្មនោះ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ៣ នៃមាត្រា ៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកគ្រប់គ្រងជាបណ្ដោះអាសន្ន ។

មាត្រា ១២៦៥.- សោហ៊ុយដែលទាក់ទងទៅនឹងមត៌ក

សោហ៊ុយដែលទាក់ទងទៅនឹងមត៌ក ត្រូវចំណាយចេញពីក្នុងទ្រព្យសម្បត្តិនោះ ។ ប៉ុន្តែ សោហ៊ុយដែលកើតចេញពីកំហុសរបស់សន្តតិជន គឺជាបន្ទុករបស់សន្តតិជននោះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

10/455

ផ្នែកទី ២
ការបែងចែកមត៌ក

មាត្រា ១២៦៦.- ការពិភាក្សាបែងចែកមត៌ក

១-សហសន្តតិជនអាចចាប់ផ្តើមពិភាក្សាបែងចែកមត៌ក នៅពេលណាក៏បាន បើអំឡុងពេល ១ (មួយ) ខែ បានកន្លងផុត ក្រោយពីការចាប់ផ្តើមសន្តតិកម្ម ។ ប៉ុន្តែ ចំពោះការផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិលើមត៌ក ដោយសារលទ្ធផលនៃការបែងចែកមត៌ក ត្រូវអនុលោមតាមបញ្ញត្តិនៃមាត្រា ១២៧៧(ការហាមឃាត់មិនឱ្យផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិ) នៃក្រមនេះ ឬ ចំពោះករណីដែលមតកជនហាមឃាត់ការបែងចែកមត៌កតាមមតកសាសន៍ ការបែងចែកមត៌កពុំអាចធ្វើបានឡើយ នៅក្នុងអំឡុងពេលដែលហាមឃាត់នោះ ។

២-ដើម្បីផ្ទេរសិទ្ធិចំពោះវត្ថុតាមការបែងចែកមត៌ក ការបែងចែកត្រូវធ្វើជាលាយលក្ខណ៍អក្សរទៅតាមទម្រង់នីមួយៗ ដែលចាំបាច់នៅក្នុងការផ្ទេរសិទ្ធិនោះ ។

មាត្រា ១២៦៧.- មូលដ្ឋាននៃការបែងចែក

១-បើពុំបានកំណត់វិធីបែងចែកនៅក្នុងមតកសាសន៍ទេ ការបែងចែកមត៌កនេះ ត្រូវធ្វើដោយពិចារណាទៅលើប្រភេទ និង លក្ខណៈនៃវត្ថុ ឬ សិទ្ធិដែលមាននៅក្នុងមត៌ក ឬ អាយុ មុខរបរ ស្ថានភាពផ្លូវកាយ និង ផ្លូវចិត្ត ស្ថានភាពជីវភាព របស់សហសន្តតិជននីមួយៗ និង ស្ថានភាពផ្សេងទៀត ។

២-ក្នុងករណីដែលការបែងចែកបណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់តម្លៃ បើយល់ឃើញថាសមរម្យ សហសន្តតិជនអាចឱ្យសហសន្តតិជនណាម្នាក់ ធ្វើលទ្ធកម្មទ្រព្យសម្បត្តិនោះបាន ដោយដាក់លក្ខខ័ណ្ឌឱ្យបង់ប្រាក់សម្រួល ចំពោះសហសន្តតិជនផ្សេងទៀត តាមការពិភាក្សា ។

មាត្រា ១២៦៨.- សិទ្ធិអាទិភាពរបស់សហព័ទ្ធ

ក្នុងករណីដែលសហព័ទ្ធក្លាយជាសន្តតិជន បើមានទ្រព្យសម្បត្តិដែលទទួលបានជាកម្មសិទ្ធិអវិភាគជាមួយនឹងមតកជន ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ នៅក្នុងការបែង

ចែកមតិក សហព័ទ្ធនេះមានអាទិភាពជាងសហសន្តតិជនផ្សេងទៀត ក្នុងការទទួលយកចំណែកកម្មសិទ្ធិអវិភាគដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិនោះ រហូតដល់គ្រប់ចំនួននៃចំណែកមតិកនោះ ។

មាត្រា ១២៦៩.- សំណងនៃកាតព្វកិច្ចរបស់មតកជន ជាអាទិ៍

បើមតកជនមានកាតព្វកិច្ច សហសន្តតិជនត្រូវបែងចែកមតិក ដោយពិចារណាពីការណ៍ថា ខ្លួនត្រូវសងកាតព្វកិច្ចនោះ និង មិនអាចប្តូរភាគបន្ទុកនៃកាតព្វកិច្ចនោះ ដោយគ្មានការយល់ព្រមពីសំណាក់ម្ចាស់បំណុលឡើយ ។

មាត្រា ១២៧០.- ការបែងចែកដោយតុលាការ

១-បើការពិភាក្សារវាងសហសន្តតិជន ចំពោះការបែងចែកមតិក ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ សហសន្តតិជនណាម្នាក់ អាចដាក់ពាក្យសុំទៅតុលាការឱ្យធ្វើការបែងចែកមតិកនោះបាន ។

២-ក្នុងការបែងចែកមតិក ក្រៅពីបញ្ញត្តិចាប់ពីមាត្រា ១២៦៧(មូលដ្ឋាននៃការបែងចែក) រហូតដល់មាត្រា ១២៦៩ (សំណងនៃកាតព្វកិច្ចរបស់មតកជន ជាអាទិ៍) ខាងលើនេះ តុលាការត្រូវធ្វើការពិចារណានូវទំនៀមទម្លាប់នៅក្នុងតំបន់នោះ និង មតិលើសពីពាក់កណ្តាលរបស់សហសន្តតិជន ។

មាត្រា ១២៧១.- ការប្តូរជាប្រាក់ដោយការលក់

ចំពោះទ្រព្យសម្បត្តិដែលមិនអាចទទួលការព្រមព្រៀងអំពីការបែងចែក ឬ អំពីបុគ្គលដែលត្រូវទទួលរវាងសហសន្តតិជនទេ តុលាការអាចលក់ ហើយធ្វើការបែងចែកប្រាក់ដែលបានមកពីការលក់នោះបាន ។

មាត្រា ១២៧២.- ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្ម ដោយផ្អែកលើការចាត់ចែងទ្រព្យសម្បត្តិនៅមុនពេលបែងចែក ជាអាទិ៍

ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្ម ដោយការសងជំនួសការបាត់បង់ ការខូចខាត ឬ ការបំពានលើទ្រព្យមតិក ឬ តាមកិច្ចសន្យាដែលយកមតិកជាកម្មវត្ថុ ដោយផ្អែកលើសិទ្ធិដែលស្ថិតនៅក្នុងមតិកនោះ ត្រូវស្ថិតនៅក្នុងមតិក ។

ROYAUME DU CAMBODGE · LE MINISTRE du PALAIS ROYAL

453 k

មាត្រា ១២៧៣.- អានុភាពនៃការបែងចែក

១-ការបែងចែកមត៌ក មានអានុភាពប្រតិសកម្ម គិតចាប់ពីពេលដែលបានចាប់ផ្តើមសន្តតិកម្ម ។ ប៉ុន្តែ ការបែងចែកនេះ ពុំអាចបំពានសិទ្ធិរបស់តតិយជនដែលបានចុះបញ្ជី ឬ បានទទួលល័ក្ខខ័ណ្ឌតតាំងបានឡើយ ។

២-សហសន្តតិជននីមួយៗ ត្រូវទទួលយកលិខិតបញ្ជាក់សិទ្ធិដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិដែលខ្លួនបានធ្វើលទ្ធកម្ម ។

មាត្រា ១២៧៤.- ការទាមទាររបស់ជនដែលត្រូវបានទទួលស្គាល់ក្រោយការបែងចែកមត៌ក

ក្នុងករណីដែលជនដែលបានក្លាយជាសន្តតិជន ដោយសារជននោះត្រូវបានទទួលស្គាល់ក្រោយពេលមតកជនបានទទួលមរណភាព មានបំណងទាមទារឱ្យបែងចែកមត៌ក បើសហសន្តតិជនផ្សេងទៀតបានបែងចែកមត៌ក ឬ បានធ្វើការចាត់ចែងផ្សេងទៀតចំពោះមត៌ក ជននោះមានសិទ្ធិទាមទារឱ្យសងដោយតម្លៃតែប៉ុណ្ណោះ ។

មាត្រា ១២៧៥.- ល័ក្ខខ័ណ្ឌតតាំង ជាអាទិ៍ នៃការបែងចែកសិទ្ធិលើបំណុល

១-នៅក្នុងការបែងចែកមត៌ក ក្នុងករណីដែលបានបែងចែកសិទ្ធិលើបំណុលដែលមតកជនមាន ទៅតាមភាគក្រៅពីចំណែកមត៌កដែលកំណត់ដោយច្បាប់ បើសហសន្តតិជនទាំងអស់មិនបានជូនដំណឹងពីការបែងចែកនោះ ឬ បើការបែងចែកមត៌កនោះ ត្រូវបានធ្វើដោយលិខិតយថាភូត តែមិនបានបង្ហាញលិខិតនោះ ឬ ប្រគល់លិខិតចម្លងនោះ ទៅឱ្យកូនបំណុលទេពុំអាចតតាំងជាមួយកូនបំណុលបានឡើយ ។

២-កូនបំណុលនៃមតកជន ដែលបានសងសំណងតាមចំណែកមត៌កដែលកំណត់ដោយច្បាប់ ចំពោះសហសន្តតិជន នៅមុនពេលបានទទួលដំណឹង ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចតតាំងចំពោះសហសន្តតិជនដែលបានធ្វើលទ្ធកម្មសិទ្ធិលើបំណុលតាមការបែងចែកមត៌កនោះបាន ។

មាត្រា ១២៧៦.- ការទទួលខុសត្រូវក្នុងការធានា របស់សហសន្តតិជន

សហសន្តតិជនម្នាក់ៗ ត្រូវមានបន្ទុកទទួលខុសត្រូវក្នុងការធានា ទៅតាមសមាមាត្រនៃ

ROYAUME DU CAMBODGE * LE MINISTERE DU PALAIS ROYAL *

ចំណែកមត៌កនោះ ដូចជាអ្នកលក់ដែរ ចំពោះសហសន្តតិជនដទៃទៀត ។

ផ្នែកទី ៣

ការសម្រួលខាងម្ចាស់បំណុល

មាត្រា ១២៧៧.- ការហាមឃាត់មិនឱ្យផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិ

សន្តតិជន និង អ្នកគ្រប់គ្រងមត៌ក មិនអាចផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិលើមត៌កទៅឱ្យ សន្តតិជន ឬ អច្ច័យលាភី បានឡើយ រហូតដល់ពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ បានកន្លងហួស ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិលើមត៌ក តាមភាពចាំបាច់ដើម្បីសងកាតព្វកិច្ចរបស់មតកជន ។

មាត្រា ១២៧៨.- ម្ចាស់បំណុលរបស់មតកជន

ម្ចាស់បំណុលនៃមតកជនពុំអាចអនុវត្តសិទ្ធិរបស់ខ្លួន ចំពោះទ្រព្យសម្បត្តិផ្ទាល់របស់សន្តតិជនបានឡើយ រហូតដល់ពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ បានកន្លងហួស ។

មាត្រា ១២៧៩.- ម្ចាស់បំណុលរបស់សន្តតិជន

ម្ចាស់បំណុលរបស់សន្តតិជន មិនអាចអនុវត្តសិទ្ធិរបស់ខ្លួន ចំពោះមត៌កបានឡើយរហូតដល់ពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ បានកន្លងហួស ។

ផ្នែកទី ៤

ការជម្រះបញ្ជីអាទិ៍ នៅក្នុងករណីដែលមានការយល់ព្រមដោយកម្រិត

មាត្រា ១២៨០.- ការគ្រប់គ្រងមត៌កនៅក្រោយពេលយល់ព្រមដោយកម្រិត

អ្នកយល់ព្រមដោយកម្រិត ត្រូវបន្តការគ្រប់គ្រងមត៌ក ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

មាត្រា ១២៨១.- ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន

១-អ្នកយល់ព្រមដោយកម្រិត ត្រូវជូនដំណឹងជាសាធារណៈ នៅក្នុងអំឡុងពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានយល់ព្រមដោយកម្រិតហើយ ចំពោះម្ចាស់បំណុលរបស់មតកជន និង អច្ច័យលាភីទាំងអស់ អំពីការណ៍ដែលខ្លួនបានយល់ព្រមដោយកម្រិត និង ការណ៍ ដែលម្ចាស់បំណុល និង អច្ច័យលាភីទាំងនោះ ត្រូវស្នើសុំអំពីការទាមទារនៅក្នុងអំឡុងពេលដែលកំណត់ ។ ប៉ុន្តែ អំឡុងពេលនេះ មិនត្រូវឱ្យតិចជាង ២ (ពីរ) ខែ ឡើយ ។

២-នៅក្នុងការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកយល់ព្រមដោយកម្រិត ត្រូវសរសេរបន្ថែមថា បើម្ចាស់បំណុលមិនបានស្នើសុំនៅក្នុងអំឡុងពេលកំណត់នោះទេ សិទ្ធិលើបំណុលនោះនឹងត្រូវដកចេញពីការជម្រះ ។ ប៉ុន្តែ អ្នកយល់ព្រមដោយកម្រិតនេះ មិនអាចដកម្ចាស់បំណុលដែលខ្លួនបានដឹងចេញបានឡើយ ។

៣-អ្នកយល់ព្រមដោយកម្រិត ត្រូវដាស់តឿនដោយឡែកៗ ចំពោះម្ចាស់បំណុល ដែលខ្លួនបានដឹងឱ្យធ្វើការស្នើសុំ ។

មាត្រា ១២៨២.- សិទ្ធិបដិសេធការសងនៅក្នុងអំឡុងពេលដាស់តឿន

នៅមុនពេលផុតអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) ខាងលើនេះ អ្នកយល់ព្រមដោយកម្រិត អាចបដិសេធការសង ចំពោះម្ចាស់បំណុលរបស់មតកជន និង អច្ច័យលាភីបាន ។

មាត្រា ១២៨៣.- ការសងតាមការចែកចំណែក

ក្រោយពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) ខាងលើនេះ បានកន្លងហួស អ្នកយល់ព្រមដោយកម្រិត ត្រូវយកមតកនោះមកសងឱ្យម្ចាស់បំណុលដែលបានស្នើសុំនៅក្នុងអំឡុងពេលនោះ និង ម្ចាស់បំណុលផ្សេងទៀតដែលខ្លួនបានដឹង ស្របតាមសមាមាត្រនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលនីមួយៗនោះ ។ ប៉ុន្តែការសងនេះ ពុំអាចរំលោភបំពានសិទ្ធិរបស់ម្ចាស់បំណុលដែលមានសិទ្ធិអាទិភាពបានឡើយ ។

មាត្រា ១២៨៤.- ការសងកាតព្វកិច្ច ជាអាទិ៍ នៅមុនពេលកំណត់

១-ទោះបីជាសិទ្ធិលើបំណុលមិនទាន់ដល់ពេលកំណត់សងក៏ដោយ អ្នកយល់ព្រមដោយកម្រិត ត្រូវសងដោយយោងតាមបញ្ញត្តិនៃមាត្រា ១២៨៣(ការសងតាមការចែកចំណែក)ខាងលើនេះ ។

២-ចំពោះសិទ្ធិលើបំណុលដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌ ឬ សិទ្ធិលើបំណុលដែលអំឡុងពេលបន្តអត្ថិភាពមិនពិតប្រាកដ អ្នកយល់ព្រមដោយកម្រិតត្រូវសងសិទ្ធិលើបំណុលនោះ ដោយយោងតាមការវាយតម្លៃរបស់អ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការ ។

មាត្រា ១២៨៥.- ការសងចំពោះអច្ច័យលាភី

អ្នកយល់ព្រមដោយកម្រិត មិនអាចសងទៅឱ្យអច្ច័យលាភីបានឡើយ បើមិនទាន់បានសងចំពោះម្ចាស់បំណុលនីមួយៗ តាមបញ្ញត្តិនៃមាត្រា ១២៨៣(ការសងតាមការចែកចំណែក) និង មាត្រា ១២៨៤(ការសងកាតព្វកិច្ច ជាអាទិ៍ នៅមុនពេលកំណត់) ខាងលើនេះ ។

មាត្រា ១២៨៦.- ការប្តូរមត៌កជាប្រាក់

១-ប្រសិនបើចាំបាច់ត្រូវលក់មត៌កដើម្បីសង ដោយយោងតាមបញ្ញត្តិចាប់ពីមាត្រា ១២៨៣ (ការសងតាមការចែកចំណែក) រហូតដល់មាត្រា ១២៨៥ (ការសងចំពោះអច្ច័យលាភី) ខាងលើនេះ អ្នកយល់ព្រមដោយកម្រិត ត្រូវលក់មត៌កនោះ តាមវិធីលក់ ដោយបង្ខំ ឬ លក់ក្នុងតម្លៃខ្ពស់ជាងការវាយតម្លៃរបស់អ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការ ។

២-អ្នកយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជន ឬ អច្ច័យលាភី អាចក្លាយជាអ្នកទិញដោយផ្ទាល់ខ្លួន នៅក្នុងការលក់ដោយបង្ខំ ឬ ការលក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ។

មាត្រា ១២៨៧.- ការទទួលខុសត្រូវក្នុងការសងមិនត្រឹមត្រូវ

១-ប្រសិនបើអ្នកយល់ព្រមដោយកម្រិតមានការធ្វេសប្រហែស ក្នុងការជូនដំណឹងជាសាធារណៈ ឬ ការដាស់តឿនដែលបានកំណត់នៅក្នុងមាត្រា ១២៨១(ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) នៃក្រមនេះ ឬ បើពុំអាចសងទៅឱ្យម្ចាស់បំណុល ឬ អច្ច័យលាភីដទៃ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ទៀត ដោយសារបានសងទៅឱ្យម្ចាស់បំណុល ឬ អច្ច័យលាភីណាផ្សេង នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១នៃមាត្រា ជដែលនេះទេ អ្នកយល់ព្រមដោយកម្រិតនោះ ត្រូវសងសំណងការខូចខាតដែលកើតឡើងដោយសារហេតុនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងការទាមទារសំណងការខូចខាតរបស់ម្ចាស់បំណុល ឬ អច្ច័យលាភីដទៃ ចំពោះម្ចាស់បំណុល ឬ អច្ច័យលាភីដែលបាន ទទួលការសង , ដោយដឹងអំពីភាពមិនត្រឹមត្រូវនៃការសងនោះ ។

មាត្រា ១២៨៨.- ករណីដែលពុំបានស្នើសុំ

ម្ចាស់បំណុល និង អច្ច័យលាភី ដែលពុំបានស្នើសុំនៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) នៃក្រមនេះ ហើយដែលអ្នកយល់ព្រមដោយកម្រិតពុំអាចដឹងបាន អាចអនុវត្តសិទ្ធិរបស់ខ្លួនបាន ត្រឹមតែចំពោះទ្រព្យសម្បត្តិដែលនៅសេសសល់ប៉ុណ្ណោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះជនដែលមានសិទ្ធិប្រាតិ-ភោគលើវត្ថុ ឬ សិទ្ធិដែលបានកំណត់ជាក់លាក់ក្នុងចំណោមមតិក ។

មាត្រា ១២៨៩.- ករណីដែលមានសន្តតិជនច្រើននាក់

១-នៅក្នុងករណីដែលមានសន្តតិជនច្រើននាក់ បើមានការយល់ព្រមដោយកម្រិត តុ-លាការត្រូវជ្រើសតាំងអ្នកគ្រប់គ្រងមតិក ពីក្នុងចំណោមសន្តតិជនទាំងនោះ ។

២-អ្នកគ្រប់គ្រង ត្រូវបំពេញរាល់សកម្មភាពចាំបាច់ក្នុងការគ្រប់គ្រងមតិក និង សងកាតព្វកិច្ច ដើម្បីខ្លួនឯងផ្ទាល់ និង ជំនួសសហសន្តតិជនដទៃទៀត ។

៣-បញ្ញត្តិចាប់ពីមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និងការដាស់តឿន) រហូតដល់មាត្រា ១២៨៨ (ករណីដែលពុំបានស្នើសុំ) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកគ្រប់គ្រង ។ ប៉ុន្តែ អំឡុងពេលដែលត្រូវជូនដំណឹងជាសាធារណៈ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) នៃក្រមនេះ គឺត្រូវធ្វើក្នុងរយៈពេល ១០ (ដប់) ថ្ងៃ បន្ទាប់ពីបានជ្រើសតាំងអ្នកគ្រប់គ្រង ។

ជំពូកទី ៧
នត្ថិភាពនៃសន្តតិជន

មាត្រា ១២៩០.- នីតិបុគ្គលមតិក

ប្រសិនបើពុំច្បាស់ថាមានសន្តតិជនទេ មតិកនោះត្រូវក្លាយជានីតិបុគ្គល ។

មាត្រា ១២៩១.- ការជ្រើសតាំងអ្នកគ្រប់គ្រង

១-ក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ១២៩០ (នីតិបុគ្គលមតិក) ខាងលើនេះ តុលាការត្រូវជ្រើសតាំងអ្នកគ្រប់គ្រងមតិក តាមពាក្យសុំរបស់បុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋាន ចុងក្រោយរបស់មតកជន ឬ តំណាងអយ្យការ ។

២-បើបានជ្រើសតាំងអ្នកគ្រប់គ្រងមតិកហើយ តុលាការត្រូវធ្វើការជូនដំណឹងជាសាធារណៈអំពីករណីនោះ ដោយគ្មានការយឺតយ៉ាវ ។

មាត្រា ១២៩២.- សិទ្ធិ និង ភារកិច្ចរបស់អ្នកគ្រប់គ្រង

១-អ្នកគ្រប់គ្រង ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌដែលទាក់ទងទៅនឹងមតិក ដោយគ្មានការយឺតយ៉ាវ ។

២-អ្នកគ្រប់គ្រង ត្រូវថែរក្សា និង គ្រប់គ្រងមតិក ។ បើមានការចាំបាច់ដើម្បីថែរក្សានិងគ្រប់គ្រងមតិកនោះ អ្នកគ្រប់គ្រងអាចប្តូរមតិកជាប្រាក់ ឬ អាចចាត់ចែង មតិកនោះបានដោយទទួលការអនុញ្ញាតពីតុលាការ ។

៣-បើមានការទាមទារពីម្ចាស់បំណុលរបស់មតកជន ឬ អច្ច័យលាភី អ្នកគ្រប់គ្រងត្រូវរាយការណ៍អំពីស្ថានភាពនៃមតិកទៅឱ្យជននោះ ។

៤-អ្នកគ្រប់គ្រងត្រូវអនុវត្តតាមចំណុចនីមួយៗ ដែលបានកំណត់ក្នុងបញ្ញត្តិចាប់ពីមាត្រា ១២៨២ (សិទ្ធិបដិសេធការសងនៅក្នុងអំឡុងពេលដាស់តឿន) រហូតដល់មាត្រា ១២៨៨ (ករណីដែលពុំមានស្នើសុំ) នៃក្រមនេះ ដែលត្រូវយកមកអនុវត្តដូចគ្នា ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១២៨៦(ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុល

ជាអាទិ៍) ខាងក្រោមនេះ ។

៥-តាមការបង្គាប់របស់តុលាការ អ្នកគ្រប់គ្រង ត្រូវស្រាវជ្រាវអង្គហេតុ ហើយត្រូវធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនោះទៅតុលាការ ។

មាត្រា ១២៩៣.- កម្រៃសម្រាប់ អ្នកគ្រប់គ្រង

តុលាការអាចផ្តល់កម្រៃសមរម្យ ចេញពីក្នុងចំណោមមត៌ក ឱ្យទៅអ្នកគ្រប់គ្រង បានដោយគិតពិចារណាទៅលើស្ថានភាពនៃមត៌ក និង ស្ថានភាពផ្សេងទៀត ។

មាត្រា ១២៩៤.- ករណីដែលដឹងច្បាស់អំពីសន្តតិជន

ប្រសិនបើដឹងច្បាស់ថាមានសន្តតិជន នីតិបុគ្គលមត៌កត្រូវចាត់ទុកថាពុំមានអត្ថិភាព តាំងពីដំបូង ។ ប៉ុន្តែ បញ្ញត្តិនេះពុំរារាំងអានុភាពនៃសកម្មភាពដែលអ្នកគ្រប់គ្រងបានធ្វើ ហើយនៅក្នុងទំហំនៃសិទ្ធិអំណាចរបស់ខ្លួនឡើយ ។

មាត្រា ១២៩៥.- ពេលរលត់សិទ្ធិអំណាចរបស់អ្នកគ្រប់គ្រង

១-សិទ្ធិអំណាចរបស់អ្នកគ្រប់គ្រង ត្រូវរលត់ នៅពេលដែលសន្តតិជនបានយល់ព្រមទទួលសន្តតិកម្ម ។

២-បើសន្តតិជនបានយល់ព្រមទទួលសន្តតិកម្មហើយ អ្នកគ្រប់គ្រងត្រូវគណនាអំពីការគ្រប់គ្រងនោះ ចំពោះសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

មាត្រា ១២៩៦.- ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុល ជាអាទិ៍

១-បើពុំបានដឹងច្បាស់អំពីអត្ថិភាពនៃសន្តតិជន នៅក្នុងអំឡុងពេល ២ (ពីរ) ខែ បន្ទាប់ពីបានធ្វើការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ១២៩១ (ការជ្រើសតាំងអ្នកគ្រប់គ្រង) នៃក្រមនេះទេ អ្នកគ្រប់គ្រង ត្រូវជូនដំណឹងជាសាធារណៈ ដោយគ្មានការយឺតយ៉ាវ ចំពោះម្ចាស់បំណុលរបស់មតកជន និង អច្ច័យលាភីទាំងអស់អំពីការណ៍ដែលម្ចាស់បំណុល និង អច្ច័យលាភីទាំងនោះ ត្រូវស្នើសុំអំពី ការទាមទារក្នុងអំឡុងពេលដែលកំណត់ ។ ប៉ុន្តែ អំឡុងពេលនេះ មិនត្រូវឱ្យតិចជាង ២ (ពីរ) ខែ ឡើយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការ

ដាស់តឿន) និង បញ្ញត្តិចាប់ពីមាត្រា ១២៨២ (សិទ្ធិបដិសេធការសងនៅក្នុងអំឡុងពេលដាស់តឿន) រហូតដល់មាត្រា ១២៨៨ (ករណីដែលពុំបានស្នើសុំ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។ ប៉ុន្តែ អ្នកគ្រប់គ្រង ពុំអាចក្លាយជាអ្នកទិញនៅក្នុងការលក់ដោយបង្ខំ ឬ ការលក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨៦ (ការប្តូរមត៌កជាប្រាក់) នៃក្រមនេះ ដែលត្រូវបានយកមកអនុវត្តដូចគ្នាបានឡើយ ។

មាត្រា ១២៩៧.- ការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជន

១-ក្រោយពីអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៩៦ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុល ជាអាទិ៍) ខាងលើនេះ បានកន្លងហួស ប្រសិនបើនៅតែមិនទាន់ដឹងច្បាស់ថាមានសន្តតិជននៅឡើយ តាមពាក្យសុំរបស់អ្នកគ្រប់គ្រង ឬ តំណាងអយ្យការ តុលាការត្រូវធ្វើការជូនដំណឹងជាសាធារណៈថា ប្រសិនបើមានសន្តតិជន សន្តតិជននោះត្រូវធ្វើការស្នើសុំអំពីការណ៍នោះនៅក្នុងអំឡុងពេលដែលកំណត់ ។ ប៉ុន្តែ អំឡុងពេលនេះមិនត្រូវឱ្យតិចជាង ៦ (ប្រាំមួយ) ខែឡើយ ។

២-បើប៉ាន់ប្រមាណឃើញថាគ្មានសេសសល់មត៌កទេ អ្នកគ្រប់គ្រង ឬ តំណាងអយ្យការ មិនអាចធ្វើការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះឡើយ ។

មាត្រា ១២៩៨.- ការដកហូតសិទ្ធិតាមការជូនដំណឹងជាសាធារណៈ

បើគ្មានការស្នើសុំថា ខ្លួនជាសន្តតិជន នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងបញ្ញត្តិនៃមាត្រា ១២៩៧ (ការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជន) ខាងលើនេះទេ សន្តតិជន ព្រមទាំងម្ចាស់បំណុលរបស់មតកជន និង អច្ច័យលាភី ដែលអ្នកគ្រប់គ្រងមិនអាចដឹងបានពុំអាចអនុវត្តសិទ្ធិបានឡើយ ។

មាត្រា ១២៩៩.- ការចែកមត៌កឱ្យទៅជនដែលមាននិស្ស័យពិសេស

១-នៅក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ១២៩៨ (ការដកហូតសិទ្ធិតាមការជូនដំណឹងជាសាធារណៈ) ខាងលើនេះ បើយល់ឃើញថាសមរម្យ តុលាការអាចចែកមួយផ្នែកនៃ

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

មត៌កដែលនៅសេសសល់ក្រោយការជម្រះ ទៅឱ្យជនដែលមានជីវភាពជាមួយគ្នានឹងមតកជន ជនដែលបានខិតខំមើលថែទាំព្យាបាលមតកជន និង ជនដែលមាននិស្ស័យ ពិសេសផ្សេងទៀត តាមពាក្យសុំរបស់ជននោះ ។ ប៉ុន្តែ ចំនួនសរុបនៃតម្លៃទ្រព្យដែលត្រូវ ចែកទៅឱ្យនោះ មិនត្រូវលើសពីចំនួនពាក់កណ្តាលនៃមត៌កដែលនៅសេសសល់នោះទេ ។

២-ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើនៅក្នុងអំឡុងពេល ៣ (បី) ខែ ក្រោយពីអំឡុងពេលដែលបានកំណត់នៅក្នុងមាត្រា ១២៩៧(ការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជន) ខាងលើនេះ បានកន្លងហួស ដោយបញ្ជាក់អំពីហេតុនៃនិស្ស័យពិសេសនោះឱ្យបានច្បាស់លាស់ ។

៣-ក្នុងការចែកទ្រព្យដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ តុលាការ អាចស្រាវជ្រាវអំពីអង្គហេតុបាន ។ បើនៅក្នុងការស្រាវជ្រាវនេះ តុលាការអាចសួរយោបល់របស់មេឃុំ ឬ ចៅសង្កាត់បាន ។

មាត្រា ១៣០០.- មត៌កដែលធ្លាក់ទៅជាទ្រព្យរដ្ឋ

មត៌កដែលមិនត្រូវបានចាត់ចែង តាមបញ្ញត្តិនៃមាត្រា ១២៩៩(ការចែកមត៌កឱ្យទៅជនដែលមាននិស្ស័យពិសេស) ខាងលើនេះ ត្រូវធ្លាក់ទៅជាទ្រព្យរដ្ឋ ។ ក្នុងករណីនេះ អ្នកគ្រប់គ្រងត្រូវគណនាអំពីការគ្រប់គ្រងនោះ ហើយដាក់ជូនទៅតុលាការ ដោយគ្មានការយឺតយ៉ាវ ។

ជំពូកទី ៨

ការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម

មាត្រា ១៣០១.- គោលបំណងនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម

សន្តតិជនដែលត្រូវបានដកហូតសិទ្ធិសន្តតិកម្ម អាចទាមទារឱ្យធ្វើបដិទានសន្តតិកម្ម ដើម្បីទទួលបដិទាននៃមត៌កទាំងអស់ ឬ មួយភាគ បាន ។

មាត្រា ១៣០២.- អត្ថន័យនៃការទាមទារឱ្យធ្វើបដិទាននូវសន្តតិកម្ម

សន្តតិជនអាចទាមទារចំពោះជនដែលបានទទួលមត៌ក តាមសិទ្ធិសន្តតិកម្មដែលពុំត្រូវបានផ្តល់ជូនទៅនោះឱ្យប្រគល់មកវិញ នូវទ្រព្យដែលបានទទួលនោះ ។

២-ទ្រព្យដែលភាគីម្ខាងទៀតនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម បានទទួលតាមកិច្ចសន្យាដែលយកមត៌កធ្វើជាកម្មវត្ថុ ក៏ត្រូវក្លាយជាកម្មវត្ថុនៃការទាមទារឱ្យធ្វើបដិទាននូវសន្តតិកម្មផងដែរ ។

មាត្រា ១៣០៣.- ខ្លឹមសារនៃករណីយកិច្ចប្រគល់វិញ

១-ភាគីម្ខាងទៀតនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម ត្រូវប្រគល់មត៌កមកឱ្យសន្តតិជនដែលបានទាមទារវិញ ។ បើភាគីម្ខាងទៀតសុចរិត ជននោះមានសិទ្ធិរក្សាទុកនូវផល និងការប្រាក់ដែលបានទទួល សិទ្ធិទាមទារឱ្យសងវិញនូវសោហ៊ុយដែលបានបង្កើនតម្លៃចំពោះទ្រព្យនោះ ហើយមានសិទ្ធិទាមទារសំណងចំពោះកាតព្វកិច្ចដែលត្រូវបានទទួលតាមរយៈសន្តតិកម្មដែលបានសងរួចហើយនោះ ។

២-បើភាគីម្ខាងទៀតទុច្ចរិត ជននោះមានកាតព្វកិច្ចត្រូវប្រគល់វិញនូវផល និង ការប្រាក់ដែលបានទទួល ហើយមិនត្រឹមតែគ្មានសិទ្ធិទាមទារសំណងចំពោះកាតព្វកិច្ចដែលត្រូវបានទទួលតាមរយៈសន្តតិកម្មដែលបានសងនោះទេ ថែមទាំងគ្មានសិទ្ធិទាមទារឱ្យសងវិញនូវសោហ៊ុយដែលបានបង្កើនតម្លៃចំពោះទ្រព្យនោះផង ។

មាត្រា ១៣០៤.- អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យធ្វើបដិទានសន្តតិកម្ម

អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យធ្វើបដិទានសន្តតិកម្ម នៅក្នុងករណីដែលមត៌កត្រូវបានផ្ទេរទៅភាគីម្ខាងទៀតនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម តាមមតកសាសន៍ ឬ ការបែងចែកមត៌ក មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលនោះ រីឯក្នុងករណីដែលជនតែម្នាក់បានទទួលសន្តតិកម្មក្នុងនាមជាសន្តតិជន មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំគិតចាប់ពីថ្ងៃដែលមតកជនបានទទួលមរណភាព ។

ROYAUME DU CAMBODGE * LE MINISTERE DU PALAIS ROYAL *

គន្ថីទី ៩

អវសានប្បញ្ញត្តិ

ជំពូកទោល

អវសានប្បញ្ញត្តិ

មាត្រា ១៣០៥.- កាលបរិច្ឆេទនៃការអនុវត្ត ជាអាទិ៍

១-ក្រមនេះ ត្រូវអនុវត្ត ចាប់តាំងពីថ្ងៃដែលកំណត់ផ្សេងដោយច្បាប់ ។

២-ចំពោះវិធានការអន្តរកាលដែលទាក់ទងនឹងការអនុវត្តក្រមនេះ និងចំណុចចាំបាច់ផ្សេងទៀតដែលទាក់ទងនឹងការអនុវត្តក្រមនេះ ត្រូវកំណត់ផ្សេងដោយច្បាប់ ។

រាជធានីភ្នំពេញថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧
ក្នុងព្រះបរមនាម និងតាមព្រះរាជឡ្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

[illegible]

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
ហត្ថលេខា
អង្គ វង្សវឌ្ឍានា

លេខៈ ៥៧៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ុន ចិនកេន